# ជួនហ្វាលុន

# 轉法輪

(Khmer Version)

លីហ៊ុងជឺ

李洪志

# សុន្ទរកថា

មហាធម៌ជាបញ្ញានៃម្ចាស់បង្កើតលោក។ គាត់ជាមូលដ្ឋាននៃការបង្កើតមេឃបង្កើតដី, ប្រឌិតចក្រវាល, អត្ថន័យពីតូចបំផុតរហូតដល់ធំបំផុត, នៅក្នុងជាន់ថ្នាក់រាងកាយលោកធាតុខុសគ្នា, មានការបង្ហាញខុសគ្នា។ ពីអតិសុខុមបំផុតនៃរាងកាយលោកធាតុរហូតដល់ភាគល្អិតអតិសុខុមបំផុតលេចឡើង, ជាន់ៗភាគល្អិតច្រើនរាប់មិនអស់, ពីតូចដល់ធំរហូតដល់អាតូម, ម៉ូលេគុល, ភពផ្កាយ, កញ្ចុំផ្កាយនៅជាន់ខាងលើផ្ទៃដែលមនុស្សជាតិយល់ដឹងព្រមទាំងដ៏មហិមាជាងទៀត, ភាគល្អិតធំតូចខុសគ្នាបង្កើតជាជីវិតធំតូចខុសគ្នាក៏ដូចជាពិភពធំតូចខុសគ្នាស្ថិតនៅគ្រប់ទីកន្លែងក្នុងរាងកាយលោកធាតុចក្រវាល។ និយាយចំពោះជីវិតលើរាងកាយភាគល្អិតនៃជាន់ថ្នាក់ខុសគ្នា, ភាគល្អិតនៃជាន់ធំជាងមួយខ្នាតជាក់ស្តែងគឺជាភពផ្កាយក្នុងផ្ទៃមេឃរបស់ពួកគាត់, ជាន់ៗដូច្នេះ។ និយាយចំពោះជីវិតបណ្តាជាន់ចក្រវាលគ្មានទីបញ្ចប់។ មហាធម៌នៅបង្កើតចេញពេលវេលា, អវកាស, សម្បូរបែបប្រភេទនៃជីវិតក៏ដូចជាអ្វីៗគ្រប់យ៉ាង, គ្មានអ្វីមិនរួមបញ្ចូល, គ្មានអ្វីត្រូវបានបោះបង់។ នេះជាការបង្ហាញពិស្តារនៅក្នុងជាន់ថ្នាក់ខុសគ្នានៃចរិតពិសេសសច្ចៈ-ករុណា-ខន្តីរបស់មហាធម៌។

បែបវិធីដែលមនុស្សជាតិរុករកចក្រវាល, ជីវិតទោះបីរីកចម្រើនដល់ណា, ក៏គ្រាន់តែមើលឃើញបានអវកាសមួយផ្នែកទីមនុស្សជាតិស្ថិតនៅក្នុងចក្រវាលជាន់ទាប។ ក្នុងច្រើនដងលេចឡើងអរិយធម៌មនុស្សជាតិបុរេប្រវត្តិសុទ្ធតែធ្លាប់បានរុករកដល់ភពផ្កាយដទៃទៀត, ប៉ុន្តែទោះបីហើរខ្ពស់ហើរឆ្ងាយដល់ណា, ក៏មិនឃ្លាតចេញពីអវកាសបិតនៅរបស់មនុស្សជាតិ។ មនុស្សជាតិជានិច្ចក៏មិនអាចពិតប្រាកដយល់ដឹងបានការបង្ហាញ

ពិតមែនរបស់ចក្រវាល។ មនុស្សជាតិប្រសិនចង់យល់ច្បាស់នូវអាថ៌កំបាំងនៃចក្រវាល, វេលា-អវកាស, រាងកាយមនុស្សមានតែបួសហាត់នៅក្នុងសុចរិតធម៌, បានត្រាស់ដោយសុចរិត, លើកកម្ពស់ជាន់ថ្នាក់របស់ជីវិត។ ក្នុងបួសហាត់ក៏នឹងធ្វើឲ្យគុណសម្បត្តិសីលធម៌បានលើកកម្ពស់, ពេលបែងចែកចេញបានពិតប្រាកដករុណានិងកំណាច, ល្អនិងអាក្រក់, ក្នុងពេលដំណាលគ្នាចេញផុតពីជាន់ថ្នាក់មនុស្សជាតិ, ទើបអាចមើលឃើញបាន, ទើបអាចទាក់ទងបានចក្រវាលពិតប្រាកដក៏ដូចជាជីវិតនៅបណ្ដាជាន់ថ្នាក់ខុសគ្នាបណ្ដាអវកាសខុសគ្នា។

រុករករបស់មនុស្សជាតិគឺដើម្បីប្រកួតប្រជែងបច្ចេកទេស, យកលេសគឺដើម្បីផ្លាស់ប្ដូរលក្ខខណ្ឌរស់រានមានជីវិត, ភាគច្រើនគឺយកការច្រានចោលអាទិទេព, បណ្ដោយសីលធម៌មនុស្សជាតិដើម្បីទប់ឃាត់ខ្លួនឯងធ្វើជាមូលដ្ឋាន, ហេតុនោះអរិយធម៌លេចឡើងនៃមនុស្សជាតិអតីតកាលត្រូវបានរំលាយចោលច្រើនដង។ ក្នុងការរុករកក៏គ្រាន់តែអាចកំហិតនៅក្នុងពិភពសារធាតុ, បែបវិធីគឺពេលដែលប្រភេទវត្ថុមួយត្រូវបានយល់ដឹងរួចហើយទើបទៅស្រាវជ្រាវវា, ហើយបាតុភូតដែលប៉ះមិនបាន, មើលមិនឃើញនៅក្នុងអវកាសមនុស្សជាតិ, តែស្ថិតនៅដោយធម្មជាតិ, ហើយម្ដងទៀតអាចប្រាកដជាក់ស្ដែងឆ្លុះបញ្ចាំងដល់ក្នុងតថភាពមនុស្សជាតិ, រួមបញ្ចូលស្មារតី, ជំនឿ, ទេវកថា, ទេវនិទាន, ដោយសារផលប៉ះពាល់នៃការច្រានចោលអាទិទេពហេតុនេះនៅតែមិនហ៊ានទាក់ទងដល់។

ប្រសិនជាមនុស្សជាតិអាចយកសីលធម៌ធ្វើជាមូលដ្ឋានដើម្បីលើកកម្ពស់ចរិយា, គោលគំនិតរបស់មនុស្សជាតិ, បែបនោះអរិយធម៌នៃសង្គមមនុស្សជាតិទើបអាចយូរអង្វែង, ទេវនិទានក៏នឹងលេចឡើងសាជាថ្មីនៅក្នុងសង្គមមនុស្សជាតិ។ ក្នុងសង្គមមនុស្សជាតិអតីតកាលក៏ធ្លាប់បានលេចឡើងច្រើនដងវប្បធម៌ពាក់កណ្ដាលទេព, ពាក់កណ្ដាលមនុស្ស,

ធ្វើឲ្យមនុស្សជាតិលើកកម្ពស់ការយល់ដឹងពិតប្រាកដចំពោះជីវិតនិងចក្រវាល។ មនុស្សជាតិចំពោះការបង្ហាញរបស់មហាធម៌នៅក្នុងលោកីយ៍អាចថ្លែងនូវភាពគោរពជ្រាលជ្រៅនិងស្មោះត្រង់គួរសម, នោះនឹងនាំមកសុភមង្គលឬសិរីរុងរឿងឲ្យមនុស្ស, ជាតិសាសន៍, ឬប្រទេស។ រាងកាយលោកធាតុ, ចក្រវាល, ជីវិត, ក៏ដូចជាអ្វីៗគ្រប់យ៉ាងគឺជាមហាធម៌នៃចក្រវាលបើកបំភ្លឺ, ជីវិតឃ្លាតចាកគាត់ជាក់ស្ដែងគឺជាពិតប្រាកដអន្តរាយ; មនុស្សលោកីយ៍អាចសមស្របជាមួយគាត់ជាក់ស្ដែងគឺជាមនុស្សល្អពិតប្រាកដ, ព្រមទាំងនឹងនាំមកមគ្គផល, ជន្មាយុ; ធ្វើជាអ្នកបួសហាត់, សមកាលកម្មនឹងគាត់លោកអ្នកគឺជាអង្គសម្រេចតាវ៖ អាទិទេព។

*—លីហុងជឺ*
*ថ្ងៃទី២៤ខែឧសភាឆ្នាំ២០១៥*

# តារាងមាតិកា

សុន្ទរកថា

**មេសម្ដែងទី១** 1

ពិតប្រាកដនាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់ 1

ជាន់ថ្នាក់ខុសគ្នាមានធម៌នៃជាន់ថ្នាក់ខុសគ្នា 8

សច្ចៈ, ករុណា, ខន្តីជាបរមាណីយតែមួយគត់ដើម្បីវាស់វែងមនុស្សល្អ និងអាក្រក់ 14

ឈើគង់ជាវប្បធម៌បុរេប្រវត្តិ 19

ឈើគង់ជាក់ស្ដែងគឺជាប្ញសហាត់ 26

ហាត់គង់ហេតុអ្វីមិនបង្កើនគង់ 30

លក្ខណៈរបស់ហ្វាលូនតាហ្វា 44

**មេសម្ដែងទី២** 55

អំពីបញ្ហាភ្នែកទិព្វ 55

ស៊ីលគង់ទូរនេត្រ 74

ស៊ីលគង់ដឹងជោគវាសនា 78

មិននៅក្នុងធាតុទាំង៥, ដើរចេញក្រៅត្រៃភព 85

បញ្ហាមានចំណង់ 93

**មេសម្ដែងទី៣** 108

ខ្ញុំចាត់ទុកសិក្ខាកាមសុទ្ធតែដូចជាសិស្ស 108

គង់ពុទ្ធវង្សនិងពុទ្ធសាសនា 110

ប្ញសហាត់ត្រូវឯកទេសតែមួយគត់ 117

សីលគង់និងអំណាចគង់ 122
បួសបញ្ជោសនិងកម្មីគង់ 124
កាយភ្ជាប់ 134
ភាសាចក្រវាល 144
លោកគ្រូផ្តល់អ្វីខ្លះឲ្យសិក្ខាកាម 147
វាលថាមពល 159
សិក្ខាកាមហ្វាលូនតាហ្វាបង្រៀនគង់ដូចម្តេច 161
**មេសម្តែងទី៤** 166
បាត់និងបាន 166
បំប្លែងអំណាចកម្ម 169
លើកកម្ពស់ចិត្តចរិត 185
ស្រោចកំពូល 194
ទ្វារអាថ៌កំបាំងកំណត់ទី 199
**មេសម្តែងទី៥** 211
និមិត្តរូបហ្វាលូន 211
គង់ហ្វាទ្វារវិសេស 215
ហាត់ទុច្ចរិតធម៌ 218
ប្រុសស្រីបួសទាំងទ្វេ 223
ចរិតជីវិតបួសទាំងទ្វេ 226
បរមី 229
អភិសេក 230

ផ្ទេកជូយ៉ូវ 242

**មេសម្តែងទី៦** 244

ឆ្លតវង្វេងអារក្សចូល 244

ហាត់គង់អន្ទងខ្មោច 259

ចិត្តខ្លួនឯងបង្កើតខ្មោច 270

សតិម្ចាស់ត្រូវតែខ្លាំង 278

ចិត្តជាក់លាក់ត្រូវតែសុចរិត 280

ឈើគង់ក្បាច់គុន 291

ចិត្តសាស្ត្របង្ហាញ 298

**មេសម្តែងទី៧** 305

បញ្ហាសម្លាប់ជីវិត 305

បញ្ហាញ៉ាំសាច់ 312

ចិត្តច្រណែន 322

បញ្ហាព្យាបាលជំងឺ 330

ព្យាបាលជំងឺនៅមន្ទីរពេទ្យនិងព្យាបាលជំងឺដោយឈើគង់ 338

**មេសម្តែងទី៨** 346

ពីគូ 346

លួចឈើ 349

ស្រូបឈើ 353

នរណាហាត់គង់អ្នកនោះទទួលបានគង់ 358

វង់សកល 369

ចិត្តត្រេកអរ 384

បួសមាត់ 387

**មេសម្ដែងទី៩** 391

ឈើគង់និងលំហាត់ប្រាណ 391

គំនិត 395

ចិត្តស្ងប់ស្ងាត់ 406

និស្ស័យ 414

ភ្ញាក់ដឹង 418

មនុស្សមហានិស្ស័យ 428

# មេសម្តែងទី១

## ពិតប្រាកដនាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់

នៅក្នុងដំណើរការបង្រៀនធម៌, បង្រៀនគង់ទាំងមូល, ខ្ញុំក្នុងស្មារតីទទួលខុសត្រូវចំពោះសង្គម, ទទួលខុសត្រូវចំពោះសិក្ខាកាម, ប្រសិទ្ធភាពទទួលបានគឺល្អ, ឥទ្ធិពលចំពោះសង្គមទាំងមូលក៏ជាល្អបង្គួរ។ ប៉ុន្មានឆ្នាំមុនមានគ្រូឈីគង់ជាច្រើនបង្រៀនគង់, ប្រការដែលពួកគាត់សម្តែងសុទ្ធតែជាស្ថិតក្នុងការព្យាបាលជំងឺកាយសម្បទាមួយជាន់ថ្នាក់នោះ។ ប្រាកដណាស់មិនមែននិយាយថាគង់ហ្វារបស់អ្នកដទៃមិនល្អ, ខ្ញុំគ្រាន់តែនិយាយ, ប្រការលើជាន់ថ្នាក់ខ្ពស់, ពួកគាត់គ្មានបង្រៀន។ ខ្ញុំក៏ដឹងអំពីស្ថានការណ៍ឈីគង់ក្នុងប្រទេសទាំងមូល។ នៅក្នុងនិងក្រៅប្រទេស, ពិតជាបង្រៀនគង់ឡើងលើជាន់ថ្នាក់ខ្ពស់, បច្ចុប្បន្នមានតែខ្ញុំម្នាក់កំពុងធ្វើ។ បង្រៀនគង់ឡើងលើជាន់ថ្នាក់ខ្ពស់, ហេតុអ្វីគ្មានមនុស្សធ្វើ? ដោយសារវាជាប់ទាក់ទងដល់បញ្ហាដ៏ធំ, ប្រភពដើមប្រវត្តិសាស្ត្រដែលជាប់ទាក់ទងដ៏ជ្រៅ, ទិដ្ឋភាពដែលជាប់ទាក់ទងក៏ដ៏ទូលាយ, បញ្ហាដែលពាក់ព័ន្ធក៏មុតស្រួចណាស់ផងដែរ។ វាក៏មិនមែនមនុស្សធម្មតាម្នាក់អាចបង្រៀនបាន, ដោយសារវាជាប់ទាក់ទងដល់ប្រការត្រូវការកម្រើកនៃនិកាយជាច្រើន។ ជាពិសេសគឺពួកយើងមានមនុស្សហាត់គង់ជាច្រើន, គាត់ថ្ងៃហ្នឹងរៀនគង់នេះ, ថ្ងៃស្អែករៀនគង់នោះ, ធ្វើឲ្យរាងកាយរបស់ខ្លួនឯងរញ៉េរញ៉ៃ, គាត់បានកំណត់គឺបួសឡើងលើមិនបានទៀត។ គេ{តាម} ផ្លូវធំមួយបួសឡើងលើ, គាត់សុទ្ធតែជាតាមផ្លូវបំបែកមួយចំនួន, គាត់បួសមួយនេះ, មួយនោះជ្រៀតជ្រែក; បួសមួយនោះ, មួយនេះជ្រៀតជ្រែក, សុទ្ធតែកំពុងជ្រៀតជ្រែកគាត់, គាត់លែងបួសបានទៀតរួចហើយ។

រឿងរ៉ាវទាំងនេះយើងខ្ញុំសុទ្ធតែត្រូវការដោះស្រាយ, ល្អរក្សាទុក, អាក្រក់កម្ចាត់ចោល, ធានាលោកអ្នកពីថ្ងៃនេះតទៅអាចបួសហាត់, ប៉ុន្តែចាំបាច់គឺមករៀនមហាធម៌ពិតប្រាកដ។ ប្រសិនលោកអ្នកឱបយកចិត្តប្រកាន់គ្រប់ប្រភេទ, ឱបយកមកចំណង់សីលគង់, មកព្យាបាលជំងឺ, មកសាកស្ដាប់ទ្រឹស្ដី, ឬក៏បានឱបយកគោលបំណងមិនល្អអ្វីមួយ, នេះសុទ្ធតែមិនបាន។ ដោយសារខ្ញុំបានសម្ដែងរួចហើយ, រឿងរ៉ាវនេះមានតែខ្ញុំម្នាក់កំពុងធ្វើ។ រឿងរ៉ាវបែបនេះ, ឱកាសមិនច្រើន, ខ្ញុំក៏នឹងមិនរមែងបង្រៀនបែបនេះ។ ខ្ញុំមានអារម្មណ៍មនុស្សដែលអាចដោយផ្ទាល់ស្ដាប់បានខ្ញុំបង្រៀនគង់សម្ដែងធម៌, ខ្ញុំនិយាយពិតជា..........អនាគតលោកអ្នកនឹងដឹង, លោកអ្នកនឹងមានអារម្មណ៍ថាពេលវេលាដំណាក់កាលនេះគឺគួរឲ្យរីករាយខ្លាំងណាស់។ ប្រាកដណាស់យើងខ្ញុំសម្ដែងវាសនា, អ្នករាល់គ្នាអង្គុយនៅទីនេះសុទ្ធតែជាវាសនា។

បង្រៀនគង់ឡើងលើជាន់ថ្នាក់ខ្ពស់, អ្នករាល់គ្នាគិតសាកមើល, ជាបញ្ហាអ្វី? នោះមិនមែនប្រោសមនុស្សឬ? ប្រោសមនុស្ស, លោកអ្នកជាក់ស្ដែងគឺបួសហាត់ពិតប្រាកដ, គឺមិនគ្រាន់តែជាព្យាបាលជំងឺកាយសម្បទា។ ដូច្នោះបួសហាត់ពិតប្រាកដ, ចំពោះចិត្តចរិតរបស់សិក្ខាកាមតម្រូវក៏ជាត្រូវខ្ពស់ផងដែរ។ ពួកយើងមនុស្សដែលអង្គុយនៅទីនេះ, គឺមករៀនមហាធម៌, ដូច្នោះលោកអ្នកគឺត្រូវតែចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់ម្នាក់ពិតប្រាកដអង្គុយនៅទីនេះ, លោកអ្នកគឺត្រូវតែបោះចោលចិត្តប្រកាន់។ លោកអ្នកឱបយកគោលបំណងមានចំណង់គ្រប់ប្រភេទមករៀនគង់, រៀនមហាធម៌, នោះលោកអ្នករៀនមិនបានអ្វីទាំងអស់។ ប្រាប់លោកអ្នកសច្ចធម៌មួយ៖ ដំណើរការបួសហាត់ទាំងមូលរបស់មនុស្សជាក់ស្ដែងគឺជាដំណើរការបន្តកម្ចាត់ចិត្តប្រកាន់របស់មនុស្ស។ មនុស្ស

នៅក្នុងសង្គមមនុស្សសាមញ្ញ, អ្នកប្រជែងខ្ញុំប្រយុទ្ធ, បន្លំបញ្ឆោតគ្នា, ដើម្បីផលប្រយោជន៍ឯកជនបន្តិចនេះ, ទៅធ្វើបាបអ្នកដទៃ, ចិត្តទាំងនេះសុទ្ធតែត្រូវបោះចោល។ ជាពិសេសពួកយើងមនុស្សដែលកំពុងរៀនគង់ថៃហ្គឹង, ចិត្តទាំងនេះត្រូវតែបោះចោលជាងទៀត។

ខ្ញុំនៅទីនេះមិនសម្តែងព្យាបាលជំងឺ, យើងខ្ញុំក៏មិនព្យាបាលជំងឺ។ ប៉ុន្តែជាមនុស្សបួសហាត់ពិតប្រាកដ, លោកអ្នកនាំតាមរាងកាយដែលមានជំងឺ, លោកអ្នកគឺបួសហាត់មិនបាន។ ខ្ញុំត្រូវការបន្សុទ្ធរាងកាយឲ្យលោកអ្នក។ បន្សុទ្ធរាងកាយគ្រាន់តែកំហិតនៅមនុស្សដែលមករៀនគង់ពិតប្រាកដ, មនុស្សដែលមករៀនធម៌ពិតប្រាកដ។ យើងខ្ញុំសង្កត់ធ្ងន់ចំណុចមួយ៖ លោកអ្នកបោះចោលមិនបានចិត្តមួយនោះ, លោកអ្នកបោះចោលមិនបានជំងឺមួយនោះ, យើងខ្ញុំមិនអាចធ្វើអ្វីបាន, សម្រាប់លោកអ្នកមិនអាចជួយបានអ្វី។ ហេតុអី? ដោយសារក្នុងចក្រវាលនេះមានគោលសីលធម៌មួយបែបនេះ, រឿងរ៉ាវក្នុងមនុស្សសាមញ្ញ, យោងតាមពុទ្ធវង្សសម្តែង, សុទ្ធតែជាមានទំនាក់ទំនងកម្មផល, កើតចាស់ឈឺស្លាប់, នៅទីមនុស្សសាមញ្ញជាក់ស្តែងគឺស្ថិតនៅបែបនេះ។ ដោយសារមនុស្សពីមុនធ្លាប់បានធ្វើរឿងអាក្រក់ហើយសាងបង្កើតអំណាចកម្មទើបបង្កជាមានជំងឺឬគ្រោះលំបាក។ ទទួលទោសជាក់ស្តែងគឺកំពុងសងបំណុលកម្ម, ដូច្នេះ, នរណាក៏មិនអាចផ្លាស់ប្តូរវាតាមអំពើចិត្ត, ផ្លាស់ប្តូររួចហើយគឺស្មើនឹងជំពាក់បំណុលអាចមិនសង; ក៏មិនអាចតាមអំពើចិត្តស្រេចតែចិត្តទៅធ្វើ, បើមិនដូច្នេះទេ, គឺស្មើនឹងកំពុងធ្វើរឿងអាក្រក់។

មនុស្សខ្លះសន្មតថាព្យាបាលជំងឺឲ្យគេ, ព្យាបាលជំងឺកាយសម្បទាគឺជាធ្វើរឿងល្អ។ តាមខ្ញុំសង្កេតមើល, សុទ្ធតែគ្មានព្យាបាលជំងឺជាសះស្បើយពិតប្រាកដ, គឺសុទ្ធតែយកជំងឺរុញថយមកក្រោយ, ឬក៏បំប្លែង,

និងគ្មានយកវាចេញបាត់ទៅ។ ពិតប្រាកដកម្ចាត់ចោលគ្រោះមួយនេះ, គឺត្រូវតែលុបជម្រះអំណាចកម្ម។ ប្រសិនពិតប្រាកដអាចព្យាបាលជំងឺនេះជាសះស្បើយ, លុបជម្រះទាំងស្រុងអំណាចកម្មទាំងនេះ, ពិតប្រាកដអាចសម្រេចបានចំណុចមួយនេះ, ជាន់ថ្នាក់ឯកជននេះក៏មិនទាបផងដែរ។ គាត់បានមើលឃើញគោលសីលធម៌មួយរួចហើយ, ក៏ជាក់ស្ដែងជាគោលសីលធម៌ក្នុងមនុស្សសាមញ្ញគឺមិនអាចបំផ្លាញតាមអំពើចិត្ត។ នៅក្នុងដំណើរការបួសហាត់, អ្នកបួសហាត់ផុសពីចិត្តមេត្តា, ទៅធ្វើរឿងល្អមួយចំនួន, ជួយមនុស្សព្យាបាលជំងឺ, ព្យាបាលជំងឺកាយសម្បទា, នេះគឺអនុញ្ញាត, ប៉ុន្តែក៏មិនអាចព្យាបាលឲ្យមនុស្សជាសះស្បើយទាំងស្រុង។ ប្រសិនអាចលុបចោលឫសគល់ជំងឺរបស់មនុស្សសាមញ្ញ, មនុស្សសាមញ្ញម្នាក់មិនបួសហាត់ពីក្នុងទីនេះដើរចេញទៅ, ជំងឺអ្វីក៏គ្មានទៀត, ចេញពីទ្វារនៅតែជាមនុស្សសាមញ្ញម្នាក់, ខាងផលប្រយោជន៍ឯកជននៅតែប្រជែងប្រយុទ្ធដូចជាមនុស្សសាមញ្ញ, ធ្វើម្ដេចអាចតាមអំពើចិត្តលុបបំបាត់អំណាចកម្មរបស់គាត់? នេះគឺដាច់ខាតមិនអនុញ្ញាត។

ដូច្នោះហេតុអ្វីអាចធ្វើឲ្យមនុស្សបួសហាត់? ដោយសារមនុស្សបួសហាត់គឺដ៏មានតម្លៃបំផុត, គាត់ចង់បួសហាត់, ដូច្នេះ, គំនិតមួយផុសចេញមកគឺដ៏មានតម្លៃបំផុត។ ក្នុងពុទ្ធវង្សសម្ដែងពុទ្ធចរិត, ពុទ្ធចរិតផុសចេញកាលណា, ពួកអង្គត្រាស់ដឹងគឺអាចជួយគាត់។ មានន័យថាយ៉ាងម៉េច? បើហៅខ្ញុំសម្ដែង, ដោយសារខ្ញុំនៅលើជាន់ថ្នាក់ខ្ពស់បង្រៀនគង់, ពាក់ព័ន្ធដល់គោលសីលធម៌ក្នុងជាន់ថ្នាក់ខ្ពស់, បញ្ហាដែលពាក់ព័ន្ធដ៏ធំ។ នៅក្នុងចក្រវាលនេះ, យើងខ្ញុំមើលឃើញជីវិតរបស់មនុស្ស, មិនមែនសាងបង្កើតនៅក្នុងសង្គមមនុស្សសាមញ្ញ។ ការសាងបង្កើតជីវិតពិតប្រាកដរបស់មនុស្ស, គឺសាងបង្កើតនៅក្នុងអវកាសចក្រវាល។ ដោយ

សារក្នុងចក្រវាលនេះមានសារធាតុដ៏ច្រើនគ្រប់ប្រភេទសាងបង្កើតជីវិត, សារធាតុទាំងនេះនៅក្នុងការធ្វើចលនាទៅវិញទៅមកអាចសាងបង្កើតជីវិត, ក៏មានន័យថា, ជីវិតដំបូងបំផុតរបស់មនុស្សគឺប្រភពមកពីក្នុងចក្រវាល។ អវកាសចក្រវាលដើមមកជាក់ស្តែងគឺស្លូតករុណា, ជាក់ស្តែងគឺមានគ្រប់គ្រាន់ប្រភេទចរិតពិសេសនេះនៃសច្ចៈ-ករុណា-ខន្តី, មនុស្សកើតមកនិងចក្រវាលគឺចរិតដូចគ្នា។ ប៉ុន្តែកាយជីវិតសាងបង្កើតច្រើនរួចហើយ, ក៏បានកើតឡើងប្រភេទទំនាក់ទំនងសង្គមមួយក្នុងចំណោមក្រុម។ ពីក្នុងចំណោមមានមនុស្សខ្លះ, អាចបង្កើតថែមចិត្តអាត្មានិយម, បន្តិចម្តងៗបន្ទាបជាន់ថ្នាក់របស់ពួកគាត់, នឹងមិនអាចរក្សាបាននៅក្នុងជាន់ថ្នាក់មួយនេះទៀត, ពួកគាត់គឺត្រូវធ្លាក់ចុះក្រោម។ ប៉ុន្តែនៅក្នុងជាន់ថ្នាក់មួយផ្សេង, ម្តងទៀតប្រែជាមិនសូវល្អ, ពួកគាត់នៅតែរក្សាមិនបាន, នឹងបន្តធ្លាក់ចុះក្រោម, ទីបំផុតបានធ្លាក់ដល់ក្នុងជាន់ថ្នាក់មួយនេះរបស់មនុស្សជាតិ។

សង្គមមនុស្សជាតិទាំងមូល, សុទ្ធតែជាកំពុងនៅក្នុងមួយជាន់ថ្នាក់។ ធ្លាក់មកដល់ជំហានមួយនេះ, ឈរលើទស្សនៈសីលគង់សង្កេតមើល, ឬក៏ឈរលើទស្សនៈអង្គមហាត្រាស់ដឹងដើម្បីសង្កេតមើល, ដើមមកកាយជីវិតទាំងនេះគឺគួរតែកម្ទេចចោល។ ប៉ុន្តែពួកអង្គមហាត្រាស់ដឹងផុសពីចិត្តមេត្តា, ផ្តល់ឲ្យពួកគាត់ឱកាសម្តងទៀត, បានបង្កើតឡើងបរិយាកាសពិសេស, អវកាសពិសេសមួយបែបនេះ។ ហើយកាយជីវិតនៃអវកាសនេះខុសគ្នានឹងកាយជីវិតនៃអវកាសទាំងអស់ក្នុងចក្រវាល។ កាយជីវិតនៃអវកាសនេះ, មើលមិនឃើញកាយជីវិតនៃអវកាសផ្សេង, មើលមិនឃើញសេចក្តីពិតនៃចក្រវាល, ដូច្នេះមនុស្សទាំងនេះស្មើនឹងធ្លាក់នៅក្នុងភាពវង្វេង។ ចង់ជាជំងឺ, កម្ចាត់គ្រោះ, បំបាត់កម្ម, មនុស្ស

ទាំងនេះចាំបាច់ត្រូវតែបួសហាត់, ត្រឡប់ដើមមកសច្ចៈ, នេះគឺនៅក្នុងបួសហាត់គ្រប់ប្រភេទសុទ្ធតែមើលឃើញបែបនេះ។ មនុស្សចង់ត្រឡប់ដើមមកសច្ចៈ, នេះទើបជាគោលបំណងធ្វើមនុស្សពិតប្រាកដ, ដូច្នេះឯកជននេះចង់បួសហាត់កាលណា, ជាក់ស្តែងត្រូវបានសន្មតថាគឺពុទ្ធចរិតផុសចេញ។ គំនិតមួយនេះគឺដ៏មានតម្លៃបំផុត, ដោយសារគាត់ចង់ត្រឡប់ដើមមកសច្ចៈ, ចង់ពីក្នុងជាន់ថ្នាក់នេះរបស់មនុស្សសាមញ្ញលោតចេញទៅ។

អាចអ្នករាល់គ្នាស្តាប់បានក្នុងពុទ្ធសាសនាមានប្រយោគមួយបែបនេះ៖ ពុទ្ធចរិតផុសចេញកាលណា, រញ្ជួយដល់ពិភពដប់ទិស។ នរណាមើលឃើញ, សុទ្ធតែចង់ជួយគាត់, ជួយគាត់ដោយអត់លក្ខខណ្ឌ។ ពុទ្ធវង្សប្រោសមនុស្សគឺមិនសម្តែងលក្ខខណ្ឌ, ដោយមិនគិតថ្លៃ, អាចជួយគាត់ដោយអត់លក្ខខណ្ឌ, ដូច្នេះពួកយើងគឺអាចដើម្បីសិក្ខាកាមធ្វើរឿងរ៉ាវដ៏ច្រើន។ ហើយធ្វើជាមនុស្សសាមញ្ញម្នាក់, គ្រាន់តែចង់ធ្វើមនុស្សក្នុងមនុស្សសាមញ្ញ, គាត់ចង់ជាជំងឺ, គឺមិនបាន។ មនុស្សខ្លះគិតថា៖ ជំងឺខ្ញុំជារួចហើយ, ខ្ញុំនឹងបួសហាត់។ បួសហាត់គឺគ្មានលក្ខខណ្ឌណាមួយ, ចង់បួសហាត់, ដូច្នោះគឺបួសហាត់។ ប៉ុន្តែនាំតាមរាងកាយមួយដែលមានជំងឺ, ឬក៏មនុស្សខ្លះព័ត៌មានលើរាងកាយនៅតែដ៏រញ៉េរញ៉ៃ, មនុស្សខ្លះជាមូលដ្ឋានមិនធ្លាប់ហាត់គង់, ក៏មានមនុស្សខ្លះធ្លាប់ហាត់គង់រាប់សិបឆ្នាំ, នៅតែវង្វេងនៅក្នុងឈើ, ក៏គ្មានបួសឡើងទៅលើបាន។

ធ្វើដូចម្តេច? យើងខ្ញុំគឺនឹងបន្សុទ្ធរាងកាយរបស់គាត់, ធ្វើឲ្យគាត់អាចបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់។ ពេលដែលបួសហាត់នៅលើជាន់ថ្នាក់ទាបបំផុត, មានដំណើរការមួយ, នោះគឺយករាងកាយលោកអ្នកបន្សុទ្ធចុះមកទាំងស្រុង, របស់មិនល្អទាំងអស់ដែលស្ថិតនៅក្នុងមនោគតិ,

វាលអំណាចកម្មដែលស្ថិតនៅជុំវិញរាងកាយនិងកត្តាដែលបង្កជារាងកាយមិនសម្បទា, ទាំងអស់សុទ្ធតែសម្អាតចេញទៅ។ ប្រសិនមិនសម្អាត, នាំតាមរាងកាយមួយដែលល្អក់បែបនេះ, រាងកាយដែលខ្មៅងងឹតនិងមនោគតិមួយដែលកខ្វក់, ធ្វើដូចម្ដេចអាចសម្រេចបានបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់? យើងខ្ញុំនៅទីនេះមិនហាត់ឈី, ជាន់ថ្នាក់ទាបបំផុតអ្វីទាំងនេះមិនចាំបាច់លោកអ្នកហាត់, យើងខ្ញុំរុញលោកអ្នកឆ្លងទៅ, ទុកឲ្យរាងកាយលោកអ្នកសម្រេចបានស្ថានភាពគ្មានជំងឺ។ ក្នុងពេលដំណាលគ្នាយើងខ្ញុំថែមទាំងផ្ដល់ឲ្យលោកអ្នកនូវសំណុំដែលត្រៀមរួចជាស្រេចនៃប្រការទាំងនេះដែលត្រូវការដាក់មូលដ្ឋានលើជាន់ថ្នាក់ទាប, បែបនេះ, ពួកយើងនឹងនៅលើជាន់ថ្នាក់ដ៏ខ្ពស់ដើម្បីហាត់គង់។

យោងតាមការថ្លែងនៃការបួសហាត់, ប្រសិនរាប់ឈី, មានបីជាន់ថ្នាក់។ តែបួសហាត់ពិតប្រាកដ (ហាត់ឈីមិនរាប់), សរុបមានពីរជាន់ថ្នាក់ធំ៖ មួយគឺបួសហាត់លោកីយ៍ធម៌; មួយគឺបួសហាត់ផុតពីលោកីយ៍ធម៌។ លោកីយ៍ធម៌, ផុតពីលោកីយ៍ធម៌នេះនិងចេញលោកីយ៍, ចូលលោកីយ៍ក្នុងវត្តគឺជារឿងពីរផ្សេងគ្នា, នោះគឺអ្វីនៅលើទ្រឹស្ដី។ ពួកយើងគឺជាការផ្លាស់ប្រែរបស់ពីរជាន់ថ្នាក់ធំនៃការបួសហាត់រាងកាយមនុស្សពិតប្រាកដ។ ដោយសារនៅក្នុងដំណើរការបួសហាត់លោកីយ៍ធម៌, រាងកាយរបស់មនុស្សសុទ្ធតែជាកំពុងបន្តបន្សុទ្ធ, បន្តបន្សុទ្ធ, ដូច្នេះពេលដែលដើរដល់ទម្រង់ខ្ពស់បំផុតនៃលោកីយ៍ធម៌, រាងកាយត្រូវបានសារធាតុថាមពលខ្ពស់ជំនួសទាំងស្រុងរួចហើយ។ ហើយបួសហាត់ផុតពីលោកីយ៍ធម៌, ជាមូលដ្ឋាននោះគឺបួសហាត់ពុទ្ធកាយ, ជារាងកាយមួយដែលផ្សំឡើងដោយសារធាតុថាមពលខ្ពស់, សីលគង់ទាំងអស់បញ្ចេញសាជាថ្មីម្ដងទៀត។ ពួកយើងសំដៅលើគឺពីរជាន់ថ្នាក់ធំនេះ។

យើងខ្ញុំសម្ដែងវាសនា, អ្នករាល់គ្នាអង្គុយនៅទីនេះ, ខ្ញុំអាចធ្វើរឿងរ៉ាវនេះឲ្យអ្នករាល់គ្នា។ ពួកយើងពេលនេះក៏ច្រើនជាងពីរពាន់នាក់, រាប់ពាន់នាក់, សូម្បីតែមនុស្សច្រើនជាងទៀត, ជាងម៉ឺននាក់, ខ្ញុំសុទ្ធតែអាចធ្វើបាន, ក៏មានន័យថា, នៅលើជាន់ថ្នាក់ទាបមិនចាំបាច់លោកអ្នកហាត់ម្ដងទៀត។ បន្ទាប់ពីបន្សុទ្ធរាងកាយរបស់លោកអ្នក, រុញលោកអ្នកឆ្លងទៅ, ខ្ញុំដំឡើងឲ្យលោកអ្នកមួយសំណុំពេញលេញនៃប្រព័ន្ធបួសហាត់, លោកអ្នកពេលចាប់ផ្ដើមដោយផ្ទាល់គឺបួសហាត់នៅលើជាន់ថ្នាក់ខ្ពស់។ ប៉ុន្តែ, គ្រាន់តែកំហិតចំពោះសិក្ខាកាមដែលមកបួសហាត់ពិតប្រាកដ, មិនមែននិយាយថាលោកអ្នកអង្គុយនៅទីនេះ, លោកអ្នកជាក់ស្ដែងគឺជាអ្នកបួសហាត់។ ពេលដែលមានការផ្លាស់ប្ដូរជាមូលដ្ឋានក្នុងមនោគតិ, យើងខ្ញុំនឹងអាចផ្ដល់ឱ្យ, ក៏មិនត្រឹមតែជាទាំងនេះ, ក្រោយមកលោកអ្នកនឹងយល់, ខ្ញុំសុទ្ធតែបានផ្ដល់ឲ្យអ្នករាល់គ្នារបស់អ្វីខ្លះ។ យើងខ្ញុំនៅទីនេះក៏មិនសម្ដែងព្យាបាលជំងឺ, ប៉ុន្តែយើងខ្ញុំសម្ដែងកែសម្រួលរាងកាយសិក្ខាកាមទាំងមូល, ធ្វើឲ្យលោកអ្នកអាចហាត់គង់បាន។ លោកអ្នកនាំតាមរាងកាយមួយដែលមានជំងឺ, លោកអ្នកជាមូលដ្ឋាននឹងមិនបញ្ចេញគង់បាន, ដូច្នេះអ្នករាល់គ្នាក៏កុំមករកខ្ញុំព្យាបាលជំងឺ, ខ្ញុំក៏មិនធ្វើរឿងរ៉ាវនេះ។ គោលបំណងនាំមុខដែលខ្ញុំចេញមកសាធារណៈ, ជាក់ស្ដែងគឺនាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់, ពិតប្រាកដនាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់។

## ជាន់ថ្នាក់ខុសគ្នាមានធម៌នៃជាន់ថ្នាក់ខុសគ្នា

អតីតកាលមានគ្រូឈីគង់ជាច្រើនសម្ដែងឈីគង់មានអ្វីបឋម, មធ្យម, ឧត្ដម។ នោះសុទ្ធតែជាឈី, សុទ្ធតែជាអ្វីនៃការហាត់ឈីក្នុងមួយជាន់ថ្នាក់នោះ, ក៏ត្រូវបានបែងចែកជាបឋម, មធ្យម, ឧត្ដម។ ប្រការលើជាន់ថ្នាក់ខ្ពស់ពិតប្រាកដ, នៅក្នុងខួរក្បាលរបស់អ្នកបួសហាត់ឈី

គង់ពួកយើងភាគច្រើនគឺជាទទេ, ជាមូលដ្ឋានគឺមិនដឹង។ ចាប់ពីពេលនេះតទៅដែលយើងខ្ញុំបរិយាយយ៉ាងល្អិតល្អន់សុទ្ធតែជាធម៌ក្នុងជាន់ថ្នាក់ខ្ពស់។ ក្រៅពីនេះ, ខ្ញុំចង់កែតម្រូវឡើងវិញកេរ្ដិ៍ឈ្មោះរបស់បួសហាត់។ ក្នុងពេលខ្ញុំកំពុងសម្ដែងមេរៀន, នឹងនិយាយដល់បាតុភូតមិនល្អមួយចំនួនក្នុងពិភពបួសហាត់។ ពួកយើងប្រព្រឹត្តដូចម្ដេច, យល់ឃើញដូចម្ដេចចំពោះបាតុភូតទាំងនេះ, ខ្ញុំសុទ្ធតែត្រូវការសម្ដែងចេញ; នៅមានបង្រៀនគង់សម្ដែងធម៌នៅក្នុងជាន់ថ្នាក់ខ្ពស់, ទិដ្ឋភាពដែលពាក់ព័ន្ធ, បញ្ហាដែលពាក់ព័ន្ធសុទ្ធតែធំបង្គួរ, សូម្បីតែគឺមុតស្រួចណាស់ផង, រឿងរ៉ាវទាំងនេះខ្ញុំក៏ចង់យកវាសម្ដែងចេញមក; មានជ្រៀតជ្រែកមួយចំនួនចំពោះសង្គមមនុស្សសាមញ្ញពួកយើងដែលប្រភពមកពីអវកាសផ្សេង, ជាពិសេសគឺជ្រៀតជ្រែកចំពោះពិភពបួសហាត់, ខ្ញុំក៏ចង់យកវាសម្ដែងចេញ, ក្នុងពេលដំណាលគ្នាដោះស្រាយបញ្ហាទាំងនេះឲ្យសិក្ខាកាមរបស់ពួកយើង។ បញ្ហាទាំងនេះប្រសិនជាមិនដោះស្រាយ, លោកអ្នកហាត់គង់មិនបាន។ ចង់ដោះស្រាយបញ្ហាទាំងនេះពីឫសគល់, យើងខ្ញុំគឺចាំបាច់ចាត់ទុកអ្នករាល់គ្នាធ្វើជាមនុស្សបួសហាត់ពិតប្រាកដទើបអាចធ្វើបែបនេះបាន។ ប្រាកដណាស់, ចង់ភ្លាមៗប្រែផ្លាស់មនោគតិរបស់លោកអ្នកមិនងាយស្រួលនោះទេ, ក្នុងពេលស្ដាប់សម្ដែងពីពេលនេះតទៅ, លោកអ្នកនឹងសន្សឹមៗប្រែផ្លាស់មនោគតិរបស់លោកអ្នក, ក៏សង្ឃឹមថាអ្នករាល់គ្នាស្ដាប់ដោយយកចិត្តទុកដាក់។ ខ្ញុំបង្រៀនគង់ខុសនឹងអ្នកដទៃបង្រៀនគង់។ មនុស្សខ្លះបង្រៀនគង់, គាត់គ្រាន់តែសុទ្ធសាធសម្ដែងបន្តិចអំពីទ្រឹស្ដីនៃគង់របស់គាត់, បន្ទាប់មកតភ្ជាប់បន្តិចព័ត៌មាន, បង្រៀនមួយសំណុំបច្ចេកទេសគឺចប់រឿង។ គេបានទម្លាប់បង្រៀនគង់បែបនេះរួចហើយ។

បង្រៀនគង់ពិតប្រាកដត្រូវសម្ដែងអំពីធម៌, ត្រូវនិយាយអំពីតាវ។ នៅក្នុង១០មេសម្ដែង, ខ្ញុំចាំបាច់យកគោលសីលធម៌នៃជាន់ថ្នាក់ខ្ពស់ សុទ្ធតែបរិយាយចេញយ៉ាងល្អិតល្អន់, លោកអ្នកទើបអាចបួសហាត់បាន; បើមិនដូច្នេះទេ, ជាមូលដ្ឋានគឺគ្មានវិធីបួសហាត់។ ដែលអ្នកដទៃបង្រៀន សុទ្ធតែជាប្រការនៃការព្យាបាលជំងឺកាយសម្បទាមួយជាន់ថ្នាក់នោះ, លោកអ្នកចង់បួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, លោកអ្នកគ្មានធម៌ក្នុង ជាន់ថ្នាក់ខ្ពស់ធ្វើការដឹកនាំ, លោកអ្នកក៏បួសហាត់មិនបាន។ ដូចជា លោកអ្នកទៅរៀន, លោកអ្នកកាន់សៀវភៅបឋមសិក្សាទៅរៀនមហាវិទ្យា ល័យ, លោកអ្នកនៅតែជាសិស្សបឋមសិក្សា។ មនុស្សខ្លះសន្មតថារៀន គង់ដ៏ច្រើន, គង់នេះ, គង់នោះ, វិញ្ញាបនបត្របញ្ចប់ការសិក្សាមានមួយ គំនរយ៉ាងនោះ, ប៉ុន្ដែ, គង់របស់គាត់នៅតែគ្មានបង្កើនឡើង។ គាត់សន្មត ថាទាំងនេះជាក់ស្ដែងគឺជាសេចក្ដីពិតនិងទាំងអស់របស់ឈីគង់រួចហើយ, មិនមែន, វាគ្រាន់តែជាសំបកក្រៅរបស់ឈីគង់, ប្រការដែលនៅលើជាន់ ថ្នាក់ទាបបំផុត។ ឈីគង់មិនមែនត្រឹមតែប៉ុណ្ណោះ, វាគឺជាបួសហាត់, គឺជា អ្វីមួយធំទូលាយស៊ីជម្រៅ, លើសពីនេះជាន់ថ្នាក់ខុសគ្នានៅស្ថិតនៅធម៌ ខុសគ្នា, ដូច្នេះមិនដូចអ្វីនៃការហាត់ឈីដែលពួកយើងបានដឹងបច្ចុប្បន្ន, លោកអ្នកហាត់ច្រើនដល់ណាក៏ដូចគ្នាផងដែរ។ លើកឧទាហរណ៍, សៀវភៅបឋមសិក្សាអង់គ្លេសលោកអ្នករៀន; សៀវភៅបឋមសិក្សាអាមេ រិកលោកអ្នករៀន; សៀវភៅបឋមសិក្សាជប៉ុនលោកអ្នករៀន; សៀវភៅ បឋមសិក្សាចិនលោកអ្នកក៏រៀន, ហើយលោកអ្នកនៅតែជាសិស្សបឋម សិក្សា។ មេរៀនគង់នៃជាន់ទាបលោកអ្នករៀនច្រើនដល់ណា, ស្រោច ចូលពេញដល់ណា, ផ្ទុយមកវិញកាន់តែមានគ្រោះថ្នាក់ចំពោះលោកអ្នក, លើរាងកាយលោកអ្នកបានរញ៉េរញ៉ៃរួចហើយ។

ខ្ញុំចង់សង្កត់ធ្ងន់បញ្ហាមួយទៀត, ពួកយើងបួសហាត់, គឺត្រូវបង្រៀនគង់សម្តែងធម៌។ ព្រះសង្ឃនៅតាមវត្តអារាមមួយចំនួន, ជាពិសេសគឺឆានចុង, អាចមានមតិមួយចំនួន។ ដរាបណាស្តាប់និយាយអំពីសម្តែងធម៌, គាត់គឺមិនចូលចិត្តស្តាប់។ ហេតុអ្វី? ឆានចុងសន្មតថា៖ ធម៌នេះមិនអាចសម្តែង, ធម៌កាលណាសម្តែងចេញមក, គឺមិនមែនជាធម៌, គ្មានធម៌អាចសម្តែង, គ្រាន់តែអាចយល់ពីក្នុងចិត្តប៉ុណ្ណោះ, ដូច្នេះឆានចុងដល់សព្វថ្ងៃនេះ, ធម៌អ្វីសុទ្ធតែមិនសម្តែង។ តាហ៏ម៉រ{ខាង}ឆានចុងបង្រៀនប្រការនេះ, គឺយោងតាមប្រយោគមួយដែលសក្យមុនីបាននិយាយ។ សក្យមុនីសម្តែងថា៖ ធម៌មិនកំណត់ធម៌។ គាត់គឺយោងតាមប្រយោគមួយនេះដែលសក្យមុនីសម្តែងបានបង្កើតឡើងធម្មក្ខន្ធឆានចុង។ យើងខ្ញុំនិយាយថាធម្មក្ខន្ធមួយនេះជាក់ស្តែងគឺខួងចុងស្នែងគោ។ ដូចម្តេចហៅថាខួងចុងស្នែងគោ? ពេលដែលតាហ៏ម៉រចាប់ផ្តើមខួងចូលខាងក្នុង, នៅតែមានអារម្មណ៍ថាដ៏ទូលាយ; ជំនាន់ទី២ខួងគឺមិនសូវទូលាយទៀត; ជំនាន់ទី៣នៅតែខិតចូលបាន; ជំនាន់ទី៤គឺបានចង្អៀតណាស់រួចហើយ; ជំនាន់ទី៥ជាមូលដ្ឋានគ្មានអ្វីអាចខួងបានទៀត; ដល់ជំនាន់ទី៦ហួយណឹងទីនេះ, គឺដល់កំពូលរួចហើយ, ខួងទៀតក៏ចូលក្នុងមិនបាន។ សព្វថ្ងៃលោកអ្នកចង់ដល់ឆានចុងរៀនធម៌, លោកអ្នកកុំសួរ, លោកអ្នកមានបញ្ហាអ្វីចង់សួរគាត់, វិលមកឲ្យក្បាលលោកអ្នកមួយដំបង, ហៅថា "ប៉ាង់ហឿ"។ មានន័យថាលោកអ្នកកុំសួរ, ត្រូវតែភ្ញាក់ដឹងដោយខ្លួនឯង។ លោកអ្នកនិយាយថា៖ ខ្ញុំមិនដឹងអ្វីទាំងអស់ទើបមករៀន, ភ្ញាក់ដឹងបានអ្វី? លោកឲ្យខ្ញុំមួយដំបង? នេះជាក់ស្តែងគឺចុងស្នែងគោបានខួងដល់កំពូលរួចហើយ, ក៏គ្មានអ្វីអាចសម្តែងបានទៀត។ តាហ៏ម៉រក៏សម្តែងថាគាត់គ្រាន់តែអាចបង្រៀនបាន៦ជំនាន់, ក្រោយមកគឺមិនបានទៀត។ រាប់រយ

ឆ្នាំបានកន្លងផុតទៅ, តែបច្ចុប្បន្ននៅតែមានមនុស្សឱបស្លាប់ទ្រឹស្ដីរបស់ឆានចុងមិនលែង។ អត្ថន័យពិតប្រាកដដែលសក្យមុនីសម្ដែង [ធម៌មិនកំណត់ធម៌] ជាអ្វី? ជាន់ថ្នាក់បិតនៅរបស់សក្យមុនីគឺយូឡាយ, រួមបញ្ចូលព្រះសង្ឃជាច្រើនក្រោយមកសុទ្ធតែគ្មានភ្ញាក់ដឹងដល់ជាន់ថ្នាក់បិតនៅរបស់សក្យមុនី, ស្ថានភាពផ្លូវចិត្តក្នុងកម្រិតភពមនោគតិរបស់គាត់, អត្ថន័យពិតប្រាកដនៃធម៌ដែលគាត់សម្ដែង, អត្ថន័យពិតប្រាកដនៃពាក្យដែលគាត់និយាយចេញ។ ដូច្នេះមនុស្សក្រោយមកពន្យល់យ៉ាងនេះ, ពន្យល់យ៉ាងនោះ, ពន្យល់ដ៏រញ៉េរញ៉ៃ, សន្មតថាធម៌មិនកំណត់ធម៌ជាក់ស្ដែងគឺលោកអ្នកកុំសម្ដែង, សម្ដែងចេញមកគឺមិនមែនជាធម៌ទៀត។ ភាពពិតមិនមែនជាន័យនេះ។ បន្ទាប់ពីសក្យមុនីនៅក្រោមដើមពោធិបើកគង់ត្រាស់ដឹង, មិនមែនភ្លាមៗគឺសម្រេចបានជាន់ថ្នាក់យូឡាយមួយនេះ។ គាត់នៅក្នុងអំឡុងពេល៤៩ឆ្នាំទាំងមូលបង្រៀនធម៌, ក៏កំពុងបន្តលើកកម្ពស់ខ្លួនឯង។ រាល់ពេលគាត់លើកកម្ពស់មួយជាន់ថ្នាក់, វិលមកមើលធម៌ដែលខ្លួនឯងទើបសម្ដែងសុទ្ធតែមិនត្រូវទៀត។ បន្ទាប់ពីលើកកម្ពស់ម្ដងទៀត, គាត់រកឃើញថាធម៌ដែលគាត់សម្ដែងរួចហើយក៏មិនត្រូវទៀត។ រង់ចាំគាត់លើកកម្ពស់ម្ដងទៀត, គាត់រកឃើញថាធម៌ដែលទើបតែសម្ដែងក៏មិនត្រូវទៀត។ ៤៩ឆ្នាំទាំងមូល, គាត់សុទ្ធតែជាបន្តថ្កើងឡើងបែបនេះ, រាល់ពេលបន្ទាប់ពីលើកកម្ពស់មួយជាន់ថ្នាក់, រកឃើញថាធម៌ដែលគាត់ធ្លាប់សម្ដែងពីមុននៅលើការយល់ដឹងសុទ្ធតែជាដ៏ទាប។ គាត់ក៏រកឃើញថាធម៌នៃជាន់ថ្នាក់នីមួយៗសុទ្ធតែជាការបង្ហាញនៃធម៌នៅក្នុងជាន់ថ្នាក់នីមួយៗ, ជាន់ថ្នាក់នីមួយៗសុទ្ធតែមានធម៌, ប៉ុន្តែសុទ្ធតែមិនមែនសច្ចធម៌ដាច់ខាតក្នុងចក្រវាល។ ហើយធម៌នៃមួយជាន់ថ្នាក់ខ្ពស់ខិតទៅជិតចរិតពិសេសនៃចក្រវាលជាងមួយជាន់ថ្នាក់ទាប, ដូច្នេះ, គាត់

បានសម្ដែងថា៖ ធម៌មិនកំណត់ធម៌។

ទីបំផុតសក្យមុនីក៏សម្ដែងទៀតថា៖ យើងមួយឆាកជីវិតគ្មានសម្ដែងធម៌អ្វីទាំងអស់។ ឆានចុងម្ដងទៀតពន្យល់ថាគ្មានធម៌អាចសម្ដែង។ សក្យមុនីក្នុងវ័យចំណាស់សម្រេចបានជាន់ថ្នាក់យូឡាយរួចហើយ, គាត់ហេតុអ្វីនិយាយថាគ្មានសម្ដែងធម៌អ្វីទាំងអស់? ភាពពិតគាត់បានសម្ដែងមួយបញ្ហាអ្វី? គាត់គឺនិយាយថា៖ សម្រេចបានជាន់ថ្នាក់យូឡាយបែបនេះដូចយើងរួចហើយ, យើងក៏មិនទាន់មើលឃើញបានគោលសីលធម៌ចុងបញ្ចប់, ធម៌ចុងបញ្ចប់នៃចក្រវាលជាអ្វី។ ដូច្នេះគាត់ហៅមនុស្សជំនាន់ក្រោយមិនបានយកពាក្យដែលគាត់សម្ដែងធ្វើជាសច្ចធម៌ដាច់ខាត, សច្ចធម៌មិនផ្លាស់ប្ដូរ, បែបនោះនឹងធ្វើឲ្យមនុស្សជំនាន់ក្រោយកំហិតនៅក្នុងជាន់ថ្នាក់យូឡាយឬក៏ទាបជាងយូឡាយ, មិនអាចទម្លុះដល់ជាន់ថ្នាក់ខ្ពស់ជាង។ មនុស្សជំនាន់ក្រោយពន្យល់មិនបានន័យពិតប្រាកដរបស់ប្រយោគនេះ, ក៏សន្មតថាធម៌បានសម្ដែងចេញមកគឺមិនមែនធម៌ទៀត, ទៅពន្យល់បែបនេះ។ ភាពពិតសក្យមុនីគឺសម្ដែងថា៖ ជាន់ថ្នាក់ខុសគ្នាមានធម៌នៃជាន់ថ្នាក់ខុសគ្នា, ធម៌នៃជាន់ថ្នាក់នីមួយៗសុទ្ធតែមិនមែនសច្ចធម៌ដាច់ខាតក្នុងចក្រវាល, ប៉ុន្តែធម៌ក្នុងមួយជាន់ថ្នាក់នេះគឺមានផលប៉ះពាល់ដឹកនាំនៅក្នុងមួយជាន់ថ្នាក់នេះ។ គាត់ភាពពិតបានសម្ដែងគោលសីលធម៌មួយយ៉ាងនេះ។

អតីតកាលមានមនុស្សជាច្រើន, ជាពិសេសគឺឆានចុង, តែងតែរក្សាការយល់ដឹងលម្អៀងនិងខុសជ្រុលមួយប្រភេទបែបនេះ។ មិនបង្រៀនលោកអ្នក, ធ្វើដូចម្ដេចដឹកនាំដើម្បីហាត់, ហាត់របៀបណា, ហើយបួសរបៀបណា? ក្នុងពុទ្ធសាសនាមានរឿងនិទានពុទ្ធសាសនាជាច្រើន, អាចមនុស្សខ្លះធ្លាប់បានអានរួចហើយ, និយាយថាឡើងលើមេឃ, បន្ទាប់ពី

ដល់ឋានសួគ៌, រកឃើញថា 《គម្ពីរជីនកាង》 នៅខាងលើនិង 《គម្ពីរជីនកាង》 នៅខាងក្រោមអក្សរនីមួយៗសុទ្ធតែមិនដូចគ្នា, ន័យសុទ្ធតែមិនដូចគ្នា។ 《គម្ពីរជីនកាង》 នេះហេតុអ្វីខុសគ្នានឹង 《គម្ពីរជីនកាង》 នោះក្នុងឋានមនុស្សសាមញ្ញ? ក៏មានមនុស្សនិយាយថា៖ គម្ពីរសៀវភៅពិភពសុខៈនិងឋានក្រោមសុទ្ធសាធខុសគ្នាទាំងស្រុង, មិនដូចគ្នាទាល់តែសោះ, មិនត្រឹមតែអក្សរខុសគ្នា, អត្ថន័យ, ន័យទាំងអស់សុទ្ធតែខុសគ្នា, កើតឡើងការផ្លាស់ប្ដូររួចហើយ។ ភាពពិតជាក់ស្ដែងគឺជាធម៌មួយដូចគ្នានៅជាន់ថ្នាក់ខុសគ្នាសុទ្ធតែមានការផ្លាស់ប្ដូរនិងទម្រង់បង្ហាញខុសគ្នា, ចំពោះអ្នកបួសហាត់នៅជាន់ថ្នាក់ខុសគ្នាអាចផ្ដើមផលប៉ះពាល់ដឹកនាំខុសគ្នា។

អ្នករាល់គ្នាដឹងថា, ក្នុងពុទ្ធសាសនាមានសៀវភៅតូចមួយក្បាលហៅថា 《កំណត់ត្រាដំណើរកម្សាន្តពិភពសុខៈទិសខាងលិច》, និយាយថាមានព្រះសង្ឃមួយអង្គអង្គុយសមាធិហាត់គង់, វិញ្ញាណដើមបានដល់ពិភពសុខៈមើលឃើញទស្សនីយភាព, អស់មួយថ្ងៃ, ត្រឡប់ដល់ឋានមនុស្ស៦ឆ្នាំបានកន្លងទៅរួចហើយ។ គាត់មើលឃើញឬអត់? មើលឃើញ, ប៉ុន្តែដែលគាត់មើលឃើញមិនមែនសេចក្តីពិត។ ហេតុអ្វី? ដោយសារជាន់ថ្នាក់របស់គាត់មិនគ្រប់, គ្រាន់តែអាចនៅក្នុងជាន់ថ្នាក់នេះរបស់គាត់លាតត្រដាងចេញឲ្យគាត់ការបង្ហាញនៃពុទ្ធធម៌ដែលគាត់គួរតែមើលឃើញប៉ុណ្ណោះ។ ព្រោះពិភពមួយបែបនោះជាក់ស្ដែងគឺជាការបង្ហាញពីសមាសភាគរបស់ធម៌, ដូច្នេះគាត់មិនអាចមើលឃើញសេចក្ដីពិត។ ខ្ញុំសម្ដែងធម៌មិនកំណត់ធម៌នេះជាក់ស្ដែងជាអត្ថន័យមួយបែបនេះ។

## សច្ចៈ, ករុណា, ខន្តីជាបរមាណីយតែមួយគត់ដើម្បីវាស់វែងមនុស្សល្អនិងអាក្រក់

នៅក្នុងពុទ្ធសាសនាគេតែងតែកំពុងពិភាក្សាពុទ្ធធម៌ជាអ្វី។ ក៏មានមនុស្សសន្មតថាធម៌ដែលសម្ដែងក្នុងពុទ្ធសាសនា, ជាក់ស្ដែងគឺពុទ្ធធម៌ទាំងមូល, ភាពពិតមិនមែន។ ធម៌ដែលសក្យមុនីសម្ដែង, គ្រាន់តែឲ្យប្រភេទមនុស្សសាមញ្ញនោះនៃជាន់ថ្នាក់យ៉ាងទាបបំផុតនៅ២ពាន់៥រយឆ្នាំមុន, ជាក់ស្ដែងគឺទើបដោះលែងចេញពីសង្គមបុព្វកាល, ធម៌ដែលសម្ដែងឲ្យប្រភេទមនុស្សនេះដែលមនោគតិសាមញ្ញតែមួយបង្គួរ។ គាត់សម្ដែងអំពីសម័យកាលផុតធម៌, ជាក់ស្ដែងគឺថ្ងៃនេះ, មនុស្សបច្ចុប្បន្នប្រើធម៌នោះលែងបួសហាត់បានទៀតរួចហើយ។ សម័យកាលផុតធម៌ព្រះសង្ឃក្នុងវត្តអារាមសុទ្ធតែដឹពិបាកប្រោសខ្លួនឯងរួចហើយ, កុំថាឡើយប្រោសមនុស្ស។ ធម៌ដែលសក្យមុនីបង្រៀននាពេលនោះគឺតម្រង់ផ្ទាល់កាលៈទេសៈបែបនោះដើម្បីបង្រៀន, ហើយគាត់ក៏មិនបានសម្ដែងចេញពុទ្ធធម៌ទាំងមូលក្នុងជាន់ថ្នាក់បិតនៅរបស់ខ្លួនឯងបានដឹង, ចង់ទុកឲ្យវារក្សាបានជានិច្ចមិនផ្លាស់ប្ដូរ, ក៏មិនអាចបានផងដែរ។

សង្គមកំពុងអភិវឌ្ឍ, មនោគតិរបស់មនុស្សជាតិកាន់តែស្មុគស្មាញ, នឹងមិនងាយស្រួលធ្វើឲ្យមនុស្សបន្តបួសបែបនេះបានទៀត។ ធម៌ក្នុងពុទ្ធសាសនាមិនអាចគ្របដណ្ដប់ពុទ្ធធម៌ទាំងមូល, វាគ្រាន់តែជាផ្នែកមួយតូចៗក្នុងពុទ្ធធម៌ប៉ុណ្ណោះ។ នៅមានមហាធម៌ជាច្រើនរបស់ពុទ្ធវង្សកំពុងផ្សព្វផ្សាយនៅក្នុងសាធារណជន, សម័យប្រវត្តិសាស្ត្របង្រៀនឯកតា។ ជាន់ថ្នាក់ខុសគ្នាមានធម៌ខុសគ្នា, អវកាសខុសគ្នាមានធម៌ខុសគ្នា, នេះសុទ្ធតែជាការបង្ហាញខុសគ្នានៃពុទ្ធធម៌នៅក្នុងបណ្ដាអវកាស, បណ្ដាជាន់ថ្នាក់ខុសគ្នា។ សក្យមុនីក៏សម្ដែងថាបួសពុទ្ធមាន៨ម៉ឺន៤ពាន់ធម្មក្ខន្ធ, តែក្នុងពុទ្ធសាសនាមានតែឆានចុង, ជិញធូរ, ធានថាយ, ហួរយាន, មីចុងជាដើមជាង១០ធម្មក្ខន្ធ, មិនអាចគ្របដណ្ដប់ពុទ្ធធម៌ទាំង

អស់បាន។ សក្យមុនីខ្លួនឯងក៏គ្មានយកធម៌ទាំងមូលរបស់គាត់បង្រៀនចេញ, គ្រាន់តែតម្រង់ផ្ទាល់សមត្ថភាពទទួលយករបស់មនុស្សនាពេលនោះបានបង្រៀនមួយផ្នែករបស់វាប៉ុណ្ណោះ។

ដូច្នោះពុទ្ធធម៌ជាអ្វី? ចរិតពិសេសមូលដ្ឋានបំផុតក្នុងចក្រវាលនេះ សច្ចៈ, ករុណា, ខន្តីគាត់ជាក់ស្តែងគឺជាភាពបង្ហាញខ្ពស់បំផុតរបស់ពុទ្ធធម៌, គាត់ជាក់ស្តែងគឺជាពុទ្ធធម៌មូលដ្ឋានបំផុត។ ពុទ្ធធម៌នៅក្នុងជាន់ថ្នាក់ខុសគ្នាមានទម្រង់បង្ហាញខុសគ្នា, នៅក្នុងជាន់ថ្នាក់ខុសគ្នាមានផលប៉ះពាល់ដឹកនាំខុសគ្នា, ជាន់ថ្នាក់កាន់តែទាបបង្ហាញកាន់តែស្មុគស្មាញ។ ភាគល្អិតនៃខ្យល់អាកាស, ថ្ម, ឈើ, ដី, ដែក, រាងកាយមនុស្ស, ក្នុងសារធាតុទាំងអស់សុទ្ធតែស្ថិតនៅប្រភេទចរិតពិសេសសច្ចៈ, ករុណា, ខន្តីនេះ; សម័យបុរាណសម្តែងធាតុទាំង៥បង្កើតជាអ្វីៗគ្រប់យ៉ាងក្នុងចក្រវាល, ក៏សុទ្ធតែស្ថិតនៅប្រភេទចរិតពិសេសសច្ចៈ, ករុណា, ខន្តីនេះ។ មនុស្សបួសហាត់ដល់ជាន់ថ្នាក់មួយណាគឺគ្រាន់តែអាចយល់ដឹងពីការបង្ហាញពិស្តារនៃពុទ្ធធម៌ក្នុងជាន់ថ្នាក់មួយនោះ, នេះជាក់ស្តែងគឺជាផលញាណ, ជាន់ថ្នាក់របស់បួសហាត់។ សម្តែងឲ្យទូលំទូលាយ, ធម៌ធំណាស់។ ដល់ចំណុចយ៉ាងខ្ពស់បំផុតដើម្បីសម្តែង, នោះជាក់ស្តែងគឺដ៏សាមញ្ញ, ដោយសារធម៌គឺដូចរាងសាជីជ្រុង។ ដល់ជាន់ថ្នាក់យ៉ាងខ្ពស់បំផុតប្រើ៣អក្សរគឺអាចគ្របដណ្តប់បាន, នោះជាក់ស្តែងគឺជាសច្ចៈ, ករុណា, ខន្តី, លាតត្រដាងដល់បណ្តាជាន់ថ្នាក់គឺយ៉ាងស្មុគស្មាញបំផុត។ យកមនុស្សធ្វើជាឧទាហរណ៍, តាវវង្សចាត់ទុករាងកាយមនុស្សជាចក្រវាលតូច, មនុស្សមានរាងកាយសារធាតុ, ប៉ុន្តែមានតែរាងកាយសារធាតុនៅតែមិនអាចផ្សំឡើងជាមនុស្សម្នាក់ពេញលេញបាន, នៅតែចាំបាច់មានអធ្យាស្រ័យ, ចរិតធម្មជាតិ, ចរិតពិសេស, វិញ្ញាណដើមរបស់

មនុស្សស្ថិតនៅ, ទើបអាចផ្សំឡើងជាមនុស្សម្នាក់ពេញលេញ, ឯករាជ្យ, មាននាំតាមបុគ្គលភាពខ្លួនឯង។ ចក្រវាលរបស់ពួកយើងក៏ដូចគ្នា, មានប្រព័ន្ធកញ្ចុំផ្កាយ, ប្រព័ន្ធផ្កាយដទៃ, ក៏មានជីវិតនិងទឹក, អ្វីៗគ្រប់យ៉ាងក្នុងចក្រវាលនេះ, នេះជាទិដ្ឋភាពមួយដែលសារធាតុស្ថិតនៅ; ប៉ុន្តែក្នុងពេលដំណាលគ្នាវាក៏ស្ថិតនៅចរិតពិសេសសច្ចៈ, ករុណា, ខន្តី។ ក្នុងភាគល្អិតសារធាតុណាមួយសុទ្ធតែរួមបញ្ចូលចរិតពិសេសប្រភេទនេះ, ក្នុងភាគល្អិតយ៉ាងតូចបំផុតសុទ្ធតែរួមបញ្ចូលចរិតពិសេសប្រភេទនេះ។

ប្រភេទចរិតពិសេសសច្ចៈ, ករុណា, ខន្តីនេះជាបរមាណីយដើម្បីវាស់វែងល្អនិងអាក្រក់ក្នុងចក្រវាល។ អ្វីជាល្អអ្វីជាអាក្រក់? ជាក់ស្តែងគឺប្រើគាត់ដើម្បីវាស់វែង។ គុណធម៌ដែលពួកយើងនិយាយក្នុងអតីតកាលក៏ដូចគ្នាផងដែរ។ ប្រាកដណាស់កម្រិតសីលធម៌សង្គមមនុស្សជាតិថ្ងៃនេះបានកើតឡើងការផ្លាស់ប្តូររួចហើយ, បរមាណីយសីលធម៌សុទ្ធតែរមួលបត់រួចហើយ។ បច្ចុប្បន្នមានមនុស្សរៀនតាមឡីហ្វឹង, អាចគឺត្រូវគេនិយាយថាគាត់ជាជំងឺវិកលចរិត, ប៉ុន្តែនៅសម័យទសវត្សរ៍៥០, ៦០, មាននរណានឹងនិយាយថាគាត់ជាជំងឺវិកលចរិត? កម្រិតសីលធម៌មនុស្សជាតិកំពុងជម្រាលចុះចំណោតធំ, ពិភពលោកកាន់តែអាក្រក់ទៅៗ, ផលចំណេញមកមុន, ដើម្បីផលប្រយោជន៍ឯកជនបន្តិចនោះទៅធ្វើបាបអ្នកដទៃ, អ្នកប្រជែងខ្ញុំប្រយុទ្ធ, ធ្វើបែបនេះមិនរើសអើងល្បិចកលណាមួយឡើយ។ អ្នករាល់គ្នាគិតសាកមើល, អាចអនុញ្ញាតឲ្យបន្តបែបនេះបានឬ? មនុស្សខ្លះធ្វើរឿងអាក្រក់, លោកអ្នកនិយាយប្រាប់គាត់គឺកំពុងធ្វើរឿងអាក្រក់, គាត់សុទ្ធតែមិនជឿ, គាត់ពិតជាមិនជឿខ្លួនឯងកំពុងធ្វើរឿងអាក្រក់; មានមនុស្សមួយចំនួនគាត់នៅតែប្រើកម្រិតសីលធម៌ដែលជម្រាលចុះដើម្បីវាស់វែងខ្លួនឯង, សន្មតថាខ្លួនឯងល្អជាងអ្នក

ដទៃ, ដោយសារបរមាណីយដើម្បីរាស់រវៃងសុទ្ធតែបានកើតឡើងការផ្លាស់ប្តូររួចហើយ។ មិនថាបរមាណីយសីលធម៌របស់មនុស្សជាតិផ្លាស់ប្តូរដូចម្តេច, ប៉ុន្តែចរិតពិសេសនៃចក្រវាលនេះផ្ទុយមកវិញនឹងមិនផ្លាស់ប្តូរ, គាត់គឺជាបរមាណីយតែមួយគត់ដើម្បីវាស់វែងមនុស្សល្អនិងអាក្រក់។ ដូច្នោះធ្វើជាមនុស្សបួសហាត់ម្នាក់គឺត្រូវតែយោងតាមចរិតពិសេសនេះនៃចក្រវាលដើម្បីតម្រូវខ្លួនឯង, មិនអាចយោងតាមបរមាណីយរបស់មនុស្សសាមញ្ញដើម្បីតម្រូវខ្លួនឯង។ លោកអ្នកចង់ត្រឡប់ដើមមកសច្ចៈ, លោកអ្នកចង់បួសហាត់ឡើងលើ, លោកអ្នកគឺត្រូវតែយោងតាមបរមាណីយនេះដើម្បីធ្វើ។ ធ្វើជាមនុស្សម្នាក់, អាចសម្របខ្លួនតាមចរិតពិសេសសច្ចៈ, ករុណា, ខន្តីនេះ, នោះទើបជាមនុស្សល្អ; មនុស្សដែលអនុវត្តចាកចេញពីចរិតពិសេសនេះ, នោះគឺមនុស្សអាក្រក់ពិតប្រាកដ។ នៅក្នុងអង្គភាព, នៅលើសង្គម, មនុស្សខ្លះអាចនិយាយថាលោកអ្នកអាក្រក់, លោកអ្នកក៏មិនជាក់លាក់ពិតជាអាក្រក់; មនុស្សខ្លះនិយាយថាលោកអ្នកល្អ, លោកអ្នកក៏មិនជាក់លាក់ពិតជាល្អ។ ធ្វើជាអ្នកបួសហាត់ម្នាក់, សមកាលកម្មជាមួយចរិតពិសេសនេះ, លោកអ្នកជាក់ស្តែងគឺជាអង្គសម្រេចតាវ, ជាគោលសីលធម៌សាមញ្ញយ៉ាងនេះ។

តាវវង្សបួសហាត់សច្ចៈ, ករុណា, ខន្តីចំណុចសំខាន់បួសសច្ចៈ។ ដូច្នេះតាវវង្សសម្តែងបួសសច្ចៈអប់រំចរិត, និយាយពាក្យសច្ចៈ, ធ្វើរឿងសច្ចៈ, ធ្វើមនុស្សសច្ចៈ, ត្រឡប់ដើមមកសច្ចៈ, ទីបំផុតបួសត្រាស់ជាអង្គសច្ចំ។ ប៉ុន្តែខន្តីក៏មាន, ករុណាក៏មាន, ចំណុចសំខាន់ធ្លាក់នៅលើសច្ចៈដើម្បីបួស។ ចំណុចសំខាន់របស់ពុទ្ធវង្សធ្លាក់នៅលើករុណានៃសច្ចៈ, ករុណា, ខន្តីដើម្បីបួស។ ដោយសារបួសករុណាអាចបួសផុសចេញចិត្តមហាមេត្តា, ផុសចេញចិត្តមហាមេត្តាកាលណា, មើលឃើញ

សត្វលោកទាំងឡាយសុទ្ធតែទុក្ខ, ដូច្នេះក៏បានកើតចេញបំណងមួយ, ចង់ប្រោសសត្វលោកទាំងឡាយ។ ប៉ុន្តែសច្ចៈក៏មាន, ខន្តីក៏មាន, ចំណុចសំខាន់ធ្លាក់នៅលើករុណានៃសច្ចៈ-ករុណា-ខន្តីដើម្បីបួស។ ធម្មក្ខន្ធហ្វាលូនតាហ្វាមួយនេះរបស់ពួកយើងគឺយោងតាមបរមាណើយខ្ពស់បំផុតនៃចក្រវាល—សច្ចៈ, ករុណា, ខន្តីបួសដំណាលគ្នា, គង់ដែលពួកយើងហាត់ធំណាស់។

## ឈីគង់ជាវប្បធម៌បុរេប្រវត្តិ

តើឈីគង់ជាអ្វី? គ្រូឈីគង់ដ៏ច្រើនសុទ្ធតែកំពុងសម្តែង, ដែលខ្ញុំសម្តែងនិងដែលពួកគាត់សម្តែងគឺមិនដូចគ្នា។ គ្រូឈីគង់ដ៏ច្រើនគឺសម្តែងនៅក្នុងមួយជាន់ថ្នាក់នោះ, ខ្ញុំគឺសម្តែងការយល់ដឹងអំពីឈីគង់នៅលើជាន់ថ្នាក់ខ្ពស់ជាង, ជាមួយនឹងការយល់ដឹងរបស់ពួកគាត់ខុសគ្នាទាំងស្រុង។ គ្រូឈីគង់ខ្លះសម្តែងថា៖ ឈីគង់នៅប្រទេសយើងមានប្រវត្តិ២ពាន់ឆ្នាំ; ក៏មានមនុស្សសម្តែងមានប្រវត្តិ៣ពាន់ឆ្នាំ; មានមនុស្សសម្តែងមានប្រវត្តិ៥ពាន់ឆ្នាំ, ជាមួយនឹងប្រវត្តិសាស្ត្រអរិយធម៌ជាតិសាសន៍ចិនពួកយើងមិនខុសគ្នាប៉ុន្មាន; ក៏មានមនុស្សសម្តែងថា, ពីក្នុងកំណាយវត្ថុបុរាណដើម្បីសង្កេតមើល, មានប្រវត្តិ៧ពាន់ឆ្នាំរួចហើយ, លើសឆ្ងាយខ្លាំងណាស់ពីប្រវត្តិសាស្ត្រអរិយធម៌ជាតិសាសន៍ចិនពួកយើង។ ប៉ុន្តែមិនថាធ្វើដូចម្តេចដើម្បីយល់ដឹង, សុទ្ធតែមិនលើសផុតពីប្រវត្តិសាស្ត្រអរិយធម៌របស់មនុស្សជាតិច្រើនពេកដែរ។ យោងតាមទ្រឹស្តីនៃការវិវត្តន៍របស់ Darwin, មនុស្សជាតិពីរុក្ខជាតិក្នុងទឹកដល់សត្វក្នុងទឹក; បន្ទាប់មកឡើងទៅលើដី; ហើយឡើងទៅលើដើមឈើ; ម្តងទៀតចុះមកលើដីក្លាយជាស្វាមនុស្ស; ទីបំផុតវិវត្តទៅជាមនុស្សជាតិទំនើបមានវប្បធម៌, មានមនោគតិដើម្បីប៉ាន់ស្មាន, អរិយធម៌មនុស្សជាតិពិតប្រាកដលេចឡើងក៏មិន

លើសផុតពី១ម៉ឺនឆ្នាំ។ រុញទៅមុខទៀត, សូម្បីតែភ្ជាប់ខ្សែព្ធួរចំណាំរឿងក៏គ្មាន។ នោះជាក់ស្តែងគឺរុំព័ទ្ធដោយស្លឹកឈើ, ស៊ីសាច់ឆៅ; ទៅមុខទៀតអាចសូម្បីតែភ្លើងក៏មិនចេះប្រើ, ទាំងស្រុងគឺជាប្រភេទមនុស្សព្រៃ, ប្រភេទមនុស្សបុព្វកាល។

ប៉ុន្តែផ្ទុយមកវិញយើងខ្ញុំរកឃើញបញ្ហាមួយ, នៅកន្លែងជាច្រើនលើផែនដីបានបន្សល់ទុកជាច្រើនៗសំណល់បុរាណអរិយធម៌, សុទ្ធតែលើសផុតសែនឆ្ងាយប្រវត្តិសាស្ត្រអរិយធម៌របស់មនុស្សជាតិពួកយើង។ សំណល់បុរាណទាំងនេះ, ពីទស្សនៈបច្ចេកទេសសង្កេតមើល, សុទ្ធតែមានកម្រិតបច្ចេកទេសដ៏ខ្ពស់, ពីកម្រិតសិល្បៈដើម្បីសង្កេតមើល, ដ៏ក្រៃលែង, មនុស្សទំនើបសុទ្ធសាធសុទ្ធតែកំពុងធ្វើត្រាប់តាមសិល្បៈនៃមនុស្សបុរាណ, មានតម្លៃសិល្បៈដ៏ខ្ពស់។ ប៉ុន្តែវាគឺបានបន្សល់ទុកពីជាង១០ម៉ឺនឆ្នាំមុន, រាប់សិបម៉ឺនឆ្នាំមុន, រាប់រយម៉ឺនឆ្នាំមុន, សូម្បីតែជាងមួយរយលានឆ្នាំមុន។ លោកអ្នកគិតសាកមើល, នេះមិនមែនកំពុងលេងសើចជាមួយនឹងប្រវត្តិសាស្ត្រសព្វថ្ងៃហើយឬ? ក៏គ្មានអ្វីអាចលេងសើច, ដោយសារមនុស្សជាតិក៏កំពុងបន្តធ្វើឲ្យខ្លួនឯងល្អឥតខ្ចោះ, កំពុងបន្តយល់ដឹងខ្លួនឯងសាជាថ្មី, សង្គមជាក់ស្តែងគឺអភិវឌ្ឍបែបនេះ, ការយល់ដឹងដំបូងមិនជាក់លាក់គឺត្រឹមត្រូវដាច់ខាតនោះទេ។

អាចមានមនុស្សជាច្រើនធ្លាប់ឮថា "វប្បធម៌បុរេប្រវត្តិ", ក៏បានហៅថា "អរិយធម៌បុរេប្រវត្តិ", យើងខ្ញុំនឹងសម្តែងអំពីអរិយធម៌បុរេប្រវត្តិនោះ។ នៅលើផែនដីមានទ្វីបអាស៊ី, ទ្វីបអឺរ៉ុប, អាមេរិកខាងត្បូង, អាមេរិកខាងជើង, ទ្វីបអូស្ត្រាលី, ទ្វីបអាហ្វ្រិកនិងទ្វីបអង់តាកទិក, ភូគព្ភវិទូហៅរួមពួកវាថា "ប្លុកដីគោក"។ ប្លុកដីគោកបង្កើតឡើងរហូតមកដល់ថ្ងៃនេះ, បានមានប្រវត្តិរាប់សិបលានឆ្នាំរួចហើយ។ ក៏មានន័យថា, មានទ្វីបជាច្រើន

គឺអណ្ដែតឡើងពីបាតសមុទ្រ, ក៏មានទីបជាច្រើនបានលិចចុះទៅបាតសមុទ្រ, ស្ថេរភាពមកដល់ស្ថានភាពនេះសព្វថ្ងៃមានប្រវត្តិរាប់ពាន់ម៉ឺនឆ្នាំរួចហើយ។ ប៉ុន្តែនៅក្រោមបាតមហាសាគរជាច្រើន, ផ្ទុយមកវិញបានរកឃើញអគារបុរាណធំខ្ពស់មួយចំនួន, រូបចម្លាក់នៃអគារទាំងនេះស្រស់ស្អាតខ្លាំងណាស់, មិនមែនជាបេតិកភណ្ឌនៃមនុស្សជាតិបច្ចុប្បន្នពួកយើង, ដូច្នោះ, វាបញ្ជាក់ថាបានសាងសង់មុនពេលលិចចុះបាតសមុទ្រ។ ដូច្នោះរាប់សិបលានឆ្នាំមុនគឺនរណាបានបង្កើតអរិយធម៌ទាំងនេះ? ពេលនោះ, មនុស្សជាតិពួកយើងមិនទាន់ជាសត្វស្វានៅឡើយ, ធ្វើដូចម្ដេចចេះបង្កើតចេញរបស់ដែលមានប្រាជ្ញាខ្ពស់យ៉ាងនេះ? នៅលើពិភពលោក, បុរាណវិទូបានរកឃើញសត្វមួយប្រភេទ, ហៅថា Trilobite, វាជាសត្វនៃ៦០០លានឆ្នាំមុនដល់២៦០លានឆ្នាំមុន, ដល់២៦០លានឆ្នាំក្រោយមក, សត្វប្រភេទនេះក៏គ្មានទៀត។ អ្នកវិទ្យាសាស្ត្រជនជាតិអាមេរិកម្នាក់បានរកឃើញបាសាណីភូត Trilobite មួយបំណែក, ក្នុងពេលដំណាលគ្នាខាងលើផ្ទៃនៅមានស្នាមជើងរបស់មនុស្សម្នាក់, គឺពាក់ស្បែកជើងជាន់ពីលើ, ផ្ចិតយ៉ាងច្បាស់នៅលើផ្ទៃ។ នេះមិនមែនកំពុងលេងសើចជាមួយប្រវត្តិវិទូហើយឬ? យោងតាមទ្រឹស្ដីនៃការវិវត្តន៍របស់ Darwin, ២៦០លានឆ្នាំមុនធ្វើម្ដេចនឹងមានមនុស្សបានទៅ?

នៅក្នុងសារមន្ទីរនៃមហាវិទ្យាល័យជាតិប៉េរូមានថ្មមួយដុំ, ខាងលើដុំថ្មឆ្លាក់រូបមនុស្សម្នាក់, យោងតាមការស៊ើបអង្កេតរូបមនុស្សនេះគឺបានឆ្លាក់កាលពី៣ម៉ឺនឆ្នាំមុន។ ប៉ុន្តែ, ផ្ទុយមកវិញរូបមនុស្សនេះស្លៀកសម្លៀកបំពាក់, ពាក់មួក, ពាក់ស្បែកជើង, ក្នុងដៃនៅមានកាន់កែវយឺតតារាសាស្ត្រមួយកំពុងសង្កេតមើលរាងកាយលោកធាតុ។ មនុស្ស៣ម៉ឺនឆ្នាំមុន, ធ្វើដូចម្ដេចចេះត្បាញនិងស្លៀកពាក់? រឹតតែមិនគួរឲ្យជឿ, គាត់

នៅកាន់កែវយឺតតារាសាស្ត្រសង្កេតមើលរាងកាយលោកធាតុ, ថែមទាំងមានចំណេះដឹងជាក់លាក់អំពីតារាសាស្ត្រទៀតផង។ ពួកយើងរហូតសន្មតថាមនុស្សទ្វីបអឺរ៉ុប Galileo បានបង្កើតកែវយឹតតារាសាស្ត្រ, មកដល់បច្ចុប្បន្នប្រវត្តិហួសពេកទើបតែជាង៣០០ឆ្នាំ, ប៉ុន្តែ៣ម៉ឺនឆ្នាំមុនជានរណាបានប្រឌិតកែវយឹតតារាសាស្ត្រនេះ? នៅមានអាថ៌កំបាំងជាច្រើនទៀតដែលមិនទាន់ពន្យល់បាន។ ដូចជាមានរូបគំនូរលើផ្ទាំងថ្មជាច្រើនក្នុងរូងភ្នំនៅប្រទេសបារាំង, អាហ្វ្រិកខាងត្បូង, ជួរភ្នំអ័ល្ប, ឆ្លាក់ពិតជាដូចមានជីវិត, រស់រវើក។ រូបមនុស្សដែលបានឆ្លាក់, ប្រណិតនិងស្អាតខ្លាំងណាស់, នៅបានលាបពណ៌ដោយសារធាតុរ៉ែទៀតផង។ ប៉ុន្តែ, មនុស្សទាំងនេះសុទ្ធតែជាសម្លៀកបំពាក់របស់មនុស្សទំនើប, មានចំណុចដូចជាឈុតមួយ, ស្លៀកខោជើងវែង។ អ្នកខ្លះកាន់វត្ថុដូចជាខ្សៀ, អ្នកខ្លះកាន់ឈើច្រត់, ពាក់មួក។ សត្វស្វារាប់សិបម៉ឺនឆ្នាំមុន, ធ្វើដូចម្តេចអាចមានកម្រិតសិល្បៈខ្ពស់យ៉ាងនេះ?

និយាយឆ្ងាយបន្តិចទៀត, ទ្វីបអាហ្វ្រិកមានប្រទេសសាធារណៈរដ្ឋហ្គាបុងមានរ៉ែអ៊ុយរ៉ាញ៉ូម, ប្រទេសនេះឱនថយបង្គួរ, ខ្លួនឯងមិនអាចធ្វើការចម្រាញ់អ៊ុយរ៉ាញ៉ូមបាន, យកវានាំចេញទៅប្រទេសជឿនលឿន។ ឆ្នាំ១៩៧២, រោងចក្រមួយនៅប្រទេសបារាំងបាននាំចូលរ៉ែអ៊ុយរ៉ាញ៉ូមប្រភេទនេះ។ ឆ្លងកាត់ការធ្វើតេស្តមន្ទីរពិសោធន៍បានរកឃើញរ៉ែអ៊ុយរ៉ាញ៉ូមប្រភេទនេះសុទ្ធតែធ្លាប់ត្រូវបានចម្រាញ់រួចហើយ, ធ្លាប់ត្រូវបានប្រើរួចហើយ។ មានអារម្មណ៍ដ៏ចម្លែក, ក៏បញ្ជូនបុគ្គលិកបច្ចេកវិទ្យាទៅស៊ើបអង្កេត, អ្នកវិទ្យាសាស្ត្រនៃប្រទេសជាច្រើនក៏ទៅស៊ើបអង្កេតផងដែរ។ ទីបំផុតបានបញ្ជាក់ថាអណ្តូងរ៉ែអ៊ុយរ៉ាញ៉ូមនេះគឺជារ៉ែអាក់ទ័រនុយក្លេអ៊ែខ្នាតធំមួយ, លើសពីនេះទៀតប្លង់គឺសមហេតុផលខ្លាំងណាស់, មនុស្សពួក

យើងបច្ចុប្បន្នក៏មិនអាចបង្កើតចេញបាន។ ដូច្នេះ, សាងសង់នៅពេលណា? គឺ២ពាន់លានឆ្នាំមុន, វាបានដំណើរការ៥សែនឆ្នាំមុនរួចហើយ។ នេះសុទ្ធសាធជាតួលេខតារាសាស្ត្រ, យោងតាមទ្រឹស្តីនៃការវិវត្តន៍របស់ Darwin ជាមូលដ្ឋានមិនអាចពន្យល់បាន, រឿងរ៉ាវទាំងនេះច្រើនខ្លាំងណាស់។ អ្វីដែលបានរកឃើញក្នុងពិភពបច្ចេកវិទ្យាបច្ចុប្បន្នគ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរសៀវភៅសិក្សារួចហើយ។ បន្ទាប់ពីគោលគំនិតចាស់ប្រពៃណីនិយមរបស់មនុស្សជាតិបង្កើតជាវិធីធ្វើការងារនិងការគិតជាប្រព័ន្ធ, វាពិបាកណាស់ក្នុងការទទួលយកការយល់ដឹងថ្មី។ សច្ចធម៌បានលេចឡើងហើយក៏មិនហ៊ានទៅទទួលយកវា, បង្កើតឡើងការច្រានចោលមួយប្រភេទតាមសភាវគតិ។ ដោយឥទ្ធិពលរបស់គោលគំនិតប្រពៃណី, បច្ចុប្បន្នគ្មាននរណាទៅកែសម្រួលប្រការទាំងនេះជាប្រព័ន្ធ, ដូច្នេះគោលគំនិតរបស់មនុស្សតែងតែតាមមិនទាន់ការអភិវឌ្ឍន៍, លោកអ្នកនិយាយដល់រឿងទាំងនេះកាលណា, ទោះបីវាមិនទាន់ជាសកលក៏ដោយ, ត្រូវបានរកឃើញរួចហើយ, ប៉ុន្តែមានមនុស្សនៅតែនិយាយថាជាអបិយជំនឿ, ទទួលយកមិនបាន។

អ្នកវិទ្យាសាស្ត្រក្លាហានបរទេសជាច្រើនបានទទួលស្គាល់ជាសាធារណៈថាវាជាប្រភេទវប្បធម៌បុរេប្រវត្តិមួយ, ជាអរិយធម៌ដែលមានមុនអរិយធម៌លើកនេះរបស់មនុស្សជាតិពួកយើង, ជាក់ស្តែងគឺនៅពីមុនអរិយធម៌លើកនេះរបស់ពួកយើងនៅតែស្ថិតនៅសម័យកាលអរិយធម៌, ថែមទៀតក៏មិនត្រឹមតែមួយដង។ ពីកំណាយវត្ថុបុរាណដើម្បីសង្កេតមើល, សុទ្ធតែមិនមែនជាផលិតផលនៃមួយសម័យកាលអរិយធម៌, ដូច្នេះសន្មតថាបន្ទាប់ពីអរិយធម៌ច្រើនដងនៃមនុស្សជាតិទទួលរងវាយប្រហារនៃចរិតកម្ទេចចោល, មានតែមនុស្សមួយចំនួនប៉ុណ្ណោះដែលបានរួចជីវិត, រស់

នៅក្នុងជីវិតបុព្វកាល, ម្តងទៀតរីកចម្រើនបន្តិចម្តងៗទៅជាមនុស្សជាតិថ្មី, ឈានចូលក្នុងអរិយធម៌ថ្មី។ បន្ទាប់មកម្តងទៀតដើរសំដៅកម្ទេចចោល, ម្តងទៀតរីកចម្រើនទៅជាមនុស្សជាតិថ្មី, វាជាក់ស្តែងគឺឆ្លងកាត់វដ្តផ្លាស់ប្តូរមួយខុសៗគ្នាបែបនេះ។ រូបវិទូនិយាយថា, សារធាតុធ្វើចលនាគឺមានបទច្បាប់, ការផ្លាស់ប្តូរនៃចក្រវាលរបស់ពួកយើងក៏មានបទច្បាប់។

ការធ្វើចលនារបស់ផែនដីពួកយើង, នៅក្នុងចក្រវាលសែនធំធេងនេះ, ខណៈពេលប្រព័ន្ធកញ្ចុំផ្កាយកំពុងដំណើរការ, មិនអាចពេលណាក៏ដំណើរការរលូនដោយគ្មានឧបសគ្គ, ទំនងណាស់នឹងប៉ះទង្គិចលើភពណាមួយ, ឬក៏បានកើតឡើងបញ្ហាផ្សេង, បានបង្កជាគ្រោះមហន្តរាយដ៏ធំ។ ឈរនៅលើទស្សនៈនៃសីលគង់ពួកយើងដើម្បីសង្កេតមើល, ជាក់ស្តែងគឺរៀបចំយ៉ាងនោះ។ មានម្តងខ្ញុំបានពិនិត្យដោយប្រុងប្រយ័ត្ន, រកឃើញថាមនុស្សជាតិមាន៨១ដងទាំងស្រុងស្ថិតក្នុងស្ថានភាពនៃកម្ទេចចោល, មានតែមនុស្សមួយចំនួនប៉ុណ្ណោះបានរួចជីវិត, បន្សល់ទុកបន្តិចអរិយធម៌បុរេប្រវត្តិដើម, ឈានចូលក្នុងមួយសម័យកាលបន្ទាប់, រស់នៅក្នុងជីវិតបុព្វកាល។ មនុស្សជាតិរីកចម្រើនច្រើនហើយ, ទីបំផុតម្តងទៀតបានលេចឡើងអរិយធម៌។ ឆ្លងកាត់៨១ដងវដ្តផ្លាស់ប្តូរបែបនេះ, ខ្ញុំនេះក៏មិនទាន់ពិនិត្យដល់ចុងបញ្ចប់។ ជនជាតិចិនសម្តែងថាវេលានៃមេឃ, ប្រយោជន៍នៃដី, សន្តិភាពនៃមនុស្ស។ បាតុភូតតារាសាស្ត្រផ្លាស់ប្តូរខុសគ្នា, វេលានៃមេឃខុសគ្នា, នឹងនាំមកឱ្យសង្គមមនុស្សសាមញ្ញស្ថានភាពសង្គមខុសគ្នា។ ប្រើរូបវិទ្យាដើម្បីសម្តែងសារធាតុធ្វើចលនាគឺមានបទច្បាប់, ការធ្វើចលនារបស់ចក្រវាលក៏ជាដូចគ្នា។

វប្បធម៌បុរេប្រវត្តិដែលសម្តែងខាងលើចម្បងគឺប្រាប់អ្នករាល់គ្នាថា៖ ឈើគង់ក៏មិនមែនជាមនុស្សជាតិពួកយើងថ្ងៃនេះប្រឌិតឡើងផងដែរ, ក៏

ជាបានឆ្លងកាត់យុគ្គសម័យយូរអង្វែងបង្គួរបន្សល់ទុកមក, ក៏ជាប្រភេទវប្បធម៌បុរេប្រវត្តិមួយ។ នៅក្នុងសៀវភៅគម្ពីរពួកយើងក៏អាចរកឃើញការអធិប្បាយមួយចំនួន។ សក្យមុនីនាពេលនោះធ្លាប់បានសម្ដែង, គាត់នៅប៉ុន្មានអ៊ីកប្បមុនបានបួសសម្រេចតាវរួចហើយ។ មួយកប្បគឺជាប៉ុន្មានឆ្នាំ? មួយកប្បជាក់ស្ដែងគឺជាប៉ុន្មានអ៊ីឆ្នាំ, តួលេខដែលធំមហិមាយ៉ាងនេះ, សុទ្ធសាធមិនគួរឲ្យជឿ។ ប្រសិនគឺជាពាក្យពិត, តើនេះមិនស្របគ្នានឹងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ, ការផ្លាស់ប្រែរបស់ផែនដីទាំងមូលឬ? លើសពីនេះសក្យមុនីនៅធ្លាប់សម្ដែងថា, មុនគាត់នៅមានព្រះពុទ្ធបុព្វកាល៦អង្គស្ថិតនៅ, គាត់ក៏មានគ្រូជាដើម, សុទ្ធតែជាប៉ុន្មានអ៊ីកប្បមុនបានបួសហាត់សម្រេចតាវរួចហើយ។ ប្រសិនជារឿងរ៉ាវទាំងនេះសុទ្ធតែជាពាក្យពិត, ដូច្នោះនៅក្នុងគង់ហ្វាបង្រៀនសុចរិត, គង់ហ្វាផ្លូវការពិតប្រាកដទាំងនោះដែលបានបង្រៀននៅលើសង្គមពួកយើងថ្ងៃនេះ, តើមានវិធីសាស្ត្របួសហាត់បែបនេះដែរឬអត់? បើហៅខ្ញុំឆ្លើយ, ប្រាកដណាស់គឺបញ្ជាក់, ប៉ុន្តែជួបមិនច្រើន។ បច្ចុប្បន្នឈីគង់ក្លែងក្លាយ, ឈីគង់ក្លែងបន្លំ, មនុស្សដែលមាននាំតាមកាយភ្ជាប់, បង្កើតអ្វីរញ៉េរញ៉ៃមួយចំនួនដើម្បីបញ្ឆោតមនុស្ស, លើសពីឈីគង់ពិតប្រាកដច្រើនទ្វេដង, ពិតនិងក្លែងក្លាយពិបាកសំគាល់។ ឈីគង់ពិតប្រាកដមិនសូវងាយស្រួលសំគាល់, ក៏មិនសូវងាយស្រួលរកឃើញបាន។

ភាពពិតមិនគ្រាន់តែជាឈីគង់បានបន្សល់មកពីយុគ្គសម័យយូរអង្វែង, ថៃជី, ហឿធូ, ល្អូរស៊ូ, ចូវយី, ប៉ាក្វាជាដើម, សុទ្ធតែជាបុរេប្រវត្តិបន្សល់ទុកមក។ ដូច្នេះពួកយើងថ្ងៃនេះឈរនៅទស្សនៈរបស់មនុស្សសាមញ្ញទៅស្រាវជ្រាវវា, ទៅយល់ដឹងវា, ធ្វើដូចម្ដេចក៏ស្រាវជ្រាវមិនបានច្បាស់លាស់។ ឈរនៅក្នុងជាន់ថ្នាក់នេះ, ទស្សនៈនេះ, កម្រិតភាពមនោ

គតិនេះរបស់មនុស្សសាមញ្ញ, ពន្យល់មិនបានប្រការពិតប្រាកដ។

## ឈើគង់ជាក់ស្តែងគឺជាបួសហាត់

ឈើគង់បានមានប្រវត្តិយូរអង្វែងយ៉ាងនេះ, នៅទីបញ្ចប់គឺប្រើសម្រាប់ធ្វើអ្វី? ខ្ញុំប្រាប់អ្នករាល់គ្នា, ពួកយើងនេះជាមហាធម៌បួសហាត់នៃពុទ្ធវង្ស, ប្រាកដណាស់ជាក់ស្តែងគឺជាបួសពុទ្ធ; ដូច្នោះតាវវង្សគឺជាបួសតាវសម្រេចតាវ។ ខ្ញុំប្រាប់អ្នករាល់គ្នា, "ពុទ្ធ" នេះមិនមែនជាអបិយជំនឿ។ អក្សរ "ពុទ្ធ" នេះគឺជាភាសាសំស្ក្រឹត, ភាសាឥណ្ឌាបុរាណ។ ពេលនោះចម្លងចូលក្នុងប្រទេសចិនពួកយើងមានពីរអក្សរ, ហៅថា "ពុទ្ធោ", ក៏បានបកប្រែវាជា "ភូធូ" ផងដែរ។ ចម្លងមកចម្លងទៅ, ជនជាតិពួកយើងបានដកមួយអក្សរ, ហៅវាថាជា "ពុទ្ធ"។ បកប្រែជាភាសាចិន, គឺមានន័យថាយ៉ាងម៉េច? ជាក់ស្តែងគឺជាអង្គត្រាស់ដឹង, មនុស្សដែលឆ្លងកាត់ការបួសហាត់បានត្រាស់ដឹងរួចហើយ។ ទីនេះកន្លែងណាមានឱជារសអបិយជំនឿ?

អ្នករាល់គ្នាគិតសាកមើល, បួសហាត់គឺអាចបញ្ចេញសីលគង់ពិសេស។ បច្ចុប្បន្ននៅលើពិភពលោកមានសីលគង់ពិសេស៦ប្រភេទត្រូវបានទទួលស្គាល់រួចហើយ, មិនត្រឹមតែទាំងនេះ, ខ្ញុំនិយាយថាសីលគង់ពិតប្រាកដមានជាងម៉ឺនប្រភេទ។ មនុស្សអង្គុយនៅទីនោះ, មិនកម្រើកដៃមិនកម្រើកជើង, ហើយអាចធ្វើបានរឿងរ៉ាវដែលគេកម្រើកដៃកម្រើកជើងធ្វើមិនបាន; អាចមើលឃើញគោលសីលធម៌ពិតប្រាកដនៃបណ្តាអវកាសក្នុងចក្រវាល, មើលឃើញសេចក្តីពិតនៃចក្រវាល; មើលឃើញរឿងរ៉ាវដែលមនុស្សសាមញ្ញមើលមិនឃើញ។ នេះនៅតែមិនមែនជាអង្គបួសហាត់សម្រេចតាវឬ? នៅតែមិនមែនជាអង្គមហាត្រាស់ដឹងឬ? អាចនិយាយថាដូចគ្នានឹងមនុស្សសាមញ្ញឬ? នៅតែមិនមែនជាមនុស្ស

បួសហាត់បានត្រាស់ដឹងហើយឬ? ហៅថាអង្គត្រាស់ដឹងមិនត្រូវឬ? បកប្រែជាភាសាតណ្ហាបុរាណជាក់ស្តែងគឺជាពុទ្ធ។ ភាពពិតជាក់ស្តែងគឺជាបែបនេះ, ឈីគង់ជាក់ស្តែងគឺសម្រាប់គោលបំណងនេះ។

និយាយដល់ឈីគង់កាលណា, មានមនុស្សនិយាយថា៖ តើគ្មានជំងឺនរណាហាត់ឈីគង់? ដោយបង្កប់ន័យ, ឈីគង់ជាក់ស្តែងគឺដើម្បីព្យាបាលជំងឺ, នោះជាការយល់ដឹងដ៏រាក់កំផែលៗ។ ចំណុចមួយនេះក៏មិនបន្ទោសអ្នករាល់គ្នា, ដោយសារគ្រូឈីគង់ជាច្រើនសុទ្ធតែជាកំពុងធ្វើរឿងរ៉ាវនេះព្យាបាលជំងឺកាយសម្បទា, សុទ្ធតែសម្តែងអំពីព្យាបាលជំងឺកាយសម្បទា, នរណាក៏គ្មានឆ្ពោះឡើងលើជាន់ថ្នាក់ខ្ពស់សម្តែង។ នេះមិនមែននិយាយថាគង់ហ្វារបស់គេមិនល្អ, បេសកកម្មរបស់គាត់ជាក់ស្តែងគឺជាបង្រៀនប្រការព្យាលបាលជំងឺកាយសម្បទាលើមួយជាន់ថ្នាក់នោះ, ជាសកលឈីគង់។ មានមនុស្សដ៏ច្រើនចង់បួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, មានការគិតបែបនេះ, មានបំណងបែបនេះ, ប៉ុន្តែបួសហាត់មិនទទួលបានធម៌, លទ្ធផលបានបង្កជាភាពលំបាកដ៏ធំ, ថែមទាំងបានលេចឡើងបញ្ហាជាច្រើន។ ប្រាកដណាស់ពិតប្រាកដបង្រៀនគង់នៅលើជាន់ថ្នាក់ខ្ពស់, ពាក់ព័ន្ធដល់បញ្ហាដ៏ខ្ពស់។ ដូច្នេះយើងខ្ញុំក្នុងស្មារតីទទួលខុសត្រូវចំពោះសង្គម, ទទួលខុសត្រូវចំពោះមនុស្ស, ប្រសិទ្ធភាពបង្រៀនគង់ទាំងមូលគឺល្អ។ មានប្រការមួយចំនួនមែនទែនខ្ពស់ណាស់, និយាយទៅដូចជាអបិយជំនឿ, ប៉ុន្តែ, យើងខ្ញុំនឹងព្យាយាមប្រើវិទ្យាសាស្ត្រទំនើបដើម្បីយកវាពន្យល់ចេញមក។

មានប្រការមួយចំនួនយើងខ្ញុំសម្តែងកាលណា, មនុស្សខ្លះនឹងនិយាយថាជាអបិយជំនឿ។ ហេតុអ្វី? បរមាណីយរបស់គាត់ជាក់ស្តែងគឺវិទ្យាសាស្ត្រនៅតែមិនទាន់យល់ដឹងដល់, ឬក៏គាត់ខ្លួនឯងមិនទាន់ទាក់ទង

ដល់, គាត់សន្មតថាមិនអាចស្ថិតនៅ, គាត់គឺសន្មតថាសុទ្ធតែជាអបិយជំនឿ, សុទ្ធតែជាស្ថិតក្នុងឧត្តមគតិ, គាត់ជាក់ស្តែងគឺជាប្រភេទគោលគំនិតនេះ។ ប្រភេទគោលគំនិតនេះត្រូវឬអត់? វិទ្យាសាស្ត្រមិនទាន់យល់ដឹងដល់, នៅតែមិនទាន់អភិវឌ្ឍដល់ជំហានមួយនេះ, គឺអាចនិយាយថាជាអបិយជំនឿ, ជាឧត្តមគតិឬ? ឯកជននេះគាត់ខ្លួនឯងមិនមែនកំពុងធ្វើអបិយជំនឿឬ? ធ្វើឧត្តមគតិឬ? យោងតាមប្រភេទគោលគំនិតនេះ, វិទ្យាសាស្ត្រអាចអភិវឌ្ឍ, អាចជឿនលឿនឬ? សង្គមមនុស្សជាតិក៏មិនអាចជំរុញឆ្ពោះទៅមុខ។ ប្រការដែលពិភពបច្ចេកវិទ្យាពួកយើងប្រឌិតសុទ្ធតែជាប្រការដែលមនុស្សពីមុនមិនទាន់{ដឹង}, សុទ្ធតែចាត់ទុកជាអបិយជំនឿ, ប្រាកដណាស់ក៏មិនចាំបាច់អភិវឌ្ឍទៀត។ ឈើគង់ក៏មិនមែនប្រការឧត្តមគតិអ្វី, មានមនុស្សជាច្រើនមិនយល់ដឹងចំពោះឈើគង់, ដូច្នេះតែងតែសន្មតថាឈើគង់គឺជាឧត្តមគតិ។ បច្ចុប្បន្នប្រើឧបករណ៍វាស់បាននៅលើរាងកាយគ្រូឈើគង់មានសមាសភាគនៃរលក infrasound, រលក supersonic, រលក electromagnetic, កាំរស្មី infrared, កាំរស្មី ultraviolet, កាំរស្មី gamma, នឺត្រុង, អាតូម, និងដានធាតុមីក្រូលោហធាតុជាដើម, អ្វីទាំងនេះមិនសុទ្ធតែជារបស់អត្ថិភាពសារធាតុឬ? វាក៏ជាសារធាតុ។ តើរបស់ណាមួយមិនសុទ្ធតែដោយបានសារធាតុផ្សំឡើង? វេលា-អវកាសផ្សេងទៀតក៏មិនដោយបានសារធាតុផ្សំឡើងឬ? ធ្វើម្តេចអាចនិយាយជាអបិយជំនឿ? ឈើគង់បានជាប្រើដើម្បីប្ញសពុទ្ធរួចហើយ, ដូច្នោះចៀសមិនរួចនឹងពាក់ព័ន្ធដល់បញ្ហាខ្ពស់ជ្រៅជាច្រើន, យើងខ្ញុំសុទ្ធតែត្រូវការសម្តែង។

ឈើគង់បានជាធ្វើសម្រាប់ការនេះរួចហើយ, ពួកយើងហេតុអ្វីហៅវាថាឈើគង់? ភាពពិតវាមិនត្រូវបានហៅថាឈើគង់, ហៅថាអ្វី? ហៅថា

[ប្ញួសហាត់], ជាក់ស្តែងគឺជាប្ញួសហាត់។ ប្រាកដណាស់, វានៅមានឈ្មោះពិស្តារដទៃទៀត, ជារួមហៅថាប្ញួសហាត់។ ហេតុអ្វីហៅថាឈើគង់? អ្នករាល់គ្នាដឹងថា, ឈើគង់ជាសកលនៅលើសង្គមបានមានប្រវត្តិជាង ២០ឆ្នាំរួចហើយ, បានចាប់ផ្តើមនៅសម័យកណ្តាលនៃ [មហាបដិវត្តន៍វប្បធម៌], ដល់សម័យក្រោយគឺឈានចូលក្នុងកម្រិតខ្ពស់បំផុត។ អ្នករាល់គ្នាសាកគិតមើល, នៅពេលនោះមនោគមវិជ្ជាឆ្វេងនិយមគឺធ្ងន់ធ្ងរណាស់។ ពួកយើងមិនសម្តែងអំពីឈ្មោះរបស់ឈើគង់នៃវប្បធម៌បុរេប្រវត្តិហៅថាអ្វី, នៅក្នុងដំណើរការអភិវឌ្ឍន៍នៃអរិយធម៌មនុស្សជាតិលើកនេះរបស់ពួកយើង, វាបានឆ្លងកាត់សង្គមសក្តិភូមិ។ ដូច្នេះជាញឹកញាប់មាននាំតាមឈ្មោះដែលរចនាបថសក្តិភូមិដ៏ក្រាស់។ មានទំនាក់ទំនងជាមួយនឹងសាសនា, ជាញឹកញាប់មាននាំតាមឈ្មោះដែលរចនាបថសាសនាដ៏ក្រាស់។ ឧបមា៖ អ្វី [សៀវតាវតាហ្វា], [ជីនកាងឆាន], [ល្វហានហ្វា], [សៀវភ្ជួរតាហ្វា], [ជីវជួនជីនតានស៊្វ], សុទ្ធតែជាយ៉ាងនេះ។ ប្រសិនហៅវាចេញនៅពេល [មហាបដិវត្តន៍វប្បធម៌], តើលោកអ្នកមិនត្រូវបានរិះគន់ឬ? ទោះបីបំណងដែលគ្រូឈើគង់ជាសកលឈើគង់គឺល្អ, ដើម្បីមហាជនព្យាបាលជំងឺកាយសម្បទា, លើកកម្ពស់គុណភាពរាងកាយរបស់អ្នករាល់គ្នា, រឿងនេះល្អប៉ុណ្ណា, នោះក៏ធ្វើមិនបាន, គេគឺមិនហ៊ានហៅបែបនេះ។ ដូច្នេះគ្រូឈើគង់ជាច្រើនដើម្បីជាសកលឈើគង់, បានសម្រង់ពីក្នុងបរិបទ《តានជីញ》,《តាវចាង》យកចេញពីរអក្សរ, ហៅថាឈើគង់។ មានមនុស្សមួយចំនួននៅតែខួងចូលក្នុងនាមសព្ទឈើគង់ដើម្បីស្រាវជ្រាវ, ប៉ុន្តែគ្មានអ្វីដើម្បីស្រាវជ្រាវ, អតីតកាលវាបានហៅថាប្ញួសហាត់។ ឈើគង់គ្រាន់តែជានាមសព្ទថ្មីដាក់ចេញដើម្បីសមស្របជាមួយនឹងសតិមនោគតិរបស់មនុស្សសម័យទំនើបប៉ុណ្ណោះ។

# ហាត់គង់ហេតុអ្វីមិនបង្កើនគង់

ហាត់គង់ហេតុអ្វីមិនបង្កើនគង់? មនុស្សដ៏ច្រើនមានការគិតបែបនេះ៖ ខ្ញុំហាត់គង់គ្មានទទួលបានការបង្រៀនពិតប្រាកដ, គ្រូណាមួយបង្រៀនឲ្យខ្ញុំបន្តិចជំនាញពិសេស, ហើយបន្តិចបច្ចេកទេសកម្រិតខ្ពស់, គង់នេះរបស់ខ្ញុំនឹងបង្កើនឡើង។ បច្ចុប្បន្នមានមនុស្ស៩៥ភាគរយសុទ្ធតែមានការគិតបែបនេះ, ខ្ញុំមានអារម្មណ៍ដ៏គួរឲ្យសើច។ ហេតុអ្វីគួរឱ្យសើច? ដោយសារឈើគង់មិនមែនភាពជំនាញការក្នុងមនុស្សសាមញ្ញ, វាទាំងស្រុងគឺជាប្រការវិសាមញ្ញ, ដូច្នោះគឺត្រូវប្រើគោលសីលធម៌នៃជាន់ថ្នាក់ខ្ពស់ដើម្បីវាស់វែងវា។ ខ្ញុំសម្ដែងឲ្យអ្នករាល់គ្នា, មូលហេតុមូលដ្ឋានគង់ឡើងមិនបាន៖ ពីរអក្សរ [បួស, ហាត់], គេគ្រាន់តែយកចិត្តទុកដាក់លើអក្សរហាត់តែមិនយកចិត្តទុកដាក់លើអក្សរបួស។ លោកអ្នកឆ្ពោះចេញក្រៅដើម្បីចំណង់, ធ្វើដូចម្ដេចក៏ចំណង់មិនបាន។ រាងកាយរបស់មនុស្សសាមញ្ញលោកអ្នក, ដៃមនុស្សសាមញ្ញ, មនោគតិរបស់មនុស្សសាមញ្ញ, លោកអ្នកចង់វិវត្តសារធាតុថាមពលខ្ពស់ប្រែក្លាយជាគង់? បង្កើនឡើងលើ? និយាយងាយស្រួលពេកហើយ! តាមខ្ញុំមើលឃើញជាក់ស្ដែងគឺជារឿងកំប្លែង។ នេះគឺស្មើនឹងឆ្ពោះចេញក្រៅដើម្បីចំណង់, ឆ្ពោះចេញក្រៅដើម្បីរក, ជានិច្ចក៏រកមិនឃើញ។

នេះមិនដូចជាភាពជំនាញការអ្វីមួយក្នុងមនុស្សសាមញ្ញពួកយើង, លោកអ្នកចំណាយលុយបន្តិច, រៀនបច្ចេកទេសបន្តិច, នឹងរៀនបានវាក្នុងដៃ។ តែនេះមិនមែនរឿងយ៉ាងនោះ, វាជាប្រការដែលលើសផុតពីជាន់ថ្នាក់មួយនេះរបស់មនុស្សសាមញ្ញ, ដូច្នេះសម្រាប់លោកអ្នកត្រូវតែប្រើគោលសីលធម៌វិសាមញ្ញដើម្បីតម្រូវ។ តម្រូវដូចម្ដេច? លោកអ្នកគឺត្រូវតែឆ្ពោះចូលក្នុងដើម្បីបួស, មិនអាចឆ្ពោះចេញក្រៅដើម្បីរក។ មនុស្សជា

ច្រើនសុទ្ធតែកំពុងឆ្ពោះចេញក្រៅដើម្បីចំណង់, ថ្ងៃនេះចំណង់មួយនេះ, ថ្ងៃស្អែកចំណង់មួយនោះ, ថែមទាំងឱបយកចិត្តប្រកាន់ស្វែងរកសីលគង់, មានគោលបំណងគ្រប់ប្រភេទ។ មានមនុស្សនៅតែចង់ធ្វើគ្រូឈីគង់, នៅតែចង់ព្យាបាលជំងឺមានមហាសម្បត្តិ! បួសហាត់ពិតប្រាកដត្រូវតែបួសហាត់ចិត្តនេះរបស់លោកអ្នក, ហៅថាបួសចិត្តចរិត។ ឧបមាថា, ពួកយើងនៅក្នុងទំនាស់រវាងមនុស្សនិងមនុស្ស, យកស្នេហា៧តណ្ហា៦របស់ឯកជន, តណ្ហាគ្រប់ប្រភេទមើលឱ្យស្រាលបន្តិច។ ពេលដែលដើម្បីផលប្រយោជន៍ឯកជនទៅប្រជែងទៅប្រយុទ្ធ, លោកអ្នកក៏ចង់បង្កើនគង់, និយាយងាយស្រួលពេកហើយ! លោកអ្នកនេះមិនមែនដូចគ្នានឹងមនុស្សសាមញ្ញហើយឬ? លោកអ្នកធ្វើដូចម្ដេចអាចបង្កើនគង់? ដូច្នេះត្រូវផ្ដោតលើចិត្តចរិតដើម្បីបួសហាត់, គង់របស់លោកអ្នកទើបអាចបង្កើនឡើងលើ, ជាន់ថ្នាក់ទើបអាចលើកកម្ពស់បាន។

ចិត្តចរិតជាអ្វី? ចិត្តចរិតរួមបញ្ចូលគុណធម៌ (គុណធម៌ជាប្រភេទសារធាតុមួយ); រួមបញ្ចូលខន្តី; រួមបញ្ចូលភ្ញាក់ដឹង; រួមបញ្ចូលលះ, លះចោលតណ្ហាគ្រប់ប្រភេទ, ចិត្តប្រកាន់គ្រប់ប្រភេទក្នុងមនុស្សសាមញ្ញ; នៅតែត្រូវអាចរងទុក្ខជាដើម, រួមបញ្ចូលប្រការនៃទិដ្ឋភាពជាច្រើន។ គ្រប់ទិដ្ឋភាពនៃចិត្តចរិតរបស់មនុស្សសុទ្ធតែចាំបាច់សម្រេចបានការលើកកម្ពស់, បែបនេះលោកអ្នកទើបអាចពិតប្រាកដលើកកម្ពស់ឡើងបាន, នេះជាមូលហេតុសំខាន់មួយនៃការលើកកម្ពស់អំណាចគង់។

មានមនុស្សគិតថា៖ បញ្ហាចិត្តចរិតដែលលោកនិយាយដល់, នេះជាប្រការក្នុងទម្រង់សតិ, ជារឿងរ៉ាវនៃទិដ្ឋភាពកម្រិតភពមនោគតិរបស់មនុស្ស, វានិងគង់ដែលពួកខ្ញុំហាត់មិនដូចគ្នា, ធ្វើដូចម្ដេចមិនដូចគ្នា? នៅក្នុងពិភពមនោគតិពីដើមមកគឺស្ថិតនៅបញ្ហាថាសារធាតុជាចរិត

ទីមួយ, ឬក៏ស្មារតីជាចរិតទីមួយ, តែងតែពិភាក្សា, ជជែករំរែកញែកអំពីបញ្ហានេះ។ ភាពពិតខ្ញុំប្រាប់អ្នករាល់គ្នា, សារធាតុនិងស្មារតីជាចរិតតែមួយ។ នៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្ររាងកាយមនុស្ស, បច្ចុប្បន្នអ្នកវិទ្យាសាស្ត្រសន្មតថា, ផ្នត់គំនិតដែលខួរធំរបស់មនុស្សធ្វើចេញជាក់ស្ដែងគឺជាសារធាតុ។ ដូច្នោះវាជារបស់នៃអត្ថិភាពសារធាតុ, វាមិនជាក់ស្ដែងជារបស់ក្នុងស្មារតីមនុស្សឬ? វាមិនជាក់ស្ដែងជាចរិតតែមួយឬ? គឺដូចចក្រវាលដែលខ្ញុំសម្ដែង, មានអត្ថិភាពសារធាតុរបស់វា, ក្នុងពេលដំណាលគ្នាមានអត្ថិភាពចរិតពិសេសរបស់វា។ ចរិតពិសេសសច្ចៈ, ករុណា, ខន្តិក្នុងចក្រវាល, មនុស្សសាមញ្ញទទួលដឹងមិនបានអត្ថិភាពរបស់គាត់, ដោយសារមនុស្សសាមញ្ញទាំងមូលសុទ្ធតែនៅលើផ្ទៃមួយជាន់ថ្នាក់នេះ។ ពេលលោកអ្នកចេញផុតពីជាន់ថ្នាក់នេះរបស់មនុស្សសាមញ្ញ, គឺអាចពិសោធចេញមកបាន។ ធ្វើដូចម្ដេចពិសោធចេញមកបាន? សារធាតុណាមួយក្នុងចក្រវាល, រួមបញ្ចូលសារធាតុទាំងអស់ដែលនៅពាសពេញក្នុងចក្រវាលទាំងមូលសុទ្ធតែជាកាយវិញ្ញាណ, សុទ្ធតែជាមានមនោគតិ, សុទ្ធតែជាទម្រង់អត្ថិភាពនៃធម៌ចក្រវាលនៅក្នុងជាន់ថ្នាក់ខុសគ្នា។ គាត់មិនអនុញ្ញាតឲ្យលោកអ្នកថ្កើងឡើងលើ, លោកអ្នកចង់លើកកម្ពស់, ជាក់ស្ដែងគឺលើកកម្ពស់ឡើងមិនបាន, គាត់គឺមិនអនុញ្ញាតឲ្យលោកអ្នកឡើងលើ។ ហេតុអ្វីមិនអនុញ្ញាតឲ្យលោកអ្នកឡើងលើ? ដោយសារចិត្តចរិតរបស់លោកអ្នកមិនទាន់លើកកម្ពស់ឡើងលើ។ ជាន់ថ្នាក់នីមួយៗសុទ្ធតែមានបរមាណីយខុសគ្នា, ចង់លើកកម្ពស់ជាន់ថ្នាក់, លោកអ្នកចាំបាច់បោះចោលមនោគតិមិនល្អរបស់លោកអ្នកនិងចាក់ចេញអ្វីកខ្វក់របស់លោកអ្នក, សមកាលកម្មជាមួយនឹងតម្រូវបរមាណីយរបស់ជាន់ថ្នាក់មួយនោះ, បែបនេះលោកអ្នកទើបអាចឡើងលើ

បាន។

ចិត្តចរិតរបស់លោកអ្នកលើកកម្ពស់ឡើង, រាងកាយលោកអ្នកនឹងកើតឡើងផ្លាស់ប្រែមួយធំ; ចិត្តចរិតរបស់លោកអ្នកលើកកម្ពស់ឡើង, សារធាតុលើរាងកាយលោកអ្នកធានានឹងលេចឡើងផ្លាស់ប្រែ។ ផ្លាស់ប្រែអ្វី? របស់មិនល្អទាំងនោះដែលលោកអ្នកស្វែងរកប្រកាន់, លោកអ្នកនឹងបោះចោល។ លើកឧទាហរណ៍និយាយ, ក្នុងដបមួយពោរពេញទៅដោយវត្ថុកខ្វក់, មូលគម្របរបស់វាដ៏តឹង, បោះទៅក្នុងទឹក, វានឹងលិចភ្លាមដល់បាត។ លោកអ្នកយកវត្ថុកខ្វក់ខាងក្នុងចាក់ចេញ, ចាក់ចេញកាន់តែច្រើន, វានឹងអណ្តែតឡើងកាន់តែខ្ពស់; ចាក់ចេញទាំងស្រុង, វានឹងអណ្តែតឡើងលើទាំងស្រុង។ ពួកយើងនៅក្នុងដំណើរការបួសហាត់, នោះគឺត្រូវកម្ចាត់ចោលអ្វីដែលមិនល្អគ្រប់ប្រភេទស្ថិតនៅលើរាងកាយមនុស្ស, ទើបអាចធ្វើឲ្យលោកអ្នកថ្កើងឡើងបាន, ចរិតពិសេសនៃចក្រវាលគឺផ្តើមប្រភេទផលប៉ះពាល់មួយបែបនេះ។ លោកអ្នកមិនបួសហាត់ចិត្តចរិតរបស់លោកអ្នក, កម្រិតសីលធម៌របស់លោកអ្នកមិនលើកកម្ពស់ឡើង, មនោគតិអាក្រក់, សារធាតុអាក្រក់មិនកម្ចាត់ចោល, គាត់នឹងមិនអនុញ្ញាតឲ្យលោកអ្នកថ្កើងឡើង, លោកអ្នកនិយាយវាធ្វើម្តេចមិនមែនជាចរិតតែមួយ? ពួកយើងនិយាយរឿងកំប្លែង, ប្រសិនមានមនុស្សនៅក្នុងមនុស្សសាមញ្ញស្នេហា៧តណ្ហា៦សុទ្ធតែមាន, ហើយអនុញ្ញាតឲ្យគាត់ហើរឡើងធ្វើព្រះពុទ្ធ, អ្នករាល់គ្នាគិតសាកមើលអាចឬ? គាត់ប្រហែលពេលមើលឃើញមហាពោធិសត្វអង្គនោះស្អាតយ៉ាងនោះ, គាត់បានកើតគំនិតទុច្ចរិតរួចហើយ។ ដោយសារចិត្តច្រណែនមិនទាន់ចោលនឹងកើតទំនាស់នឹងព្រះពុទ្ធ, អាចអនុញ្ញាតឲ្យរឿងរ៉ាវប្រភេទនេះស្ថិតនៅឬ? ដូច្នោះធ្វើដូចម្តេច? លោកអ្នកចាំបាច់យកមនោគតិមិនល្អគ្រប់ប្រភេទ

នៅក្នុងមនុស្សសាមញ្ញកម្ចាត់ចោលទាំងអស់, លោកអ្នកទើបអាចលើកខ្ពស់ឡើងបាន។

ក៏មានន័យថា, លោកអ្នកត្រូវតែយកចិត្តទុកដាក់លើចិត្តចរិតដើម្បីបួសហាត់, យោងតាមចរិតពិសេសសច្ចៈ, ករុណា, ខន្តីនៃចក្រវាលដើម្បីបួសហាត់, បោះចោលតណ្ហា, ចិត្តមិនល្អ, ការគិតធ្វើរឿងអាក្រក់ក្នុងមនុស្សសាមញ្ញ។ កម្រិតភពមនោគតិដរាបណាលើកកម្ពស់ឡើងបន្តិច, របស់អាក្រក់លើរាងកាយខ្លួនឯងបានកម្ចាត់ចោលមួយចំនួនរួចហើយ។ ក្នុងពេលដំណាលគ្នាលោកអ្នកនៅតែត្រូវរងទុក្ខបន្តិច, ទទួលរងទោសបន្តិច, ធ្វើឲ្យអំណាចកម្មនៃរាងកាយខ្លួនឯងរំលាយបាត់បន្តិច, ដូច្នោះលោកអ្នកគឺអាចច្មើងឡើងបានបន្តិច, ក៏មានន័យថា, កម្លាំងរឹតត្បិតរបស់ចរិតពិសេសនៃចក្រវាលចំពោះលោកអ្នកមិនធំយ៉ាងនោះទៀត។ បួសនៅខ្លួនឯង, គង់នៅលោកគ្រូ។ លោកគ្រូផ្តល់ឲ្យលោកអ្នកគង់មួយសម្រាប់បង្កើនគង់, គង់នេះផ្តើមផលប៉ះពាល់, គឺអាចយកសារធាតុគុណធម៌របស់លោកអ្នកនៅខាងក្រៅរាងកាយលោកអ្នកវិវត្តប្រែក្លាយជាគង់។ លោកអ្នកបន្តលើកកម្ពស់, បន្តបួសហាត់ឡើងលើ, សសរគង់របស់លោកអ្នកក៏កំពុងបន្តទម្លុះឡើងលើ។ ធ្វើជាមនុស្សបួសហាត់ម្នាក់, គឺត្រូវតែនៅក្នុងបរិយាកាសរបស់មនុស្សសាមញ្ញដើម្បីបួសហាត់ខ្លួនឯង, ហ្វឹកហាត់ខ្លួនឯង, បន្តិចម្តងៗយកចិត្តប្រកាន់, តណ្ហាគ្រប់ប្រភេទកម្ចាត់ចោល។ មនុស្សជាតិពួកយើងជាញឹកញាប់សន្មតថាជាប្រការល្អ, ប៉ុន្តែនៅលើជាន់ថ្នាក់ខ្ពស់សង្កេតមើលជាញឹកញាប់គឺជាអាក្រក់។ ដូច្នេះគេសន្មតថាល្អ, ផលប្រយោជន៍ឯកជននៅក្នុងមនុស្សសាមញ្ញទទួលបានកាន់តែច្រើន, រស់កាន់តែល្អ, នៅទីពួកអង្គមហាត្រាស់ដឹងមើលមក, ឯកជននេះគឺកាន់តែមិនល្អ។ មិនល្អនៅកន្លែងណា? គាត់ទទួលបាន

កាន់តែច្រើន, គាត់កាន់តែធ្វើបាបអ្នកដទៃ, ទទួលបានរបស់ដែលមិនគួរបាន, គាត់នឹងឲ្យតម្លៃកិត្តិនាមនិងផលប្រយោជន៍, ស្មើនឹងគាត់នឹងបាត់បង់គុណធម៌។ លោកអ្នកចង់បង្កើនគង់, លោកអ្នកមិនយកចិត្តទុកដាក់បួសហាត់ចិត្តចរិត, គង់របស់លោកអ្នកជាមូលដ្ឋានគឺបង្កើនឡើងមិនបាន។

ពិភពបួសហាត់ពួកយើងសម្ដែង, វិញ្ញាណដើមរបស់មនុស្សគឺជាអមតៈ។ អតីតកាលសម្ដែងអំពីវិញ្ញាណដើមរបស់មនុស្ស, គេអាចនឹងនិយាយថាជាអបិយជំនឿ។ អ្នករាល់គ្នាដឹងថារូបវិទ្យាស្រាវជ្រាវរាងកាយមនុស្សពួកយើង, មានម៉ូលេគុល, ប្រូតុង, អេឡិចត្រុង, ស្រាវជ្រាវសំដៅចុះរហូតដល់គ្រាប់ quark, neutrino។ល។ ដល់ជំហាននោះរួចហើយ, មីក្រូទស្សន៍ក៏មើលមិនឃើញទៀត។ ប៉ុន្តែនោះឃ្លាតពីមូលដ្ឋានដើមនៃជីវិត, មូលដ្ឋានដើមនៃសារធាតុនៅឆ្ងាយខ្លាំងណាស់។ អ្នករាល់គ្នាដឹងថាការបំបែកនុយក្លេអ៊ែ, ត្រូវការមានថាមពលដ៏ធំបុកទង្គិចនិងកំដៅដ៏ធំទើបអាចធ្វើឱ្យវាកើតឡើងការលាយបញ្ចូលគ្នា, ទើបអាចធ្វើឱ្យបំបែកនុយក្លេអ៊ែ។ ពេលដែលមនុស្សស្លាប់, គ្រាប់នុយក្លេអ៊ែក្នុងរាងកាយមនុស្សធ្វើម្ដេចអាចស្រេចតាមចិត្តស្លាប់បាត់បានទៅ? ដូច្នេះពួកយើងរកឃើញថាមនុស្សស្លាប់រួចហើយ, ហួសពេកគ្រាន់តែជាអវកាសជាន់នេះរបស់ពួកយើង, សមាសភាគម៉ូលេគុលធំបំផុតនៃជាន់នេះត្រូវរបូតចេញ; នៅក្នុងអវកាសផ្សេងរាងកាយនោះគឺមិនទាន់បំផ្លាញបាត់។ អ្នករាល់គ្នាគិតសាកមើល, នៅក្រោមមីក្រូទស្សន៍មើលរាងកាយមនុស្សគឺជាបែបណា? រាងកាយទាំងមូលរបស់មនុស្សគឺធ្វើចលនា, លោកអ្នកអង្គុយនៅទីនោះមិនកម្រើក, ប៉ុន្តែរាងកាយទាំងមូលគឺធ្វើចលនា, ម៉ូលេគុលកោសិកាកំពុងធ្វើចលនា, រាងកាយទាំងមូលគឺរលុង, ដូចកកើតឡើង

ដោយគ្រាប់ខ្សាច់។ នៅក្រោមមីក្រូទស្សន៍មើលរាងកាយមនុស្សគឺជាបែប នេះ, និងកែវភ្នែកពួកយើងមើលរាងកាយមនុស្សបានកើតឡើងការផ្លាស់ ប្រែទាំងស្រុង។ នេះគឺដោយសារគូនេត្រានេះរបស់មនុស្សអាចបង្កជា សេចក្តីមិនពិតដល់លោកអ្នក, មិនអនុញ្ញាតឲ្យលោកអ្នកមើលឃើញ ប្រការទាំងនេះ។ ភ្នែកទិព្វបើករួចហើយ, អាចពង្រីកធំវត្ថុដើម្បីមើល, ដើម មកវាគឺជាសភាវគតិរបស់មនុស្ស, បច្ចុប្បន្នហៅថាសីលគង់ពិសេស, លោកអ្នកចង់លេចឡើងសីលគង់ពិសេស, គឺត្រូវតែត្រឡប់ដើមមក សច្ចៈ, បួសត្រឡប់មកវិញ។

ពួកយើងចូរនិយាយអំពីគុណធម៌នេះ។ ទំនាក់ទំនងរួមគ្នាពិស្តារ រវាងពួកវាជាអ្វី? ពួកយើងវះកាត់វាចេញមកដើម្បីសម្តែង។ មនុស្សពួក យើងនៅក្នុងអវកាសដ៏ច្រើនសុទ្ធតែមានរាងកាយមួយស្ថិតនៅ។ ពួក យើងបច្ចុប្បន្នមើលសមាសភាគរាងកាយរបស់មនុស្ស, ធំបំផុតគឺជា កោសិកា, នេះគឺរាងកាយសាច់របស់មនុស្សពួកយើង។ ឧបមាពេល លោកអ្នកឈានចូលក្នុងអវកាសរវាងកោសិកានិងម៉ូលេគុល, អវកាស រវាងម៉ូលេគុលនិងម៉ូលេគុល, គឺលោកអ្នកនឹងពិសោធបានការឈាន ចូលក្នុងអវកាសផ្សេង។ ទម្រង់អត្ថិភាពរបស់រាងកាយនោះគឺជាបែប ណា? ប្រាកដណាស់លោកអ្នកមិនអាចប្រើទស្សនាទានកំពុងមាននៃ អវកាសនេះដើម្បីពន្យល់បានទេ, រាងកាយលោកអ្នកត្រូវតែសមកាលកម្ម តាមតម្រូវទម្រង់អត្ថិភាពរបស់អវកាសនោះ។ រាងកាយនៅអវកាសផ្សេង ដើមមកជាក់ស្តែងគឺអាចធំអាចតូច, ពេលនោះលោកអ្នកនឹងរកឃើញថា នោះក៏ជាអវកាសមួយធំទូលាយមិនអាចប្រៀបផ្ទឹមបាន។ នេះគ្រាន់តែ ជាសំដៅលើទម្រង់អត្ថិភាពសាមញ្ញមួយរបស់អវកាសផ្សេង, ក្នុងពេល តែមួយកន្លែងតែមួយកំពុងស្ថិតនៅអវកាសផ្សេង។ មនុស្សនៅអវកាស

ដទៃជាច្រើនសុទ្ធតែមានរាងកាយពិសេសជាក់លាក់មួយ, ហើយនៅក្នុងអវកាសពិសេសជាក់លាក់មួយ, ជុំវិញរាងកាយមនុស្សស្ថិតនៅវាលមួយ។ វាលអ្វី? វាលនេះជាក់ស្តែងគឺជាគុណធម៌ដែលពួកយើងធ្លាប់បាននិយាយ។ គុណធម៌ជាប្រភេទសារធាតុពណ៌សមួយ, វាមិនមែនដូចជារបស់ដែលពួកយើងអតីតកាលសន្មតថាស្ថិតក្នុងស្មារតីមនុស្ស, របស់ដែលនៅក្នុងទម្រង់សតិរបស់មនុស្ស, វាទាំងស្រុងគឺជាអត្ថិភាពសារធាតុ, ដូច្នេះមនុស្សចាស់អតីតកាលសម្តែងថាសន្សំគុណធម៌, ខាតគុណធម៌, ពាក្យនោះនិយាយត្រូវណាស់។ គុណធម៌នេះនៅជុំវិញរាងកាយមនុស្ស, វាបង្កើតជាវាលមួយ។ អតីតកាលតាវង្សសម្តែងថាលោកគ្រូរកកូនសិស្ស, មិនមែនកូនសិស្សរកលោកគ្រូ។ មានន័យថាយ៉ាងម៉េច? គាត់គឺត្រូវសង្កេតមើលសមាសភាគគុណធម៌នាំតាមរាងកាយកូនសិស្សនេះធំឬអត់, ធំគាត់គឺងាយស្រួលបួស, មិនធំគាត់នឹងពិបាកបួស, គាត់គឺដ៏ពិបាកបង្កើនគង់ឡើងខ្ពស់។

អត្ថិភាពក្នុងពេលដំណាលគ្នានៅមានប្រភេទសារធាតុពណ៌ខ្មៅមួយទៀត, យើងខ្ញុំទីនេះហៅថាអំណាចកម្ម, នៅក្នុងពុទ្ធសាសនាហៅវាថាអកុសលកម្ម។ សារធាតុពណ៌សនិងសារធាតុពណ៌ខ្មៅ, ប្រភេទសារធាតុទាំងពីរអត្ថិភាពក្នុងពេលដំណាលគ្នា។ រវាងប្រភេទសារធាតុទាំងពីរនេះជាទំនាក់ទំនងដូចម្តេច? សារធាតុគុណធម៌គឺពួកយើងបានរងទុក្ខរួចហើយ, ទទួលរងវាយទាត់រួចហើយ, ធ្វើរឿងល្អរួចហើយទទួលបាន; ហើយសារធាតុពណ៌ខ្មៅនោះគឺមនុស្សបានធ្វើរឿងអាក្រក់, បានធ្វើរឿងមិនល្អ, សម្លុតមនុស្ស, ទទួលបានប្រភេទសារធាតុពណ៌ខ្មៅនេះ។ បច្ចុប្បន្នមិនគ្រាន់តែជាផលចំណេញមកមុន, មនុស្សខ្លះគ្មានអំពើអាក្រក់អ្វីមិនធ្វើ, ដើម្បីលុយ, រឿងអាក្រក់អ្វីក៏ធ្វើ៖ សម្លាប់មនុស្សធ្វើបាបជីវិត,

ប្រើលុយទិញជីវិត, ស្រឡាញ់ភេទដូចគ្នា, ជក់គ្រឿងញៀនជាដើម, រឿងរ៉ាវអ្វីក៏មាន។ ពេលដែលមនុស្សកំពុងធ្វើរឿងរ៉ាវមិនល្អ, គឺនឹងខូតខាតគុណធម៌។ ខូតខាតដូចម្ដេច? នៅពេលឯកជននេះជេរអ្នកដទៃ, គាត់មានអារម្មណ៍កាន់កាប់បានភាពងាយស្រួល, ធូរស្រាល។ នៅក្នុងចក្រវាលនេះមានគោលសីលធម៌, ហៅថាមិនបាត់គឺមិនបាន, បានគឺត្រូវតែបាត់, លោកអ្នកមិនបាត់, នឹងបង្ខំឲ្យលោកអ្នកបាត់។ នរណាផ្ដើមផលប៉ះពាល់នេះ? ជាក់ស្ដែងគឺជាចរិតពិសេសរបស់ចក្រវាលផ្ដើមផលប៉ះពាល់នេះ, ដូច្នេះលោកអ្នកគ្រាន់តែចង់បានមិនអាចទេ។ ធ្វើដូចម្ដេច? នៅពេលលោកអ្នកជេរអ្នកដទៃ, សម្លុតអ្នកដទៃ, គាត់គឺនឹងយកគុណធម៌បោះទៅឲ្យគេ, ហើយភាគីម្ខាងទៀតស្ថិតក្នុងភាគីរងអយុត្តិធម៌, ភាគីបាត់បង់, ភាគីទទួលរងទុក្ខឈឺចាប់, ដូច្នេះគឺផ្ដល់សំណងឱ្យគាត់។ គាត់ខាងនេះជេរគាត់, ស្របតាមគាត់ជេរកាលណា, គឺពីខាងក្នុងវិសាលភាពវាលអវកាសខ្លួនឯងហើរទៅគុណធម៌មួយដុំ, ធ្លាក់នៅលើខ្លួនរបស់គេ។ គាត់ជេរកាន់តែធ្ងន់, គុណធម៌ដែលផ្ដល់ឱ្យគេកាន់តែច្រើន។ វាយមនុស្ស, សម្លុតអ្នកដទៃក៏ដូចគ្នាផងដែរ។ គាត់{នេះ}វាយគាត់{នោះ}មួយដៃ, ទាត់គាត់មួយជើង, គឺស្របតាមឯកជននេះវាយធ្ងន់ប៉ុណ្ណា, គុណធម៌គឺធ្លាក់ឆ្លងទៅច្រើនប៉ុណ្ណោះ។ មនុស្សសាមញ្ញមើលមិនឃើញជាន់គោលសីលធម៌នេះ, គាត់សន្មតថាទទួលរងសម្លុត, គាត់ទ្រាំមិនបាន៖ អ្នកវាយខ្ញុំ, ខ្ញុំវិលមកវាយអ្នកវិញ។ [ផាំង] វិលមកឱ្យគាត់មួយដៃ, យកគុណធម៌នេះរុញទៅវិញ, អ្នកទាំងពីរសុទ្ធតែមិនបាត់មិនបាន។ អាចគាត់គិតថា៖ អ្នកវាយខ្ញុំមួយ, ខ្ញុំវាយអ្នកពីរ, បើមិនដូច្នោះទេគឺមិនអាចរក្សាទុកមុខនេះបាន។ គាត់ក៏វាយថែមមួយដៃទៀត, ពីរាងកាយខ្លួនឯងម្ដងទៀតហើរទៅគុណធម៌មួយដុំឱ្យភាគី។

ហេតុអ្វីមើលគុណធម៌សំខាន់យ៉ាងនេះ? ការបំប្លែងរបស់គុណធម៌នេះគឺជាទំនាក់ទំនងដូចម្ដេច? នៅក្នុងសាសនាសម្ដែងថា៖ មានគុណធម៌នេះហើយ, ជាតិនេះមិនបានជាតិក្រោយបាន។ គាត់បានអ្វី? គុណធម៌គាត់ធំ, អាចនឹងធ្វើមហាមន្ត្រី, មានមហាសម្បត្តិ, ចង់អីមាននោះ, ជាក់ស្ដែងគឺប្រើគុណធម៌នេះដើម្បីផ្ដោះប្ដូរ។ ក្នុងសាសនានៅតែសម្ដែង៖ ឯកជននេះប្រសិនគ្មានគុណធម៌, គឺរូប-វិញ្ញាណកម្ទេចទាំងស្រុង។ វិញ្ញាណដើមរបស់គាត់គឺកម្ទេចចោល, បន្ទាប់ពីគាត់អាយុ១០០សុទ្ធតែស្លាប់ទាំងអស់, អ្វីក៏គ្មានទៀត។ ហើយពិភពបួសហាត់យើងខ្ញុំសម្ដែងគុណធម៌អាចដោយផ្ទាល់វិវត្តក្លាយជាគង់។

យើងខ្ញុំគឺសម្ដែងអំពីគុណធម៌ធ្វើដូចម្ដេចវិវត្តក្លាយជាគង់។ នៅពិភពបួសហាត់មានប្រយោគមួយយ៉ាងនេះ, ហៅថា ប្រួសនៅខ្លួនឯង, គង់នៅលោកគ្រូ។ តែមនុស្សខ្លះសម្ដែងអំពីរៀបទីញបង្កើតឡ, ជ្រើសឱសថស្លតាន, សកម្មភាពគំនិត, គាត់មានអារម្មណ៍ថាសំខាន់ណាស់។ ខ្ញុំប្រាប់លោកអ្នក, បន្តិចក៏មិនសំខាន់, លោកអ្នកគិតច្រើនជាក់ស្ដែងគឺជាចិត្តប្រកាន់។ លោកអ្នកគិតធ្ងន់, លោកអ្នកមិនមែនប្រកាន់ស្វែងរកហើយឬ? បួសនៅខ្លួនឯង, គង់នៅលោកគ្រូ, លោកអ្នកមានបំណងនេះគឺបានហើយ។ ហើយពិតប្រាកដធ្វើរឿងរ៉ាវនេះ, គឺលោកគ្រូធ្វើឱ្យ, លោកអ្នកជាមូលដ្ឋានគឺធ្វើមិនបាន។ រាងកាយមនុស្សសាមញ្ញរបស់លោកអ្នក, តើអាចវិវត្តសារធាតុថាមពលខ្ពស់នេះផ្សំឡើងជាកាយជីវិតកម្រិតខ្ពស់នោះបានទេ? ជាមូលដ្ឋានគឺមិនអាច។ និយាយចេញសុទ្ធតែជារឿងកំប្លែង។ ដំណើរការវិវត្តន៍របស់រាងកាយមនុស្សនៅអវកាសផ្សេងគឺដ៏អាថ៌កំបាំងអស្ចារ្យ, ដ៏ស្មុគស្មាញ, លោកអ្នកជាមូលដ្ឋានគឺធ្វើមិនបានរឿងរ៉ាវទាំងនេះ។

លោកគ្រូនឹងផ្តល់ឲ្យលោកអ្នកប្រការអ្វី? នឹងផ្តល់ឲ្យលោកអ្នកគង់មួយសម្រាប់បង្កើនគង់។ ដោយសារគុណធម៌នៅខាងក្រៅរាងកាយមនុស្ស, គង់ពិតប្រាកដរបស់មនុស្សជាក់ស្តែងគឺបានបង្កើតចេញដោយគុណធម៌។ ជាន់របស់ឯកជនខ្ពស់ឬទាប, អំណាចគង់ធំប៉ុណ្ណា, ទាំងស្រុងគឺគុណធម៌បង្កើតចេញ។ វាវិវត្តគុណធម៌របស់លោកអ្នកក្លាយជាគង់, បង្កើនសំដៅឡើងលើតាមរាងគូទខ្យង។ គង់ពិតប្រាកដកំណត់ជាន់ថ្នាក់ខ្ពស់ឬទាបរបស់មនុស្សគឺបង្កើននៅខាងក្រៅរាងកាយ, ចុងក្រោយបន្ទាប់ពីបង្កើនដល់កំពូលក្បាលតាមរាងគូទខ្យងបង្កើតជាសសរគង់មួយ។ គង់របស់ឯកជននេះខ្ពស់ប៉ុណ្ណា, មើលមួយភ្លែតគឺមើលឃើញសសរគង់របស់គាត់ខ្ពស់ប៉ុណ្ណា, នេះជាក់ស្តែងគឺជាន់ថ្នាក់របស់គាត់, ផលញាណដែលសម្តែងក្នុងពុទ្ធសាសនា។ មនុស្សខ្លះពេលដែលអង្គុយសមាធិវិញ្ញាណដើមអាចឃ្លាតពីកាយ, ភ្លាមៗនោះឡើងខ្ពស់ប៉ុណ្ណា, ឆ្ពោះឡើងខ្ពស់ទៀត, ឡើងទៅមិនបាន, មិនហ៊ានឡើង។ គាត់គឺកំពុងអង្គុយលើសសរគង់របស់ខ្លួនឯងដើម្បីឡើងទៅ, គាត់គ្រាន់តែអាចឡើងខ្ពស់បានយ៉ាងនោះ។ ដោយសារសសរគង់របស់គាត់គឺខ្ពស់យ៉ាងនោះ, ខ្ពស់ទៀតគាត់ក៏ឡើងទៅមិនបាន, នេះជាបញ្ហាផលញាណដែលសម្តែងក្នុងពុទ្ធសាសនា។

វាស់វែងចិត្តចរិតខ្ពស់ប៉ុណ្ណា, នៅមានបន្ទាត់មួយទៀត។ បន្ទាត់និងសសរគង់មិនស្ថិតនៅក្នុងអវកាសតែមួយ, តែវាផ្ទុយមកវិញគឺស្ថិតនៅក្នុងពេលដំណាលគ្នា។ ចិត្តចរិតរបស់លោកអ្នកបួសឡើងលើរួចហើយ, ឧបមាថានៅក្នុងមនុស្សសាមញ្ញ, អ្នកដទៃជេរលោកអ្នកមួយប្រយោគ, លោកអ្នកមិនមាត់, ក្នុងចិត្តលោកអ្នកដ៏ស្ងប់ស្ងៀម; វាយលោកអ្នកមួយដៃ, លោកអ្នកក៏មិនមាត់, គ្រាន់តែសើច, រំលងចោល, ចិត្តចរិតម្នាក់នេះគឺ

បានខ្ពស់ណាស់រួចហើយ។ ដូច្នោះលោកអ្នកជាមនុស្សហាត់គង់, ដែលលោកអ្នកគួរបានជាអ្វី? លោកអ្នកមិនមែនបានគង់ឬ? ចិត្តចរិតរបស់លោកអ្នកលើកខ្ពស់ឡើងរួចហើយ, គង់របស់លោកអ្នកគឺបង្កើនឡើងតាម។ ចិត្តចរិតខ្ពស់ប៉ុណ្ណាគង់ខ្ពស់ប៉ុណ្ណោះ, នេះជាសច្ចធម៌ដាច់ខាត។ អតីតកាលមានមនុស្សនៅឧទ្យានហាត់គង់ក៏ដោយ, នៅក្នុងផ្ទះហាត់គង់ក៏ដោយ, ហាត់ដោយដ៏យកចិត្តទុកដាក់, ដ៏ស្មោះត្រង់, ហាត់បានក៏ដ៏ល្អផងដែរ។ ចេញពីទ្វារកាលណាគឺមិនមែនគាត់ទៀត, ចង់អីធ្វើនោះ, នៅក្នុងមនុស្សសាមញ្ញដើម្បីកិត្តិនាម, ផលប្រយោជន៍ទៅប្រជែងទៅប្រយុទ្ធជាមួយគេ, គង់របស់គាត់អាចបង្កើនបានឬ? ជាមូលដ្ឋានគឺបង្កើនមិនបាន, ជំងឺរបស់គាត់ក៏មិនជាសះស្បើយ, ក៏ជាមូលហេតុនេះ។ ហេតុអ្វីមានមនុស្សហាត់គង់រយៈពេលយូរគឺជំងឺមិនជាសះស្បើយ? ឈីគង់គឺជាបួសហាត់, ជាប្រការវិសាមញ្ញ, មិនមែនកីឡាក្នុងមនុស្សសាមញ្ញ, ចាំបាច់គោរពចិត្តចរិតទើបអាចជាជំងឺឬបង្កើនគង់បាន។

មនុស្សមួយចំនួនសន្មតថារៀបទីញបង្កើតឡ, ជ្រើសឱសថស្លតាន, តាននេះជាក់ស្តែងគឺជាគង់, មិនមែន។ តាននេះវាគ្រាន់តែស្តុកទុកថាមពលមួយផ្នែក, វាមិនមែនទាំងអស់ថាមពល។ តានជាអ្វី? អ្នករាល់គ្នាដឹងថា, ពួកយើងនៅមានរបស់មួយផ្នែកផ្សេងទៀតដើម្បីបួសជីវិត, រាងកាយក៏ត្រូវការបញ្ចេញសីលគង់, នៅមានប្រការនៃសិល្ប៍សាស្ត្រដ៏ច្រើនទៀត។ ប្រការទាំងនេះភាគច្រើនគឺត្រូវបានចាក់សោ, មិនទុកឲ្យលោកអ្នកយកចេញប្រើ។ មានសីលគង់ជាច្រើន, សីលគង់ជាងម៉ឺនប្រភេទ, បង្កើតចេញមួយណាចាក់សោមួយនោះ។ ហេតុអ្វីមិនឲ្យបញ្ចេញ? គោលបំណងគឺមិនទុកឲ្យលោកអ្នកប្រើប្រាស់វាដើម្បីធ្វើរឿងរ៉ាវតាមអំពើចិត្តនៅក្នុងសង្គមមនុស្សសាមញ្ញ, មិនអាចតាមអំពើចិត្តជ្រៀតជ្រែកសង្គមមនុ

ស្សសាមញ្ញ, ក៏មិនអាចតាមអំពើចិត្តនៅក្នុងសង្គមមនុស្សសាមញ្ញលាត ត្រដាងអានុភាពរបស់លោកអ្នក, ដោយសារនេះនឹងបំផ្លាញស្ថានភាព សង្គមមនុស្សសាមញ្ញ។ មានមនុស្សជាច្រើនគឺបួសនៅក្នុងភ្ញាក់ដឹង, លោកអ្នកសុទ្ធតែលាតត្រដាងចេញមកឲ្យគាត់, គេមើលឃើញគឺជាការ ពិត, សុទ្ធតែមកបួស, មនុស្សអំពើអាក្រក់អីក៏មិនប្រណីក៏មកបួស, នោះ គឺមិនបាន។ មិនអាចទុកឲ្យលោកអ្នកទៅបង្ហាញបែបនេះ; លោកអ្នកក៏ ងាយស្រួលធ្វើរឿងអាក្រក់, ដោយសារលោកអ្នកមើលមិនឃើញទំនាក់ ទំនងកម្មផលរបស់វា, លោកអ្នកមើលមិនឃើញធាតុដើមរបស់វា, លោក អ្នកសន្មតថាជារឿងល្អ, អាចធ្វើទៅជារឿងអាក្រក់, ដូច្នេះមិនទុកឲ្យ លោកអ្នកប្រើ។ ដោយសារពេលណាធ្វើរឿងអាក្រក់, គឺត្រូវធ្លាក់ជាន់ថ្នាក់, បួសដូចមិនបួស, ដូច្នេះសីលគង់ដ៏ច្រើនគឺបានចាក់សោ។ ធ្វើដូចម្តេច? ដល់ថ្ងៃមួយនោះបើកគង់ត្រាស់ដឹង, តាននេះជាក់ស្តែងគឺជាគ្រាប់ផ្ទុះ មួយ, វានឹងយកសីលគង់ទាំងអស់, សោទាំងអស់និងរាប់រយឈាវរបស់ រាងកាយផ្ទុះបើកទាំងអស់, [ផាំង] រញ្ជួយ, រញ្ជួយបើកទាំងអស់, គឺ សម្រាប់គោលបំណងនេះ។ ព្រះសង្ឃបន្ទាប់ពីអាយុ១០០ពេលបូជាគឺ មានសារីរិកធាតុ, មានមនុស្សនិយាយថានោះគឺជាឆ្អឹង, ធ្មេញ។ មនុស្ស សាមញ្ញហេតុម្តេចគ្មាន? ជាក់ស្តែងគឺជាតាននោះផ្ទុះបើក, ថាមពល របស់វាដោះលែងចេញក្រៅ, ខ្លួនវានេះរួមបញ្ចូលសារធាតុចំនួនធំនៃ អវកាសផ្សេង។ យ៉ាងណាមិញវាក៏ជារបស់នៃអត្ថិភាពសារធាតុ, តែវាក៏ គ្មានប្រយោជន៍អ្វី។ មនុស្សបច្ចុប្បន្នមើលវាក្លាយជារបស់ដ៏មានតម្លៃ, វា មានថាមពល, ភ្លឺរលោង, រឹងណាស់, ជាក់ស្តែងគឺជារបស់នេះ។ មិន បង្កើនគង់នៅមានមូលហេតុមួយទៀត, ជាក់ស្តែងគឺមិនដឹងធម៌ក្នុងជាន់ ថ្នាក់ខ្ពស់, មិនអាចបួសហាត់ឡើងទៅលើ។ មានន័យថាយ៉ាងម៉េច? គឺ

ដូចខ្ញុំទើបតែសម្តែង, មានមនុស្សមួយចំនួនបានហាត់គង់ហ្វាជាច្រើន, ខ្ញុំប្រាប់លោកអ្នករៀនច្រើនដល់ណាក៏គ្មានប្រយោជន៍, ក៏គ្រាន់តែជាសិស្សបឋមសិក្សា, ជាសិស្សបឋមសិក្សានៅក្នុងបួសហាត់, សុទ្ធតែជាគោលសីលធម៌ក្នុងជាន់ថ្នាក់ទាប។ លោកអ្នកកាន់គោលសីលធម៌ក្នុងជាន់ថ្នាក់ទាបនេះដើម្បីបួសហាត់ឆ្ពោះឡើងជាន់ថ្នាក់ខ្ពស់, គឺគ្មានផលប៉ះពាល់ដឹកនាំ។ នៅក្នុងមហាវិទ្យាល័យអានសៀវភៅបឋមសិក្សា, លោកអ្នកនៅតែជាសិស្សបឋមសិក្សា, រៀនច្រើនដល់ណាក៏គ្មានប្រយោជន៍, ផ្ទុយមកវិញកាន់តែខូចការ។ ក្នុងជាន់ថ្នាក់ខុសគ្នាមានធម៌ក្នុងជាន់ថ្នាក់ខុសគ្នា។ ធម៌នៅក្នុងជាន់ថ្នាក់ខុសគ្នាមានផលប៉ះពាល់ដឹកនាំខុសគ្នា, ដូច្នេះលោកអ្នកកាន់គោលសីលធម៌ក្នុងជាន់ថ្នាក់ទាបដឹកនាំមិនបានលោកអ្នកបួសហាត់ឆ្ពោះឡើងជាន់ខ្ពស់។ អ្វីដែលយើងខ្ញុំនឹងបរិយាយយ៉ាងល្អិតល្អន់នៅពេលក្រោយសុទ្ធតែជាគោលសីលធម៌បួសហាត់នៅក្នុងជាន់ថ្នាក់ខ្ពស់, ខ្ញុំគឺរួបរួមគ្នានូវប្រការក្នុងជាន់ថ្នាក់ខុសគ្នាចូលក្នុងមេសម្តែង, ដូច្នេះនៅក្នុងការបួសហាត់របស់លោកអ្នកពីពេលនេះតទៅរហូតគឺមានផលប៉ះពាល់ដឹកនាំ។ ខ្ញុំមានសៀវភៅប៉ុន្មានក្បាល, នៅមានខ្សែអាត់, វីដេអូ, ពីក្នុងនោះលោកអ្នកនឹងរកឃើញថា, បន្ទាប់ពីលោកអ្នកអានហើយ, ស្តាប់ហើយមួយដង, ឃ្លាតមួយដំណាក់កាលអានឡើងវិញស្តាប់ឡើងវិញ, ធានាចំពោះលោកអ្នកនៅតែមានផលប៉ះពាល់ដឹកនាំ។ លោកអ្នកក៏កំពុងបន្តលើកកម្ពស់ខ្លួនឯង, ចំពោះលោកអ្នកបន្តមានផលប៉ះពាល់ដឹកនាំ, នេះជាក់ស្តែងគឺជាធម៌។ ខាងលើជាមូលហេតុពីរដែលហាត់គង់មិនបង្កើនគង់៖ មិនដឹងធម៌ក្នុងជាន់ថ្នាក់ខ្ពស់គឺគ្មានធម៌ដើម្បីបួស; មិនសំដៅចូលក្នុងដើម្បីបួស, មិនបួសហាត់ចិត្តចរិតមិនបង្កើនគង់។ ជាមូលហេតុទាំងពីរនេះ។

# លក្ខណៈរបស់ហ្វាលូនតាហ្វា

ហ្វាលូនតាហ្វាយើងខ្ញុំជាធម្មក្ខន្ធមួយក្នុង៨ម៉ឺន៤ពាន់ធម្មក្ខន្ធនៃពុទ្ធវង្ស, នៅសម័យកាលប្រវត្តិសាស្ត្រអរិយធម៌មនុស្សជាតិពួកយើងលើកនេះមិនធ្លាប់បានបង្រៀនចេញជាសាធារណៈ, ប៉ុន្តែ, នៅសម័យកាលបុរេប្រវត្តិមួយធ្លាប់បានប្រោសមនុស្សយ៉ាងទូលំទូលាយ។ ខ្ញុំនៅសម័យកាលចុងក្រោយផុតកប្បម្ដងទៀតយកគាត់បង្រៀនធំទូលាយចេញមក, ដូច្នេះគាត់គឺដ៏មានតម្លៃក្រៃលែង។ ខ្ញុំបានសម្ដែងទម្រង់គុណធម៌ដោយផ្ទាល់បំប្លែងក្លាយជាគង់។ គង់ភាពពិតមិនមែនហាត់ចេញមក, វាគឺបួសចេញមក។ មនុស្សដ៏ច្រើនស្វែងរកបង្កើនគង់, គ្រាន់តែយកចិត្តទុកដាក់ហាត់ដូចម្ដេច, គ្មានយកចិត្តទុកដាក់បួសដូចម្ដេច, ភាពពិតគង់ទាំងស្រុងគឺពឹងលើបួសចិត្តចរិតបួសចេញមក។ ដូច្នោះហេតុអ្វីយើងខ្ញុំទីនេះក៏បង្រៀនលោកអ្នកហាត់គង់? ដំបូងនិយាយបន្តិចព្រះសង្ឃហេតុអ្វីមិនហាត់គង់? គាត់ចម្បងគឺអង្គុយសមាធិ, សូត្រធម៌, បួសចិត្តចរិត, គាត់គឺបង្កើនគង់, គាត់គឺបង្កើនគង់ជាន់ថ្នាក់ខ្ពស់ឬទាបរបស់គាត់។ ដោយសារសក្យមុនីសម្ដែងបោះចោលទាំងអស់ក្នុងលោកីយ៍, រួមបញ្ចូលរាងកាយដើម, ដូច្នេះមិនចាំបាច់ចលនារូបកាយ។ តាវវង្សមិនសម្ដែងប្រោសសត្វលោកទាំងឡាយ, មនុស្សគាត់ប្រឈមមុខ, មិនមែនស្ថានភាពផ្លូវចិត្តគ្រប់ប្រភេទ, ជាន់ថ្នាក់គ្រប់ប្រភេទ, មនុស្សអ្វីក៏មាន, មនុស្សខ្លះអាត្មានិយមធំ, មនុស្សខ្លះអាត្មានិយមតូច។ គាត់គឺជ្រើសរើសកូនសិស្ស, រកកូនសិស្ស៣នាក់, មានតែម្នាក់ក្នុងចំណោមត្រូវបានស្នងបង្រៀនពិត, កំណត់ថាកូនសិស្សម្នាក់នេះគុណធម៌គឺខ្ពស់, គឺល្អ, នឹងមិនលេចឡើងបញ្ហា។ ដូច្នេះគាត់សង្កត់ធ្ងន់បង្រៀនប្រការនៃបច្ចេកទេសរបស់គាត់, ដើម្បីបួសជីវិត។ ហាត់របស់នៃទេពអំណាចសិល្ប៍សាស្ត្រ,

នេះត្រូវការមានចលនាមួយចំនួន។

ហ្វាលូនតាហ្វាក៏ជាគង់ហ្វាចរិតជីវិតបួសទាំងទ្វេ, គឺត្រូវការមានចលនាដើម្បីហាត់។ ចលនាទិដ្ឋភាពមួយគឺប្រើដើម្បីពង្រឹងសីលគង់, អ្វីហៅថាពង្រឹង? ប្រើអំណាចគង់ខ្លាំងធំរបស់លោកអ្នកដើម្បីពង្រឹងសីលគង់របស់លោកអ្នក, នឹងមួយថ្ងៃកាន់តែខ្លាំង; ទិដ្ឋភាពមួយទៀតនៅក្នុងរាងកាយលោកអ្នកនៅត្រូវការវិវត្តចេញកាយជីវិតជាច្រើន។ ដល់បួសហាត់លើជាន់ថ្នាក់ខ្ពស់, តាវវង្សសម្តែងអំពីទារកអមតៈចាប់កំណើត, ពុទ្ធវង្សសម្តែងអំពីរាងកាយជីនកាងមិនអាចបំផ្លាញ, នៅត្រូវការវិវត្តចេញរបស់សិល្ប៍សាស្ត្រដ៏ច្រើន។ អ្វីទាំងនេះសុទ្ធតែត្រូវការតាមរយៈបច្ចេកទេសដើម្បីអភិវឌ្ឍ, ចលនាគឺដើម្បីហាត់អ្វីទាំងនេះ។ សំណុំគង់ហ្វាចរិតជីវិតបួសទាំងទ្វេពេញលេញមួយ, នោះគឺត្រូវបួសផង, ត្រូវហាត់ផង។ ខ្ញុំគិតថាអ្នករាល់គ្នាបានយល់ច្បាស់ហើយគង់នេះគឺមកដូចម្តេច, គង់ដែលពិតប្រាកដកំណត់ជាន់ថ្នាក់ខ្ពស់ឬទាបរបស់លោកអ្នក, ជាមូលដ្ឋានគឺមិនមែនហាត់ចេញមក, គឺបួសចេញមក។ គឺលោកអ្នកនៅក្នុងដំណើរការបួស, នៅក្នុងមនុស្សសាមញ្ញបានលើកកម្ពស់ចិត្តចរិតរបស់លោកអ្នក, បានសមកាលកម្មចរិតពិសេសនៃចក្រវាល, ចរិតពិសេសនៃចក្រវាលនឹងមិនរឹតត្បិតលោកអ្នកទៀត, លោកអ្នកគឺអាចថ្កើងឡើងលើ។ គុណធម៌នេះគឺចាប់ផ្តើមវិវត្តក្លាយជាគង់, ស្របតាមការលើកកម្ពស់បរមាណើយចិត្តចរិតរបស់លោកអ្នក, វាគឺថ្កើងឡើងតាម, វាជាក់ស្តែងគឺជាទំនាក់ទំនងបែបនេះ។

សំណុំគង់ហ្វានេះរបស់យើងខ្ញុំ, គឺពិតប្រាកដស្ថិតក្នុងគង់ហ្វាចរិតជីវិតបួសទាំងទ្វេ, គង់ដែលពួកយើងហាត់ស្តុកទុកនៅក្នុងកោសិកានីមួយៗនៃរាងកាយ, រហូតដល់សមាសភាគភាគល្អិតមូលដ្ឋានដើមនៃ

សារធាតុស្ថិតនៅក្នុងស្ថានភាពអតិសុខុមបំផុត, សុទ្ធតែកំពុងស្តុកទុកគង់នៃសារធាតុថាមពលខ្ពស់នោះ។ ស្របតាមអំណាចគង់លោកអ្នកមួយថ្ងៃកាន់តែខ្ពស់, ដង់ស៊ីតេរបស់វាមួយថ្ងៃកាន់តែធំ, អានុភាពរបស់វាក៏មួយថ្ងៃកាន់តែធំ។ សារធាតុថាមពលខ្ពស់នេះគឺមាននាំតាមប្រាជ្ញា, ដោយសារវាស្តុកទុកនៅក្នុងកោសិកានីមួយៗនៃរាងកាយមនុស្ស, រហូតដល់មូលដ្ឋានដើមនៃជីវិត, យូរៗទៅវាគឺបង្កើតជាសណ្ឋានមួយដូចគ្នានឹងកោសិកានៃរាងកាយលោកអ្នក, ក៏ជាដូចគ្នានឹងលំដាប់រៀបចំនៃម៉ូលេគុល, គឺដូចគ្នានឹងសណ្ឋាននៃស្នូលអាតូមទាំងអស់។ ប៉ុន្តែផ្ទុយមកវិញធាតុដើមបានកើតឡើងការផ្លាស់ប្រែរួចហើយ, លែងនៅជាប្រភេទរាងកាយនេះដែលបានផ្សំឡើងពីកោសិការាងកាយសាច់, លោកអ្នកមិនមែនមិននៅក្នុងធាតុទាំង៥ហើយឬ? ប្រាកដណាស់បួសហាត់របស់លោកអ្នកនៅមិនទាន់បញ្ចប់, លោកអ្នកនៅតែបួសហាត់នៅក្នុងមនុស្សសាមញ្ញ, ដូច្នេះនៅលើផ្ទៃមើលដូចជាមនុស្សសាមញ្ញ, ភាពខុសគ្នាតែមួយគត់នោះគឺលោកអ្នកមើលទៅក្មេងណាស់បើប្រៀបនឹងមនុស្សស្មើអាយុ។ ប្រាកដណាស់, ដំបូងត្រូវតែកម្ចាត់របស់មិនល្អលើរាងកាយលោកអ្នក, រួមបញ្ចូលជំងឺឈឺថ្កាត់។ ប៉ុន្តែ, ទីនេះគឺមិនព្យាបាលជំងឺ, យើងខ្ញុំគឺសម្អាតរាងកាយ, នាមសព្ទក៏មិនហៅថាព្យាបាលជំងឺ, យើងខ្ញុំគឺហៅថាសម្អាតរាងកាយ, ដើម្បីមនុស្សបួសហាត់ពិតប្រាកដសម្អាតរាងកាយ។ មានមនុស្សមួយចំនួនជាក់ស្តែងគឺមកព្យាបាលជំងឺ។ អ្នកជំងឺដ៏ធ្ងន់ធ្ងរ, យើងខ្ញុំមិនអនុញ្ញាតឲ្យគាត់ចូលក្នុងថ្នាក់, ដោយសារគាត់ដាក់ចុះមិនបានចិត្តព្យាបាលជំងឺនេះ, គាត់ដាក់ចុះមិនបានការគិតមានជំងឺ។ គាត់កើតជំងឺធ្ងន់ធ្ងរ, ដ៏ពិបាកទ្រាំ, គាត់អាចដាក់ចុះបានឬ? គាត់បួសហាត់មិនបាន។ យើងខ្ញុំសង្កត់ធ្ងន់ម្តងទៀត, អ្នកជំងឺធ្ងន់ធ្ងរយើងខ្ញុំគឺមិន

ទទួល, ទីនេះគឺជាបួសហាត់, ខុសគ្នាឆ្ងាយខ្លាំងណាស់នឹងរឿងរ៉ាវដែលគាត់គិត, គាត់អាចរកគ្រូឈីគង់ផ្សេងដើម្បីធ្វើរឿងរ៉ាវនេះ។ ប្រាកដណាស់មានសិក្ខាកាមជាច្រើនគឺមានជំងឺ, ដោយសារលោកអ្នកជាមនុស្សបួសហាត់ពិតប្រាកដ, យើងខ្ញុំនឹងធ្វើរឿងរ៉ាវនេះឲ្យលោកអ្នក។

សិក្ខាកាមហ្វាលូនតាហ្វាយើងខ្ញុំបន្ទាប់ពីបួសហាត់មួយដំណាក់កាលពេលវេលា, ពីលើផ្ទៃមើលទៅកែលម្អធំណាស់, ស្បែកប្រែជាទន់, សក្រហម, មនុស្សអាយុដ៏ច្រើនក៏លេចឡើងស្នាមជ្រួញកាត់បន្ថយ, ដល់ថ្នាក់ដ៏តិចៗ, នេះជាបាតុភូតទូទៅមួយ។ ខ្ញុំទីនេះមិនមែនសម្ដែងរឿងដោយរកស្មានមិនដល់, សិក្ខាកាមយូរឆ្នាំរបស់ពួកយើងកំពុងអង្គុយបានដឹងចំណុចមួយនេះ។ លើសពីនេះទៀតស្ត្រីចំណាស់ក៏នឹងមករដូវ, ដោយសារគង់ហ្វាចរិតជីវិតបួសទាំងទ្វេ, ចាំបាច់ឈីនៃឈាមរដូវដើម្បីបួសជីវិតរបស់លោកអ្នក។ មករដូវ, តែនឹងមិនច្រើន, ដំណាក់កាលបច្ចុប្បន្នបន្តិចយ៉ាងនោះ, គ្រប់ប្រើគឺបានហើយ, នេះក៏ជាបាតុភូតទូទៅមួយ។ បើមិនដូច្នោះទេ, លោកអ្នកខ្វះវាធ្វើដូចម្ដេចបួសជីវិត? បុរសក៏ដូចគ្នា, មនុស្សចាស់, យុវជនសុទ្ធតែនឹងមានអារម្មណ៍បានរាងកាយមួយស្រាល។ មនុស្សបួសហាត់ពិតប្រាកដ, លោកអ្នកនឹងទទួលដឹងបានការផ្លាស់ប្រែនេះ។

សំណុំគង់ហ្វានេះរបស់យើងខ្ញុំហាត់បានធំណាស់, មិនដូចមានគង់ហ្វាជាច្រើនធ្វើត្រាប់តាមសត្វដើម្បីហាត់។ សំណុំគង់ហ្វានេះហាត់បានសុទ្ធសាធធំខ្លាំងណាស់។ គោលសីលធម៌ដែលសក្យមុនី, ឡៅជឺសម្ដែងនាពេលនោះ, សុទ្ធតែជាគោលសីលធម៌ខាងក្នុងវិសាលភាពប្រព័ន្ធកញ្ចុំផ្កាយរបស់ពួកយើង។ ហ្វាលូនតាហ្វារបស់ពួកយើងហាត់អ្វី? ពួកយើងគឺបួសហាត់យោងតាមគោលការណ៍វិវត្តរបស់ចក្រវាល, យោងតាមចរិត

ពិសេសខ្ពស់បំផុតរបស់ចក្រវាល.................បរមាណើយនៃសច្ចៈ, ករុណា, ខន្តីដឹកនាំពួកយើងបួសហាត់។ ពួកយើងហាត់ប្រការមួយធំយ៉ាងនេះ, ស្មើនឹងគឺហាត់ចក្រវាល។

ហ្វាលូនតាហ្វាយើងខ្ញុំនៅមានលក្ខណៈធំបំផុតមួយយ៉ាងពិសេសបំផុតខុសគ្នាជាមួយគង់ហ្វាទាំងអស់។ បច្ចុប្បន្នឈីគង់ដែលផ្សព្វផ្សាយនៅលើសង្គមសុទ្ធតែជាស្ថិតក្នុងដើរតានតាវ, ហាត់តាន។ ឈីគង់ដែលហាត់តានចង់នៅក្នុងមនុស្សសាមញ្ញសម្រេចបានបើកគង់ត្រាស់ដឹងគឺដ៏ពិបាកធ្វើបាន។ ហ្វាលូនតាហ្វាពួកយើងមិនដើរតានតាវ, សំណុំគង់ហ្វានេះរបស់ពួកយើងគឺបួសហាត់ហ្វាលូនមួយនៅទីតាំងពោះក្រោម, នៅលើថ្នាក់បង្រៀនខ្ញុំផ្ទាល់ខ្លួនដំឡើងឲ្យសិក្ខាកាម។ ពេលដែលខ្ញុំកំពុងសម្តែងហ្វាលូនតាហ្វា, យើងខ្ញុំនឹងបន្តបន្ទាប់ផ្តល់ហ្វាលូនឲ្យអ្នករាល់គ្នា, មនុស្សខ្លះមានអារម្មណ៍បាន, មនុស្សខ្លះគ្មានអារម្មណ៍បាន។ មនុស្សភាគច្រើនមានអារម្មណ៍បាន, ដោយសារគុណសម្បត្តិរាងកាយរបស់មនុស្សមិនដូចគ្នា។ ពួកយើងហាត់ហ្វាលូន, តែមិនហាត់តាន។ ហ្វាលូនជារូបភាពបង្រួមតូចរបស់ចក្រវាល, មានគ្រប់គ្រាន់សីលគង់ទាំងអស់របស់ចក្រវាល, គាត់អាចធ្វើចលនា, បង្វិលដោយស្វ័យប្រវត្តិ។ គាត់នៅទីតាំងពោះក្រោមរបស់លោកអ្នកនឹងបង្វិលបន្តជានិច្ច, បន្ទាប់ពីដំឡើងឲ្យលោកអ្នកតទៅ, មិនដែលបញ្ឈប់, ជានិច្ចមួយឆ្នាំទៅមួយឆ្នាំបង្វិលបន្តបែបនេះ។ គាត់នៅក្នុងដំណើរការវិលបណ្តោយ, នឹងស្វ័យប្រវត្តិស្រូបយកថាមពលពីចក្រវាល, គាត់ខ្លួនឯងក៏ចេះវិវត្តថាមពល, ផ្គត់ផ្គង់ថាមពលឲ្យតម្រូវការវិវត្តនៃផ្នែករាងកាយទាំងអស់របស់លោកអ្នក។ ក្នុងពេលដំណាលគ្នា, ពេលដែលគាត់វិលបញ្ច្រាស (ទ្រនិចនាឡិកា) នឹងបញ្ចេញថាមពល, រុញសារធាតុកាកសំណល់ចេញក្រៅ, រួចហើយខ្ចាត់បាត់នៅជុំ

វិញរាងកាយ។ ពេលគាត់បញ្ចេញថាមពល, នឹងរុញចេញទៅដ៏ឆ្ងាយ, សាជាថ្មីនាំចូលមកថាមពលថ្មី។ ថាមពលដែលគាត់រុញចេញ, មនុស្សនៅជុំវិញរាងកាយលោកអ្នកសុទ្ធតែនឹងទទួលបានអត្ថប្រយោជន៍។ ពុទ្ធវង្សសម្តែងប្រោសខ្លួនប្រោសមនុស្ស, ប្រោសសត្វលោកទាំងឡាយ, មិនគ្រាន់តែបួសខ្លួន, នៅចាំបាច់ប្រោសសត្វលោកទាំងឡាយ, អ្នកដទៃនឹងតាមនោះទទួលបានអត្ថប្រយោជន៍, ដោយអចេតនាអាចកែសម្រួលរាងកាយឱ្យអ្នកដទៃ, ព្យាបាលជំងឺ។ល។ ប្រាកដណាស់ថាមពលគឺនឹងមិនបាត់, នៅពេលហ្វាលូនវិលបណ្តោយ (តាមទ្រនិចនាឡិកា), គាត់ខ្លួនឯងនឹងប្រមូលមកវិញ, ដោយសារគាត់បង្វិលជាប្រចាំមិនឈប់។

មនុស្សខ្លះគិតថា៖ ហេតុអ្វីហ្វាលូននេះចេះបង្វិលជាប្រចាំមិនឈប់? ក៏មានមនុស្សសួរខ្ញុំ៖ វាហេតុអ្វីចេះបង្វិល? គោលការណ៍នៅកន្លែងណា? ថាមពលប្រមូលផ្តុំច្រើនហើយអាចបង្កើតជាតាននេះងាយស្រួលពន្យល់, ហ្វាលូនបង្វិលគឺមិនគួរឲ្យជឿ។ ខ្ញុំលើកឧទាហរណ៍ឲ្យអ្នករាល់គ្នា, ចក្រវាលកំពុងធ្វើចលនា, ប្រព័ន្ធកញ្ចុំផ្កាយទាំងអស់, ប្រព័ន្ធផ្កាយទាំងអស់ក្នុងចក្រវាលសុទ្ធតែកំពុងធ្វើចលនា, មហាភពផ្កាយទាំង៩កំពុងវិលជុំវិញព្រះអាទិត្យ, ផែនដីក៏កំពុងបង្វិលដោយខ្លួនឯង។ លោកអ្នកគិតសាកមើល, នរណារុញវា? នរណាបន្ថែមកម្លាំងឱ្យវា? លោកអ្នកមិនអាចប្រើគោលគំនិតក្នុងមនុស្សសាមញ្ញដើម្បីយល់ដឹងវា, វាជាក់ស្តែងជាប្រភេទយន្តការបង្វិលមួយបែបនេះ។ ហើយហ្វាលូនរបស់ពួកយើងក៏ជាបែបនេះ, គាត់ក៏ជាធ្វើចលនា។ គាត់បានដោះស្រាយបញ្ហាមនុស្សសាមញ្ញហាត់គង់នៅក្នុងស្ថានភាពជីវិតធម្មតា, បង្កើនពេលវេលាហាត់គង់។ បង្កើនដូចម្តេច? ដោយសារគាត់បង្វិលមិនឈប់, បន្តស្រូបយកថាមពលពីក្នុងចក្រវាល, វិវត្តថាមពល។ លោកអ្នកទៅធ្វើការ, គាត់កំពុងហាត់លោក

អ្នក។ ប្រាកដណាស់ក៏មិនគ្រាន់តែជាហ្វាលូន, យើងខ្ញុំត្រូវការដំឡើងឲ្យរាងកាយលោកអ្នកប្រព័ន្ធថាមពល, យន្តការជាច្រើន, សូម្បីតែហ្វាលូនគឺធ្វើចលនាដោយស្វ័យប្រវត្តិ, វិវត្តដោយស្វ័យប្រវត្តិ។ ដូច្នេះគង់នេះទាំងស្រុងគឺជាកំពុងវិវត្តមនុស្សដោយស្វ័យប្រវត្តិ, បែបនេះគឺបង្កើតជាមួយប្រភេទ [គង់ហាត់មនុស្ស], ក៏ហៅថា [ធម៌ហាត់មនុស្ស]។ ពេលលោកអ្នកមិនហាត់គង់, គង់ហាត់លោកអ្នក; ពេលលោកអ្នកហាត់គង់, គង់ក៏កំពុងហាត់លោកអ្នក។ លោកអ្នកញ៉ាំបាយ, គេង, ទៅធ្វើការ, សុទ្ធតែនៅក្នុងការវិវត្តន៍របស់គង់។ លោកអ្នកហាត់គង់ធ្វើអ្វី? លោកអ្នកហាត់គង់គឺដើម្បីពង្រឹងហ្វាលូន, ពង្រឹងប្រព័ន្ធថាមពលនិងយន្តការទាំងអស់នេះដែលខ្ញុំបានផ្តល់ឲ្យលោកអ្នក។ ពេលដែលបួសហាត់នៅក្នុងជាន់ថ្នាក់ខ្ពស់, សុទ្ធតែជាសភាពគ្មានបំណង, ចលនាក៏ជាកម្រើកតាមយន្តការ, គ្មានគំនិតណាមួយណែនាំ, ក៏មិនសម្តែងដកដង្ហើម។ល។

យើងខ្ញុំក៏មិនសម្តែងអ្វីពេលវេលា, ទីកន្លែងហាត់គង់។ មានមនុស្សសម្តែង, ពេលវេលាណាហាត់គង់ល្អ? អធ្រាត្រ, ពេលព្រឹក, ថ្ងៃត្រង់? ពួកយើងមិនសម្តែងស្ទីឆឹន, អធ្រាត្រលោកអ្នកមិនហាត់គង់, គង់ហាត់លោកអ្នក; ពេលព្រឹកលោកអ្នកមិនហាត់គង់, គង់ក៏កំពុងហាត់លោកអ្នក; លោកអ្នកគេង, គង់ក៏កំពុងហាត់លោកអ្នក; លោកអ្នកដើរតាមផ្លូវ, គង់ក៏កំពុងហាត់លោកអ្នក; លោកអ្នកទៅធ្វើការ, គង់នៅតែកំពុងហាត់លោកអ្នក។ នេះមិនកាត់បន្ថយដ៏ធំពេលវេលាហាត់គង់របស់លោកអ្នកឬ? មនុស្សដ៏ច្រើនពួកយើងឱបយកចិត្តសម្រេចតាវពិតប្រាកដ, នោះប្រាកដណាស់ជាគោលបំណងរបស់បួសហាត់, គោលបំណងចុងបញ្ចប់របស់បួសហាត់ជាក់ស្តែងគឺជាសម្រេចតាវ, សម្រេចបរិបូរ។ តែមានមនុស្សមួយចំនួននៅក្នុងអំឡុងពេលមានជីវិតរបស់គាត់, អាយុបានដ៏មាន

កំហិតរួចហើយ, មិនជាក់លាក់គ្រប់គ្រាន់ប្រើ, ហ្វាលូនតាហ្វាយើងខ្ញុំអាចដោះស្រាយបញ្ហាមួយបែបនេះ, កាត់បន្ថយដំណើរការហាត់គង់។ ក្នុងពេលដំណាលគ្នាក៏ជាគង់ហ្វាចរិតជីវិតបួសទាំងទ្វេ, ពេលដែលលោកអ្នកកំពុងបន្តបួសហាត់, គឺនឹងបន្តអូសវែងជីវិតរបស់លោកអ្នក, លោកអ្នកបន្តហាត់, បន្តអូសវែង, មនុស្សនិស្ស័យល្អតែអាយុច្រើន, ពេលវេលាហាត់គង់របស់លោកអ្នកក៏ជាគ្រប់ប្រើ។ ប៉ុន្តែមានបរមាណើយមួយ, លើសផុតដំណើរការជីវិតនៃមេឃកំណត់, ដើមមករបស់លោកអ្នក, ជីវិតដែលបានអូសវែងបន្តក្រោយមក, ទាំងស្រុងគឺផ្តល់ឲ្យលោកអ្នកប្រើដើម្បីហាត់គង់, មនោគតិលោកអ្នកលេចឡើងគម្លាតបន្តិចភ្លាម, គឺនឹងនាំមកគ្រោះថ្នាក់ដល់ជីវិត, ដោយសារដំណើរការជីវិតរបស់លោកអ្នកគឺកន្លងផុតតាំងពីយូររួចហើយ។ លុះត្រាតែពេលក្រោយលោកអ្នកដើរឆ្លងបួសហាត់ផុតពីលោកីយ៍ធម៌, គ្មានការឃុំគ្រងនេះទៀត, ពេលនោះជាក់ស្តែងគឺស្ថានភាពមួយផ្សេង។

មិនសម្តែងទិសដៅ, ក៏មិនសម្តែងដកហូតគង់។ ដោយសារហ្វាលូនបង្វិលជាប្រចាំមិនឈប់, ក៏មិនអាចដកហូតឈប់។ មានទូរសព្ទឆាទ៍, មានមនុស្សគោះទ្វារ, លោកអ្នកភ្លាមៗគឺទៅធ្វើការ, ក៏មិនចាំបាច់ដកហូតគង់។ ពេលលោកអ្នកទៅធ្វើការ, ហ្វាលូនភ្លាមៗនោះនឹងបង្វិលតាមទ្រនិចនាឡិកា, មួយរំពេចស្រូបមកវិញថាមពលដែលខ្ចាត់ខ្ចាយខាងក្រៅរាងកាយលោកអ្នក។ មនុស្សចេតនាឱបឈីស្រោចកំពូល, លោកអ្នកឱបច្រើនដល់ណាក៏នឹងបាត់។ ហ្វាលូនជារបស់ដែលមានប្រាជ្ញា, គាត់ខ្លួនឯងដឹងធ្វើរឿងរ៉ាវទាំងនេះ។ ក៏មិនសម្តែងទិសដៅ, ដោយសារចក្រវាលទាំងមូលសុទ្ធតែកំពុងធ្វើចលនា, ប្រព័ន្ធកញ្ចុំផ្កាយកំពុងបង្វិល, មហាភពផ្កាយទាំង៩កំពុងវិលជុំវិញព្រះអាទិត្យ, ផែនដីក៏កំពុងវិលដោយ

ខ្លួនឯង។ ពួកយើងយោងតាមគោលសីលធម៌ធំយ៉ាងនោះរបស់ចក្រវាល ដើម្បីហាត់, ទីណាជាកើតត្បូងលិចជើង? គ្មាន។ បែរមុខទល់ទិសដៅណាដើម្បីហាត់, ក៏ជាបែរមុខទល់ទិសដៅទាំងអស់ដើម្បីហាត់; បែរមុខទល់ទិសដៅណាដើម្បីហាត់, ក៏ស្មើនឹងក្នុងពេលដំណាលគ្នាបែរមុខទល់កើតត្បូងលិចជើងដើម្បីហាត់។ ហ្វាលូនតាហ្វាយើងខ្ញុំនឹងការពារសិក្ខាកាមមិនលេចឡើងគម្លាត។ ការពារដូចម្តេច? លោកអ្នកធ្វើជាមនុស្សបួសហាត់ម្នាក់ពិតប្រាកដ, ហ្វាលូនរបស់យើងខ្ញុំនឹងការពារលោកអ្នក។ គល់របស់ខ្ញុំភ្ជាប់នៅលើចក្រវាល, នរណាអាចប៉ះដល់លោកអ្នក, គឺអាចប៉ះដល់ខ្ញុំ, និយាយត្រង់ចេញ, គាត់គឺអាចប៉ះដល់ចក្រវាលនេះ។ ពាក្យដែលខ្ញុំសម្តែងស្តាប់ទៅដ៏អាថ៌កំបាំង, ក្រោយមកលោកអ្នករៀនឡើង, លោកអ្នកគឺយល់ច្បាស់បាន។ នៅមានប្រការផ្សេង, ខ្ពស់ពេកខ្ញុំមិនអាចសម្តែង។ យើងខ្ញុំនឹងបរិយាយយ៉ាងល្អិតល្អន់តាមប្រព័ន្ធពីរាក់ដល់ជ្រៅធម៌លើជាន់ថ្នាក់ខ្ពស់។ ប្រសិនចិត្តចរិតលោកអ្នកខ្លួនឯងមិនសុចរិតមិនអាចបានទេ, លោកអ្នកទៅចំណង់, នោះអាចគឺលេចឡើងបញ្ហា។ ខ្ញុំរកឃើញថាហ្វាលូនរបស់សិក្ខាកាមយូរឆ្នាំជាច្រើននៅតែប្រែទម្រង់។ ហេតុអ្វី? លោកអ្នកលាយរបស់ផ្សេងចូលក្នុងដើម្បីហាត់, លោកអ្នកចង់បានប្រការរបស់អ្នកដទៃ។ ដូច្នោះហ្វាលូនហេតុអ្វីមិនការពារលោកអ្នក? ផ្តល់ឲ្យលោកអ្នករួចហើយ, ជាក់ស្តែងជារបស់លោកអ្នក, រងការគ្រប់គ្រងពីសតិរបស់លោកអ្នក។ ដែលលោកអ្នកចង់បាននរណាក៏មិនគ្រប់គ្រង, នេះជាគោលសីលធម៌នៃចក្រវាលនេះ។ លោកអ្នកមិនចង់បួស, នរណាក៏មិនអាចបង្ខំលោកអ្នកទៅបួស, នោះស្មើនឹងគឺកំពុងធ្វើរឿងអាក្រក់។ នរណាអាចបង្ខំលោកអ្នកប្រែផ្លាស់ចិត្តរបស់លោកអ្នកបាន? លោកអ្នកខ្លួនឯងត្រូវតែតម្រូវខ្លួនឯង។ យកចំណុចខ្លាំងរបស់អ្នករាល់គ្នា, ប្រការ

របស់គេសុទ្ធតែយកមក, ថ្ងៃហ្នឹងហាត់គង់នេះ, ថ្ងៃស្អែកហាត់គង់នោះ, គោលបំណងកម្ចាត់ជំងឺរបស់លោកអ្នក, ព្យាបាលបានឬអត់? ព្យាបាលមិនបាន, គ្រាន់តែជារុញថយមកក្រោយឲ្យលោកអ្នក។ បួសហាត់នៅក្នុងជាន់ថ្នាក់ខ្ពស់, ត្រូវការសម្តែងបញ្ហាឯកទេសតែមួយគត់, ត្រូវការកាន់ជាប់ធម្មក្ខន្ធមួយដើម្បីបួស, បួសហាត់ធម្មក្ខន្ធមួយណា, ជាក់លាក់ត្រូវការដាក់ចិត្តនៅលើធម្មក្ខន្ធមួយនោះ, រហូតដល់នៅក្នុងធម្មក្ខន្ធនេះបើកគង់ត្រាស់ដឹង, លោកអ្នកទើបអាចផ្លាស់ចូលទៅគង់ហ្វាផ្សេងបួសម្តងទៀត, នោះជាសំណុំប្រការមួយផ្សេង។ ដោយសារសំណុំប្រការមួយពិតប្រាកដបានស្នងបង្រៀនមក, គឺឆ្លងកាត់យុគ្គសម័យដ៏យូរអង្វែងបន្សល់ទុកមក, វាសុទ្ធតែជាដំណើរការវិវត្តន៍មួយដ៏ស្មុគស្មាញ។ មានមនុស្សពឹងផ្អែកលើអារម្មណ៍ដើម្បីហាត់គង់, អារម្មណ៍របស់លោកអ្នកចាត់ថាអ្វី? មិនជាអ្វីទាំងអស់។ ដំណើរការវិវត្តន៍ពិតប្រាកដនៅអវកាសផ្សេង, ស្មុគស្មាញនិងអាថ៌កំបាំងស្អាតជាទីបំផុត, ខុសបន្តិចក៏មិនបាន, គឺដូចឧបករណ៍ភាពជាក់លាក់លោកអ្នកថែមចូលគ្រឿងផ្សំផ្សេងគឺខូចភ្លាម។ រាងកាយនៃបណ្តាអវកាសទាំងអស់របស់លោកអ្នកសុទ្ធតែកំពុងកើតឡើងការផ្លាស់ប្រែ, អាថ៌កំបាំងនិងស្អាតខ្លាំងណាស់, ខុសបន្តិចក៏មិនបាន។ មិនមែនខ្ញុំសម្តែងឲ្យលោកអ្នកហើយឬ, បួសនៅខ្លួនឯង, គង់នៅលោកគ្រូ។ លោកអ្នកតាមអំពើចិត្តយកអ្វីរបស់អ្នកដទៃ, បន្ថែមចូលក្នុង, មាននាំតាមព័ត៌មានផ្សេង, គឺបានជ្រៀតជ្រែកដល់ប្រការនៃធម្មក្ខន្ធមួយនេះ, លោកអ្នកគឺនឹងដើរគម្លាត, លើសពីនេះទៀតនឹងឆ្លុះបញ្ចាំងមកក្នុងសង្គមមនុស្សសាមញ្ញ, នឹងនាំមកការរំខានរបស់មនុស្សសាមញ្ញ, គឺលោកអ្នកខ្លួនឯងចង់បាន, អ្នកដទៃគឺមិនអាចគ្រប់គ្រង, នេះជាបញ្ហាចរិតភ្ញាក់ដឹង។ ក្នុងពេលដំណាលគ្នារបស់ដែលលោកអ្នកលាយ

ចូលក្នុងបានធ្វើឲ្យគង់រញ៉េរញ៉ៃរួចហើយ, លោកអ្នកលែងអាចបួសបានទៀត, នឹងលេចឡើងបញ្ហានេះ។ ខ្ញុំក៏មិនមែនហៅអ្នករាល់គ្នាត្រូវតែរៀនហ្វាលូនតាហ្វា។ លោកអ្នកមិនរៀនហ្វាលូនតាហ្វា, លោកអ្នកនៅក្នុងគង់ហ្វាដទៃទទួលបានការបង្រៀនពិតប្រាកដ, នោះខ្ញុំក៏គាំទ្រ។ ប៉ុន្តែខ្ញុំប្រាប់លោកអ្នក, ពិតប្រាកដបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, ជាក់លាក់ត្រូវឯកទេសតែមួយគត់។ មានចំណុចមួយខ្ញុំក៏ត្រូវសម្ដែងជាមួយលោកអ្នក៖ បច្ចុប្បន្នដូចខ្ញុំបែបនេះពិតប្រាកដបង្រៀនគង់ឡើងលើជាន់ថ្នាក់ខ្ពស់, គ្មានមនុស្សទីពីរធ្វើ។ ក្រោយមកលោកអ្នកនឹងដឹងថាខ្ញុំបានធ្វើឲ្យលោកអ្នករឿងរ៉ាវអ្វីខ្លះ, ដូច្នេះសង្ឃឹមថាលោកអ្នកក៏កុំភ្ញាក់ដឹងទាបពេក។ មានមនុស្សជាច្រើនចង់បួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, របស់នេះដាក់នៅពីមុខឲ្យលោកអ្នករួចហើយ, លោកអ្នកអាចនៅតែមិនទាន់មានប្រតិកម្មអ្វី, លោកអ្នកដល់គ្រប់ទីកន្លែងសំពះគ្រូ, ចំណាយលុយទាំងប៉ុន្មាន, លោកអ្នករកមិនបាន។ ថ្ងៃនេះជូនដល់ខ្លោងទ្វារឲ្យលោកអ្នក, លោកអ្នកប្រហែលជាមិនទាន់ទទួលស្គាល់បាននៅឡើយ! នេះជាក់ស្ដែងជាបញ្ហាភ្ញាក់ដឹងឬមិនភ្ញាក់ដឹង, ក៏ជាក់ស្ដែងជាបញ្ហាអាចប្រោសឬមិនអាចប្រោស។

# មេសម្ដែងទី២

## អំពីបញ្ហាភ្នែកទិព្វ

មានគ្រូឈីគង់ជាច្រើនក៏បាននិយាយដល់កាលៈទេសៈមួយចំនួនរបស់ភ្នែកទិព្វ, ប៉ុន្តែ, ធម៌នៅក្នុងជាន់ថ្នាក់ខុសគ្នាមានទម្រង់លាតត្រដាងខុសគ្នា។ មនុស្សប្រួសហាត់ដល់ជាន់ថ្នាក់មួយណា, គាត់គ្រាន់តែអាចមើលឃើញទស្សនីយភាពនៅក្នុងជាន់ថ្នាក់មួយនោះ, សេចក្ដីពិតលើសពីជាន់ថ្នាក់នេះគាត់គឺមើលមិនឃើញ, ក៏មិនជឿ, ដូច្នេះគាត់សន្មតថាអ្វីដែលមើលឃើញក្នុងមួយជាន់ថ្នាក់នេះរបស់ខ្លួនឯងទើបជាត្រឹមត្រូវ។ ពេលដែលគាត់មិនទាន់ប្រួសហាត់ដល់ជាន់ថ្នាក់ខ្ពស់យ៉ាងនោះ, គាត់សន្មតថាអ្វីទាំងនោះគឺមិនស្ថិតនៅ, មិនអាចជឿ, នេះជាជាន់ថ្នាក់កំណត់, មនោគតិរបស់គាត់ក៏មិនអាចថ្កើងឡើងបាន។ ក៏មានន័យថា, នៅលើបញ្ហាភ្នែកទិព្វរបស់មនុស្ស, មានមនុស្សសម្ដែងយ៉ាងនេះ, មានមនុស្សសម្ដែងយ៉ាងនោះ, លទ្ធផលសម្ដែងដ៏រញ៉េរញ៉ៃ, ចុងក្រោយក៏គ្មាននរណានិយាយវាបានច្បាស់លាស់, ភាពពិតភ្នែកទិព្វនេះក៏មិនមែនលើជាន់ថ្នាក់ទាបអាចសម្ដែងឲ្យច្បាស់បាន។ អតីតកាល, ដោយសាររចនាសម្ព័ន្ធរបស់ភ្នែកទិព្វស្ថិតក្នុងអាថ៌កំបាំងក្នុងអាថ៌កំបាំង, គឺមិនទុកឲ្យមនុស្សសាមញ្ញដឹងបាន, ដូច្នេះពីដើមមកក៏គ្មានមនុស្សទៅសម្ដែង។ ហើយយើងខ្ញុំទីនេះក៏មិនមែនជាវិលជុំវិញប្រភេទទ្រឹស្ដីនោះនៃអតីតកាលដើម្បីសម្ដែង, យើងខ្ញុំប្រើវិទ្យាសាស្ត្រទំនើប, ប្រើភាសាទំនើបរាក់សាមញ្ញបំផុតដើម្បីពន្យល់វាចេញ, និងសម្ដែងបញ្ហាមូលដ្ឋានរបស់វា។

ភ្នែកទិព្វដែលយើងខ្ញុំនិយាយ, ធាតុពិតទៅគឺនៅចន្លោះចិញ្ចើមទាំងពីររបស់មនុស្សខិតឡើងលើបន្តិចតភ្ជាប់ដល់ទីតាំងក្រពេញស្រល់, នេះ

ជាផ្លូវរន្ធចម្បង។ រាងកាយនៅមានភ្នែកដ៏ច្រើនទៀត, តាវវង្សសម្តែងឈាវនីមួយៗសុទ្ធតែជាភ្នែក។ តាវវង្សហៅស្មៀវ៉ីថាឈាវ, វេជ្ជសាស្ត្រចិនហៅថាស្មៀវ៉ី។ ពុទ្ធវង្សសម្តែងថារន្ធរោមនីមួយៗសុទ្ធតែជាភ្នែកមួយ, ដូច្នេះមនុស្សខ្លះប្រើត្រចៀកមើលអក្សរ, នៅមានប្រើដៃ, ប្រើខាងក្រោយក្បាលដើម្បីមើល, នៅមានខ្លះប្រើជើងដើម្បីមើល, ប្រើពោះដើម្បីមើល, សុទ្ធតែអាចបាន។

សម្តែងដល់ភ្នែកទិព្វ, ពួកយើងជាដំបូងនិយាយបន្តិចអំពីគូនេត្រាសាច់នេះរបស់ពួកយើង។ បច្ចុប្បន្នមនុស្សមួយចំនួនសន្មតថាគូនេត្រានេះអាចមើលឃើញសារធាតុណាមួយ, វត្ថុណាមួយក្នុងពិភពលោកនេះរបស់ពួកយើង។ ដូច្នេះមានមនុស្សមួយចំនួនបានសាងបង្កើតប្រភេទគោលគំនិតប្រកាន់មួយ, គាត់សន្មតថាអ្វីដែលបានមើលឃើញតាមរយៈភ្នែកទើបជាប្រាកដជាក់ស្តែង; ដែលគាត់មើលមិនឃើញគឺមិនជឿ។ អតីតកាលតែងតែសន្មតថាមនុស្សប្រភេទនេះចរិតភ្ញាក់ដឹងមិនល្អ, មានមនុស្សមួយចំនួនក៏សម្តែងមិនច្បាស់លាស់ហេតុអ្វីបានជាចរិតភ្ញាក់ដឹងមិនល្អ។ មើលមិនឃើញគឺមិនជឿ, ពាក្យនេះស្តាប់ទៅដ៏សមហេតុផល។ ប៉ុន្តែនៅក្នុងជាន់ថ្នាក់ខ្ពស់ជាងបន្តិចសង្កេតមើល, វាគឺមិនសមហេតុផលទៀត។ អវកាសណាមួយ, សុទ្ធតែបានផ្សំឡើងដោយសារធាតុ, ប្រាកដណាស់វេលា-អវកាសខុសគ្នាមានរចនាសម្ព័ន្ធសារធាតុខុសគ្នា, មានទម្រង់លាតត្រដាងគ្រប់ប្រភេទនៃកាយជីវិតខុសគ្នា។

ខ្ញុំលើកឧទាហរណ៍ឱ្យអ្នករាល់គ្នា, ក្នុងពុទ្ធសាសនាសម្តែងថាបាតុភូតទាំងអស់នៃសង្គមមនុស្សជាតិសុទ្ធតែជាការបំភាន់, គឺមិនពិត។ ដូចម្តេចជាការបំភាន់? វត្ថុនេះដាក់តាំងប្រាកដជាក់ស្តែងនៅទីនោះ, នរណាអាចនិយាយថាវាជាក្លែងក្លាយ? ទម្រង់អត្ថិភាពរបស់វត្ថុគឺជាបែបនេះ,

ប៉ុន្តែទម្រង់បង្ហាញរបស់វាផ្ទុយមកវិញមិនមែនបែបនេះ។ ហើយភ្នែករបស់ពួកយើងផ្ទុយមកវិញមានប្រភេទសីលគង់មួយ, អាចធ្វើឲ្យវត្ថុនៃអវកាសសារធាតុពួកយើងថេរដល់ស្ថានភាពប្រភេទនេះដែលពួកយើងមើលឃើញបច្ចុប្បន្ន។ ភាពពិតវាមិនមែនប្រភេទស្ថានភាពនេះ, នៅក្នុងអវកាសពួកយើងនេះវាក៏មិនមែនស្ថានភាពនេះ។ ឧបមានៅក្រោមមីក្រូទស្សន៍មើលមនុស្សគឺជាបែបណា? រាងកាយទាំងមូលគឺរលុង, បានផ្សំឡើងដោយម៉ូលេគុលតូចៗ, ដូចជាគ្រាប់ខ្សាច់, ស្ថានភាពភាគល្អិត, ធ្វើចលនា, អេឡិចត្រុងកំពុងធ្វើចលនាជុំវិញស្នូលអាតូម, រាងកាយទាំងមូលសុទ្ធតែកំពុងកម្រើករើកៗ, កំពុងធ្វើចលនា។ លើផ្ទៃរាងកាយមិនមែនរលោង, មិនទៀងទាត់។ ប្រភេទវត្ថុណាមួយក្នុងចក្រវាល, ដែក, ថែប, ថ្មសុទ្ធតែដូចគ្នា, សមាសភាគម៉ូលេគុលខាងក្នុងវាសុទ្ធតែធ្វើចលនា, លោកអ្នកមិនអាចមើលឃើញទម្រង់ទាំងមូល, ភាពពិតវាសុទ្ធតែមិនមែនស្ថេរភាព។ តុនេះក៏កំពុងកម្រើករើកៗ, ប៉ុន្តែផ្ទុយមកវិញភ្នែកមើលមិនឃើញសេចក្ដីពិត, គូនេត្រានេះអាចបង្កជាប្រភេទអារម្មណ៍ខុសមួយឲ្យមនុស្ស។

មិនមែនពួកយើងមើលមិនឃើញវត្ថុនៅក្រោមអតិសុខុម, មិនមែនមនុស្សគ្មានអានុភាពនេះ, ហើយមនុស្សកើតមកមានគ្រប់គ្រាន់អានុភាពប្រភេទបែបនេះ, វត្ថុនៅក្រោមអតិសុខុមពិសេសជាក់លាក់មួយគាត់គឺអាចមើលឃើញបាន។ ច្បាស់ណាស់បន្ទាប់ពីមនុស្សពួកយើងមានគូនេត្រានៃអវកាសសារធាតុនេះរួចហើយ, គឺអាចបង្កើតឲ្យមនុស្សប្រភេទភាពមិនពិតមួយបែបនេះ៖ ធ្វើឱ្យមនុស្សមើលមិនឃើញ។ ដូច្នេះអតីតកាលសម្ដែងថា, នរណាមើលមិនឃើញហើយមិនទទួលស្គាល់, ពិភពបួសហាត់ពីដើមមកសន្មតថាមនុស្សប្រភេទនេះចរិតភ្ញាក់ដឹងមិនល្អ, ត្រូវ

បានភាពមិនពិតនៃមនុស្សសាមញ្ញពង្វក់, វង្វេងនៅក្នុងមនុស្សសាមញ្ញ, នេះជាប្រយោគដែលបានសម្តែងពីដើមមកក្នុងសាសនា, ភាពពិតយើងខ្ញុំឃើញថាក៏សមហេតុផលផងដែរ។

គូនេត្រានេះអាចធ្វើឲ្យវត្ថុនៃអវកាសសារធាតុកំពុងមានរបស់ពួកយើងថេរដល់ប្រភេទស្ថានភាពនេះ, ក្រៅពីនេះ, វាគ្មានអានុភាពអ្វីធំ។ មនុស្សមើលអ្វីមួយ, ក៏មិនមែនបង្កជារូបភាពដោយផ្ទាល់នៅទីភ្នែក, ភ្នែកក៏ដូចជាកែវថតរបស់កាមេរ៉ា, គ្រាន់តែមានមុខងារជាប្រភេទឧបករណ៍មួយ។ មើលកន្លែងឆ្ងាយ, កែវថតនឹងលាតសន្ធឹង, ភ្នែករបស់ពួកយើងក៏បម្រើមុខងារបែបនេះ; មើលកន្លែងងងឹត, រន្ធប្រស្រីចាំបាច់ពង្រីកធំ, កាមេរ៉ានៅពេលថតរូបកន្លែងងងឹត, រន្ធកែវថតចាំបាច់ពង្រីកធំ, បើមិនដូច្នោះទេ, ការប៉ះពាល់នឹងពន្លឺមិនគ្រប់គ្រាន់, សុទ្ធតែជាងងឹត។ ដើរទៅកន្លែងភ្លឺខ្លាំងនៅខាងក្រៅ, រន្ធប្រស្រីចាំបាច់ភ្លាមៗបង្រួមតូច, បើមិនដូច្នោះទេ, ស្រវាំងភ្នែក, មើលអ្វីក៏មិនច្បាស់, កាមេរ៉ាក៏ជាគោលការណ៍នេះ, រន្ធកែវថតក៏ចាំបាច់បង្រួមតូច។ វាគ្រាន់តែអាចចាប់យកវត្ថុប៉ុណ្ណោះ, វាគ្រាន់តែជាឧបករណ៍មួយប្រភេទ។ ពួកយើងមើលឃើញអ្វីមួយពិតប្រាកដ, ឃើញមនុស្សម្នាក់, ឃើញទម្រង់វត្ថុមួយស្ថិតនៅ, គឺបង្កជារូបភាពនៅលើខួរធំរបស់មនុស្ស។ ក៏ជាក់ស្តែងគឺតាមរយៈភ្នែករបស់មនុស្សដើម្បីមើល, ម្តងទៀតតាមរយៈសរសៃប្រសាទភ្នែកបញ្ជូនដល់ក្រពេញស្រល់នៅពាក់កណ្តាលផ្នែកខាងក្រោយខួរធំ, នៅក្នុងតំបន់នេះធ្វើឲ្យវាបញ្ចាំងចេញជារូបភាព។ ពោលគឺបញ្ចាំងរូបភាពពិតប្រាកដមើលឃើញអ្វីមួយ, គឺជាផ្នែកក្រពេញស្រល់នៃខួរធំរបស់ពួកយើង, វេជ្ជសាស្ត្រទំនើបក៏ទទួលស្គាល់ចំណុចមួយនេះ។

បើកភ្នែកទិព្វដែលយើងខ្ញុំសម្តែងជាក់ស្តែងគឺចៀសវាងបើកសរសៃ

ប្រសាទភ្នែករបស់មនុស្ស, នៅចន្លោះចិញ្ចើមទាំងពីររបស់មនុស្សវាយចេញផ្លូវរន្ធមួយ, ធ្វើឱ្យក្រពេញស្រល់មើលចេញខាងក្រៅដោយផ្ទាល់, នេះគឺហៅថាបើកភ្នែកទិព្វ។ មនុស្សខ្លះកំពុងគិតថា៖ នេះក៏មិនតថភាពអ៊ំា, យ៉ាងណាមិញគូនេត្រានេះក៏អាចបម្រើមុខងារជាឧបករណ៍, វាអាចចាប់យកវត្ថុ, គ្មានភ្នែកក៏មិនបាន។ នៅក្នុងកាយវិភាគសាស្ត្របានរកឃើញថា, ពាក់កណ្តាលផ្នែកខាងមុខរបស់ក្រពេញស្រល់, វាមានគ្រប់គ្រាន់ទាំងអស់រចនាសម្ព័ន្ធនៃភ្នែករបស់មនុស្ស។ ដោយសារវាលូតលាស់នៅខាងក្នុងលលាដ៏ក្បាលរបស់មនុស្ស, ដូច្នេះវាបានគេសម្តែងថាជាភ្នែកមួយដែលនៅតែស្នាម។ ជាភ្នែកមួយដែលនៅតែស្នាមមែនឬអត់, ពិភពបួសហាត់យើងខ្ញុំនៅតែរក្សាអាកប្បកិរិយា។ ប៉ុន្តែយ៉ាងណាមិញវេជ្ជសាស្ត្របានយល់ដឹងថាលើទីតាំងនោះនៅក្នុងខួរក្បាលរបស់មនុស្សមានភ្នែកមួយ។ យើងខ្ញុំវាយចេញផ្លូវរន្ធមួយគាប់ជួនតម្រង់ផ្ទាល់ចំណុចមួយនេះរបស់វា, គាប់ជួនសមស្របទៅនឹងការយល់ដឹងរបស់វិទ្យាសាស្ត្រទំនើប។ ភ្នែកមួយនេះគឺនឹងមិនដូចគូនេត្រាសាច់នេះរបស់ពួកយើងបង្កើតភាពមិនពិតដល់មនុស្ស, វាអាចមើលឃើញធាតុដើមរបស់រឿងការណ៍, មើលឃើញធាតុដើមរបស់សារធាតុ។ ដូច្នេះមនុស្សមានជាន់ថ្នាក់ភ្នែកទិព្វដ៏ខ្ពស់, គាត់អាចឆ្លងផ្លុះអវកាសរបស់ពួកយើងមើលឃើញវេលា-អាវកាសផ្សេង, អាចមើលឃើញទស្សនីយភាពដែលមនុស្សសាមញ្ញមើលមិនឃើញ; មនុស្សដែលជាន់ថ្នាក់មិនខ្ពស់អាចមានកម្លាំងឆ្លងផ្លុះ, បាំងជញ្ជាំងមើលវត្ថុ, មើលធ្លុះរាងកាយមនុស្ស, គាត់គឺមានគ្រប់គ្រាន់ប្រភេទសីលគង់មួយបែបនេះ។

ពុទ្ធវង្សសម្តែង៥ចក្ខុវិស័យ៖ សាច់ចក្ខុវិស័យ, ទិព្វចក្ខុវិស័យ, បញ្ញាចក្ខុវិស័យ, ធម៌ចក្ខុវិស័យ, ពុទ្ធចក្ខុវិស័យ។ នេះគឺ៥ជាន់ថ្នាក់ធំរបស់ភ្នែក

ទិព្វ, ជាន់ថ្នាក់នីមួយៗនៅបែងចែកជាលើ, កណ្តាល, ក្រោម។ តាវវង្ស សម្តែងប្រាំបួនប្រាំបួនដងប៉ែតសិបមួយជាន់ចក្ខុវិស័យ។ យើងខ្ញុំទីនេះ បើកភ្នែកទិព្វឲ្យអ្នករាល់គ្នា, ប៉ុន្តែមិនបើកដល់ទិព្វចក្ខុវិស័យចុះក្រោម។ ហេតុអ្វី? ទោះបីលោកអ្នកអង្គុយនៅទីនេះចាប់ផ្តើមបួសហាត់រួចហើយក្តី, ប៉ុន្តែលោកអ្នកយ៉ាងណាមិញគឺទើបតែចាប់ផ្តើមបោះជំហានពីក្នុងមនុស្សសាមញ្ញ, មានចិត្តប្រកាន់របស់មនុស្សសាមញ្ញជាច្រើននៅតែមិនទាន់ដាក់ចុះ។ ប្រសិនជាបើកដល់ទិព្វចក្ខុវិស័យចុះក្រោម, លោកអ្នកនឹងលេចឡើងអ្វីដែលមនុស្សសាមញ្ញបានសន្មតថាជាសីលគង់ពិសេស, លោកអ្នកនឹងបាំងជញ្ជាំងមើលវត្ថុ, មើលធ្លុះរាងកាយមនុស្ស។ បើសិនជាយើងខ្ញុំយកសីលគង់បែបនេះបង្រៀនលើទ្រង់ទ្រាយធំ, នរណាៗក៏បានបើកដល់កម្រិតប្រភេទនេះ, គឺនឹងជ្រៀតជ្រែកធ្ងន់ធ្ងរដល់សង្គមមនុស្សសាមញ្ញ, បំផ្លាញស្ថានភាពសង្គមមនុស្សសាមញ្ញ។ អាថ៌កំបាំងប្រទេសជាតិក៏មិនអាចការពារបាន; គេស្លៀកឬមិនស្លៀកខោអាវក៏ដូចគ្នាផងដែរ; មនុស្សនៅក្នុងបន្ទប់, លោកអ្នកនៅខាងក្រៅសុទ្ធតែមើលឃើញបាន; ដើរនៅតាមផ្លូវមើលឃើញសំបុត្រឆ្នោត, សំបុត្រលេខ១សុទ្ធតែត្រូវបានលោកអ្នកប៉ះត្រូវ, នេះគឺមិនបាន! អ្នករាល់គ្នាគិតសាកមើល, ម្នាក់ៗសុទ្ធតែបានបើកភ្នែកទិព្វដល់ទិព្វចក្ខុវិស័យ, នោះជាសង្គមមនុស្សជាតិឬ? បាតុភូតដែលជ្រៀតជ្រែកធ្ងន់ធ្ងរដល់សង្គមមនុស្សជាតិគឺជាដាច់ខាតមិនអនុញ្ញាតឲ្យស្ថិតនៅ។ ខ្ញុំប្រសិនពិតជាបើកឲ្យលោកអ្នកដល់ជាន់ថ្នាក់មួយនេះ, លោកអ្នកអាចភ្លាមៗនោះនឹងធ្វើជាគ្រូឈីគង់។ មានមនុស្សអតីតកាលគឺចង់ធ្វើគ្រូឈីគង់, ពេលនេះបានបើកភ្នែកទិព្វរួចហើយ, គាត់ជួនអាចពិនិត្យជំងឺឲ្យមនុស្ស។ ខ្ញុំមិនមែននាំលោកអ្នកទៅលើផ្លូវទុច្ចរិតហើយឬ?

ដូច្នោះខ្ញុំបើកឲ្យលោកអ្នកដល់ជាន់ថ្នាក់មួយណា? ខ្ញុំបើកឲ្យលោកអ្នកដោយផ្ទាល់ដល់ជាន់ថ្នាក់បញ្ញាចក្ខុវិស័យនេះ។ បើកឆ្ពោះឡើងជាន់ថ្នាក់ខ្ពស់, ចិត្តចរិតលោកអ្នកមិនគ្រប់; បើកឆ្ពោះចុះជាន់ថ្នាក់ទាប, នឹងបំផ្លាញធ្ងន់ធ្ងរដល់ស្ថានភាពសង្គមមនុស្សសាមញ្ញ។ បើកដល់បញ្ញាចក្ខុវិស័យ, លោកអ្នកគ្មានគ្រប់គ្រាន់អានុភាពបាំងជញ្ជាំងមើលវត្ថុ, មើលធ្លុះរាងកាយមនុស្ស, ប៉ុន្តែផ្ទុយមកវិញលោកអ្នកអាចមើលឃើញទស្សនីយភាពស្ថិតនៅទីអវកាសផ្សេង។ នេះមានកន្លែងល្អអ្វី? វាអាចបង្កើនជំនឿចិត្តហាត់គង់របស់លោកអ្នក, លោកអ្នកយ៉ាងជាក់ស្ដែងបានមើលឃើញប្រការដែលមនុស្សសាមញ្ញមើលមិនឃើញ, លោកអ្នកនឹងមានអារម្មណ៍ថាវាគឺជាអត្ថិភាពដោយពិតប្រាកដ។ បច្ចុប្បន្នមិនថាលោកអ្នកមើលច្បាស់ក៏ដោយ, មើលមិនច្បាស់ក៏ដោយ, សុទ្ធតែបើកឲ្យលោកអ្នកដល់ជាន់ថ្នាក់មួយនេះ, ចំពោះការហាត់គង់របស់លោកអ្នកគឺមានកន្លែងល្អ។ មនុស្សដែលបួសមហាធម៌ពិតប្រាកដ, តឹងរឹងតម្រូវលើកកម្ពស់ចិត្តចរិត, អានសៀវភៅនេះក៏មានប្រសិទ្ធភាពដូចគ្នា។

ប្រការដែលកំណត់ជាន់ថ្នាក់ភ្នែកទិព្វរបស់មនុស្សជាអ្វី? មិនមែនបន្ទាប់ពីបើកភ្នែកទិព្វឲ្យលោកអ្នករួចហើយគឺអ្វីក៏អាចមើលឃើញ, មិនមែនជាបែបនេះ, វានៅមានការបែងចែកនៃមួយជាន់ថ្នាក់។ ដូច្នោះជាន់ថ្នាក់នេះគឺដោយបានអ្វីកំណត់? មាន៣កត្តា៖ កត្តាទីមួយជាក់ស្ដែងគឺពីក្នុងដល់ក្រៅភ្នែកទិព្វរបស់មនុស្សចាំបាច់ត្រូវមានវាលមួយ, យើងខ្ញុំហៅវាថាជាឈីសារៈ។ វាផ្ដើមផលប៉ះពាល់អ្វី? ដូចជាអេក្រង់របស់ទូរទស្សន៍, ប្រសិនជាគ្មានផូស្វ័រ, ដូច្នោះបន្ទាប់ពីបើកទូរទស្សន៍, វាជាក់ស្ដែងគឺជាអំពូលភ្លើង, មានតែពន្លឺ, គ្មានរូបភាព។ ដោយសារមានផូស្វ័រ, វាទើបអាចបង្ហាញរូបភាពចេញមកបាន។ ប្រាកដណាស់ឧទាហរណ៍នេះក៏មិនសូវ

សមរម្យយ៉ាងនោះ។ ដោយសារពួកយើងគឺមើលដោយផ្ទាល់, វាគឺតាមរយៈទទួលពន្លឺពីគេដើម្បីលាតត្រដាង, និយាយរួមជាក់ស្តែងគឺមានន័យយ៉ាងនោះ។ ឈើសារៈបន្តិចនេះគឺដ៏មានតម្លៃបំផុត, បានផ្សំឡើងពីរបស់កាន់តែសារៈដែលចម្រាញ់ចេញមកពីក្នុងគុណធម៌។ ជាញឹកញាប់ឈើសារៈដែលស្ថិតនៅក្នុងឯកជនម្នាក់ៗសុទ្ធតែមិនដូចគ្នា, ប្រហែលជាក្នុងចំណោមមនុស្សមួយម៉ឺននាក់អាចរកចេញមនុស្សពីរនាក់នៅក្នុងមួយជាន់ថ្នាក់។

ជាន់ថ្នាក់ភ្នែកទិព្វដោយផ្ទាល់ជាក់ស្តែងគឺជាការបង្ហាញនៃធម៌ក្នុងចក្រវាលនេះរបស់ពួកយើង។ គាត់ជាប្រការវិសាមញ្ញ, និងចិត្តចរិតរបស់មនុស្សគឺទាក់ទងយ៉ាងជិតស្និទ្ធ, ចិត្តចរិតរបស់ឯកជនម្នាក់ទាប, ជាន់ថ្នាក់របស់គាត់នឹងទាប។ ដោយសារចិត្តចរិតទាប, ឈើសារៈបន្តិចនេះរបស់គាត់នឹងខ្ទាត់បាត់ច្រើន; ហើយចិត្តចរិតឯកជននេះដ៏ខ្ពស់, គាត់ពីតូចដល់ធំនៅក្នុងសង្គមមនុស្សសាមញ្ញ, ចំពោះកិត្តិនាម, ផលប្រយោជន៍, ទំនាស់រវាងមនុស្សនិងមនុស្ស, ប្រយោជន៍ឯកជន, ស្នេហា៧តណ្ហា៦មើលដ៏ស្រាល, ឈើសារៈអាចរក្សាបានល្អបង្គួរ, ដូច្នេះបន្ទាប់ពីវាយបើកភ្នែកទិព្វ, នឹងមើលឃើញច្បាស់លាស់បង្គួរ។ កុមារអាយុ៦ឆ្នាំចុះក្រោម, បន្ទាប់ពីវាយបើកមើលបានសែនច្បាស់លាស់, ក៏ងាយស្រួលវាយបើក, {ខ្ញុំ}និយាយមួយម៉ាត់នឹងអាចវាយបើក។

បំពុលរបស់លំហូរធំ, ធុងជ្រលក់ពណ៌ធំនៃសង្គមមនុស្សសាមញ្ញ, គេសន្មតថាជារឿងរ៉ាវដែលត្រូវ, ភាពពិតច្រើនណាស់សុទ្ធតែជាខុស។ មនុស្សនរណាមិនចង់ខ្លួនឯងរស់បានល្អ? ចង់រស់បានល្អ, អាចនឹងធ្វើខូចខាតផលប្រយោជន៍របស់អ្នកដទៃ, អាចនឹងសំលៀងចិត្តសាស្ត្រអាត្មានិយមរបស់មនុស្ស, អាចនឹងកាន់កាប់ផលប្រយោជន៍របស់អ្នក

ដទៃ, សម្លុតអ្នកដទៃ, ធ្វើបាបអ្នកដទៃ។ ដើម្បីផលប្រយោជន៍ឯកជន, គឺនៅក្នុងមនុស្សសាមញ្ញទៅប្រជែងទៅប្រយុទ្ធ, នេះមិនផ្ទុយមកវិញនឹងចរិតពិសេសនៃចក្រវាលហើយឬ? ដូច្នេះប្រការដែលមនុស្សសន្មតថាត្រូវ, វាក៏មិនប្រាកដថាជាត្រូវ។ ពេលអប់រំចំពោះកុមារ, មនុស្សធំជាញឹកញាប់ដើម្បីអនាគតរបស់គាត់អាចមានកន្លែងឈរជើងនៅក្នុងសង្គមមនុស្សសាមញ្ញ, ពីតូចគឺអប់រំថា [កូនត្រូវរៀនវៃបន្តិច]។ [វៃ] នៅក្នុងចក្រវាលពួកយើងនេះសង្កេតមើលបានជាខុសរួចហើយ, ដោយសារពួកយើងសម្ដែងថាបណ្ដោយតាមធម្មជាតិ, ចំពោះផលប្រយោជន៍ឯកជនត្រូវមើលឱ្យស្រាល។ គាត់វាងវៃយ៉ាងនេះ, ជាក់ស្ដែងគឺដើម្បីស្វែងរកផលប្រយោជន៍ឯកជន។ [នរណាសម្លុតកូន, កូនរកគ្រូរបស់គាត់, រកអាណាព្យាបាលរបស់គាត់], [មើលឃើញលុយកូនត្រូវតែរើស], គឺអប់រំគាត់បែបនេះ។ ពីតូចដល់ធំប្រការដែលកុមារនេះទទួលយកជាច្រើន, ជាបណ្ដើរចិត្តសាស្ត្រអាត្មានិយមរបស់គាត់នៅក្នុងសង្គមមនុស្សសាមញ្ញកាន់តែធំ, គាត់នឹងកាន់កាប់ភាពងាយស្រួល, គាត់នឹងខូតខាតគុណធម៌។

គុណធម៌ប្រភេទសារធាតុនេះបន្ទាប់ពីបាត់បង់រួចហើយវានឹងមិនខ្វាត់បាត់, វាបំប្លែងឲ្យអ្នកដទៃ, ប៉ុន្តែប្រភេទឈីសារៈនេះវានឹងខ្វាត់បាត់។ ប្រសិនជាឯកជននេះពីតូចដល់ធំដ៏វាងវៃ, ផលប្រយោជន៍ឯកជនដ៏ខ្លាំង, ផលចំណេញមកមុន, ជាញឹកញាប់ភ្នែកទិព្វរបស់មនុស្សប្រភេទនេះបន្ទាប់ពីវាយបើករួចហើយក៏ប្រើមិនបាន, ក៏មើលមិនច្បាស់, ប៉ុន្តែក៏មិនមែននិយាយថាពីពេលនេះតទៅប្រើមិនបានជានិច្ច។ ហេតុអ្វីពួកយើងនៅក្នុងដំណើរការបួសហាត់ជាក់ស្ដែងគឺត្រូវតែត្រឡប់ដើមមកសច្ចៈ, បន្តហាត់គង់, ក៏កំពុងបន្តផ្គត់ផ្គង់ឡើងវិញ, សំណាងសាជាថ្មី។ ដូច្នេះត្រូវសម្ដែងចិត្តចរិត, យើងខ្ញុំសម្ដែងលើកកម្ពស់ទាំងមូល, ថ្មើង

ឡើងទាំងមូល។ ចិត្តចរិតឡើងលើរួចហើយ, អ្វីៗផ្សេងនឹងឡើងលើតាម; ចិត្តចរិតឡើងលើមិនបាន, ឈើសារៈបន្តិចនោះនៃភ្នែកទិព្វក៏នឹងមិនផ្គត់ផ្គង់ឡើងវិញបាន, ជាក់ស្ដែងជាគោលសីលធម៌នេះ។

កត្តាទីពីរនោះគឺនៅពេលដែលខ្លួនឯងហាត់គង់, ប្រសិននិស្ស័យល្អ, ក៏អាចហាត់ឲ្យភ្នែកទិព្វបើក។ ជាញឹកញាប់មនុស្សខ្លះភ្នែកទិព្វទើបបើកភ្លាមនោះ, ក៏ភ្ញាក់ផ្អើល។ ហេតុអ្វីភ្ញាក់ផ្អើល? ដោយសារជាធម្មតាហាត់គង់សុទ្ធតែជ្រើសរើសនៅកណ្ដាលអធ្រាត្រ, ពេលយប់ជ្រៅស្ងាត់មនុស្ស។ គាត់កំពុងហាត់ៗ, ស្រាប់តែមើលឃើញភ្នែកធំមួយនៅចំពោះមុខ, ភ្លាមៗធ្វើឲ្យគាត់ភ្ញាក់ផ្អើល។ ការបន្លាចនេះមិនមែនរឿងតូចតាច, ពីពេលនេះតទៅក៏មិនហ៊ានហាត់ម្ដងទៀត។ នេះគួរឲ្យខ្លាចណាស់! ភ្នែកមួយធំយ៉ាងនេះ, មើលភ្លឹបភ្លែតៗ, ច្បាស់លាស់ណាស់។ ដូច្នេះមនុស្សខ្លះយកវាហៅថាភ្នែកខ្មោច, ក៏មានមនុស្សហៅថាពុទ្ធនេត្រជាដើម, ភាពពិតវាជាក់ស្ដែងគឺភ្នែករបស់លោកអ្នកខ្លួនឯង។ ប្រាកដណាស់, បួសនៅខ្លួនឯង, គង់នៅលោកគ្រូ។ ដំណើរការវិវត្តន៍គង់ទាំងមូលរបស់មនុស្សបួសហាត់, នៅក្នុងអវកាសផ្សេងគឺជាដំណើរការមួយដ៏ស្មុគស្មាញ, ក៏មិនមែនមួយអវកាសផ្សេង, អវកាសទាំងអស់, រាងកាយក្នុងគ្រប់អវកាសសុទ្ធតែកំពុងកើតឡើងការផ្លាស់ប្រែ។ លោកអ្នកខ្លួនឯងអាចធ្វើបានឬ? ធ្វើមិនបាន។ រឿងរ៉ាវទាំងនេះគឺដោយសារលោកគ្រូរៀបចំ, លោកគ្រូកំពុងធ្វើ, ដូច្នេះហៅថាបួសនៅខ្លួនឯង, គង់នៅលោកគ្រូ។ លោកអ្នកខ្លួនឯងគ្រាន់តែមានបំណងនេះ, ទៅគិតបែបនេះ, រឿងរ៉ាវពិតប្រាកដនោះគឺលោកគ្រូធ្វើឲ្យ។

មានមនុស្សមួយចំនួនគឺខ្លួនឯងហាត់បើកភ្នែកទិព្វ, យើងខ្ញុំសម្ដែងគឺជាភ្នែករបស់លោកអ្នក, ប៉ុន្តែលោកអ្នកខ្លួនឯងវិវត្តចេញមិនបាន។

មនុស្សខ្លះមានលោកគ្រូ, លោកគ្រូមើលឃើញភ្នែកទិព្វលោកអ្នកបានបើករួចហើយ, នឹងវិវត្តភ្នែកមួយឲ្យលោកអ្នក, នោះហៅថាសច្ចនេត្រ។ ប្រាកដណាស់មានមនុស្សមួយចំនួនគ្មានលោកគ្រូ, ប៉ុន្តែផ្ទុយមកវិញមានលោកគ្រូដើរកាត់មួយ។ ពុទ្ធវង្សសម្តែង៖ "ពុទ្ធគ្មានទីណាមិននៅ", ដល់កន្លែងណាក៏មាន, ច្រើនដល់កម្រិតប្រភេទនេះ, ក៏មានមនុស្សសម្តែង៖ "លើក្បាលបីឆឺមានអាទិទេព", ពោលគឺច្រើនខ្លាំងណាស់។ លោកគ្រូដើរកាត់ពេលមើលឃើញលោកអ្នកហាត់បានយ៉ាងល្អ, ភ្នែកទិព្វបានបើករួចហើយ, កង្វះតែភ្នែកមួយ, នឹងវិវត្ត{ភ្នែក}មួយផ្តល់ឲ្យលោកអ្នក, នេះក៏បានចាត់ថាលោកអ្នកហាត់ចេញមកដោយខ្លួនឯង។ ដោយសារព្រោះមនុស្សមិនសម្តែងលក្ខខណ្ឌ, មិនសម្តែងតម្លៃ, មិនគិតពីតបស្នង, ក៏មិនគិតពីកេរ្តិ៍ឈ្មោះ, ប្រៀបធៀបនឹងតួអង្គគំរូក្នុងមនុស្សសាមញ្ញគឺខ្ពស់ជាងច្រើនណាស់, នេះទាំងស្រុងគឺផុសពីចិត្តមេត្តា។

បន្ទាប់ពីបើកភ្នែកទិព្វរបស់មនុស្ស, នឹងលេចឡើងស្ថានភាពមួយប្រភេទ៖ ត្រូវពន្លឺចាំងខ្លាំងសម្បើមណាស់, មានអារម្មណ៍រំញោចភ្នែក។ ភាពពិតមិនមែនរំញោចភ្នែករបស់លោកអ្នក, តែគឺរំញោចក្រពេញស្រល់របស់លោកអ្នក, លោកអ្នកមានអារម្មណ៍ហាក់ដូចជាគឺរំញោចភ្នែក។ នោះជាក់ស្តែងគឺលោកអ្នកនៅមិនទាន់មានភ្នែកមួយនេះ, បន្ទាប់ពីដំឡើងឲ្យលោកអ្នកភ្នែកមួយនេះ, លោកអ្នកគឺនឹងគ្មានទទួលដឹងបានការរំញោចទៀត។ មនុស្សមួយភាគរបស់ពួកយើងនឹងទទួលដឹងបាន, ឃើញបានភ្នែកមួយនេះ។ ដោយសារវានិងចរិតដើមរបស់ចក្រវាលគឺដូចគ្នា, វាដ៏ឆោតត្រង់, ក៏ដ៏ចង់ដឹងចង់ឃើញ, ក៏ឆ្លោះចូលក្នុងដើម្បីមើល, មើលភ្នែកទិព្វលោកអ្នកបើកហើយឬនៅ, អាចមើលហើយឬនៅ, វាក៏ឆ្លោះចូលខាងក្នុងសម្លឹងមើលលោកអ្នក។ នៅពេលនេះភ្នែកទិព្វលោកអ្នកបាន

បើករួចហើយ, វាកំពុងមើលលោកអ្នក, ស្រាប់តែពេលលោកអ្នកមើលឃើញវាក៏ភ្ញាក់ផ្អើល។ ភាពពិតនេះជាក់ស្ដែងគឺជាភ្នែករបស់លោកអ្នក, ពីពេលនេះតទៅម្ដងទៀតលោកអ្នកមើលអ្វីមួយក៏តាមរយៈភ្នែកនេះដើម្បីមើល, លោកអ្នកគ្មានភ្នែកនេះជាមូលដ្ឋាននឹងមើលមិនបាន, បើករួចហើយក៏មើលមិនបាន។

កត្តាទីបីជាក់ស្ដែងគឺទម្លុះជាន់ថ្នាក់លាតត្រដាងចេញភាពទីទៃពីគ្នារបស់បណ្ដាអវកាស, នេះជាក់ស្ដែងជាបញ្ហាពិតប្រាកដដែលកំណត់ជាន់ថ្នាក់។ ដើម្បីមើលអ្វីមួយក្រៅពីផ្លូវរន្ធចម្បង, មនុស្សនៅមានផ្លូវរន្ធរងជាច្រើនទៀត។ ពុទ្ធវង្សសម្ដែងថារន្ធរោមនីមួយៗសុទ្ធតែជាភ្នែកមួយ; តាវវង្សសម្ដែងឈាវទាំងអស់នៃរាងកាយសុទ្ធជាភ្នែក, នោះគឺស្មៀរ៉ីទាំងអស់សុទ្ធតែជាភ្នែក។ ប្រាកដណាស់ដែលគាត់សម្ដែងក៏ជាប្រភេទទម្រង់មួយនៃការវិវត្តន៍របស់ធម៌នៅលើរាងកាយ, គ្មានកន្លែងណាមិនអាចមើល។

ជាន់ថ្នាក់ដែលពួកយើងសម្ដែងនិង{ប្រការ}នេះនៅតែមិនដូចគ្នា។ ក្រៅពីផ្លូវរន្ធចម្បង, នៅចិញ្ចើមទាំងពីរ, ខាងលើត្របកភ្នែក, ខាងក្រោមត្របកភ្នែកនិងសានកិនមានផ្លូវរន្ធរងសំខាន់មួយចំនួន។ ពួកវាជាក់ស្ដែងបានកំណត់បញ្ហាទម្លុះជាន់ថ្នាក់។ ប្រាកដណាស់មនុស្សបួសហាត់ធម្មតា, ប្រសិនជាប៉ុន្មានកន្លែងនេះសុទ្ធតែអាចមើលឃើញ, ជាន់ថ្នាក់ដែលឯកជននេះទម្លុះបានខ្ពស់ណាស់រួចហើយ។ មនុស្សខ្លះភ្នែកក៏អាចមើលឃើញ, គាត់ក៏បួសហាត់សម្រេចភ្នែករបស់គាត់រួចហើយ, ក៏មានគ្រប់គ្រាន់ទម្រង់សីលគង់គ្រប់ប្រភេទ។ ប៉ុន្តែភ្នែកនេះប្រសិនជាធ្វើម្ចាស់ការមិនបានល្អ, គាត់រមែងមើលឃើញបុគ្គលនេះមើលមិនឃើញបុគ្គលនោះ, ក៏មិនបាន, ដូច្នេះមនុស្សខ្លះជាញឹកញាប់ភ្នែកមួយមើលខាងនោះភ្នែកមួយមើលខាងនេះ។ ហើយខាងក្រោមភ្នែកមួយនេះ (ភ្នែកស្ដាំ) គ្មាន

ផ្លូវវន្ទរង, ដោយសារនេះនិងធម៌មានទំនាក់ទំនងដោយផ្ទាល់, គេធ្វើរឿងរ៉ាវមិនល្អច្រើនតែប្រើភ្នែកស្តាំ, ដូច្នេះនៅក្រោមភ្នែកខាងស្តាំគ្មានផ្លូវវន្ទរង។ នេះគឺសំដៅលើផ្លូវវន្ទរងសំខាន់មួយចំនួនដែលលេចឡើងនៅក្នុងបួសហាត់លោកីយ៍ធម៌។

ដល់ជាន់ថ្នាក់យ៉ាងខ្ពស់បំផុត, បន្ទាប់ពីដើរ{ឆ្លង}បួសហាត់ផុតពីលោកីយ៍ធម៌, ក៏នឹងលេចឡើងភ្នែកមួយប្រភេទមើលទៅដូចជាភ្នែកស្មុគស្មាញ, នោះគឺនៅពាក់កណ្តាលខាងលើនៃមុខទាំងមូលនឹងសាងបង្កើតភ្នែកធំមួយ, ខាងក្នុងមានអនេកភ្នែកតូចៗ។ មានអង្គមហាត្រាស់ដឹងដ៏ខ្ពស់ខ្លះបួសហាត់ចេញបានភ្នែកច្រើនពិសេស, ពេញផ្ទៃមុខ។ ភ្នែកទាំងអស់សុទ្ធតែតាមរយៈភ្នែកធំមួយនេះដើម្បីមើល, ចង់មើលអីក៏ឃើញនោះ, ក្រឡេកមួយមើលឃើញជាន់ថ្នាក់ទាំងអស់។ អ្នកសត្វសាស្ត្រ, អ្នកបាណកសាស្ត្របច្ចុប្បន្នស្រាវជ្រាវរុយខៀវ។ ភ្នែករបស់រុយខៀវធំណាស់, ប្រើមីក្រូទស្សន៍សង្កេតមើលកាលណា, ខាងក្នុងវានៅមានអនេកភ្នែកតូចៗ, បានហៅវាថាភ្នែកស្មុគស្មាញ។ ដល់ជាន់ថ្នាក់យ៉ាងខ្ពស់បំផុតរួចហើយអាចនឹងលេចឡើងស្ថានភាពនេះ, ខ្ពស់ជាងដ៏ច្រើនៗប្រៀបនឹងយូឡាយទើបអាចលេចឡើង។ ប៉ុន្តែផ្ទុយមកវិញមនុស្សសាមញ្ញមើលមិនឃើញ, ជាន់ថ្នាក់ធម្មតាក៏មើលមិនឃើញអត្ថិភាពរបស់វា, ឃើញតែដូចជាមនុស្សធម្មតា, ដោយសារវានៅអវកាសផ្សេង។ នេះគឺបានសម្តែងអំពីការទម្លុះជាន់ថ្នាក់រួចហើយ, ជាក់ស្តែងគឺជាបញ្ហាអាចទម្លុះបណ្តាអវកាស។

ខ្ញុំលើមូលដ្ឋានបានយករចនាសម្ព័ន្ធរបស់ភ្នែកទិព្វសម្តែងចេញឲ្យអ្នករាល់គ្នារួចហើយ។ យើងខ្ញុំប្រើកម្លាំងខាងក្រៅបើកភ្នែកទិព្វឲ្យលោកអ្នក, នឹងបានមកលឿនបង្គួរ, ងាយស្រួលបង្គួរ។ នៅពេលខ្ញុំកំពុង

សម្ដែងអំពីភ្នែកទិព្វ, ខាងមុខថ្ងាសរបស់មនុស្សម្នាក់ៗពួកយើងសុទ្ធតែនឹងមានអារម្មណ៍ឡើងតឹង, សាច់ប្រមូលផ្ដុំចូលគ្នា, ប្រមូលផ្ដុំមកខួងឆ្ពោះចូលក្នុង។ តើបែបនេះមែនទេ? គឺបែបនេះឯង។ ដរាបណាជាមនុស្សពិតប្រាកដដាក់ចិត្តចុះមករៀនហ្វាលូនតាហ្វាទីនេះ, នរណាៗសុទ្ធតែនឹងមានទទួលដឹងបាន, អំណាចនៅតែដ៏ធំ, រុញចូលទៅក្នុង។ យើងខ្ញុំវាយចេញគង់ឯកទេសសម្រាប់បើកភ្នែកទិព្វឲ្យលោកអ្នកកំពុងបើកភ្នែកទិព្វឲ្យលោកអ្នក, ក្នុងពេលដំណាលគ្នា, ក៏វាយចេញទៅហ្វាលូនកំពុងជួសជុលឲ្យលោកអ្នក។ នៅពេលយើងខ្ញុំកំពុងសម្ដែងអំពីភ្នែកទិព្វ, ដរាបណាគឺជាប្អូសហាត់ហ្វាលូនតាហ្វា, យើងខ្ញុំបើកឲ្យអ្នកគ្រប់គ្នា, ប៉ុន្តែមិនជាក់លាក់នរណាៗសុទ្ធតែអាចមើលបានច្បាស់, ក៏មិនជាក់លាក់នរណាៗសុទ្ធតែអាចមើលឃើញបាន, នេះជាមួយនឹងលោកអ្នកខ្លួនឯងមានទំនាក់ទំនងដោយផ្ទាល់។ កុំបារម្ភ, លោកអ្នកមើលមិនឃើញកុំបារម្ភ, ប្អូសហាត់សន្សឹមៗ។ ស្របតាមពេលដែលលោកអ្នកបន្តលើកកម្ពស់ជាន់ថ្នាក់, លោកអ្នកនឹងមើលឃើញបានបន្តិចម្ដងៗ, ពីមើលមិនឃើញនឹងបន្តិចម្ដងៗមើលបានច្បាស់។ ដរាបណាលោកអ្នកប្អូសហាត់, ពេលដែលលោកអ្នកដាក់ចិត្តនេះចុះដើម្បីប្អូស, ដែលលោកអ្នកខ្វាត់បាត់សុទ្ធតែនឹងផ្ដត់ផ្ដង់ឡើងវិញ។

បើកភ្នែកទិព្វដោយខ្លួនឯងលំបាកបង្គួរ។ ខ្ញុំសម្ដែងបន្តិចបើកភ្នែកទិព្វដោយខ្លួនឯងមានទម្រង់ប៉ុន្មានប្រភេទ។ ឧបមាថាពួកយើងមានមនុស្សខ្លះនៅពេលអង្គុយសមាធិសង្កេតខាងមុខថ្ងាស, សង្កេតភ្នែកទិព្វ, មានអារម្មណ៍ថាខាងមុខថ្ងាសខ្មៅងងឹត, អ្វីក៏គ្មាន។ ពេលវេលាយូរកាលណា, គាត់មានអារម្មណ៍ថាខាងមុខថ្ងាសសឡើងបន្តិចម្ដងៗ។ ប្អូសហាត់មួយដំណាក់កាលពេលវេលា, គាត់រកឃើញថាខាងមុខថ្ងាសភ្លឺ

ឡើងបន្តិចម្ដងៗ, បន្ទាប់ពីភ្លឺរួចហើយនឹងប្រែជាក្រហម។ ដល់ពេលនេះវានឹងរីកផ្កា, ដូចជាក្នុងភាពយន្ត, ទូរទស្សន៍បែបនោះ, ពន្លកផ្កាបានរីកភ្លាមៗ, នឹងលេចឡើងទស្សនីយភាពនេះ។ ពណ៌ក្រហមនោះដើមឡើយគឺជារាបស្មើ, មួយរំពេចប៉ោងឡើងពីកណ្ដាល, បន្តរីក, បន្តរីក។ លោកអ្នកចង់ខ្លួនឯងធ្វើឲ្យវារីកធ្លាយទាំងស្រុង, ១០ឆ្នាំ៨ឆ្នាំក៏មិនគ្រប់, ដោយសារភ្នែកទិព្វទាំងមូលត្រូវបានស្ទះទាំងស្រុងរួចហើយ។

ភ្នែកទិព្វមនុស្សខ្លះគ្មានស្ទះទាំងស្រុង, គាត់មានគ្រប់គ្រាន់ផ្លូវរន្ធ, ប៉ុន្តែដោយសារគាត់មិនហាត់គង់, ក៏គ្មានថាមពលស្ថិតនៅ, ដូច្នេះពេលដែលគាត់ហាត់គង់នឹងភ្លាមៗលេចឡើងខាងមុខភ្នែករបស់មួយមូលខ្មៅៗ។ ពេលវេលាហាត់គង់យូរកាលណា, វានឹងបន្តិចម្ដងៗសឡើង, ពីសដល់បន្តិចម្ដងៗប្រែជាភ្លឺ, ចុងក្រោយកាន់តែភ្លឺ, មានបន្តិចអារម្មណ៍រំញោចភ្នែក។ មនុស្សខ្លះក៏សម្ដែងថា៖ ខ្ញុំមើលឃើញព្រះអាទិត្យ, ខ្ញុំមើលឃើញព្រះចន្ទ។ ភាពពិតលោកអ្នកគ្មានមើលឃើញព្រះអាទិត្យ, ក៏គ្មានមើលឃើញព្រះចន្ទ។ ដូច្នោះដែលលោកអ្នកមើលឃើញជាអ្វី? ជាក់ស្ដែងគឺផ្លូវរន្ធនេះរបស់លោកអ្នក។ មនុស្សខ្លះជាន់ថ្នាក់ទម្លុះឆាប់រហ័សបង្គួរ, បន្ទាប់ពីដំឡើងភ្នែករួចហើយ, អាចមើលឃើញបានដោយផ្ទាល់។ មនុស្សខ្លះគឺពិបាកខ្លាំងណាស់, គាត់បណ្ដោយតាមផ្លូវរន្ធមួយនេះ, ដូចជាផ្លូវរូងក្រោមដីមួយ, ក៏មានខ្លះដូចជាអណ្ដូងមួយ, ហាត់គង់កាលណាក៏រត់ចេញទៅខាងក្រៅ, សូម្បីតែពេលគេងក៏មានអារម្មណ៍ថាខ្លួនឯងរត់ចេញទៅខាងក្រៅ។ អ្នកខ្លះមានអារម្មណ៍ដូចជាជិះសេះផាយ, អ្នកខ្លះកំពុងហើរ, អ្នកខ្លះកំពុងរត់, អ្នកខ្លះដូចជាអង្គុយនៅក្នុងឡានស្ទុះចេញទៅខាងក្រៅ, ប៉ុន្តែរមែងមានអារម្មណ៍ស្ទុះមិនដល់ក្បាល{ខាងនោះ}, ដោយសារបើកភ្នែកទិព្វដោយខ្លួនឯងគឺដ៏ពិបាក។ តាវវង្សចាត់ទុករាងកាយមនុស្ស

ជាចក្រវាលតូចមួយ, ប្រសិនជាចក្រវាលតូចមួយ, អ្នករាល់គ្នាគិតសាកមើល, ពីខាងមុខថ្ងាសដល់ក្រពេញស្រល់៨ម៉ឺន៤ពាន់លីក៏មិនគ្រប់, ដូច្នេះគាត់រមែងមានអារម្មណ៍ស្មុះចេញទៅខាងក្រៅ, រមែងស្មុះមិនដល់ក្បាល{ខាងនោះ}។

តាវវង្សចាត់ទុករាងកាយមនុស្សជាចក្រវាលតូចមួយ, ដ៏សមហេតុផល។ មិនមែននិយាយថារចនាសម្ព័ន្ធរៀបចំរបស់គាត់ប្រហាក់ប្រហែលនឹងចក្រវាល, ក៏មិនមែនសម្តែងអំពីទម្រង់អត្ថិភាពនៃរាងកាយក្នុងអវកាសសារធាតុនេះរបស់ពួកយើង។ យើងខ្ញុំសម្តែង, រាងកាយសារធាតុពីកោសិកាចុះក្រោមដែលវិទ្យាសាស្ត្របច្ចុប្បន្នយល់ដឹងបានគឺជាស្ថានភាពអ្វី? សមាសភាគម៉ូលេគុលគ្រប់ប្រភេទ, ក្រោមម៉ូលេគុលគឺជាអាតូម, ប្រូតុង, ស្នូលអាតូម, អេឡិចត្រុង, គ្រាប់ quark, បច្ចុប្បន្នស្រាវជ្រាវដល់ភាគល្អិតតូចបំផុតគឺជាគ្រាប់ neutrino។ ដូច្នោះដល់ភាគល្អិតតូចបំផុតៗជាអ្វី? ចង់ស្រាវជ្រាវពិតជាដ៏ពិបាក។ សក្យមុនីនៅវ័យចំណាស់បានសម្តែងប្រយោគមួយបែបនេះ, គាត់និយាយ៖ [ធំនោះគ្មានក្រៅ, តូចនោះគ្មានក្នុង]។ តើមានន័យថាយ៉ាងម៉េច? នៅលើជាន់ថ្នាក់យូឡាយនេះ, ធំ, មើលមិនឃើញព្រំដែនរបស់ចក្រវាល; តូច, មើលមិនឃើញភាគល្អិតតូចបំផុតរបស់សារធាតុ, ដូច្នេះគាត់បានសម្តែង [ធំនោះគ្មានក្រៅ, តូចនោះគ្មានក្នុង]។

សក្យមុនីក៏បានសម្តែងទ្រឹស្តី៣ពាន់មហាពិភព។ គាត់និយាយក្នុងចក្រវាលនេះរបស់ពួកយើង, ក្នុងប្រព័ន្ធកញ្ចុំផ្កាយនេះរបស់ពួកយើង, មាន៣ពាន់ភពផ្កាយដែលស្ថិតនៅសម្បូររាងកាយដូចជាមនុស្សជាតិពួកយើង។ គាត់ក៏បានសម្តែងក្នុងគ្រាប់ខ្សាច់មួយនៅមាន៣ពាន់មហាពិភពបែបនេះ។ គ្រាប់ខ្សាច់មួយដូចជាចក្រវាលមួយ, ខាងក្នុងនៅមានមនុស្ស

ដែលមានបញ្ញាបែបនេះដូចពួកយើង, មានភពផ្កាយបែបនេះ, ក៏មានភ្នំទន្លេព្រៃកទឹកហូរ។ ស្តាប់ទៅដ៏អាថ៌កំបាំង! ប្រសិនជាបែបនេះ, អ្នករាល់គ្នាគិតសាកមើល, ខាងក្នុងនោះរបស់វាមិនមែននៅមានគ្រាប់ខ្សាច់ឬ? ខាងក្នុងគ្រាប់ខ្សាច់នោះក៏មិនមែននៅមាន៣ពាន់មហាពិភពឬ? ដូច្នោះខាងក្នុង៣ពាន់មហាពិភពនោះមិនមែននៅមានគ្រាប់ខ្សាច់, ខាងក្នុងគ្រាប់ខ្សាច់នោះមិនមែននៅមាន៣ពាន់មហាពិភពឬ? ដូច្នេះនៅលើជាន់ថ្នាក់នេះរបស់យូឡាយមើលមិនឃើញចុងបញ្ចប់របស់វា។

កោសិកាម៉ូលេគុលរបស់មនុស្សក៏ដូចគ្នាផងដែរ។ គេសួរថាចក្រវាលធំប៉ុណ្ណា, ខ្ញុំប្រាប់អ្នករាល់គ្នា, ចក្រវាលនេះវាគឺមានព្រំដែន, ប៉ុន្តែនៅលើជាន់ថ្នាក់បែបនេះរបស់យូឡាយ, សុទ្ធតែមើលវាក្លាយជាគ្មានដែនគ្មានត្រើយ, ធំគ្មានកំណត់។ ហើយផ្នែកខាងក្នុងនៃរាងកាយមនុស្ស, ពីម៉ូលេគុលដល់ភាគល្អិតនៅអតិសុខុមចុះក្រោមនិងចក្រវាលនេះធំដូចគ្នា, ស្តាប់ទៅដ៏អាថ៌កំបាំង។ បង្កើតជាមនុស្សម្នាក់, ជីវិតមួយ, នៅយ៉ាងអតិសុខុមបំផុតចុះក្រោមបានផ្សំឡើងសមាសភាគជីវិតជាក់លាក់របស់គាត់, ធាតុដើមរបស់គាត់រួចហើយ។ ដូច្នេះវិទ្យាសាស្ត្រទំនើបរបស់ពួកយើងស្រាវជ្រាវប្រការនេះ, នៅតែខុសឆ្ងាយណាស់, ប្រៀបធៀបទៅនឹងបណ្តាជីវិតដែលស្ថិតនៅភពផ្កាយមានបញ្ញាកម្រិតខ្ពស់ក្នុងចក្រវាលទាំងមូល, កម្រិតបច្ចេកវិទ្យារបស់មនុស្សជាតិពួកយើងគឺទាបបង្អួរ។ ជាក់ស្តែងក្នុងពេលតែមួយកន្លែងតែមួយស្ថិតនៅអវកាសផ្សេងពួកយើងសុទ្ធតែទម្លុះមិនបាន, ហើយយានអវកាសក្រៅភពជាក់ស្តែងដើរនៅក្នុងអវកាសផ្សេងដោយផ្ទាល់, ទស្សនាទាននៃវេលា-អវកាសនោះសុទ្ធតែបានកើតឡើងការផ្លាស់ប្រែរួចហើយ, ដូច្នេះគាត់ថាមកគឺមក, ថាទៅគឺទៅ, ឆាប់រហ័សធ្វើឲ្យគោលគំនិតរបស់មនុស្សទទួលយកមិនបាន។

យើងខ្ញុំសម្តែងភ្នែកទិព្វនិយាយដល់បញ្ហាបែបនេះ, ដោយសារពេលដែលលោកអ្នកនៅក្នុងផ្លូវរន្ធរត់ឆ្ពោះចេញក្រៅ, លោកអ្នកនឹងមានអារម្មណ៍ថាវាគឺគ្មានដែនគ្មានត្រើយ។ មនុស្សខ្លះអាចមើលឃើញប្រភេទកាលៈទេសៈមួយផ្សេង៖ គាត់នឹងមានអារម្មណ៍ថាគាត់មិនមែនកំពុងរត់បណ្តោយតាមផ្លូវរន្ធក្រោមដី, ប៉ុន្តែគឺកំពុងរត់ឆ្ពោះទៅមុខបណ្តោយតាមមហាវិថីមួយដែលគ្មានដែនគ្មានត្រើយ, សងខាងផ្លូវមានភ្នំមានទឹកមានទីក្រុង, រហូតរត់ឆ្ពោះចេញក្រៅ, ស្តាប់ទៅកាន់តែអាថ៌កំបាំង។ ខ្ញុំចងចាំថាមានគ្រូឈីគង់ម្នាក់ធ្លាប់សម្តែងប្រយោគមួយបែបនេះ៖ គាត់និយាយថាខាងក្នុងរន្ធរោមមួយរបស់មនុស្សគឺមានទីក្រុងមួយ, ខាងក្នុងមានរថភ្លើងរថយន្តកំពុងរត់។ អ្នកដទៃស្តាប់ទៅមានអារម្មណ៍ដ៏ភ្ញាក់ផ្អើល, អាថ៌កំបាំងណាស់។ អ្នករាល់គ្នាបានដឹង, សារធាតុនៅអតិសុខុមចុះក្រោមមានម៉ូលេគុល, អាតូម, ប្រូត្រុង, ទីបំផុតស៊ើបអង្កេតបន្តឆ្ពោះចុះក្រោម, ប្រសិនជាន់នីមួយៗលោកអ្នកអាចមើលឃើញផ្ទៃមុខរបស់មួយជាន់នេះ, ហើយមិនមែនចំណុចមួយ, ផ្ទៃមុខនៃមួយជាន់ម៉ូលេគុល, ផ្ទៃមុខនៃមួយជាន់អាតូម, ផ្ទៃមុខនៃមួយជាន់ប្រូតុង, ផ្ទៃមុខនៃមួយជាន់ស្នូលអាតូម, លោកអ្នកគឺបានមើលឃើញទម្រង់អត្ថិភាពក្នុងអវកាសខុសគ្នារួចហើយ។ វត្ថុណាមួយរួមបញ្ចូលរាងកាយមនុស្សសុទ្ធតែនិងជាន់ថ្នាក់អវកាសនៃអវកាសចក្រវាលស្ថិតនៅក្នុងពេលដំណាលគ្នា, ផ្សារភ្ជាប់គ្នាទៅវិញទៅមក។ រូបវិទ្យាទំនើបពួកយើងស្រាវជ្រាវភាគល្អិតនៃសារធាតុ, គ្រាន់តែស្រាវជ្រាវភាគល្អិតមួយ, វិភាគវា, បំបែក, បន្ទាប់ពីបំបែកស្នូលអាតូមហើយម្តងទៀតស្រាវជ្រាវអំពីសមាសភាគបំប្លែងក្រោយមករបស់វា។ ប្រសិនជាមានឧបករណ៍បែបនេះបើកដំណើរការ, មើលក្នុងជាន់ថ្នាក់មួយនេះរបស់វា, ការបង្ហាញទាំងមូលនៃសមាសភាគអាតូមទាំងអស់ឬ

ក៏សមាសភាគម៉ូលេគុលនៅក្នុងជាន់មួយនេះ, ប្រសិនអាចមើលឃើញទស្សនីយភាពនេះ, លោកអ្នកជាក់ស្ដែងបានទម្លុះអវកាសនេះរួចហើយ, មើលឃើញសេចក្ដីពិតដែលស្ថិតនៅអវកាសផ្សេងរួចហើយ។ រាងកាយមនុស្សនិងអវកាសខាងក្រៅគឺឆ្លុះបញ្ចាំងជាមួយគ្នា, វាសុទ្ធតែស្ថិតនៅទម្រង់អត្ថិភាពបែបនេះ។

បើកភ្នែកទិព្វដោយខ្លួនឯងនៅមានស្ថានភាពខុសគ្នាមួយចំនួន, យើងខ្ញុំចម្បងសម្ដែងអំពីបាតុភូតទូទៅបង្គួរមួយចំនួន។ នៅមានមនុស្សមើលឃើញភ្នែកទិព្វកំពុងវិល, មនុស្សហាត់គង់តាវវង្សជាធម្មតាមើលឃើញខាងក្នុងភ្នែកទិព្វបង្វិល, ថាស់ថៃជី [ប៉ា] បំបែកបើកចេញ, បន្ទាប់មកគាត់មើលឃើញរូបភាព។ ប៉ុន្ដែនោះមិនមែនខាងក្នុងខួរក្បាលលោកអ្នកមានថៃជី, គឺលោកគ្រូពេលចាប់ផ្ដើមបានដំឡើងមួយសំណុំអ្វីៗឲ្យលោកអ្នក, មួយក្នុងចំណោមនោះគឺជាថៃជី, គាត់យកភ្នែកទិព្វលោកអ្នកបិទមកវិញ, ដល់ពេលដែលលោកអ្នកបើក, វាបំបែកបើកចេញ។ គាត់មានបំណងពិសេសរៀបចំសម្រាប់លោកអ្នក, មិនមែនក្នុងខួរក្បាលលោកអ្នកមានស្រាប់ពីមុន។

នៅមានមនុស្សមួយផ្នែកស្វែងរកបើកភ្នែកទិព្វ, ផ្ទុយមកវិញកាន់តែហាត់កាន់តែមិនបើក, មូលហេតុអ្វី? គាត់ខ្លួនឯងក៏មិនច្បាស់លាស់។ ចម្បងដោយសារភ្នែកទិព្វគឺមិនអាចចំណង់, កាន់តែចំណង់កាន់តែគ្មាន។ កាន់តែចំណង់, វាមិនត្រឹមតែមិនបើក, ផ្ទុយមកវិញពីខាងក្នុងភ្នែកទិព្វរបស់គាត់ក៏ហៀរចេញប្រភេទវត្ថុមួយ, ខ្មៅមិនខ្មៅ, សមិនស, វានឹងគ្របជិតភ្នែកទិព្វរបស់លោកអ្នក។ ពេលវេលាយូរក្រោយមក, វានឹងបង្កើតជាវាលមួយដ៏ធំ, កាន់តែហៀរចេញកាន់តែច្រើន។ ភ្នែកទិព្វកាន់តែមិនបើក, កាន់តែស្វែងរកវា, វត្ថុនេះហៀរចេញកាន់តែច្រើន, លទ្ធផល

សុទ្ធតែព័ទ្ធជាប់ជុំវិញរាងកាយទាំងមូលរបស់គាត់, ថៃមទាំងកម្រាស់របស់វាក៏ដ៏ធំ, បាននាំតាមវាលមួយដ៏ធំ។ ភ្នែកទិព្វឯកជននេះបើសិនពិតជាបើករួចហើយ, គាត់ក៏មើលមិនឃើញ, ដោយសារគាត់ត្រូវបានប្រភេទចិត្តប្រកាន់នេះរបស់ខ្លួនឯងបិទជិតរួចហើយ។ លុះត្រាតែអនាគតគាត់មិនទៅគិតអំពីវាទៀត, នៅពេលបោះចោលចិត្តប្រកាន់ប្រភេទនេះទាំងស្រុង, វានឹងខ្វាត់បាត់សន្សឹមៗ, ប៉ុន្តែត្រូវឆ្លងកាត់ដំណើរការបួសហាត់ដំណាក់កាលមួយយូរអង្វែងដ៏ទុក្ខលំបាកទើបអាចកម្ចាត់បាន, នេះគឺរឹតតែមិនចាំបាច់។ មនុស្សខ្លះគាត់មិនដឹង, លោកគ្រូប្រាប់គាត់ថាមិនអាចចំណង់, មិនអាចចំណង់, គាត់គឺមិនជឿ, តែងតែកំពុងចំណង់, លទ្ធផលផ្ទុយពីអ្វីដែលចង់បាន។

## សីលគង់ទូរនេត្រ

ប្រភេទសីលគង់មួយដែលមានទំនាក់ទំនងដោយផ្ទាល់នឹងភ្នែកទិព្វហៅថាទូរនេត្រ។ មានមនុស្សសម្តែង៖ ខ្ញុំអង្គុយនៅទីនេះអាចមើលឃើញទស្សនីយភាពរបស់ប៉េកាំង, មើលឃើញទស្សនីយភាពរបស់អាមេរិច, មើលឃើញម្ខាងនោះនៃផែនដី។ មានមនុស្សពន្យល់មិនបាន, តាមវិទ្យាសាស្ត្រក៏ពន្យល់មិនបាន, ហេតុម្តេចទៅជាបែបនេះ? មានមនុស្សពន្យល់យ៉ាងនេះ, ពន្យល់យ៉ាងនោះ, ក៏និយាយមិនបានធ្លុះធ្លាយ, សន្មតថាហេតុអ្វីមនុស្សមានអានុភាពធំយ៉ាងនេះ។ មិនមែនបែបនេះ, មនុស្សបួសហាត់នៅក្នុងជាន់ថ្នាក់នេះរបស់លោកីយ៍ធម៌គ្មានអានុភាពនេះ។ ប្រការដែលគាត់មើលឃើញ, រួមបញ្ចូលទូរនេត្រ, រួមបញ្ចូលសីលគង់ពិសេសដ៏ច្រើន, សុទ្ធតែជានៅក្នុងអវកាសពិសេសជាក់លាក់មួយផ្តើមផលប៉ះពាល់, ធំបំផុតក៏មិនលើសផុតពីអវកាសសារធាតុនេះដែលមនុស្សជាតិពួកយើងស្ថិតនៅ, ជាធម្មតាសុទ្ធតែមិនលើសហួសពីវាលអវ

កាសរបស់រាងកាយខ្លួនឯង។

រាងកាយពួកយើងនៅក្នុងអវកាសពិសេសជាក់លាក់មួយមានវាលមួយស្ថិតនៅ, វាលនេះនិងវាលគុណធម៌នោះក៏មិនមែនវាលតែមួយ, មិនមែនអវកាសមួយដូចគ្នា, តែវិសាលភាពវាលធំតូចគឺដូចគ្នា។ វាលនេះនិងចក្រវាលមានប្រភេទទំនាក់ទំនងឆ្លុះបញ្ចាំងមួយ, ចក្រវាលខាងនោះមានអ្វី, នៅក្នុងវាលនេះរបស់គាត់អាចឆ្លុះបញ្ចាំងឆ្លងមកអ្វី, សុទ្ធតែអាចឆ្លុះបញ្ចាំងឆ្លងមក។ វាគឺរូបស្រមោលមួយប្រភេទ, មិនមែនដោយពិតប្រាកដ។ ឧបមាលើផែនដីមានប្រទេសអាមេរិច, មានវ៉ាស៊ីនតោន; ក្នុងវាលរបស់គាត់ក៏បញ្ចាំងចេញប្រទេសអាមេរិច, បញ្ចាំងចេញវ៉ាស៊ីនតោន, ប៉ុន្តែវាគឺជាស្រមោល។ យ៉ាងណាមិញស្រមោលក៏ជាប្រភេទអត្ថិភាពសារធាតុមួយ, វាគឺជាទំនាក់ទំនងឆ្លុះបញ្ចាំងឆ្លងមក, ស្របតាមការប្រែប្រួលរបស់ខាងនោះហើយប្រែប្រួលតាម, ដូច្នេះសីលគង់ទូរនេត្រដែលមនុស្សខ្លះបាននិយាយ, ជាក់ស្ដែងគឺមើលឃើញអ្វីៗនៅខាងក្នុងវិសាលភាពវាលអវកាសរបស់គាត់ខ្លួនឯង។ បន្ទាប់ពីគាត់ដើរឆ្លងបួសហាត់ផុតពីលោកីយ៍ធម៌, ជាក់ស្ដែងមិនមែនមើលបែបនេះ, នោះគឺមើលដោយផ្ទាល់, ហៅថាទេពអំណាចពុទ្ធធម៌, នោះជាអ្វីមួយដែលមានអំណាចមិនអាចប្រៀបផ្ទឹម។

នៅក្នុងលោកីយ៍ធម៌សីលគង់ទូរនេត្រគឺជារឿងដូចម្ដេច? ខ្ញុំវិភាគចេញមកឲ្យអ្នករាល់គ្នា៖ នៅក្នុងអវកាសរបស់វាលនេះ, នៅទីតាំងខាងមុខថ្ងាសរបស់មនុស្សមានមុខកញ្ចក់មួយ, មនុស្សមិនហាត់គង់គឺផ្កាប់ចូល; មនុស្សហាត់គង់វាគឺវិលក្រឡាប់មកវិញ។ នៅពេលសីលគង់ទូរនេត្ររបស់មនុស្សជិតលេចឡើងមក, វានឹងវិលក្រឡាប់មកវិញ។ អ្នករាល់គ្នាបានដឹងខ្សែភាពយន្តមួយវិនាទី២៤រូបអាចធ្វើឲ្យចលនាមានភាព

ជាប់គ្នា, ពេលតិចជាង២៤រូបគឺមានអារម្មណ៍លោតញាក់។ ល្បឿនវិលក្រឡាប់របស់វាលើសហួសពី២៤រូបមួយវិនាទី, វាយកអ្វីដែលបញ្ចាំងដល់ផ្ចិតឡើងលើកញ្ចក់, វិលក្រឡាប់មកទុកឲ្យលោកអ្នកមើល, ម្តងទៀតបន្ទាប់ពីក្រឡាប់ទៅគឺលុបចោល។ ក្រោយមកបញ្ចាំងម្តងទៀត, ក្រឡាប់ម្តងទៀត, លុបម្តងទៀត, បន្តវិលក្រឡាប់, ដូច្នេះអ្វីដែលលោកអ្នកមើលឃើញគឺធ្វើចលនា, នេះជាក់ស្តែងគឺជាអ្វីវាបានបញ្ចាំងដល់ខាងក្នុងវាលអវកាសរបស់លោកអ្នកឲ្យលោកអ្នកមើល, ហើយអ្វីៗក្នុងវាលអវកាសគឺពីក្នុងមហាចក្រវាលឆ្លុះបញ្ចាំងឆ្លងមក។

ដូច្នោះខាងក្រោយរាងកាយមនុស្សធ្វើដូចម្តេចមើលបាន? កញ្ចក់តូចយ៉ាងនេះ, ជុំវិញរាងកាយមិនជាក់លាក់ទាំងអស់សុទ្ធតែបញ្ចាំងដល់បាន? អ្នករាល់គ្នាដឹង, ជាន់ថ្នាក់ភ្នែកទិព្វរបស់មនុស្សបើកដល់លើសហួសទិព្វចក្ខុវិស័យ, ពេលដែលជិតឈានចូលក្នុងបញ្ញាចក្ខុវិស័យ, គឺនឹងទម្លុះអវកាសនេះរបស់ពួកយើង។ ជាក់ស្តែងនៅចំពេលនេះ, ពេលដែលជិតនឹងទម្លុះនៅមិនទាន់ទម្លុះទាំងស្រុង, ភ្នែកទិព្វគឺនឹងកើតឡើងការផ្លាស់ប្រែមួយ៖ មើលវត្ថុសុទ្ធតែមិនស្ថិតនៅ, មើលមនុស្សក៏គ្មាន, ជញ្ជាំងក៏គ្មាន, អ្វីសុទ្ធតែគ្មាន, វត្ថុមិនស្ថិតនៅ។ ជាក់ស្តែងគឺនិយាយនៅក្នុងអវកាសពិសេសជាក់លាក់នេះ, ពេលដែលមើលជ្រៅចុះបន្តទៀត, នឹងរកឃើញថាមនុស្សគ្មានទៀត, មានតែមុខកញ្ចក់មួយឈរនៅខាងក្នុងវិសាលភាពវាលអវកាសនេះរបស់លោកអ្នក។ ហើយមុខកញ្ចក់នេះនៅវាលអវកាសរបស់លោកអ្នកធំដូចគ្នានឹងវាលអវកាសទាំងមូលរបស់លោកអ្នក, ដូច្នេះពេលដែលវានៅខាងក្នុងក្រឡាប់មកក្រឡាប់ទៅ, គឺគ្មានកន្លែងណាបញ្ចាំងមិនដល់។ ខាងក្នុងវិសាលភាពវាលអវកាសរបស់លោកអ្នកដរាបណាគឺប្រការដែលឆ្លុះបញ្ចាំងឆ្លងមកក្នុងចក្រវាល, វាអាច

បញ្ចាំងចូលក្នុងឲ្យលោកអ្នកទាំងស្រុង, នេះជាក់ស្តែងគឺសីលគង់ទូរនេត្រដែលយើងខ្ញុំសម្តែង។

ពេលដែលស្រាវជ្រាវវិទ្យាសាស្ត្រអំពីរាងកាយមនុស្សត្រួតពិនិត្យសីលគង់នេះ, ជាញឹកញាប់ងាយស្រួលបដិសេធវា, ហេតុផលបដិសេធគឺ៖ ឧបមាថាសាច់ញាតិនរណាម្នាក់នៅប៉េកាំងកំពុងធ្វើអ្វីក្នុងផ្ទះ? ពេលបន្ទាប់ពីនិយាយចេញឈ្មោះរបស់សាច់ញាតិនិងកាលៈទេសៈទូទៅរួច, គាត់គឺមើលឃើញបាន។ គាត់និយាយថា៖ អគារនេះគឺជាបែបណា, ចូលក្នុងខ្លោងទ្វារនេះដូចម្តេច, បានចូលក្នុងបន្ទប់, គ្រឿងសង្ហារិមរបស់បន្ទប់គឺជាបែបណា។ និយាយត្រូវទាំងអស់។ មនុស្សកំពុងធ្វើអ្វី? និយាយថាមនុស្សកំពុងសរសេរអក្សរ។ ដើម្បីបញ្ជាក់ការពិតនេះ, កាន់ទូរស័ព្ទឡើងផ្ទេររកដល់សាច់ញាតិរបស់គាត់៖ បងកំពុងធ្វើអីហ្នឹង? ខ្ញុំកំពុងញ៉ាំបាយ។ នេះមិនមែនពុំស្របនឹងអ្វីដែលគាត់មើលឃើញហើយឬ? អតីតកាលមូលហេតុបដិសេធប្រភេទសីលគង់នេះគឺនៅកន្លែងនេះ, ប៉ុន្តែបរិយាកាសដែលគាត់មើលឃើញបន្តិចក៏មិនខុស។ ដោយសារអវកាសនេះរបស់ពួកយើងនិងពេលវេលា, យើងខ្ញុំហៅថាវេលា-អវកាស, និងវេលា-អវកាសនៃអវកាសនោះដែលសីលគង់បានស្ថិតនៅគឺមានពេលវេលាមួយខុសគ្នា, ទស្សនាទានពេលវេលាសងខាងមិនដូចគ្នា។ គាត់ទើបតែជានៅទីនោះសរសេរអក្សរ, ឥឡូវកំពុងញ៉ាំបាយ, មានភាពខុសគ្នានៃពេលវេលាយ៉ាងនេះ។ ដូច្នេះជាញឹកញាប់មនុស្សធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រអំពីរាងកាយមនុស្ស, ប្រសិនជាឈរនៅលើទ្រឹស្តីធម្មតា, យោងតាមវិទ្យាសាស្ត្របច្ចុប្បន្នយ៉ាងនេះទៅវែកញែក, ទៅស្រាវជ្រាវ, កន្លងមួយម៉ឺនឆ្នាំទៀតក៏គ្មានប្រយោជន៍។ ដោយសារទាំងនេះដើមឡើយជាក់ស្តែងគឺលើសផុតពីប្រការរបស់មនុស្សសាមញ្ញ, ដូច្នេះមនោគតិមនុ

ស្សត្រូវការកើតឡើងប្រភេទប្រែផ្លាស់មួយ, មិនអាចទៅពន្យល់រឿងរ៉ាវទាំងនេះបែបនេះទៀត។

## សីលគង់ដឹងជោគវាសនា

នៅមានប្រភេទសីលគង់មួយមានទំនាក់ទំនងដោយផ្ទាល់នឹងភ្នែកទិព្វ, ហៅថាដឹងជោគវាសនា។ បច្ចុប្បន្ននៅលើពិភពលោកមានសីលគង់៦ប្រភេទត្រូវបានទទួលស្គាល់រួចហើយ, ក្នុងចំណោមនោះរួមបញ្ចូលភ្នែកទិព្វ, ទូរនេត្រ, នៅមានដឹងជោគវាសនា។ អ្វីហៅថាដឹងជោគវាសនា? នោះគឺអាចដឹងពីអនាគតនិងអតីតរបស់មនុស្សម្នាក់; ធំជាងអាចដឹងពីការកើនឡើងនិងការដួលរលំរបស់សង្គម; ធំជាងទៀតអាចមើលឃើញបទច្បាប់ផ្លាស់ប្រែនៃរាងកាយលោកធាតុទាំងមូល, នេះជាក់ស្តែងគឺជាសីលគង់ដឹងជោគវាសនា។ ដោយសារសារធាតុគឺយោងតាមបទច្បាប់ជាក់លាក់ដើម្បីធ្វើចលនា, នៅក្នុងអវកាសពិសេសជាក់លាក់, វត្ថុណាមួយសុទ្ធតែមានទម្រង់អត្ថិភាពជាច្រើនៗនៅក្នុងអវកាសផ្សេង។ លើកឧទាហរណ៍និយាយ, រាងកាយមនុស្សកម្រើកពេលណា, កោសិកាក្នុងរាងកាយមនុស្សសុទ្ធតែកម្រើកតាម, ហើយនៅក្រោមអតិសុខុមម៉ូលេគុល, ប្រូតុង, អេឡិចត្រុង, តូចបំផុតៗទាំងអស់, សមាសភាគទាំងអស់សុទ្ធតែកើតឡើងការធ្វើចលនាតាម។ តែផ្ទុយមកវិញវាមានទម្រង់អត្ថិភាពឯករាជ្យរបស់វា, ទម្រង់រាងកាយដែលស្ថិតនៅក្នុងអវកាសផ្សេងក៏នឹងកើតឡើងការផ្លាស់ប្រែ។

ពួកយើងមិនមែនសម្ដែងថាសារធាតុអមតៈឬ? នៅក្នុងអវកាសពិសេសជាក់លាក់មួយ, គេធ្វើរឿងរ៉ាវនេះចប់, ជាក់ស្តែងគឺមនុស្សកាលណាគ្រវាសដៃធ្វើរឿងរ៉ាវអ្វីមួយ, សុទ្ធតែជាអត្ថិភាពសារធាតុ, ធ្វើរឿងរ៉ាវអ្វីមួយសុទ្ធតែនឹងបន្សល់ទុករូបស្រមោលមួយនិងព័ត៌មាន។ នៅក្នុង

អវកាសផ្សេង, វាគឺអមតៈ, ជានិច្ចនឹងស្ថិតនៅទីនោះ, មនុស្សមានសីលគង់កាលណាមើលឃើញទស្សនីយភាពអតីត, គឺដឹងបានភ្លាម។ អនាគតបន្ទាប់ពីលោកអ្នកមានសីលគង់ដឹងជោគវាសនា, លោកអ្នកមើលសាកមើលទម្រង់ដែលពួកយើងថ្ងៃនេះសម្តែងមេរៀននៅទីនេះ, វានៅតែនឹងស្ថិតនៅ, បានក្នុងពេលដំណាលគ្នាស្ថិតនៅទីនោះរួចហើយ។ ពេលដែលមនុស្សម្នាក់ចាប់កំណើត, នៅក្នុងអវកាសពិសេសជាក់លាក់មួយដែលគ្មានទស្សនាទានពេលវេលា, មួយជីវិតរបស់មនុស្សបានក្នុងពេលដំណាលគ្នាស្ថិតនៅរួចហើយ, មានខ្លះក៏មិនត្រឹមតែមួយជាតិ។

អាចមានមនុស្សគិតថា៖ នោះការពុះពារតស៊ូឯកជន, កែប្រែខ្លួនឯងរបស់ពួកយើង, គឺគ្មានចាំបាច់ទៀតឬ? គាត់ទទួលយកមិនបាន។ ភាពពិតពុះពារតស៊ូឯកជនអាចផ្លាស់ប្រែប្រការតូចនៃជីវិតមនុស្ស, ប្រការតូចមួយចំនួន, តាមរយៈពុះពារតស៊ូឯកជនអាចកើតឡើងការផ្លាស់ប្រែមួយចំនួន។ ប៉ុន្តែត្រង់ដោយសារលោកអ្នកខិតខំផ្លាស់ប្រែគឺអាចទទួលយកអំណាចកម្ម, បើមិនដូច្នោះទេគឺមិនស្ថិតនៅបញ្ហាសាងកម្ម, គឺមិនស្ថិតនៅបញ្ហាធ្វើរឿងល្អធ្វើរឿងអាក្រក់។ ពេលដែលរឹងរូសធ្វើបែបនេះ, គាត់គឺនឹងកាន់កាប់ភាពងាយស្រួលរបស់អ្នកដទៃ, គាត់បានធ្វើរឿងអាក្រក់រួចហើយ។ ដូច្នេះនៅក្នុងបួសហាត់ម្តងទៀតសម្តែងថាត្រូវបណ្តោយតាមធម្មជាតិ។ ជាក់ស្តែងជាគោលសីលធម៌នេះ, ដោយសារលោកអ្នកតាមរយៈខិតខំគឺនឹងធ្វើបាបដល់អ្នកដទៃ។ ដើមមកក្នុងជីវិតលោកអ្នកគ្មានប្រការនេះ, ប៉ុន្តែនៅក្នុងសង្គមលោកអ្នកទទួលបានប្រការដើមមកជារបស់អ្នកដទៃ, គឺលោកអ្នកបានជំពាក់គេរួចហើយ។

រឿងរ៉ាវធំគាត់ចង់កម្រើក, មនុស្សសាមញ្ញគឺជាមូលដ្ឋានកម្រើកមិនបាន។ ក៏មានវិធីមួយអាចកម្រើក, ជាក់ស្តែងគឺបុគ្គលនេះសុទ្ធតែធ្វើរឿង

អាក្រក់, គ្មានអំពើអាក្រក់អីមិនធ្វើ, គាត់អាចផ្លាស់ប្រែខ្សែជីវិតរបស់គាត់, ប៉ុន្តែប្រឈមមុខដាក់គាត់គឺកម្ទេចចោលទាំងស្រុង។ យើងខ្ញុំសង្កេតមើលនៅលើជាន់ថ្នាក់ខ្ពស់, មនុស្សស្លាប់រួចហើយ, វិញ្ញាណដើមអមតៈ។ វិញ្ញាណដើមអមតៈដូចម្ដេច? ភាពពិតយើងខ្ញុំមើលឃើញបន្ទាប់ពីមនុស្សស្លាប់រួចហើយ, ឯកជននោះដែលដាក់ក្នុងទីបញ្ចុះសព, វាហួសពេកគ្រាន់តែជាកោសិកានៃរាងកាយមនុស្សក្នុងអវកាសនេះរបស់ពួកយើង។ បណ្ដាកោសិកាលើសរីរាង្គខាងក្នុងនិងខាងក្នុងរាងកាយ, រាងកាយមនុស្សទាំងមូល, កោសិកានៅក្នុងអវកាសនេះរបូតធ្លាក់ចុះ, ហើយរាងកាយនៅអវកាសផ្សេងដូចជាម៉ូលេគុល, អាតូម, ប្រូតុងរហូតដល់ភាគល្អិតសារធាតុនៃសមាសភាគតូចជាងជាមូលដ្ឋានគឺគ្មានស្លាប់, វានៅក្នុងអវកាសផ្សេង, នៅក្នុងអវកាសក្រោមអតិសុខុមនៅតែស្ថិតនៅ។ ហើយមនុស្សគ្មានអំពើអាក្រក់អីមិនធ្វើប្រឈមមុខដាក់ស្ដែងគឺកោសិកាទាំងមូលរុះរើទាំងអស់, ក្នុងពុទ្ធសាសនាហៅថារូប-វិញ្ញាណកម្ទេចទាំងស្រុង។

នៅមានវិធីសាស្ត្រមួយទៀតអាចផ្លាស់ប្រែខ្សែជីវិតរបស់គាត់, នេះគឺវិធីសាស្ត្រតែមួយគត់, នោះគឺឯកជននេះពីពេលនេះតទៅដើរលើផ្លូវបួសហាត់។ ដូច្នោះហេតុអ្វីដើរលើផ្លូវបួសហាត់អាចផ្លាស់ប្រែខ្សែជីវិតរបស់គាត់? ប្រការនេះនរណាអាចងាយស្រួលផ្លាស់ប្ដូរបាន? ដោយសារឯកជននេះកាលណាចង់ដើរលើផ្លូវបួសហាត់, គំនិតមួយនេះកម្រើកកាលណា, គឺដូចជាមាសចែងចាំងពន្លឺ, រញ្ជួយដល់ពិភព១០ទិស។ ពុទ្ធវង្សចំពោះទស្សនាទាននៃចក្រវាលគឺជាទ្រឹស្ដីពិភព១០ទិស។ ដោយសារនៅទីជីវិតកម្រិតខ្ពស់មើលមក, ជីវិតមនុស្សមិនមែនដើម្បីធ្វើជាមនុស្ស។ គាត់សន្មតថាជីវិតរបស់មនុស្សគឺសាងបង្កើតនៅក្នុងអវកាសចក្រវាល, និងចក្រវាលគឺដូចគ្នាចរិតតែមួយ, គឺស្ជួតករុណា, គឺប្រភេទសារធាតុ

សច្ចៈ-ករុណា-ខន្តីនេះផ្សំឡើង។ ប៉ុន្តែគាត់ក៏មានទំនាក់ទំនងរបស់ចំណោមក្រុម, ពេលដែលគាត់នៅក្នុងចំណោមក្រុមកើតឡើងទំនាក់ទំនងសង្គម, មានមួយចំនួនគឺប្រែជាមិនល្អ, ដូច្នេះគឺធ្លាក់ចុះក្រោម; នៅក្នុងជាន់ថ្នាក់នេះគាត់ម្តងទៀតរក្សាមិនបាន, គាត់ម្តងទៀតប្រែជាអាក្រក់ជាង, គាត់ក៏ធ្លាក់មួយជាន់ថ្នាក់ទៀត; ធ្លាក់, ធ្លាក់, ធ្លាក់, ចុងក្រោយគឺធ្លាក់មកដល់ក្នុងជាន់ថ្នាក់នេះរបស់មនុស្សសាមញ្ញ។

នៅក្នុងជាន់ថ្នាក់នេះ, ឯកជននេះគឺគួរតែកម្ទេចចោល, រំលាយកម្ទេចបាត់។ ប៉ុន្តែពួកអង្គមហាត្រាស់ដឹងទាំងនោះផុសពីចិត្តមហាមេត្តា, គឺគោលបំណងបង្កចេញប្រភេទអវកាសមួយយ៉ាងនេះ, គឺដូចអវកាសនេះរបស់សង្គមមនុស្សជាតិពួកយើង។ នៅអវកាសនេះ, ផ្តល់ឲ្យគាត់ថែមរាងកាយសាច់មួយរបស់មនុស្ស, ថែមនេត្រាមួយគូយ៉ាងនេះដែលមើលវត្ថុកំហិតនៅអវកាសសារធាតុនេះរបស់ពួកយើង, ពោលគឺធ្លាក់នៅក្នុងភាពវង្វេង, ធ្វើឲ្យគាត់មើលមិនឃើញសេចក្តីពិតនៃចក្រវាល, ហើយនៅក្នុងអវកាសដទៃសុទ្ធតែអាចមើលឃើញបាន។ នៅក្នុងភាពវង្វេងនេះ, នៅក្រោមស្ថានភាពនេះ, បន្សល់ឲ្យគាត់ឱកាសមួយបែបនេះ។ ដោយសារនៅក្នុងភាពវង្វេង, ដូច្នេះក៏ជាទុក្ខបំផុត, មានរាងកាយនេះ, គឺទុកឲ្យគាត់មករងទុក្ខ។ មនុស្សនៅអវកាសនេះបើសិនអាចត្រឡប់ឡើងវិញបាន, តាវវង្សហាត់គង់សម្តែងអំពីត្រឡប់ដើមមកសច្ចៈ, ប្រសិនគាត់មានចិត្តបួសហាត់, ជាក់ស្តែងគឺពុទ្ធចរិតផុសចេញមកហើយ, យកចិត្តនេះមើលដ៏មានតម្លៃបំផុត, គេគឺនឹងជួយគាត់។ មនុស្សនៅក្រោមបរិយាកាសទុក្ខយ៉ាងនេះនៅតែមិនទាន់វង្វេងបាត់, នៅតែចង់ត្រឡប់មកវិញ, ដូច្នេះគេជាក់ស្តែងនឹងជួយគាត់, ជួយគាត់ដោយអត់លក្ខខណ្ឌ, អ្វីក៏អាចជួយគាត់បាន។ ហេតុអ្វីយើងខ្ញុំអាចដើម្បីមនុស្សបួសហាត់ធ្វើរឿងរ៉ាវនេះ,

ហើយមិនអាចធ្វើដើម្បីមនុស្សសាមញ្ញ? ជាក់ស្តែងជាគោលសីលធម៌នេះ។

ដូច្នោះធ្វើជាមនុស្សសាមញ្ញម្នាក់ចង់ព្យាបាលជំងឺ, អ្វីក៏ជួយមិនបានលោកអ្នក, មនុស្សសាមញ្ញជាក់ស្តែងគឺជាមនុស្សសាមញ្ញ, មនុស្សសាមញ្ញគឺគួរតែជាស្ថានភាពរបស់មនុស្សសាមញ្ញ។ មនុស្សជាច្រើនសម្តែង, ព្រះពុទ្ធប្រោសសត្វលោកទាំងឡាយអាំ, ពុទ្ធវង្សសម្តែងប្រោសសត្វលោកទាំងឡាយអាំ។ ខ្ញុំប្រាប់លោកអ្នក, លោកអ្នកសាកបើកគម្ពីរទាំងអស់ក្នុងពុទ្ធសាសនា, គ្មាននិយាយព្យាបាលជំងឺឲ្យមនុស្សសាមញ្ញចាត់ថាប្រោសសត្វលោកទាំងឡាយ។ ប៉ុន្មានឆ្នាំថ្មីៗនេះជាក់ស្តែងគឺគ្រូឈីគង់ក្លែងក្លាយទាំងនោះកំពុងធ្វើចលាចលរឿងរ៉ាវនេះ។ គ្រូឈីគង់ពិតប្រាកដទាំងនោះ, គ្រូឈីគង់បើកផ្លូវទាំងនោះ, ជាមូលដ្ឋានគឺមិនសម្តែងហៅលោកអ្នកព្យាបាលជំងឺឲ្យមនុស្ស, គាត់គ្រាន់តែជាបង្រៀនលោកអ្នកហ្វឹកហាត់, ខ្លួនឯងព្យាលបាលជំងឺកាយសម្បទា។ លោកអ្នកជាមនុស្សសាមញ្ញ, លោកអ្នករៀនបានពីរថ្ងៃលោកអ្នកធ្វើដូចម្តេចអាចព្យាបាលជំងឺ? នោះមិនមែនបញ្ឆោតមនុស្សឬ? នោះមិនបង្កើនចិត្តប្រកាន់ឬ? ស្វែងរកកិត្តិនាមផលប្រយោជន៍, ស្វែងរកប្រការវិសាមញ្ញដើម្បីបង្ហាញនៅក្នុងមនុស្សសាមញ្ញ! នោះគឺដាច់ខាតមិនអនុញ្ញាត។ ដូច្នេះមនុស្សខ្លះកាន់តែស្វែងរកកាន់តែគ្មាន, មិនអនុញ្ញាតឲ្យលោកអ្នកធ្វើបែបនេះ, ក៏មិនអនុញ្ញាតឲ្យលោកអ្នកតាមអំពើចិត្តបែបនេះបំផ្លាញស្ថានភាពសង្គមនេះរបស់មនុស្សសាមញ្ញ។

ចក្រវាលនេះគឺមានគោលសីលធម៌យ៉ាងនេះ, ពេលដែលលោកអ្នកចង់ត្រឡប់ដើមមកសច្ចៈ, គឺគេនឹងជួយលោកអ្នក, គាត់សន្មតថាជីវិតរបស់មនុស្សជាក់ស្តែងគឺគួរតែត្រឡប់មកវិញ, ហើយមិនមែនគួរនៅក្នុង

មនុស្សសាមញ្ញ។ ប្រសិនជាមនុស្សជាតិជំងឺអ្វីក៏គ្មាន, រស់យ៉ាងសុខស្រួល, ហៅលោកអ្នកធ្វើអាទិទេពលោកអ្នកក៏មិនទៅ។ គ្មានជំងឺ, ក៏គ្មានទុក្ខ, ចង់អីមាននោះ, នេះល្អប៉ុណ្ណា, ពិតជាពិភពអាទិទេពរួចហើយ។ ប៉ុន្តែលោកអ្នកគឺប្រែជាមិនល្អហើយធ្លាក់ចុះដល់ជំហានមួយនេះ, ដូច្នេះលោកអ្នកនឹងមិនសុខស្រួល។ មនុស្សនៅក្នុងភាពវង្វេងងាយស្រួលធ្វើរឿងអាក្រក់, នៅក្នុងពុទ្ធសាសនាហៅថាបង្វិលកម្មផល។ ដូច្នេះជាញឹកញាប់មនុស្សមួយចំនួនគាត់ខ្លួនឯងពេលដែលមានគ្រោះលំបាកអ្វី, មានរឿងរ៉ាវអ្វីមិនល្អ, សុទ្ធតែនៅក្នុងបង្វិលកម្មផលសងកម្មរបស់គាត់។ ក្នុងពុទ្ធសាសនាក៏និយាយ, ពុទ្ធគ្មានទីណាមិននៅ។ ព្រះពុទ្ធមួយអង្គគ្រវាសដៃមួយ, ជំងឺរបស់មនុស្សជាតិទាំងអស់សុទ្ធតែគ្មានទៀត, រឿងនេះគឺធានាអាចធ្វើបាន។ ព្រះពុទ្ធច្រើនយ៉ាងនេះហេតុអ្វីមិនធ្វើរឿងរ៉ាវនេះ? ដោយសារគាត់គឺពីមុនបានធ្វើរឿងមិនល្អរួចហើយជំពាក់, គាត់ទើបទទួលទោសនេះ។ ប្រសិនជាលោកអ្នកព្យាបាលឲ្យគាត់ជាសះស្បើយ, គឺស្មើនឹងបំផ្លាញគោលសីលធម៌របស់ចក្រវាល, គឺស្មើនឹងឯកជននេះអាចធ្វើរឿងអាក្រក់, ជំពាក់គេអាចមិនសង, នេះគឺមិនអនុញ្ញាត។ ដូច្នេះនរណាក៏រក្សាស្ថានភាពរបស់សង្គមមនុស្សសាមញ្ញ, នរណាក៏មិនទៅបំផ្លាញវា។ សុខស្រួលគ្មានជំងឺពិតប្រាកដតែមួយគត់ដែលលោកអ្នករកឃើញ, អាចសម្រេចបានគោលបំណងរំដោះពិតប្រាកដ, គឺមានតែបួសហាត់ប៉ុណ្ណោះ! ហៅមនុស្សបួសសុចរិតធម៌, ទើបជាប្រោសសត្វលោកទាំងឡាយពិតប្រាកដ។

មានគ្រូឈីគង់ជាច្រើនធ្វើដូចម្តេចអាចព្យាបាលជំងឺបាន? គាត់ហេតុអ្វីសម្តែងព្យាបាលជំងឺ? មនុស្សខ្លះអាចគិតដល់បញ្ហានេះ, ភាគច្រើនប្រភេទមួយនេះសុទ្ធតែមិនមែនផ្លូវសុចរិត។ គ្រូឈីគង់ពិតប្រាកដ

ផុសពីចិត្តមេត្តា, ផុសពីការអាណិត, នៅក្នុងដំណើរការបួសហាត់មើលឃើញសត្វលោកសុទ្ធតែទុក្ខ, គាត់ជួយគេ, នេះគឺអនុញ្ញាត។ ប៉ុន្តែគាត់ព្យាបាលមិនជាស្រឡះ, គាត់គ្រាន់តែអាចបណ្តោះអាសន្នយកជំងឺនេះរឹតត្បិតជាប់ឲ្យលោកអ្នក; ឬក៏ជាចៀសបន្តិចឲ្យលោកអ្នក, បច្ចុប្បន្នមិនឈឺអនាគតឈឺ, យកជំងឺរុញទៅខាងក្រោយ; ឬក៏ជាបំប្លែងឲ្យលោកអ្នក, បំប្លែងដល់លើរាងកាយសាច់ញាតិរបស់លោកអ្នក។ ហើយពិតប្រាកដអាចយកកម្មនេះរបស់លោកអ្នកលុបចោលទាំងស្រុង, គាត់គឺធ្វើមិនបាន, មិនអនុញ្ញាតតាមអំពើចិត្តធ្វើបែបនេះឲ្យមនុស្សសាមញ្ញ, ហើយគ្រាន់តែអាចធ្វើឲ្យមនុស្សបួសហាត់, ជាក់ស្តែងជាគោលសីលធម៌នេះ។

អត្ថន័យប្រយោគប្រោសសត្វលោកទាំងឡាយដែលពុទ្ធវង្សសម្តែង៖ គឺយកលោកអ្នកពីក្នុងស្ថានភាពទុក្ខបំផុតរបស់មនុស្សសាមញ្ញនាំទៅលើជាន់ថ្នាក់ខ្ពស់, ជានិច្ចមិនរងទុក្ខ, រំដោះ, ដែលគាត់សម្តែងគឺអត្ថន័យនេះ។ សក្យមុនីមិនមែនបានសម្តែងអំពីត្រើយខាងនោះនៃនិព្វានឬ? នេះគឺអត្ថន័យពិតប្រាកដនៃប្រោសសត្វលោកទាំងឡាយរបស់គាត់។ ប្រសិនហៅលោកអ្នកនៅក្នុងមនុស្សសាមញ្ញសុទ្ធតែទទួលផលបុណ្យ, មានលុយដល់ថ្នាក់, គ្រែក្នុងផ្ទះលោកអ្នកសុទ្ធតែយកលុយមកទ្រនាប់, ទោសអ្វីសុទ្ធតែគ្មាន, នោះហៅលោកអ្នកធ្វើអាទិទេពលោកអ្នកក៏មិនធ្វើ។ ធ្វើជាមនុស្សបួសហាត់ម្នាក់, អាចផ្លាស់ប្រែផ្លូវជីវិតឲ្យលោកអ្នក, ក៏មានតែបួសហាត់ប៉ុណ្ណោះទើបអាចផ្លាស់ប្រែបាន។

ទម្រង់របស់សីលគង់ដឹងជោគវាសនាគឺនៅទីតាំងខាងមុខថ្ងាសរបស់មនុស្សមានមួយដូចជាអេក្រង់ផ្ទូស្វ័រតូចរបស់ទូរទស្សន៍។ មនុស្សខ្លះនៅទីតាំងនេះរបស់ខាងមុខថ្ងាស; មនុស្សខ្លះឃ្លាតពីខាងមុខថ្ងាសចម្ងាយមួយដ៏ជិត; មនុស្សខ្លះនៅខាងក្នុងរបស់ខាងមុខថ្ងាស។ មនុស្ស

ខ្លះបិទភ្នែកអាចមើលឃើញបាន; ក្នុងករណីវាពិតជាខ្លាំង, មនុស្សខ្លះបើកភ្នែកអាចមើលឃើញបាន។ ប៉ុន្តែអ្នកដទៃមើលមិនឃើញ, នេះជាប្រការនៅក្នុងវិសាលភាពវាលអវកាសរបស់គាត់។ ក៏មានន័យថា, បន្ទាប់ពីប្រភេទសីលគង់នេះលេចឡើងរួចហើយ, នៅមានសីលគង់មួយប្រភេទទៀតធ្វើជាកាយចម្លង, យកទស្សនីយភាពដែលមើលឃើញក្នុងអវកាសផ្សេងបញ្ចាំងឆ្លងមក, ដូច្នេះគឺនៅក្នុងភ្នែកទិព្វនេះមើលឃើញបាន។ មើលឃើញអនាគតរបស់មនុស្សម្នាក់, មើលឃើញអតីតរបស់មនុស្សម្នាក់, មើលឃើញចំៗខ្លាំងណាស់។ ហោរាសាស្ត្រទស្សន៍ទាយច្បាស់លាស់ដល់ណា, រឿងរ៉ាវតូច, ពិស្ដារក៏ទស្សន៍ទាយចេញមកមិនបាន, ផ្ទុយមកវិញគាត់អាចមើលបានច្បាស់លាស់ខ្លាំងណាស់, ជំនាន់ក៏អាចមើលចេញមកបាន។ ការផ្លាស់ប្រែពិស្ដារសុទ្ធតែអាចមើលចេញមកបាន, ដោយសារដែលគាត់មើលឃើញជាក់ស្ដែងជាការឆ្លុះបញ្ចាំងពិតមែនរបស់មនុស្សឬវត្ថុនៃអវកាសខុសគ្នា។

ដរាបណាគឺបួសហាត់ហ្វាលូនតាហ្វា, ភ្នែកទិព្វនរណាក៏បានបើកឲ្យ។ ប៉ុន្តែសីលគង់មួយចំនួនដែលយើងខ្ញុំនិយាយដល់ក្រោយមក, មួយនេះគឺមិនបើកឲ្យ។ ពេលដែលស្របតាមជាន់ថ្នាក់បន្តលើកកម្ពស់, សីលគង់ដឹងជោគវាសនាតាមធម្មជាតិនឹងលេចឡើង, អនាគតក្នុងពេលបួសហាត់នឹងជួបប្រទះកាលៈទេសៈប្រភេទនេះ។ ពេលដែលលេចឡើងសីលគង់ប្រភេទនេះ, គឺដឹងបានជារឿងដូចម្ដេច, ដូច្នេះធម៌, គោលសីលធម៌ទាំងនេះយើងខ្ញុំសុទ្ធតែសម្ដែងចេញមកឲ្យ។

## មិននៅក្នុងធាតុទាំង៥, ដើរចេញក្រៅត្រៃភព

[មិននៅក្នុងធាតុទាំង៥, ដើរចេញក្រៅត្រៃភព] ជាអ្វី? បញ្ហានេះនិយាយចេញមកចាក់ដោតណាស់។ អតីតកាលមានគ្រូឈីគង់ជាច្រើន

និយាយដល់បញ្ហានេះ, ត្រូវបានមនុស្សមិនជឿឈីគង់ធ្វើឲ្យអួលអាក់។ [ពួកលោកហាត់គង់នរណាដើរចេញក្រៅធាតុទាំង៥, ពួកលោកនរណាមិននៅក្នុងត្រៃភព?] មានមនុស្សមួយចំនួនគាត់មិនមែនជាគ្រូឈីគង់, គ្រូឈីគង់នេះរបស់គាត់គឺតែងតាំងដោយខ្លួនឯង។ និយាយមិនច្បាស់លាស់ក៏កុំនិយាយ, គាត់នៅតែហ៊ាននិយាយ, គេក៏ធ្វើឲ្យមាត់របស់គាត់ជាប់រឹង។ បង្កជាការបង់ខាតដ៏ធំដល់ពិភពបួសហាត់, បង្កជាភាពច្របូកច្របល់ដ៏ធំ, គេបានយកលេសនេះដើម្បីវាយប្រហារលើឈីគង់។ មិននៅក្នុងធាតុទាំង៥, ដើរចេញក្រៅត្រៃភព, គឺជាប្រយោគមួយនៃពិភពបួសហាត់, ប្រភពរបស់វាស្ថិតក្នុងសាសនា, គឺសាងបង្កើតនៅក្នុងសាសនា។ ដូច្នេះពួកយើងមិនអាចបំបែកចេញពីសាវតាប្រវត្តិសាស្ត្រនេះ, មិនអាចបំបែកចេញពីបរិយាកាសនៅគ្រានោះដើម្បីសម្ដែងបញ្ហានេះ។

មិននៅក្នុងធាតុទាំង៥ជាអ្វី? រូបវិទ្យាបុរាណរបស់ប្រទេសចិនពួកយើង, រូបវិទ្យាបច្ចុប្បន្នសុទ្ធតែសន្មតថាទ្រឹស្ដីធាតុទាំង៥របស់ប្រទេសចិនគឺត្រឹមត្រូវ។ លោហៈ, ឈើ, ទឹក, ភ្លើង, ដីធាតុទាំង៥នេះបានផ្សំឡើងអ្វីៗគ្រប់យ៉ាងក្នុងចក្រវាលរបស់ពួកយើង, នេះគឺត្រឹមត្រូវ, ដូច្នេះពួកយើងសម្ដែងអំពីធាតុទាំង៥នេះ។ និយាយថាមនុស្សម្នាក់នេះដើរចេញក្រៅធាតុទាំង៥, ប្រើពាក្យបច្ចុប្បន្នដើម្បីសម្ដែង, ជាក់ស្ដែងគឺដើរចេញក្រៅពិភពសារធាតុនេះរបស់ពួកយើង, ស្ដាប់ទៅដ៏អាថ៌កំបាំង។ អ្នករាល់គ្នាគិតបញ្ហាមួយបែបនេះ, គ្រូឈីគង់គឺមានគង់ស្ថិតនៅ។ ខ្ញុំធ្លាប់ធ្វើការសាកល្បង, គ្រូឈីគង់ដ៏ច្រើនក៏សុទ្ធតែធ្លាប់បានធ្វើសាកល្បងបែបនេះ, វាស់ថាមពលរបស់គាត់។ ដោយសារសមាសភាគសារធាតុក្នុងគង់នេះឧបករណ៍ដ៏ច្រើនដែលពួកយើងកំពុងមានសុទ្ធតែអាចវាស់ចេញបាន, ពោលគឺសមាសភាគដែលគ្រូឈីគង់បញ្ចេញដរាបណាមាន

ប្រភេទឧបករណ៍មួយបែបនោះស្ថិតនៅ, គឺអាចវាស់បានអត្ថិភាពរបស់គង់។ ឧបករណ៍បច្ចុប្បន្នអាចវាស់បានកាំរស្មី infrared, កាំរស្មី ultraviolet, រលក ultrasound, រលក infrasound, អគ្គិសនី, ចុម្ពិត, កាំរស្មី gamma, អាតូម, នឺត្រុង។ គ្រូឈីគង់សុទ្ធតែមានសារធាតុទាំងនេះ, នៅមានសារធាតុមួយចំនួនដែលគ្រូឈីគង់បញ្ចេញមកវាស់មិនបាន, គ្មានឧបករណ៍។ ដរាបណាមានឧបករណ៍ទាំងអស់អាចវាស់ចេញមកបាន, រកឃើញថាសារធាតុដែលគ្រូឈីគង់បញ្ចេញគឺសម្បូរបែបជាទីបំផុត។

នៅក្រោមផលប៉ះពាល់នៃវាលអេឡិចត្រូម៉ាញ៉េទិចពិសេសជាក់លាក់មួយ, គ្រូឈីគង់អាចបញ្ចេញរស្មីខ្លាំងធំ, ស្រស់ស្អាតពិសេស។ អំណាចគង់កាន់តែខ្ពស់, វាលថាមពលបញ្ចេញកាន់តែធំ។ ហើយមនុស្សសាមញ្ញក៏មាន, តែជាប្រភេទរស្មីមួយដ៏តូចៗ។ នៅក្នុងស្រាវជ្រាវរូបវិទ្យាអំពីថាមពលខ្ពស់, គេសន្មតថាថាមពលជាក់ស្តែងគឺជានឺត្រុង, អាតូមរបស់ទាំងនេះ។ គ្រូឈីគង់ជាច្រើនក៏សុទ្ធតែធ្លាប់បានវាស់, គ្រូឈីគង់មានល្បីឈ្មោះបង្គួរសុទ្ធតែធ្លាប់បានចូលរួម។ ខ្ញុំក៏ត្រូវបានវាស់, វាស់បានកាំរស្មី Gamma និងនឺត្រុងកំដៅដែលបញ្ចេញលើសពីបរិមាណវិទ្យុសកម្មធម្មតា៨០ដងទៅ១៧០ដង។ ពេលនេះ, ទ្រនិចរបស់ឧបករណ៍វាស់បានចង្អុលដល់ដែនកំណត់រួចហើយ, ដោយសារចង្អុលដល់ដែនកំណត់រួចហើយ, ចុងក្រោយធំប៉ុណ្ណាក៏មិនដឹងបាន។ នឺត្រុងខ្លាំងធំយ៉ាងនេះ, សុទ្ធសាធមិនគួរឱ្យជឿ! មនុស្សធ្វើដូចម្តេចបញ្ចេញបាននឺត្រុងខ្លាំងធំយ៉ាងនេះ? នេះក៏សបញ្ជាក់ថាគ្រូឈីគង់យើងខ្ញុំគឺមានគង់ស្ថិតនៅ, គឺមានថាមពលស្ថិតនៅ, ចំណុចមួយនេះនៅពិភពបច្ចេកវិទ្យាត្រូវបានបញ្ជាក់រួចហើយ។

ដើរចេញក្រៅធាតុទាំង៥, នៅតែត្រូវជាគង់ហ្វាចរិតជីវិតបួសទាំងទ្វេ, មិនមែនគង់ហ្វាចរិតជីវិតបួសទាំងទ្វេ, គ្រាន់តែបង្កើនគង់នៃជាន់ថ្នាក់ខ្ពស់ឬទាបរបស់គាត់។ ហើយគង់ហ្វាមិនបួសជីវិត, ក៏មិនស្ថិតនៅបញ្ហានេះ, វាមិនសម្តែងអំពីដើរចេញក្រៅធាតុទាំង៥។ គង់ហ្វាចរិតជីវិតបួសទាំងទ្វេ, ថាមពលរបស់វាគឺបានស្តុកទុកនៅក្នុងកោសិកាទាំងអស់នៃរាងកាយ។ មនុស្សហាត់គង់ធម្មតាពួកយើង, មនុស្សដែលទើបតែបង្កើនគង់, ភាគល្អិតថាមពលដែលបញ្ចេញគ្រើមណាស់, មានចន្លោះ, ដង់ស៊ីតេមិនធំ, ដូច្នេះអំណាចដ៏តូច។ ចាំពេលដែលដល់ជាន់ថ្នាក់កាន់តែខ្ពស់, ដង់ស៊ីតេថាមពលរបស់វាប្រៀបនឹងម៉ូលេគុលរបស់ទឹកធម្មតាអាចលើសជាង១០០ដង, ១០០០ដង, មួយរយលានដង, សុទ្ធតែអាចមាន។ ដោយសារជាន់ថ្នាក់កាន់តែខ្ពស់, ដង់ស៊ីតេរបស់វាកាន់តែធំ, កាន់តែម៉ដ្តរលោង, អំណាចកាន់តែធំ។ នៅក្រោមកាលៈទេសៈបែបនេះ, ថាមពលស្តុកទុកនៅក្នុងកោសិកានីមួយៗរបស់រាងកាយ, ក៏មិនគ្រាន់តែជាក្នុងរាល់កោសិកានៃរាងកាយអវកាសសារធាតុនេះរបស់ពួកយើង, នៅរាងកាយទាំងអស់ក្នុងអវកាសផ្សេង, ម៉ូលេគុល, អាតូម, ប្រូតុង, អេឡិចត្រុង, រហូតដល់កោសិកាយ៉ាងអតិសុខុមបំផុតចុះក្រោម, សុទ្ធតែត្រូវបានប្រភេទថាមពលនេះបំពេញ។ យូរៗទៅ, រាងកាយគឺបានពោរពេញទាំងស្រុងទៅដោយប្រភេទសារធាតុថាមពលខ្ពស់នេះ។

ប្រភេទសារធាតុថាមពលខ្ពស់នេះគឺមានប្រាជ្ញា, វាគឺមានអានុភាព។ វាច្រើនឡើងកាលណា, ដង់ស៊ីតេធំឡើងកាលណា, បន្ទាប់ពីពោរពេញកោសិកាទាំងអស់នៃរាងកាយមនុស្ស, វាគឺអាចរឹតត្បិតជាប់កោសិការាងកាយសាច់របស់មនុស្ស, កោសិកាដែលអត់ប្រយោជន៍បំផុត។ បន្ទាប់ពីរឹតត្បិតជាប់កាលណា, គឺនឹងមិនសាងបង្កើតមេតាបូលីស, ចុង

ក្រោយជំនួសទាំងស្រុងកោសិការាងកាយសាច់របស់មនុស្ស។ ប្រាកដណាស់យើងខ្ញុំសម្តែងចេញងាយស្រួល, តែចង់បួសដល់ជំហានមួយនេះគឺជាដំណើរការយឺតយូរ។ ពេលដែលលោកអ្នកបួសដល់ជំហានមួយនេះ, កោសិកាទាំងអស់នៃរាងកាយរបស់លោកអ្នកសុទ្ធតែត្រូវបានប្រភេទសារធាតុថាមពលខ្ពស់នេះជំនួស, លោកអ្នកគិតសាកមើល, រាងកាយលោកអ្នកនៅតែជាធាតុទាំង៥ផ្សំឡើងទៀតឬ? នៅតែជាសារធាតុនៃអវកាសនេះរបស់ពួកយើងទៀតឬ? វាគឺបានផ្សំឡើងដោយសារធាតុថាមពលខ្ពស់ដែលប្រមូលផ្តុំពីអវកាសផ្សេងរួចហើយ។ សមាសភាគរបស់គុណធម៌នោះក៏ជាអត្ថិភាពសារធាតុក្នុងអវកាសផ្សេង, វាក៏មិនរងការរឹតត្បិតរបស់វាលពេលវេលានៃអវកាសនេះរបស់ពួកយើង។

បច្ចុប្បន្នវិទ្យាសាស្ត្រសន្មតថាពេលវេលាគឺមានវាលស្ថិតនៅ, មិននៅក្នុងវិសាលភាពវាលពេលវេលាគឺមិនទទួលរងការរឹតត្បិតរបស់ពេលវេលា។ អវកាសផ្សេងទស្សនាទានវេលា-អវកាសរបស់វានិងពួកយើងខាងនេះសុទ្ធតែមិនដូចគ្នា, វាធ្វើម្តេចអាចរឹតត្បិតសារធាតុនៃអវកាសផ្សេងបាន? ជាមូលដ្ឋានគឺមិនផ្តើមផលប៉ះពាល់។ អ្នករាល់គ្នាគិតសាកមើល, ពេលនេះលោកអ្នកមិនមែនមិននៅក្នុងធាតុទាំង៥ហើយឬ? លោកអ្នកនៅតែជារាងកាយមនុស្សសាមញ្ញទៀតឬ? ជាមូលដ្ឋានគឺមិនមែន។ តែមានចំណុចមួយ, មនុស្សសាមញ្ញផ្ទុយទៅវិញមើលមិនចេញ។ ទោះបីរាងកាយរបស់គាត់ផ្លាស់ប្រែដល់កម្រិតប្រភេទនេះក្តី, នៅតែមិនចាត់ថាបួសហាត់បញ្ចប់, គាត់នៅតែត្រូវបន្តទម្លុះជាន់ថ្នាក់ឡើងលើដើម្បីបួស, ដូច្នេះគាត់នៅតែត្រូវបួសហាត់នៅក្នុងមនុស្សសាមញ្ញ, គេសុទ្ធតែមើលមិនឃើញគាត់គឺមិនបាន។

នោះក្រោយមកធ្វើដូចម្តេច? គាត់នៅក្នុងដំណើរការបួសហាត់,

កោសិកាម៉ូលេគុលទាំងអស់របស់គាត់ទោះបីត្រូវបានសារធាតុថាមពលខ្ពស់ជំនួសរួចហើយក្តី, ប៉ុន្តែអាតូមនោះគឺមានលំដាប់រៀបចំ, លំដាប់រៀបចំរបស់ម៉ូលេគុល, ស្នូលអាតូមគ្មានកើតឡើងការផ្លាស់ប្រែ។ លំដាប់រៀបចំម៉ូលេគុលរបស់កោសិកាក៏ជាស្ថានភាពបែបនោះ, ស្ទាបឡើងទៅគឺទន់; ដង់ស៊ីតេលំដាប់រៀបចំម៉ូលេគុលរបស់ឆ្អឹងចាំបាច់ធំ, ស្ទាបឡើងទៅគឺរឹង; ដង់ស៊ីតេម៉ូលេគុលរបស់ឈាមគឺតូចខ្លាំងណាស់, វាជាក់ស្តែងគឺជាធាតុរាវ។ មនុស្សសាមញ្ញពីខាងលើផ្ទៃមើលមិនចេញការផ្លាស់ប្រែរបស់លោកអ្នក, កោសិកាម៉ូលេគុលរបស់គាត់នៅតែរក្សាប្រភេទរចនាសម្ព័ន្ធដើមនិងលំដាប់រៀបចំមួយបែបនោះ, រចនាសម្ព័ន្ធរបស់គាត់គ្មានកើតឡើងការផ្លាស់ប្រែ, ប៉ុន្តែថាមពលខាងក្នុងរបស់គាត់បានកើតឡើងការផ្លាស់ប្រែរួចហើយ, ដូច្នេះឯកជននេះពីពេលនេះតទៅនឹងមិនចាស់ខ្សោយតាមធម្មជាតិ, កោសិការបស់គាត់នឹងមិនស្លាប់បាត់, ដូច្នោះគាត់គឺនៅក្មេងជារៀងរហូត។ នៅក្នុងដំណើរការបួសហាត់, មនុស្សនឹងបង្ហាញចេញក្មេងជាងវ័យ, ចុងក្រោយគឺកំណត់នៅទីនោះ។

ប្រាកដណាស់, រាងកាយនោះប្រសិនបុកត្រូវឡានប្រហែលជានៅតែនឹងបាក់ឆ្អឹង, ទាញមួយកាំបិតនៅតែនឹងហូរឈាម។ ដោយសារលំដាប់រៀបចំម៉ូលេគុលរបស់គាត់គ្មានផ្លាស់, គ្រាន់តែជាគាត់នឹងមិនស្លាប់តាមធម្មជាតិ, នឹងមិនចាស់ទៅតាមធម្មជាតិ, គ្មានមេតាបូលីស, នេះជាក់ស្តែងគឺដើរចេញក្រៅធាតុទាំង៥ដែលយើងខ្ញុំនិយាយ។ ទីនេះកន្លែងណាមានអបិយជំនឿអ្វី? ប្រើគោលសីលធម៌វិទ្យាសាស្ត្រសុទ្ធតែអាចពន្យល់ធ្លុះធ្លាយបាន។ មានមនុស្សមួយចំនួននិយាយមិនច្បាស់លាស់ហើយនិយាយតាមអំពើចិត្ត, គេគឺនឹងនិយាយលោកអ្នកធ្វើអបិយជំនឿ។ ដោយសារប្រយោគនេះប្រភពរបស់វាក្នុងសាសនា, មិនមែន

នាមសព្ទដែលឈឺគង់ទំនើបពួកយើងលើកឡើង។

ដើរចេញក្រៅត្រៃភពជាអ្វី? ថ្ងៃនោះខ្ញុំបានសម្ដែង, គន្លឹះរបស់បង្កើនគង់គឺពួកយើងប្ដូសហាត់ចិត្តចរិត, សមកាលកម្មនឹងចរិតពិសេសនៃចក្រវាល, ចរិតពិសេសនៃចក្រវាលចំពោះលោកអ្នកមិនដំណើរការរឹតត្បិតទៀត, ចិត្តចរិតរបស់លោកអ្នកថ្កើងឡើងលើ, សមាសភាគរបស់គុណធម៌នោះនឹងវិវត្តក្លាយជាគង់។ បន្តបង្កើនសំដៅឡើងលើ, ថ្កើងសំដៅឡើងលើ, បន្ទាប់ពីថ្កើងឡើងដល់ជាន់ថ្នាក់ខ្ពស់, គឺបង្កើតជាសសរគង់មួយ។ សសរគង់នេះខ្ពស់ប៉ុណ្ណា, គង់របស់លោកអ្នកគឺខ្ពស់ប៉ុណ្ណោះ។ មានប្រយោគមួយបែបនេះមហាធម៌គ្មានដែន, ទាំងស្រុងពឹងផ្អែកលើចិត្តនោះរបស់លោកអ្នកដើម្បីប្ដូស, មើលលោកអ្នកប្ដូសខ្ពស់ប៉ុណ្ណា, ទាំងស្រុងពឹងផ្អែកលើកម្លាំងអត់ធ្មត់និងសមត្ថភាពរងទុក្ខរបស់លោកអ្នក។ សារធាតុពណ៌សរបស់ខ្លួនលោកអ្នកផ្ទាល់ប្រើអស់រួចហើយ, សារធាតុពណ៌ខ្មៅរបស់លោកអ្នកខ្លួនឯងតាមរយៈរងទុក្ខវាក៏អាចបំប្លែងក្លាយជាសារធាតុពណ៌ស។ នៅតែមិនគ្រប់ប្រើ, សាច់ញាតិមិត្តភក្តិ, គាត់មិនប្ដូសហាត់, លោកអ្នកជំនួសគាត់ទទួលទោស, លោកអ្នកក៏អាចបង្កើនគង់, នេះគឺសំដៅលើមនុស្សដែលប្ដូសហាត់ដល់ជាន់ថ្នាក់យ៉ាងខ្ពស់បំផុត។ មនុស្សសាមញ្ញម្នាក់ប្ដូសហាត់លោកអ្នកគឺកុំមានការគិតជំនួសសាច់ញាតិទទួលទោស, អំណាចកម្មធំបែបនោះមនុស្សធម្មតាគឺប្ដូសមិនសម្រេច។ ដែលខ្ញុំសម្ដែងទីនេះជាគោលសីលធម៌នៃជាន់ថ្នាក់ខុសគ្នា។

ត្រៃភពដែលធ្លាប់បាននិយាយក្នុងសាសនា, គឺនិយាយអំពីមេឃ៩ជាន់ឬក៏មេឃ៣៣ជាន់, ក៏មានន័យថាលើមេឃ, លើដី, ក្រោមដី, បានផ្សំឡើងជាសត្វលោកទាំងឡាយក្នុងត្រៃភព។ វាសម្ដែងអំពីភាវៈទាំងអស់

ខាងក្នុងមេឃ៣៣ជាន់សុទ្ធតែត្រូវដំណើរវដ្ដសង្សារ៦ផ្លូវ។ អត្ថន័យវដ្ដសង្សារ៦ផ្លូវជាក់ស្ដែងគឺជាតិនេះជាមនុស្ស, ជាតិក្រោយអាចជាសត្វ។ ក្នុងពុទ្ធសាសនាសម្ដែង៖ ត្រូវចាប់យកអំឡុងឆ្នាំមានជីវិត, ឥឡូវមិនបួសពេលណាបួស? ដោយសារសត្វគឺមិនអនុញ្ញាតឲ្យបួសហាត់, គឺមិនអនុញ្ញាតឲ្យស្ដាប់ធម៌, បួសហើយក៏មិនសម្រេចមគ្គផល, គង់ខ្ពស់ក៏ត្រូវបានមេឃសម្លាប់។ លោកអ្នករាប់រយឆ្នាំពុំបានកាយមនុស្ស, ជាងពាន់ឆ្នាំទើបបានកាយមនុស្ស, បានកាយមនុស្សរួចហើយក៏មិនដឹងគោរពឲ្យតម្លៃ។ លោកអ្នកប្រសិនជាស្លាប់កើតជាថ្មមួយដុំម៉ឺនឆ្នាំចេញមិនបាន, ដុំថ្មនោះមិនកម្ទេច, មិនសឹកដោយខ្យល់, លោកអ្នកគឺជានិច្ចចេញមិនបាន, បានកាយមនុស្សពិបាកប៉ុណ្ណា! បើពិតជាអាចទទួលបានមហាធម៌, ឯកជននេះសុទ្ធសាធសែនសំណាង។ រាងមនុស្សពិបាកបាន, សម្ដែងគោលសីលធម៌នេះ។

ពួកយើងហាត់គង់សម្ដែងអំពីបញ្ហាជាន់ថ្នាក់, ជាន់ថ្នាក់នេះពឹងផ្អែកទាំងស្រុងលើខ្លួនឯងដើម្បីបួសហាត់, ប្រសិនលោកអ្នកចង់ចេញផុតពីត្រៃភពរបស់វា, សសរគង់របស់លោកអ្នកបួសបានដ៏ខ្ពស់ៗរួចហើយ, មិនមែនលោកអ្នកទម្លុះត្រៃភពរបស់វាហើយឬ? មនុស្សខ្លះពេលដែលអង្គុយសមាធិវិញ្ញាណដើមឃ្លាតពីកាយ, ភ្លាមៗបានឡើងដ៏ខ្ពស់។ សិក្ខាកាមខ្លះសរសេរមកខ្ញុំក្នុងចិត្តបានយល់ដឹងនិយាយដល់៖ លោកគ្រូ, កូនបានឡើងលើមេឃប៉ុន្មានៗជាន់, កូនមើលឃើញទស្សនីយភាពដូចនេះដូចនោះ។ ខ្ញុំនិយាយថាកូនឆ្លោះឡើងខ្ពស់ទៀតមើល។ គាត់និយាយ៖ កូនឡើងទៅមិនបានទៀត, មិនហ៊ានឡើង, ឡើងលើទៀតមិនបាន។ ហេតុអ្វី? ដោយសារសសរគង់របស់គាត់គ្រាន់តែខ្ពស់យ៉ាងនោះ, គាត់គឺអង្គុយលើសសរគង់របស់គាត់ឡើងទៅ។ នេះជាក់ស្ដែងគឺផលញាណ

សម្ដែងក្នុងពុទ្ធសាសនា, បួសឡើងដល់ផលញាណនោះ។ ប៉ុន្តែនេះចំពោះមនុស្សបួសហាត់ដើម្បីនិយាយ, នៅតែមិនមែនបានដល់ចំណុចកំពូលរបស់ផលញាណ។ គាត់នៅតែកំពុងបន្តថ្កើងឆ្ពោះឡើងលើ, បន្តថ្កើងឡើង, បន្តលើកកម្ពស់។ សសរគង់របស់លោកអ្នកប្រសិនទម្លុះបានព្រំដែនរបស់ត្រៃភព, មិនមែនលោកអ្នកដើរចេញក្រៅត្រៃភពហើយឬ? យើងខ្ញុំធ្លាប់បានវាស់រួចហើយ, រកឃើញថាត្រៃភពដែលសាសនាសម្ដែង, ហួសពេកគ្រាន់តែជាខាងក្នុងវិសាលភាព៩មហាភពផ្កាយរបស់ពួកយើង។ មានមនុស្សសម្ដែង១០មហាភពផ្កាយ, ខ្ញុំនិយាយនោះជាមូលដ្ឋានមិនស្ថិតនៅ។ គ្រូឈីគង់ទាំងនោះក្នុងអតីតកាល, ខ្ញុំឃើញថាសសរគង់ខ្លះបានឈានដល់ខាងក្រៅប្រព័ន្ធកញ្ចុំផ្កាយរួចហើយ, ខ្ពស់ណាស់, ត្រៃភពនោះគាត់តាំងពីយូរបានឆ្លងផុតរួចហើយ។ ដើរចេញក្រៅត្រៃភពនេះដែលខ្ញុំទើបសម្ដែងដល់, ភាពពិតជាក់ស្ដែងគឺជាបញ្ហាជាន់ថ្នាក់។

## បញ្ហាមានចំណង់

មានមនុស្សជាច្រើនឱបយកចិត្តមានចំណង់ដើរចូលក្នុងវាលបួសហាត់របស់ពួកយើង។ មនុស្សខ្លះឱបយកចំណង់សីលគង់, មនុស្សខ្លះចង់សាកស្ដាប់ទ្រឹស្ដី, មនុស្សខ្លះចង់ព្យាបាលជំងឺ, ក៏មានមនុស្សខ្លះចង់មកដើម្បីទទួលបានហ្វាលូន, ស្ថានភាពផ្លូវចិត្តអ្វីក៏មាន។ ក៏មានមនុស្សខ្លះនិយាយថា៖ ផ្ទះរបស់ពួកខ្ញុំនៅមានមនុស្សមិនទាន់មកចូលរួមថ្នាក់បង្រៀន, ខ្ញុំបង់បន្តិចថ្លៃសិក្សា, ទ្រង់ផ្ដល់ហ្វាលូនឲ្យគាត់។ យើងខ្ញុំបានឆ្លងកាត់ទាំងប៉ុន្មានជំនាន់មនុស្ស, បានឆ្លងកាត់យុគ្គសម័យយ៉ាងយូរអង្វែងបំផុត, តួលេខដែលសម្ដែងចេញសុទ្ធតែដ៏បន្លាចមនុស្ស, របស់ដែលបង្កើតឡើងដោយយុគ្គសម័យយូរអង្វែងមួយបែបនេះ, លោកអ្នក

បង់លុយប៉ុន្មានសិបយ័នគឺទិញបានហ្វាលូន? យើងខ្ញុំហេតុអ្វីអាចផ្ដល់ឲ្យអ្នករាល់គ្នាដោយអត់លក្ខខណ្ឌ? ជាក់ស្ដែងគឺដោយសារលោកអ្នកចង់ធ្វើជាមនុស្សបួសហាត់, ចិត្តនេះគឺប្រើលុយប៉ុន្មានក៏ទិញមិនបាន, គឺពុទ្ធចរិតផុសចេញមក, យើងខ្ញុំទើបធ្វើបែបនេះ។

លោកអ្នកឱបយកចិត្តមានចំណង់, លោកអ្នកជាក់ស្ដែងគឺមកដើម្បីប្រការនេះឬ? ក្នុងមនោគតិលោកអ្នកគិតជាអ្វី, នៅក្នុងអវកាសផ្សេងបរមីរបស់ខ្ញុំអ្វីក៏ដឹង។ ដោយសារទស្សនាទានវេលា-អវកាសទាំងពីរមិនដូចគ្នា, នៅក្នុងអវកាសផ្សេងសង្កេតមើល, ការផ្សំឡើងផ្ទត់គំនិតរបស់លោកអ្នកគឺជាដំណើរការមួយយ៉ាងយឺតយូរបំផុត។ នៅមុនពេលលោកអ្នកគិត, គាត់សុទ្ធតែអាចដឹងបាន, ដូច្នេះលោកអ្នកត្រូវតែយកមនោគតិមិនត្រឹមត្រូវរបស់លោកអ្នកសុទ្ធតែបោះបង់ចោល។ ពុទ្ធវង្សគឺសម្ដែងវាសនា, អ្នករាល់គ្នាសុទ្ធតែជាវាសនាមក, ទទួលបានរួចហើយនេះអាចជាលោកអ្នកគួរតែទទួលបាន, ដូច្នេះលោកអ្នកត្រូវការគោរពរក្សា, កុំឱបយកចិត្តមានចំណង់ណាមួយ។

បួសហាត់សាសនាអតីតកាល, ពុទ្ធវង្សសម្ដែង "ទទេ", អ្វីក៏មិនគិត, ចូលក្នុងទ្វារទទេ; តាវវង្សសម្ដែង "គ្មាន", អ្វីក៏គ្មាន, ក៏មិនចង់, ក៏មិនស្វែងរក។ មនុស្សហាត់គង់សម្ដែង៖ ចេតនាហាត់គង់, អចេតនាទទួលបានគង់។ ឱបយកប្រភេទបួសហាត់មួយស្ថានភាពសភាពគ្មានបំណង, គ្រាន់តែគ្រប់គ្រងបួសហាត់ចិត្តចរិតរបស់លោកអ្នក, ជាន់ថ្នាក់របស់លោកអ្នកគឺកំពុងទម្លុះ, អ្វីដែលលោកអ្នកគួរមានប្រាកដណាស់នឹងមាន។ លោកអ្នកដាក់ចុះមិនបាន, មិនជាក់ស្ដែងជាចិត្តប្រកាន់ឬ? យើងខ្ញុំទីនេះភ្លាមៗបង្រៀនធម៌ខ្ពស់យ៉ាងនេះ, ប្រាកដណាស់តម្រូវចិត្តចរិតចំពោះលោកអ្នកក៏ជាខ្ពស់ផងដែរ, ដូច្នេះមិនអាចឱបយកចិត្តមាន

ចំណង់មករៀនធម៌បានទេ។

ដើម្បីទទួលខុសត្រូវចំពោះអ្នករាល់គ្នា, យើងខ្ញុំគឺនាំអ្នករាល់គ្នាតាមផ្លូវសុចរិត, ធម៌នេះត្រូវតែសម្តែងធ្លុះធ្លាយឲ្យលោកអ្នក។ ពេលដែលមានមនុស្សចំណង់ភ្នែកទិព្វ, ភ្នែកទិព្វនេះនឹងរាំងស្ទះដោយខ្លួនឯង, នឹងបិទជិតលោកអ្នកខ្លួនឯង។ ថែមទៀតខ្ញុំនៅតែប្រាប់អ្នករាល់គ្នាថា, ពេលដែលបួសហាត់នៅលោកីយ៍ធម៌, សីលគង់ទាំងអស់ដែលមនុស្សលេចឡើងសុទ្ធតែជាប្រភេទអានុភាពពីដើមកំណើតមួយដែលរាងកាយសាច់បាននាំតាម, ពួកយើងបច្ចុប្បន្នហៅថាសីលគង់ពិសេស។ វាគ្រាន់តែអាចនៅអវកាសកំពុងមាន, ខាងក្នុងអវកាសនេះរបស់ពួកយើងដើរតួនាទីរបស់វា, រឹតត្បិតលើមនុស្សសាមញ្ញ។ សមត្ថភាពតូចបច្ចេកទេសតូចទាំងនេះលោកអ្នកស្វែងរកធ្វើអ្វី? ស្វែងរកមកស្វែងរកទៅ, បន្ទាប់ពីដល់ផុតពីលោកីយ៍ធម៌រួចហើយ, នៅក្នុងអវកាសដទៃមិនផ្តើមផលប៉ះពាល់។ ពេលដែលដើរឆ្លងបួសហាត់ផុតពីលោកីយ៍ធម៌, សីលគង់ទាំងនេះទាំងអស់សុទ្ធតែត្រូវបោះចោលទាំងស្រុង, យកពួកវាសង្កត់ចូលទៅក្នុងអវកាសមួយដ៏ជ្រៅ, ស្តុកផ្ទុកមកវិញ, អនាគតធ្វើជាកំណត់ត្រាមួយក្នុងដំណើរការបួសហាត់របស់លោកអ្នក, គ្រាន់តែអាចផ្តើមផលប៉ះពាល់បន្តិចយ៉ាងនេះ។

បន្ទាប់ពីដើរឆ្លងផុតពីលោកីយ៍ធម៌, មនុស្សត្រូវបួសហាត់សាជាថ្មី។ រាងកាយប្រភេទនោះជាក់ស្តែងគឺជារាងកាយដើរចេញក្រៅធាតុទាំង៥ដែលខ្ញុំទើបបានសម្តែង, គាត់ជាពុទ្ធកាយមួយ។ ប្រភេទរាងកាយនោះនៅតែមិនហៅថាពុទ្ធកាយបានឬ? ពុទ្ធកាយនេះត្រូវតែចាប់ផ្តើមបួសហាត់សាជាថ្មី, ចាប់ផ្តើមលេចឡើងសីលគង់សាជាថ្មី, គាត់មិនហៅថាសីលគង់, ហៅថាទេពអំណាចពុទ្ធធម៌។ អំណាចរបស់គាត់គ្មានទីបញ្ចប់,

រឹតត្បិតគ្រប់អវកាស, គឺជារបស់ដែលពិតប្រាកដមានប្រសិទ្ធភាព, លោកអ្នកនិយាយលោកអ្នកនៅតែស្វែងរកសីលគង់មានប្រយោជន៍អ្វី? ដរាបណាមនុស្សដែលស្វែងរកសីលគង់, មិនមែនលោកអ្នកចង់ប្រើនៅក្នុងមនុស្សសាមញ្ញ, បង្ហាញនៅក្នុងមនុស្សសាមញ្ញ, មិនដូច្នោះទេលោកអ្នកចង់បានវាធ្វើអ្វី? មើលមិនឃើញ, ប៉ះមិនបាន, ធ្វើជាវត្ថុតែងលម្អក៏ត្រូវតែរករបស់ដែលល្អមើលផងដែរ! ធានាថានៅក្នុងអឌ្ឍសម្បជញ្ញៈរបស់លោកអ្នកមានគោលបំណងចង់ប្រើវា។ វាគឺមិនអាចធ្វើជាភាពជំនាញការនៅក្នុងមនុស្សសាមញ្ញដើម្បីចំណង់បានទេ, វាទាំងស្រុងគឺជាប្រការវិសាមញ្ញ, គឺមិនអាចទុកឲ្យលោកអ្នកបង្ហាញនៅក្នុងមនុស្សសាមញ្ញ។ ការបង្ហាញខ្លួនវាជាក់ស្ដែងជាប្រភេទចិត្តប្រកាន់មួយដ៏ខ្លាំង, ចិត្តដែលសែនមិនល្អ, ជាចិត្តដែលមនុស្សបួសហាត់ត្រូវតែកម្ចាត់។ លោកអ្នកចង់ប្រើវាដើម្បីរកលុយ, ចង់ប្រើវាដើម្បីមានមហាសម្បត្តិ, នៅក្នុងការតស៊ូឯកជនសម្រេចបានគោលដៅក្នុងមនុស្សសាមញ្ញរបស់លោកអ្នក, នោះគឺកាន់តែមិនបាន។ នោះគឺប្រើប្រការរបស់ជាន់ថ្នាក់ខ្ពស់ជ្រៀតជ្រែកសង្គមមនុស្សសាមញ្ញ, បំផ្លាញសង្គមមនុស្សសាមញ្ញ, ការគិតកាន់តែអាក្រក់, ដូច្នេះគឺមិនអនុញ្ញាតឲ្យប្រើប្រាស់តាមអំពើចិត្ត។

ជាញឹកញាប់ពួកយើងលេចឡើងសីលគង់នៅពីរក្បាលច្រើនបង្គួរ, កុមារនិងមនុស្សចាស់អាយុច្រើន។ ជាពិសេសគឺស្ត្រីអាយុច្រើន, ជាញឹកញាប់ចិត្តចរិតអាចរក្សាបានជាប់, គាត់នៅក្នុងមនុស្សសាមញ្ញគ្មានចិត្តប្រកាន់អ្វី។ បន្ទាប់ពីលេចឡើងសីលគង់, គាត់ងាយស្រួលរក្សាបាន, គ្មានចិត្តសាស្ត្របង្ហាញនោះ។ មនុស្សវ័យក្មេងហេតុអ្វីមិនងាយស្រួលលេចឡើង? ជាពិសេសគឺបុរសវ័យក្មេង, គាត់នៅតែចង់នៅក្នុងសង្គមមនុស្សសាមញ្ញខិតខំប្រឹងប្រែងមួយដង, នៅតែចង់សម្រេចបានគោល

ដៅអ្វីមួយ! ពេលណាលេចឡើងសីលគង់, គឺនឹងអនុវត្តវា, បំពេញគោលបំណងរបស់គាត់, ធ្វើជាអានុភាពមួយប្រភេទដើម្បីគាត់បំពេញគោលបំណង, នោះគឺដាច់ខាតមិនអនុញ្ញាត, ដូច្នេះគាត់គឺនឹងមិនលេចឡើងសីលគង់។

រឿងរ៉ាវបួសហាត់, ពិតណាស់មិនមែនល្បែងក្មេងលេង, ក៏មិនមែនភាពជំនាញការក្នុងមនុស្សសាមញ្ញ, ជារឿងរ៉ាវតឹងរឹងខ្លាំងណាស់។ លោកអ្នកចង់ឬមិនចង់បួស, លោកអ្នកអាចឬមិនអាចបួស, ទាំងស្រុងមើលចិត្តចរិតលោកអ្នកខ្លួនឯងធ្វើដូចម្តេចដើម្បីលើកកម្ពស់។ ប្រសិនឯកជននេះពិតប្រាកដចង់គឺអាចចំណង់បានសីលគង់, នោះអាចខូចហើយ។ លោកអ្នកឃើញគាត់បួសហាត់ឬមិនបួសហាត់អ្វី, ជាមូលដ្ឋានមិនគិតដល់រឿងរ៉ាវនេះ។ ដោយសារចិត្តចរិតរបស់គាត់នៅលើមូលដ្ឋានរបស់មនុស្សសាមញ្ញ, សីលគង់ក៏ជាមកពីចំណង់, រឿងអាក្រក់អ្វីគាត់ក៏អាចនឹងធ្វើ។ ធនាគារមានសុទ្ធតែលុយ, កើបយកបន្តិច; តាមផ្លូវធំមានសុទ្ធតែសំបុត្រឆ្នោត, ចាប់យករង្វាន់ទី១។ ហេតុអ្វីគ្មានរឿងរ៉ាវប្រភេទនេះស្ថិតនៅ? គ្រូឈីគង់ខ្លះសម្តែងថា៖ មិនគោរពគុណធម៌លេចឡើងសីលគង់រួចហើយងាយស្រួលធ្វើរឿងអាក្រក់។ ខ្ញុំនិយាយនេះជាការថ្លែងខុសឆ្គង, ជាមូលដ្ឋានគឺមិនមែនរឿងយ៉ាងនេះ។ លោកអ្នកមិនគោរពគុណធម៌, មិនបួសចិត្តចរិត, ជាមូលដ្ឋានគឺនឹងមិនលេចឡើងសីលគង់។ មនុស្សខ្លះចិត្តចរិតល្អ, នៅលើជាន់ថ្នាក់ណាមួយ, កាលណាលេចឡើងសីលគង់, ក្រោយមកគាត់រក្សាមិនជាប់, បានធ្វើរឿងដែលមិនគួរធ្វើ, ក៏មានប្រភេទបាតុភូតនេះស្ថិតនៅ។ ប៉ុន្តែពេលណាគាត់ធ្វើរឿងអាក្រក់, សីលគង់គឺចុះខ្សោយឬក៏បាត់។ នេះកាលណាបាត់គឺបាត់ជានិច្ច, លើសពីនេះទៀតសំខាន់បំផុតគឺអាចធ្វើឲ្យមនុស្សផុសឡើងចិត្តប្រកាន់។

គ្រូឈើគង់ខ្លះសម្តែង, រៀនគង់របស់គាត់៣ថ្ងៃអាចព្យាបាលជំងឺ, ៥ ថ្ងៃអាចព្យាបាលជំងឺ, ដូចចាក់ផ្សាយពាណិជ្ជកម្ម, នេះហៅថាអាជីវកម្មឈើគង់។ អ្នករាល់គ្នាគិតសាកមើល, លោកអ្នកជាមនុស្សសាមញ្ញម្នាក់, លោកអ្នកបញ្ចេញបន្តិចឈើតើអាចព្យាបាលជំងឺរបស់អ្នកដទៃទេ? លើរាងកាយមនុស្សសាមញ្ញក៏មានឈើ, លោកអ្នកក៏មានឈើ, លោកអ្នកទើបតែហាត់គង់, គ្រាន់តែស្មៀ "ឡាវគុង" របស់លោកអ្នកវាយបើក, អាចនាំឈើចូលអាចបញ្ជូនឈើចេញ។ ពេលដែលលោកអ្នកទៅព្យាបាលជំងឺឲ្យអ្នកដទៃ, លើរាងកាយអ្នកដទៃក៏ជាឈើ, ប្រហែលជាព្យាបាលឲ្យលោកអ្នកវិញមិនខាន! រវាងឈើនិងឈើទីណាមានផលប៉ះពាល់រឹតត្បិត? ឈើជាមូលដ្ឋានគឺព្យាបាលជំងឺមិនបាន។ ថែមទៀតពេលលោកអ្នកព្យាបាលជំងឺឲ្យគាត់, លោកអ្នកនិងអ្នកជំងឺបង្កើតជាវាលមួយ, ឈើជំងឺលើរាងកាយអ្នកជំងឺទាំងស្រុងសុទ្ធតែរត់ឆ្លងមកលើរាងកាយលោកអ្នក, ច្រើនដូចគ្នា, {ឫស}គល់ទោះបីនៅលើរាងកាយគាត់, ឈើជំងឺបើសិនច្រើនឡើងក៏នឹងធ្វើឲ្យលោកអ្នកកើតជំងឺ។ ពេលដែលកាលណាលោកអ្នកមានអារម្មណ៍លោកអ្នកអាចព្យាបាលជំងឺ, លោកអ្នកនឹងបើកទ្វារដើម្បីព្យាបាលជំងឺឲ្យគេ, អ្នកណាមកក៏មិនបដិសេធ, លោកអ្នកនឹងផុសឡើងចិត្តប្រកាន់។ មើលជំងឺឲ្យគេជា, ត្រេកអរប៉ុណ្ណា! ហេតុអ្វីអាចមើលជា? លោកអ្នកមិនគិតសាកមើល, លើរាងកាយគ្រូឈើគង់ក្លែងក្លាយសុទ្ធតែមានកាយភ្ជាប់, ដើម្បីឲ្យលោកអ្នកជឿ, បានផ្តល់ឲ្យលោកអ្នកបន្តិចព័ត៌មានយ៉ាងនោះ។ លោកអ្នកព្យាបាលបាន៣នាក់៥នាក់, ១០នាក់៨នាក់រួចហើយគឺអស់។ វាជាប្រភេទថាមពលបង្ខិនមួយ, ពីពេលនេះតទៅថាមពលបន្តិចនេះក៏គ្មានទៀត។ លោកអ្នកខ្លួនឯងគ្មានគង់, គង់មកពីណា? គ្រូឈើគង់យើងខ្ញុំឆ្លងកាត់រាប់សិបឆ្នាំបួសហាត់, អតីត

កាលបួសតាវដ៏មិនងាយស្រួល។ មិនកាន់ជាប់ធម្មក្ខន្ធសុចរិតដើម្បីបួស, បួសតាមធម្មក្ខន្ធគម្លាត, បួសតាមតាវតូច, គឺដ៏ពិបាក។

លោកអ្នកសង្កេតមើលមានគ្រូធំឈើគង់មួយចំនួនដ៏ល្បីឈ្មោះ, បួសកាលណារាប់សិបឆ្នាំ, ទើបអាចបួសចេញមកគង់បន្តិចបន្តួចយ៉ាងនោះ។ លោកអ្នកមិនធ្លាប់បួស, ចូលរួមថ្នាក់បង្រៀនលោកអ្នកគឺបានគង់មក? ទីណាមានរឿងនោះ? លោកអ្នកពីពេលនេះតទៅសាងបង្កើតចិត្តប្រកាន់។ ចិត្តប្រកាន់ផុសឡើងកាលណា, លោកអ្នកព្យាបាលមិនជាជំងឺ, លោកអ្នកនឹងបារម្ភ។ មនុស្សខ្លះដើម្បីរក្សាកិត្តិនាមខ្លួនឯង, សូម្បីតែពេលដែលគាត់ពិនិត្យជំងឺបានគិតអ្វី? ជំងឺនេះទុកឲ្យខ្ញុំទទួល, ឲ្យជំងឺរបស់គាត់ជា។ នោះមិនមែនផុសពីចិត្តមេត្តា, ចិត្តកិត្តិនាមផលប្រយោជន៍នោះរបស់គាត់ជាមូលដ្ឋានគឺមិនទាន់កម្ចាត់, ជាមូលដ្ឋានគឺមិនកើតចេញចិត្តមេត្តា។ គាត់ខ្លាចខ្លួនឯងបាត់កិត្តិនាម, អន្ទះសាខ្លាំងណាស់ទុកខ្លួនឯងទទួលជំងឺនេះ, គាត់សុទ្ធតែខ្លាចបាត់កិត្តិនាមនេះ, ចិត្តចំណង់កិត្តិនាមខ្លាំងប៉ុណ្ណា! បំណងនេះរបស់គាត់ផុសឡើងកាលណា, នោះល្អ, ជំងឺនោះភ្លាមៗគឺបំប្លែងឆ្លងមកលើរាងកាយរបស់គាត់, ពិតជាបានផ្តើមផលប៉ះពាល់នេះ, គាត់ត្រឡប់មកផ្ទះកើតជំងឺ, គេជាសះស្បើយ, មើលជំងឺឲ្យអ្នកដទៃចប់ខ្លួនឯងត្រឡប់មកផ្ទះពិបាកទ្រាំ។ លោកអ្នកមានអារម្មណ៍បានព្យាបាលជំងឺជា, អ្នកដទៃហៅលោកអ្នកមួយម៉ាត់ "គ្រូឈើគង់", លោកអ្នកត្រេកអរពេញចិត្តខ្លួនឯងអប្បមាណ, រីករាយណាស់។ នេះមិនមែនចិត្តប្រកាន់ឬ? ពេលព្យាបាលមិនជាជំងឺឱនក្បាលខកចិត្ត, នេះមិនមែនចិត្តកិត្តិនាមផលប្រយោជន៍កំពុងផ្តើមផលប៉ះពាល់ឬ? ថែមទៀតឈើជំងឺរបស់អ្នកជំងឺលោកអ្នកពិនិត្យសុទ្ធតែនឹងរត់ឆ្លងមកលើរាងកាយលោកអ្នក។ គ្រូឈើគង់នោះបង្រៀនលោកអ្នករុញចេញក្រៅដូចម្តេច, ខ្ញុំ

ប្រាប់លោកអ្នក, ជាមូលដ្ឋានគឺរុញចេញក្រៅមិនបាន, បន្តិចក៏រុញចេញក្រៅមិនបាន, ដោយសារខ្លួនលោកអ្នកផ្ទាល់គ្មានសមត្ថភាពសម្គាល់ឈឺល្អឈឺអាក្រក់។ យូរៗទៅ, ខាងក្នុងរាងកាយលោកអ្នកទាំងមូលគឺជាខ្មៅ, នោះជាក់ស្តែងជាអំណាចកម្ម។

ពេលដែលបួសហាត់ពិតប្រាកដ, លោកអ្នកត្រូវតែប្រឈមមុខនឹងបញ្ហាលំបាក, លោកអ្នកធ្វើដូចម្តេច? លោកអ្នកត្រូវតែរងទុក្ខទាំងប៉ុន្មានទើបអាចបំប្លែងវាក្លាយជាសារធាតុពណ៌ស? ពិបាកណាស់, ជាពិសេសគឺមនុស្សនិស្ស័យកាន់តែល្អកាន់តែងាយស្រួលលេចឡើងបញ្ហានេះ។ មនុស្សខ្លះតែងតែស្វែងរកព្យាបាលជំងឺ, ព្យាបាលជំងឺ។ លោកអ្នកមានចំណង់, កូនសត្វនោះអាចនឹងមើលឃើញ, វាគឺនឹងឡើងមក, នេះជាក់ស្តែងគឺជាកាយភ្ជាប់។ លោកអ្នកមិនមែនចង់ព្យាបាលជំងឺឬ? ទុកឲ្យលោកអ្នកព្យាបាល, ប៉ុន្តែវាក៏មិនមែនដោយគ្មានហេតុផលទុកឲ្យលោកអ្នកព្យាបាល, មិនបាត់គឺមិនបាន, គ្រោះថ្នាក់ណាស់, ចុងក្រោយលោកអ្នកអន្ទងវាមករួចហើយ, លោកអ្នកនៅបួសហាត់អ្វីទៀត? គឺចប់ទាំងស្រុងរួចហើយ។

មានមនុស្សនិស្ស័យល្អមួយចំនួនគឺប្រើនិស្ស័យរបស់ខ្លួនឯងប្តូរយកកម្មរបស់គេ។ មនុស្សនោះគឺមានជំងឺ, អំណាចកម្មរបស់គាត់ធំ, លោកអ្នកចង់ព្យាបាលអ្នកជំងឺធ្ងន់មួយ, លោកអ្នកពិនិត្យជំងឺចប់ត្រឡប់មកផ្ទះកុំនិយាយពិបាកទ្រាំប៉ុណ្ណា! នៅអតីតមនុស្សដ៏ច្រើនពួកយើងធ្លាប់ពិនិត្យជំងឺគឺមានប្រភេទអារម្មណ៍នេះ, អ្នកជំងឺជា, តែលោកអ្នកត្រឡប់មកផ្ទះកើតជំងឺធ្ងន់ធ្ងរ។ ពេលវេលាយូរ, អំណាចកម្មបំប្លែងដូរឆ្លងមកច្រើន, លោកអ្នកឲ្យគេគុណធម៌ប្តូរយកអំណាចកម្ម, មិនបាត់មិនបានទេតើ។ កុំឃើញលោកអ្នកចង់គឺជាជំងឺ, កម្មក៏ត្រូវប្រើគុណធម៌ដើម្បីផ្តោះប្តូរ។ ក្នុង

ចក្រវាលនេះគឺមានគោលសីលធម៌នេះ, គឺលោកអ្នកខ្លួនឯងចង់, នរណាក៏មិនគ្រប់គ្រង, ក៏មិនអាចនិយាយលោកអ្នកល្អ។ ក្នុងចក្រវាលមានប្រការពិសេសជាក់លាក់មួយ, នោះគឺអំណាចកម្មនរណាច្រើនអ្នកនោះជាក់ស្តែងជាមនុស្សអាក្រក់។ លោកអ្នកគឺប្រើនិស្ស័យរបស់ខ្លួនឯងបំប្លែងដូរយកអំណាចកម្មរបស់គាត់, អំណាចកម្មច្រើនហើយនៅបួសហាត់អ្វី? និស្ស័យទាំងមូលរបស់លោកអ្នកសុទ្ធតែត្រូវបានគាត់បំផ្លាញ។ នោះមិនគួរឲ្យខ្លាចឬ? អ្នកដទៃជាជំងឺ, គាត់សុខស្រួល, លោកអ្នកត្រឡប់មកផ្ទះពិបាកទ្រាំ។ បើសិនលោកអ្នកមើលជាអ្នកជំងឺមហារីកពីរនាក់, លោកអ្នកខ្លួនឯងគឺត្រូវតែទៅជំនួសគាត់, នេះមិនគ្រោះថ្នាក់ឬ? ជាក់ស្តែងគឺជាបែបនេះ, មនុស្សដ៏ច្រើនមិនដឹងគោលសីលធម៌ក្នុងរឿងនេះ។

មានគ្រូឈីគង់ក្លែងក្លាយមួយចំនួន, លោកអ្នកកុំឃើញថាកេរ្តិ៍ឈ្មោះគាត់ធំប៉ុណ្ណា, មានឈ្មោះល្បីល្បាញមិនជាក់លាក់គឺច្បាស់លាស់។ មនុស្សសាមញ្ញដឹងបានអ្វី? មួយក្រុមបោកបញ្ឆោត, គឺជឿតាម។ លោកអ្នកកុំឃើញគាត់បច្ចុប្បន្នធ្វើបែបនេះ, គាត់មិនត្រឹមតែធ្វើបាបមនុស្ស, គាត់ក៏ធ្វើបាបគាត់ខ្លួនឯង, កន្លងមួយទៅពីរឆ្នាំលោកអ្នកមើលគាត់បែបណា, បួសហាត់គឺមិនអនុញ្ញាតឲ្យបំផ្លាញបែបនេះ។ បួសហាត់អាចព្យាបាលជំងឺ, ប៉ុន្តែមិនមែនដើម្បីប្រើមកព្យាបាលជំងឺ។ វាជាអ្វីមួយវិសាមញ្ញ, មិនមែនភាពជំនាញការក្នុងមនុស្សសាមញ្ញពួកយើង, លោកអ្នកយកវាមកស្រេចតាមចិត្តបំផ្លាញយ៉ាងនេះគឺដាច់ខាតមិនអនុញ្ញាត។ បច្ចុប្បន្នមានគ្រូឈីគង់ក្លែងក្លាយមួយចំនួនពិតជាធ្វើឱ្យបរិយាកាសខ្មៅអួអាប់, យកឈីគង់ធ្វើជាល្បិចដើម្បីចំណង់កិត្តិនាមមានមហាសម្បត្តិ, គាត់គឺបង្កើតក្រុមអាក្រក់ដើម្បីពង្រីកឥទ្ធិពល, លើសជាងច្រើនទ្វេដងប្រៀបនឹងគ្រូឈីគង់ពិតប្រាកដ, មនុស្សសាមញ្ញសុទ្ធតែ

និយាយយ៉ាងនេះ, ធ្វើយ៉ាងនេះ, លោកអ្នកគឺជឿតាម? សន្មតថាឈើគង់ជាក់ស្តែងគឺជាបែបនេះ, មិនមែន។ តែដែលខ្ញុំសម្តែងជាគោលសីលធម៌ពិតប្រាកដ។

ពេលដែលរវាងមនុស្សនិងមនុស្សកើតឡើងគ្រប់ប្រភេទទំនាក់ទំនងសង្គម, ដើម្បីប្រយោជន៍ឯកជនបានធ្វើរឿងអាក្រក់, របស់ដែលជំពាក់, គឺត្រូវការទៅទទួលរងសំណង។ ឧបមាថា, លោកអ្នកតាមអំពើចិត្តព្យាបាល, បើសិនលោកអ្នកជាក់ស្តែងគឺពិតជាអាចព្យាបាលជាសះស្បើយ, នោះអាចអនុញ្ញាតឬ? ពុទ្ធគ្មានទីណាមិននៅ, ព្រះពុទ្ធច្រើនយ៉ាងនោះហេតុម្តេចមិនធ្វើរឿងរ៉ាវនេះ? គាត់ធ្វើឲ្យមនុស្សជាតិសុទ្ធតែសុខស្រួលល្អប៉ុណ្ណា! គាត់ហេតុអ្វីមិនធ្វើ? អំណាចកម្មរបស់មនុស្សខ្លួនឯងគឺត្រូវតែខ្លួនឯងសង, នរណាក៏មិនហ៊ានបំផ្លាញគោលសីលធម៌នេះ។ មនុស្សម្នាក់នៅក្នុងដំណើរការបួសហាត់, អាចគាត់ផុសពីចិត្តមេត្តាជួយមនុស្សម្តងម្កាល, ប៉ុន្តែនោះហួសពេកគ្រាន់តែពន្យាពេលជំងឺ។ លោកអ្នកបច្ចុប្បន្នមិនទទួលទោសក្រោយមកទទួលទោស, ឬក៏បំប្លែងដូរឲ្យលោកអ្នក, លោកអ្នកមិនកើតជំងឺលោកអ្នកបាត់លុយ, ជួបគ្រោះ, អាចជាបែបនេះ។ ពិតប្រាកដអាចធ្វើរឿងរ៉ាវនេះ, ភ្លាមៗយកកម្មនោះរំលាយចោលឲ្យលោកអ្នក, នោះគ្រាន់តែកំហិតចំពោះមនុស្សបួសហាត់, ហើយមិនអាចធ្វើឲ្យមនុស្សសាមញ្ញ។ ទីនេះខ្ញុំមិនមែនកំពុងសម្តែងអំពីគោលសីលធម៌នៃវង្សនេះរបស់ខ្ញុំ, ខ្ញុំគឺកំពុងនិយាយអំពីសច្ចធម៌នៃចក្រវាលទាំងមូលរបស់ពួកយើង, ខ្ញុំកំពុងនិយាយអំពីកាលៈទេសៈជាក់ស្តែងរបស់ពិភពបួសហាត់។

យើងខ្ញុំនៅទីនេះក៏មិនបង្រៀនលោកអ្នកព្យាបាលជំងឺ, យើងខ្ញុំគឺដឹកនាំលោកអ្នកឆ្ពោះលើផ្លូវធំ, ផ្លូវសុចរិត, នាំលោកអ្នកឆ្ពោះឡើងលើ។

ដូច្នេះពេលខ្ញុំនៅលើថ្នាក់សុទ្ធតែសម្តែងថា, សិស្សហ្វាលូនតាហ្វាសុទ្ធតែមិនអនុញ្ញាតពិនិត្យជំងឺ, លោកអ្នកពិនិត្យជំងឺគឺមិនមែនជាមនុស្សរបស់ហ្វាលូនតាហ្វាខ្ញុំ។ ដោយសារយើងខ្ញុំនាំលោកអ្នកឆ្ពោះលើផ្លូវសុចរិត, នៅក្នុងដំណើរការបួសហាត់លោកីយ៍ធម៌បន្តជួយលោកអ្នកបន្សុទ្ធរាងកាយ, បន្សុទ្ធរាងកាយ, បន្សុទ្ធរាងកាយ, រហូតដល់បានសារធាតុថាមពលខ្ពស់បំប្លែងទាំងស្រុង។ លោកអ្នកនៅតែដាក់លើរាងកាយខ្លួនឯងរបស់ពណ៌ខ្មៅទាំងនោះ, លោកអ្នកធ្វើដូចម្តេចបួសហាត់? នោះជាអំណាចកម្មទេតើ! ជាមូលដ្ឋានគឺមិនអាចបួសហាត់។ ធ្វើឲ្យលោកអ្នកច្រើន, លោកអ្នកទ្រាំមិនរួច, រងទុក្ខរងច្រើនពេកលោកអ្នកគឺមិនអាចបួស, ជាក់ស្តែងជាគោលសីលធម៌នេះ។ ខ្ញុំយកមហាធម៌នេះបង្រៀនចេញមក, លោកអ្នកអាចនៅតែមិនដឹងដែលខ្ញុំបង្រៀនជាប្រការអ្វី។ មហាធម៌នេះបានអាចបង្រៀនចេញរួចហើយ, គឺមានវិធីដើម្បីការពារគាត់។ ប្រសិនលោកអ្នកពិនិត្យជំងឺឲ្យគេ, ទាំងអស់អ្វីបួសហាត់បានដំឡើងក្នុងរាងកាយលោកអ្នក, បរមីរបស់ខ្ញុំនឹងដកហូតមកវិញទាំងស្រុង។ មិនអាចទុកឲ្យលោកអ្នកដើម្បីកិត្តិនាមផលប្រយោជន៍តាមអំពើចិត្តបំផ្លាញប្រការដ៏មានតម្លៃយ៉ាងនេះ។ មិនធ្វើតាមតម្រូវរបស់ធម៌, គឺមិនមែនជាមនុស្សរបស់ហ្វាលូនតាហ្វាយើងខ្ញុំ, រាងកាយរបស់លោកអ្នកសងត្រឡប់មកវិញឲ្យលោកអ្នកដល់ទីតាំងមនុស្សសាមញ្ញ, យករបស់មិនល្អសងមកវិញឲ្យលោកអ្នក, ដោយសារលោកអ្នកចង់ធ្វើមនុស្សសាមញ្ញ។

ចាប់ផ្តើមពីម្សិលមិញក្រោយពីស្តាប់មេរៀនចប់, មនុស្សពួកយើងដ៏ច្រើនមានអារម្មណ៍បានរាងកាយមួយស្រាល។ តែអ្នកជំងឺធ្ងន់តិចតួចបំផុតធ្វើមុន, ម្សិលមិញចាប់ផ្តើមពិបាកទ្រាំ។ ម្សិលមិញក្រោយពីខ្ញុំយកចុះរបស់មិនល្អលើរាងកាយអ្នករាល់គ្នា, មនុស្សពួកយើងភាគច្រើន

មានអារម្មណ៍បានរាងកាយមួយស្រាល, រាងកាយសែនសុខស្រួល។ ប៉ុន្តែ, ក្នុងចក្រវាលនេះរបស់ពួកយើងមានគោលសីលធម៌ហៅថាមិនបាត់មិនបាន, មិនអាចជួយលោកអ្នកយកចុះទាំងអស់បាន, លោកអ្នកមិនរងទ្រាំសូម្បីតែបន្តិចនេះគឺដាច់ខាតមិនអនុញ្ញាត។ ក៏មានន័យថាមូលហេតុមូលដ្ឋានរបស់ជំងឺលោកអ្នក, មូលហេតុមូលដ្ឋាននៃអ្វីមិនល្អរបស់រាងកាយលោកអ្នកយើងខ្ញុំជួយលោកអ្នកយកចេញបាត់, ប៉ុន្តែលោកអ្នកនៅមានវាលជំងឺមួយ។ ពេលដែលភ្នែកទិព្វបើកនៅជាន់ថ្នាក់ដ៏ទាប, មើលឃើញក្នុងរាងកាយមានឈើខ្មៅមួយក្រុមៗ, ឈើជំងឺកខ្វក់, វាក៏ជាឈើខ្មៅមួយក្រុមដែលខាប់, មួយក្រុមឈើខ្មៅកំហាប់ដ៏ធំ, វាខ្ចាត់ចេញកាលណានឹងពោរពេញទាំងមូលរាងកាយលោកអ្នក។

ចាប់ផ្តើមពីថ្ងៃនេះ, មនុស្សខ្លះនឹងមានអារម្មណ៍បានរាងកាយទាំងមូលត្រជាក់, ដូចបែបកើតផ្តាសាយធ្ងន់ធ្ងរ, អាចឆ្អឹងត្រូវឈឺចាប់ទាំងសព្វ។ មនុស្សភាគច្រើននឹងមានអារម្មណ៍បានមិនសុខស្រួលតាមតំបន់, ឈឺជើង, វិលមុខ។ ពីមុនកន្លែងលោកអ្នកធ្លាប់មានជំងឺអាចមានអារម្មណ៍ថាហាត់ឈើគង់ហាត់ជារួចហើយ, ក៏អាចគ្រូឈើគង់ណាមើលឲ្យលោកអ្នករួចហើយ, តែលេចឡើងសាជាថ្មីម្តងទៀត។ នោះគឺដោយសារគាត់មិនព្យាបាលជាសះស្បើយឲ្យលោកអ្នក, គ្រាន់តែពន្យាមកក្រោយឲ្យលោកអ្នក, នៅតែនៅលើទីតាំងនោះ, លោកអ្នកឥឡូវមិនកើត, អនាគតកើត។ យើងខ្ញុំសុទ្ធតែត្រូវកកាយវាចេញ, សុទ្ធតែត្រូវរុញចេញឲ្យលោកអ្នក, កម្ចាត់ទាំងអស់ពីឫសគល់។ បែបនេះបន្តមក, អាចលោកអ្នកមានអារម្មណ៍ថាជំងឺកើតឡើងម្តងទៀត, នេះគឺកម្ចាត់កម្មពីឫសគល់, ដូច្នេះលោកអ្នកនឹងមានប្រតិកម្ម, មនុស្សខ្លះនឹងមានប្រតិកម្មតាមតំបន់, ពិបាកទ្រាំយ៉ាងនេះ, ពិបាកទ្រាំយ៉ាងនោះ, ពិបាកទ្រាំគ្រប់

ប្រភេទសុទ្ធតែនឹងឡើងមក, សុទ្ធតែជាធម្មតា។ ខ្ញុំប្រាប់អ្នករាល់គ្នា, មិនថាពិបាកទ្រាំដូចម្តេច, ដាច់ខាតត្រូវព្យាយាមមកស្តាប់សម្តែងមេរៀន, ដរាបណាលោកអ្នកចូលក្នុងថ្នាក់បង្រៀន, រោគសញ្ញាអ្វីរបស់លោកអ្នកក៏បាត់, នឹងមិនលេចឡើងគ្រោះថ្នាក់ណាមួយ។ ចំណុចមួយនេះនិយាយជាមួយអ្នករាល់គ្នា, លោកអ្នកមានអារម្មណ៍ថាជំងឺទោះធ្ងន់ដូចម្តេច, សង្ឃឹមថាលោកអ្នកសុទ្ធតែព្យាយាមមក, ធម៌ពិបាកបាន។ ពេលលោកអ្នកកាន់តែពិបាកទ្រាំនិយាយច្បាស់ថាវត្ថុដល់ប៉ូលនឹងបញ្ច្រាស, រាងកាយលោកអ្នកទាំងមូលត្រូវការបន្សុទ្ធ, ចាំបាច់បន្សុទ្ធទាំងអស់។ ឫសគល់ជំងឺបានដកចេញរួចហើយ, គ្រាន់តែនៅសល់បន្តិចឈីខ្មៅនេះទុកឲ្យវាបញ្ចេញទៅក្រៅដោយខ្លួនឯង, ទុកឲ្យលោកអ្នករងទ្រាំលំបាកបន្តិចយ៉ាងនោះ, ទទួលរងទោសបន្តិច, លោកអ្នកមិនរងទ្រាំសូម្បីតែបន្តិចនេះគឺមិនបាន។

នៅក្នុងសង្គមមនុស្សសាមញ្ញព្រោះតែកិត្តិនាម, ផលប្រយោជន៍, ប្រជែងប្រយុទ្ធរវាងមនុស្សនិងមនុស្ស, លោកអ្នកដេកមិនលក់, បាយមិនឆ្ងាញ់, លោកអ្នកបានធ្វើឲ្យរូបរាងកាយដ៏យ៉ាប់យ៉ុនរួចហើយ, នៅអវកាសផ្សេងមើលរាងកាយលោកអ្នក, ឆ្អឹងនោះកង់ណាក៏ជាខ្មៅ។ ជារាងកាយបែបនេះ, ភ្លាមៗបន្សុទ្ធចេញមកឲ្យលោកអ្នក, គ្មានប្រតិកម្មបន្តិចណាសោះក៏មិនបាន, ដូច្នេះលោកអ្នកនឹងមានប្រតិកម្ម។ មនុស្សខ្លះសូម្បីតែនឹងក្អួតរាគបន្តបន្ទាប់។ អតីតមានសិក្ខាកាមជាច្រើនតំបន់សរសេរឲ្យខ្ញុំក្នុងចិត្តបានយល់ដឹងលើកឡើងបញ្ហានេះនិយាយថា៖ លោកគ្រូ, កូនពីថ្នាក់បង្រៀនស្តាប់មេសម្តែងចប់ត្រឡប់មកផ្ទះ, ដើរតាមផ្លូវរមែងរកបន្ទប់ទឹក, រហូតរកដល់ផ្ទះ។ ដោយសារសរីរាង្គខាងក្នុងសុទ្ធតែត្រូវតែបន្សុទ្ធ។ មនុស្សខ្លះដោយឡែកក៏នឹងគេង, ខ្ញុំសម្តែងចប់គាត់ក៏ភ្ញាក់ពី

គេង។ ហេតុអ្វី? ដោយសារខាងក្នុងខួរធំរបស់គាត់មានជំងឺ, ត្រូវកែសម្រួលឲ្យគាត់។ ខួរធំប្រសិនកែសម្រួល, គាត់ជាមូលដ្ឋានទ្រាំមិនបាន, ដូច្នេះចាំបាច់ត្រូវទុកឲ្យគាត់ចូលក្នុងស្ថានភាពសន្លប់, គាត់មិនដឹង។ ប៉ុន្តែមនុស្សខ្លះផ្នែកសោតវិញ្ញាណគ្មានបញ្ហា, គាត់គេងស្ងប់ណាស់, តែផ្ទុយមកវិញមួយអក្សរមិនជ្រុះ, សុទ្ធតែស្ដាប់ចូលបានទាំងអស់, មនុស្សពីពេលនេះស្មារតីផុសឡើង, ពីរថ្ងៃមិនគេងក៏មិនងងុយ។ សុទ្ធតែជាស្ថានភាពខុសគ្នា, សុទ្ធតែត្រូវការកែសម្រួល, រាងកាយទាំងមូលត្រូវការបន្សុទ្ធទាំងអស់ឲ្យលោកអ្នក។

មនុស្សហាត់ហ្វាលូនតាហ្វាពិតប្រាកដ, ពេលដែលលោកអ្នកអាចដាក់ចិត្តចុះ, ចាប់ផ្ដើមពីពេលនេះសុទ្ធតែមានប្រតិកម្ម។ មនុស្សទាំងនោះដែលដាក់ចុះមិនបាន, គាត់លើមាត់និយាយថាដាក់ចុះ, ភាពពិតគាត់ជាមូលដ្ឋានដាក់ចុះមិនបាន, ដូច្នេះគឺដ៏ពិបាកធ្វើបាន។ ក៏មានមនុស្សមួយផ្នែកក្រោយមកបានស្ដាប់យល់ច្បាស់ខ្លឹមសារនៃមេរៀនខ្ញុំសម្ដែង, គាត់ដាក់ចុះបាន, រាងកាយបានបន្សុទ្ធ, អ្នកដទៃសុទ្ធតែរាងកាយមួយស្រាល, គាត់ទើបចាប់ផ្ដើមបានជាជំងឺ, ទើបចាប់ផ្ដើមពិបាកទ្រាំ។ រាល់ថ្នាក់បង្រៀនសុទ្ធតែមានប្រភេទឱនថយនេះ, ចរិតភ្ជាក់ដឹងខ្សោយបន្តិច, ដូច្នេះលោកអ្នកមិនថាជួបប្រទះកាលៈទេសៈអ្វីសុទ្ធតែជាធម្មតា។ ពេលដែលបើកថ្នាក់នៅតំបន់ផ្សេង, សុទ្ធតែលេចឡើងកាលៈទេសៈនេះ, មនុស្សខ្លះដ៏ពិបាកទ្រាំ, ពោបនៅលើកៅអីមិនក្រោក, ចាំខ្ញុំពីលើវេទិកាចុះមកព្យាបាលឲ្យគាត់។ ខ្ញុំនឹងមិនកម្រើកដៃព្យាបាល, គ្រាន់តែទ្វារមួយនេះលោកអ្នកក៏ឆ្លងមិនបាន, ក្រោយមកពេលលោកអ្នកខ្លួនឯងបួសហាត់, លោកអ្នកនឹងលេចឡើងមហាគ្រោះថ្នាក់ជាច្រើន, នេះក៏ឆ្លងមិនបាន, លោកអ្នកនៅបួសហាត់អ្វីទៀត? រឿងបន្តិចយ៉ាងនេះលោកអ្នកក៏ឆ្លងមិន

បានឬ? សុទ្ធតែអាចឆ្លងបាន។ ដូច្នេះលោកអ្នកកុំរកខ្ញុំព្យាបាលជំងឺទៀត, ខ្ញុំក៏មិនព្យាបាលជំងឺ, លោកអ្នកលើកឡើងពាក្យ "ជំងឺ" នេះកាលណា, ខ្ញុំគឺមិនចង់ស្តាប់។

មនុស្សជាក់ស្តែងគឺដ៏ពិបាកប្រោស, រាល់ថ្នាក់បង្រៀនណាក៏មានមនុស្ស៥, ១០ភាគរយយ៉ាងនោះមិនឡើងតាមបាន។ នរណាៗក៏សម្រេចតាវគឺមិនអាច, គឺសុទ្ធតែមនុស្សអាចព្យាយាមហាត់រួចហើយ, នៅត្រូវការមើលលោកអ្នកអាចឬមិនអាចបួសចេញមក, នៅតែត្រូវមើលលោកអ្នកអាចឬមិនអាចប្តេជ្ញាចិត្តបួស, នរណាៗក៏ក្លាយជាព្រះពុទ្ធនេះមិនអាចទេ។ ពិតជាបួសមហាធម៌, អានសៀវភៅនឹងមានស្ថានភាពដូចគ្នាលេចឡើង, ដូចគ្នាទទួលបានទាំងអស់អ្វីដែលគួរទទួលបាន។

# មេសម្តែងទី៣

## ខ្ញុំចាត់ទុកសិក្ខាកាមសុទ្ធតែដូចជាសិស្ស

អ្នករាល់គ្នាដឹងឬ? ខ្ញុំកំពុងធ្វើរឿងរ៉ាវអ្វី? ខ្ញុំចាត់ទុកសិក្ខាកាមទាំងអស់សុទ្ធតែណែនាំដូចជាសិស្ស, រួមទាំងមនុស្សដែលរៀនខ្លួនឯងហើយអាចបួសហាត់ពិតប្រាកដ។ បង្រៀនគង់ឡើងលើជាន់ថ្នាក់ខ្ពស់, មិនណែនាំលោកអ្នកបែបនេះមិនបាន, នោះគឺស្មើនឹងមិនទទួលខុសត្រូវ, ធ្វើចលាចល។ យើងខ្ញុំផ្ដល់ឲ្យលោកអ្នករបស់ច្រើនយ៉ាងនេះ, ទុកឲ្យលោកអ្នកបានដឹងគោលសីលធម៌ច្រើនយ៉ាងនេះដែលមនុស្សសាមញ្ញមិនគួរបានដឹង, ខ្ញុំយកមហាធម៌នេះបង្រៀនឲ្យលោកអ្នក, ព្រមទាំងផ្ដល់ឲ្យលោកអ្នករបស់ដ៏ច្រើន។ រាងកាយបន្សុទ្ធឲ្យលោកអ្នក, លើសពីនេះនៅជាប់ពាក់ព័ន្ធដល់បញ្ហាផ្សេងមួយចំនួន, ដូច្នេះមិនចាត់ទុកលោកអ្នកណែនាំដូចជាសិស្ស, ជាមូលដ្ឋានគឺមិនបាន។ តាមអំពើចិត្តហើយបង្ហាញអាថ៌កំបាំងធម្មជាតិច្រើនយ៉ាងនេះឲ្យមនុស្សសាមញ្ញម្នាក់, នោះគឺមិនអនុញ្ញាត។ តែមានចំណុចមួយ, សម័យកាលបច្ចុប្បន្នក៏ប្រែរួចហើយ, ពួកយើងក៏មិនធ្វើតាមទម្រង់ក្រាបក្បាលសំពះគ្រូនោះទៀត។ ទម្រង់នោះគ្មានប្រយោជន៍អ្វី, ធ្វើទៅដូចសាសនា, ពួកយើងមិនធ្វើដូច្នេះ។ ដោយសារលោកអ្នកក្រាបក្បាលរួចហើយ, សំពះគ្រូរួចហើយ, លោកអ្នកចេញផុតទ្វារនៅតែជាចង់អីធ្វើនោះ, នៅក្នុងមនុស្សសាមញ្ញលោកអ្នកគួរតែធ្វើអ្វីនៅតែធ្វើនោះ, ព្រោះតែកិត្តិនាមផលប្រយោជន៍របស់លោកអ្នក, លោកអ្នកទៅប្រជែង, លោកអ្នកទៅប្រយុទ្ធ, នោះមានប្រយោជន៍អ្វី? លោកអ្នកអាចនៅនឹងកាន់បដារបស់ខ្ញុំ, បង្ខូចកេរ្តិ៍ឈ្មោះរបស់មហាធម៌ទៀតផង!

រឿងរ៉ាវបួសហាត់ពិតប្រាកដគឺពឹងផ្អែកទាំងស្រុងលើចិត្តនេះរបស់លោកអ្នកដើម្បីបួស, ដរាបណាលោកអ្នកអាចបួស, ដរាបណាលោកអ្នកអាចបួសខ្ជាប់ខ្ជួនដោយមិនប្រែប្រួល, យើងខ្ញុំគឺចាត់ទុកលោកអ្នកណែនាំដូចជាសិស្ស, មិនប្រព្រឹត្តបែបនេះក៏មិនបាន។ ប៉ុន្តែមានមនុស្សមួយចំនួន, គាត់មិនជាក់លាក់អាចពិតប្រាកដចាត់ទុកខ្លួនឯងធ្វើជាមនុស្សបួសហាត់ដើម្បីបន្តបួស, មានមនុស្សមួយចំនួនគឺមិនអាច។ ប៉ុន្តែមនុស្សដ៏ច្រើននឹងបន្តបួសហាត់ពិតប្រាកដ។ ដរាបណាលោកអ្នកបន្តបួស, យើងខ្ញុំគឺចាត់ទុកលោកអ្នកណែនាំដូចជាសិស្ស។

រាល់ថ្ងៃហាត់តែប៉ុន្មានសំណុំចលនានេះ, គឺចាត់ថាជាសិស្សរបស់ហ្វាលូនតាហ្វាឬ? នោះគឺមិនប្រាកដទេ។ ដោយសារបួសហាត់ពិតប្រាកដត្រូវតែយោងតាមបរមាណើយចិត្តចរិតនោះដែលយើងខ្ញុំនិយាយដើម្បីតម្រូវ, ត្រូវតែពិតប្រាកដលើកកម្ពស់ចិត្តចរិតខ្លួនឯង, នោះទើបជាបួសហាត់ពិតប្រាកដ។ លោកអ្នកគ្រាន់តែទៅហាត់ចលនាទាំងនោះ, ចិត្តចរិតលើកកម្ពស់ឡើងមិនបាន, គ្មានថាមពលខ្លាំងធំដើម្បីពង្រឹងទាំងអស់, មិនទាន់និយាយដល់បួសហាត់បាន, យើងខ្ញុំក៏មិនអាចចាត់ទុកលោកអ្នកធ្វើជាសិស្សរបស់ហ្វាលូនតាហ្វា។ លោកអ្នកបន្តដូចនេះ, កុំឃើញថាលោកអ្នកហាត់គង់, មិនយោងតាមតម្រូវហ្វាលូនតាហ្វារបស់យើងខ្ញុំ, លោកអ្នកមិនលើកកម្ពស់ចិត្តចរិត, នៅក្នុងមនុស្សសាមញ្ញលោកអ្នកនៅតែជាចង់អីធ្វើនោះ, ប្រហែលជាលោកអ្នកនៅតែអាចជួបប្រទះរឿងរំខានផ្សេងៗ, ធ្វើមិនល្អលោកអ្នកនៅអាចនិយាយថាហាត់ហ្វាលូនតាហ្វាយើងខ្ញុំធ្វើឲ្យលោកអ្នកហាត់គម្លាត, ប្រការនេះសុទ្ធតែអាច។ ដូច្នេះលោកអ្នកត្រូវតែពិតប្រាកដយោងតាមតម្រូវបរមាណើយចិត្តចរិតរបស់យើងខ្ញុំដើម្បីធ្វើ, នោះទើបជាមនុស្សបួសហាត់ពិតប្រាកដ។

ខ្ញុំសម្តែងឲ្យអ្នករាល់គ្នាច្បាស់លាស់រួចហើយ, ដូច្នេះអ្នករាល់គ្នាក៏កុំរកខ្ញុំធ្វើរឿងរ៉ាវសំពះគ្រូទម្រង់ទាំងនេះទៀត, ដរាបណាលោកអ្នកបួសពិត, ខ្ញុំគឺប្រព្រឹត្តបែបនេះចំពោះលោកអ្នក។ បរមីរបស់ខ្ញុំច្រើនមិនអាចរាប់បាន, ពុំថាសិក្ខាកាមទាំងនេះ, ច្រើនទៀតខ្ញុំក៏គ្រប់គ្រងបាន។

## គង់ពុទ្ធវង្សនិងពុទ្ធសាសនា

គង់ពុទ្ធវង្សមិនមែនពុទ្ធសាសនា, ចំណុចមួយនេះខ្ញុំសម្តែងច្បាស់លាស់ឲ្យអ្នករាល់គ្នា, ភាពពិតគង់តាវវង្សក៏មិនមែនតាវសាសនា។ ពួកយើងមានមនុស្សមួយចំនួនរមែងមិនយល់ច្បាស់រឿងរ៉ាវទាំងនេះ។ មានមនុស្សមួយចំនួនគឺជាព្រះសង្ឃក្នុងវត្ត, ក៏មានមនុស្សមួយចំនួនគឺជាឧបាសក, គាត់មានអារម្មណ៍ថាគាត់ដឹងច្រើនចំពោះរឿងក្នុងពុទ្ធសាសនា, គាត់គឺឃោសនាយ៉ាងក្លៀវក្លារឿងរ៉ាវក្នុងពុទ្ធសាសនានៅក្នុងសិក្ខាកាមពួកយើង។ ខ្ញុំប្រាប់លោកអ្នក, លោកអ្នកកុំធ្វើបែបនេះ, ដោយសារនេះជាប្រការក្នុងធម្មក្ខន្ធខុសគ្នា។ សាសនាមានទម្រង់របស់សាសនា, ហើយយើងខ្ញុំទីនេះគឺបង្រៀនផ្នែកមួយនៃធម្មក្ខន្ធបួសហាត់របស់យើងខ្ញុំ, ក្រៅពីសិស្សបួសជំនាញរបស់ហ្វាលូនតាហ្វាមិនសម្តែងទម្រង់សាសនា, ដូច្នេះមិនមែនជាពុទ្ធសាសនាក្នុងសម័យកាលផុតធម៌។

ពុទ្ធសាសនាគ្រាន់តែជាផ្នែកតូចមួយក្នុងពុទ្ធវង្ស, នៅមានមហាធម៌ខ្ពស់ជ្រៅជាច្រើន, ក្នុងបណ្តាជាន់ថ្នាក់នៅមានធម៌ខុសគ្នា។ សក្យមុនីសម្តែង, បួសហាត់មាន៨ម៉ឺន៤ពាន់ធម្មក្ខន្ធ។ ក្នុងពុទ្ធសាសនាមានតែប៉ុន្មានធម្មក្ខន្ធប៉ុណ្ណោះ, វាមានតែធានថាយចុង, ហួរយានចុង, ឆានចុង, ជិញធូ, មីចុងជាដើមប៉ុន្មានធម្មក្ខន្ធយ៉ាងនេះ, សូម្បីតែប្រភាគក៏មិនគ្រប់! ដូច្នេះវាគ្របដណ្តប់មិនបានពុទ្ធធម៌ទាំងមូល, វាគ្រាន់តែជាផ្នែកតូចមួយរបស់ពុទ្ធធម៌។ ហ្វាលូនតាហ្វាពួកយើងក៏ជាធម្មក្ខន្ធមួយក្នុង៨ម៉ឺន៤ពាន់

ធម្មក្ខន្ធ, គ្មានទំនាក់ទំនងអ្វីនឹងពុទ្ធសាសនាបុព្វកាលរហូតដល់ពុទ្ធសាសនាសម័យកាលផុតធម៌, ក៏គ្មានទំនាក់ទំនងនឹងសាសនាបច្ចុប្បន្នផងដែរ។

ពុទ្ធសាសនាគឺដោយបានសក្យមុនីបង្កើតឡើង២៥០០ឆ្នាំមុននៅប្រទេសឥណ្ឌាបុរាណ។ នាគ្រានោះបន្ទាប់ពីសក្យមុនីបើកគង់ត្រាស់ដឹង, ក្នុងការចងចាំរបស់គាត់បាននឹកឃើញដល់ប្រការដែលគាត់ខ្លួនឯងបួសហាត់ពីមុន, យកវាបង្រៀនចេញប្រោសមនុស្ស។ ធម្មក្ខន្ធមួយនោះរបស់គាត់មិនថាចេញបានសៀវភៅគម្ពីរប៉ុន្មានម៉ឺនក្បាល, ភាពពិតគឺ៣អក្សរ, លក្ខណៈធម្មក្ខន្ធនោះរបស់គាត់បានហៅថា [សីល---សមាធិ---បញ្ញា]។ សីល, នោះគឺបោះបង់តណ្ហាទាំងអស់ក្នុងមនុស្សសាមញ្ញ, បង្ខំធ្វើឱ្យលោកអ្នកបាត់ទៅការស្វែងរកចំពោះផលប្រយោជន៍, កាត់ផ្ដាច់ប្រការទាំងអស់របស់លោកីយ៍។ល។ បែបនេះចិត្តរបស់គាត់គឺប្រែជាទទេ, អ្វីក៏មិនគិត, ក៏ជាអាចរម្ងាប់ចុះបាន, វាគឺបំពេញគ្នាទៅវិញទៅមក។ ក្រោយពីរម្ងាប់ចុះ, ត្រូវការអង្គុយសមាធិបួសជាក់ស្ដែង, ពឹងផ្អែកកម្លាំងរម្ងាប់បួសឡើងលើ, នេះជាក់ស្ដែងជាផ្នែកបួសហាត់ពិតប្រាកដរបស់ធម្មក្ខន្ធនោះ, គាត់ក៏មិនសម្ដែងប្រការនៃលំហាត់, មិនផ្លាស់ប្រែរាងកាយដើមរបស់ខ្លួនឯង។ គាត់គ្រាន់តែជាបួសគង់ជាន់ថ្នាក់ខ្ពស់ឬទាបរបស់គាត់, ដូច្នេះតែប្រការមួយបួសហាត់ចិត្តចរិតរបស់គាត់, មិនបួសជីវិតក៏មិនសម្ដែងការបំប្លែងរបស់គង់។ ក្នុងពេលដំណាលគ្នាគាត់នៅក្នុងសមាធិពង្រឹងកម្លាំងរម្ងាប់របស់គាត់, នៅក្នុងអង្គុយសមាធិរងទុក្ខ, រំលាយកម្មរបស់គាត់។ បញ្ញា, នោះជាក់ស្ដែងគឺសំដៅលើមនុស្សត្រាស់ដឹង, មហាប្រាជ្ញាមហាបញ្ញា។ មើលឃើញសច្ចធម៌នៃចក្រវាល, មើលឃើញសេចក្ដីពិតនៃបណ្ដាអវកាសចក្រវាល, ទេពអំណាចមហាបង្ហាញ។ បើកបញ្ញា, ត្រាស់

ដឹង, ក៏ហៅថាបើកគង់ផងដែរ។

នាគ្រានោះពេលដែលសក្យមុនីបង្កើតឡើងធម្មក្ខន្ធមួយនេះ, នៅឥណ្ឌាមានសាសនា៨ប្រភេទផ្សព្វផ្សាយក្នុងពេលដំណាលគ្នា, មានសាសនាមួយចាក់ឫសជ្រៅរឹងមាំហៅថាព្រាហ្មណ៍សាសនា។ សក្យមុនីនៅអំឡុងឆ្នាំមានជីវិត, តែងតែកើតឡើងការតស៊ូខាងមនោគមវិជ្ជានឹងសាសនាដទៃ។ ដោយសារសក្យមុនីបង្រៀនជាសុចរិតធម៌, ដូច្នេះនៅក្នុងដំណើរការបង្រៀនធម៌ទាំងមូល, ពុទ្ធធម៌ដែលគាត់បង្រៀនមួយថ្ងៃកាន់តែពេញនិយម។ ហើយសាសនាដទៃគឺមួយថ្ងៃកាន់តែចុះខ្សោយ, សូម្បីតែព្រាហ្មណ៍សាសនាដែលចាក់ឫសជ្រៅរឹងមាំនោះក៏ស្ថិតក្នុងស្ថានភាពជិតវិនាស។ ប៉ុន្តែក្រោយពីសក្យមុនីនិព្វាន, សាសនាដទៃក៏ចាប់ផ្ដើមរីកចម្រើនឡើងវិញ, ជាពិសេសគឺព្រាហ្មណ៍សាសនា, ក៏ចាប់ផ្ដើមរីកចម្រើនសាជាថ្មី។ ហើយផ្ទុយមកវិញក្នុងពុទ្ធសាសនាបានលេចឡើងកាលៈទេសៈអ្វី? មានព្រះសង្ឃមួយចំនួននៅក្នុងជាន់ថ្នាក់ខុសគ្នាបានបើកគង់, បានត្រាស់ដឹង, តែជាន់ថ្នាក់ដែលត្រាស់ដឹងទាបបង្គួរ។ សក្យមុនីសម្រេចបានជាន់ថ្នាក់យូឡាយ, ហើយព្រះសង្ឃជាច្រើនមិនទាន់សម្រេចបានជាន់ថ្នាក់នេះ។

នៅក្នុងជាន់ថ្នាក់ខុសគ្នាពុទ្ធធម៌មានលាតត្រដាងខុសគ្នា, ប៉ុន្តែកាន់តែខ្ពស់កាន់តែឈានជិតសច្ចធម៌, កាន់តែទាបឃ្លាតសច្ចធម៌កាន់តែឆ្ងាយ។ ដូច្នេះព្រះសង្ឃទាំងនោះនៅលើជាន់ថ្នាក់ទាបបើកគង់ត្រាស់ដឹង, ពួកគាត់ប្រើបាតុភូតលាតត្រដាងក្នុងចក្រវាលដែលគាត់មើលឃើញនៅក្នុងជាន់ថ្នាក់របស់ខ្លួនឯង, កាលៈទេសៈដែលយល់បាននិងគោលសីលធម៌ដែលត្រាស់បាន, ទៅពន្យល់ពាក្យដែលសក្យមុនីធ្លាប់សម្ដែង។ ក៏មានន័យថា, ព្រះសង្ឃខ្លះចំពោះធម៌ដែលសក្យមុនីធ្លាប់សម្ដែងធ្វើការ

ពន្យល់យ៉ាងនេះ, ពន្យល់យ៉ាងនោះ។ នៅមានព្រះសង្ឃមួយចំនួនប្រើប្រការដែលខ្លួនឯងបួសយល់បានចាត់ទុកដូចជាពាក្យរបស់សក្យមុនីដើម្បីសម្តែង, ប៉ុន្តែមិនសម្តែងដោយពាក្យដើមរបស់សក្យមុនី។ បែបនេះបណ្តាលឱ្យពុទ្ធធម៌ទ្រង់ទ្រាយផ្លាស់ប្តូរទាំងស្រុង, ជាមូលដ្ឋានគឺមិនមែនធម៌ដែលសក្យមុនីធ្លាប់បង្រៀន, ចុងក្រោយគឺធ្វើឲ្យពុទ្ធធម៌ក្នុងពុទ្ធសាសនានៅឥណ្ឌារលាយបាត់។ នេះជាមេរៀនប្រវត្តិសាស្ត្រមួយដងសំខាន់បំផុត, ដូច្នេះក្រោយមកឥណ្ឌាផ្ទុយមកវិញគ្មានពុទ្ធសាសនាទៀត។ នៅមុនពេលរលាយបាត់ពុទ្ធសាសនាបានឆ្លងកាត់កំណែទម្រង់ច្រើនដង, ចុងក្រោយបានបញ្ចូលជាមួយនឹងប្រការរបស់ព្រាហ្មណ៍សាសនា, បង្កើតជាប្រភេទសាសនាមួយបច្ចុប្បន្ននៅឥណ្ឌា, ហៅថាហិណ្ឌូសាសនា, ក៏មិនគោរពបូជាព្រះពុទ្ធណា, តែគោរពបូជាប្រការផ្សេងៗ, ក៏មិនជំនឿសក្យមុនី, វាជាកាលៈទេសៈមួយបែបនេះ។

ពុទ្ធសាសនានៅក្នុងដំណើរការអភិវឌ្ឍន៍, បានលេចឡើងកំណែទម្រង់ប៉ុន្មានដងធំបង្គួរ។ មួយគឺពេលវេលាមិនយូរក្រោយពីសក្យមុនីមិននៅលើលោក, មានមនុស្សបានយោងតាមគោលសីលធម៌នៅជាន់ថ្នាក់ខ្ពស់ដែលសក្យមុនីធ្លាប់សម្តែង, បង្កើតឡើងពុទ្ធសាសនាមហាយាន។ សន្មតថាធម៌ដែលសក្យមុនីសម្តែងជាសាធារណៈគឺសម្តែងឱ្យមនុស្សធម្មតាស្តាប់, ប្រើដើម្បីរំដោះខ្លួនឯង, សម្រេចបានផលញាណអរហន្ត, មិនសម្តែងប្រោសសត្វលោកទាំងឡាយ, ក៏បានហៅវាថាពុទ្ធសាសនាហិនយាន។ ព្រះសង្ឃបណ្តាប្រទេសអាស៊ីភាគអាគ្នេយ៍បានរក្សាវិធីសាស្ត្របួសហាត់បុព្វកាលនៃសម័យកាលសក្យមុនី, ជនជាតិហានពួកយើងយកវាហៅថាពុទ្ធសាសនាហិនយាន។ ប្រាកដណាស់គាត់ខ្លួនឯងគឺមិនទទួលស្គាល់, ពួកគាត់សន្មតថាពួកគាត់គឺទទួល

មរតកប្រការដើមរបស់សក្យមុនី។ មែនទែនគឺជាបែបនេះ, ពួកគាត់ជាមូលដ្ឋានបានទទួលដំណែលវិធីសាស្ត្របួសហាត់សម័យកាលសក្យមុនី។

ពុទ្ធសាសនាមហាយានដែលឆ្លងកាត់កំណែទម្រង់ក្រោយពីបង្រៀនចូលក្នុងប្រទេសចិនពួកយើង, នៅប្រទេសចិនពួកយើងបានថេរមកវិញ, នោះជាប្រភេទពុទ្ធសាសនាដែលបានផ្សព្វផ្សាយនៅប្រទេសយើងបច្ចុប្បន្ន។ តាមពិតទៅវានិងពុទ្ធសាសនាសម័យកាលសក្យមុនីទ្រង់ទ្រាយផ្លាស់ប្តូរទាំងស្រុងរួចហើយ, ពីស្បង់ចីពររហូតដល់ស្ថានភាពយល់ដឹងទាំងមូល, ដំណើរការបួសហាត់សុទ្ធតែកើតឡើងការផ្លាស់ប្តូរ។ ពុទ្ធសាសនាបុព្វកាលគ្រាន់តែចាត់ទុកសក្យមុនីធ្វើជាអង្គសក្ការៈដើម្បីគោរពបូជា, ប៉ុន្តែពុទ្ធសាសនាបច្ចុប្បន្នបានលេចឡើងព្រះពុទ្ធនិងព្រះមហាពោធិសត្វជាច្រើនជាដើម, លើសពីនេះទៀតគឺជាជំនឿពហុពុទ្ធ។ បានលេចឡើងជំនឿចំពោះព្រះពុទ្ធដ៏ច្រើន, បានក្លាយជាប្រភេទពុទ្ធសាសនាពហុពុទ្ធមួយ។ ដូចជាព្រះពុទ្ធអាមីធួរ, ព្រះពុទ្ធយ៉ាវស៊ឺ, តារីយូឡាយជាដើម, ក៏លេចឡើងព្រះមហាពោធិសត្វជាច្រើនផងដែរ។ បែបនេះបន្តមកពុទ្ធសាសនាទាំងមូលនិងពេលដែលសក្យមុនីបង្កើតឡើងនាពេលនោះបានខុសគ្នាទាំងស្រុងរួចហើយ។

នៅរយៈកាលនេះក៏ធ្លាប់កើតឡើងដំណើរការកំណែទម្រង់មួយ, ដោយសារព្រះពោធិសត្វឡុងស៊ូបានបង្រៀនចេញប្រភេទវិធីសាស្ត្របួសសម្ងាត់មួយ, ពីឥណ្ឌាឆ្លងកាត់អាហ្វហ្គានីស្តង់, បន្ទាប់មកបង្រៀនចូលក្នុងស៊ីនជាំងដីជនជាតិហានពួកយើង, គាប់ជួនជារាជវង្សថាង, ដូច្នេះយកវាហៅថាថាងមី។ ដោយសារប្រទេសចិនពួកយើងទទួលរងឥទ្ធិពលរបស់ខុងជឺវង្សធំបង្គួរ, គំនិតសីលធម៌និងជាតិសាសន៍ធម្មតាមិន

ដូចគ្នា។ ក្នុងធម្មក្ខន្ធបួសហាត់របស់មីចុងនេះមានប្រការនៃប្រុសស្រី បួសទាំងទ្វេ, មិនអាចត្រូវបានសង្គមនាគ្រានោះទទួលយក, ដូច្នេះ ក្នុងសម័យកាលពន្លត់ព្រះពុទ្ធនៅអំឡុងឆ្នាំហួយឆាងនៃរាជវង្សថាងវាត្រូវ បានបំបាត់រួចហើយ, ថាងមីនៅដីជនជាតិហានពួកយើងបានរំលាយ បាត់រួចហើយ។ បច្ចុប្បន្នជប៉ុនមានហៅថាទុងមី, នាគ្រានោះជាក់ស្តែង គឺរៀនចេញទៅពីប្រទេសចិនពួកយើង, ប៉ុន្តែគាត់គ្មានឆ្លងកាត់ស្រោច កំពូល។ យោងតាមមីចុងសម្តែង, គ្មានស្រោចកំពូលហើយរៀនប្រការ របស់មីចុង, គឺស្ថិតក្នុងលួចធម៌, មិនបានទទួលស្គាល់ជាបង្រៀនដោយ ផ្ទាល់។ មួយមែកផ្សេងពីឥណ្ឌា, នេប៉ាល់បង្រៀនចូលក្នុងទីបេ, ហៅ ថាចាងមី, រហូតផ្សព្វផ្សាយដល់បច្ចុប្បន្ន។ ពុទ្ធសាសនាជាមូលដ្ឋាន ជាក់ស្តែងគឺកាលៈទេសៈយ៉ាងនេះ, តាមរបៀបសាមញ្ញនិងទូទៅបំផុតខ្ញុំ បាននិយាយមួយត្រួសអំពីដំណើរការអភិវឌ្ឍន៍និងវិវត្តន៍របស់វា។ ពុទ្ធ សាសនាទាំងមូលនៅក្នុងដំណើរការអភិវឌ្ឍន៍, នៅលេចឡើងដូចជា ឆានចុងដោយបានតាហ៍ម័របង្កើតឡើង, នៅមានជិញធូចុង, ហួរយាន ចុងជាដើម, សុទ្ធតែជាយោងតាមប្រការដែលសក្យមុនីនាគ្រានោះធ្លាប់ សម្តែងយល់ដឹងចេញបាន។ ទាំងនេះក៏ស្ថិតក្នុងពុទ្ធសាសនាដែល កំណែទម្រង់ផងដែរ។ ក្នុងពុទ្ធសាសនាមានជាង១០ធម្មក្ខន្ធយ៉ាងនេះ, វាសុទ្ធតែបានដើរចូលក្នុងទម្រង់សាសនា, ដូច្នេះវាសុទ្ធតែស្ថិតក្នុងពុទ្ធ សាសនា។

សាសនាដែលសាងបង្កើតនៃសតវត្សនេះ, មិនត្រឹមតែជាសតវត្ស នេះ, ប៉ុន្មានសតវត្សមុននៅគ្រប់ទីកន្លែងលើពិភពលោកមានសាសនាជា ច្រើនសាងបង្កើត, ទាំងនេះភាគច្រើនសុទ្ធតែស្ថិតក្នុងក្លែងក្លាយ។ ពួក អង្គមហាត្រាស់ដឹងប្រោសមនុស្ស, សុទ្ធតែមានឋានសួគ៌មួយរបស់ខ្លួន

ឯង, សក្យមុនី, ព្រះពុទ្ធអាមីធួរ, តារីយូឡាយជាដើម, ព្រះពុទ្ធយូឡាយទាំងនេះពួកគាត់ប្រោសមនុស្ស, សុទ្ធតែមានពិភពមួយដែលខ្លួនឯងធ្វើម្ចាស់, នៅក្នុងប្រព័ន្ធកញ្ចុំផ្កាយនេះរបស់ពួកយើង, មានជាងមួយរយពិភពបែបនេះ, ហ្វាលូនតាហ្វាយើងខ្ញុំក៏មានពិភពហ្វាលូនផងដែរ។

មានធម្មក្ខន្ធក្លែងក្លាយមួយចំនួនប្រោសមនុស្សប្រោសទៅកន្លែងណា? វាប្រោសមិនបានមនុស្ស, ដែលវាសម្ដែងចេញមិនមែនជាធម៌។ ប្រាកដណាស់មានមនុស្សមួយចំនួនបានបង្កើតឡើងសាសនា, គោលបំណងដំបូងគាត់មិនចង់ធ្វើជាខ្មោចបំផ្លាញសុចរិតសាសនា។ គាត់នៅជាន់ថ្នាក់ខុសគ្នាបើកគង់ត្រាស់ដឹងរួចហើយ, មើលឃើញគោលសីលធម៌បន្តិច, ប៉ុន្តែគាត់ឃ្លាតពីអង្គត្រាស់ដឹងដែលប្រោសមនុស្សខុសឆ្ងាយខ្លាំងណាស់, គាត់ទាបណាស់។ គាត់រកឃើញគោលសីលធម៌មួយចំនួន, រកឃើញថារឿងមួយចំនួនក្នុងមនុស្សសាមញ្ញគឺខុស, គាត់ក៏ប្រាប់គេធ្វើដូចម្ដេចដើម្បីធ្វើរឿងល្អ, ពេលចាប់ផ្ដើមក៏មិនជំទាស់សាសនាដទៃ។ គេចុងក្រោយជឿគោរពគាត់, សន្មតថាដែលគាត់សម្ដែងសមហេតុផល, បន្ទាប់មកកាន់តែជឿលើគាត់, លទ្ធផលមនុស្សទាំងនេះគោរពបូជាគាត់, មិនគោរពបូជាសាសនា, ចិត្តកិត្តិនាមផលប្រយោជន៍របស់គាត់ខ្លួនឯងផុសឡើងកាលណា, ហៅមហាជនតាំងនាមឲ្យគាត់ធ្វើជាអ្វីមួយ, ពីពេលនេះតទៅគាត់បង្កើតឡើងសាសនាថ្មីមួយ។ ខ្ញុំប្រាប់អ្នករាល់គ្នា, ទាំងនេះសុទ្ធតែជាស្ថិតក្នុងទុច្ចរិតធម៌, ទោះបីវាមិនធ្វើបាបមនុស្សក៏ដោយ, វាក៏ជាទុច្ចរិតធម៌។ ដោយសារវាបានជ្រៀតជ្រែកគេជឿលើសុចរិតសាសនា, សុចរិតសាសនាគឺប្រោសមនុស្ស, វាផ្ទុយមកវិញមិនអាច។ យូរៗទៅអភិវឌ្ឍបន្តមក, បែរទៅជាធ្វើរឿងអាក្រក់។ ថ្មីៗនេះមានប្រភេទនេះជាច្រើនក៏ផ្សព្វផ្សាយដល់ប្រទេសចិនពួកយើង, ដូចអ្វីដែលគេហៅថា

ធម្មក្ខន្ធក្នានយីនជាក់ស្ដែងគឺមួយក្នុងចំណោមនោះ។ ដូច្នេះអ្នករាល់គ្នាដាច់ខាតយកចិត្តទុកដាក់, ត្រូវបានគេនិយាយថាប្រទេសមួយនៅអាស៊ីបូព៌ាមានជាង២០០០ប្រភេទ, នៅអាស៊ីភាគអាគ្នេយ៍និងបណ្ដាប្រទេសលោកខាងលិចផ្សេងៗ, ជឿលើអ្វីក៏មាន, មានប្រទេសមួយគឺដោយផ្ទាល់បានទទួលស្គាល់មានវូរសាសនា។ អ្វីទាំងនេះសុទ្ធតែជាខ្មោចដែលលេចឡើងនៅសម័យកាលផុតធម៌។ សម័យកាលផុតធម៌មិនគ្រាន់តែជាសំដៅលើពុទ្ធសាសនាប៉ុណ្ណោះ, គឺសំដៅលើជាន់ថ្នាក់ដ៏ខ្ពស់ចុះក្រោមអវកាសដ៏ច្រើនសុទ្ធតែអន្តរាយរួចហើយ។ ផុតធម៌មិនគ្រាន់តែជាសំដៅលើផុតធម៌នៃពុទ្ធសាសនាប៉ុណ្ណោះ, តែគឺសង្គមមនុស្សជាតិគ្មានរក្សាបានធម៌ផ្លូវចិត្តដើម្បីរឹតត្បិតសីលធម៌ទៀត។

## បួសហាត់ត្រូវឯកទេសតែមួយគត់

យើងខ្ញុំសម្ដែងថាបួសហាត់ត្រូវឯកទេសតែមួយគត់, មិនថាលោកអ្នកធ្វើដូចម្ដេចដើម្បីបួស, សុទ្ធតែមិនអាចលាយឡំប្រការផ្សេងៗចូលក្នុងដើម្បីបួសរញ៉េរញ៉ៃ។ ឧបាសកខ្លះ, គាត់បួសប្រការក្នុងពុទ្ធសាសនាផង, បួសប្រការរបស់ហ្វាលូនតាហ្វាពួកយើងផង។ ខ្ញុំប្រាប់លោកអ្នក, ចុងក្រោយលោកអ្នកមិនទទួលបានអ្វីទាំងអស់, នរណាក៏នឹងមិនផ្ដល់ឲ្យលោកអ្នក។ ដោយសារយើងខ្ញុំសុទ្ធតែជាពុទ្ធវង្ស, ប៉ុន្តែទីនេះមានបញ្ហាចិត្តចរិត, ក្នុងពេលដំណាលគ្នាមានបញ្ហាឯកទេសតែមួយគត់ផងដែរ។ លោកអ្នកមានតែរាងកាយមួយ, រាងកាយលោកអ្នកសាងបង្កើតគង់តាមធម្មក្ខន្ធមួយណា? ធ្វើដូចម្ដេចវិវត្តឲ្យលោកអ្នក? លោកអ្នកចង់ទៅកន្លែងណា? លោកអ្នកតាមធម្មក្ខន្ធមួយណាដើម្បីបួសលោកអ្នកជាក់ស្ដែងគឺទៅកន្លែងនោះ។ លោកអ្នកយោងតាមជិញធូដើម្បីបួស, នោះលោកអ្នកជាក់ស្ដែងគឺបានទៅពិភពសុខៈរបស់ព្រះពុទ្ធអាមីធួរ; លោកអ្នកបួស

យោងតាមព្រះពុទ្ធយ៉ាវស្ទី, ដូច្នោះលោកអ្នកនឹងបានទៅពិភពកញ្ចក់ពណ៌; នៅក្នុងពុទ្ធសាសនាជាក់ស្ដែងគឺសម្ដែងបែបនេះ, ហៅថាអទ្វេធម្មក្ខន្ធ។

ហាត់គង់ដែលយើងខ្ញុំសម្ដែងទីនេះ, ក៏មែនទែនជាដំណើរការវិវឌ្ឍន៍ទាំងមូលរបស់គង់, សុទ្ធតែយោងតាមធម្មក្ខន្ធបួសហាត់នោះរបស់វាខ្លួនឯងដើម្បីដើរ។ លោកអ្នកនិយាយលោកអ្នកដើរទៅទីណា? ជើងលោកអ្នកជាន់លើទូកពីរ, អ្វីក៏ទទួលមិនបាន។ មិនត្រឹមតែរវាងហាត់គង់និងបួសក្នុងវត្តមិនអាចលាយឡំបាន, រវាងវិធីសាស្ត្របួសហាត់, រវាងឈើគង់និងឈើគង់, រវាងសាសនានិងសាសនាក៏មិនអាចលាយឡំបានផងដែរ។ ជាក់ស្ដែងជាសាសនាតែមួយ, រវាងប៉ុន្មានធម្មក្ខន្ធរបស់វាក៏មិនអាចបួសលាយឡំបាន, គ្រាន់តែអាចជ្រើសយកធម្មក្ខន្ធមួយប៉ុណ្ណោះ។ លោកអ្នកបួសជិញធូ, នោះជាក់ស្ដែងគឺជាជិញធូ; លោកអ្នកបួសមីចុង, នោះជាក់ស្ដែងគឺជាមីចុង; លោកអ្នកបួសឆានចុង, នោះជាក់ស្ដែងគឺជាឆានចុង។ បើសិនជាលោកអ្នកជើងជាន់លើទូកពីរ, បួសមួយនេះផង, បួសមួយនោះផង, អ្វីក៏ទទួលមិនបាន។ ក៏មានន័យថានៅក្នុងពុទ្ធសាសនាសុទ្ធតែសម្ដែងអទ្វេធម្មក្ខន្ធ, ក៏មិនអនុញ្ញាតឲ្យលោកអ្នកលាយចូលដើម្បីបួស។ វាក៏ជាហាត់គង់, វាក៏ជាបួសហាត់, ដំណើរការបង្កើតគង់របស់វាសុទ្ធតែយោងតាមដំណើរការបួសហាត់និងវិវត្តន៍ក្នុងធម្មក្ខន្ធនោះរបស់វាខ្លួនឯងដើម្បីដើរ។ នៅក្នុងអវកាសផ្សេងក៏មានដំណើរការវិវត្តន៍របស់គង់មួយ, ក៏ជាដំណើរការយ៉ាងស្មុគស្មាញនិងអាថ៌កំបាំងបំផុត, ក៏មិនអាចតាមអំពើចិត្តលាយចូលក្នុងប្រការផ្សេងៗដើម្បីបួសបានឡើយ។

មានឧបាសកមួយចំនួន, ពេលស្ដាប់ឮថាជាហាត់គង់ពុទ្ធវង្ស, ក៏អូសទាញសិក្ខាកាមរបស់ពួកយើងចូលក្នុងវត្តសាងផ្នួស។ ខ្ញុំប្រាប់លោក

អ្នក, សិក្ខាកាមពួកយើងកំពុងអង្គុយ, នរណាក៏កុំទៅធ្វើរឿងបែបនោះ។ លោកអ្នកបំផ្លាញមហាធម៌របស់យើងខ្ញុំផង, ក៏បំផ្លាញទាំងសិក្ខាបទក្នុងពុទ្ធសាសនា, ក្នុងពេលដំណាលគ្នាលោកអ្នកក៏កំពុងជ្រៀតជ្រែកសិក្ខាកាម, លោកអ្នកធ្វើឲ្យគេអ្វីក៏ទទួលមិនបាន, នេះគឺមិនបាន។ បួសហាត់ជាបញ្ហាតឹងរឹង, ជាក់លាក់ត្រូវតែឯកទេសតែមួយគត់។ ផ្នែកនេះដែលយើងខ្ញុំបង្រៀននៅក្នុងមនុស្សសាមញ្ញ, ទោះបីមិនមែនសាសនាក្តី, ប៉ុន្តែគោលដៅបួសហាត់គឺឯកច្ឆន្ទ, សុទ្ធតែចង់សម្រេចបានបើកគង់, ត្រាស់ដឹង, ជោគជ័យសម្រេចបរិបូរគោលបំណងមួយបែបនេះ។

សក្យមុនីសម្តែង, ដល់សម័យកាលផុតធម៌, ព្រះសង្ឃក្នុងវត្តអារាមក៏ពិបាកប្រោសខ្លួនឯងណាស់ហើយ, កុំថាឡើយឧបាសក, កាន់តែគ្មានមនុស្សគ្រប់គ្រង។ កុំឃើញលោកអ្នកថ្វាយបង្គំគ្រូក៏ដោយ, ដែលបានគេហៅថាគ្រូនោះក៏ជាមនុស្សបួសហាត់, គាត់មិនបួសជាក់ស្តែងក៏គ្មានប្រយោជន៍, មិនបួសចិត្តនេះ, នរណាក៏ឡើងលើមិនបាន។ សាងផ្នួសគឺជាទម្រង់ក្នុងមនុស្សសាមញ្ញ, តើលោកអ្នកសាងផ្នួសរួចហើយជាក់ស្តែងជាមនុស្សរបស់ពុទ្ធវង្ស? តើព្រះពុទ្ធគឺគ្រប់គ្រងលោកអ្នក? គ្មានរឿងនោះទេ។ មួយថ្ងៃៗលោកអ្នកក្រាបក្បាលសំពះដល់បែកទាំងក្បាល, អុជធូបមួយសរសៃទៅមួយសរសៃ, ក៏គ្មានប្រយោជន៍ផងដែរ, លោកអ្នកត្រូវតែពិតប្រាកដបួសជាក់ស្តែងចិត្តនោះរបស់លោកអ្នកទើបបាន។ ដល់សម័យកាលផុតធម៌, ចក្រវាលបានកើតឡើងការផ្លាស់ប្រែដ៏ធំរួចហើយ, សូម្បីតែទីកន្លែងជំនឿសាសនាក៏មិនបានទៀត, មនុស្សដែលមានសីលគង់ (រួមទាំងព្រះសង្ឃ) ក៏បានរកឃើញកាលៈទេសៈនេះ។ បច្ចុប្បន្នពិភពលោកទាំងមូលមានតែខ្ញុំម្នាក់គត់កំពុងបង្រៀនសុចរិតធម៌ជាសាធារណៈ, ខ្ញុំបានធ្វើរឿងរ៉ាវមួយដែលមនុស្សពីមុនមិនដែលធ្វើ, លើសពីនេះទៀត

នៅសម័យកាលផុតធម៌បានបើកទ្វារធំមួយយ៉ាងនេះ។ ភាពពិតគឺរាប់ពាន់ឆ្នាំមិនដែលជួបប្រទះ, រាប់ម៉ឺនឆ្នាំមិនដែលជួបប្រទះ, ប៉ុន្តែអាចប្រោសបានឬអត់ក៏ដូចជាអាចបួសបានឬអត់នៅតែត្រូវពឹងផ្អែកលើខ្លួនឯង, ដែលខ្ញុំសម្តែងជាគោលសីលធម៌របស់ចក្រវាលធំមហិមា។

ខ្ញុំក៏មិនមែនហៅលោកអ្នកត្រូវតែទៅរៀនហ្វាលូនតាហ្វានេះរបស់ខ្ញុំ, ដែលខ្ញុំសម្តែងជាគោលសីលធម៌មួយ។ លោកអ្នកចង់បួសហាត់, លោកអ្នកគឺចាំបាច់ឯកទេសតែមួយគត់, បើមិនដូច្នោះទេ, លោកអ្នកជាមូលដ្ឋានក៏បួសមិនបាន។ ប្រាកដណាស់ប្រសិនលោកអ្នកមិនចង់បួសហាត់, យើងខ្ញុំក៏មិនគ្រប់គ្រងលោកអ្នក, ធម៌គឺសម្តែងឲ្យមនុស្សបួសហាត់ពិតប្រាកដស្តាប់, ដូច្នេះជាក់លាក់ត្រូវតែឯកទេសតែមួយគត់, សូម្បីតែគំនិតរបស់គង់ហ្វាដទៃក៏មិនអាចលាយឡំចូលក្នុង។ ខ្ញុំទីនេះមិនសម្តែងសកម្មភាពគំនិត, ហ្វាលូនតាហ្វាយើងខ្ញុំគ្មានសកម្មភាពគំនិតណាមួយ, ដូច្នេះអ្នករាល់គ្នាក៏កុំបន្ថែមប្រការនៃគំនិតអ្វីមួយចូលខាងក្នុង។ ជាក់លាក់ត្រូវតែយកចិត្តទុកដាក់ចំណុចមួយនេះ, ជាមូលដ្ឋានគ្មានសកម្មភាពគំនិត, ពុទ្ធវង្សសម្តែងទទេ, តាវវង្សសម្តែងគ្មាន។

មានម្តងខ្ញុំបានយកមនោគតិរបស់ខ្លួនឯងនិង៤, ៥អង្គមហាត្រាស់ដឹង, មហាតាវនៃជាន់ថ្នាក់យ៉ាងខ្ពស់បំផុតភ្ជាប់ជាមួយគ្នា។ ប្រសិននិយាយថាខ្ពស់, សុទ្ធសាធខ្ពស់មនុស្សសាមញ្ញឮក៏ភ្ញាក់ផ្អើល។ ពួកគាត់ចង់ដឹងក្នុងចិត្តខ្ញុំគិតជាអ្វី។ ខ្ញុំបួសហាត់ច្រើនឆ្នាំយ៉ាងនេះ, អ្នកដទៃចង់ដឹងមនោគតិរបស់ខ្ញុំជាមូលដ្ឋានមិនអាចបាន, សីលគង់របស់អ្នកដទៃជាមូលដ្ឋានវាយចូលមិនបាន។ នរណាក៏មិនដឹងបានខ្ញុំ, គាត់ក៏មិនដឹងបានខ្ញុំគិតអ្វី, ពួកគាត់ចង់ពន្យល់ពីសកម្មភាពមនោគតិរបស់ខ្ញុំ, ដូច្នេះពួកគាត់តាមរយៈបានខ្ញុំយល់ព្រម, មានដំណាក់កាលមួយបានយកមនោ

គតិរបស់ខ្ញុំតភ្ជាប់ជាមួយពួកគាត់។ បន្ទាប់ពីតភ្ជាប់ជាមួយគ្នា, ខ្ញុំមានបន្តិចទ្រាំមិនបាន, មិនថាជាន់ថ្នាក់របស់ខ្ញុំខ្ពស់ប៉ុណ្ណា, ក៏មិនថាជាន់ថ្នាក់របស់ខ្ញុំទាបប៉ុណ្ណា, ដោយសារខ្ញុំនៅក្នុងមនុស្សសាមញ្ញ, ខ្ញុំនៅតែធ្វើប្រភេទរឿងរ៉ាវមួយសភាពមានបំណង, រឿងរ៉ាវប្រោសមនុស្ស, ចិត្តកំពុងប្រោសមនុស្ស។ ប៉ុន្តែចិត្តរបស់ពួកគាត់ស្ងប់ដល់កម្រិតណា? ស្ងប់ដល់កម្រិតមួយគួរឲ្យខ្លាច។ ប្រសិនលោកអ្នកមនុស្សម្នាក់ស្ងប់ដល់កម្រិតនេះនៅបាន, មនុស្ស៤, ៥នាក់អង្គុយនៅទីនេះ, សុទ្ធតែស្ងប់ដល់កម្រិតប្រភេទនោះ, ដូចស្រះទឹកងាប់អ្វីក៏គ្មាន, ខ្ញុំចង់ទទួលដឹងពួកគាត់តែមិនអាចទទួលដឹងបាន។ ប៉ុន្មានថ្ងៃនោះក្នុងចិត្តខ្ញុំពិតជាដ៏ពិបាកទ្រាំ, គ្រាន់តែមានអារម្មណ៍ថាមានរសជាតិយ៉ាងនោះ។ មនុស្សធម្មតាពួកយើងនឹកស្មានមិនដល់, មិនអាចទទួលដឹងបាន, ទាំងស្រុងគឺជាសភាពគ្មានបំណង, គឺជាទទេ។

នៅលើជាន់ថ្នាក់ដ៏ខ្ពស់ជាមូលដ្ឋានគឺគ្មានសកម្មភាពគំនិត, ដោយសារលោកអ្នកនៅទីមនុស្សសាមញ្ញដាក់មូលដ្ឋានលើជាន់ថ្នាក់នេះ, សំណុំមូលដ្ឋាននោះបានកសាងរួចរាល់។ ដល់ឫសហាត់លើជាន់ថ្នាក់ខ្ពស់, ជាពិសេសគង់ហ្វារបស់យើងខ្ញុំគឺជាស្វ័យប្រវត្តិ, ទាំងស្រុងសុទ្ធតែជាឫសហាត់ដោយស្វ័យប្រវត្តិ។ ដរាបណាលោកអ្នកលើកកម្ពស់ចិត្តចរិតរបស់លោកអ្នក, គង់របស់លោកអ្នកនឹងកំពុងបង្កើន, លោកអ្នកសូម្បីតែមិនចាំបាច់ធ្វើលំហាត់ណាមួយ។ ចលនារបស់យើងខ្ញុំគឺដើម្បីពង្រឹងយន្តការស្វ័យប្រវត្តិ, ហេតុអ្វីនៅក្នុងសមាធិគាត់រមែងអង្គុយសមាធិមិនកម្រើក? ជាមូលដ្ឋានជាក់ស្តែងគឺជាសភាពគ្មានបំណង។ លោកអ្នកឃើញថាតាវវង្សសម្ដែងលំហាត់នេះ, លំហាត់នោះ, អ្វីសកម្មភាពគំនិត, គំនិតណែនាំ។ ខ្ញុំប្រាប់លោកអ្នក, តាវវង្សបន្ទាប់ពីលោតចេញក្រៅជាន់

ថ្នាក់របស់ឈើនោះបន្តិច, គឺគ្មានអ្វីទាំងអស់, ជាមូលដ្ឋានគឺមិនសម្តែងគំនិតនេះ, គំនិតនោះទៀត។ ដូច្នេះមានមនុស្សមួយចំនួនដែលបានហាត់គង់ដទៃគាត់តែងតែដាក់ចុះមិនបានអ្វីដកដង្ហើម, គំនិត។ល។ ខ្ញុំបង្រៀនឱ្យគាត់ប្រការនៃមហាវិទ្យាល័យ, គាត់តែងតែសួរខ្ញុំរឿងរបស់សិស្សបឋមសិក្សា, ណែនាំដូចម្តេច, សកម្មភាពគំនិតដូចម្តេច, គាត់បានទម្លាប់បែបនេះរួចហើយ, គាត់សន្មតថាឈើគង់ជាក់ស្តែងគឺជាបែបនេះ, ភាពពិតមិនមែនជាបែបនេះ។

## សីលគង់និងអំណាចគង់

ពួកយើងមានមនុស្សជាច្រើនចំពោះនាមសព្ទក្នុងឈើគង់យល់ដឹងមិនច្បាស់លាស់, ក៏មានមនុស្សមួយចំនួនគឺច្រឡំមិនច្បាស់។ គាត់យកសីលគង់និយាយក្លាយជាអំណាចគង់, អំណាចគង់និយាយក្លាយជាសីលគង់។ ពួកយើងពឹងផ្អែកលើចិត្តចរិតរបស់ខ្លួនឯងបានបួសចេញប្រភេទគង់នេះ, គឺបានសមកាលកម្មនឹងចរិតពិសេសនៃចក្រវាល, គុណធម៌របស់ខ្លួនឯងកំពុងវិវត្តក្លាយជាគង់។ នេះគឺកំណត់ជាន់ថ្នាក់ខ្ពស់ឬទាបរបស់មនុស្សម្នាក់, អំណាចគង់ធំឬតូច, បញ្ញាផលញាណខ្ពស់ឬទាបរបស់គាត់, នេះជាក់ស្តែងគឺជាគង់គន្លឹះបំផុត។ នៅក្នុងដំណើរការបួសហាត់, មនុស្សនឹងលេចឡើងប្រភេទស្ថានភាពអ្វី? នោះគឺអាចលេចឡើងសីលគង់ពិសេសមួយចំនួន, យើងខ្ញុំហៅកាត់ថាសីលគង់។ គង់លើកកម្ពស់ជាន់ថ្នាក់ដែលខ្ញុំទើបបាននិយាយដល់, ហៅថាអំណាចគង់។ ជាន់ថ្នាក់កាន់តែខ្ពស់, អំណាចគង់កាន់តែធំ, សីលគង់កាន់តែខ្លាំង។

សីលគង់គ្រាន់តែជាផលិតផលរងក្នុងដំណើរការបួសហាត់, វាមិនតំណាងឲ្យជាន់ថ្នាក់, មិនតំណាងឲ្យជាន់ថ្នាក់ខ្ពស់ឬទាបរបស់មនុស្ស

ម្នាក់, អំណាចគង់ធំឬតូច, មនុស្សខ្លះអាចលេចឡើងសីលគង់ច្រើនបន្តិច, មនុស្សខ្លះលេចឡើងសីលគង់តិច។ លើសពីនេះទៀតសីលគង់ក៏មិនមែនជារបស់ដើម្បីស្វែងរកដូចជាប្រការសំខាន់ដើម្បីបួសហើយអាចទទួលបាន។ ក្នុងពេលដំណាលគ្នាមនុស្សម្នាក់នេះចាំបាច់កំណត់ថាគាត់ចង់បួសហាត់ពិតប្រាកដ, គាត់ទើបអាចលេចឡើងសីលគង់បាន, មិនអាចចាត់ទុកជាគោលបំណងចម្បងដើម្បីបួស។ លោកអ្នកចង់ហាត់របស់ទាំងនេះធ្វើអ្វី? ចង់ប្រើនៅក្នុងមនុស្សសាមញ្ញឬ? នោះគឺដាច់ខាតមិនអាចទុកឲ្យលោកអ្នកតាមអំពើចិត្តប្រើនៅក្នុងមនុស្សសាមញ្ញ, ដូច្នេះលោកអ្នកកាន់តែចំណង់កាន់តែគ្មាន។ ដោយសារលោកអ្នកគឺកំពុងចំណង់, ចំណង់ខ្លួនវាជាក់ស្តែងគឺជាចិត្តប្រកាន់, បួសហាត់ចង់កម្ចាត់ជាក់ស្តែងគឺជាចិត្តប្រកាន់។

មានមនុស្សដ៏ច្រើននៅក្នុងពេលបួសហាត់ដល់កម្រិតភពខ្ពស់ជ្រៅ, គាត់មិនទាន់មានសីលគង់។ គ្រូជួយគាត់ចាក់សោទាំងអស់, ខ្លាចគាត់រក្សាខ្លួនឯងមិនល្អហើយធ្វើរឿងអាក្រក់, ដូច្នេះតែងតែមិនទុកឱ្យគាត់សម្តែងទេពអំណាចរបស់គាត់, មនុស្សបែបនេះគឺច្រើនបង្គួរ។ សីលគង់គឺទទួលរងការត្រួតត្រារបស់សតិមនុស្ស។ ពេលដែលមនុស្សគេង, អាចរក្សាខ្លួនឯងមិនជាប់, យល់សប្តិប្រហែលជាព្រឹកថ្ងៃបន្ទាប់គឺមេឃដីក្រឡាប់ចាក់, នោះគឺមិនអនុញ្ញាត។ ដោយសារគឺបួសហាត់នៅក្នុងមនុស្សសាមញ្ញ, ដូច្នេះដរាបណាមានសីលគង់ធំជាធម្មតាសុទ្ធតែមិនអនុញ្ញាតឱ្យប្រើ, ភាគច្រើនត្រូវបានចាក់សោ, តែក៏មិនមែនដាច់ខាត។ មានមនុស្សដ៏ច្រើនបួសហាត់បានល្អ, អាចរក្សាខ្លួនឯងបានល្អ, គឺអនុញ្ញាតឱ្យមានសីលគង់មួយចំនួន។ មនុស្សបែបនេះ, លោកអ្នកហៅគាត់យកសីលគង់ចេញដើម្បីបង្ហាញស្រេចតាមចិត្ត, គាត់នឹងមិនយកចេញជាដាច់ខាត,

គាត់អាចរក្សាខ្លួនឯងបានជាប់។

## បួសបញ្ញាសនិងកម្មវិធីគង់

មនុស្សខ្លះមិនធ្លាប់ហាត់គង់, ឬក៏គ្រាន់តែជានៅលើថ្នាក់ឈីគង់ណាមួយរៀនបានប្រការមួយចំនួន, ប៉ុន្តែនោះសុទ្ធតែជាស្ថិតក្នុងព្យាបាលជំងឺកាយសម្បទា, ក៏មិនមែនជាបួសហាត់អ្វី។ ក៏មានន័យថា, មនុស្សទាំងនេះគាត់មិនធ្លាប់ទទួលបានការបង្រៀនពិតប្រាកដ, ប៉ុន្តែគាត់ចៃដន្យក្នុងមួយយប់ទទួលបានគង់។ យើងខ្ញុំនឹងសម្ដែងបន្តិចថាតើប្រភេទគង់នេះបានមកដូចម្ដេច, មានប៉ុន្មានប្រភេទទម្រង់។

មានមួយប្រភេទគឺស្ថិតក្នុងបួសបញ្ញាស។ បួសបញ្ញាសជាអ្វី? នោះគឺពួកយើងមានមនុស្សមួយចំនួនអាយុច្រើនបង្គួរចង់បួសហាត់, វាយឺតពេលរួចហើយសម្រាប់បួសតាំងពីដំបូង។ នៅក្នុងកម្រិតខ្ពស់បំផុតរបស់ឈីគង់គាត់ក៏ចង់បួសហាត់, គាត់ដឹងថាឈីគង់អាចដើម្បីអ្នកដទៃធ្វើរឿងល្អ, ក្នុងពេលដំណាលគ្នាខ្លួនឯងក៏អាចទទួលបានការលើកកម្ពស់, គាត់មានបំណងបែបនេះ, ចង់លើកកម្ពស់, ចង់បួសហាត់។ ប៉ុន្តែប៉ុន្មានឆ្នាំមុននៅក្នុងកម្រិតខ្ពស់បំផុតរបស់ឈីគង់, គ្រូឈីគង់ទាំងនោះសុទ្ធតែជាសកលឈីគង់, តែគ្មាននរណាពិតប្រាកដបង្រៀនប្រការលើជាន់ថ្នាក់ខ្ពស់។ រហូតដល់ថ្ងៃនេះ, ពិតប្រាកដបង្រៀនគង់ជាសាធារណៈនៅលើជាន់ថ្នាក់ខ្ពស់, ក៏មានតែឯកជនខ្ញុំម្នាក់កំពុងធ្វើ, មិនមានមនុស្សទីពីរ។ បួសបញ្ញាសជាទូទៅ, សុទ្ធតែជាអាយុជាង៥០ឆ្នាំ, មនុស្សដែលអាយុធំបង្គួរ, និស្ស័យសែនល្អ, អ្វីៗនាំលើខ្លួនដ៏ល្អ, ស្ទើរតែសុទ្ធតែជាសិស្សដែលគេចង់បង្រៀន, បុគ្គលដែលស្មងបង្រៀន។ ប៉ុន្តែមនុស្សទាំងនេះអាយុច្រើនរួចហើយ, ចង់បួស, និយាយងាយស្រួលពេកហើយ! ទៅទីណាដើម្បីរកគ្រូ? ប៉ុន្តែគាត់ចង់បួសហាត់កាលណា, ចិត្តនេះបានគិត

យ៉ាងនេះ, គឺដូចជាមាសបញ្ចេញពន្លឺ, រញ្ជួយដល់ពិភពដប់ទិស។ គេនិយាយថាពុទ្ធចរិតៗ, នោះគឺសំដៅលើពុទ្ធចរិតនេះផុសចេញមក។

នៅលើជាន់ថ្នាក់ខ្ពស់សង្កេតមើល, ជីវិតរបស់មនុស្សមិនមែនដើម្បីធ្វើមនុស្ស។ ដោយសារជីវិតរបស់មនុស្សគឺសាងបង្កើតនៅក្នុងអវកាសចក្រវាល, គឺសមកាលកម្មនឹងចរិតពិសេសសច្ចៈ-ករុណា-ខន្តីនៃចក្រវាល, គឺចរិតដើមករុណា, ស្លូតករុណា។ ប៉ុន្តែដោយសារបន្ទាប់ពីកាយជីវិតច្រើនឡើងរួចហើយ, គាត់ក៏បានសាងបង្កើតប្រភេទទំនាក់ទំនងសង្គមមួយ, ដូច្នេះពីក្នុងចំណោមមានមនុស្សមួយចំនួនបានប្រែក្លាយទៅជាអាត្មានិយមឬក៏មិនល្អ, ហើយមិនអាចរក្សានៅលើជាន់ថ្នាក់ដ៏ខ្ពស់បានទៀត, ត្រូវធ្លាក់ចុះក្រោម, ធ្លាក់ដល់ក្នុងជាន់ថ្នាក់មួយ។ នៅក្នុងជាន់ថ្នាក់នេះគាត់ម្ដងទៀតប្រែក្លាយជាមិនល្អ, ម្ដងទៀតធ្លាក់ចុះក្រោម, ធ្លាក់ចុះក្រោម, ចុងក្រោយបានធ្លាក់មកដល់ជាន់ថ្នាក់នេះរបស់មនុស្សសាមញ្ញ។ ធ្លាក់ដល់ជាន់ថ្នាក់នេះ, គឺត្រូវតែយកមនុស្សរំលាយកម្ទេចទាំងស្រុង, ប៉ុន្តែពួកអង្គមហាត្រាស់ដឹងទាំងនោះផុសពីចិត្តមេត្តា, សម្រេចចិត្តនៅក្នុងបរិយាកាសទុក្ខបំផុតផ្ដល់ឱកាសឲ្យមនុស្សម្ដងទៀត, ហើយបានបង្កើតចេញអវកាសមួយយ៉ាងនេះ។

មនុស្សនៅអវកាសដទៃសុទ្ធតែមិនស្ថិតនៅរាងកាយបែបនេះ, គាត់អាចអណ្ដែតឡើង, គាត់ក៏អាចប្រែជាធំ, បង្រួញមកតូច។ ហើយអវកាសនេះទុកឲ្យមនុស្សមានរាងកាយមួយបែបនេះ, រាងកាយសាច់នេះរបស់ពួកយើង។ បន្ទាប់ពីមានរាងកាយនេះរួចហើយ, ត្រជាក់ទ្រាំមិនបាន, ក្ដៅទ្រាំមិនបាន, ហត់ទ្រាំមិនបាន, ឃ្លានទ្រាំមិនបាន, ទោះយ៉ាងណាគឺជាទុក្ខ។ មានជំងឺលោកអ្នកនឹងពិបាកទ្រាំ, កើតចាស់ឈឺស្លាប់, នោះគឺទុកឲ្យលោកអ្នកនៅក្នុងទុក្ខនេះសងកម្ម, មើលថាតើលោកអ្នកអាចត្រឡប់

មកបានឬអត់, ផ្តល់ឲ្យលោកអ្នកឱកាសម្តងទៀត, ដូច្នេះមនុស្សគឺធ្លាក់នៅក្នុងភាពវង្វេង។ បន្ទាប់ពីធ្លាក់មកដល់ទីនេះ, បានបង្កើតចេញគូនេត្រានេះផ្តល់ឲ្យលោកអ្នក, មិនអនុញ្ញាតឲ្យលោកអ្នកមើលឃើញអវកាសដទៃ, មើលមិនឃើញសេចក្តីពិតរបស់សារធាតុ។ ប្រសិនលោកអ្នកអាចត្រឡប់មកបាន, ទុក្ខបំផុតក៏ជាដ៏មានតម្លៃបំផុត, នៅក្នុងភាពវង្វេងពឹងផ្អែកលើភ្ញាក់ដឹងបួសត្រឡប់ថយក្រោយទុក្ខច្រើនណាស់, ត្រឡប់មកវិញនឹងលឿន។ ប្រសិនលោកអ្នកបន្តអាក្រក់ទៀត, ជីវិតនឹងត្រូវរំលាយកម្ទេច, ដូច្នេះតាមទស្សនៈរបស់ពួកគាត់, ជីវិតរបស់មនុស្ស, ធ្វើមនុស្សមិនមែនជាគោលបំណង, គឺហៅលោកអ្នកត្រឡប់ដើមមកសច្ចៈ, ត្រឡប់មកវិញ។ មនុស្សសាមញ្ញភ្ញាក់ដឹងមិនបានចំណុចមួយនេះ, មនុស្សសាមញ្ញនៅក្នុងសង្គមមនុស្សសាមញ្ញ, គាត់ជាក់ស្តែងគឺជាមនុស្សសាមញ្ញ, ចង់អភិវឌ្ឍដូចម្តេច, រស់បានល្អដូចម្តេច។ គាត់រស់កាន់តែល្អ, គាត់កាន់តែអាត្មានិយម, ជាក់ស្តែងកាន់តែចង់កាន់កាប់, គាត់កាន់តែបង្វែរចេញពីចរិតពិសេសនៃចក្រវាល, គាត់នឹងដើរសំដៅដល់វិនាស។

នៅលើជាន់ថ្នាក់ខ្ពស់ជាក់ស្តែងគឺមើលឃើញបែបនេះ, លោកអ្នកមានអារម្មណ៍ថាឈានឆ្ពោះទៅមុខ, តាមពិតទៅគឺឆ្ពោះថយមកក្រោយ។ មនុស្សជាតិមានអារម្មណ៍ថាកំពុងអភិវឌ្ឍវិទ្យាសាស្ត្រកំពុងជឿនលឿន, ភាពពិតក៏គ្រាន់តែយោងតាមបទច្បាប់ចក្រវាលដើម្បីដើរប៉ុណ្ណោះ។ ច្ចាងគួរទ្បៅក្នុងចំណោម៨ទេពជិះលាថយក្រោយ, មនុស្សតិចតួចណាស់ដែលដឹងបានហេតុអ្វីគាត់ជិះលាថយក្រោយ។ គាត់រកឃើញថាដើរឆ្ពោះទៅមុខជាក់ស្តែងគឺថយមកក្រោយ, គាត់ក៏បង្វែរមកវិញដើម្បីជិះ។ ដូច្នោះមានមនុស្សមួយចំនួនពេលដែលចង់បួសហាត់កាលណា, ពួកអង្គមហាត្រាស់ដឹងគឺមើលឃើញចិត្តនេះដ៏មានតម្លៃបំផុត, គឺអាចជួយដោយឥត

លក្ខខណ្ឌ។ ដូចជាសិក្ខាកាមពួកយើងថ្ងៃហ្នឹងអង្គុយនៅទីនេះ, លោកអ្នកចង់បួសហាត់ខ្ញុំអាចជួយលោកអ្នកដោយឥតលក្ខខណ្ឌ។ តែធ្វើជាមនុស្សសាមញ្ញម្នាក់, លោកអ្នកចង់ពិនិត្យជំងឺ, ចំណង់មួយនេះ, ចំណង់មួយនោះ, គឺមិនបាន, គឺមិនអាចជួយលោកអ្នកបាន។ ហេតុអ្វី? ដោយសារលោកអ្នកចង់ធ្វើមនុស្សសាមញ្ញ, មនុស្សសាមញ្ញនោះគឺគួរតែកើតចាស់ឈឺស្លាប់, ជាក់ស្តែងគឺគួរតែបែបនោះ, ទាំងអស់សុទ្ធតែជាមានទំនាក់ទំនងកម្មផល, មិនអាចធ្វើចលាចល។ មនុស្សម្នាក់នៅក្នុងខ្សែជីវិតលោកអ្នកដើមមកមិនមានបួសហាត់, ឥឡូវនេះលោកអ្នកចង់បួសហាត់, ដូច្នោះត្រូវតែរៀបចំសាជាថ្មីផ្លូវពីថ្ងៃនេះតទៅឲ្យលោកអ្នក, គឺអាចកែសម្រួលរាងកាយឲ្យលោកអ្នក។

ដូច្នោះមនុស្សចង់បួសហាត់, បំណងមួយនេះផុសចេញកាលណា, ពួកអង្គមហាត្រាស់ដឹងមើលឃើញរួចហើយ, សុទ្ធសាធដ៏មានតម្លៃខ្លាំងណាស់។ ប៉ុន្តែជួយដូចម្តេច? លោកីយ៍ទីណាមានគ្រូបង្រៀន? ថែមទៀតជាមនុស្សអាយុជាង៥០ឆ្នាំរួចហើយ, ពួកអង្គមហាត្រាស់ដឹងមិនអាចបង្រៀន, ដោយសារប្រសិនគាត់លាតត្រដាងចេញមកបង្រៀនលោកអ្នក, សម្តែងធម៌, បង្រៀនគង់ឱ្យលោកអ្នក, នោះគឺបង្ហាញអាថ៌កំបាំងធម្មជាតិ, គាត់ក៏ត្រូវធ្លាក់ចុះក្រោម, មនុស្សខ្លួនឯងធ្វើរឿងអាក្រក់ធ្លាក់ដល់ក្នុងភាពវង្វេង, គឺត្រូវតែភ្ញាក់ដឹងនៅក្នុងភាពវង្វេងដើម្បីបួស, ដូច្នេះអង្គត្រាស់ដឹងមិនអាចបង្រៀន។ មើលឃើញព្រះពុទ្ធរស់សម្តែងធម៌ឲ្យលោកអ្នក, ថែមទាំងបង្រៀនគង់ឲ្យលោកអ្នក, មនុស្សដែលអំពើអាក្រក់អីក៏មិនប្រណីសុទ្ធតែនឹងមករៀន, នរណាៗសុទ្ធតែនឹងជឿ, នោះនៅភ្ញាក់ដឹងអីទៀត, នឹងមិនស្ថិតនៅបញ្ហាភ្ញាក់ដឹងទៀត។ ដោយសារមនុស្សគឺខ្លួនឯងធ្លាក់ដល់ក្នុងភាពវង្វេង, គួរតែកម្ទេចចោល, ផ្តល់ឲ្យលោកអ្នកឱកាសម្តងនៅ

ក្នុងភាពវង្វេងនេះអនុញ្ញាតឲ្យលោកអ្នកត្រឡប់មកវិញ។ អាចត្រឡប់មកបានគឺត្រឡប់មកបាន, ត្រឡប់មកមិនបាន, នោះគឺបន្តវដ្តសង្សារនិងកម្ទេចចោល។

ផ្លូវគឺខ្លួនឯងដើរ, លោកអ្នកចង់បួសហាត់ធ្វើដូចម្ដេច? គាត់គិតដល់វិធីសាស្ត្រនេះ, ដោយសារនាគ្រានោះឈីគង់លេចឡើងកម្រិតខ្ពស់បំផុត, នេះក៏ជាប្រភេទប្រែប្រួលមួយនៃបាតុភូតតារាសាស្ត្រផងដែរ។ ដូច្នេះដើម្បីសហការនឹងបាតុភូតតារាសាស្ត្រប្រភេទនេះ, គេក៏បន្ថែមគង់ឲ្យគាត់ដោយពឹងផ្អែកលើទីតាំងចិត្តចរិតរបស់គាត់, ផ្ដល់ថែមលើរាងកាយរបស់គាត់ប្រភេទបំពង់ទន់មួយ, ដូចជាក្បាលម៉ាស៊ីនទឹក, បន្ទាប់ពីបើកវានឹងមក។ គាត់ចង់បញ្ចេញគង់គង់នឹងមក, គាត់មិនបញ្ចេញគង់, រាងកាយគាត់ខ្លួនឯងក៏គ្មានគង់, ជាក់ស្ដែងជាស្ថានភាពមួយបែបនេះ, នេះហៅថាបួសបញ្ច្រាស, ពីលើចុះក្រោមបួសសម្រេចបរិបូរ។

បួសហាត់ធម្មតារបស់ពួកយើង, គឺបួសពីក្រោមឡើងលើ, រហូតដល់បើកគង់បួសសម្រេចបរិបូរ, បួសបញ្ច្រាសដែលបាននិយាយ, អាយុច្រើនរួចហើយបួសពីក្រោមឡើងលើមិនទាន់, ដូច្នេះគាត់បួសពីលើចុះក្រោមគឺឆាប់រហ័សជាង, ក៏ជាប្រភេទបាតុភូតមួយដែលបង្កឡើងនាគ្រានោះ។ មនុស្សប្រភេទនេះចិត្តចរិតរបស់គាត់ចាំបាច់ដ៏ខ្ពស់, នៅលើទីតាំងចិត្តចរិតរបស់គាត់បានថែមឲ្យគាត់ថាមពលធំយ៉ាងនោះ។ គោលបំណងដើម្បីធ្វើអ្វី? មួយគឺសហការនឹងបាតុភូតតារាសាស្ត្រនាគ្រានោះ, ក្នុងពេលដំណាលគ្នាមនុស្សនេះធ្វើរឿងល្អ, គាត់អាចរងទុក្ខ។ ដោយសារប្រឈមមុខនឹងមនុស្សសាមញ្ញ, ចិត្តរបស់មនុស្សសាមញ្ញគ្រប់ប្រភេទកំពុងជ្រៀតជ្រែកដល់គាត់។ មនុស្សខ្លះលោកអ្នកពិនិត្យជំងឺឲ្យគាត់ជាសះស្បើយរួចហើយ, គាត់ក៏មិនយោគយល់លោកអ្នក, ពេលលោកអ្នក

ពិនិត្យជំងឺឲ្យគាត់បានយកចុះរបស់អាក្រក់ច្រើនប៉ុណ្ណា, ព្យាបាលឲ្យគាត់ដល់កម្រិតណាមួយ, នាគ្រានោះមិនជាក់លាក់មានការប្រែប្រួលច្បាស់លាស់។ ប៉ុន្តែក្នុងចិត្តគាត់គឺមិនរីករាយ, ក៏មិនអរគុណលោកអ្នក, ប្រហែលថែមទាំងជេរលោកអ្នកថាបោកបញ្ឆោតគាត់! គឺតម្រង់ចំបញ្ហាទាំងនេះ, ទុកឲ្យចិត្តរបស់លោកអ្នកនៅក្នុងបរិយាកាសនេះដើម្បីហាត់ពត់។ គោលបំណងផ្តល់គង់ឲ្យគាត់គឺទុកឱ្យគាត់បួសហាត់, លើកកម្ពស់ឡើងលើ។ ក្នុងពេលដំណាលគ្នាធ្វើរឿងល្អអភិវឌ្ឍសីលគង់របស់ខ្លួនឯង, បង្កើនគង់របស់ខ្លួនឯង, ប៉ុន្តែមានមនុស្សមួយចំនួនមិនដឹងគោលសីលធម៌នេះ។ មិនមែនខ្ញុំបានសម្តែងហើយឬ? មិនអាចសម្តែងធម៌ឲ្យគាត់, ភ្ញាក់ដឹងបានគឺភ្ញាក់ដឹងបាន, ជាបញ្ហាភ្ញាក់ដឹង, ភ្ញាក់ដឹងមិនបាននោះគឺគ្មានវិធីសាស្រ្ត។

មានមនុស្សមួយចំនួនពេលដែលទទួលបានគង់, ស្រាប់តែមានថ្ងៃមួយយប់គេងក្តៅទ្រាំមិនបាន, ភួយក៏ដណ្តប់មិនជាប់, ព្រឹកក្រោកឡើងប៉ះទីណាទីនោះមានអគ្គិសនី។ គាត់ដឹងថាគង់បានមករួចហើយ, រាងកាយរបស់នរណាឈឺចាប់កន្លែងណា? ដោយចៃដន្យប៉ះមួយក៏ជាល្អមិនខុស, ដ៏ល្អ។ គាត់ដឹងថាពីថ្ងៃនេះតទៅគង់បានមករួចហើយ, ធ្វើគ្រូឈឺគង់, ព្យួរយីហោឡើង, គាត់តាំងនាមខ្លួនឯងឡើងធ្វើគ្រូឈឺគង់។ នៅពេលចាប់ផ្តើម, ដោយសារឯកជននេះល្អ, គាត់ពិនិត្យឲ្យគេជាសះស្បើយជំងឺ, គេក៏ឲ្យគាត់លុយ, ជូនឲ្យគាត់វត្ថុអ្វីមួយ, គាត់អាចសុទ្ធតែមិនទទួល, បដិសេធដាច់ខាត។ ប៉ុន្តែមិនអាចបញ្ឈរនឹងនៅក្នុងធុងជ្រលក់ពណ៌ធំរបស់មនុស្សសាមញ្ញហើយមិនត្រូវបានឆ្លងកខ្វក់, ដោយសារប្រភេទបួសបព្វជ្ជាសមួយនេះគ្មានឆ្លងកាត់បួសហាត់ចិត្តចរិតពិតប្រាកដ, រក្សាចិត្តចរិតខ្លួនឯងដ៏ពិបាក។ សន្សឹមៗជូនវត្ថុអនុស្សាវរីយ៍តូចៗទទួលយក,

បន្តិចម្តងៗជូនរបស់ធំក៏យកផងដែរ, ចុងក្រោយជូនតិចតួចមិនពេញចិត្ត។ ចុងក្រោយគាត់និយាយថា៖ ឱ្យខ្ញុំរបស់ច្រើនយ៉ាងនោះធ្វើអី, ឱ្យលុយបានហើយ! ឱ្យលុយតិចតួចក៏មិនពេញចិត្ត។ គាត់ក៏មិនគោរពគ្រូឈីគង់បានបង្រៀនពិតប្រាកដ, ពោរពេញត្រចៀកសុទ្ធតែជាពាក្យដែលគេសរសើរគាត់មានអានុភាពយ៉ាងណាៗ។ ប្រសិននរណានិយាយគាត់មិនល្អ, គាត់ក៏មិនរីករាយ, ចិត្តកិត្តិនាមផលប្រយោជន៍ផុសឡើងទាំងស្រុង, គាត់សន្មតថាគាត់ឆ្លាតជាងអ្នកដទៃ, គាត់អស្ចារ្យណាស់។ គាត់សន្មតថាគង់នេះផ្តល់ឱ្យគាត់, គឺទុកឲ្យគាត់ធ្វើគ្រូឈីគង់, មានមហាសម្បត្តិ, ភាពពិតគឺទុកឱ្យគាត់បួសហាត់។ ចិត្តកិត្តិនាមផលប្រយោជន៍ផុសឡើងពេលណា, តាមពិតទៅចិត្តចរិតរបស់គាត់បានធ្លាក់ចុះរួចហើយ។

ខ្ញុំសម្តែងរួចហើយ, ចិត្តចរិតខ្ពស់ប៉ុណ្ណា, គង់ខ្ពស់ប៉ុណ្ណោះ។ ធ្លាក់ចុះរួចហើយគង់នេះក៏មិនអាចផ្តល់ឲ្យគាត់ធំយ៉ាងនោះបានទៀត, ក៏ត្រូវតែស្របគ្នាតាមចិត្តចរិតដើម្បីផ្តល់ឲ្យ, ចិត្តចរិតខ្ពស់ប៉ុណ្ណា, គង់ខ្ពស់ប៉ុណ្ណោះ។ ចិត្តកិត្តិនាមផលប្រយោជន៍នេះកាន់តែធ្ងន់, នៅក្នុងមនុស្សសាមញ្ញធ្លាក់ចុះកាន់តែខ្លាំង, គង់របស់គាត់ក៏ធ្លាក់ចុះក្រោមតាមនោះ។ ចុងក្រោយពេលដែលគាត់ធ្លាក់ចុះទាំងស្រុង, គង់ក៏មិនផ្តល់ឱ្យ, គង់អ្វីក៏គ្មានទៀត។ ប៉ុន្មានឆ្នាំមុនលេចឡើងមនុស្សបែបនេះមិនតិច, ស្ត្រីអាយុជាង៥០ឆ្នាំជួបច្រើនបង្គួរ។ ស្ត្រីចំណាស់នោះលោកអ្នកមើលឃើញគាត់ហាត់គង់, ក៏គ្មានទទួលបានការបង្រៀនពិតប្រាកដអ្វី, ប្រហែលជានៅលើថ្នាក់ឈីគង់ណាមួយរៀនបានប៉ុន្មានចលនាព្យាបាលជំងឺកាយសម្បទា, មានថ្ងៃមួយស្រាប់តែទទួលបានគង់។ ពេលចិត្តចរិតខូចរួចហើយ, ចិត្តកិត្តិនាមផលប្រយោជន៍ផុសឡើងកាលណានឹងត្រូវធ្លាក់ចុះ,

លទ្ធផលបច្ចុប្បន្នមិនជាអ្វីទាំងអស់, គង់ក៏មិនមានទៀត។ បច្ចុប្បន្ន ប្រភេទបួសបញ្ច្រាសនេះធ្លាក់ចុះច្រើនខ្លាំងណាស់, នៅសេសសល់ក៏មិន ច្រើន។ ហេតុអ្វី? គាត់មិនដឹងនេះគឺទុកឲ្យគាត់បួសហាត់, គាត់សន្មតថា គឺទុកឱ្យគាត់នៅក្នុងមនុស្សសាមញ្ញមានទ្រព្យសម្បត្តិ, ល្បីល្បាញ, ធ្វើគ្រូ ឈីគង់, ភាពពិតគឺទុកឱ្យគាត់បួសហាត់។

កម្មីគង់ជាអ្វី? នេះគ្មានកំណត់អាយុកាល, ប៉ុន្តែមានតម្រូវមួយ, នោះគឺចំបាច់ត្រូវតែជាមនុស្សចិត្តចរិតល្អពិសេស។ គាត់ដឹងថាឈីគង់ អាចបួសហាត់, គាត់ក៏ចង់បួសហាត់។ ចិត្តនេះចង់បួសហាត់, ប៉ុន្តែទៅទី ណាដើម្បីរកគ្រូ? ប៉ុន្មានឆ្នាំមុនមែនទែនគឺមានគ្រូឈីគង់សុចរិតកំពុង បង្រៀនគង់, ប៉ុន្តែដែលពួកគាត់បង្រៀនសុទ្ធតែជាប្រការព្យាបាលជំងឺ កាយសម្បទា, គ្មានបង្រៀនមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់, គេក៏មិន បង្រៀន។

សម្តែងដល់កម្មីគង់, ខ្ញុំនៅសម្តែងបញ្ហាមួយទៀត, មនុស្សក្រៅ ពីវិញ្ញាណដើមម្ចាស់របស់គាត់ (សតិម្ចាស់), នៅមានវិញ្ញាណដើមរង (សតិរង)។ វិញ្ញាណដើមរងរបស់មនុស្សខ្លះមានមួយ, ពីរ, បី, បួន, នៅមានដល់ទាំងប្រាំ។ វិញ្ញាណដើមរងនេះនិងភេទរបស់គាត់មិនជាក់ លាក់ដូចគ្នា, មានខ្លះជាប្រុស, មានខ្លះជាស្រី, សុទ្ធតែមិនដូចគ្នា។ ភាព ពិតវិញ្ញាណដើមម្ចាស់ក៏មិនជាក់លាក់ដូចនឹងរាងកាយសាច់។ ដោយ សារយើងខ្ញុំរកឃើញថាបច្ចុប្បន្នវិញ្ញាណដើមស្រីរបស់ប្រុសច្រើនពិសេស, វិញ្ញាណដើមប្រុសរបស់ស្រីច្រើនពិសេស, គាប់ជួនស្របគ្នាតាមអ្វីដែល បច្ចុប្បន្នតាវវង្សហៅថាបាតុភូតតារាសាស្ត្រអវិជ្ជមាន-វិជ្ជមានបញ្ច្រាសគ្នា, អវិជ្ជមានខ្លាំងវិជ្ជមានខ្សោយ។

ជាន់ថ្នាក់វិញ្ញាណដើមរងរបស់មនុស្សជាញឹកញាប់ខ្ពស់ជាងប្រៀប

នឹងវិញ្ញាណដើមម្ចាស់, ពិសេសគឺមានមនុស្សមួយចំនួន, វិញ្ញាណដើមរងរបស់គាត់មកពីជាន់ថ្នាក់ខ្ពស់ពិសេស។ វិញ្ញាណដើមរងក៏មិនមែនជាកាយភ្ជាប់, គាត់និងលោកអ្នកក្នុងពេលដំណាលគ្នាកើតចេញពីពោះម៉ែតែមួយ, និងលោកអ្នកហៅឈ្មោះតែមួយ, ក៏ជាផ្នែកមួយនៃរាងកាយរបស់លោកអ្នក។ ពេលធម្មតាគេគិតដល់បញ្ហាអ្វី, ធ្វើរឿងរ៉ាវអ្វី, ដោយសារវិញ្ញាណដើមម្ចាស់សម្រេចចិត្ត។ វិញ្ញាណដើមរងជាចម្បងខំប្រឹងគ្រប់សង្កត់វិញ្ញាណដើមម្ចាស់របស់មនុស្សមិនធ្វើរឿងអាក្រក់, ប៉ុន្តែពេលវិញ្ញាណដើមម្ចាស់ប្រកាន់ខ្លាំងពេកវិញ្ញាណដើមរងក៏មិនអាចធ្វើអ្វីបាន។ វិញ្ញាណដើមរងមិនទទួលរងភាពវង្វេងនៃសង្គមមនុស្សសាមញ្ញ, ហើយវិញ្ញាណដើមម្ចាស់ងាយស្រួលទទួលរងភាពវង្វេងនៃសង្គមមនុស្សសាមញ្ញ។

មានវិញ្ញាណដើមរងមួយចំនួនមកពីជាន់ថ្នាក់ដ៏ខ្ពស់, អាចជាខុសបន្តិចយ៉ាងនោះសម្រេចមគ្គផល។ វិញ្ញាណដើមរងចង់បួសហាត់, តែវិញ្ញាណដើមម្ចាស់មិនចង់បួសហាត់ក៏គ្មានវិធីណា។ មានថ្ងៃមួយវិញ្ញាណដើមម្ចាស់នៅក្នុងកម្រិតខ្ពស់បំផុតរបស់ឈីគង់, ក៏ចង់រៀនគង់, បួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, ប្រាកដណាស់មនោគតិគឺដ៏ទៀងត្រង់, និងគ្មានគិតស្វែងរកកិត្តិនាមផលប្រយោជន៍អ្វីទាំងនេះ។ វិញ្ញាណដើមរងរីករាយណាស់៖ "យើងចង់បួសហាត់, យើងនិយាយមិនបានរាប់; ឯងចង់បួសហាត់, ត្រូវស្របតាមចិត្តយើង"។ ប៉ុន្តែទៅទីណារកគ្រូ? វិញ្ញាណដើមរងដ៏មានអានុភាព, គាត់ក៏ឃ្លាតពីកាយដើម្បីស្វែងរកអង្គមហាត្រាស់ដឹងដែលគាត់បានដឹងក្នុងជាតិមុន។ ដោយសារវិញ្ញាណដើមរងខ្លះជាន់ថ្នាក់ដ៏ខ្ពស់, នឹងអាចឃ្លាតពីកាយ, បន្ទាប់ពីចេញទៅនិយាយថាចង់បួសហាត់, ចង់ខ្ចីគង់។ គេពេលមើលឃើញឯកជននេះក៏ល្អ, បួសហាត់

នោះប្រាកដណាស់នឹងជួយ, បែបនេះវិញ្ញាណដើមរងខ្វីបានគង់មក។ ជាញ៉ឹកញាប់គង់នេះមានថាមពលខ្វាត់ខ្វាយ, គឺដឹកបញ្ជូនតាមបំពង់; ក៏មានខ្លះខ្វីមកគឺជារបស់បង្ករូបរួចហើយ, របស់បង្ករូបរួចហើយជាញ៉ឹកញាប់មានសីលគង់ភ្ជាប់ជាមួយស្ថិតនៅ។

បែបនេះបន្តមក, គាត់អាចក្នុងពេលដំណាលគ្នាមានសីលគង់ភ្ជាប់ជាមួយ, ឯកជននេះក៏ដូចខ្ញុំទើបបានសម្ដែង, យប់គេងមានអារម្មណ៍ក្ដៅទ្រាំមិនបាន, ព្រឹកថ្ងៃបន្ទាប់ក្រោកឡើងពីគេង, ទទួលបានគង់។ ប៉ះទីណាទីនោះមានអគ្គិសនី, អាចព្យាបាលជំងឺឲ្យគេ, គាត់ក៏ដឹងថាគឺគង់បានមករួចហើយ។ មកពីទីណា? គាត់មិនច្បាស់លាស់។ ជាទូទៅគាត់ដឹងថាគឺមកពីក្នុងអវកាសចក្រវាល, ប៉ុន្តែពិស្ដារមកដូចម្ដេច, គាត់មិនដឹង, វិញ្ញាណដើមរងមិនបានប្រាប់គាត់, ដោយសារឫសហាត់គឺជាវិញ្ញាណដើមរង, គាត់គ្រាន់តែដឹងថាគង់បានមករួចហើយ។

ជាញ៉ឹកញាប់មនុស្សដែលខ្វីគង់មិនទទួលរងកំណត់អាយុកាល, យុវជនច្រើនបង្គួរ, ដូច្នេះប៉ុន្មានឆ្នាំមុនក៏លេចឡើងមួយចំនួនអាយុ២០ឆ្នាំ, ៣០ឆ្នាំ, ៤០ឆ្នាំ, អាយុច្រើនជាងក៏មាន។ យុវជនគឺកាន់តែមិនងាយស្រួលរក្សាខ្លួនឯង, លោកអ្នកឃើញថាគាត់ពេលធម្មតាល្អណាស់, នៅក្នុងសង្គមមនុស្សសាមញ្ញពេលដែលមិនទាន់មានអានុភាពអ្វី, ចិត្តកិត្តិនាមផលប្រយោជន៍របស់គាត់ដ៏ស្រាល។ ពេលដែលល្បីល្បាញកាលណា, ជាញ៉ឹកញាប់គឺងាយស្រួលទទួលរងជ្រៀតជ្រែករបស់កិត្តិនាមផលប្រយោជន៍, គាត់មានអារម្មណ៍ថានៅក្នុងអំឡុងឆ្នាំមានជីវិតនៅតែមានផ្លូវដ៏វែង, នៅតែចង់រត់ឆ្វេងរត់ស្ដាំ, តស៊ូមួយសាទៀត, សម្រេចបានគោលដៅអ្វីមួយរបស់មនុស្សសាមញ្ញ។ ដូច្នេះបានលេចឡើងសីលគង់កាលណា, ពេលបានមានអានុភាព, នៅក្នុងសង្គមមនុស្សសាមញ្ញជា

ញឹកញាប់គាត់គឺយកវាធ្វើជាមធ្យោបាយដើម្បីស្វែងរកគោលដៅឯកជន។ ដូច្នោះគឺមិនបាន, ក៏ជាមិនអនុញ្ញាតឱ្យប្រើបែបនេះ, កាន់តែប្រើគង់នេះកាន់តែតិច, ចុងក្រោយអ្វីក៏គ្មានទាំងអស់។ មនុស្សបែបនេះត្រូវធ្លាក់ចុះច្រើនណាស់, ខ្ញុំឃើញថាបច្ចុប្បន្នម្នាក់ក៏គ្មាន។ កាលៈទេសៈពីរប្រភេទនេះដែលខ្ញុំទើបបានសម្ដែងសុទ្ធតែស្ថិតក្នុងមនុស្សដែលចិត្តចរិតល្អបង្គួរទទួលបានគង់, គង់នេះមិនមែនខ្លួនឯងហាត់ចេញមកបាន, គឺមកពីអង្គត្រាស់ដឹងទីនោះ, ដូច្នេះគង់នោះខ្លួនវាគឺល្អ។

# កាយភ្ជាប់

ពួកយើងអាចមានមនុស្សជាច្រើននៅពិភពបួសហាត់ធ្លាប់ស្ដាប់និយាយអំពីរឿងកាយភ្ជាប់ដែលមានទាក់ទងនឹងសត្វ, កញ្ជ្រោងសំពោចព្រាយពស់ជាដើមប្រការទាំងនេះ។ នៅទីបញ្ចប់ជារឿងដូចម្ដេច? មានមនុស្សសម្ដែងហាត់គង់អភិវឌ្ឍសីលគង់ពិសេស, ភាពពិតមិនមែនអភិវឌ្ឍសីលគង់ពិសេស, សីលគង់ពិសេសនោះជាក់ស្ដែងគឺជាសភាវគតិរបស់មនុស្ស, ប៉ុន្តែដោយសារស្របតាមការអភិវឌ្ឍន៍ទៅមុខរបស់សង្គមមនុស្សជាតិ, មនុស្សមួយថ្ងៃកាន់តែផ្ដោតលើរបស់មានរូបនៃអវកាសសារធាតុនេះរបស់ពួកយើង, កាន់តែបង្អែកទៅលើឧបករណ៍ទំនើបកម្មរបស់ពួកយើង, ដូច្នេះសភាវគតិរបស់មនុស្សពួកយើងគឺមួយថ្ងៃកាន់តែឱនថយ, ចុងក្រោយធ្វើឲ្យប្រភេទសភាវគតិនេះរលាយបាត់ទាំងស្រុង។

ចង់មានសីលគង់, នៅតែត្រូវឆ្លងកាត់បួសហាត់, ត្រឡប់ដើមមកសច្ចៈ, យកវាបួសចេញមក។ ហើយកូនសត្វគ្មានមនោគតិស្មុគស្មាញយ៉ាងនេះ, ដូច្នេះវានិងចរិតពិសេសនៃចក្រវាលគឺផ្សារភ្ជាប់ទៅវិញទៅមក, វាមានសភាវគតិពីដើមកំណើត។ មនុស្សខ្លះសម្ដែងថាសត្វចេះបួសហាត់, និយាយថាកញ្ជ្រោងចេះហាត់តាន, ពស់នោះជាដើមចេះបួស

ហាត់។ មិនមែនវាចេះបួសហាត់, ដំបូងឡើយវាក៏មិនយល់អ្វីអំពីហាត់ឬក៏មិនហាត់ទាល់តែសោះ, នោះគឺដោយសារវាមានប្រភេទសភាវគតិនោះពីដើមកំណើត។ ដូច្នោះនៅក្រោមលក្ខខណ្ឌពិសេសជាក់លាក់, ក្រោមបរិយាកាសពិសេសជាក់លាក់, ពេលវេលាយូររួចហើយអាចដំណើរការ, វាគឺអាចទទួលបានគង់, ក៏អាចលេចឡើងសីលគង់ផងដែរ។

បែបនេះបន្តមក, ដូច្នោះវាគឺមានអានុភាព, អតីតកាលពួកយើងសម្ដែងថាទទួលបានលិញឈី, មានអានុភាព។ នៅមនុស្សសាមញ្ញសង្កេតមើល, សត្វខ្លាំងពូកែដូច្នេះដូច្នោះ, អាចប្រើមនុស្សដោយងាយស្រួល។ ភាពពិតខ្ញុំនិយាយថាមិនខ្លាំងពូកែ, នៅពីមុខអ្នកបួសហាត់ពិតប្រាកដ, វាក៏មិនជាអ្វី, លោកអ្នកកុំឃើញថាវាបួសបាន៨០០ឆ្នាំ, ១០០០ឆ្នាំ, ក៏មិនគ្រប់ម្រាមដៃតូចមួយឈ្លីផង។ យើងខ្ញុំសម្ដែងថាសត្វមានសភាវគតិពីដើមកំណើត, វាអាចមានអានុភាព។ ប៉ុន្តែក្នុងចក្រវាលនេះរបស់ពួកយើងនៅមានគោលសីលធម៌មួយ, នោះគឺមិនអនុញ្ញាតឲ្យសត្វបួសសម្រេច។ ដូច្នេះអ្នករាល់គ្នាមើលឃើញក្នុងសៀវភៅបុរាណសរសេរ, ប៉ុន្មានរយឆ្នាំត្រូវសម្លាប់វាម្ដង, គ្រោះកប្បធំគ្រោះកប្បតូច។ សត្វដល់ពេលវេលាជាក់លាក់នឹងបង្កើនគង់, គឺត្រូវតែរំលាយកម្ទេចវា, រន្ទះបាញ់វាជាដើម, មិនអនុញ្ញាតឱ្យវាបួសហាត់។ ដោយសារវាគ្មានគ្រប់គ្រាន់ចរិតដើមរបស់មនុស្ស, វាគឺមិនអាចដូចជាមនុស្សបែបនេះទៅបួសហាត់, គ្មានគ្រប់គ្រាន់លក្ខណៈរបស់មនុស្ស, វាបួសសម្រេចធានាជាក់ស្ដែងគឺជាខ្មោច, ក៏ជាមិនអនុញ្ញាតឲ្យវាបួសសម្រេច, ដូច្នេះត្រូវមេឃមកសម្លាប់, វាក៏ដឹងចំណុចមួយនេះ។ ប៉ុន្តែខ្ញុំសម្ដែងរួចហើយ, សង្គមមនុស្សជាតិបច្ចុប្បន្នកំពុងជម្រាលលើចំណោតធំ, មានមនុស្សមួយចំនួនគ្មានអំពើអាក្រក់អីមិនធ្វើ, ពេលដែលដល់ស្ថានភាពនេះ, សង្គមមនុស្សជាតិមិន

គ្រោះថ្នាក់ហើយឬ?

វត្ថុដល់ប៉ូលនឹងបញ្ច្រាស! យើងខ្ញុំរកឃើញថានៅវដ្តកម្មេចចោល ខុសគ្នារាល់ដងរបស់សង្គមមនុស្សជាតិសម័យកាលបុរេប្រវត្តិ, សុទ្ធតែជាកើតឡើងក្រោមកាលៈទេសៈដែលមនុស្សជាតិស្ថិតក្នុងសីលធម៌យ៉ាងអន្តរាយបំផុត។ បច្ចុប្បន្នអវកាសដែលមនុស្សជាតិពួកយើងរស់រាននិងអវកាសដទៃជាច្រើន, សុទ្ធតែឋិតក្នុងស្ថានភាពមួយយ៉ាងគ្រោះថ្នាក់បំផុត, អវកាសដទៃនៅក្នុងជាន់ថ្នាក់នេះក៏ដូចគ្នាផងដែរ, វាក៏ចង់ប្រញាប់លោតចេញ, វាក៏ចង់ឡើងលើជាន់ថ្នាក់ខ្ពស់, លើកកម្ពស់ជាន់ថ្នាក់វាគឺសន្មតថាអាចលោតចេញបាន។ ប៉ុន្តែនិយាយងាយស្រួលពេកហើយ? ចង់បួសហាត់, គឺចាំបាច់ត្រូវតែមានកាយមនុស្ស, ដូច្នេះគឺបានលេចឡើងមនុស្សហាត់គង់ត្រូវបានកាយភ្ជាប់, គឺជាមូលហេតុមួយក្នុងនោះ។

មានមនុស្សគិតថា, ហេតុអ្វីអង្គមហាត្រាស់ដឹងច្រើនយ៉ាងនេះ, គ្រូជំនាញខ្ពស់ច្រើនយ៉ាងនេះមិនគ្រប់គ្រង? ក្នុងចក្រវាលនេះរបស់ពួកយើងនៅមានគោលសីលធម៌មួយ៖ លោកអ្នកខ្លួនឯងចំណង់, ដែលលោកអ្នកចង់អ្នកដទៃមិនចង់ជ្រៀតជ្រែក។ យើងខ្ញុំទីនេះបង្រៀនអ្នករាល់គ្នាដើរផ្លូវសុចរិត, ក្នុងពេលដំណាលគ្នាយកធម៌សម្តែងធ្លុះធ្លាយឲ្យលោកអ្នក, ទុកឲ្យលោកអ្នកខ្លួនឯងទៅភ្ញាក់ដឹង, រៀនឬមិនរៀននៅតែជាបញ្ហារបស់លោកអ្នកខ្លួនឯង។ គ្រូនាំចូលខ្លោងទ្វារ, បួសហាត់នៅឯកជន។ គ្មាននរណាបង្គាប់លោកអ្នក, បង្ខំលោកអ្នកត្រូវតែបួស, បួសឬមិនបួសជាបញ្ហាឯកជនរបស់លោកអ្នក, ក៏មានន័យថា, លោកអ្នកចង់ដើរផ្លូវមួយណា, លោកអ្នកចង់បានអ្វី, លោកអ្នកចង់ទទួលបានអ្វី, នរណាក៏មិនជ្រៀតជ្រែកលោកអ្នក, គ្រាន់តែអាចដាស់តឿនសប្បុរស។

មានមនុស្សមួយចំនួនលោកអ្នកមើលឃើញគាត់ហាត់គង់, ភាព

ពិតសុទ្ធតែទុកឲ្យកាយភ្ជាប់ទទួលយក។ ហេតុអ្វីអន្ទងមកកាយភ្ជាប់? មនុស្សហាត់គង់គ្រប់ទីកន្លែងទូទាំងប្រទេស, មានមនុស្សប៉ុន្មាននាក់ខាងក្រោយខ្នងមានកាយភ្ជាប់? ប្រសិនសម្តែងចេញមនុស្សដ៏ច្រើននឹងមិនហ៊ានហាត់គង់, ព្រោះតួលេខដ៏គួរឲ្យបន្លាចមនុស្ស! ដូច្នោះហេតុអ្វីលេចឡើងស្ថានភាពយ៉ាងនេះ? របស់ទាំងនេះកំពុងធ្វើចលាចលសង្គមមនុស្សសាមញ្ញ, ហេតុអ្វីលេចឡើងបាតុភូតខ្លាំងសាហាវយ៉ាងនេះ? នេះក៏ជាមនុស្សជាតិខ្លួនឯងអន្ទងមក, ដោយសារមនុស្សជាតិកំពុងអន្តរាយ, ខ្មោចនៅគ្រប់ទីកន្លែង។ ជាពិសេសលើរាងកាយគ្រូឈីគង់ក្លែងក្លាយទាំងនោះសុទ្ធតែមាននាំតាមកាយភ្ជាប់, គាត់បង្រៀនគង់ជាក់ស្តែងគឺបង្រៀនរបស់ទាំងនេះ។ ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិសុទ្ធតែមិនអនុញ្ញាតឲ្យសត្វឡើងលើរាងកាយមនុស្ស, ឡើងមកគឺត្រូវសម្លាប់វា, នរណាមើលឃើញសុទ្ធតែមិនអនុញ្ញាត។ ប៉ុន្តែនៅក្នុងសង្គមពួកយើងបច្ចុប្បន្នមានមនុស្សគឺចំណង់វា, ចង់បានវា, សែនព្រេនវា។ មានមនុស្សគិតថា៖ ខ្ញុំគ្មានចំណង់វាយ៉ាងជាក់ច្បាស់ឯណា! លោកអ្នកមិនចំណង់វា, តែលោកអ្នកចំណង់សីលគង់, អង្គត្រាស់ដឹងនៃបួសហាត់សុចរិតធម៌អាចផ្តល់ឲ្យលោកអ្នកឬ? ចំណង់គឺចិត្តប្រកាន់មួយក្នុងមនុស្សសាមញ្ញ, ប្រភេទចិត្តនេះត្រូវតែចោល។ នោះនរណាអាចផ្តល់ឲ្យ? មានតែខ្មោចនៃអវកាសផ្សេងនិងសត្វគ្រប់ប្រភេទអាចផ្តល់ឲ្យ, នោះមិនស្មើនឹងគឺចំណង់វាហើយឬ? វានឹងមក។

មានមនុស្សប៉ុន្មាន{នាក់}គឺឱបយកការគិតត្រឹមត្រូវដើម្បីហាត់គង់? ហាត់គង់ត្រូវតែគោរពគុណធម៌, ត្រូវធ្វើរឿងល្អ, ត្រូវអនុវត្តករុណា, ទីណាធ្វើអ្វីសុទ្ធតែត្រូវតម្រូវខ្លួនឯងបែបនេះ។ នៅក្នុងឧទ្យានហាត់ក៏ដោយ, នៅក្នុងផ្ទះហាត់ក៏ដោយ, មានមនុស្សប៉ុន្មាននាក់គិតបែបនេះ? មនុស្សខ្លះក៏

មិនដឹងថាគាត់ហាត់គង់អ្វី, កំពុងហាត់ផង, កំពុងឃោលផង, ក្នុងមាត់នៅតែនិយាយ៖ អ៊ា! កូនប្រសាស្រីខ្ញុំនោះជាក់ស្តែងគឺគ្មានចិត្តកតញ្ញូចំពោះខ្ញុំ; ម្តាយក្មេករបស់ខ្ញុំនោះ, គាត់ហេតុអ្វីក៏អាក្រក់យ៉ាងនោះ! មនុស្សខ្លះនៅនិយាយតាំងពីរឿងអង្គភាពរហូតដល់កិច្ចការជាតិ, គ្មានអ្វីគាត់មិននិយាយដល់, មិនស្របគ្នាតាមគោលគំនិតឯកជនគាត់ក៏ខឹងពិបាកទ្រាំ។ លោកអ្នកនិយាយនេះជាហាត់គង់ឬ? ក៏មានមនុស្សហាត់គង់នៅទីនោះហាត់ឈរបង្គោល, ជើងញ័រអស់កម្លាំងហើយ, តែខួរក្បាលគាត់គ្មានសម្រាក៖ អ្វីៗឥឡូវសុទ្ធតែថ្លៃយ៉ាងនេះ, តម្លៃទីផ្សារក៏កើនឡើង, អង្គភាពពួកយើងក៏មិនទាន់បើកប្រាក់ខែ, ហេតុអ្វីខ្ញុំមិនអាចហាត់ចេញបានសីលគង់? ខ្ញុំហាត់ចេញបានសីលគង់រួចហើយ, ខ្ញុំក៏ធ្វើគ្រូឈីគង់, ខ្ញុំក៏មានទ្រព្យសម្បត្តិ, ខ្ញុំក៏ពិនិត្យជំងឺឲ្យអ្នកដទៃដើម្បីរកលុយ។ គាត់ពេលណាឃើញអ្នកដទៃលេចឡើងសីលគង់, គាត់គឺកាន់តែអន្ទះអន្ទែង, គាត់រមែងស្វែងរកសីលគង់, ស្វែងរកភ្នែកទិព្វ, ស្វែងរកសមត្ថភាពព្យាបាលជំងឺ។ អ្នករាល់គ្នាគិតសាកមើល, នេះនិងចរិតពិសេសក្នុងចក្រវាលពួកយើងសច្ចៈ-ករុណា-ខន្តីខុសគ្នាឆ្ងាយប៉ុណ្ណា! ទាំងមូលសុទ្ធតែជាបង្វែរចេញ។ និយាយធ្ងន់ធ្ងរបន្តិច, គាត់កំពុងហាត់ទុច្ចរិតធម៌! តែគាត់គឺដោយមិនដឹងខ្លួន។ គាត់កាន់តែគិតបែបនេះ, គំនិតដែលផុសចេញកាន់តែអាក្រក់។ ឯកជននេះគាត់មិនទទួលបានធម៌, គាត់មិនដឹងគោរពគុណធម៌, ហើយសន្មតថាហាត់គង់តាមរយៈចលនាគឺអាចហាត់ចេញគង់បាន, គាត់ចង់បានអ្វីគឺអាចស្វែងរកចេញបាន, គាត់សន្មតថាគឺជាបែបនេះ។

គឺដោយសារមនោគតិខ្លួនឯងមិនសុចរិត, ទើបអន្ទងមករបស់មិនល្អ។ សត្វនោះអាចមើលឃើញ៖ ម្នាក់នេះចង់ហាត់គង់មានទ្រព្យសម្បត្តិ,

ម្នាក់នោះចង់ល្បីឈ្មោះ, ចង់បានសីលគង់។ បុរសល្អ, រាងកាយនេះរបស់គាត់ក៏ល្អ, អ្វីៗនាំតាមក៏ល្អណាស់ដែរ, ប៉ុន្តែមនោគតិរបស់គាត់ពិតជាអាក្រក់, គាត់ស្វែងរកសីលគង់ទេតើ! អាចគាត់មានគ្រូ, ប៉ុន្តែគាត់មានគ្រូយើងក៏មិនខ្លាច។ វាដឹងថាគ្រូនៃបួសហាត់សុចរិតធម៌មើលឃើញគាត់ស្វែងរកសីលគង់យ៉ាងនេះ, កាន់តែស្វែងរកកាន់តែមិនអាចផ្ដល់ឱ្យ, គាប់ជួនគឺជាចិត្តប្រកាន់ត្រូវកម្ចាត់ចោល។ គាត់កាន់តែមានការគិតនេះ, គឺកាន់តែមិនផ្ដល់សីលគង់ឲ្យគាត់, គាត់គឺកាន់តែមិនភ្ញាក់ដឹង, កាន់តែស្វែងរកការគិតកាន់តែមិនល្អ។ ចុងក្រោយគ្រូនោះដកដង្ហើមថ្ងូរ, ពេលឃើញថាឯកជននេះចប់ហើយ, គឺមិនចាប់អារម្មណ៍ដល់គាត់ទៀត។ មនុស្សខ្លះគ្មានគ្រូ, អាចមាន‹គ្រូ›ដើរកាត់ផ្លូវគ្រប់គ្រងបន្តិច។ ដោយសារអង្គត្រាស់ដឹងនៅបណ្ដាអវកាសច្រើនណាស់, អង្គត្រាស់ដឹងនោះពេលមើលឃើញឯកជននេះ, សម្លឹងគាត់បន្តិច, តាមគាត់មួយថ្ងៃពេលឃើញថាមិនបាន, ចេញទៅ; ថ្ងៃស្អែកមកមួយទៀត, សម្លឹងឯកជននេះបន្តិចមិនបាន, ក៏ចេញទៅ។

កូនសត្វដឹងថា, គាត់មានគ្រូក៏ដោយ, មានគ្រូដើរកាត់ផ្លូវក៏ដោយ, អ្វីដែលគាត់ស្វែងរក, គ្រូរបស់គាត់មិនអាចផ្ដល់ឲ្យ។ ដោយសារកូនសត្វមើលមិនឃើញអវកាសដែលអង្គមហាត្រាស់ដឹងនៅ, ដូច្នេះវាក៏មិនក្រែងខ្លាច, វាទាញយកប្រយោជន៍ពីចន្លោះប្រហោង។ ក្នុងចក្រវាលពួកយើងមានគោលសីលធម៌មួយ, គាត់ខ្លួនឯងស្វែងរក, ខ្លួនឯងចង់បាន, កាលៈទេសៈធម្មតាអ្នកដទៃមិនអាចជ្រៀតជ្រែក, វាទាញយកប្រយោជន៍ពីចន្លោះប្រហោងនេះ៖ គាត់ចង់បាន, យើងផ្ដល់ឲ្យគាត់, យើងផ្ដល់ឲ្យគាត់តើមានខុសអី? វាផ្ដល់ឲ្យ។ ពេលចាប់ផ្ដើមវាមិនហ៊ានឡើង, ដំបូងវាផ្ដល់ឲ្យគាត់បន្តិចគង់ដើម្បីសាកមើល។ មានថ្ងៃមួយគាត់ស្រាប់តែពិតជា

ទទួលបានគង់ដែលខ្លួនឯងស្វែងរក, ទាំងអាចព្យាបាលជំងឺ។ វាឃើញថាល្អណាស់, ដូចជាការផ្តើមរបស់ប្រគុំតន្ត្រីមួយ៖ គាត់ស្ម័គ្រចិត្តចង់, ដូច្នោះយើងគឺឡើងទៅ, ឡើងទៅផ្តល់ឲ្យច្រើនជាង, ផ្តល់ឲ្យឆាប់រហ័សជាង។ មិនមែនឯងចង់បានភ្នែកទិព្វឬ? លើកនេះអ្វីៗសុទ្ធតែផ្តល់ឲ្យឯង, វាគឺឡើងមក។

មនោគតិស្វែងរកនោះរបស់គាត់, ស្វែងរកចំអ្វីទាំងនេះ, ភ្នែកទិព្វបើកហើយ, នៅអាចលេចឡើងគង់, នៅអាចមានបន្តិចសីលគង់តូចតាច។ គាត់អាចរីករាយយ៉ាងខ្លាំង, គាត់សន្មតថាខ្លួនឯងទីបំផុតស្វែងរកប្រការនេះទទួលបានរួចហើយ, ហាត់ចេញបានរួចហើយ, ភាពពិត, គាត់មិនហាត់ចេញបានអ្វីទាំងអស់។ គាត់មានអារម្មណ៍ថាគាត់អាចមើលធ្លុះរាងកាយមនុស្ស, អាចមើលឃើញរាងកាយមនុស្សកន្លែងណាមានជំងឺ។ ភាពពិតភ្នែកទិព្វរបស់គាត់ជាមូលដ្ឋានគឺមិនទាន់បើក, គឺកូនសត្វនោះបានគ្របសង្កត់ខួរធំរបស់គាត់, កូនសត្វនោះប្រើភ្នែករបស់ខ្លួនឯងដើម្បីមើល, បញ្ចាំងឡើងលើខួរធំរបស់គាត់, គាត់គឺសន្មតថាភ្នែកទិព្វខ្លួនឯងបានបើករួចហើយ។ បញ្ចេញគង់, ឯងបញ្ចេញទៅ, កាលណាគាត់សន្ទឹងដៃបញ្ចេញគង់, ក្រចកតូចរបស់កូនសត្វនោះពីខាងក្រោយខ្នងគាត់ក៏សន្ទឹងចេញមក; គាត់បញ្ចេញគង់កាលណា, ក្បាលពស់តូចនោះកំពុងលៀនអណ្តាតចេញ, គឺសំដៅទីជំងឺនោះ, ទីតាំងមានដំបៅនោះប្រើអណ្តាតលិឍៗ។ គឺប្រភេទមួយនេះច្រើនណាស់, កាយភ្ជាប់របស់មនុស្សទាំងនេះសុទ្ធតែជាគាត់ខ្លួនឯងចំណង់មក។

ដោយសារគាត់ស្វែងរក, គាត់ចង់មានទ្រព្យសម្បត្តិ, ចង់ល្បីឈ្មោះ។ ល្អ, សីលគង់នេះក៏មាន, ក៏អាចព្យាបាលជំងឺ, ភ្នែកទិព្វក៏អាចមើលឃើញទៀត, នេះគាត់គឺរីករាយ។ កូនសត្វមើលឃើញកាល

ណា, ឯងមិនចង់មានទ្រព្យសម្បត្តិឬ? ល្អ, យើងទុកឲ្យឯងមានទ្រព្យសម្បត្តិ។ គ្របសង្កត់ខួរធំរបស់មនុស្សសាមញ្ញម្នាក់សុទ្ធសាធជារឿងរ៉ាវដ៏ងាយស្រួល។ វាអាចគ្របសង្កត់មនុស្សដ៏ច្រើនមករកគាត់ពិនិត្យជំងឺ, មកច្រើនៗ។ បុរសល្អ, គាត់ខាងនេះកំពុងពិនិត្យជំងឺ, ហើយខាងនោះ, វាណែនាំអ្នកសារព័ត៌មានឱ្យចុះផ្សាយលើកាសែត។ វាគ្របសង្កត់មនុស្សសាមញ្ញដើម្បីធ្វើរឿងរ៉ាវទាំងនេះ, មនុស្សពីណាមកពិនិត្យជំងឺប្រសិនឱ្យលុយតិចសុទ្ធតែមិនបាន, ធ្វើឱ្យលោកអ្នកឈឺក្បាល, ទោះយ៉ាងណាលោកអ្នកត្រូវតែឲ្យលុយច្រើន។ កិត្តិនាមផលប្រយោជន៍បានទាំងព្រម, លុយក៏បាន, ឈ្មោះក៏ល្បី, គ្រូឈីគង់នេះក៏បានធ្វើរួចហើយ។ ជាញឹកញាប់មនុស្សទាំងនេះមិនសម្តែងចិត្តចរិត, អ្វីក៏ហ៊ាននិយាយ, មេឃទីមួយ, គាត់ទីពីរ។ គាត់ហ៊ាននិយាយគាត់គឺជាម្ចាស់ក្សត្រីមាតា, ព្រះឥន្ទ្រាធិរាជយាងចុះ, គាត់ក៏ហ៊ាននិយាយគាត់គឺជាព្រះពុទ្ធផងដែរ។ ដោយសារគាត់មិនធ្លាប់ឆ្លងកាត់ការបួសហាត់ចិត្តចរិតពិតប្រាកដ, ដូច្នេះគាត់ហាត់គង់គឺស្វែងរកសីលគង់, លទ្ធផលបានអន្ទងមកកាយភ្ជាប់សត្វ។

មានមនុស្សអាចគិតថា៖ នេះមានអីមិនល្អ, ទោះយ៉ាងណាអាចរកលុយមានទ្រព្យសម្បត្តិគឺបានហើយ, ទាំងអាចល្បីឈ្មោះ, មានមនុស្សមិនតិចបានគិតបែបនេះ។ ខ្ញុំប្រាប់អ្នករាល់គ្នា, ភាពពិតវាគឺមានគោលបំណង, វាមិនមែនផ្តល់ឲ្យលោកអ្នកដោយគ្មានហេតុផល។ ក្នុងចក្រវាលនេះមានគោលសីលធម៌មួយ, ហៅថាមិនបាត់គឺមិនបាន។ វាបានអ្វី? មិនមែនខ្ញុំទើបបាននិយាយដល់បញ្ហានេះហើយឬ? វាចង់បានបន្តិចសារៈនោះនៃរាងកាយលោកអ្នកដើម្បីបួសក្លាយជារូបមនុស្ស, វានឹងនៅលើកាយមនុស្សប្រមូលយកសារៈរបស់មនុស្ស។ ហើយសារៈនៃកាយ

មនុស្សមានតែមួយផ្នែកនេះ, ប្រសិនចង់បួសហាត់, មានតែមួយផ្នែកនេះ។ ប្រសិនលោកអ្នកទុកឲ្យវាយកបាត់, លោកអ្នកក៏មិនចាំបាច់គិតដល់ការបួសហាត់ទៀត, នោះលោកអ្នកនៅបួសហាត់អ្វីទៀត? លោកអ្នកគ្មាននៅសល់អ្វី, លោកអ្នកជាមូលដ្ឋានគឺបួសហាត់មិនបានទៀត។ មនុស្សខ្លះអាចនិយាយ៖ ខ្ញុំក៏មិនចង់បួសហាត់, ខ្ញុំគឺចង់មានទ្រព្យសម្បត្តិ, មានលុយគឺបានហើយ, ខ្វល់អី! ខ្ញុំប្រាប់អ្នករាល់គ្នា, លោកអ្នកចង់មានទ្រព្យសម្បត្តិ, ខ្ញុំសម្តែងចេញឲ្យលោកអ្នកគោលសីលធម៌មួយនេះ, លោកអ្នកនឹងមិនគិតបែបនេះទៀត។ ហេតុអ្វី? ប្រសិនវាចាកចេញពីលើរាងកាយលោកអ្នកឆាប់, លោកអ្នកនឹងអវយវៈគ្មានកម្លាំង។ ពីពេលនេះតទៅ, មួយជីវិតសុទ្ធតែបែបនេះ, ដោយសារសារៈរបស់មនុស្សត្រូវបានវាយកទៅច្រើនពេកហើយ; ប្រសិនវាចាកចេញពីលើរាងកាយលោកអ្នកយឺត, លោកអ្នកជាក់ស្តែងគឺជាមនុស្សរុក្ខជាតិ, ពាក់កណ្តាលជីវិតក្រោយមកលោកអ្នកនឹងគេងលើគ្រែដកដង្ហើម។ លោកអ្នកមានលុយលោកអ្នកអាចចាយបានឬ? មានល្បីឈ្មោះលោកអ្នកអាចទទួលផលបុណ្យបានឬ? មិនគួរឲ្យខ្លាចឬ?

រឿងរ៉ាវប្រភេទនេះនៅក្នុងមនុស្សហាត់គង់បច្ចុប្បន្នគឺជាលេចធ្លោពិសេស, ច្រើនពិសេស។ វាមិនត្រឹមតែកាយភ្ជាប់, ថែមទាំងសម្លាប់វិញ្ញាណដើមរបស់មនុស្ស, វាខួងចូលក្នុងវិមាននីវ៉ានរបស់មនុស្ស, អង្គុយនៅទីនោះ។ មើលទៅវាគឺជាមនុស្ស, ប៉ុន្តែវាមិនមែនជាមនុស្ស, សព្វថ្ងៃសុទ្ធតែលេចឡើងកាលៈទេសៈប្រភេទនេះ។ ដោយសារកម្រិតសីលធម៌របស់មនុស្សជាតិសុទ្ធតែកើតឡើងការផ្លាស់ប្តូររួចហើយ, មនុស្សខ្លះធ្វើរឿងអាក្រក់, លោកអ្នកប្រាប់ថាគាត់កំពុងធ្វើរឿងអាក្រក់, គាត់សុទ្ធតែមិនជឿ។ គាត់សន្មតថារកលុយ, ស្វែងរកលុយ, មានទ្រព្យសម្បត្តិ, នេះជាក់

ស្តែងគឺសមតាមគោលការណ៍មេឃដី, នេះជាក់ស្តែងគឺជាត្រឹមត្រូវ, ដូច្នេះធ្វើបាបអ្នកដទៃ, ធ្វើឲ្យអ្នកដទៃឈឺចាប់, ដើម្បីរកលុយគ្មានអំពើអាក្រក់អីមិនធ្វើ, អ្វីគាត់ក៏ហ៊ានធ្វើ។ គាត់មិនបាត់, គាត់គឺមិនបាន។ វាអាចផ្តល់ឲ្យលោកអ្នកដោយគ្មានហេតុផលឬ? វាចង់បានរបស់លើរាងកាយលោកអ្នក។ ប្រាកដណាស់, យើងខ្ញុំសម្តែង, មនុស្សសុទ្ធតែជាដោយសារគោលគំនិតនេះរបស់ខ្លួនឯងមិនត្រឹមត្រូវ, ចិត្តមិនសុចរិតអន្ទងមករំខាន។

យើងខ្ញុំសម្តែងហ្វាលូនតាហ្វា។ បួសហាត់ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំ, ដរាបណាចិត្តចរិតលោកអ្នករក្សាជាប់, សុចរិតមួយបង្ក្រាប់រាប់រយទុច្ចរិត, លោកអ្នកនឹងមិនលេចឡើងបញ្ហាណាមួយ។ ប្រសិនចិត្តចរិតលោកអ្នករក្សាមិនជាប់, លោកអ្នកស្វែងរកមួយនេះ, ស្វែងរកមួយនោះ, បញ្ជាក់ថានឹងអន្ទងមករំខាន។ មនុស្សខ្លះជាក់ស្តែងគឺដាក់ចុះមិនបានប្រការទាំងនោះដែលធ្លាប់ហាត់ពីមុន, យើងខ្ញុំសម្តែងបួសហាត់ត្រូវឯកទេសតែមួយគត់, បួសហាត់ពិតប្រាកដត្រូវឯកទេសតែមួយគត់។ លោកអ្នកកុំឃើញថាមានគ្រូឈីគង់មួយចំនួនសុទ្ធតែសរសេរចេញសៀវភៅ, ខ្ញុំប្រាប់លោកអ្នកក្នុងសៀវភៅនោះអ្វីក៏មាន, ដូចគ្នានឹងអ្វីដែលគាត់បានហាត់, វាគឺជាពស់, វាគឺជាកញ្ជ្រោង, វាគឺជាសំពោច។ លោកអ្នកមើលសៀវភៅទាំងនោះ, របស់ទាំងនេះនឹងពីក្នុងអក្សរលោតចេញក្រៅ។ ខ្ញុំបានសម្តែង, គ្រូឈីគង់ក្លែងក្លាយនេះលើសជាងគ្រូឈីគង់ពិតច្រើនទ្វេដង, លោកអ្នកក៏សំគាល់មិនច្បាស់, ដូច្នេះអ្នករាល់គ្នាជាក់លាក់ត្រូវតែរក្សាជាប់។ ខ្ញុំទីនេះក៏មិនមែនហៅលោកអ្នកត្រូវតែបួសហ្វាលូនតាហ្វា, លោកអ្នកបួសធម្មក្ខន្ធណាមួយក៏បាន។ ប៉ុន្តែអតីតកាលមានប្រយោគថា៖ ពាន់ឆ្នាំមិនបានសុចរិតធម៌, ល្អជាងមួយថ្ងៃបួសសមាធិកញ្ជ្រោង

ព្រៃ។ ដូច្នេះ, ជាក់លាក់ត្រូវតែរក្សាជាប់, ពិតប្រាកដបួសហាត់សុចរិតធម៌, កុំលាយបញ្ចូលប្រការណាមួយដើម្បីបួស, សូម្បីតែគំនិតក៏មិនអាចថែមចូល។ មានហ្វាលូនរបស់មនុស្សមួយចំនួនសុទ្ធតែប្រែទម្រង់, ហេតុអ្វីប្រែទម្រង់? គាត់និយាយថាខ្ញុំគ្មានហាត់គង់នោះឯណា? ប៉ុន្តែគាត់ហាត់កាលណា, គំនិតគាត់គឺថែមចូលប្រការធ្លាប់មានពីមុនរបស់គាត់, នោះមិនមែននាំចូលទៅក្នុងហើយឬ? កាយភ្ជាប់បញ្ហានេះ, យើងខ្ញុំគ្រាន់តែសម្តែងត្រឹមនេះ។

## ភាសាចក្រវាល

ភាសាចក្រវាលជាអ្វី? នោះគឺឯកជននេះស្រាប់តែអាចនិយាយប្រភេទពាក្យមួយដែលមិនអាចពន្យល់, ទីលីទូលូ, ទីលីទូលូ, ដែលនិយាយជាអ្វី, គាត់ខ្លួនឯងក៏មិនដឹង។ មនុស្សមានសីលគង់អានគំនិត, អាចដឹងពីអត្ថន័យទូទៅ, ផ្ទុយមកវិញមិនអាចដឹងបានគាត់និយាយពិស្តារជាអ្វី។ លើសពីនេះទៀតមនុស្សខ្លះអាចនិយាយចេញភាសាផ្សេងៗគ្នាជាច្រើនប្រភេទ។ មនុស្សខ្លះនៅមានអារម្មណ៍ថាអស្ចារ្យណាស់, សន្មតថាជាអានុភាព, ជាសីលគង់។ វាក៏មិនមែនសីលគង់, ក៏មិនមែនអានុភាពរបស់អ្នកបួសហាត់, ក៏មិនតំណាងឲ្យជាន់ថ្នាក់របស់លោកអ្នក។ នោះជារឿងដូចម្តេច? នោះគឺមនោគតិរបស់លោកអ្នកត្រូវបានប្រភេទកាយវិញ្ញាណមួយខាងក្រៅគ្របសង្កត់ជាប់, លោកអ្នកនៅតែមានអារម្មណ៍ថាល្អណាស់, លោកអ្នកចូលចិត្តចង់បាន, លោកអ្នករីករាយ, លោកអ្នកកាន់តែរីករាយ, វាគ្របសង្កត់លោកអ្នកនឹងកាន់តែរឹងមាំ។ ធ្វើជាមនុស្សបួសហាត់ពិតប្រាកដម្នាក់, លោកអ្នកអាចសុខចិត្តទុកឱ្យវាគ្របសង្កត់ឬ? លើសពីនេះវាមកពីជាន់ថ្នាក់សែនទាប, ដូច្នេះពួកយើងធ្វើជាមនុស្សបួសហាត់ពិតប្រាកដ, កុំអន្ទងមករំខានទាំងនេះ។

មនុស្សគឺដ៏មានតម្លៃបំផុត, ជារៀមច្បងរបស់សព្វសត្វ, ហេតុអ្វីលោកអ្នកអាចសុខចិត្តទុកឱ្យរបស់ទាំងនេះគ្រប់សង្កត់? រាងកាយរបស់លោកអ្នកសុទ្ធតែមិនចង់បានទៀត, សោកស្តាយប៉ុណ្ណា! អ្វីទាំងនេះមានខ្លះភ្ជាប់នៅលើរាងមនុស្ស; ក៏មានខ្លះមិនភ្ជាប់នៅលើរាងមនុស្ស, ឃ្លាតពីមនុស្សមួយគម្លាត, ប៉ុន្តែវាកាច់ចង្កូតលោកអ្នក, គ្រប់សង្កត់លោកអ្នក។ លោកអ្នកចង់និយាយវាគឺទុកឲ្យលោកអ្នកនិយាយ, និយាយទីលីទូលូ។ នៅអាចបង្រៀន, នរណាចង់រៀន, ហ៊ានថ្លើមធំ, ហ៊ានបើកមាត់, គាត់ក៏អាចនិយាយចេញបាន។ ភាពពិតរបស់នោះដើរតាមក្រុមតាមហ្វូង, លោកអ្នកចង់និយាយវាគឺឡើងមកមួយទុកឲ្យលោកអ្នកនិយាយ។

ហេតុអ្វីលេចឡើងកាលៈទេសៈនេះ? ក៏ជាដូចខ្ញុំធ្លាប់និយាយ, វាចង់លើកកម្ពស់ជាន់ថ្នាក់ខ្លួនឯង, ប៉ុន្តែខាងនោះគ្មានទុក្ខដើម្បីរង, គឺមិនអាចបួសហាត់, មិនអាចលើកកម្ពស់។ វាបានគិតវិធីសាស្ត្រមួយ, ជួយមនុស្សធ្វើរឿងល្អ, ប៉ុន្តែក៏មិនយល់ត្រូវធ្វើដូចម្តេច, តែវាដឹងថាថាមពលដែលវាបញ្ជូនចេញ, អាចសាងបង្កើតផលប៉ះពាល់រឹតត្បិតតិចតួចចំពោះមនុស្សមានជំងឺ, អាចលុបបំបាត់ការឈឺចាប់ឲ្យអ្នកជំងឺនាពេលនោះ, តែមិនអាចព្យាបាលជាសះស្បើយ, ដូច្នេះវាដឹងថាការបញ្ជូនវាចេញដោយមាត់មនុស្សអាចដើរតួនាទីបែបនេះ, ជាក់ស្តែងជារឿងយ៉ាងនេះ។ ក៏មានមនុស្សនិយាយថាវាជាពាក្យរបស់ទេវតា, ក៏មានមនុស្សនិយាយថាវាជាពាក្យរបស់ព្រះពុទ្ធ, នេះគឺប្រមាថព្រះពុទ្ធ។ ខ្ញុំនិយាយនោះសុទ្ធសាធជាក់ស្តែងគឺជាផ្តេសផ្តាស!

អ្នករាល់គ្នាដឹងថា, ព្រះពុទ្ធមិនងាយបើកមាត់។ ប្រសិននៅអវកាសនេះរបស់ពួកយើងបើកមាត់និយាយស្តី, គាត់អាចធ្វើឲ្យមនុស្សជាតិកើត

ឡើងរញ្ជួយដី, វាមិនអាចទៅរួច! រញ្ជួយញ័រគ្រឹមៗយ៉ាងនោះ។ មនុស្សខ្លះនិយាយថា៖ ភ្នែកទិព្វរបស់ខ្ញុំមើលឃើញ, គាត់និយាយគ្នាជាមួយខ្ញុំ។ គាត់មិនមែននិយាយគ្នាជាមួយលោកអ្នក។ មនុស្សខ្លះមើលឃើញបរមីរបស់ខ្ញុំក៏ដោយ, មិនមែននិយាយគ្នាជាមួយលោកអ្នក, គំនិតដែលគាត់វាយចេញគឺមាននាំតាមសំឡេងស្តេរ៉េអូ, លោកអ្នកស្តាប់ឮដូចជាគាត់និយាយស្តី។ តាមធម្មតាគាត់អាចនិយាយនៅក្នុងអវកាសនោះរបស់គាត់, ប៉ុន្តែបន្ទាប់ពីចម្លងមក, លោកអ្នកស្តាប់មិនច្បាស់គាត់និយាយជាអ្វី។ ដោយសារទស្សនាទានវេលា-អវកាសនៃអវកាសទាំងពីរមិនដូចគ្នា, មួយស៊ីឆឺនរបស់អវកាសពួកយើងខាងនេះ, នោះគឺ២ម៉ោងនាឡិកាបច្ចុប្បន្ន។ ហើយនៅក្នុងមហាអវកាសនោះ, មួយស៊ីឆឺននេះរបស់ពួកយើងជាក់ស្តែងគឺជាមួយឆ្នាំរបស់គាត់, ផ្ទុយមកវិញយឺតជាងពេលវេលារបស់គាត់។

អតីតកាលមានប្រយោគនិយាយថា [មួយថ្ងៃឋានសួគ៌, ពាន់ឆ្នាំឋានមនុស្ស], គឺសំដៅលើពិភពឯកតាគ្មានទស្សនាទានអវកាស, គ្មានទស្សនាទានពេលវេលា, ជាក់ស្តែងគឺជាពិភពដែលអង្គមហាត្រាស់ដឹងនៅ, ដូចជាពិភពសុខៈ, ពិភពកញ្ចក់ពណ៌, ពិភពហ្វាលូន, ពិភពផ្កាឈូកជាដើម, ជាកន្លែងទាំងនោះ។ ហើយពេលវេលានៃមហាអវកាសនោះផ្ទុយមកវិញលឿនជាង, ប្រសិនលោកអ្នកអាចទទួលបាន, ស្តាប់បានពាក្យដែលគាត់និយាយស្តី, មនុស្សខ្លះត្រចៀកទិព្វ, ត្រចៀកនេះបើករួចហើយ, ពេលដែលអាចស្តាប់បានគាត់និយាយស្តី, លោកអ្នកស្តាប់មិនច្បាស់។ លោកអ្នកស្តាប់អ្វីសុទ្ធតែបែបនោះ, ដូចជាចាបស្រែក, ដូចជាម៉ាស៊ីនចាក់សំឡេងវិលលឿន, មិនអាចស្តាប់ចេញបាន។ ប្រាកដណាស់មនុស្សខ្លះអាចស្តាប់បានតន្ត្រី, ក៏អាចស្តាប់បានការនិយាយស្តី។ ប៉ុន្តែ

គាត់ចាំបាច់ត្រូវតែតាមរយៈប្រភេទសីលគង់មួយធ្វើជាកាយចម្លង, លុបបំបាត់ភាពខុសគ្នាអំពីពេលវេលា, ចម្លងដល់ក្នុងត្រចៀករបស់លោកអ្នក, លោកអ្នកទើបអាចស្តាប់ច្បាស់បាន, នោះជាកាលៈទេសៈបែបនេះ។ មានមនុស្សនិយាយថាជាភាសារបស់ព្រះពុទ្ធ, ជាមូលដ្ឋានវាគឺមិនមែន។ រវាងអង្គត្រាស់ដឹងជាមួយគ្នាពេលដែលជួបមុខ, អង្គទាំងពីរញញឹម, ហើយយល់គ្រប់យ៉ាង។ ដោយសារនេះជាទូរវេទន៍គ្មានសំឡេង, ដែលទទួលបានគឺមាននាំតាមសំឡេងស្តេរ៉េអូ។ ពេលដែលអង្គទាំងពីរញញឹម, យោបល់បានផ្តោះប្តូរចប់រួចហើយ។ ក៏មិនមែនជ្រើសប្រើទម្រង់តែមួយ, ពេលខ្លះក៏ជ្រើសប្រើវិធីសាស្រ្តផ្សេងឯទៀត។ អ្នករាល់គ្នាបានដឹង, នៅមីចុង, ឡាម៉ាទីបេយកចិត្តទុកដាក់វាយក្បាច់ដៃ, ប៉ុន្តែ, លោកអ្នកសាកសួរក្បាច់ដៃនោះរបស់ឡាម៉ាជាអ្វី? គាត់ប្រាប់លោកអ្នកថាជាយោគៈកំពូល។ ពិស្តារជាអ្វី? គាត់ក៏មិនដឹង។ ភាពពិតជាក់ស្តែងគឺជាភាសារបស់អង្គមហាត្រាស់ដឹង។ ពេលដែលមនុស្សច្រើន, គាត់វាយក្បាច់ដៃធំ, ស្អាតខ្លាំងណាស់, ក្បាច់ដៃធំគ្រប់ប្រភេទ; ពេលដែលមនុស្សតិច, គាត់វាយក្បាច់ដៃតូច, ក៏ស្អាតណាស់ផងដែរ។ ឥរិយាបថក្បាច់ដៃតូចគ្រប់ប្រភេទ, ស្មុគស្មាញខ្លាំងណាស់, សម្បូរបែបខ្លាំងណាស់, ដោយសារវាគឺជាភាសា។អតីតកាលនេះសុទ្ធតែជាអាថ៌កំបាំងធម្មជាតិ, យើងខ្ញុំសុទ្ធតែសម្តែងចេញ។ អ្វីដែលបានប្រើនៅទីបេគ្រាន់តែជាប៉ុន្មានចលនាសាមញ្ញសម្រាប់ហាត់គង់យ៉ាងនោះ, គាត់សរុបវាមក, រៀបចំជាប្រព័ន្ធ។ វាគ្រាន់តែជាភាសាសាមញ្ញសម្រាប់ហាត់គង់, លើសពីនេះទៀតគ្រាន់តែជាប៉ុន្មានទម្រង់សម្រាប់ហាត់គង់ប៉ុណ្ណោះ, ក្បាច់ដៃពិតប្រាកដ, គឺស្មុគស្មាញណាស់។

## លោកគ្រូផ្តល់អ្វីខ្លះឲ្យសិក្ខាកាម

មានមនុស្សមួយចំនួនបន្ទាប់ពីបានឃើញខ្ញុំហើយចាប់ដៃខ្ញុំ, កាន់ជាប់គឺមិនចង់ដោះលែង។ មនុស្សផ្សេងពេលឃើញអ្នកដទៃចាប់ដៃ, គាត់ក៏កាន់ដៃខ្ញុំផងដែរ។ ខ្ញុំដឹងក្នុងចិត្តរបស់គាត់គិតអ្វី។ មនុស្សខ្លះចង់សាកកាន់ដៃនឹងលោកគ្រូ, មានអារម្មណ៍រីករាយណាស់; មនុស្សខ្លះចង់បានបន្តិចព័ត៌មាន, ចាប់ដៃគឺមិនចង់ដោះលែង។ យើងខ្ញុំប្រាប់អ្នករាល់គ្នា, បួសហាត់ពិតប្រាកដជារឿងឯកជនរបស់លោកអ្នក, នៅទីនេះក៏មិនមែនព្យាបាលជំងឺកាយសម្បទា, ផ្តល់ឲ្យលោកអ្នកបន្តិចព័ត៌មាន, ព្យាបាលជំងឺឲ្យលោកអ្នក, យើងខ្ញុំក៏មិនសម្តែងរឿងនេះ។ ជំងឺលោកអ្នកដោយសារខ្ញុំមកដោយផ្ទាល់ព្យាបាលឲ្យលោកអ្នក, នៅទីតាំងហាត់គង់ដោយសារបរមីរបស់ខ្ញុំព្យាបាលឲ្យ, មើលសៀវភៅរៀនដោយខ្លួនឯងក៏ដោយសារបរមីរបស់ខ្ញុំព្យាបាលឲ្យផងដែរ។ លោកអ្នកសន្មតថាប៉ះៗដៃរបស់ខ្ញុំគឺអាចបង្កើនគង់ឬ? នោះមិនមែនជារឿងកំប្លែងឬ?

គង់គឺពឹងផ្អែកលើចិត្តចរិតខ្លួនឯងដើម្បីបួស, លោកអ្នកមិនទៅបួសជាក់ស្តែង, គង់នោះគឺបង្កើនឡើងមិនបាន, ដោយសារវាគឺមានបរមាណើយចិត្តចរិតនៅទីនោះ។ ពេលដែលលោកអ្នកបង្កើនគង់, ជាន់ថ្នាក់ខ្ពស់អាចមើលឃើញចិត្តប្រកាន់របស់លោកអ្នក, សារធាតុនោះកម្ចាត់ចោលរួចហើយ, នៅលើកំពូលក្បាលគឺនឹងកើតចេញមករង្វាស់មួយ។ លើសពីនេះទៀតប្រភេទរង្វាស់នេះគឺជាអត្ថិភាពរបស់សសរគង់, រង្វាស់ខ្ពស់ប៉ុណ្ណា, សសរគង់ខ្ពស់ប៉ុណ្ណោះ, វាតំណាងឱ្យគង់ដែលលោកអ្នកខ្លួនឯងបួសចេញបាន, ក៏តំណាងឱ្យចិត្តចរិតខ្ពស់ឬទាបរបស់លោកអ្នក។ អ្នកដទៃនរណាថែមឡើងឱ្យលោកអ្នកប៉ុន្មានសុទ្ធតែមិនបាន, ថែមឡើងបន្តិចក៏ដាក់មិនជាប់, សុទ្ធតែត្រូវធ្លាក់ចុះ។ ខ្ញុំជាបន្ទាន់អាចទុកឱ្យលោកអ្នកសម្រេចបាន [ផ្កាបីផ្តុំកំពូល], ប៉ុន្តែលោកអ្នកចេញពីទ្វារកាល

ណាគង់គឺធ្លាក់ចុះ។ នោះមិនមែនជារបស់លោកអ្នក, មិនមែនលោកអ្នកបួសចេញបាន, ដាក់ឡើងមិនបាន, ដោយសារបរមាណើយចិត្តចរិតរបស់លោកអ្នកមិននៅទីនោះ, នរណាថែមឱ្យសុទ្ធតែថែមឡើងមិនបាន, នោះទាំងស្រុងគឺពឹងផ្អែកលើខ្លួនឯងដើម្បីបួស, បួសហាត់ចិត្តរបស់ខ្លួនឯង។ បង្កើនគង់ឡើងលើដោយរឹងមាំនិងប្រាកដ, បន្តលើកកម្ពស់ខ្លួនឯង, សមកាលកម្មនឹងចរិតពិសេសនៃចក្រវាល, លោកអ្នកទើបអាចឡើងលើបាន។ មានមនុស្សរកខ្ញុំស៊ីញ៉េឈ្មោះ, ខ្ញុំគឺមិនចង់ស៊ីញ៉េ។ មានមនុស្សនិយាយថាធ្លាប់បានលោកគ្រូស៊ីញ៉េឈ្មោះឱ្យ, គាត់ចង់បង្ហាញ, ចង់ព័ត៌មានរបស់លោកគ្រូការពារ។ នេះក៏មិនមែនចិត្តប្រកាន់ឬ? បួសហាត់ត្រូវតែពឹងផ្អែកលើខ្លួនឯង, លោកអ្នកសម្ដែងព័ត៌មានអ្វី? បួសហាត់នៅលើជាន់ថ្នាក់ខ្ពស់លោកអ្នកអាចសម្ដែងអំពីប្រការនេះឬ? នោះចាត់ថាជាអ្វី? នោះគ្រាន់តែជាសម្ដែងព្យាបាលជំងឺកាយសម្បទាប៉ុណ្ណោះ។

គង់នោះដែលលោកអ្នកខ្លួនឯងហាត់ចេញ, នៅក្រោមអតិសុខុមបំផុត, ភាគល្អិតរបស់គង់នោះដូចគ្នាបេះបិទនឹងរូបភាពរបស់លោកអ្នក។ ពេលដែលដើរឆ្លងផុតពីលោកីយ៍ធម៌, លោកអ្នកជាក់ស្ដែងគឺជាបួសហាត់ពុទ្ធកាយ។ គង់នោះសុទ្ធតែជារូបរាងពុទ្ធកាយ, ស្អាតខ្លាំងណាស់, អង្គុយនៅលើផ្កាឈូក, លើភាគល្អិតតូចនីមួយៗសុទ្ធតែដូច្នោះ។ ហើយគង់នោះរបស់សត្វ, សុទ្ធតែជាកញ្ជ្រោងតូច, ពស់តូច, លើភាគល្អិតក្រោមអតិសុខុមបំផុតសុទ្ធតែជារបស់ទាំងនេះ។ នៅមានអ្វីព័ត៌មាន, កូរៗទឹកតែហើយយកឱ្យលោកអ្នកផឹក, យ៉ាងណាមិញវាក៏ជាគង់។ មនុស្សសាមញ្ញគ្រាន់តែចង់បណ្ដោះអាសន្នបំបាត់ការឈឺចាប់, យកជំងឺរុញថយទៅក្រោយ, រឹតត្បិតៗ, យ៉ាងណាមិញមនុស្សសាមញ្ញជាក់ស្ដែងគឺជាមនុស្សសាមញ្ញ, គាត់ធ្វើឱ្យរាងកាយអាក្រក់ដូចម្ដេច, ពួក

យើងក៏មិនខ្វល់។ ពួកយើងគឺជាមនុស្សហាត់គង់, ទើបខ្ញុំសម្ដែងចេញរឿងរ៉ាវទាំងនេះឱ្យលោកអ្នក។ ពីពេលនេះតទៅអ្នករាល់គ្នាក៏កុំធ្វើរឿងរ៉ាវទាំងនេះ, ព័ត៌មានអ្វី, មួយនេះមួយនោះ, ក៏ជាដាច់ខាតកុំចង់បានអ្វីទាំងនេះ។ គ្រូឈីគង់ខ្លះនិយាយថា៖ ខ្ញុំធ្វើចេញព័ត៌មានឱ្យអ្នកគ្រប់គ្នា, អ្នកគ្រប់គ្នានៅគ្រប់ទីកន្លែងទូទាំងប្រទេសទទួលយក។ ទទួលយកអ្វីទៅ? ខ្ញុំសម្ដែងឲ្យលោកអ្នក, រឿងរ៉ាវទាំងនេះមិនអាចផ្ដើមផលប៉ះពាល់អ្វីធំ, ឧបមាថាវាគឺមានកន្លែងល្អ, នោះគ្រាន់តែដើម្បីព្យាបាលជំងឺកាយសម្បទា។ ហើយពួកយើងធ្វើជាមនុស្សហាត់គង់ម្នាក់, គង់គឺខ្លួនឯងបួសចេញមក, អ្នកដទៃធ្វើចេញព័ត៌មានគង់អ្វីក៏មិនអាចលើកកម្ពស់ជាន់ថ្នាក់, គ្រាន់តែជាព្យាបាលជំងឺឲ្យមនុស្សសាមញ្ញ។ ជាក់លាក់ត្រូវតែដាក់ចិត្តឲ្យសុចរិត, បួសហាត់គ្មាននរណាជំនួសបាន, មានតែលោកអ្នកខ្លួនឯងបួសហាត់ដោយពិតប្រាកដ, ខ្លួនឯងទើបអាចលើកកម្ពស់ជាន់ថ្នាក់។

ដូច្នោះខ្ញុំផ្ដល់អ្វីខ្លះឲ្យអ្នករាល់គ្នា? អ្នករាល់គ្នាដឹងថាពួកយើងមានមនុស្សជាច្រើនមិនធ្លាប់ហាត់គង់, រាងកាយគឺមានជំងឺ; មានមនុស្សជាច្រើនទោះបីហាត់គង់ច្រើនឆ្នាំ, ប៉ុន្តែនៅតែវិលចុះវិលឡើងនៅក្នុងឈី, ក៏មិនទាន់មានគង់។ ប្រាកដណាស់មានមនុស្សមួយចំនួនព្យាបាលជំងឺឲ្យគេ, លោកអ្នកមិនដឹងហេតុអ្វីព្យាបាលជំងឺបាន? ពេលខ្ញុំសម្ដែងអំពីបញ្ហាកាយភ្ជាប់, ខ្ញុំបានយកកាយភ្ជាប់នាំតាមរាងកាយមនុស្សដែលអាចពិតជាបួសមហាធម៌, មិនថាជារបស់អ្វី, អ្វីមិនល្អទាំងអស់ពីក្នុងដល់ក្រៅដែលនាំតាមលើរាងកាយ, សុទ្ធតែយកចុះទាំងអស់។ មនុស្សដែលពិតប្រាកដបួសដោយខ្លួនឯងពេលមើលមហាធម៌នេះ, ក៏នឹងសម្អាតរាងកាយឲ្យលោកអ្នក, លើសពីនេះទៀតបរិយាកាសក្នុងផ្ទះរបស់លោកអ្នក, ក៏ត្រូវតែសម្អាតចេញមក។ អតីតកាលលោកអ្នកធ្លាប់សែនព្រេនបន្ទះ

របស់កញ្ច្រោង, សំរាម, លោកអ្នកប្រញាប់បោះវាចោល, សុទ្ធតែសម្អាតឲ្យលោកអ្នករួចហើយ, សុទ្ធតែមិនស្ថិតនៅទៀត។ ដោយសារលោកអ្នកចង់បួសហាត់, យើងខ្ញុំគឺអាចបើកស្លាបទ្វារងាយស្រួលបំផុតឲ្យលោកអ្នក, ធ្វើរឿងរ៉ាវទាំងនេះឲ្យលោកអ្នក, ប៉ុន្តែកំហិតតែក្នុងមនុស្សបួសហាត់ពិតប្រាកដ។ ប្រាកដណាស់មានមនុស្សមួយចំនួនគ្មានចង់បួសហាត់, ដល់បច្ចុប្បន្នគាត់ក៏មិនទាន់យល់ច្បាស់, ដូច្នេះយើងខ្ញុំមិនអាចគ្រប់គ្រងបាន, ដែលយើងខ្ញុំគ្រប់គ្រងគឺជាមនុស្សបួសហាត់ពិតប្រាកដ។

នៅមានមនុស្សមួយប្រភេទ, អតីតកាលគេនិយាយថាលើខ្លួនគាត់មានកាយភ្ជាប់, គាត់ខ្លួនឯងក៏មានអារម្មណ៍ថាមាន, ប៉ុន្តែបន្ទាប់ពីយកចុះឲ្យគាត់រួចហើយ, ចិត្តជំងឺនោះរបស់គាត់កម្ចាត់មិនបាន, គាត់តែងតែមានអារម្មណ៍ថាស្ថានភាពនោះនៅតែស្ថិតនៅ, គាត់សន្មតថានៅតែមាន, នេះបានក្លាយជាចិត្តប្រកាន់មួយរួចហើយ, ហៅថាចិត្តសង្ស័យ។ យូរៗទៅ, គាត់ខ្លួនឯងធ្វើមិនល្អនៅតែនឹងអន្ទងមក។ លោកអ្នកខ្លួនឯងត្រូវតែដាក់ចិត្តចុះ, ជាមូលដ្ឋានគឺមិនស្ថិតនៅទៀត។ មានមនុស្សមួយចំនួនយើងខ្ញុំពីមុនបើកថ្នាក់គឺធ្លាប់ដោះស្រាយឲ្យគាត់, ខ្ញុំបានធ្វើរឿងរ៉ាវទាំងនេះ, យកកាយភ្ជាប់ទាំងអស់កម្ចាត់ចោលរួចហើយ។

តាវវង្សហាត់គង់នៅលើជាន់ថ្នាក់ទាបត្រូវការដាក់មូលដ្ឋានមួយចំនួន, ត្រូវការបង្កើតវង់សកល, មួយដុំធាននោះនៃតានធានត្រូវតែបង្កើត, នៅមានប្រការនៃទិដ្ឋភាពមួយចំនួនក៏ត្រូវការបង្កើតផងដែរ។ យើងខ្ញុំទីនេះត្រូវការដំឡើងហ្វាលូន, យន្តការឈី, យន្តការបួសហាត់ទាំងអស់ជាដើមច្រើនណាស់, រាប់ម៉ឺននិងច្រើនទៀត, ទាំងនេះសុទ្ធតែត្រូវផ្ដល់ឲ្យលោកអ្នក, ដូចជាគ្រាប់ពូជសាបព្រួសលើលោកអ្នក។ បន្ទាប់ពីកម្ចាត់

ជំងឺរបស់លោកអ្នក, ដែលគួរធ្វើសុទ្ធតែធ្វើ, អ្វីដែលគួរផ្តល់ឲ្យទាំងអស់ដំឡើងឲ្យលោកអ្នក, លោកអ្នកទើបអាចនៅក្នុងធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំពិតប្រាកដបួសហាត់ចេញបាន។ បើមិនដូច្នោះទេ, អ្វីក៏មិនផ្តល់ឲ្យលោកអ្នក, នោះជាក់ស្តែងគឺព្យាបាលជំងឺកាយសម្បទា។ និយាយដោយត្រង់, មានមនុស្សមួយចំនួនមិនសម្តែងចិត្តចរិត, មិនស្មើទាំងហាត់កីឡា។

បួសហាត់ពិតប្រាកដគឺត្រូវតែទទួលខុសត្រូវចំពោះលោកអ្នក, មនុស្សទាំងនេះដែលបួសដោយខ្លួនឯងក៏ទទួលបានដូចគ្នា, ប៉ុន្តែចាំបាច់គឺជាបួសពិត, យើងខ្ញុំយកអ្វីទាំងនេះសុទ្ធតែផ្តល់ឲ្យអ្នកបួសហាត់ពិតប្រាកដ។ ខ្ញុំសម្តែងរួចហើយ, ត្រូវតែពិតប្រាកដចាត់ទុកលោកអ្នកដូចជាសិស្សដើម្បីណែនាំ។ ក្រៅពីនេះ, ធម៌នៅលើជាន់ថ្នាក់ខ្ពស់ជាក់លាក់ត្រូវរៀនឱ្យធ្លុះធ្លាយ, ដឹងធ្វើបែបណាដើម្បីបួសហាត់; ៥សំណុំលំហាត់ត្រូវបានបង្រៀនអស់ដើម្បីរៀន។ អនាគតលោកអ្នកអាចសម្រេចបានជាន់ថ្នាក់មួយដ៏ខ្ពស់, លោកអ្នកសុទ្ធតែនឹកស្មានមិនដល់ជាន់ថ្នាក់ខ្ពស់យ៉ាងនោះ, សម្រេចមគ្គផលគឺគ្មានបញ្ហា។ ដរាបណាលោកអ្នកបួសហាត់, ធម៌នេះខ្ញុំបានរួមបញ្ចូលនូវជាន់ថ្នាក់ផ្សេងៗគ្នាដើម្បីសម្តែង, ពីពេលនេះតទៅខណៈពេលលោកអ្នកបួសហាត់នៅជាន់ថ្នាក់ខុសគ្នា, លោកអ្នកនឹងរកឃើញថាគាត់សុទ្ធតែនឹងមានតួនាទីដឹកនាំចំពោះលោកអ្នក។

ធ្វើជាមនុស្សបួសហាត់ម្នាក់, ផ្លូវនៃជីវិតពីពេលនេះតទៅនឹងផ្លាស់ប្រែ, បរមីរបស់ខ្ញុំនឹងរៀបចំសាជាថ្មីឲ្យលោកអ្នក។ រៀបចំដូចម្តេច? មានមនុស្សមួយចំនួនដំណើរការជីវិតនៅបានប៉ុន្មាន? គាត់ខ្លួនឯងក៏មិនដឹង; មានមនុស្សមួយចំនួនកន្លងមួយឆ្នាំ, កន្លះឆ្នាំអាចនឹងកើតជំងឺធ្ងន់ធ្ងរ, ឈឺពេលណាអាចនឹងច្រើនឆ្នាំជាប់គ្នា; មនុស្សខ្លះអាចនឹងស្ទះសរសៃឈាម

ខួរក្បាលឬជំងឺផ្សេង, ជាមូលដ្ឋានកម្រើកមិនបាន។ នៅក្នុងផ្លូវនៃជីវិតពីពេលនេះតទៅ, លោកអ្នកធ្វើដូចម្តេចបួសហាត់? យើងខ្ញុំសុទ្ធតែត្រូវការសម្អាតឲ្យលោកអ្នក, មិនអាចទុកឲ្យរឿងរ៉ាវទាំងនេះកើតឡើង។ ប៉ុន្តែយើងខ្ញុំមានពាក្យជាមុន, គ្រាន់តែអាចធ្វើរឿងរ៉ាវនេះឲ្យមនុស្សបួសហាត់ពិតប្រាកដ, តាមអំពើចិត្តធ្វើឲ្យមនុស្សសាមញ្ញនោះគឺមិនអាច, នោះស្មើនឹងធ្វើរឿងអាក្រក់។ កើតចាស់ឈឺស្លាប់ទីមនុស្សសាមញ្ញរឿងរ៉ាវទាំងនេះសុទ្ធតែជាមានទំនាក់ទំនងកម្មផល, មិនអាចបំផ្លាញតាមអំពើចិត្ត។

យើងខ្ញុំមើលមនុស្សបួសហាត់គឺដ៏មានតម្លៃបំផុត, ដូច្នេះគ្រាន់តែអាចធ្វើឲ្យមនុស្សបួសហាត់។ ធ្វើដូចម្តេច? ប្រសិនអធិកភាពគុណធម៌របស់គ្រូដ៏ខ្ពស់, មានន័យថាអំណាចគង់របស់គ្រូដ៏ខ្ពស់, គាត់អាចរំលាយកម្មឲ្យលោកអ្នក។ គង់របស់គ្រូខ្ពស់អាចរំលាយកម្មឲ្យលោកអ្នកដ៏ច្រើន, គង់របស់គ្រូទាបគ្រាន់តែអាចរំលាយបានតិចតួច។ យើងខ្ញុំលើកឧទាហរណ៍និយាយ៖ យកអំណាចកម្មគ្រប់ប្រភេទក្នុងផ្លូវនៃជីវិតពីពេលនេះតទៅរបស់លោកអ្នកប្រមូលផ្តុំមកវិញ, យកវារំលាយចោលមួយផ្នែក, រំលាយចោលពាក់កណ្តាល។ នៅសល់ពាក់កណ្តាលលោកអ្នកក៏ឆ្លងមិនបាន, ខ្ពស់ជាងភ្នំទៀត។ ធ្វើដូចម្តេច? អាចពេលដែលលោកអ្នកត្រាស់ដឹង, អនាគតមានមនុស្សដ៏ច្រើនសុទ្ធតែនឹងទទួលបានអត្ថប្រយោជន៍, បែបនេះបន្តមក, មានមនុស្សដ៏ច្រើនជំនួសលោកអ្នកទទួលបន្ទុកមួយចំណែក។ ប្រាកដណាស់និយាយចំពោះពួកគាត់មិនចាត់ថាអ្វី។ លោកអ្នកខ្លួនឯងនៅមានវិវត្តនិងហាត់ចេញកាយជីវិតជាច្រើន, លើសពីនេះលោកអ្នកខ្លួនឯងក្រៅពីវិញ្ញាញដើមម្ចាស់, វិញ្ញាណដើមរង, នៅមានលោកអ្នកជាច្រើនទៀត, សុទ្ធតែនឹងជំនួសលោកអ្នកទទួលបន្ទុកមួយចំណែក។ ដល់ពេលលោកអ្នកឆ្លងបានគ្រោះកប្ប, គឺនៅសល់

គ្មានប៉ុន្មាន។ និយាយថានៅសល់គ្មានប៉ុន្មាន, នោះនៅតែធំណាស់, លោកអ្នកនៅតែឆ្លងមិនបាន, ធ្វើដូចម្ដេច? គឺយកវាបែងចែកជាចំណែកច្រើនរាប់មិនអស់, ដាក់នៅក្នុងបណ្ដាជាន់ថ្នាក់បួសហាត់របស់លោកអ្នក, កេងប្រវ័ញ្ចវាដើម្បីលើកកម្ពស់ចិត្តចរិតរបស់លោកអ្នក, បំប្លែងអំណាចកម្មរបស់លោកអ្នក, បង្កើនគង់របស់លោកអ្នក។

ក្រៅពីនេះ, មនុស្សម្នាក់ចង់បួសហាត់, ប៉ុន្តែមិនមែនរឿងរ៉ាវមួយងាយស្រួលយ៉ាងនោះ។ ខ្ញុំបានសម្ដែងថានេះជារឿងរ៉ាវមួយដែលតឹងរឹងខ្លាំងណាស់, លើសពីនេះទៀតវាគឺលើសពីមនុស្សសាមញ្ញ, ប្រៀបនឹងរឿងរ៉ាវណាមួយក្នុងមនុស្សសាមញ្ញសុទ្ធតែពិបាកជាង។ នោះមិនមែនវិសាមញ្ញឬ? ដូច្នេះប្រៀបនឹងរឿងរ៉ាវណាមួយក្នុងមនុស្សសាមញ្ញតម្រូវចំពោះលោកអ្នកសុទ្ធតែខ្ពស់ជាង។ មនុស្សពួកយើងគឺមានវិញ្ញាណដើម, វិញ្ញាណដើមគឺអមតៈ។ ប្រសិនវិញ្ញាណដើមគឺអមតៈ, អ្នករាល់គ្នាគិតសាកមើល, តើវិញ្ញាណដើមរបស់លោកអ្នកនៅក្នុងសកម្មភាពសង្គមជាតិមុនរបស់លោកអ្នកមិនមែនធ្លាប់ធ្វើរឿងអាក្រក់? ទំនងណាស់។ ធ្លាប់សម្លាប់ជីវិត, ធ្លាប់ជំពាក់នរណារបស់អ្វី, ធ្លាប់សម្លុតនរណា, ធ្លាប់ធ្វើបាបនរណា, គឺអាចបានធ្វើរឿងរ៉ាវទាំងនេះ។ ប្រសិនជាបែបនេះ, លោកអ្នកនៅខាងនេះបួសហាត់, វានៅខាងនោះមើលគឺច្បាស់លាស់ណាស់។ លោកអ្នកព្យាបាលជំងឺកាយសម្បទាវាមិនខ្វល់លោកអ្នក, វាដឹងថាលោកអ្នករុញថយទៅក្រោយ, បច្ចុប្បន្នលោកអ្នកមិនសងអនាគតសង, អនាគតសងនៅធ្ងន់ជាង។ ដូច្នេះលោកអ្នកបណ្ដោះអាសន្នមិនសង, វាក៏មិនខ្វល់។

លោកអ្នកនិយាយលោកអ្នកចង់បួសហាត់, វាអាចមិនព្រម៖ ឯងចង់បួសហាត់, ឯងចង់ចេញទៅ, ឯងបង្កើនគង់រួចហើយ, យើងក៏ធ្វើបាប

ឯងមិនបានទៀត, យើងប៉ះដល់ឯងមិនបានទៀត, វាអាចមិនព្រម។ វាតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានដើម្បីរារាំងលោកអ្នក, មិនទុកឱ្យលោកអ្នកបួសហាត់, ដូច្នេះជ្រើសប្រើគ្រប់ប្រភេទវិធីសាស្ត្រដើម្បីជ្រៀតជ្រែកលោកអ្នក, សូម្បីតែពិតជាមកសម្លាប់លោកអ្នក។ ប្រាកដណាស់លោកអ្នកនឹងមិនអាចដោយសារអង្គុយសមាធិនៅទីនេះហើយក្បាលផ្លាស់ទីទៅបាត់, នេះគឺមិនអាច, ដោយសារត្រូវស្របគ្នាតាមស្ថានភាពរបស់សង្គមមនុស្សសាមញ្ញ។ អាចទើបតែចេញពីទ្វារត្រូវឡានបុក, ធ្លាក់ពីជាន់ខាងលើ, ឬក៏លេចឡើងគ្រោះថ្នាក់ផ្សេងៗ, គឺអាចលេចឡើងរឿងរ៉ាវទាំងនេះ, គឺគ្រោះថ្នាក់ណាស់។ បួសហាត់ពិតប្រាកដអាចមិនដូចលោកអ្នកនឹកគិតងាយស្រួលយ៉ាងនោះ, តើលោកអ្នកចង់បួសហាត់, គឺបួសហាត់ឡើងទៅបាន? ប្រសិនលោកអ្នកបួសហាត់ដោយពិតប្រាកដ, ភ្លាមៗនោះនឹងជួបប្រទះគ្រោះថ្នាក់ដល់ជីវិត, ភ្លាមៗនោះនឹងពាក់ព័ន្ធដល់បញ្ហានេះ។ មានគ្រូឈីគង់ដ៏ច្រើនមិនហ៊ានបង្រៀនគង់នាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់។ ហេតុអ្វី? គាត់ជាក់ស្ដែងគឺធ្វើមិនបានរឿងរ៉ាវនេះគាត់ការពារលោកអ្នកមិនបាន។

អតីតកាលមានមនុស្សបង្រៀនតាវជាច្រើន, គាត់អាចបង្រៀនឲ្យសិស្សតែម្នាក់ប៉ុណ្ណោះ, គាត់ថែរក្សាបានសិស្សម្នាក់គឺល្អណាស់ហើយ។ ប៉ុន្តែផ្ទៃក្រឡាធំយ៉ាងនេះ, មនុស្សធម្មតាគឺមិនសូវហ៊ានធ្វើ។ ប៉ុន្តែយើងខ្ញុំទីនេះសម្ដែងឲ្យអ្នករាល់គ្នា, ខ្ញុំអាចធ្វើរឿងរ៉ាវនេះ, ដោយសារខ្ញុំមានបរមីច្រើនរាប់មិនអស់, មានគ្រប់គ្រាន់ទេពអំណាចធម៌អំណាចសែនធំរបស់ខ្ញុំ, អាចលាតត្រដាងឡើងទេពអំណាចដ៏ធំ, ធម៌អំណាចដ៏ធំ។ លើសពីនេះទៀតរឿងរ៉ាវនេះដែលយើងខ្ញុំធ្វើថ្ងៃហ្នឹងក៏មិនសាមញ្ញដូច្នោះដូចដែលពួកយើងមើលឃើញ, ខ្ញុំក៏មិនមែនខួរក្បាលក្ដៅមួយឆាវទើបចេញមក

ធ្វើ។ ខ្ញុំអាចប្រាប់លោកអ្នក, មានអង្គមហាត្រាស់ដឹងជាច្រើនសុទ្ធតែកំពុងឃ្លាំមើលរឿងរ៉ាវនេះ, នេះគឺយើងខ្ញុំនៅសម័យកាលផុតធម៌បង្រៀនសុចរិតធម៌មួយដងចុងក្រោយ។ យើងខ្ញុំធ្វើរឿងរ៉ាវនេះក៏មិនអនុញ្ញាតឲ្យដើរគម្លាត, ពិតប្រាកដឆ្ពោះលើផ្លូវសុចរិតដើម្បីបួសហាត់, គ្មាននរណាហ៊ានងាយស្រួលប៉ះដល់លោកអ្នក, លើសពីនេះទៀតលោកអ្នកមានបរមីរបស់ខ្ញុំការពារលោកអ្នក, នឹងមិនលេចឡើងគ្រោះថ្នាក់ណាមួយ។

ជំពាក់បំណុលត្រូវការសង, ដូច្នេះនៅលើផ្លូវបួសហាត់អាចនឹងកើតឡើងរឿងរ៉ាវគ្រោះថ្នាក់មួយចំនួន។ ប៉ុន្តែពេលដែលលេចឡើងរឿងរ៉ាវប្រភេទនេះ, លោកអ្នកនឹងមិនភ័យខ្លាច, ក៏នឹងមិនទុកឲ្យលោកអ្នកលេចឡើងគ្រោះថ្នាក់ពិតប្រាកដ។ ខ្ញុំអាចលើកឧទាហរណ៍មួយចំនួនឲ្យអ្នករាល់គ្នា។ ពេលដែលខ្ញុំបើកថ្នាក់នៅប៉េកាំង, មានសិក្ខាកាមម្នាក់, ជិះកង់ឆ្លងផ្លូវ, ពេលដែលនៅលើផ្លូវដល់កន្លែងបត់មួយ, មានរថយន្តប្រណិតមួយគ្រឿងកំពុងបត់ប្រញាប់បុកសិក្ខាកាមរូបនេះរបស់ពួកយើង, សិក្ខាកាមរូបនេះគឺជាស្ត្រី, អាយុជាង៥០ឆ្នាំ។ ឡាននោះភ្លាមៗក៏បុកគាត់, បុកយ៉ាងខ្លាំង, ឮសូរសំឡេងមួយ [តាង] បុកត្រង់ក្បាល, ក្បាលរបស់គាត់គាប់ជួនបុកនៅលើក្បាលឡាន។ ពេលនេះបាតជើងរបស់សិក្ខាកាមរូបនេះនៅថ្កក់ជាប់លើឡាន, ក្បាលបុករួចហើយ, ផ្ទុយមកវិញគ្មានអារម្មណ៍ឈឺ។ មិនត្រឹមតែគ្មានអារម្មណ៍ឈឺ, ក៏មិនចេញឈាម, សូម្បីតែហើមក៏គ្មាន។ អ្នកបើកបរនោះរន្ធត់ខ្លាំងណាស់, លោតចុះពីឡានប្រញាប់មកសួរគាត់, និយាយថាបុកធ្ងន់ឬអត់, ពួកយើងទៅមន្ទីរពេទ្យឬអត់? គាត់និយាយថាមិនអីទេ។ ប្រាកដណាស់, សិក្ខាកាមនេះរបស់ពួកយើងចិត្តចរិតខ្ពស់ណាស់, នឹងមិនទុកឲ្យគេជួបរំខាន។ និយាយថាមិនអីទេ, ប៉ុន្តែឡាននោះត្រូវបុកចូលខូងមួយដុំធំរួចហើយ។

ដូចប្រភេទរឿងរ៉ាវនេះ, សុទ្ធតែជាមកផ្តាច់ជីវិត, ប៉ុន្តែនឹងមិនជួបប្រទះគ្រោះថ្នាក់។ ពេលយើងខ្ញុំបើកថ្នាក់លើកមុននៅសកលវិទ្យាល័យជីលីន, មានសិក្ខាកាមម្នាក់ចេញទៅពីទ្វារធំរបស់សកលវិទ្យាល័យជីលីន, បណ្ដើរកង់, ទើបដើរចេញដល់កណ្ដាល, ឡានប្រណិតពីរគ្រឿងភ្លាមៗបានគាបគាត់នៅកណ្ដាល, ភ្នែកមើលឃើញគឺជិតបុកហើយ, ប៉ុន្តែគាត់ភ័យខ្លាចបន្តិចក៏គ្មាន។ ពួកយើងជាញឹកញាប់ជួបប្រទះរឿងរ៉ាវប្រភេទនេះសុទ្ធតែមិនភ័យខ្លាច, នៅមួយសន្ទុះនោះ, ឡានក៏ឈប់ង៉ក់, គ្មានលេចឡើងបញ្ហា។

នៅប៉េកាំងនៅមានរឿងមួយយ៉ាងនេះ។ រដូវរងាមេឃឆាប់ងងឹត, គេក៏ឆាប់ចូលគេង។ លើដងផ្លូវគ្មានមនុស្ស, ស្ងាត់ណាស់។ មានសិក្ខាកាមម្នាក់ជិះកង់ប្រញាប់ទៅផ្ទះ, ខាងមុខមានឡានហ្ស៊ីបតែមួយកំពុងរត់, កំពុងរត់ៗ, ឡាននោះស្រាប់តែចាប់ហ្វ្រាំង។ គាត់គ្មានយកចិត្តទុកដាក់, នៅតែឱនក្បាលកំពុងជិះទៅមុខ។ ប៉ុន្តែឡានហ្ស៊ីបនោះស្រាប់តែថយមកក្រោយ, ថយឡានយ៉ាងឆាប់រហ័ស, ថយឡានដ៏លឿន, កម្លាំងទាំងពីរនេះរួមគ្នា, នោះក៏ដូចជាមកផ្តាច់ជីវិត។ មួយសន្ទុះនោះភ្នែកមើលឃើញដូចបុកគ្នារួចហើយ, កម្លាំងមួយភ្លាមៗបានទាញកង់របស់គាត់ថយមកក្រោយជាងកន្លះម៉ែត្រ, លើសពីនេះទៀតឡានហ្ស៊ីបភ្លាមៗនោះបានចាប់ហ្វ្រាំងបញ្ឈប់សូរងឹតៗក្បែរកង់របស់គាត់, អាចអ្នកបើកបររកឃើញថាខាងក្រោយមានមនុស្ស។ សិក្ខាកាមនេះនាពេលនោះក៏គ្មានភ័យខ្លាច, និយាយរួមជួបប្រទះប្រភេទកាលៈទេសៈនេះសុទ្ធតែគ្មានភ័យខ្លាច, អាចក្រោយមកទើបនឹកឃើញខ្លាច។ គាត់គិតដល់មុនដំបូងគឺ៖ អ៊ាយយ៉ា, គឺនរណាទាញយើងមកវិញ, យើងត្រូវអរគុណគាត់។ វិលក្បាលទើបចង់និយាយអរគុណ, ក្រឡេកមើលលើផ្លូវមនុស្សម្នាក់ក៏គ្មាន, ស្ងាត់ជ្រៀប។

គាត់ភ្លាមៗយល់ថា៖ គឺលោកគ្រូកំពុងការពារយើងហើយ។

នៅមានរឿងមួយនៅឆាងឈុន។ មានសិក្ខាកាមម្នាក់ក្បែរផ្ទះកំពុងសង់អគារ, បច្ចុប្បន្នអគារនេះសង់ខ្ពស់ណាស់, រន្ទានោះសុទ្ធតែជាបំពង់ដែកក្រាស់ពីរតឹក, ប្រវែងបួនម៉ែត្រ។ សិក្ខាកាមនេះពីក្នុងផ្ទះដើរចេញមិនឆ្ងាយ, បំពង់ដែកមួយក៏ពីលើអគារខ្ពស់នោះធ្លាក់ត្រង់ចុះមក, ធ្លាក់ត្រង់ចុះឆ្លងកាត់កំពូលក្បាលរបស់គាត់, មនុស្សនៅតាមផ្លូវសុទ្ធតែភ័យរន្ធត់។ គាត់និយាយថា៖ នរណាទះខ្ញុំ? គាត់នៅតែសន្មតថានរណាបានទះក្បាលរបស់គាត់។ គឺនៅមួយសន្ទុះនេះពេលដែលវិលក្បាលមក, មើលឃើញលើកំពូលក្បាលហ្វាលូនធំមួយកំពុងបង្វិលនៅទីនោះ, បំពង់ដែកនេះបណ្តោយតាមក្បាលហើយជម្រាលចុះ, បន្ទាប់ពីជម្រាលចុះដោតត្រង់ចូលក្នុងដី។ នោះប្រសិនពិតជាដោតចូលក្នុងរាងកាយមនុស្ស, អ្នករាល់គ្នាគិតសាកមើល, ធ្ងន់យ៉ាងនោះ, នោះដូចជាដោតឆ្លងគ្រាប់ស្ករតាំងម៉ែ, ឆ្លងមួយដល់បាត, គឺគ្រោះថ្នាក់ណាស់!

ប្រភេទរឿងរ៉ាវនេះច្រើនណាស់, ច្រើនពេកមិនអាចរាប់បាន, ប៉ុន្តែគ្មានលេចឡើងគ្រោះថ្នាក់។ រឿងរ៉ាវប្រភេទនេះមិនជាក់លាក់សុទ្ធតែជួបប្រទះ, មនុស្សដោយឡែកពួកយើងនឹងជួបប្រទះប្រភេទរឿងរ៉ាវនេះ។ ជួបប្រទះក៏ដោយ, មិនជួបប្រទះក៏ដោយ, ធានាថាលោកអ្នកនឹងមិនលេចឡើងគ្រោះថ្នាក់ណាមួយ, ចំណុចមួយនេះខ្ញុំអាចធានា។ មានសិក្ខាកាមមួយចំនួន, គាត់មិនយោងតាមតម្រូវចិត្តចរិតដើម្បីធ្វើ, គ្រាន់តែហាត់ចលនាមិនបួសចិត្តចរិត, គាត់មិនអាចចាត់ថាមនុស្សហាត់គង់។

សម្តែងដល់លោកគ្រូផ្តល់ឲ្យអ្វីខ្លះ, ខ្ញុំគឺផ្តល់ឲ្យអ្នករាល់គ្នាអ្វីទាំងនេះ។ បរមីរបស់ខ្ញុំនឹងការពារលោកអ្នករហូតដល់លោកអ្នកអាចការពារខ្លួនឯងបានទើបឈប់, ពេលនោះលោកអ្នកបានដើរឆ្លងបួសហាត់ផុតពី

លោកីយ៍ធម៌រួចហើយ, លោកអ្នកបានត្រាស់ដឹងរួចហើយ។ ប៉ុន្តែលោកអ្នកចាំបាច់ចាត់ទុកលោកអ្នកខ្លួនឯងធ្វើជាមនុស្សប្អូសហាត់ពិតប្រាកដ, ទើបអាចធ្វើដល់ចំណុចមួយនេះ។ មានមនុស្សក្នុងដៃកាន់សៀវភៅរបស់ខ្ញុំ, នៅលើផ្លូវធំដើរផងស្រែកផង៖ មានលោកគ្រូលីការពារមិនខ្លាចទ្បានបុក។ នេះគឺបំផ្លាញមហាធម៌, នឹងមិនការពារមនុស្សប្រភេទនេះ, ភាពពិតសិស្សប្អូសពិតនឹងមិនធ្វើយ៉ាងនេះ។

## វាលថាមពល

ពួកយើងពេលហាត់គង់បរិវេណនឹងលេចឡើងវាលមួយ, វាលនេះជាវាលអ្វី? មានមនុស្សនិយាយថាជាវាលឈី, វាលចុម្ពិត, វាលអគ្គិសនី។ ភាពពិតលោកអ្នកហៅវាថាជាវាលអ្វីក៏មិនត្រូវ, ដោយសារសារធាតុដែលប្រភេទវាលនេះគ្របដណ្តប់គឺយ៉ាងបរិបូរណ៍បំផុត។ សារធាតុដែលផ្សំឡើងអវកាសទាំងអស់នៃចក្រវាលពួកយើង, ស្ទើរតែមាននៅក្នុងគង់នេះ, យើងខ្ញុំហៅវាថាវាលថាមពលសមស្របជាង, ដូច្នេះយើងខ្ញុំតាមធម្មតាបានហៅវាថាវាលថាមពល។

ដូច្នោះវាលនេះផ្តើមផលប៉ះពាល់អ្វី? អ្នករាល់គ្នាបានដឹង, មនុស្សប្អូសហាត់សុចរិតធម៌ពួកយើងនឹងមានប្រភេទអារម្មណ៍មួយយ៉ាងនេះ៖ ដោយសារគឺប្អូសហាត់សុចរិតធម៌, វាគឺសម្តែងមេត្តា, វាគឺសមកាលកម្មនឹងចរិតពិសេសសច្ចៈ-ករុណា-ខន្តីនៃចក្រវាល, ដូច្នេះសិក្ខាកាមពួកយើងអង្គុយនៅក្នុងវាលនេះសុទ្ធតែអាចទទួលដឹងបាន, ក្នុងមនោគតិគ្មានគំនិតអាក្រក់, លើសពីនេះទៀតសិក្ខាកាមរបស់ពួកយើងជាច្រើនអង្គុយនៅទីនេះសូម្បីតែជក់បារីក៏មិនគិតដល់, មានអារម្មណ៍ថាបរិយាកាសសន្តិភាពខ្លាំងណាស់, សុខស្រួលខ្លាំងណាស់, នេះជាក់ស្តែងជាប្រភេទថាមពលដែលអ្នកប្អូសសុចរិតធម៌យកតាម, នៅក្នុងវិសាលភាព

របស់វាលនេះផ្តើមផលប៉ះពាល់។ អនាគតបន្ទាប់ពីលោកអ្នករៀនចប់ថ្នាក់នេះតទៅ, មនុស្សភាគច្រើនពួកយើងសុទ្ធតែជាមានគង់, លេចឡើងគង់ពិតប្រាកដ, ដោយសារខ្ញុំបង្រៀនឲ្យលោកអ្នកគឺជាប្រការបួសហាត់សុចរិតធម៌, លោកអ្នកខ្លួនឯងក៏យោងតាមបរមាណើយចិត្តចរិតនេះដើម្បីតម្រូវខ្លួនឯង។ ស្របតាមលោកអ្នកបន្តបួសហាត់, យោងតាមតម្រូវចិត្តចរិតរបស់យើងខ្ញុំដើម្បីបួសហាត់, ថាមពលរបស់លោកអ្នកបន្តិចម្តងៗនឹងកាន់តែធំ។

យើងខ្ញុំសម្តែងប្រោសខ្លួនប្រោសមនុស្ស, ប្រោសសត្វលោកទាំងឡាយ, ដូច្នេះហ្វាលូនគាត់វិលចូលក្នុងប្រោសខ្លួនឯង, វិលចេញក្រៅប្រោសមនុស្ស។ ពេលវិលចេញក្រៅគាត់បញ្ចេញថាមពល, បណ្តាលឱ្យអ្នកដទៃទទួលបានអត្ថប្រយោជន៍, បែបនេះបន្តមក, មនុស្សដែលនៅខាងក្នុងតំបន់គ្របដណ្តប់នៃវាលថាមពលរបស់លោកអ្នកសុទ្ធតែនឹងទទួលបានអត្ថប្រយោជន៍, គាត់អាចមានអារម្មណ៍ដ៏សុខស្រួល។ មិនថាលោកអ្នកដើរតាមផ្លូវក៏ដោយ, នៅលើឡាន, នៅក្នុងផ្ទះសុទ្ធតែអាចផ្តើមផលប៉ះពាល់បែបនេះ។ មនុស្សដែលនៅខាងក្នុងវិសាលភាពវាលរបស់លោកអ្នកប្រហែលជាដោយអចេតនាលោកអ្នកបានកែសម្រួលរាងកាយឲ្យគាត់, ដោយសារប្រភេទវាលនេះអាចកែតម្រូវទាំងអស់ស្ថានភាពមិនត្រឹមត្រូវ។ រាងកាយមនុស្សគឺមិនគួរមានជំងឺ, មានជំងឺគឺស្ថិតក្នុងស្ថានភាពមិនត្រឹមត្រូវ, វាគឺអាចកែតម្រូវប្រភេទស្ថានភាពមិនត្រឹមត្រូវនេះ។ មនុស្សដែលមានមនោគតិអាក្រក់, ពេលដែលគិតដល់រឿងមិនត្រឹមត្រូវ, នៅក្រោមផលប៉ះពាល់ខ្លាំងក្លារបស់វាលលោកអ្នក, ក៏អាចផ្លាស់ប្រែមនោគតិរបស់គាត់, ពេលនោះគាត់ប្រហែលជាមិនគិតដល់រឿងអាក្រក់ទៀត។ អាចមានមនុស្សចង់ជេរគេ, ស្រាប់តែផ្លាស់ប្រែមនោគតិ, មិនចង់

ដេរទៀត។ មានតែវាលថាមពលនៃបួសហាត់សុចរិតធម៌, ទើបអាចផ្តើមផលប៉ះពាល់បែបនេះ។ ដូច្នេះក្នុងពុទ្ធសាសនានៅអតីតកាលមានប្រយោគមួយបែបនេះ, ហៅថា [ពន្លឺព្រះពុទ្ធចែងចាំង, សុជីវធម៌មូលភ្លឺថ្លា], ជាក់ស្តែងគឺជាអត្ថន័យនេះ។

## សិក្ខាកាមហ្វាលូនតាហ្វាបង្រៀនគង់ដូចម្តេច

ពួកយើងមានសិក្ខាកាមជាច្រើនបន្ទាប់ពីត្រឡប់ទៅវិញ, មានអារម្មណ៍ថាគង់ហ្វាដ៏ល្អ, ចង់បង្រៀនឲ្យសាច់ញាតិមិត្តភក្តិ។ អាចបាន, លោកអ្នកសុទ្ធតែអាចបង្រៀន, បង្រៀនឱ្យនរណាក៏បាន។ ប៉ុន្តែមានចំណុចមួយ, យើងខ្ញុំត្រូវការប្រកាសដល់អ្នករាល់គ្នា, យើងខ្ញុំផ្តល់ឱ្យអ្នករាល់គ្នាអ្វីច្រើនយ៉ាងនេះ, គឺមិនអាចប្រើគុណតម្លៃមកវាស់វែងបាន។ ហេតុអ្វីផ្តល់ឱ្យអ្នករាល់គ្នា? គឺទុកឱ្យលោកអ្នកបួសហាត់, មានតែបួសហាត់, ទើបអាចផ្តល់ឱ្យលោកអ្នកអ្វីទាំងនេះ, ដូច្នោះក៏មានន័យថា, អនាគតពេលដែលអ្នកទាំងអស់គ្នាបង្រៀនគង់, មិនអាចប្រើអ្វីទាំងនេះដើម្បីចំណង់កិត្តិនាមចំណង់ផលប្រយោជន៍, ដូច្នេះលោកអ្នកមិនអាចដូចខ្ញុំបែបនេះបើកថ្នាក់ដើម្បីប្រមូលថ្លៃសេវា។ ដោយសារយើងខ្ញុំត្រូវការបោះពុម្ពសៀវភៅ, បោះពុម្ពឯកសារ, ទៅគ្រប់ទីកន្លែងដើម្បីបង្រៀនគង់, ត្រូវការថ្លៃឈ្នួល។ យើងខ្ញុំប្រមូលថ្លៃសេវា, នៅទូទាំងប្រទេសគឺបានទាបបំផុតរួចហើយ, ហើយអ្វីដែលយើងខ្ញុំផ្តល់ឲ្យគឺច្រើនបំផុត, យើងខ្ញុំគឺពិតប្រាកដនាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់, ចំណុចនេះអ្នករាល់គ្នាខ្លួនឯងអាចយល់ដឹងបាន។ ធ្វើជាសិក្ខាកាមហ្វាលូនតាហ្វាម្នាក់, អនាគតលោកអ្នកចេញទៅបង្រៀនគង់, ចំពោះលោកអ្នកយើងខ្ញុំមានតម្រូវពីរ៖

តម្រូវទីមួយគឺមិនអាចប្រមូលថ្លៃសេវា។ យើងខ្ញុំផ្តល់ឱ្យលោកអ្នកអ្វីច្រើនយ៉ាងនេះ, មិនមែនទុកឲ្យលោកអ្នកមកមានទ្រព្យសម្បត្តិ, ចំណង់

កិត្តិនាម, គឺដើម្បីប្រោសលោកអ្នក, គឺដើម្បីទុកឱ្យលោកអ្នកបួសហាត់។ ប្រសិនលោកអ្នកប្រមូលថ្លៃសេវា, បរមីរបស់ខ្ញុំនឹងយកអ្វីបានផ្តល់ឱ្យលោកអ្នកទាំងអស់សុទ្ធតែដកហូតមកវិញ, ដូច្នោះលោកអ្នកក៏ជាក់ស្តែងមិនមែនមនុស្សរបស់ហ្វាលូនតាហ្វាយើងខ្ញុំទៀត, ដែលលោកអ្នកបង្រៀនក៏ជាក់ស្តែងមិនមែនជាហ្វាលូនតាហ្វារបស់យើងខ្ញុំ។ ពេលដែលអ្នកទាំងអស់គ្នាបង្រៀនគង់គឺមិនចំណង់កិត្តិនាមមិនចំណង់ផលប្រយោជន៍, កាតព្វកិច្ចដើម្បីបម្រើអ្នករាល់គ្នា។ សិក្ខាកាមរបស់ពួកយើងគ្រប់ទីកន្លែងទូទាំងប្រទេសសុទ្ធតែធ្វើបែបនេះ, សិក្ខាកាមជួយណែនាំគ្រប់ទីកន្លែងក៏សុទ្ធតែជាយកខ្លួនឯងធ្វើគំរូបែបនេះ។ មករៀនគង់របស់យើងខ្ញុំ, ដរាបណាលោកអ្នកចង់រៀន, ដូច្នោះលោកអ្នកគឺមករៀន, យើងខ្ញុំអាចទទួលខុសត្រូវចំពោះលោកអ្នក, មួយសេនក៏មិនយក។

តម្រូវទីពីរគឺមិនបានលាយឡំអ្វីរបស់ឯកជនចូលខាងក្នុងមហាធម៌។ នោះគឺនៅក្នុងដំណើរការបង្រៀនគង់, មិនថាភ្នែកទិព្វលោកអ្នកបើករួចហើយក៏ដោយ, លោកអ្នកមើលឃើញអ្វីក៏ដោយ, លេចឡើងបានសីលគង់អ្វីក៏ដោយ, លោកអ្នកមិនអាចប្រើកាលៈទេសៈនោះដែលលោកអ្នកមើលឃើញដើម្បីសម្តែងហ្វាលូនតាហ្វារបស់យើងខ្ញុំ។ រឿងបន្តិចនោះដែលលោកអ្នកមើលឃើញនៅលើជាន់ថ្នាក់នោះអាចខុសគ្នាឆ្ងាយណាស់, ខុសគ្នាសែនឆ្ងាយជាមួយអត្ថន័យពិតប្រាកដនៃធម៌ដែលយើងខ្ញុំសម្តែង។ ដូច្នេះពីពេលនេះតទៅលោកអ្នកក្នុងពេលបង្រៀនគង់, ដាច់ខាតយកចិត្តទុកដាក់រឿងរ៉ាវនេះ, បែបនេះទើបអាចធានាថាប្រការដើមរបស់ហ្វាលូនតាហ្វាយើងខ្ញុំមិនប្រែក្លាយ។

ក៏មិនអនុញ្ញាតតាមប្រភេទទម្រង់បង្រៀនគង់នេះរបស់ខ្ញុំ, មិនអនុញ្ញាតឱ្យជ្រើសយកទម្រង់របាយការណ៍ធំបែបនេះដូចខ្ញុំដើម្បីសម្តែងធម៌,

លោកអ្នកមិនអាចសម្តែងធម៌បាន។ ដោយសារអ្វីដែលខ្ញុំសម្តែង, អត្ថន័យគឺដ៏ស៊ីជម្រៅ, រួមបញ្ចូលគ្នានូវប្រការនៃជាន់ថ្នាក់ខ្ពស់ដើម្បីសម្តែង។ លោកអ្នកប្ញូសហាត់នៅជាន់ថ្នាក់ខុសគ្នា, អនាគតបន្ទាប់ពីលោកអ្នកលើកកម្ពស់, លោកអ្នកត្រឡប់ទៅស្តាប់ខ្សែអាត់នេះ, លោកអ្នកនឹងបន្តលើកកម្ពស់, លោកអ្នកបន្តស្តាប់, លោកអ្នកតែងតែនឹងមានការយល់ដឹងថ្មី, ការប្រមូលផលថ្មី, អានសៀវភៅកាន់តែបែបនេះ។ ពាក្យទាំងនេះរបស់ខ្ញុំគឺកំពុងរួមបញ្ចូលគ្នានូវប្រការដ៏ខ្ពស់ជ្រៅដើម្បីសម្តែង, ដូច្នេះលោកអ្នកមិនអាចសម្តែងធម៌នេះបាន។ ក៏មិនអនុញ្ញាតឱ្យលោកអ្នកប្រើពាក្យដើមរបស់ខ្ញុំសម្តែងក្លាយជាពាក្យរបស់លោកអ្នក, បើមិនដូច្នេះទេ, នោះគឺជាទង្វើលួចធម៌។ លោកអ្នកគ្រាន់តែអាចប្រើពាក្យដើមរបស់ខ្ញុំដើម្បីសម្តែង, បន្ថែមថាលោកគ្រូបានសម្តែងដូច្នោះ, ក្នុងសៀវភៅបានសរសេរដូច្នោះ, គ្រាន់តែអាចនិយាយបែបនេះ។ ហេតុអ្វី, ដោយសារលោកអ្នកនិយាយបែបនេះកាលណា, គឺមាននាំតាមអំណាចរបស់មហាធម៌ស្ថិតនៅ។ លោកអ្នកមិនអាចប្រើរឿងរ៉ាវដែលលោកអ្នកដឹងដើម្បីសម្តែងធ្វើដូចជាហ្វាលូនតាហ្វា, បើមិនដូច្នេះទេដែលលោកអ្នកសម្តែងជាក់ស្តែងមិនមែនជាហ្វាលូនតាហ្វា, លោកអ្នកស្មើនឹងបំផ្លាញហ្វាលូនតាហ្វារបស់យើងខ្ញុំ។ លោកអ្នកយោងតាមការគិតរបស់លោកអ្នក, យោងតាមមនោគតិរបស់លោកអ្នកដើម្បីសម្តែង, នោះមិនមែនជាធម៌, មិនអាចប្រោសមនុស្ស, ក៏មិនអាចផ្តើមផលប៉ះពាល់ណាមួយ, ដូច្នេះនរណាក៏មិនអាចសម្តែងធម៌នេះបាន។

វិធីសាស្ត្រដែលលោកអ្នកបង្រៀនគង់, នោះគឺនៅទីតាំងហាត់គង់, ឬក៏នៅលើវាលបង្រៀនគង់អាចចាក់ខ្សែអាត់, វីដេអូឲ្យសិក្ខាកាម, ក្រោយមកដោយសារសិក្ខាកាមជួយណែនាំបង្រៀនពួកគាត់ហាត់គង់។ អាច

យោងតាមទម្រង់វេទិកាផ្តោះប្តូរយោបល់, អ្នករាល់គ្នារៀនពីគ្នាទៅវិញទៅមក, និយាយគ្នាទៅវិញទៅមក, សម្តែងឱ្យគ្នាទៅវិញទៅមក, យើងខ្ញុំតម្រូវធ្វើបែបនេះ។ ក្នុងពេលដំណាលគ្នា, មិនបានហៅសិក្ខាកាម (សិស្ស) ដែលផ្សព្វផ្សាយហ្វាលូនតាហ្វាថាគ្រូ, គ្រូធំជាដើម, គ្រូមហាធម៌មានតែម្នាក់គត់។ ចូលរៀនមិនបែងចែកចូលមុនឬក្រោយសុទ្ធតែជាសិស្ស។

ពេលអ្នកទាំងអស់គ្នាបង្រៀនគង់, អាចមានមនុស្សគិតថា៖ លោកគ្រូអាចដំឡើងហ្វាលូន, អាចកែសម្រួលរាងកាយឱ្យមនុស្ស, ពួកយើងក៏ធ្វើមិនបាន។ កុំប្រញាប់, ខ្ញុំបានសម្តែងជាមួយអ្នករាល់គ្នារួចហើយ, ក្រោយខ្នងសិក្ខាកាមនីមួយៗសុទ្ធតែមានបរមីរបស់ខ្ញុំ, ក៏មិនគ្រាន់តែមួយ, ដូច្នេះបរមីរបស់ខ្ញុំនឹងធ្វើរឿងរ៉ាវទាំងនេះ។ ពេលដែលលោកអ្នកបង្រៀនគាត់, ប្រសិនគាត់មានវាសនា, ពេលនោះគឺអាចទទួលបានហ្វាលូន។ ប្រសិនវាសនាទាបបន្តិច, តាមរយៈកែសម្រួលរាងកាយ, បន្ទាប់ពីហាត់គង់បន្តិចម្តងៗក៏អាចទទួលបាន, បរមីរបស់ខ្ញុំគឺនឹងជួយគាត់ដើម្បីកែសម្រួលរាងកាយ។ មិនគ្រាន់តែទាំងនេះ, ខ្ញុំប្រាប់លោកអ្នក, អានសៀវភៅរបស់ខ្ញុំ, មើលវីដេអូរបស់ខ្ញុំ, ឬក៏ស្តាប់ខ្សែអាត់របស់ខ្ញុំដើម្បីរៀនធម៌រៀនគង់, ពិតប្រាកដមើលខ្លួនឯងជាមនុស្សហាត់គង់, ក៏ដូចគ្នានឹងទទួលបានប្រការទាំងនេះដែលគួរតែទទួលបាន។

យើងខ្ញុំក៏មិនអនុញ្ញាតឱ្យសិក្ខាកាមទៅព្យាបាលជំងឺឲ្យអ្នកដទៃ, សិក្ខាកាមហ្វាលូនតាហ្វាគឺដាច់ខាតហាមឃាត់ទៅព្យាបាលជំងឺឲ្យអ្នកដទៃ។ យើងខ្ញុំគឺបង្រៀនលោកអ្នកបួសឡើងលើ, មិនអនុញ្ញាតឱ្យលោកអ្នកផុសឡើងចិត្តប្រកាន់ណាមួយ, ក៏មិនអនុញ្ញាតឲ្យលោកអ្នកខ្លួនឯងធ្វើខូចខាតរាងកាយខ្លួនឯង។ វាលហាត់គង់របស់យើងខ្ញុំគឺល្អជាងវាលហាត់គង់របស់គង់ហ្វាដទៃណាមួយ, វាលនោះរបស់យើងខ្ញុំដរាបណា

លោកអ្នកទៅហាត់គង់, ខ្លាំងជាងច្រើនប្រៀបនឹងការព្យាបាលជំងឺរបស់លោកអ្នក។ បរមីរបស់ខ្ញុំអង្គុយជារង្វង់មូលមួយ, លើអាកាសនៃវាលហាត់គង់នៅមានគម្រប, ខាងលើមានហ្វាលូនធំ, បរមីធំនៅលើគម្រប មើល{ថែ}វាល។ វាលនោះមិនមែនវាលធម្មតា, មិនមែនវាលហាត់គង់ធម្មតាបែបនោះ, គឺជាវាលបួសហាត់។ ពួកយើងមានមនុស្សដ៏ច្រើនមានសីលគង់សុទ្ធតែធ្លាប់មើលឃើញវាលនេះរបស់ហ្វាលូនតាហ្វាយើងខ្ញុំ, គ្របដណ្ដប់ដោយពន្លឺក្រហម, ក្រហមទាំងស្រុង។

បរមីរបស់ខ្ញុំក៏អាចដំឡើងហ្វាលូនដោយផ្ទាល់, ប៉ុន្តែពួកយើងកុំបង្កើនចិត្តប្រកាន់។ ពេលដែលលោកអ្នកបង្រៀនគាត់ចលនា, គាត់និយាយថា៖ អ៊ុំាយយ៉ា, ខ្ញុំមានហ្វាលូនហើយ។ លោកអ្នកសន្មតថាគឺលោកអ្នកដំឡើង, នេះអាចមិនមែន។ ខ្ញុំនិយាយរឿងនេះជាមួយអ្នករាល់គ្នា, ជាក់ស្ដែងគឺកុំបង្កើនចិត្តប្រកាន់មួយនេះ, សុទ្ធតែជាបរមីរបស់ខ្ញុំកំពុងធ្វើ។ សិស្សហ្វាលូនតាហ្វារបស់យើងខ្ញុំជាក់ស្ដែងបង្រៀនគង់បែបនេះ។

នរណាចង់ផ្លាស់ប្ដូរគង់ហ្វាក្នុងហ្វាលូនតាហ្វា, គាត់ជាក់ស្ដែងគឺបំផ្លាញមហាធម៌, បំផ្លាញធម្មក្ខន្ធមួយនេះ។ មានមនុស្សយកគង់ហ្វាប្រែក្លាយទៅជាខព្យាង្គ, នេះគឺដាច់ខាតមិនអនុញ្ញាត។ វិធីសាស្ត្របួសហាត់ពិតប្រាកដសុទ្ធតែបានបន្សល់ទុកពីសម័យកាលបុរេប្រវត្តិ, គឺបន្សល់ទុកពីយុគ្គសម័យដ៏យូរអង្វែង, បួសហាត់ចេញអង្គមហាត្រាស់ដឹងច្រើនរាប់មិនអស់។ គ្មាននរណាហ៊ានប៉ះដល់សូម្បីតែបន្តិច, នេះក៏ជាសម័យកាលផុតធម៌របស់ពួកយើងទើបលេចឡើងរឿងរ៉ាវបែបនេះ។ នៅក្នុងប្រវត្តិសាស្ត្រមិនដែលមានរឿងរ៉ាវបែបនេះលេចឡើង, អ្នករាល់គ្នាដាច់ខាតយកចិត្តទុកដាក់ចំណុចមួយនេះ។

# មេសម្តែងទី៤

## បាត់និងបាន

នៅពិភពបួសហាត់ជាធម្មតានិយាយដល់ទំនាក់ទំនងបាត់និងបាន, ក្នុងមនុស្សសាមញ្ញក៏កំពុងនិយាយអំពីទំនាក់ទំនងបាត់និងបាន។ មនុស្សហាត់គង់ពួកយើងប្រព្រឹត្តបែបណាចំពោះការបាត់និងបាន? នេះនិងមនុស្សសាមញ្ញមិនដូចគ្នា, មនុស្សសាមញ្ញចង់ទទួលបានជាក់ស្តែងគឺជាប្រយោជន៍ឯកជន, ធ្វើបែបណារស់បានល្អ, រស់បានសុខស្រួល, ផ្ទុយមកវិញមនុស្សហាត់គង់ពួកយើងមិនមែនជាបែបនេះ, គាប់ជួនផ្ទុយស្រឡះ, ពួកយើងមិនចង់ស្វែងរករបស់ដែលមនុស្សសាមញ្ញចង់បាន, ហើយដែលពួកយើងទទួលបានម្តងទៀតមនុស្សសាមញ្ញចង់បានសុទ្ធតែទទួលមិនបាន, លុះត្រាតែបួសហាត់។

ជាទូទៅបាត់ដែលពួកយើងសំដៅលើ, ក៏មិនមែនបាត់នៅក្នុងវិសាលភាពដ៏តូច។ មានមនុស្សនិយាយដល់បាត់, គិតថា, តើមិនមែនធ្វើទានលុយទ្រព្យបន្តិច, ឃើញនរណាលំបាកតោកយ៉ាកជួយបន្តិច, ឃើញអ្នកសុំទានលើផ្លូវឱ្យបន្តិច។ នេះក៏ជាប្រភេទលះបង់មួយ, ក៏ជាប្រភេទបាត់មួយ, ប៉ុន្តែនៅលើបញ្ហានេះគ្រាន់តែមើលស្រាលបន្តិចចំពោះមាសលុយឬសម្ភារៈប៉ុណ្ណោះ។ លះបង់ចំពោះទ្រព្យសម្បត្តិ, ប្រាកដណាស់វាក៏ជាទិដ្ឋភាពមួយ, ក៏ជាទិដ្ឋភាពមួយដែលចម្បងបង្គួរ។ ប៉ុន្តែបាត់ដែលយើងខ្ញុំសម្តែងមិនមែនវិសាលភាពតូចយ៉ាងនេះ, មនុស្សពួកយើងនៅក្នុងដំណើរការបួសហាត់, ធ្វើជាមនុស្សហាត់គង់ម្នាក់ចិត្តដែលត្រូវលះបង់ច្រើនខ្លាំងណាស់, ចិត្តបង្ហាញ, ចិត្តច្រណែន, ចិត្តប្រជែងប្រយុទ្ធ, ចិត្តត្រេកអរ, ចិត្តប្រកាន់គ្រប់ប្រភេទដ៏ច្រើនៗសុទ្ធតែត្រូវកម្ចាត់វាចោល។

បាត់ដែលយើងខ្ញុំសម្ដែងគឺក្នុងន័យទូលាយ, នៅក្នុងដំណើរការបួសហាត់ទាំងមូល, គួរតែបាត់ទៅការប្រកាន់, តណ្ហាគ្រប់ប្រភេទទាំងអស់របស់មនុស្សសាមញ្ញ។

អាចមានមនុស្សគិតថា, ពួកយើងគឺបួសហាត់នៅក្នុងមនុស្សសាមញ្ញ, សុទ្ធតែបាត់ទៅនេះមិនដូចគ្នានឹងព្រះសង្ឃហើយឬ? មិនដូចគ្នានឹងសាមណីហើយឬ? សុទ្ធតែបាត់ទៅ, ហាក់ដូចជាធ្វើមិនបាន។ ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំ, ផ្នែកបួសហាត់នៅក្នុងមនុស្សសាមញ្ញ, តម្រូវគឺបួសហាត់នៅក្នុងសង្គមមនុស្សសាមញ្ញ, រក្សាអតិបរមាដូចគ្នានឹងមនុស្សសាមញ្ញ, មិនមែនទុកឱ្យលោកអ្នកពិតប្រាកដបាត់ទៅរបស់អ្វីនៅលើផលប្រយោជន៍សម្ភារៈ។ មិនក្រែងលោកអ្នកធ្វើមន្ត្រីធំដល់ណា, មិនក្រែងលោកអ្នកមានទ្រព្យច្រើនប៉ុណ្ណា, គន្លឹះគឺលោកអ្នកអាចដាក់ចិត្តនោះចុះបានឬអត់។

ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំជាក់ស្ដែងគឺចង្អុលផ្ទាល់ចិត្តមនុស្ស, នៅលើផលប្រយោជន៍ឯកជន, នៅក្នុងទំនាស់រវាងមនុស្សនិងមនុស្ស, អាចមើលឲ្យស្រាលបញ្ហាទាំងនេះបានឬអត់, នេះគឺជាបញ្ហាគន្លឹះ។ បួសហាត់ក្នុងវត្តនិងនៅក្នុងភ្នំជ្រៅព្រៃចាស់, គឺទុកឱ្យលោកអ្នកកាត់ផ្ដាច់ទាំងស្រុងនឹងសង្គមមនុស្សសាមញ្ញ, បង្ខំឱ្យលោកអ្នកបាត់ទៅចិត្តនេះក្នុងមនុស្សសាមញ្ញ, មិនទុកឱ្យលោកអ្នកទទួលបានខាងផលប្រយោជន៍សម្ភារៈ, ដោយហេតុនេះធ្វើឱ្យលោកអ្នកបាត់។ មនុស្សបួសហាត់នៅក្នុងមនុស្សសាមញ្ញមិនដើរបែបនេះ, តម្រូវគឺនៅក្នុងស្ថានភាពរស់នៅនេះរបស់មនុស្សសាមញ្ញធ្វើដូចម្ដេចមើលវាឱ្យស្រាល, ប្រាកដណាស់នេះដ៏ពិបាក, នេះក៏ជាប្រការគន្លឹះបំផុតក្នុងធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំ។ ដូច្នេះបាត់ដែលយើងខ្ញុំសម្ដែងជាក់ស្ដែងគឺក្នុងន័យទូលាយ, មិនមែនក្នុង

ន័យដ៏ចង្អៀត។ ពួកយើងសម្តែងអំពីធ្វើរឿងល្អ, ធ្វើទានលុយទ្រព្យបន្តិច, លោកអ្នកឃើញអ្នកសុំទានតាមផ្លូវសព្វថ្ងៃ, មានមួយចំនួនគឺសុំទានជំនាញ, គាត់មានលុយទាំងច្រើនជាងលោកអ្នក។ ពួកយើងត្រូវសម្លឹងមើលកន្លែងធំ, មិនមែនសម្លឹងមើលកន្លែងតូច។ បួសហាត់, គួរតែសម្លឹងមើលកន្លែងធំបួសហាត់ដោយស្មោះត្រង់និងថ្លៃថ្នូរ។ ពួកយើងនៅក្នុងដំណើរការបាត់, ដែលពួកយើងពិតប្រាកដបាត់ទៅជាក់ស្តែងគឺប្រភេទរបស់មិនល្អទាំងនោះ។

មនុស្សជាញឹកញាប់សន្មតថាអ្វីដែលខ្លួនឯងស្វែងរកសុទ្ធតែជាល្អ, ភាពពិតសង្កេតមើលនៅលើជាន់ថ្នាក់ខ្ពស់, សុទ្ធតែជាដើម្បីបំពេញនូវអត្ថប្រយោជន៍បន្តិចនោះដែលទទួលបាននៅក្នុងមនុស្សសាមញ្ញ។ ក្នុងសាសនាសម្តែង៖ លុយលោកអ្នកច្រើនដល់ណា, ធ្វើមន្ត្រីធំដល់ណាក៏គ្រាន់តែប៉ុន្មានសិបឆ្នាំ, កើតនាំមកមិនបាន, ស្លាប់នាំទៅមិនបាន។ គង់នេះហេតុអ្វីដ៏មានតម្លៃយ៉ាងនេះ? ជាក់ស្តែងគឺដោយសារវាបង្កើនដោយផ្ទាល់នៅលើខ្លួនវិញ្ញាណដើមរបស់លោកអ្នក, កើតនាំតាមមក, ស្លាប់នាំយកទៅ, លើសពីនេះវាដោយផ្ទាល់កំណត់ផលញាណរបស់លោកអ្នក, ដូច្នេះគឺមិនងាយស្រួលក្នុងការបួស។ ក៏មានន័យថា, ដែលលោកអ្នកលះចោលគឺរបស់មិនល្អ, បែបនេះទើបអាចធ្វើឱ្យលោកអ្នកត្រឡប់ដើមមកសច្ចៈ។ ដែលទទួលបាននោះជាអ្វី? នោះគឺលើកកម្ពស់ជាន់ថ្នាក់, ចុងក្រោយសម្រេចមគ្គផល, ជោគជ័យសម្រេចបរិបូរ, ដោះស្រាយបានបញ្ហាមូលដ្ឋាន។ ជាការពិត, ពួកយើងចង់បាត់ទៅតណ្ហាគ្រប់ប្រភេទរបស់មនុស្សសាមញ្ញ, អាចសម្រេចបានបរមាណីយរបស់មនុស្សបួសហាត់ពិតប្រាកដម្នាក់, ភ្លាមៗចង់ធ្វើបានចំណុចមួយនេះក៏មិនងាយស្រួល, ត្រូវតែសន្សឹមៗដើម្បីធ្វើ។ ខ្ញុំនិយាយថាសន្សឹមៗដើម្បីធ្វើលោក

អ្នកស្ដាប់ឮរួចហើយ, លោកអ្នកនិយាយថាលោកគ្រូប្រាប់សន្សឹមៗដើម្បីធ្វើ, នោះគឺសន្សឹមៗដើម្បីធ្វើ។ ដូច្នេះអាចមិនបាន! លោកអ្នកត្រូវតែមានបរមាណីយតឹងរឹងចំពោះខ្លួនឯង, ប៉ុន្តែយើងខ្ញុំអនុញ្ញាតឱ្យលោកអ្នកសន្សឹមៗលើកកម្ពស់។ លោកអ្នកថ្ងៃនេះធ្វើបានភ្លាម, ថ្ងៃនេះលោកអ្នកជាក់ស្ដែងគឺជាព្រះពុទ្ធ, ដូច្នេះក៏មិនតថភាព, លោកអ្នកសន្សឹមៗនឹងធ្វើបានចំណុចមួយនេះ។

ដែលពួកយើងបាត់ទៅធាតុពិតគឺជាអ្វីមិនល្អ, ជាអ្វី? នោះគឺអំណាចកម្ម, វានិងចិត្តមនុស្សគ្រប់ប្រភេទគឺបំពេញគ្នាទៅវិញទៅមក។ ឧបមាថាមនុស្សសាមញ្ញពួកយើងមានចិត្តមិនល្អគ្រប់ប្រភេទ, ដើម្បីផលប្រយោជន៍ឯកជន, បានធ្វើរឿងរ៉ាវមិនល្អគ្រប់ប្រភេទ, នឹងទទួលបានប្រភេទសារធាតុពណ៌ខ្មៅនេះ—អំណាចកម្ម។ នេះនិងចិត្តពួកយើងខ្លួនឯងគឺមានទំនាក់ទំនងដោយផ្ទាល់, ប្រសិនចង់កម្ចាត់ចោលអ្វីមិនល្អទាំងនេះ, ដំបូងត្រូវតែបង្វែរចិត្តមួយនេះរបស់លោកអ្នកមកវិញ។

## បំប្លែងអំណាចកម្ម

រវាងសារធាតុពណ៌សនិងសារធាតុពណ៌ខ្មៅមានដំណើរការបំប្លែងមួយ។ រវាងមនុស្សនិងមនុស្សបន្ទាប់ពីកើតឡើងទំនាស់, វាមានដំណើរការបំប្លែងមួយ។ ធ្វើរឿងល្អទទួលបានសារធាតុពណ៌ស—គុណធម៌; ធ្វើរឿងអាក្រក់ទទួលបានសារធាតុពណ៌ខ្មៅ—អំណាចកម្ម។ នៅមានដំណើរការស្នងចម្លងមួយ, មនុស្សខ្លះសម្ដែងតើមិនមែនពាក់កណ្ដាលដំបូងនៃជីវិតបានធ្វើរឿងរ៉ាវមិនល្អ? ក៏មិនជាក់លាក់សុទ្ធតែជាបែបនេះ, ដោយសារអំណាចកម្មទាំងនេះដែលមនុស្សសន្សំមកមិនមែនក្នុងតែមួយជីវិតមួយជាតិ។ ពិភពបួសហាត់សម្ដែងវិញ្ញាណដើមអមតៈ។ ប្រសិនវិញ្ញាណដើមអមតៈ, នោះគាត់អាចជាមានសកម្មភាពសង្គមជាតិមុន

របស់គាត់, ដូច្នោះគាត់នៅក្នុងសកម្មភាពជាតិមុនអាចធ្លាប់ជំពាក់នរណា, ធ្លាប់សម្លុតនរណា, ឬក៏ធ្លាប់ធ្វើរឿងមិនល្អផ្សេងៗ, ធ្លាប់សម្លាប់ជីវិតជាដើម, ដូច្នោះគឺនឹងបង្កជាប្រភេទអំណាចកម្មនេះ, អ្វីទាំងនេះនៅក្នុងអវកាសផ្សេងវានឹងសន្សំទុកមក, រមែងនាំតាម, សារធាតុពណ៌សក៏ជាបែបនេះ, មិនត្រឹមតែប្រភេទប្រភពមួយនេះ។ នៅមានប្រភេទកាលៈទេសៈមួយទៀត, ក្នុងវង្សត្រកូល, បុព្វបុរសក៏អាចសន្សំទុកមក។ អតីតកាលមនុស្សចាស់សម្តែងប្រយោគមួយបែបនេះ៖ សន្សំគុណធម៌ៗ, បុព្វបុរសសន្សំគុណធម៌; ឯកជននេះកំពុងបាត់គុណធម៌, កំពុងខាតគុណធម៌។ ពាក្យនោះសម្តែងត្រូវខ្លាំងណាស់។ មនុស្សសាមញ្ញបច្ចុប្បន្នបានស្តាប់មិនចូលប្រយោគនេះរួចហើយ, លោកអ្នកសម្តែងជាមួយយុវជនទាំងនោះ, និយាយថាបាត់គុណធម៌ខ្វះគុណធម៌, គាត់ជាមូលដ្ឋានមិនដាក់ក្នុងចិត្ត។ ភាពពិតអត្ថន័យរបស់វាមែនទែនគឺដ៏ជ្រៅ, វាមិនគ្រាន់តែជាបរមាណើយមនោគតិនិងស្មារតីរបស់មនុស្សសម័យទំនើបប៉ុណ្ណោះ, តែជាអត្ថិភាពសារធាតុពិតប្រាកដ, រាងកាយរបស់មនុស្សពួកយើងសុទ្ធតែមានប្រភេទសារធាតុពីរនេះ។

មានមនុស្សសម្តែង៖ តើបន្ទាប់ពីសារធាតុពណ៌ខ្មៅច្រើនឡើង, គឺមិនអាចបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់? អាចនិយាយយ៉ាងនេះ, មនុស្សសារធាតុពណ៌ខ្មៅច្រើន, វាឥទ្ធិពលលើចរិតភ្ញាក់ដឹង។ ដោយសារវាបង្កើតជាវាលមួយនៅបរិវេណរាងកាយរបស់លោកអ្នក, គាប់ជួនស្រោបព័ទ្ធលោកអ្នកនៅខាងក្នុង, កាត់ផ្តាច់ជាមួយចរិតពិសេសសច្ចៈ-ករុណា-ខន្តីនៃចក្រវាល, ដូច្នេះចរិតភ្ញាក់ដឹងរបស់មនុស្សប្រភេទនេះអាចនឹងទាប។ គេសម្តែងអំពីបួសហាត់, ឈីគង់, គាត់ទាំងស្រុងចាត់ថាជាអបិយជំនឿ, ជាមូលដ្ឋានគឺមិនជឿ, គាត់មានអារម្មណ៍ថាគួរឲ្យសើច។

ជាញឹកញាប់គឺជាបែបនេះ, ប៉ុន្តែមិនជាដាច់ខាត។ តើឯកជននេះចង់បួសហាត់គឺដ៏ពិបាក, គឺមិនអាចបង្កើនគង់ឡើងខ្ពស់? ក៏មិនត្រូវ, យើងខ្ញុំសម្តែងមហាធម៌គ្មានដែន, ទាំងស្រុងពឹងផ្អែកលើចិត្តនេះរបស់លោកអ្នកទៅបួស។ គ្រូនាំចូលខ្លោងទ្វារ, បួសហាត់នៅឯកជន, ទាំងស្រុងមើលលោកអ្នកទៅបួសដូចម្តេច។ អាចឬមិនអាចបួស, ទាំងស្រុងមើលលោកអ្នកខ្លួនឯងអាចឬមិនអាចស៊ូទ្រាំ, អាចឬមិនអាចបង់ចំណាយ, អាចឬមិនអាចរងទុក្ខ។ ប្រសិនអាចប្តេជ្ញាចិត្តដ៏ក្លៀវក្លា, ឧបសគ្គណាក៏រារាំងមិនបាន, ខ្ញុំនិយាយថានោះគឺគ្មានបញ្ហា។

មនុស្សសារធាតុពណ៌ខ្មៅច្រើន, ជាញឹកញាប់ត្រូវបង់ចំណាយច្រើនជាងមនុស្សដែលសារធាតុពណ៌សច្រើន។ ដោយសារសារធាតុពណ៌សដោយផ្ទាល់សមកាលកម្មនឹងចរិតពិសេសសច្ចៈ-ករុណា-ខន្តីនៃចក្រវាល, ដូច្នេះដរាបណាចិត្តចរិតរបស់គាត់លើកកម្ពស់ឡើង, អាចនៅក្នុងទំនាស់លើកកម្ពស់ខ្លួនឯង, នោះគាត់គឺបង្កើនគង់, គឺឆាប់រហ័សយ៉ាងនេះ។ មនុស្សគុណធម៌ច្រើនចរិតភ្ញាក់ដឹងខ្ពស់, ក៏អាចរងទុក្ខ, ពលកម្មនៃសរសៃពួរឆ្អឹង, ទុក្ខនៃចិត្តឆន្ទៈ, បើទោះបីទទួលរងច្រើនបន្តិចខាងទិដ្ឋភាពរាងកាយ, ទទួលរងតិចជាងនៅលើស្មារតី, សុទ្ធតែអាចបង្កើនគង់បាន។ មនុស្សដែលសារធាតុពណ៌ខ្មៅច្រើនគឺមិនបាន, ចាំបាច់ត្រូវតែឆ្លងកាត់ដំណើរការមួយបែបនេះជាមុន៖ ដំបូងត្រូវតែបំប្លែងសារធាតុពណ៌ខ្មៅក្លាយជាសារធាតុពណ៌ស, នោះគឺជាដំណើរការមួយបែបនេះ, ក៏ជាយ៉ាងឈឺចាប់បំផុតផងដែរ។ ដូច្នេះជាញឹកញាប់មនុស្សដែលចរិតភ្ញាក់ដឹងមិនល្អនឹងរងទុក្ខច្រើន, អំណាចកម្មធំចរិតភ្ញាក់ដឹងទាប, គាត់គឺកាន់តែមិនងាយបួសហាត់។

លើកឧទាហរណ៍ពិស្តារមួយ, លោកអ្នកមើលគាត់បួសហាត់ដូច

ម្ដេច។ ក្នុងពេលសមាធិបួសហាត់តម្រូវបត់ស្មើជើងរយៈពេលយូរ, ពេលបត់ស្មើជើងឈឺផងពិបាកទ្រាំផង, ពេលវេលាយូរ, ចាប់ផ្ដើមជ្រួលចិត្ត, ជ្រួលខ្លាំងសាហាវណាស់។ ពលកម្មនៃសរសៃពួរឆ្អឹង, ទុក្ខនៃចិត្តឆន្ទៈ, រាងកាយមិនសុខស្រួល, ចិត្តក៏មិនសុខស្រួល។ មានមនុស្សមួយចំនួនបត់ស្មើជើងខ្លាចឈឺ, ដាក់ចុះមកវិញ, មិនចង់ព្យាយាម។ មានមនុស្សមួយចំនួនបត់ស្មើជើងពេលវេលាយូរបន្តិច, គឺទ្រាំមិនបាន។ ដាក់ជើងចុះមកភ្លាម, ហាត់ឥតប្រយោជន៍។ បត់ស្មើជើងឈឺកាលណា, ប្រញាប់ធ្វើសកម្មភាពចប់រួចហើយបត់ស្មើជើងបន្តទៀត, យើងខ្ញុំឃើញថានេះគឺគ្មានប្រសិទ្ធភាព។ ដោយសារពេលជើងគាត់ឈឺ, យើងខ្ញុំមើលឃើញសារធាតុពណ៌ខ្មៅកំពុងវាយលុកលើជើងរបស់គាត់។ សារធាតុពណ៌ខ្មៅជាក់ស្ដែងគឺជាអំណាចកម្ម, រងទុក្ខគឺអាចរំលាយកម្ម, ហេតុនេះបំប្លែងក្លាយជាគុណធម៌។ ឈឺកាលណាអំណាចកម្មនោះគឺចាប់ផ្ដើមរំលាយចុះ, អំណាចកម្មកាន់តែដាក់សម្ពាធចុះ, ជើងគាត់ឈឺកាន់តែខ្លាំងសាហាវ, ដូច្នេះជើងគាត់ឈឺមិនមែនគ្មានហេតុផល។ ជាញឹកញាប់មនុស្សអង្គុយសមាធិជើងចុកគឺឈឺតាមហ៊ុក, ឈឺមួយហ៊ុក, ពិបាកទ្រាំពិសេស, ឆ្លងផុតរួចក៏ឃើតៗមកម្ដងទៀត, បន្ទាប់ពីមួយរយៈក៏ចាប់ផ្ដើមឈឺឡើងវិញ, ជាញឹកញាប់គឺជាបែបនេះ។

ដោយសារអំណាចកម្មគឺរំលាយតាមមួយដុំៗ, រំលាយបាត់មួយដុំជើងគឺល្អជាងបន្តិច, មួយរយៈឡើងមកមួយដុំទៀត, ហើយចាប់ផ្ដើមឈឺម្ដងទៀត។ បន្ទាប់ពីសារធាតុពណ៌ខ្មៅរំលាយបាត់រួចហើយ, មិនមែនជាបាត់បង់, សារធាតុនេះក៏ជាអមតៈ, បន្ទាប់ពីរំលាយបាត់ដោយផ្ទាល់បំប្លែងក្លាយជាសារធាតុពណ៌ស, សារធាតុពណ៌សនេះជាក់ស្ដែងគឺជាគុណធម៌។ ហេតុអ្វីវាអាចបំប្លែងបែបនេះ? ដោយសារគាត់បានរងទុក្ខ,

គាត់ខ្លួនឯងបានបង់ចំណាយ, គាត់បានទទួលរងការឈឺចាប់រួចហើយ។ យើងខ្ញុំសម្តែង, គុណធម៌នោះគឺខ្លួនឯងបានទទួលរងឈឺចាប់, បានរងទុក្ខ, បានធ្វើរឿងល្អរួចហើយទទួលបាន, ដូច្នេះក្នុងពេលអង្គុយសមាធិនឹងលេចឡើងបញ្ហានេះ។ មនុស្សខ្លះពេលជើងឈឺបន្តិច, លោតឈរឡើង, ធ្វើសកម្មភាពៗម្តងទៀតបត់ស្មើជើង, ជាមូលដ្ឋានមិនផ្តើមផលប៉ះពាល់។ មានមនុស្សឈរបង្គោល, ដៃលើកឡើងរោយ, ទ្រាំមិនបាន, ដាក់ចុះមកវិញ, ជាមូលដ្ឋានមិនផ្តើមផលប៉ះពាល់។ ទុក្ខបន្តិចនេះចាត់ថាអ្វី? ខ្ញុំនិយាយថាមនុស្សហាត់គង់លើកដៃបែបនេះគឺអាចបួសសម្រេច, នោះសុទ្ធសាធងាយស្រួលពេកហើយ។ នេះជាកាលៈទេសៈដែលមនុស្សគ្រប់គ្នាបួសហាត់លេចឡើងក្នុងពេលអង្គុយសមាធិ។

ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំចម្បងក៏មិនមែនដើរបែបនេះ, ប៉ុន្តែក៏មានផ្នែកមួយផ្តើមផលប៉ះពាល់តាមទិដ្ឋភាពនេះ។ ពួកយើងភាគច្រើនគឺក្នុងពេលកកិតចិត្តចរិតរវាងមនុស្សនិងមនុស្សដើម្បីបំប្លែងអំណាចកម្ម, ជាញឹកញាប់បង្ហាញនៅក្នុងចំណោមនេះ។ មនុស្សក្នុងពេលទំនាស់, ក្នុងពេលកកិតរវាងមនុស្សនិងមនុស្សសូម្បីតែលើសហួសទាំងទុក្ខឈឺចាប់ប្រភេទនោះ។ ខ្ញុំនិយាយថាទុក្ខឈឺចាប់លើរាងកាយងាយស្រួលស៊ូទ្រាំបំផុត, ខាំៗធ្មេញគឺឆ្លងផុតបាន។ ពេលដែលកម្ចាត់គ្នារវាងមនុស្សនិងមនុស្ស, ចិត្តនោះគឺពិបាករក្សាជាប់បំផុត។

លើកឧទាហរណ៍, មានមនុស្សយ៉ាងនេះ, ទៅធ្វើការស្តាប់ឮពីរនាក់និយាយពាក្យអាក្រក់ពីគាត់, និយាយដ៏ពិបាកស្តាប់, ខឹងគឺដល់ថ្នាក់ទ្រាំមិនបាន។ ប៉ុន្តែយើងខ្ញុំសម្តែងរួចហើយ, ធ្វើជាមនុស្សហាត់គង់ម្នាក់, គឺត្រូវតែធ្វើបានវាយមិនសងដៃ, ជេរមិនតមាត់, ប្រើបរមាណីយខ្ពស់តម្រូវខ្លួនឯង។ គាត់បានគិតថា៖ លោកគ្រូបានប្រាប់រួចហើយ, មនុស្សហាត់

គង់ពួកយើងមិនដូចនឹងគេ, ត្រូវតែកម្រិតមារយាទខ្ពស់។ គាត់គ្មានឈ្លោះប្រកែកនឹងអ្នកទាំងពីរនោះ។ ប៉ុន្តែជាញឹកញាប់ពេលដែលទំនាស់មក, មិនរំញោចដល់សតិអារម្មណ៍របស់មនុស្សទេ, មិនចាត់ថាអ្វី, មិនប្រសិទ្ធភាព, សម្រេចមិនបានការលើកកម្ពស់។ ដូច្នេះក្នុងចិត្តដាក់ចុះមិនបាន, នឹងរំខានចិត្ត, អាចនឹងលេចឡើងទាក់ទាញចិត្តមនុស្ស, តែងតែចង់វិលក្បាលមកមើលសាកមើលរូបភាពដែលអ្នកទាំងពីរនោះនិយាយអាក្រក់អំពីគាត់។ វិលក្បាលសម្លឹងកាលណា, ទឹកមុខអ្នកទាំងពីរនោះបង្ហាញយ៉ាងកាចសាហាវ, ចំពេលនិយាយបែកធ្លាភ្លើងបំផុត, គាត់ភ្លាមៗគឺទ្រាំមិនបាន, ភ្លើងគឺបញ្ឆេះឡើង, អាចជាបន្ទាន់ឈ្លោះប្រកែកជាមួយគេ។ ពេលដែលកើតឡើងទំនាស់រវាងមនុស្សនិងមនុស្ស, ចិត្តនោះពិបាកឃាត់ជាប់ណាស់។ ខ្ញុំនិយាយថាសុទ្ធតែឆ្លងកាត់ក្នុងពេលអង្គុយសមាធិ, នោះនៅតែងាយស្រួល, ប៉ុន្តែនឹងមិនរមែងបែបនេះ។

ដូច្នេះពីពេលនេះតទៅក្នុងពេលហាត់គង់, លោកអ្នកនឹងជួបប្រទះសព្វបែបយ៉ាងគ្រោះលំបាក។ គ្មានគ្រោះលំបាកទាំងនេះលោកអ្នកបួសដូចម្តេច? អ្នករាល់គ្នាសុទ្ធតែជាអ្នកល្អខ្ញុំក៏ល្អ, គ្មានជម្លោះខាងផលប្រយោជន៍, គ្មានជ្រៀតជ្រែករបស់ចិត្តមនុស្ស, តើលោកអ្នកអង្គុយនៅទីនោះចិត្តចរិតគឺលើកកម្ពស់ឡើងបាន? នោះគឺមិនបាន។ មនុស្សត្រូវតែនៅក្នុងភាពអនុវត្តជាក់ស្តែងពិតប្រាកដដើម្បីហាត់ពត់ខ្លួនឯងទើបអាចលើកកម្ពស់ឡើងបាន។ មានមនុស្សនិយាយ៖ ពួកយើងហាត់គង់ហេតុម្តេចតែងតែជួបប្រទះរឿងរំខាន? មិនខុសគ្នាប៉ុន្មាននឹងរឿងរំខានក្នុងមនុស្សសាមញ្ញ។ ដោយសារលោកអ្នកគឺបួសហាត់នៅក្នុងមនុស្សសាមញ្ញ, គាត់នឹងមិនស្រាប់តែទុកឱ្យលោកអ្នកដាក់ក្បាលចុះក្រោម, អណ្តែតឡើងព្យួរនៅទីនោះ, ទុកឱ្យលោកអ្នកឡើងលើមេឃរងទុក្ខបន្តិច,

វាមិនអាចដូចនោះទេ។ សុទ្ធតែជាស្ថានភាពក្នុងមនុស្សសាមញ្ញ, ថ្ងៃនេះនរណារករឿងលោកអ្នក, នរណារករឿងធ្វើលោកអ្នកខឹង, នរណាប្រព្រឹត្តមិនល្អចំពោះលោកអ្នក, ស្រាប់តែបញ្ចេញពាក្យមិនគួរសមចំពោះលោកអ្នក, គឺមើលលោកអ្នកប្រព្រឹត្តដូចម្ដេចចំពោះបញ្ហាទាំងនេះ។

ហេតុអ្វីជួបប្រទះបញ្ហាទាំងនេះ? សុទ្ធតែជាអំណាចកម្មដែលលោកអ្នកជំពាក់បង្កឡើង, យើងខ្ញុំបានរំលាយចោលឱ្យលោកអ្នកចំណែកច្រើនរាប់មិនអស់រួចហើយ។ នៅសល់តែបន្តិចយ៉ាងនោះបែងចែកនៅក្នុងបណ្ដាជាន់ថ្នាក់, ដើម្បីលើកកម្ពស់ចិត្តចរិតរបស់លោកអ្នក, រៀបចំគ្រោះលំបាកមួយចំនួនដើម្បីហាត់ពត់ចិត្តមនុស្ស, កម្ចាត់ចិត្តប្រកាន់គ្រប់ប្រភេទ។ នេះសុទ្ធតែជាគ្រោះរបស់លោកអ្នកខ្លួនឯង, យើងខ្ញុំដើម្បីលើកកម្ពស់ចិត្តចរិតរបស់លោកអ្នកហើយកេងប្រវ័ញ្ចវា, សុទ្ធតែអាចទុកឱ្យលោកអ្នកឆ្លងបាន។ ដរាបណាលោកអ្នកលើកកម្ពស់ចិត្តចរិត, គឺអាចឆ្លងបាន, គឺខ្លាចតែលោកអ្នកខ្លួនឯងមិនចង់ឆ្លង, ចង់ឆ្លងគឺអាចឆ្លងបាន។ ដូច្នេះពីពេលនេះតទៅពេលដែលជួបប្រទះទំនាស់, លោកអ្នកមិនបានមើលវាជាការចៃដន្យ។ ដោយសារពេលដែលទំនាស់សាងបង្កើត, នឹងស្រាប់តែលេចឡើង, ប៉ុន្តែផ្ទុយមកវិញមិនមែនស្ថិតនៅដោយចៃដន្យ, នោះគឺដើម្បីលើកកម្ពស់ចិត្តចរិតលោកអ្នក។ លោកអ្នកដរាបណាចាត់ទុកលោកអ្នកធ្វើជាមនុស្សហាត់គង់, លោកអ្នកគឺអាចដោះស្រាយវាបានល្អ។

ប្រាកដណាស់, មុនពេលគ្រោះ, ទំនាស់មកនឹងមិនប្រាប់លោកអ្នក, សុទ្ធតែប្រាប់លោកអ្នក, លោកអ្នកនៅបួសហាត់អ្វីទៀត? វាក៏មិនផ្ដើមផលប៉ះពាល់។ វាជាញឹកញាប់ស្រាប់តែលេចឡើង, ទើបអាចត្រួតពិនិត្យចិត្តចរិតរបស់មនុស្ស, ទើបអាចធ្វើឱ្យចិត្តចរិតមនុស្សសម្រេចបានលើក

កម្ពស់ពិតប្រាកដ, មើលថាតើអាចឃាត់ជាប់ចិត្តចរិតឬអត់, នេះទើបអាចមើលចេញបាន, ដូច្នេះទំនាស់មកមិនមែនស្ថិតនៅដោយចៃដន្យ។ នៅក្នុងដំណើរការបួសហាត់ទាំងមូល, នៅពេលអំណាចកម្មបំប្លែងគឺនឹងលេចឡើងបញ្ហានេះ, វាពិបាកជាងពលកម្មនៃសរសៃពួរឆ្អឹងដែលមនុស្សធម្មតាពួកយើងនឹកស្មាន។ លោកអ្នកហាត់ៗគង់, ហាត់ច្រើនជាងបន្តិច, ដៃលើកឡើងរោយ, ឬក៏ជើងឈរឡើងអស់កំលាំង, នេះគឺបង្កើនគង់, តើលោកអ្នកហាត់ច្រើនថែមពីរបីម៉ោងគឺអាចបង្កើនគង់? នោះគ្រាន់តែផ្ដើមផលប៉ះពាល់ក្នុងការបំប្លែងរាងកាយ, តែនៅត្រូវការថាមពលដើម្បីពង្រឹង, វាមិនផ្ដើមផលប៉ះពាល់ក្នុងការលើកកម្ពស់ជាន់ថ្នាក់។ ទុក្ខនៃចិត្តឆន្ទៈទើបជាគន្លឹះលើកកម្ពស់ជាន់ថ្នាក់ពិតប្រាកដ។ និយាយថាពលកម្មនៃសរសៃពួរឆ្អឹងគឺអាចលើកកម្ពស់ឡើងបាន, ខ្ញុំនិយាយថាកសិករចិនវេទនាបំផុត, តើសុទ្ធតែគួរជាគ្រូធំឈីគង់? លោកអ្នកពលកម្មនៃសរសៃពួរឆ្អឹងដល់ណាក៏មិនស្មើគាត់, មួយថ្ងៃៗធ្វើការនៅភូមិសាស្ត្រក្រោមព្រះអាទិត្យក្ដៅ, ទាំងវេទនាទាំងហាត់, មិនមែនរឿងរ៉ាវសាមញ្ញយ៉ាងនោះ។ ដូច្នេះខ្ញុំសម្ដែង, ពិតប្រាកដចង់លើកកម្ពស់, គឺត្រូវតែពិតប្រាកដធ្វើឱ្យចិត្តនេះសម្រេចបានលើកកម្ពស់, នោះទើបពិតប្រាកដអាចលើកកម្ពស់។

អំណាចកម្មក្នុងដំណើរការបំប្លែង, ដើម្បីធ្វើឱ្យខ្លួនឯងរក្សាបានជាប់, មិនលេចឡើងដូចមនុស្សសាមញ្ញធ្វើឱ្យរឿងរ៉ាវទៅជាអាក្រក់, ដូច្នេះពួកយើងពេលធម្មតាត្រូវតែរក្សាបេះដូងមួយមេត្តា, ស្ថានភាពផ្លូវចិត្តសន្តិភាពសប្បុរស។ ពេលដែលស្រាប់តែជួបប្រទះបញ្ហាអ្វី, លោកអ្នកគឺអាចដោះស្រាយវាបានល្អ។ ជាញឹកញាប់ចិត្តលោកអ្នករមែងសន្តិភាពសប្បុរសនិងមេត្តាយ៉ាងនោះ, ពេលដែលស្រាប់តែលេចឡើងបញ្ហា, លោកអ្នកមានថែមអំឡុងចន្លោះ, ថែមចន្លោះពិចារណា។ ក្នុងចិត្តរមែង

ចង់ប្រជែងនឹងអ្នកដទៃ, ប្រយុទ្ធមកប្រយុទ្ធទៅ, ខ្ញុំនិយាយថាកាលណាជួបប្រទះបញ្ហាលោកអ្នកគឺនឹងឈ្លោះប្រកែកជាមួយគេ, ធានាគឺជាបែបនេះ។ ដូច្នេះលោកអ្នកជួបប្រទះទំនាស់អ្វី, ខ្ញុំនិយាយជាក់ស្ដែងគឺដើម្បីធ្វើឲ្យសារធាតុពណ៌ខ្មៅរបស់រាងកាយលោកអ្នកបំប្លែងក្លាយជាសារធាតុពណ៌ស, បំប្លែងក្លាយជាគុណធម៌។

មនុស្សជាតិពួកយើងអភិវឌ្ឍដល់កម្រិតដូចថ្ងៃនេះ, សឹងតែម្នាក់ៗសុទ្ធតែជាកម្មមូរយកកម្ម, លើរាងកាយមនុស្សសុទ្ធតែមានអំណាចកម្មដ៏ធំ។ ដូច្នេះជាញឹកញាប់នៅលើបញ្ហាបំប្លែងអំណាចកម្មនឹងលេចឡើងកាលៈទេសៈនេះ, ក្នុងពេលដំណាលគ្នាលោកអ្នកកំពុងបង្កើនគង់, ក្នុងពេលដំណាលគ្នាចិត្តចរិតលើកកម្ពស់, អំណាចកម្មរបស់លោកអ្នកក៏ក្នុងពេលដំណាលគ្នាកំពុងរំលាយ, ក្នុងពេលដំណាលគ្នាបំប្លែង។ នៅពេលជួបប្រទះទំនាស់, អាចនឹងបង្ហាញនៅក្នុងពេលហាត់ពត់ចិត្តចរិតរវាងមនុស្សនិងមនុស្ស, លោកអ្នកអាចខន្ដីជាប់, អំណាចកម្មលោកអ្នកក៏រំលាយ, ចិត្តចរិតលោកអ្នកក៏លើកកម្ពស់ឡើង, គង់របស់លោកអ្នកក៏បង្កើនឡើង, ពួកវាគឺរំលាយផ្សំជាមួយគ្នា។ មនុស្សអតីតកាលគុណធម៌ធំ, ចិត្តចរិតរបស់គាត់ដើមមកជាក់ស្ដែងគឺខ្ពស់, គ្រាន់តែរងទុក្ខតិចតួចក៏អាចបង្កើនគង់បាន។ មនុស្សបច្ចុប្បន្នមិនមែនបែបនេះ, កាលណារងទុក្ខគឺមិនចង់បួស, លើសពីនេះទៀតមួយថ្ងៃកាន់តែមិនភ្ញាក់ដឹង, ក៏ជាកាន់តែពិបាកបួស។

នៅក្នុងបួសហាត់, ពេលដែលប្រព្រឹត្តចំពោះទំនាស់ពិស្ដារ, ពេលដែលអ្នកដទៃប្រព្រឹត្តមិនល្អចំពោះលោកអ្នក, អាចមានស្ថិតនៅកាលៈទេសៈពីរប្រភេទ៖ មួយគឺលោកអ្នកអាចជាតិមុនធ្លាប់មានមិនល្អចំពោះគេ, ក្នុងចិត្តលោកអ្នកខ្លួនឯងបាត់តុល្យភាព, ហេតុម្ដេចប្រព្រឹត្តចំពោះខ្ញុំ

បែបនេះ? ដូច្នោះលោកអ្នកពីមុនហេតុម្តេចប្រព្រឹត្តចំពោះគេបែបនោះ? លោកអ្នកនិយាយថាពេលនោះលោកអ្នកមិនដឹង, ជាតិនេះមិនគ្រប់គ្រងរឿងជាតិនោះ, នោះគឺមិនបាន។ នៅមានបញ្ហាមួយទៀត, ក្នុងពេលទំនាស់, ជាប់ពាក់ព័ន្ធបញ្ហាបំប្លែងអំណាចកម្ម, ដូច្នេះពេលដែលពួកយើងប្រព្រឹត្តពិស្តារ, គួរតែកម្រិតមារយាទខ្ពស់, មិនអាចដូចជាមនុស្សសាមញ្ញ។ នៅក្នុងអង្គភាព, នៅក្នុងបរិយាកាសការងារផ្សេងក៏ជាដូចគ្នា, បុគ្គលអាជីវកម្មក៏ជាដូចគ្នា, ក៏មានប្រាស្រ័យទាក់ទងរវាងមនុស្សនិងមនុស្ស, មិនអាចគ្មានទំនាក់ទំនងនឹងសង្គម, យ៉ាងហោចណាស់ក៏មានការទាក់ទងរវាងអ្នកជិតខាង។

នៅក្នុងប្រាស្រ័យទាក់ទងសង្គម, សុទ្ធតែនឹងជួបប្រទះទំនាស់គ្រប់បែបគ្រប់យ៉ាង, ផ្នែកបួសហាត់ទីមនុស្សសាមញ្ញរបស់យើងខ្ញុំ, មិនថាលោកអ្នកមានលុយប៉ុន្មាន, ធ្វើមន្ត្រីធំដល់ណា, លោកអ្នកធ្វើអាជីវកម្មឯកជន, បើកក្រុមហ៊ុន, ធ្វើជួញប្រែអ្វីក៏មិនបញ្ហា, ជួញដូរស្មើភាគ, ដាក់ចិត្តសុចរិត។ វិជ្ជាជីវៈគ្រប់យ៉ាងរបស់សង្គមមនុស្សជាតិសុទ្ធតែជាគួរស្ថិតនៅ, គឺចិត្តមនុស្សមិនសុចរិត, តែមិនអាស្រ័យលើធ្វើមុខរបរអ្វី។ អតីតកាលមានការថ្លែងថា, អ្វី [១០ឈ្មួញ៩នាក់ក្បត់], នេះគឺមនុស្សសាមញ្ញសម្តែង, ខ្ញុំនិយាយថានោះគឺបញ្ហាចិត្តមនុស្ស។ ប្រសិនចិត្តមនុស្សសុទ្ធតែដាក់ឱ្យសុចរិត, ជួញដូរស្មើភាគ, លោកអ្នកបង់ចំណាយច្រើន, គឺគួរតែរកលុយបានច្រើន, នោះក៏ជានៅក្នុងមនុស្សសាមញ្ញលោកអ្នកបង់ចំណាយទើបទទួលបាន, មិនបាត់មិនបាន, ទទួលបានដោយពលកម្ម។ នៅគ្រប់ប្រភេទវណ្ណៈសុទ្ធតែអាចធ្វើមនុស្សល្អ, វណ្ណៈខុសគ្នាស្ថិតនៅទំនាស់ខុសគ្នា។ វណ្ណៈខ្ពស់មានទម្រង់ទំនាស់របស់វណ្ណៈខ្ពស់, សុទ្ធតែអាចប្រព្រឹត្តចំពោះទំនាស់ដោយត្រឹមត្រូវ, នៅវណ្ណៈណាធ្វើដូចម្តេចដើម្បី

ធ្វើមនុស្សល្អ, សុទ្ធតែអាចមើលឲ្យស្រាលតណ្ហា, ចិត្តប្រកាន់គ្រប់ប្រភេទ។ នៅវណ្ណៈខុសគ្នាសុទ្ធតែអាចបង្ហាញចេញជាមនុស្សល្អ, សុទ្ធតែអាចបួសហាត់នៅក្នុងវណ្ណៈរបស់ខ្លួនឯង។

បច្ចុប្បន្នក្នុងប្រទេសមិនថាក្នុងសហគ្រាសរដ្ឋឬសហគ្រាសផ្សេងៗ, ទំនាស់រវាងមនុស្សនិងមនុស្សយ៉ាងពិសេសបំផុត។ នៅប្រទេសនានា, នៅក្នុងប្រវត្តិសាស្ត្រពីអតីតកាលដល់ឥឡូវមិនដែលមានប្រភេទបាតុភូតនេះ, ដូច្នេះទំនាស់នៅលើផលប្រយោជន៍បង្ហាញចេញមុតស្រួចខ្លាំងណាស់, កម្ចាត់គ្នា, ប្រជែងប្រយុទ្ធព្រោះតែផលប្រយោជន៍តិចតួច, មនោគតិផុសចេញ, ល្បិចកលដែលប្រើចេញសុទ្ធតែដ៏អាក្រក់, ធ្វើមនុស្សល្អក៏ពិបាក។ ឧបមាឯកជននេះមកដល់ក្នុងអង្គភាពធ្វើការ, មានអារម្មណ៍មកដល់ក្នុងអង្គភាពបរិយាកាសមិនប្រក្រតី។ ក្រោយមកមានមនុស្សប្រាប់ថា៖ នរណាៗចេញមុខនិយាយអាក្រក់លោកអ្នក, ប្ដឹងលោកអ្នកទៅកាន់ថ្នាក់លើ, ធ្វើឱ្យលោកអ្នកដ៏សំអុយ។ អ្នកដទៃសុទ្ធតែប្រើខ្សែភ្នែកខុសប្លែកសម្លឹងមើលលោកអ្នក។ តើមនុស្សធម្មតាទ្រាំបានរឿងនេះ? ពីណាអាចទ្រាំបានកំហឹងនេះ? គាត់លេងខ្ញុំ, ខ្ញុំលេងគាត់។ គាត់មានមនុស្ស, ខ្ញុំក៏មានមនុស្ស, តស់ដោះស្រាយគ្នា។ នៅក្នុងមនុស្សសាមញ្ញ, ធ្វើបែបនេះ, មនុស្សសាមញ្ញនឹងនិយាយថាលោកអ្នកជាអ្នកខ្លាំង។ ប៉ុន្តែធ្វើជាមនុស្សហាត់គង់ម្នាក់, នោះគឺអន់ពេកហើយ, លោកអ្នកដូចគ្នានឹងមនុស្សសាមញ្ញទៅប្រជែងប្រយុទ្ធ, លោកអ្នកជាក់ស្ដែងគឺជាមនុស្សសាមញ្ញ, ប្រសិនលោកអ្នកជាងទាំងគាត់, លោកអ្នកនៅមិនស្មើមនុស្សសាមញ្ញដូចគាត់។

ពួកយើងប្រព្រឹត្តដូចម្ដេចចំពោះបញ្ហានេះ? ពេលដែលជួបប្រទះប្រភេទទំនាស់នេះ, ពួកយើងដំបូងគួរតែស្ងប់ស្ងៀម, មិនគួរទៅប្រព្រឹត្តដូច

គ្នានឹងគាត់។ ប្រាកដណាស់ពួកយើងអាចទៅពន្យល់ដោយសុច្ឆន្ទៈ, និយាយរឿងរ៉ាវច្បាស់លាស់ក៏គ្មានបញ្ហា, ប៉ុន្តែលោកអ្នកប្រកាន់ពេកក៏មិនបាន។ ពួកយើងប្រសិនពេលដែលជួបប្រទះរំខានទាំងនេះ, មិនបានដូចគេទៅប្រជែងទៅប្រយុទ្ធ។ គាត់ធ្វើយ៉ាងនេះ, លោកអ្នកក៏ធ្វើយ៉ាងនេះ, លោកអ្នកមិនជាក់ស្ដែងគឺជាមនុស្សសាមញ្ញឬ? លោកអ្នកមិនត្រឹមតែមិនបានដូចគាត់ទៅប្រជែងទៅប្រយុទ្ធ, ក្នុងចិត្តលោកអ្នកក៏មិនអាចស្អប់គាត់, ពិតជាមិនអាចស្អប់គាត់។ លោកអ្នកស្អប់គាត់កាលណា, លោកអ្នកមិនមែនបានខឹងហើយឬ? លោកអ្នកគឺមិនទាន់ធ្វើបានខន្តី។ យើងខ្ញុំសម្ដែងសច្ចៈ-ករុណា-ខន្តី, ករុណារបស់លោកអ្នកគឺកាន់តែគ្មានទៀត។ ដូច្នេះលោកអ្នកមិនអាចដូចគ្នានឹងគាត់, លោកអ្នកពិតជាមិនអាចខឹងគាត់, កុំឃើញថាគាត់ធ្វើឱ្យលោកអ្នកលើក្រោមដ៏សំអុយ, ងើបក្បាលឡើងមិនរួច។ លោកអ្នកមិនត្រឹមតែមិនអាចខឹងគាត់, ក្នុងចិត្តលោកអ្នកនៅតែត្រូវអរគុណគាត់, ពិតជាត្រូវអរគុណគាត់។ នៅមនុស្សសាមញ្ញអាចជាគិតយ៉ាងនេះ៖ នោះមិនមែនជាអា-Qហើយឬ? ខ្ញុំប្រាប់លោកអ្នក, មិនមែនរឿងយ៉ាងនេះ។

អ្នករាល់គ្នាគិតសាកមើល, លោកអ្នកជាមនុស្សហាត់គង់, តើមិនមែនត្រូវប្រើបរមាណីយខ្ពស់ដើម្បីតម្រូវលោកអ្នក? មិនអាចប្រើគោលសីលធម៌នោះរបស់មនុស្សសាមញ្ញដើម្បីតម្រូវលោកអ្នក។ លោកអ្នកជាមនុស្សបួសហាត់, លោកអ្នកទទួលបានមិនមែនប្រការលើជាន់ថ្នាក់ខ្ពស់ឬ? នោះគឺត្រូវតែប្រើគោលសីលធម៌ជាន់ថ្នាក់ខ្ពស់ដើម្បីតម្រូវលោកអ្នក។ លោកអ្នកទៅធ្វើដូចនឹងគាត់, តើលោកអ្នកមិនមែនដូចនឹងគាត់? ដូច្នោះហេតុអ្វីនៅតែត្រូវអរគុណគាត់? លោកអ្នកគិតសាកមើលដែលលោកអ្នកទទួលបានជាអ្វី? ក្នុងចក្រវាលនេះមានគោលសីលធម៌, ហៅថាមិនបាត់

គឺមិនបាន, បានគឺត្រូវតែបាត់។ នៅក្នុងមនុស្សសាមញ្ញគាត់ធ្វើឱ្យលោកអ្នកដ៏សំអុយ, គាត់ចាត់ថាភាគីខាងបាន, គាត់បានកាន់កាប់ភាពងាយស្រួល។ គាត់ធ្វើឱ្យលោកអ្នកកាន់តែសំអុយ, ឥទ្ធិពលកាន់តែខ្លាំងសាហាវ, លោកអ្នកខ្លួនឯងស៊ូទ្រាំកាន់តែធំ, គាត់ខាតគុណធម៌កាន់តែច្រើន, គុណធម៌ទាំងនេះសុទ្ធតែផ្តល់ឱ្យលោកអ្នក, ក្នុងពេលដំណាលគ្នាពេលដែលលោកអ្នកស៊ូទ្រាំ, លោកអ្នកអាចបោះចោលចិត្តដ៏ស្រាល, គ្មានដាក់វានៅក្នុងចិត្ត។

នៅក្នុងចក្រវាលនេះនៅមានគោលសីលធម៌មួយ៖ លោកអ្នកគឺបានស៊ូទ្រាំឈឺចាប់ដ៏ធំ, ដូច្នេះអំណាចកម្មនៃរាងកាយលោកអ្នកខ្លួនឯងក៏ត្រូវបានបំប្លែង។ ដោយសារលោកអ្នកបានបង់ចំណាយរួចហើយ, ស៊ូទ្រាំច្រើនប៉ុណ្ណា, បំប្លែងច្រើនប៉ុណ្ណោះ, សុទ្ធតែប្រែក្លាយជាគុណធម៌។ មនុស្សហាត់គង់មិនមែនចង់បានគុណធម៌នេះឬ? មិនមែនលោកអ្នកបានពីរ, អំណាចកម្មក៏បានរំលាយ។ ប្រសិនគាត់មិនផលិតបរិយាកាសមួយបែបនេះឲ្យលោកអ្នក, លោកអ្នកទៅទីណាដើម្បីលើកកម្ពស់ចិត្តចរិត? អ្នកល្អខ្ញុំក៏ល្អ, សុខដុមអង្គុយជាមួយគ្នាទីនោះគឺបង្កើនគង់, ឯណាមានរឿងនោះ? ត្រង់ដោយសារគាត់បានផលិតទំនាស់មួយបែបនេះឲ្យលោកអ្នក, បានសាងបង្កើតឱកាសលើកកម្ពស់ចិត្តចរិតមួយបែបនេះ, ពីក្នុងនោះលោកអ្នកអាចលើកកម្ពស់ចិត្តចរិតខ្លួនឯង, ចិត្តចរិតនេះរបស់លោកអ្នកមិនមែនបានលើកកម្ពស់ហើយឬ? បានបី។ លោកអ្នកគឺជាមនុស្សហាត់គង់, ចិត្តចរិតលើកឡើងរួចហើយគង់លោកអ្នកមិនមែនលើកឡើងហើយឬ? ទង្វើមួយបានបួន។ ហេតុអ្វីលោកអ្នកមិនគួរអរគុណគេ? ក្នុងចិត្តលោកអ្នកពិតជាត្រូវអរគុណគេយ៉ាងត្រឹមត្រូវ, មែនទែនគឺជាបែបនេះ។

ប្រាកដណាស់, ចិត្តដែលគាត់ផុសចេញគឺមិនល្អ, បើមិនដូច្នោះទេគឺនឹងមិនផ្តល់គុណធម៌ឲ្យលោកអ្នក, ប៉ុន្តែគាត់មែនទែនបានផលិតឱកាសមួយឲ្យលោកអ្នកដើម្បីលើកកម្ពស់ចិត្តចរិតរបស់លោកអ្នក។ មានន័យថាពួកយើងជាក់លាក់ត្រូវតែយកចិត្តទុកដាក់បួសហាត់ចិត្តចរិត, ពេលបួសហាត់ចិត្តចរិតក្នុងពេលដំណាលគ្នានឹងរំលាយអំណាចកម្ម, បំប្លែងក្លាយជាគុណធម៌, លោកអ្នកទើបអាចលើកកម្ពស់ជាន់ថ្នាក់, នេះគឺបំពេញគ្នាទៅវិញទៅមក។ ដល់លើជាន់ថ្នាក់ខ្ពស់សង្កេតមើល, គោលសីលធម៌នេះសុទ្ធតែកើតឡើងការផ្លាស់ប្រែ។ មនុស្សសាមញ្ញគាត់អាចមើលមិនច្បាស់រឿងនេះ, លោកអ្នកដល់លើជាន់ថ្នាក់ខ្ពស់មើលគោលសីលធម៌នេះ, ទាំងមូលសុទ្ធតែកើតឡើងការផ្លាស់ប្រែ។ នៅក្នុងមនុស្សសាមញ្ញលោកអ្នកមើលគោលសីលធម៌នេះសន្មតថាត្រូវ, ប៉ុន្តែវាមិនមែនពិតជាត្រូវ។ ដល់លើជាន់ថ្នាក់ខ្ពស់សង្កេតមើលទើបពិតប្រាកដគឺត្រូវ, ជាញឹកញាប់គឺជាបែបនេះ។

គោលសីលធម៌ខ្ញុំសម្តែងធ្លុះធ្លាយឲ្យអ្នករាល់គ្នារួចហើយ, សង្ឃឹមថាក្នុងពេលបួសហាត់ពីពេលនេះតទៅ, អ្នករាល់គ្នាអាចចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់ម្នាក់, ពិតប្រាកដដើម្បីបួសហាត់, ដោយសារគោលសីលធម៌ដាក់នៅទីនេះរួចហើយ។ អាចមានមនុស្សមួយចំនួន, ដោយសារគាត់នៅក្នុងមនុស្សសាមញ្ញ, គាត់មានអារម្មណ៍ថាផលប្រយោជន៍សម្ភារៈប្រាកដនិយមនេះរបស់មនុស្សសាមញ្ញដាក់នៅទីនោះ, នៅតែជាអត្ថប្រយោជន៍សម្ភារៈនេះ។ នៅក្នុងលំហូរមនុស្សសាមញ្ញ, គាត់នៅតែមិនអាចប្រើបរមាណីយខ្ពស់ដើម្បីតម្រូវខ្លួនឯង។ ភាពពិត, ធ្វើមនុស្សល្អម្នាក់ក្នុងមនុស្សសាមញ្ញមានតួអង្គវីរបុរសធ្វើជាគំរូរួចហើយ, នោះជាគំរូក្នុងមនុស្សសាមញ្ញ។ ប្រសិនលោកអ្នកចង់ធ្វើអ្នកបួសហាត់ម្នាក់,

ទាំងស្រុងពឹងផ្អែកលើចិត្តរបស់លោកអ្នកខ្លួនឯងដើម្បីបួស, ទាំងស្រុងពឹងផ្អែកលើលោកអ្នកខ្លួនឯងដើម្បីភ្ញាក់ដឹង, គ្មានគំរូ។ ភ័ព្វល្អថ្ងៃនេះយើងខ្ញុំបានសម្ដែងមហាធម៌ចេញទូលាយ, អតីតកាលលោកអ្នកចង់បួស, ក៏គ្មានមនុស្សសម្ដែង។ បែបនេះលោកអ្នកយោងតាមមហាធម៌ដើម្បីធ្វើអាចធ្វើបានល្អជាង, អាចឬមិនអាចបួស, អាចឬមិនអាចអនុវត្ត, ទម្លុះដល់ជាន់ថ្នាក់ណា, ទាំងស្រុងសង្កេតមើលលោកអ្នកខ្លួនឯង។

ប្រាកដណាស់, ទម្រង់បំប្លែងរបស់អំណាចកម្មក៏មិនទាំងស្រុងដូចខ្ញុំទើបសម្ដែងបែបនោះ, នៅទិដ្ឋភាពផ្សេងក៏នឹងបង្ហាញចេញមក។ នៅលើសង្គម, នៅក្នុងគ្រួសារសុទ្ធតែនឹងលេចឡើង។ ដើរនៅលើផ្លូវ, ឬក៏នៅក្នុងបរិយាកាសសង្គមផ្សេង, ក៏អាចជួបប្រទះរឿងរំខាន។ នៅក្នុងមនុស្សសាមញ្ញចិត្តដែលដាក់ចុះមិនបាន, សុទ្ធតែត្រូវទុកឲ្យលោកអ្នកដាក់ចុះ។ ចិត្តប្រកាន់ទាំងអស់, ឲ្យតែលោកអ្នកមាន, គឺត្រូវតែនៅក្នុងបរិយាកាសគ្រប់ប្រភេទយកវាបោះចោល។ ទុកឲ្យលោកអ្នកដួលចំពប់, ពីក្នុងនោះភ្ញាក់ដឹងតាវ, ជាក់ស្ដែងគឺបួសហាត់ឆ្លងមកបែបនេះ។

តួយ៉ាងបង្ហូរនៅមានកាលៈទេសៈមួយបែបនេះ៖ ពួកយើងមានមនុស្សជាច្រើននៅក្នុងដំណើរការបួសហាត់, ជាញឹកញាប់ពេលដែលលោកអ្នកហាត់គង់, ប្រពន្ធលោកអ្នកជាពិសេសមិនរីករាយ, លោកអ្នកហាត់គង់កាលណា, នឹងប្រយុទ្ធជាមួយលោកអ្នក។ លោកអ្នកធ្វើរឿងរ៉ាវផ្សេង, គាត់ក៏មិនខ្វល់។ លោកអ្នកនិយាយលោកអ្នកវាយម៉ាជាំងខ្ទះខ្ទាយពេលវេលាយ៉ាងណា, គាត់ក៏មិនរីករាយ, ប៉ុន្តែមិនដូចហាត់គង់បែបនោះ។ លោកអ្នកហាត់គង់ក៏មិនធ្វើឲ្យគាត់ខឹង, ធ្វើលំហាត់ប្រាណ, ក៏មិនឥទ្ធិពលដល់គាត់, ល្អប៉ុណ្ណា។ ប៉ុន្តែ, ដរាបណាពេលលោកអ្នកហាត់គង់, នាងនឹងបោះបោកវាយលោកអ្នក។ មានមនុស្សព្រោះតែហាត់គង់, ប្ដី

ប្រពន្ធឈ្លោះប្រកែកដល់ថ្នាក់លែងលះគ្នា។ មនុស្សដ៏ច្រើនក៏មិនដែលគិតសាកមើលថាហេតុអ្វីលេចឡើងកាលៈទេសៈនេះ? ក្រោយមកលោកអ្នកសាកសួរគាត់៖ "បងហាត់គង់ហេតុអ្វីអូនខឹងខ្លាំងយ៉ាងនោះ?" គាត់និយាយមិនចេញបានអ្វី, ពិតជានិយាយមិនចេញបានអ្វី៖ "អឺហ្ន៎, ខ្ញុំមិនគួរខឹងខ្លាំងយ៉ាងនោះសោះ", ពេលនោះជាក់ស្ដែងគឺក្ដៅក្រហាយខ្លាំងយ៉ាងនោះ។ ភាពពិតជារឿងដូចម្ដេច? ពេលហាត់គង់ក្នុងពេលដំណាលគ្នា, អំណាចកម្មនឹងបំប្លែង, មិនបាត់គឺមិនបាន, ដែលបាត់ក៏ជារបស់អាក្រក់, លោកអ្នកត្រូវតែបង់ចំណាយ។

អាចទើបចូលដល់មាត់ទ្វារ, ប្ដីឬប្រពន្ធលោកអ្នកក៏ទះក្បាលគ្រប មុខធ្វើឲ្យលោកអ្នកមួយតាំង, ប្រសិនលោកអ្នកស៊ូទ្រាំហួសបាន, គង់លោកអ្នកហាត់បានថ្ងៃនេះមិនហាត់អត់ប្រយោជន៍។ មានមនុស្សក៏ដឹងហាត់គង់ត្រូវតែគោរពគុណធម៌, ដូច្នេះជាមួយប្ដីឬប្រពន្ធគាត់ពេលធម្មតាល្អណាស់។ គិតថា៖ ពេលធម្មតាខ្ញុំនិយាយមួយមិនហ៊ានថាពីរ, ថ្ងៃនេះគាត់ជិះលើក្បាលខ្ញុំ។ ក្ដៅទប់មិនជាប់, ឈ្លោះប្រកែកជាមួយនឹងគាត់, ថ្ងៃនេះហាត់ដូចមិនហាត់។ ដោយសារអំណាចកម្មនៅទីនោះ, គាត់ជួយលោកអ្នករំលាយចោលលោកអ្នកមិនព្រម, ឈ្លោះប្រកែកជាមួយគេ, មិនទាន់រំលាយបាន។ រឿងរ៉ាវទាំងនេះច្រើនណាស់, មនុស្សជាច្រើនពួកយើងសុទ្ធតែធ្លាប់ជួបប្រទះកាលៈទេសៈនេះ, មិនធ្លាប់សាកគិតថាហេតុអ្វី។ លោកអ្នកធ្វើរឿងរ៉ាវផ្សេងគាត់ក៏មិនខ្វល់លោកអ្នក, ដើមមកគឺជារឿងល្អ, គាត់ផ្ទុយមកវិញតែងតែមានបញ្ហាជាមួយលោកអ្នក។ ភាពពិតនោះគឺជួយលោកអ្នករំលាយកម្ម, ប៉ុន្តែគាត់ខ្លួនឯងមិនដឹង។ គាត់មិនគ្រាន់តែឈ្លោះប្រកែកនឹងលោកអ្នកនៅលើផ្ទៃ, ក្នុងចិត្តនៅតែដ៏ល្អចំពោះលោកអ្នក, មិនមែនជាបែបនេះ, ពិតជាខឹងផុសពីក្នុងចិត្តខ្លួនឯង។ ព្រោះ

អំណាចកម្មធ្លាក់លើនរណាអ្នកនោះពិបាកទ្រាំ, ធានាគឺជាបែបនេះ។

## លើកកម្ពស់ចិត្តចរិត

អតីតកាលមនុស្សជាច្រើនដោយសារចិត្តចរិតរក្សាមិនជាប់, បញ្ហាលេចឡើងដ៏ច្រើន, បន្ទាប់ពីហាត់ដល់ជាន់ថ្នាក់ជាក់លាក់រួចហើយមិនឡើងបានទៀត។ មានមនុស្សខ្លួនឯងដើមមកចិត្តចរិតខ្ពស់បង្គួរ, ក្នុងពេលហាត់គង់ភ្លាមៗបើកភ្នែកទិព្វ, សម្រេចបានកម្រិតភពណាមួយ។ ដោយសារឯកជននេះនិស្ស័យល្អបង្គួរ, ចិត្តចរិតដ៏ខ្ពស់, ដូច្នេះគង់របស់គាត់កើនឡើងយ៉ាងឆាប់រហ័ស។ ពេលដែលបានដល់ទីតាំងនៃចិត្តចរិតរបស់គាត់, គង់របស់គាត់ក៏កើនឡើងដល់ទីនេះ, គាត់ត្រូវការលើកកម្ពស់គង់របស់គាត់ជាងទៀត, ដូច្នោះទំនាស់នេះក៏ស្រាប់តែលេចឡើង, គឺត្រង់ថាត្រូវការគាត់បន្តលើកកម្ពស់ចិត្តចរិតរបស់គាត់។ ជាពិសេសគឺដើមមកដែលនិស្ស័យល្អ, គាត់គឺមានអារម្មណ៍ថាគង់នេះរបស់គាត់បង្កើនបានយ៉ាងល្អ, ហាត់បានក៏ល្អណាស់ផងដែរ, ស្រាប់តែហេតុម្ដេចរឿងរំខានច្រើនយ៉ាងនេះមក? ហេតុម្ដេចអ្វីៗសុទ្ធតែមិនល្អ, គេចំពោះគាត់ក៏មិនល្អ, ថ្នាក់ដឹកនាំក៏មើលគាត់គ្មានតម្លៃ, បរិយាកាសក្នុងគ្រួសារក៏តឹងតែងណាស់ផងដែរ។ ហេតុម្ដេចបានជាស្រាប់តែលេចមកទំនាស់ច្រើនយ៉ាងនេះ? ខ្លួនគាត់ក៏មិនភ្ញាក់ដឹង។ ដោយសារនិស្ស័យគាត់ល្អ, សម្រេចបានជាន់ថ្នាក់ជាក់លាក់រួចហើយ, បានលេចឡើងស្ថានភាពមួយបែបនេះ។ ប៉ុន្តែនោះគឺជាបរមាណីយសម្រេចបរិបូរចុងក្រោយរបស់មនុស្សបួសហាត់ហើយឬនៅ? នៅឆ្ងាយណាស់ទើបបួសឡើងបាន! លោកអ្នកត្រូវតែបន្តលើកកម្ពស់ខ្លួនឯង។ នោះគឺជានិស្ស័យបន្តិចយ៉ាងនោះដែលខ្លួនឯងនាំតាមផ្ដើមផលប៉ះពាល់, លោកអ្នកទើបអាចសម្រេចបានប្រភេទស្ថានភាពនោះ, លើកកម្ពស់ជាងទៀត, បរមាណីយនោះក៏ត្រូវតែ

លើកកម្ពស់ឡើងតាម។

មនុស្សខ្លះសម្ដែង៖ ខ្ញុំរកលុយថែមបន្តិច, រៀបចំគ្រួសារល្អហើយ, ខ្ញុំគឺអ្វីក៏មិនខ្វល់ទៀត, ខ្ញុំទៅបួសតាវម្តងទៀត។ ខ្ញុំនិយាយថាលោកអ្នកគិតរវើរវាយ, លោកអ្នកជ្រៀតជ្រែកជីវិតរបស់អ្នកដទៃមិនបាន, គ្រប់គ្រងជោគវាសនាអ្នកដទៃមិនបាន, រួមបញ្ចូលប្រពន្ធកូន, ពុកម៉ែបងប្អូនជោគវាសនារបស់ពួកគាត់, នោះគឺលោកអ្នកសម្រេចចិត្តបានឬ? ក្រៅពីនេះ, លោកអ្នកគ្មានបារម្ភនៃកង្វល់ថ្ងៃក្រោយ, លោកអ្នករំខានអ្វីសុទ្ធតែគ្មាន, លោកអ្នកនៅបួសហាត់អីទៀត? នៅទីនោះហាត់គង់ដោយសុខស្រួល? ឯណាមានរឿងប្រភេទនោះ? នោះគឺលោកអ្នកឈរនៅលើជំហររបស់មនុស្សសាមញ្ញដើម្បីគិតប៉ុណ្ណោះ។

បួសហាត់គឺត្រូវតែបួសហាត់នៅក្នុងគ្រោះលំបាក, មើលស្នេហា៧តណ្ហា៦លោកអ្នកអាចលះបង់ឬអត់, អាចមើលឱ្យស្រាលឬអត់។ លោកអ្នកប្រកាន់ជាក់ស្ដែងលើរបស់ទាំងនោះ, លោកអ្នកគឺបួសមិនលេចចេញបាន។ រឿងរ៉ាវណាមួយសុទ្ធតែជាមានទំនាក់ទំនងកម្មផល, មនុស្សហេតុអ្វីអាចធ្វើមនុស្ស? ជាក់ស្ដែងគឺក្នុងមនុស្សមានស្នេហា, មនុស្សជាក់ស្ដែងគឺព្រោះតែស្នេហានេះដើម្បីរស់, ស្នេហាសាច់ញាតិ, ស្នេហាប្រុសស្រី, ស្នេហាចំពោះឪម៉ែ, មនោសញ្ចេតនា, ស្នេហាមិត្តភក្តិ, ធ្វើការសម្ដែងស្រឡាញ់គ្នាទៅវិញទៅមក, ក្នុងគ្រប់វិស័យក៏មិនឃ្លាតពីស្នេហានេះ, ចង់ធ្វើមិនចង់ធ្វើ, រីករាយមិនរីករាយ, ស្រឡាញ់និងស្អប់, ទាំងអស់នៃសង្គមមនុស្សជាតិទាំងមូល, ទាំងស្រុងគឺចេញពីស្នេហានេះឯង។ ស្នេហានេះបើសិនមិនកាត់ផ្ដាច់ទេ, លោកអ្នកគឺបួសហាត់មិនបាន។ មនុស្សបើសិនលោតចេញពីស្នេហានេះ, នរណាក៏ប៉ះមិនបានលោកអ្នក, ចិត្តរបស់មនុស្សសាមញ្ញគឺទាញកម្រើកមិនបានលោកអ្នក, ជំនួសមកវិញគឺជា

មេត្តា, គឺជាប្រការខ្ពង់ខ្ពស់ជាង។ ប្រាកដណាស់ភ្លាមៗកាត់ផ្តាច់បានប្រការទាំងនេះក៏មិនងាយស្រួល, បួសហាត់ជាដំណើរការយឺតយូរ, ជាដំណើរការមួយសន្សឹមៗកម្ចាត់ចិត្តប្រកាន់របស់ខ្លួនឯង, ប៉ុន្តែលោកអ្នកត្រូវតែខ្លួនឯងតឹងរឹងតម្រូវខ្លួនឯង។

ពួកយើងធ្វើជាមនុស្សហាត់គង់ម្នាក់, ទំនាស់នឹងស្រាប់តែសាងបង្កើត។ ធ្វើដូចម្តេច? លោកអ្នកពេលធម្មតារមែងរក្សាបេះដូងមួយមេត្តា, ស្ថានភាពផ្លូវចិត្តមួយសន្តិភាព, ជួបប្រទះបញ្ហាគឺនឹងធ្វើបានល្អ, ដោយសារវាមានអំឡុងពន្យា។ លោកអ្នករមែងមេត្តា, ករុណាចំពោះមនុស្ស, ធ្វើរឿងរ៉ាវអ្វីតែងតែពិចារណាដល់អ្នកដទៃ, រាល់ពេលជួបប្រទះបញ្ហាមុនដំបូងគិតថា, រឿងរ៉ាវនេះចំពោះអ្នកដទៃអាចស៊ូទ្រាំបានឬអត់, មានធ្វើបាបដល់អ្នកដទៃឬអត់, នេះគឺនឹងមិនលេចឡើងបញ្ហា។ ដូច្នេះលោកអ្នកហាត់គង់ត្រូវតែយោងតាមបរមាណីយខ្ពស់, បរមាណីយខ្ពស់ជាងដើម្បីតម្រូវខ្លួនឯង។

ជាញឹកញាប់មានមនុស្សមួយចំនួនមិនភ្ញាក់ដឹង។ មនុស្សខ្លះភ្នែកទិព្វបើករួចហើយ, មើលឃើញព្រះពុទ្ធ, វិលមកផ្ទះសំពះព្រះពុទ្ធ, ក្នុងចិត្តសូត្ររអ៊ូ៖ ទ្រង់ហេតុម្តេចមិនគ្រប់គ្រងកូន? សូមជួយកូនដោះស្រាយបញ្ហានេះផង! ព្រះពុទ្ធប្រាកដណាស់មិនគ្រប់គ្រង, គ្រោះមួយនោះជាក់ស្តែងគឺជាគាត់រៀបចំ, គោលបំណងគឺលើកកម្ពស់ចិត្តចរិតរបស់លោកអ្នក, នៅក្នុងទំនាស់លោកអ្នកងាយស្រួលលើកកម្ពស់ឡើងលើ។ គាត់អាចដោះស្រាយឲ្យលោកអ្នកឬ? ជាមូលដ្ឋាននឹងមិនដោះស្រាយឲ្យលោកអ្នក, ដោះស្រាយរួចហើយលោកអ្នកធ្វើដូចម្តេចបង្កើនគង់, ធ្វើដូចម្តេចលើកកម្ពស់ចិត្តចរិតនិងជាន់ថ្នាក់? ទុកឲ្យលោកអ្នកបង្កើនគង់ទើបជាគន្លឹះ។ នៅពួកអង្គមហាត្រាស់ដឹងសង្កេតមើល, ធ្វើមនុស្សមិនមែនជា

គោលបំណង, ជីវិតរបស់មនុស្សមិនមែនដើម្បីធ្វើមនុស្ស, ជាក់ស្តែងគឺទុកឲ្យលោកអ្នកត្រឡប់ទៅវិញ។ មនុស្សរងទុក្ខប៉ុណ្ណា, គាត់សន្មតថារងទុក្ខកាន់តែច្រើនកាន់តែល្អ, សងបំណុលលឿនជាង, គាត់ជាក់ស្តែងគឺគិតដូច្នេះ។ មនុស្សខ្លះមិនភ្ញាក់ដឹង, សុំព្រះពុទ្ធមិនបាន, ក៏ចាប់ផ្តើមបន្ទោសព្រះពុទ្ធ៖ ទ្រង់ហេតុម្តេចក៏មិនជួយកូន? រាល់ថ្ងៃអុជធូបក្រាបក្បាលដល់ទ្រង់។ មនុស្សខ្លះដោយសារតែរឿងនេះ, ក៏យកពុទ្ធបដិមាបោះចោល, ហេតុនេះជេរព្រះពុទ្ធ។ ដោយសារគាត់ជេរកាលណា, ចិត្តចរិតក៏ធ្លាក់ចុះក្រោម, គង់ក៏គ្មានទៀត។ គាត់ដឹងថាអ្វីក៏គ្មានទៀត, គឺកាន់តែស្អប់ព្រះពុទ្ធ, គាត់សន្មតថាព្រះពុទ្ធកំពុងធ្វើបាបគាត់។ គាត់ប្រើគោលសីលធម៌របស់មនុស្សសាមញ្ញដើម្បីវាស់វែងចិត្តចរិតរបស់ព្រះពុទ្ធ, នោះឯណាអាចវាស់វែងបាន? គាត់ប្រើបរមាណីយរបស់មនុស្សសាមញ្ញដើម្បីដោះស្រាយរឿងរ៉ាវលើជាន់ថ្នាក់ខ្ពស់, នោះឯណាអាចបាន? ដូច្នេះជាញឹកញាប់គឺលេចឡើងបញ្ហាបែបនេះ, យកទុក្ខក្នុងជីវិតចាត់ទុកជាអយុត្តិធម៌ចំពោះខ្លួនឯង, មានមនុស្សជាច្រើនដួលរលំធ្លាក់ចុះ។

ប៉ុន្មានឆ្នាំមុនមានគ្រូធំឃីគង់ជាច្រើន, កេរ្តិ៍ឈ្មោះល្បីល្បាញក៏ដួលរលំធ្លាក់ចុះ។ ប្រាកដណាស់គ្រូឃីគង់ពិតប្រាកដសុទ្ធតែត្រឡប់ទៅវិញរួចហើយ, បញ្ចប់បេសកកម្មប្រវត្តិសាស្ត្ររបស់ពួកគាត់បានត្រឡប់ទៅវិញរួចហើយ។ គ្រាន់តែនៅសល់មួយចំនួនបានវង្វេងនៅក្នុងមនុស្សសាមញ្ញ, មនុស្សដែលចិត្តចរិតធ្លាក់ចុះទាំងនោះក៏កំពុងធ្វើសកម្មភាព, គាត់បានគ្មានគង់ទៀតរួចហើយ។ មានគ្រូឃីគង់មួយចំនួនអតីតកាលមានឈ្មោះល្បីបង្គួរក៏ធ្វើសកម្មភាពនៅលើសង្គម, គ្រូរបស់គាត់មើលឃើញគាត់ធ្លាក់នៅក្នុងមនុស្សសាមញ្ញ, ធ្លាក់នៅក្នុងកិត្តិនាមផលប្រយោជន៍បានមិនអាចទាញឡើងដោយខ្លួនឯង, មិនបានរួចហើយ, គេនាំយក

វិញ្ញាញដើមរងរបស់គាត់ចេញទៅ, គង់សុទ្ធតែនៅលើរាងកាយវិញ្ញាញដើមរង។ ប្រភេទឧទាហរណ៍ជាតួយ៉ាងនេះច្រើនណាស់។

នៅក្នុងធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំ, ប្រភេទឧទាហរណ៍នេះតិចបង្គួរ, មានក៏មិនមែនលេចធ្លោយ៉ាងនោះ។ នៅទិដ្ឋភាពលើកកម្ពស់ចិត្តចរិត, ឧទាហរណ៍លេចធ្លោច្រើនពិសេស។ មានសិក្ខាកាមម្នាក់មកពីរោងចក្រវាយនភណ្ឌនៅទីក្រុងមួយក្នុងខេត្តសានទុង, បន្ទាប់ពីរៀនហ្វាលូនតាហ្វាក៏បង្រៀនឲ្យកម្មករដទៃហាត់, លទ្ធផលបានទាញកម្រើកមុខមាត់ស្មារតីរបស់រោងចក្រងើបឡើងទាំងស្រុង។ កន្លងមកក្បាលកន្សែងរបស់រោងចក្រវាយនភណ្ឌជាធម្មតាត្រូវបានលាក់យកទៅផ្ទះ, កម្មករសុទ្ធតែយក{ដូច្នោះ}។ បន្ទាប់ពីរៀនគង់គាត់មិនត្រឹមតែមិនយកទៀត, ដែលបានយកទៅផ្ទះក៏យកត្រឡប់មកវិញ។ អ្នកដទៃពេលណាឃើញគាត់ធ្វើបែបនេះ, នរណាក៏មិនយកទៀត, កម្មករខ្លះថែមទាំងយកអ្វីដែលខ្លួនឯងបានយកពីមុនសុទ្ធតែសងត្រឡប់មករោងចក្រវិញ, រោងចក្រទាំងមូលបានលេចឡើងកាលៈទេសៈនេះ។

ប្រធានឋានីយជួយណែនាំទីក្រុងមួយមករោងចក្រដើម្បីសង្កេតមើលសិក្ខាកាមហាត់ហ្វាលូនតាហ្វាហាត់បានបែបណា, នាយករោងចក្រនោះផ្ទាល់ខ្លួនបានជួបមុខពួកគាត់៖ កម្មករទាំងនេះបន្ទាប់ពីរៀនហ្វាលូនតាហ្វារបស់ពួកលោករួចហើយ, មកឆាប់ចេញយឺត, ធ្វើការងារដោយប្រុងប្រយ័ត្ន, ថ្នាក់ដឹកនាំប្រគល់ការងារអ្វីមិនដែលរើសអើង, ខាងផលប្រយោជន៍ក៏មិនទៅប្រជែង។ ពួកគាត់សុទ្ធតែធ្វើបែបនេះ, ទាញមុខមាត់ស្មារតីរបស់រោងចក្រទាំងមូលងើបឡើងទាំងស្រុង, ផលប្រយោជន៍សេដ្ឋកិច្ចរបស់រោងចក្រក៏ល្អផងដែរ។ គង់នេះរបស់ពួកលោកអស្ចារ្យយ៉ាងនេះ, ពេលណាលោកគ្រូរបស់ពួកលោកមក, ខ្ញុំក៏ទៅចូលរួម។

គោលបំណងចម្បងដែលពួកយើងបួសហាត់ហ្វានលូនតាហ្វាគឺជានាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់, និងគ្មានគិតធ្វើរឿងរ៉ាវបែបនេះ, ប៉ុន្តែផ្ទុយមកវិញគាត់អាចផ្តើមផលប៉ះពាល់ជំរុញដ៏ធំចំពោះអរិយធម៌ស្មារតីរបស់សង្គម។ ប្រសិននរណាៗសុទ្ធតែសំដៅចូលក្នុងចិត្តដើម្បីរក, នរណាៗសុទ្ធតែគិតខ្លួនឯងធ្វើដូចម្តេចឲ្យល្អ, ខ្ញុំនិយាយថាសង្គមនោះនឹងស្ថេរភាព, បរមាណីយសីលធម៌សង្គមមនុស្សជាតិក៏នឹងលើកឡើងវិញ។

ពេលខ្ញុំសម្តែងធម៌បង្រៀនគង់នៅថៃយ្វាន, មានសិក្ខាកាមម្នាក់អាយុហាសិបប្លាយ, ពីរនាក់ប្តីប្រពន្ធមកចូលរួមថ្នាក់សិក្សា។ ពេលដែលពួកគាត់ដើរនៅពាក់កណ្តាលផ្លូវ, ឡានមួយគ្រឿងបើកបរសែនលឿន, កញ្ចក់មើលក្រោយរបស់ឡានភ្លាមៗក៏ថ្ពក់ជាប់សម្លៀកបំពាក់របស់ស្ត្រីចំណាស់។ បន្ទាប់ពីថ្ពក់ជាប់បានទាញគាត់ចេញឆ្ងាយជាងដប់ម៉ែត្រ, [ផាំង] ភ្លាមដួលនៅលើដី, ឡានបើកចេញទៅជាងម្ភៃម៉ែត្រទៀតឈប់ជាប់។ បន្ទាប់ពីអ្នកបើកបរលោតចុះពីឡានក៏មិនសប្បាយចិត្ត៖ អាំ, យាយដើរឆ្លងផ្លូវមិនមើល។ បច្ចុប្បន្នឯកជននេះជាក់ស្តែងគឺជាបែបនេះ, ជួបប្រទះបញ្ហាមុនដំបូងរុញទំនួលខុសត្រូវ, អយុត្តិធម៌ឬយុត្តិធម៌គាត់សុទ្ធតែរុញចេញក្រៅ។ មនុស្សអង្គុយក្នុងឡាននិយាយ៖ មើលៗដួលយ៉ាងណាហើយ, ជូនទៅមន្ទីរពេទ្យទៅ។ អ្នកបើកបរយល់ច្បាស់រួចហើយ, ប្រញាប់និយាយ៖ យាយយ៉ាងម៉េចហើយ? តើដួលរបួសធ្ងន់ឬអត់? ពួកយើងទៅមន្ទីរពេទ្យពិនិត្យមើលទៅ។ សិក្ខាកាមនោះសន្សឹមៗបន្ទាប់ពីវារឡើងពីដីនិយាយថា៖ មិនអីទេ, ពួកលោកទៅចុះ។ បោសៗធូលី, ទាញលោកប្តីក៏ដើរទៅ។

ដល់ថ្នាក់មកនិយាយជាមួយខ្ញុំអំពីរឿងរ៉ាវនេះ, ខ្ញុំក៏សប្បាយចិត្តខ្លាំងណាស់។ ចិត្តចរិតរបស់សិក្ខាកាមពួកយើងមែនទែនបានលើក

កម្ពស់រួចហើយ។ គាត់និយាយជាមួយខ្ញុំ៖ លោកគ្រូ, កូនថ្ងៃនេះគឺបាន រៀនហ្វាលូនតាហ្វា, ប្រសិនកូនមិនមែនបានរៀនហ្វាលូនតាហ្វា, ថ្ងៃនេះ កូននឹងមិនប្រព្រឹត្តបែបនេះ។ អ្នករាល់គ្នាគិតសាកមើល, ចូលនិវត្តន៍រួច ហើយ, បច្ចុប្បន្នតម្លៃទីផ្សារខ្ពស់យ៉ាងនេះ, អត្ថប្រយោជន៍សុខុមាលភាព អ្វីក៏គ្មាន។ មនុស្សដែលអាយុហាសិបប្លាយត្រូវឡានអូសទៅឆ្ងាយយ៉ាង នោះ, ដួលនៅលើដី។ កន្លែងណាមានបញ្ហា? កន្លែងណាក៏មានបញ្ហា, ពោបនៅលើដីក៏មិនក្រោកឡើងទៀត។ ទៅមន្ទីរពេទ្យ, ទៅ, ដល់មន្ទីរ ពេទ្យស្នាក់នៅក៏មិនចេញទៀត។ មនុស្សសាមញ្ញអាចគឺជាបែបនោះ។ ប៉ុន្តែគាត់គឺជាមនុស្សហាត់គង់, គ្មានធ្វើបែបនោះ។ ពួកយើងគឺសម្ដែងថា, ល្អអាក្រក់ផុសពីគំនិតមួយរបស់មនុស្សខ្លួនឯង, ភាពខុសគ្នានៃគំនិត មួយនេះក៏នឹងនាំមកផលវិបាកខុសគ្នា។ អាយុច្រើនយ៉ាងនោះ, ជាមនុ ស្សសាមញ្ញ, អាចដួលមិនត្រូវរបួសឬ? តែគាត់សូម្បីតែស្បែកក៏មិនក កោស។ ល្អអាក្រក់ផុសពីគំនិតមួយរបស់ខ្លួនឯង, បើគាត់ដេកនៅទីនោះ និយាយថា៖ អ៉ាយយ៉ា, ខ្ញុំមិនស្រួលហើយ, នេះមិនស្រួល, នោះមិន ស្រួល។ ដូច្នោះអាចជាដាច់សរសៃពួរបាក់ឆ្អឹង, កម្រើកលែងបាន។ ឱ្យ លោកអ្នកលុយប៉ុន្មាន, លោកអ្នកស្នាក់នៅក្នុងមន្ទីរពេទ្យពាក់កណ្ដាល ជីវិតក្រោយមកក្រោកមិនបាន, លោកអ្នកអាចសុខស្រួលបានឬ? មនុ ស្សឈរខាងក្រៅមើលសុទ្ធតែមានអារម្មណ៍ថាចម្លែក, យាយចាស់នេះ ហេតុម្ដេចមិនធ្វើស៊ីលុយគាត់បន្តិចទៅ, ទារយកលុយគាត់។ កម្រិត សីលធម៌របស់មនុស្សបច្ចុប្បន្នសុទ្ធតែកើតឡើងរមួលបត់រួចហើយ។ អ្នក បើកបរគឺបើកឡានលឿន, ប៉ុន្តែគាត់អាចជាចេតនាទៅបុកមនុស្សឬ? គាត់មិនមែនអចេតនាឬ? តែមនុស្សពួកយើងបច្ចុប្បន្នជាក់ស្ដែងគឺជា បែបនេះ, បើមិនធ្វើស៊ីលុយគាត់បន្តិច, ក្នុងចិត្តរបស់មនុស្សមើលខាង

ក្រៅនេះសុទ្ធតែបាត់តុល្យភាព។ បច្ចុប្បន្នខ្ញុំនិយាយថាល្អអាក្រក់សុទ្ធតែបែងចែកមិនច្បាស់, មនុស្សខ្លះប្រាប់គាត់ថាលោកគឺកំពុងធ្វើរឿងអាក្រក់, គាត់មិនជឿ។ ដោយសារកម្រិតសីលធម៌របស់មនុស្សសុទ្ធតែកើតឡើងការផ្លាស់ប្រែរួចហើយ, មនុស្សខ្លះផលប្រយោជន៍មកមុន, ឲ្យតែអាចធ្វើបានលុយ, រឿងអ្វីក៏ធ្វើ។ គេមិនដើម្បីខ្លួន, មេឃសម្លាប់ដីបំផ្លាញ, សុទ្ធតែបានក្លាយជាបាវចនារួចហើយ។

ប៉េកាំងមានសិក្ខាកាមម្នាក់, ពេលល្ងាចញ៉ាំបាយរួចនាំកូនទៅឈានម៉ឺនដើម្បីដើរកម្សាន្ត, មើលឃើញមានឡានពាណិជ្ជកម្មកំពុងផ្សព្វផ្សាយលក់ឆ្នោត, កូនក្មេងសែនរំភើប, ចង់ទៅលេងឆ្នោត។ លេងក៏លេង, ឱ្យកូនក្មេងមួយរៀលដើម្បីលេង, លេងមួយត្រូវបានរង្វាន់ទី២, ទទួលបានកង់ប្រណិតមួយរបស់កូនក្មេង, កូនក្មេងរីករាយណាស់។ ក្នុងក្បាលគាត់ពេលនោះ [ងូង] បន្តិច៖ យើងជាមនុស្សហាត់គង់, ហេតុម្តេចអាចចំណង់របស់នេះ? យើងទទួលបានទ្រព្យសម្បត្តិអយុត្តិធម៌បាត់ហើយ, តើយើងត្រូវផ្តល់ឲ្យគាត់គុណធម៌ប៉ុន្មាន? និយាយចំពោះកូនថា៖ ពួកយើងមិនត្រូវការ, ពួកយើងប្រសិនត្រូវការទៅទិញដោយខ្លួនឯង។ កូនក្មេងមិនសប្បាយចិត្ត៖ ហៅពុកទិញពុកក៏មិនទិញឱ្យ, កូនខ្លួនឯងលេងបានពុកមិនឱ្យកូនយក។ យំផងស្រែកផងមិនព្រម, គ្មានវិធីណា, មានតែរុញត្រឡប់ទៅផ្ទះ។ បន្ទាប់ពីត្រឡប់មក, កាន់តែគិតកាន់តែពិបាកទ្រាំ, បម្រុងយកលុយទៅឱ្យពួកគេ។ តែគិតឡើងវិញ, ឆ្នោតក៏ឈប់លេងរួចហើយ, យើងយកលុយឲ្យទៅពួកគេ, តើពួកគេមិនយកទៅចែកគ្នា? បម្រុងយើងយកលុយទៅឧបត្ថម្ភឲ្យអង្គភាព។

សំណាងល្អនៅអង្គភាពមានសិក្ខាកាមហ្វាលូនតាហ្វាមិនតិច, ថ្នាក់ដឹកនាំក៏យល់គាត់បាន។ ប្រសិននៅក្នុងបរិយាកាសធម្មតា, អង្គភាពធម្ម

តា, លោកអ្នកនិយាយលោកអ្នកជាមនុស្សហាត់គង់, លេងឆ្នោតទទួលបានកង់មួយ, លោកអ្នកនិយាយលោកអ្នកមិនត្រូវការ, ចង់យកលុយឧបត្ថម្ភឲ្យអង្គភាព, ថ្នាក់ដឹកនាំសុទ្ធតែត្រូវគិតថាម្នាក់នេះស្មារតីមានជំងឺ។ អ្នកដទៃក៏ត្រូវតែពិភាក្សាជាច្រើនៈ ឯកជននេះហាត់គង់លេចឡើងគម្លាត, ឆ្កួតវង្វេងអារក្សចូលហើយឬ? ខ្ញុំសម្ដែងរួចហើយ, កម្រិតសីលធម៌បានកើតឡើងរមួលបត់រួចហើយ។ នៅសម័យទសវត្សរ៍៥០, ៦០, នេះចាត់ថារឿងអ្វី, ធម្មតាណាស់, នរណាក៏គ្មានអារម្មណ៍ភ្ញាក់ផ្អើល។

យើងខ្ញុំសម្ដែង, មិនខ្វល់កម្រិតសីលធម៌របស់មនុស្សជាតិកើតឡើងការផ្លាស់ប្រែប៉ុណ្ណា, តែចរិតពិសេសនេះរបស់ចក្រវាល-------សច្ចៈ, ករុណា, ខន្តិ, គាត់គឺមិនប្រែជានិច្ច។ មានមនុស្សនិយាយថាលោកអ្នកល្អ, លោកអ្នកមិនជាក់លាក់ពិតជាល្អ; មានមនុស្សនិយាយថាលោកអ្នកអាក្រក់, លោកអ្នកមិនជាក់លាក់ពិតជាអាក្រក់, ដោយសារបរមាណីយដើម្បីវាស់វែងល្អនិងអាក្រក់សុទ្ធតែបានកើតឡើងរមួលបត់រួចហើយ។ មានតែសមស្របនឹងចរិតពិសេសនេះរបស់ចក្រវាលគាត់ទើបជាមនុស្សល្អ, នេះគឺជាបរមាណីយតែមួយគត់ដើម្បីវាស់វែងមនុស្សល្អនិងអាក្រក់, នេះគឺបានទទួលស្គាល់ក្នុងចក្រវាល។ លោកអ្នកកុំឃើញថាសង្គមមនុស្សជាតិបានកើតឡើងការផ្លាស់ប្រែប៉ុណ្ណា, កម្រិតសីលធម៌របស់មនុស្សជាតិជម្រាលលើចំណោតធំ, ពិភពលោកកាន់តែអាក្រក់ទៅ, ផលចំណេញមកមុន, តែការផ្លាស់ប្រែរបស់ចក្រវាលក៏មិនមែនស្របតាមការផ្លាស់ប្រែរបស់មនុស្សជាតិហើយផ្លាស់ប្រែតាម។ ធ្វើជាមនុស្សបួសហាត់ម្នាក់គឺមិនអាចប្រើបរមាណីយរបស់មនុស្សសាមញ្ញទៅតម្រូវ។ មនុស្សសាមញ្ញនិយាយថារឿងរ៉ាវនេះត្រូវ, លោកអ្នកគឺយោងតាមនេះដើម្បីធ្វើ, នោះអាចមិនបាន។ មនុស្សសាមញ្ញនិយាយថាល្អក៏មិនជាក់លាក់គឺជា

ល្អ; មនុស្សសាមញ្ញនិយាយថាអាក្រក់ក៏មិនជាក់លាក់គឺជាអាក្រក់។ នៅសម័យកាលដែលបរមាណើយសីលធម៌បានរមួលបត់រួចហើយ, មនុស្សម្នាក់ធ្វើរឿងអាក្រក់, លោកអ្នកប្រាប់ថាគាត់គឺកំពុងធ្វើរឿងអាក្រក់, គាត់សុទ្ធតែមិនជឿ! ធ្វើជាមនុស្សបួសហាត់ម្នាក់, គឺត្រូវប្រើចរិតពិសេសនៃចក្រវាលដើម្បីវាស់វែង, ទើបអាចសម្គាល់ចេញអ្វីគឺជាល្អពិតប្រាកដនិងអាក្រក់ពិតប្រាកដ។

## ស្រោចកំពូល

នៅពិភពបួសហាត់មានកាលៈទេសៈមួយយ៉ាងនេះ, ហៅថាស្រោចកំពូល។ ស្រោចកំពូលជាទម្រង់សាសនាមួយនៃវិធីសាស្ត្របួសហាត់មីចុងរបស់ពុទ្ធវង្ស។ គោលបំណងគឺបន្ទាប់ពីឆ្លងកាត់ស្រោចកំពូលរួចហើយឯកជននេះគឺមិនអាចចូលទៅធម្មក្ខន្ធផ្សេងបានទៀត, គឺទទួលស្គាល់ជាសិស្សពិតប្រាកដនៃធម្មក្ខន្ធមួយនេះ។ បច្ចុប្បន្នចម្លែកនៅកន្លែងណា? ហាត់គង់ក៏លេចឡើងប្រភេទទម្រង់សាសនាមួយបែបនេះ, គង់ហ្វាតាវវង្សក៏ធ្វើស្រោចកំពូល, ក៏មិនគ្រាន់តែជាមីចុង។ ខ្ញុំសម្តែងរួចហើយ, ដរាបណាកាន់ទង់នាមមីចុងនៅលើសង្គមបង្រៀនគង់ហ្វាមីចុងទាំងស្រុងគឺជាក្លែងក្លាយ។ ហេតុអ្វីនិយាយដូច្នេះ? ដោយសារថាងមីនៅប្រទេសយើងបានរំលាយបាត់ជាងមួយពាន់ឆ្នាំរួចហើយ។ ជាមូលដ្ឋានគឺមិនស្ថិតនៅទៀត; ចាងមីដោយទទួលរងដែនកំណត់ភាសា, តែងតែគ្មានបង្រៀនចូលក្នុងតំបន់ដីជនជាតិហានពួកយើងបានពេញលេញ។ ជាពិសេសវាគឺជាសាសនាសម្ងាត់, ចាំបាច់នៅក្នុងវត្តអារាមបួសហាត់ដោយសម្ងាត់, លើសពីនេះនៅចាំបាច់ត្រូវតែឆ្លងកាត់ការបង្រៀនដោយសម្ងាត់ពីលោកគ្រូ, លោកគ្រូនាំគាត់ទៅបួសដោយសម្ងាត់។ ធ្វើមិនបានចំណុចមួយនេះ, គឺដាច់ខាតមិនអាចបង្រៀនចេញ។

មានមនុស្សជាច្រើនឱបយកគោលបំណងមួយបែបនេះឡើងទីបេទៅរៀនគង់, ចង់តាមគេសំពះគ្រូរៀនចាងមី, អនាគតធ្វើគ្រូឈីគង់, ល្បីឈ្មោះ, មានទ្រព្យសម្បត្តិ។ អ្នករាល់គ្នាគិតសាកមើល, ព្រះពុទ្ធរស់ឡាម៉ាពិតជាទទួលបានការបង្រៀនពិតប្រាកដសុទ្ធតែមានសីលគង់ដ៏ខ្លាំង, គឺអាចមើលចេញក្នុងចិត្តមនុស្សមករៀនគង់គិតអ្វី។ គាត់មកធ្វើអ្វី, មើលភ្លាមចិត្តនោះគឺយល់ច្បាស់រួចហើយ៖ ចង់ឡើងទីនេះដើម្បីរៀនប្រការនេះ, ចេញទៅធ្វើគ្រូឈីគង់មានទ្រព្យសម្បត្តិ, ល្បីឈ្មោះ, មកបំផ្លាញវិធីសាស្ត្របួសពុទ្ធរបស់ធម្មក្ខន្ធមួយនេះ។ ធម្មក្ខន្ធបួសពុទ្ធតឹងរឹងយ៉ាងនេះអាចទុកឱ្យលោកអ្នកធ្វើជាគ្រូឈីគង់អ្វីដើម្បីចំណង់កិត្តិនាមផលប្រយោជន៍បំផ្លាញតាមអំពើចិត្តឬ? លោកអ្នកមានបំណងអ្វី? ដូច្នេះគឺមិនអាចបង្រៀនគាត់ទាល់តែសោះ, មិនទទួលបានការបង្រៀនពិតប្រាកដ។ ប្រាកដណាស់, វត្តអារាមក៏ច្រើន, អាចទទួលបានអ្វីសំបកក្រៅមួយចំនួន។ ប្រសិនចិត្តមិនសុចរិត, ពេលដែលចង់ធ្វើគ្រូឈីគង់ហើយធ្វើរឿងអាក្រក់, នោះនឹងអន្ទងមកកាយភ្ជាប់។ កាយភ្ជាប់សត្វក៏មានគង់, ប៉ុន្តែមិនមែនជាចាងមី។ មនុស្សដែលពិតជាទៅទីបេចំណង់ធម៌, ឡើងទៅហើយអាចនៅជាប់ទីនោះមិនចេញមកទៀត, នេះគឺមនុស្សដែលបួសពិត។

ចម្លែក, បច្ចុប្បន្នមានគង់ហ្វាតាវវង្សជាច្រើនក៏សម្ដែងស្រោចកំពូល។ តាវវង្សគឺនាំតាមខ្សែវណ្ណ, តើធ្វើស្រោចកំពូលអី? តាមខ្ញុំដឹង, {ពេល}ខ្ញុំនៅភាគខាងត្បូងបង្រៀនគង់, ជាពិសេសតំបន់ក្វាងទុងនោះច្រើនបង្គួរ, មានប្រហែលជាងដប់គង់ហ្វារញ៉េវញ៉េសម្ដែងស្រោចកំពូល។ អត្ថន័យជាអ្វី? គាត់ស្រោចកំពូលឱ្យលោកអ្នក, លោកអ្នកជាក់ស្ដែងគឺជាកូនសិស្សរបស់គាត់, មិនអាចរៀនគង់ដទៃបានទៀត, រៀនគង់ដទៃគាត់នឹងដាក់ទោសលោកអ្នក, គាត់ធ្វើរឿងនេះ។ នេះមិនមែនធម្មក្ខន្ធទុច្ចរិត

តាវរៀចហើយឬ? គាត់សម្ដែងគឺប្រការព្យាបាលជំងឺកាយសម្បទា, បន្ទាប់ពីមហាជនរៀនហើយក៏គ្រាន់តែចង់បានរាងកាយមាំមួន។ ធ្វើរឿងនេះធ្វើអ្វី? មានមនុស្សសម្ដែង, ហាត់គង់របស់គាត់គឺមិនអាចហាត់គង់ដទៃបាន។ គាត់អាចប្រោសគេដល់សម្រេចបរិបូរឬ? នាំកូនសិស្សគេខុសផ្លូវហើយ! មនុស្សដ៏ច្រើនសុទ្ធតែធ្វើបែបនេះ។

តាវវង្សមិនសម្ដែងប្រការនេះ, ក៏បានលេចឡើងស្រោចកំពូលអីនោះ, ខ្ញុំរកឃើញថាគ្រូឈីគង់ធ្វើស្រោចកំពូលអស្ចារ្យបំផុត, សសរគង់របស់គាត់ខ្ពស់ប៉ុណ្ណា? គ្រាន់តែខ្ពស់ត្រឹមអគារពីរបីជាន់, គ្រូធំឈីគង់ដ៏ល្បីល្បាញ, ខ្ញុំឃើញថាគង់ធ្លាក់ចុះក៏ដ៏គួរឲ្យអាណិត។ មនុស្សរាប់រយរាប់ពាន់រៀបជាជួរ, គាត់ស្រោចកំពូលឱ្យគេ។ គង់របស់គាត់គឺមានកំណត់, គ្រាន់តែខ្ពស់ប៉ុណ្ណោះ, គង់នោះមួយភ្លែតនឹងធ្លាក់ចុះ, គ្មានទៀត, សួរថាប្រើអ្វីស្រោចឱ្យគេ, នោះមិនបញ្ឆោតគេឬ? ស្រោចកំពូលពិតប្រាកដ, មើលនៅក្នុងអវកាសផ្សេង, ឆ្អឹងរបស់គេពីក្បាលដល់ជើងសុទ្ធតែក្លាយជាសដូចយក់។ ជាក់ស្ដែងគឺប្រើគង់, សារធាតុថាមពលខ្ពស់បន្សុទ្ធរាងកាយ, ទាំងមូលពីក្បាលស្រោចដល់ជើង។ គ្រូឈីគង់នេះអាចធ្វើបានចំណុចមួយនេះឬ? គាត់ធ្វើមិនបាន។ គាត់ធ្វើអ្វី? ប្រាកដណាស់មិនជាក់លាក់សុទ្ធតែជាធ្វើសាសនា, គោលបំណងគឺរៀនគង់របស់គាត់រួចហើយ, ជាក់ស្ដែងគឺជាមនុស្សរបស់គាត់, លោកអ្នកត្រូវតែចូលរួមថ្នាក់របស់គាត់, រៀនសូត្រប្រការរបស់គាត់។ គោលបំណងគឺរកលុយនោះរបស់លោកអ្នក, គ្មាននរណារៀនគឺគាត់រកលុយមិនបាន។

សិស្សរបស់ហ្វាលូនតាហ្វាក៏ដូចនឹងសិស្សក្នុងធម្មក្ខន្ធពុទ្ធវង្សដទៃ, គឺបានគ្រូខាងលើស្រោចកំពូលឱ្យច្រើនដង, ប៉ុន្ដែមិនទុកឱ្យលោកអ្នកដឹង។ មនុស្សដែលមានសីលគង់អាចដឹងបាន, មនុស្សដែលឆាប់រសើប

ក៏អាចទទួលដឹងបាន, ពេលគេងឬនៅពេលណាមួយសុទ្ធតែអាចស្រាប់តែចរន្តក្តៅមួយពីលើកំពូលក្បាលចុះមកជ្រាបសព្វរាងកាយទាំងមូល។ គោលបំណងរបស់ស្រោចកំពូលមិនមែនផ្តល់គង់ថែមខ្ពស់ឲ្យលោកអ្នក, គង់គឺលោកអ្នកខ្លួនឯងបួសហាត់ចេញមក។ ស្រោចកំពូលជាប្រភេទវិធីសាស្រ្តពង្រឹងមួយ, ជាក់ស្តែងគឺបន្សុទ្ធរាងកាយឱ្យលោកអ្នក, ធ្វើឱ្យរាងកាយលោកអ្នកសម្អាតថែមមួយជំហាន។ ត្រូវការស្រោចច្រើនដង, រាល់ជាន់ថ្នាក់សុទ្ធតែត្រូវការជួយលោកអ្នកសម្អាតរាងកាយ។ ដោយសារបួសនៅខ្លួនឯង, គង់នៅលោកគ្រូ, ដូច្នេះយើងខ្ញុំក៏មិនសម្តែងប្រភេទទម្រង់ស្រោចកំពូលនេះ។

មានមនុស្សមួយចំនួននៅធ្វើអ្វីសំពះគ្រូ។ សម្តែងដល់ទីនេះ, ខ្ញុំគាប់ជួនលើកឡើងបន្តិច, មានមនុស្សជាច្រើនចង់សំពះខ្ញុំធ្វើគ្រូ។ សម័យប្រវត្តិសាស្រ្តនេះរបស់ពួកយើងបច្ចុប្បន្ននិងសង្គមសក្តិភូមិប្រទេសចិនមិនដូចគ្នា, លុតជង្គង់ទីនោះក្រាបក្បាលគឺចាត់ថាសំពះគ្រូ? ពួកយើងមិនធ្វើទម្រង់នេះ។ ពួកយើងមានមនុស្សជាច្រើនគឺគិតបែបនេះ៖ យើងក្រាបក្បាលអុជធូបសំពះព្រះពុទ្ធ, ក្នុងចិត្តស្មោះត្រង់បន្តិចគឺបង្កើនគង់។ ខ្ញុំនិយាយនោះពិតជាគួរឱ្យសើច, ហាត់គង់ពិតប្រាកដទាំងស្រុងពឹងផ្អែកលើខ្លួនឯងដើម្បីបួស, ចំណង់អ្វីក៏គ្មានប្រយោជន៍។ មិនចាំបាច់សំពះព្រះពុទ្ធ, មិនចាំបាច់អុជធូប, ពិតប្រាកដយោងតាមបរមាណើយរបស់មនុស្សបួសហាត់ដើម្បីបួសហាត់, គាត់ឃើញលោកអ្នកសុទ្ធតែដ៏សប្បាយចិត្ត។ លោកអ្នកនៅខាងក្រៅសុទ្ធតែធ្វើរឿងអាក្រក់, លោកអ្នកអុជធូបក្រាបក្បាលដល់គាត់, គាត់សម្លឹងមើលលោកអ្នកក៏ពិបាកទ្រាំ, មិនជាក់ស្តែងជាគោលសីលធម៌នេះឬ? បួសពិតត្រូវពឹងផ្អែកលើខ្លួនឯង។ ថ្ងៃនេះលោកអ្នកក្រាបក្បាលរួចហើយ, សំពះគ្រូរួចហើយ, ចេញពីទ្វារពេលណាគឺចង់

អីធ្វើនោះ, នោះមានប្រយោជន៍អ្វី? យើងខ្ញុំជាមូលដ្ឋានមិនសម្ដែងប្រភេទទម្រង់នេះ, លោកអ្នកអាចបំផ្លាញទាំងកេរ្តិ៍ឈ្មោះរបស់ខ្ញុំទៀតផង!

យើងខ្ញុំផ្ដល់ឲ្យអ្នករាល់គ្នាអ្វីច្រើនយ៉ាងនេះ, អ្នកទាំងអស់ដរាបណាបួសជាក់ស្ដែង, ហើយតឹងរឹងប្រើមហាធម៌ដើម្បីតម្រូវខ្លួនឯង, ខ្ញុំសុទ្ធតែចាត់ទុកលោកអ្នកណែនាំដូចជាសិស្ស, ដរាបណាលោកអ្នកបួសហាត់ហ្វាលូនតាហ្វា, យើងខ្ញុំគឺចាត់ទុកលោកអ្នកណែនាំដូចជាសិស្ស។ លោកអ្នកបើមិនបួស, យើងខ្ញុំគឺគ្មានវិធី។ លោកអ្នកមិនបួស, លោកអ្នកព្យួរឈ្មោះនោះមានប្រយោជន៍អ្វី? អ្វីសិក្ខាកាមអំឡុងពេលទី១, សិក្ខាកាមអំឡុងពេលទី២, លោកអ្នកគ្រាន់តែហាត់ចលនានេះជាក់ស្ដែងគឺជាសិស្សរបស់យើងខ្ញុំ? លោកអ្នកត្រូវតែពិតប្រាកដយោងតាមបរមាណើយចិត្តចរិតនេះរបស់យើងខ្ញុំដើម្បីបួសហាត់, ទើបអាចសម្រេចបានរាងកាយសម្បទា, ទើបអាចពិតប្រាកដដើរឆ្ពោះឡើងជាន់ថ្នាក់ខ្ពស់។ ដូច្នេះយើងខ្ញុំមិនសម្ដែងទម្រង់ទាំងនេះ, ដរាបណាលោកអ្នកបួសហាត់, ជាក់ស្ដែងគឺជាមនុស្សក្នុងធម្មក្ខន្ធនេះរបស់យើងខ្ញុំ។ បរមីរបស់ខ្ញុំអ្វីក៏ដឹង, លោកអ្នកគិតអ្វីគាត់សុទ្ធតែដឹង, អ្វីគាត់សុទ្ធតែអាចធ្វើបាន។ លោកអ្នកមិនបួសហាត់គាត់មិនគ្រប់គ្រងលោកអ្នក, លោកអ្នកបួសហាត់នឹងជួយដល់ទីបញ្ចប់។

ក្នុងគង់ហ្វាខ្លះមនុស្សហាត់គង់ក៏មិនដែលបានជួបលោកគ្រូ, និយាយថាបែរមុខសំដៅទៅទិសណាមួយក្រាបក្បាល, សងលុយប៉ុន្មានរយគឺបានហើយ។ នេះមិនមែនបោកខ្លួនបោកមនុស្សហើយឬ? លើសពីនេះទៀតឯកជននេះក៏ស្ម័គ្រចិត្តណាស់, ពីពេលនេះតទៅរក្សាការពារចំពោះគង់នោះ, មនុស្ស(ក្នុងគង់)នោះ, ក៏ប្រាប់អ្នកដទៃ, មិនអាចរៀនគង់ផ្សេងបាន។ ខ្ញុំមើលឃើញគឺដ៏គួរឲ្យសើច។ នៅមានមនុស្សធ្វើអ្វីស្វាប

កំពូល, ក៏មិនដឹងថាគាត់ស្ទាបមួយផ្តើមផលប៉ះពាល់អ្វី។

មិនគ្រាន់តែជាកាន់ទង់នាមរបស់មីចុងដើម្បីបង្រៀនគង់គឺជាក្លែងក្លាយ, ធម្មក្ខន្ធទាំងអស់ដែលកាន់{ទង់នាម}ពុទ្ធសាសនាដើម្បីបង្រៀនគង់ក៏ជាក្លែងក្លាយ។ អ្នករាល់គ្នាគិតសាកមើល, វិធីសាស្ត្របួសហាត់ប៉ុន្មានពាន់ឆ្នាំមករបស់ពុទ្ធសាសនាជាក់ស្តែងគឺជាប្រភេទទម្រង់នោះ, នរណាដែលផ្លាស់ប្តូរ{វា}ទៅតើនៅជាពុទ្ធសាសនាឬ? វិធីសាស្ត្របួសហាត់គឺជាបួសពុទ្ធដោយតឹងរឹង, លើសពីនេះទៀតគឺយ៉ាងអស្ចារ្យអាថ៌កំបាំងបំផុត, ផ្លាស់ប្តូរបន្តិចគឺរញ៉េរញ៉ៃភ្លាម។ ដោយសារដំណើរការវិវត្តន៍របស់គង់គឺយ៉ាងស្មុគស្មាញបំផុត, អារម្មណ៍របស់មនុស្សមិនជាអ្វីទាំងអស់, មិនអាចពឹងផ្អែកលើអារម្មណ៍ដើម្បីបួសហាត់។ ទម្រង់សាសនារបស់ព្រះសង្ឃជាក់ស្តែងគឺជាវិធីសាស្ត្របួសហាត់, ផ្លាស់ប្តូរកាលណាគឺមិនមែនប្រការនៃធម្មក្ខន្ធមួយនោះទៀត។ រាល់មួយធម្មក្ខន្ធសុទ្ធតែមានអង្គមហាត្រាស់ដឹងជាអធិបតី, រាល់មួយធម្មក្ខន្ធក៏បួសចេញអង្គមហាត្រាស់ដឹងដ៏ច្រើន, នរណាក៏មិនហ៊ានផ្លាស់ប្តូរតាមអំពើចិត្តវិធីសាស្ត្របួសហាត់របស់ធម្មក្ខន្ធមួយនោះ, ហើយគ្រូតូចឈីគង់ម្នាក់, មានអធិកភាពគុណធម៌អ្វីហ៊ានមាក់ងាយម្ចាស់ផ្លាស់ប្តូរធម្មក្ខន្ធបួសពុទ្ធ? ឧបមាពិតជាអាចផ្លាស់ប្តូរ, នោះនៅជាធម្មក្ខន្ធមួយនោះឬ? ឈីគង់ក្លែងក្លាយគឺអាចសម្គាល់ចេញបាន។

## ទ្វារអាថ៌កំបាំងកំណត់ទី

ទ្វារអាថ៌កំបាំងកំណត់ទីក៏បានហៅថាទ្វារអាថ៌កំបាំងមួយឈាវ, នៅក្នុង《តានជិញ》,《តាវចាង》,《ស៊ីញមិញហ្វួយជី》 អាចរកឃើញនាមសព្ទបែបនេះ។ ដូច្នោះវាជារឿងដូចម្តេច? មានគ្រូឈីគង់ដ៏ច្រើននិយាយមិនច្បាស់លាស់។ ដោយសារជាន់ថ្នាក់បិតនៅរបស់គ្រូឈី

គង់ធម្មតាជាមូលដ្ឋានមិនអាចមើលឃើញ, ក៏មិនអនុញ្ញាតឱ្យគាត់មើលឃើញ។ មនុស្សប្អូសហាត់ចង់អាចមើលឃើញវា, នៅជាន់លើនៃបញ្ញាចក្ខុវិស័យឡើងទៅទើបអាចមើលឃើញបាន, គ្រូឈីគង់ធម្មតាមិនទាន់សម្រេចបានជាន់ថ្នាក់នេះ, ដូច្នេះមើលមិនឃើញ។ ពិភពប្អូសហាត់ពីដើមមកកំពុងរុករកពិភាក្សាទ្វារអាថ៌កំបាំងជាអ្វី? មួយឈាវនៅទីណា? កំណត់ទីបែបណា? លោកអ្នកមើលក្នុង《តានជិញ》,《តាវចាង》,《ស៊ីញមិញហ្វួយជី》, វាសុទ្ធតែសម្តែងវិលជុំវិញទ្រឹស្តី, ជាមូលដ្ឋានសុទ្ធតែមិននិយាយនឹងលោកអ្នកធាតុពិត។ សម្តែងមកសម្តែងទៅ, នៅតែសម្តែងធ្វើឲ្យលោកអ្នកច្រឡំ, សម្តែងមិនច្បាស់លាស់, ដោយសារប្រការនៃធាតុពិតគឺមិនទុកឲ្យមនុស្សសាមញ្ញដឹងបាន។

ក្រៅពីនេះខ្ញុំប្រាប់អ្នករាល់គ្នា, ដោយសារលោកអ្នកជាសិស្សហ្វាលូនតាហ្វាយើងខ្ញុំ, ខ្ញុំទើបប្រាប់លោកអ្នកពាក្យបែបនេះ៖ ដាច់ខាតកុំទៅមើលសៀវភៅឈីគង់ក្លែងក្លាយរញ៉េរញ៉ៃទាំងនោះ, មិនមែនសៀវភៅបុរាណប៉ុន្មានក្បាលខាងលើ, គឺនិយាយសៀវភៅឈីគង់ក្លែងក្លាយដែលមនុស្សបច្ចុប្បន្នសរសេរ, លោកអ្នកសូម្បីតែបើកក៏កុំបើក។ ក្នុងខួរក្បាលលោកអ្នកស្ទួចស្ទើងមានគំនិតមួយលេចឡើងកាលណា៖ អ៊ំាយយោ, ប្រយោគនេះសមហេតុផល។ គំនិតនេះចាំងឡើងកាលណា, កាយភ្ជាប់ខាងក្នុងនោះគឺនឹងឡើងមក។ ដ៏ច្រើនគឺដោយសារកាយភ្ជាប់បញ្ជា, គ្របសង្កត់ចិត្តកិត្តិនាមផលប្រយោជន៍របស់មនុស្សដើម្បីសរសេរ។ សៀវភៅរបស់គ្រូឈីគង់ក្លែងក្លាយមានជាច្រើន, ច្រើនណាស់, មនុស្សដ៏ច្រើនគាត់គឺមិនទទួលទំនួលខុសត្រូវ, មានកាយភ្ជាប់មួយចំនួន, រញ៉េរញ៉ៃគាត់ក៏សរសេរ។ ជាក់ស្តែងគឺសៀវភៅបុរាណប៉ុន្មានក្បាលខាងលើឬក៏សៀវភៅបុរាណមានទាក់ទងធម្មតាក៏កុំអានល្អជាង, ទីនេះមានបញ្ហាឯក

ទេសតែមួយគត់មិនចលាចល។

មេដឹកនាំសមាគមឈីគង់ប្រទេសចិនម្នាក់និយាយប្រាប់ខ្ញុំរឿងរ៉ាវមួយ, ធ្វើឱ្យខ្ញុំក៏អស់សំណើចយ៉ាងខ្លាំង។ និយាយថាប៉េកាំងមានឯកជនយ៉ាងនេះ, គាត់ឧស្សាហ៍ទៅស្ដាប់មេសម្ដែងរបស់គ្រូឈីគង់, ស្ដាប់មកស្ដាប់ទៅ, ស្ដាប់ពេលវេលាយូរ, គាត់មានអារម្មណ៍ថាឈីគង់ជាក់ស្ដែងគឺជាល្បែងក្មេងលេងទាំងនេះ។ ដោយសារសុទ្ធតែនៅក្នុងមួយជាន់ថ្នាក់, សុទ្ធតែសម្ដែងប្រការទាំងនេះ។ គាត់និងគ្រូឈីគង់ក្លែងក្លាយទាំងនោះដូចគ្នា, សន្មតថាអត្ថន័យរបស់ឈីគង់គឺជាទាំងនេះ! ដូច្នោះល្អ, គាត់ក៏ចង់សរសេរសៀវភៅឈីគង់។ អ្នករាល់គ្នាគិតសាកមើល, មនុស្សមិនហាត់គង់សរសេរសៀវភៅឈីគង់, សៀវភៅឈីគង់បច្ចុប្បន្នជាក់ស្ដែងគឺលោកអ្នកចម្លងគាត់, គាត់ចម្លងលោកអ្នក។ គាត់សរសេរមកសរសេរទៅ, សរសេរដល់កន្លែងទ្វារអាថ៌កំបាំងនេះគឺសរសេរតមិនបានទៀត។ ទ្វារអាថ៌កំបាំងនរណាយល់ច្បាស់ហ្ន៎? គ្រូឈីគង់ពិតប្រាកដក៏គ្មានប៉ុន្មាននាក់យល់ច្បាស់។ គាត់ក៏បានសួរគ្រូឈីគង់ក្លែងក្លាយម្នាក់។ គាត់មិនដឹងគឺជាក្លែងក្លាយ, ដើមមកគាត់ក៏មិនយល់ឈីគង់ផងដែរ។ ប៉ុន្តែគ្រូឈីគង់ក្លែងក្លាយនេះប្រសិនទុកឲ្យគេសួរគាំង, គេមិនមែនដឹងថាគាត់ជាក្លែងក្លាយហើយឬ? ដូច្នេះគាត់ហ៊ាននិយាយផ្ដេសផ្ដាស, និយាយថាទ្វារអាថ៌កំបាំងមួយឈាវនៅលើចុងក្បាលនោម។ ស្ដាប់ទៅដ៏គួរឲ្យសើច។ លោកអ្នកក៏កុំសើច, សៀវភៅនេះនៅលើសង្គមក៏បោះពុម្ពរួចហើយ។ ជាក់ស្ដែងគឺនិយាយថា, សៀវភៅឈីគង់របស់ពួកយើងបច្ចុប្បន្នសុទ្ធតែគួរឲ្យសើចដល់កម្រិតនេះរួចហើយ, លោកអ្នកនិយាយមើលលោកអ្នកអានរបស់នោះមានប្រយោជន៍អ្វី, គ្មានប្រយោជន៍, គ្រាន់តែអាចធ្វើបាបមនុស្ស។

អ្វីហៅថាទ្វារអាថ៌កំបាំងកំណាត់ទី? មនុស្សពេលបួសហាត់នៅក្នុងលោកីយ៍ធម៌, ពេលដែលបួសដល់ជាន់កណ្ដាលឡើងទៅ, ពោលគឺពេលដែលបួសហាត់នៅលើជាន់ថ្នាក់ខ្ពស់នៃលោកីយ៍ធម៌, មនុស្សគឺចាប់ផ្ដើមលេចឡើងទារកអមតៈ។ ទារកអមតៈគឺខុសគ្នាជាមួយទារកដែលយើងខ្ញុំនិយាយ។ ទារកតូចណាស់, លោតជុំវិញដោយអំណរ, រពឹសណាស់។ ទារកអមតៈមិនកម្រើក, វិញ្ញាណដើមមិនទៅធ្វើម្ចាស់គាត់, គាត់អង្គុយនៅទីនោះមិនកម្រើក, ដៃភ្ជាប់ត្រា, បត់ស្នើជើងអង្គុយនៅលើផ្កាឈូក។ ទារកអមតៈបង្កើតចេញនៅលើតានធាន, នៅក្រោមយ៉ាងអតិសុខុមបំផុតពេលដែលតូចជាងចុងម្ជុលគឺអាចមើលឃើញគាត់។

ក្រៅពីនេះនិយាយច្បាស់បញ្ហាមួយ, តានធានពិតប្រាកដតែមួយដុំ, នៅទីតាំងពោះក្រោម។ ស្ទៀវ៉ីហួយយីនឡើងទៅ, នៅក្នុងរាងកាយរបស់មនុស្ស, ពីពោះក្រោមចុះក្រោម, ជាក់ស្ដែងគឺជាដុំធាននេះ។ គង់ដ៏ច្រើន, សីលគង់ដ៏ច្រើន, ប្រការនៃសិល្ប៍សាស្ត្រដ៏ច្រើន, បរមី, ទារកអមតៈ, ទារក, កាយជីវិតដ៏ច្រើន, សុទ្ធតែបង្កើតពីដុំធាននេះ។

អតីតកាលមានមនុស្សបួសតាវដោយឡែកសម្ដែងអំពីទ្រឹស្ដីតានធានលើ, តានធានកណ្ដាល, តានធានក្រោម, ខ្ញុំនិយាយនោះគឺជាខុស។ ក៏មានខ្លះនិយាយថាគ្រូរបស់គាត់បានបង្រៀនប៉ុន្មានជំនាន់រួចហើយ, ក្នុងសៀវភៅក៏សរសេរយ៉ាងនេះ។ ខ្ញុំប្រាប់អ្នករាល់គ្នា, របស់សំណល់អង្គាមកន្ទក់នេះសម័យបុរាណសុទ្ធតែមាន, លោកអ្នកកុំឃើញស្នងបង្រៀនប៉ុន្មានឆ្នាំក្ដី, វាក៏មិនជាក់លាក់គឺជាត្រូវ។ តាវតូចលោកីយ៍ក៏រហូតកំពុងផ្សព្វផ្សាយនៅក្នុងមនុស្សសាមញ្ញ, ប៉ុន្តែវាបួសមិនបាន, ក៏មិនមែនជាអ្វី។ គាត់យកវាហៅថាតានធានលើ, តានធានកណ្ដាល, តានធានក្រោម, បង្កប់ន័យរបស់គាត់នោះគឺកន្លែងអាចបង្កើតតានជាក់ស្ដែង

គឺជាតានធាន។ នេះមិនមែនកំប្លែងឬ? គំនិតរបស់មនុស្សប្រមូលផ្តុំចូលចំណុចមួយ, ពេលវេលាយូរ, គឺអាចសាងបង្កើតក្រុមថាមពល, បង្កតាន។ មិនជឿ, គំនិតរបស់លោកអ្នករមែងនៅលើដើមដៃ, រមែងរក្សាយ៉ាងនេះ, ពេលវេលាយូរ, វានឹងបង្កតាន។ ដូច្នេះមនុស្សខ្លះមើលឃើញរឿងរ៉ាវនេះ, និយាយថាគ្មានទីណាគ្មានតានធាន, ស្តាប់ទៅកាន់តែគួរឱ្យសើច, យល់ដឹងរបស់គាត់គឺបង្កតានរួចហើយជាក់ស្តែងគឺជាតានធាន។ ភាពពិតវាគឺជាតានតែមិនមែនធាន, គាត់និយាយគ្មានទីណាគ្មាន [តាន] ឬក៏តានលើ, តានកណ្តាល, តានក្រោម, និយាយយ៉ាងនេះផ្ទុយមកវិញគឺអាច។ ហើយធានពិតប្រាកដនោះដែលអាចបង្កើតចេញធម៌ច្រើនរាប់មិនអស់មានតែមួយដុំ, ជាក់ស្តែងគឺដុំធាននោះនៅទីតាំងពោះក្រោម។ ដូច្នេះការថ្លែងតានធានលើ, តានធានកណ្តាល, តានធានក្រោមគឺខុសឆ្គង។ គំនិតរបស់មនុស្សរក្សានៅទីណា, ពេលវេលាយូរ, គឺនឹងបង្កជាតាន។

ទារកអមតៈគឺបង្កើតចេញមកពីដុំតានធាននោះនៅទីតាំងពោះក្រោម, សន្សឹមៗមួយថ្ងៃកាន់តែធំ។ ពេលដែលធំប៉ុនបាល់ប៉េងប៉ុងយ៉ាងនោះ, ទម្រង់ក្រៅរាងកាយទាំងមូលសុទ្ធតែមើលឃើញច្បាស់លាស់រួចហើយ, ច្រមុះ, ភ្នែកសុទ្ធតែបង្កើតរួចហើយ។ ក្នុងពេលដំណាលគ្នាធំដូចបាល់ប៉េងប៉ុងយ៉ាងនោះ, ក្បែរខ្លួនគាត់បានបង្កើតចេញថង់តូចមួយមូលៗ។ បន្ទាប់ពីបង្កើតស្របតាមទារកអមតៈធំឡើង, វាក៏ធំឡើងតាម។ នៅពេលដែលទារកអមតៈធំឡើងដល់កម្ពស់៤ធុនយ៉ាងនេះ, គឺលេចឡើងផ្កាឈូកមួយស្រទាប់។ ចាំពេលធំឡើងដល់កម្ពស់៥ទៅ៦ធុនយ៉ាងនេះ, ស្រទាប់ផ្កាឈូកជាមូលដ្ឋានពេញវ័យរួចហើយ, ផ្កាឈូកមួយជាន់បានលេចឡើង, ទារកអមតៈចាំងពន្លឺមាសអង្គុយនៅក្នុងកន្សោមផ្កាឈូកពណ៌មាស, ស្អាតណាស់។ នោះជាក់ស្តែងគឺជាកាយ

ជីនកាងមិនអាចបំផ្លាញ, ពុទ្ធវង្សហៅថាពុទ្ធកាយ; តាវវង្សហៅថាទារកអមតៈ។

ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំសុទ្ធតែបួសហាត់ប្រភេទរាងកាយទាំងពីរ, សុទ្ធតែត្រូវការ, រាងកាយដើមក៏ត្រូវការបំប្លែង។ អ្នករាល់គ្នាបានដឹង, ពុទ្ធកាយនោះគឺមិនអាចលាតត្រដាងនៅក្នុងមនុស្សសាមញ្ញ, ប្រើកម្លាំងខ្លាំងបំផុតអាចលាតត្រដាងរូបសណ្ឋានចេញមក, ប្រើភ្នែករបស់មនុស្សសាមញ្ញអាចមើលឃើញបានពន្លឺស្រមោលរបស់គាត់។ ហើយរាងកាយនេះ, បន្ទាប់ពីឆ្លងកាត់បំប្លែងរួចហើយ, នៅក្នុងមនុស្សសាមញ្ញដូចគ្នានឹងមនុស្សសាមញ្ញ, មនុស្សសាមញ្ញមើលមិនចេញ, គាត់ក៏អាចឆ្លងកាត់អវកាស។ នៅពេលដែលទារកអមតៈធំឡើងដល់កម្ពស់៤ទៅ៥ធុន, ថង់ឈីក៏ធំឡើងដល់កម្ពស់យ៉ាងនេះ, វាគឺដូចបេះបិទសំបកប៉េតប៉ោង, គឺថ្លាយង់។ ទារកអមតៈអង្គុយសមាធិមិនកម្រើក។ ពេលដែលដល់ធំយ៉ាងនេះ, ថង់ឈីនេះគឺនឹងឃ្លាតចេញពីតានធាន, វាបានបង្កើតរួចហើយ, {ដូច}ឪឡឹកទុំជ្រុះទង, ដូច្នេះគឺនឹងថ្មើងឡើង។ ដំណើរការថ្មើងឡើងគឺជាដំណើរការយឺតយូរខ្លាំងណាស់, ប៉ុន្តែរាល់ថ្ងៃសុទ្ធតែអាចមើលឃើញវាកំពុងចល័ត។ បន្តិចម្តងៗចល័តឆ្ពោះឡើង, ថ្មើងឆ្ពោះឡើង។ ពួកយើងសង្កេតដោយយកចិត្តទុកដាក់នឹងទទួលដឹងបានអត្ថិភាពរបស់វា។

នៅពេលដែលថ្មើងឡើងដល់ទីតាំងស្បៀវ៉ិតានជុងរបស់មនុស្ស, វានឹងស្នាក់នៅកន្លែងនេះមួយដំណាក់កាលពេលវេលា។ ដោយសារសារៈរបស់រាងកាយមនុស្ស, មានរបស់ជាច្រើន (បេះដូងក៏នៅកន្លែងនេះ) សុទ្ធតែត្រូវការនៅក្នុងថង់ឈីនេះបង្កើតជាមួយសំណុំ។ របស់សារៈត្រូវការធ្វើឲ្យសម្បូរទៅក្នុងថង់ឈីនោះរបស់វា។ បន្ទាប់ពីឆ្លងកាត់មួយដំណាក់កាលពេលវេលា, វាម្តងទៀតចាប់ផ្តើមថ្មើងឡើង។ នៅពេលឆ្លងកាត់ក

របស់មនុស្ស, មានអារម្មណ៍ថាតឹងដង្ហើម, ហាក់ដូចជាសរសៃឈាមសុទ្ធតែជាប់គាំង, ហើមឡើងដ៏ពិបាកទ្រាំ, គឺជាយ៉ាងនោះមួយឬពីរថ្ងៃនឹងធ្លងផុត។ ហើយវាមកដល់កំពូលក្បាល, យើងខ្ញុំហៅថាឡើងនីវ៉ាន។ និយាយគឺដល់នីវ៉ាន, ភាពពិតវាធំប៉ុននឹងខួរធំទាំងមូលរបស់លោកអ្នក, លោកអ្នកនឹងមានអារម្មណ៍ក្បាលហើមឡើង។ ដោយសារនីវ៉ានជាកន្លែងដ៏គន្លឹះរបស់ជីវិតមនុស្ស, វាក៏ត្រូវការបង្កើតជារបស់សារៈនៅខាងក្នុង។ ក្រោយមកវាគឺពីផ្លូវរន្ធនេះរបស់ភ្នែកទិព្វរុញចេញក្រៅ, រសជាតិនោះគឺដ៏ពិបាកទ្រាំ។ ភ្នែកទិព្វដែលហើមឡើងឈឺណាស់, ស្មៀរីថៃយ៉ាងក៏ហើមឡើង, ភ្នែកក៏ផតចូលក្នុង, រហូតដល់វារុញចេញមក។ មួយរំពេចគឺព្យួរនៅកន្លែងខាងមុខថ្ងាសនេះ, នេះគឺបានហៅថាទ្វារអាថ៌កំបាំងកំណាត់ទី, ព្យួរនៅទីនេះ។

មនុស្សបើកភ្នែកទិព្វរួចហើយ, ដល់ពេលនេះគឺមើលមិនឃើញទៀត។ ដោយសារបួសហាត់នៃពីរវង្សពុទ្ធនិងតាវ, ដើម្បីទុកឱ្យរបស់ខាងក្នុងទ្វារអាថ៌កំបាំងបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន, ទ្វារនោះមិនបើក។ ខាងមុខមានទ្វារធំពីរបន្ទះ, ខាងក្រោយមានទ្វារពីរបន្ទះ, សុទ្ធតែបិទ, ដូចជាទ្វារចូលរបស់ធានអានម៉ឺននៅប៉េកាំង, សងខាងម្ខាងមានទ្វារធំពីរបន្ទះ។ ដើម្បីទុកឱ្យវា{បាន}កកើតនិងបំពេញបន្ថែមលឿនបំផុត, ដូច្នេះទ្វារមិននៅក្រោមកាលៈទេសៈយ៉ាងពិសេសបំផុតមិនបើក, ភ្នែកទិព្វអាចមើល, ដល់ជំហានមួយនេះក៏មើលមិនឃើញទៀត, មិនអនុញ្ញាតឱ្យមើល។ គោលបំណងវាព្យួរនៅទីនេះគឺដើម្បីធ្វើអ្វី? ដោយសាររាប់រយខ្សែវណ្ណនៃរាងកាយរបស់ពួកយើងប្រសព្វគ្នាពីទីនេះ, ដូច្នោះពេលនេះរាប់រយខ្សែវណ្ណសុទ្ធតែត្រូវឆ្លងកាត់ទ្វារអាថ៌កំបាំងមួយជុំហើយចេញទៅ, សុទ្ធតែត្រូវការដើរ{ឆ្លង}ទ្វារអាថ៌កំបាំង, គោលបំណងគឺនៅ

ខាងក្នុងទ្វារអាថ៌កំបាំងម្តងទៀតដាក់ឡើងមូលដ្ឋានមួយចំនួន, បង្កើតជារបស់មួយសំណុំនេះ។ ដោយសាររាងកាយមនុស្សជាក់ស្តែងគឺជាចក្រវាលតូច, វានឹងបង្កើតជាពិភពតូចមួយ, ទាំងអស់របស់សារៈនៃរាងកាយមនុស្សសុទ្ធតែបង្កើតនៅខាងក្នុង។ ប៉ុន្តែវាគ្រាន់តែជាកកើតឧបករណ៍មួយសំណុំ, នៅមិនអាចអនុវត្តបានទាំងស្រុង។

បួសហាត់គង់ហ្វាទ្វារវិសេស, ទ្វារអាថ៌កំបាំងគឺបើក។ ពេលដែលទ្វារអាថ៌កំបាំងបាញ់ចេញមក, គឺជាបំពង់ត្រង់, ប៉ុន្តែសន្សឹមៗក៏នឹងប្រែជាមូល, ដូច្នេះទ្វារសងខាងរបស់វាគឺបើក។ ដោយសារគង់ហ្វាទ្វារវិសេសមិនបួសពុទ្ធក៏មិនបួសតាវ, ខ្លួនឯងការពារខ្លួនឯង។ គ្រូនៃពីរវង្សពុទ្ធនិងតាវមានជាច្រើន, សុទ្ធតែអាចការពារលោកអ្នក, មិនចាំបាច់លោកអ្នកមើល, ក៏នឹងមិនលេចឡើងបញ្ហា។ ហើយគង់ហ្វាទ្វារវិសេសគឺមិនបាន, គាត់ត្រូវតែខ្លួនឯងការពារខ្លួនឯង, ដូច្នេះគាត់ត្រូវចាំបាច់រក្សាអាចមើល។ ប៉ុន្តែពេលនោះភ្នែកទិព្វមើលរបស់អ្វី, គឺដូចជាមើលតាមរយៈបំពង់ត្រង់របស់កែវយឺត។ ក្រោយមកបន្ទាប់ពីបង្កើតជាសំណុំរបស់នេះរួចហើយ, ប្រហែលជាមួយខែវាគឺចាប់ផ្តើមត្រឡប់មក។ បន្ទាប់ពីត្រឡប់ចូលក្នុងក្បាល, នោះហៅថាទ្វារអាថ៌កំបាំងប្តូរទី។

ពេលដែលត្រឡប់ទៅក៏ហើមឡើងពិបាកទ្រាំ, ក្រោយមកគឺពីស្មៀរ៉ុយ្វីច្ចិនរបស់មនុស្សរុញចេញមក។ រសជាតិដែលរុញចេញមកក៏ដ៏ពិបាកទ្រាំ, ស្រដៀងក្បាលបំបែកចេញ, មួយភ្លែតគឺចេញមក, វាចេញមកពេលណាជាបន្ទាន់គឺមានអារម្មណ៍ធូរស្បើយ។ បន្ទាប់ពីចេញមក, វាព្យួរនៅក្នុងអវកាសដ៏ជ្រៅ, ស្ថិតនៅក្នុងទម្រង់រាងកាយនោះនៅអវកាសដ៏ជ្រៅ, ដូច្នេះគេងសង្កត់មិនដល់វា។ ប៉ុន្តែមានចំណុចមួយ, នៅពេលទ្វារអាថ៌កំបាំងកំណាត់ទីលើកទីមួយខាងមុខភ្នែកមានអារម្មណ៍, ទោះបីវានៅអវ

កាសមួយផ្សេង, តែរមែងមានអារម្មណ៍ខាងមុខភ្នែកស្រអាប់, ហាក់ដូចជាស្រដៀងមានរបស់អ្វីបិទបាំង, មិនសូវសុខស្រួល។ ដោយសារស្មៀរ៉ិយ្យីច្ចិនជាទ្វារធំមួយដ៏គន្លឹះ, នៅខាងក្រោយក៏ត្រូវការបង្កើតជារបស់មួយសំណុំ, វាម្តងទៀតចាប់ផ្តើមត្រឡប់ទៅ។ ទ្វារអាថ៌កំបាំងមួយឈាវនេះភាពពិតមិនមែនជាមួយឈាវ, វាត្រូវការផ្លាស់ទីច្រើនដង។ បន្ទាប់ពីវាត្រឡប់ដល់នីវ៉ានចាប់ផ្តើមទម្លាក់ចុះ, ពីខាងក្នុងរាងកាយទម្លាក់ចុះ, រហូតដល់ស្មៀរ៉ិមិញម៉ឺន។ នៅស្មៀរ៉ិមិញម៉ឺនវាម្តងទៀតបាញ់ចេញមក។

មិញម៉ឺនរបស់មនុស្សគឺជាឈាវធំដែលចម្បងយ៉ាងគន្លឹះបំផុត, តាវវង្សហៅថា "ឈាវ", យើងខ្ញុំហៅថា "ទ្វារ"។ ទ្វារធំមួយចម្បង, នោះពិតជាទ្វារដែក, ជាន់ទ្វារដែករាប់មិនអស់។ អ្នករាល់គ្នាបានដឹងរាងកាយមានច្រើនជាន់, កោសិការាងកាយសាច់របស់ពួកយើងបច្ចុប្បន្នគឺមួយជាន់, ម៉ូលេគុលខាងក្នុងគឺមួយជាន់, អាតូម, ប្រូតុង, អេឡិចត្រុង, តូចគ្មានទីបញ្ចប់, តូចគ្មានទីបញ្ចប់, តូចគ្មានទីបញ្ចប់, ដល់ភាគល្អិតយ៉ាងតូចបំផុត, មុខនីមួយៗសុទ្ធតែដាក់មួយជាន់ទ្វារ។ ដូច្នេះមានសីលគង់ដ៏ច្រើន, របស់សិល្ប៍សាស្ត្រដ៏ច្រើន, សុទ្ធតែត្រូវបានចាក់សោនៅខាងក្នុងបណ្តាជាន់ទ្វារ។ គង់ហ្វាដទៃហាត់តាន, ពេលដែលតានត្រូវការផ្ទុះបែក, មុនដំបូងត្រូវតែរញ្ជួយបើកមិញម៉ឺន, ប្រសិនវាមិនរញ្ជួយបើក, សីលគង់គឺដោះលែងចេញមិនបាន។ បន្ទាប់ពីទ្វារអាថ៌កំបាំងនៅលើស្មៀរ៉ិមិញម៉ឺនបង្កើតជារបស់សំណុំនេះរួចហើយ, វាម្តងទៀតឈានចូលក្នុង។ បន្ទាប់ពីឈានចូលក្នុងគឺចាប់ផ្តើមត្រឡប់មកដល់ទីតាំងពោះក្រោម, នេះហៅថាទ្វារអាថ៌កំបាំងត្រឡប់មកទី។

បន្ទាប់ពីត្រឡប់មកទី, មិនមែនវិលមកដល់កន្លែងដើមរបស់វា។ ពេលនោះទារកអមតៈបានលូតលាស់ធំណាស់រួចហើយ, ចង់ឈើគឺគ្រប

នៅលើទារកអមតៈ, ស្រោបព័ទ្ធទារកអមតៈ។ ទារកអមតៈធំឡើង, វាក៏ធំឡើងតាម។ ទារកអមតៈរបស់តាវវង្សធម្មតាធំឡើងប៉ុនរូបរាងកូនក្មេងអាយុ៦ទៅ៧ឆ្នាំ, គឺអនុញ្ញាតឱ្យគាត់ឃ្លាតពីកាយ, ហៅថា "ទារកអមតៈចាប់កំណើត"។ ដោយសារវិញ្ញាណដើមរបស់មនុស្សធ្វើម្ចាស់គាត់, គាត់គឺអាចចេញមកធ្វើសកម្មភាព។ រាងកាយរបស់មនុស្សសម្ងំនៅទីនោះមិនកម្រើក, វិញ្ញាណដើមចេញមក។ ធម្មតាពេលដែលទារកអមតៈរបស់ពុទ្ធវង្សប្បួសហាត់ដល់ធំប៉ុននឹងរាងកាយនេះគឺមិនគ្រោះថ្នាក់ទៀត។ តាមធម្មតាពេលនេះអនុញ្ញាតឱ្យគាត់ឃ្លាតពីកាយ, ផ្តាច់ចេញពីរាងកាយនេះ, អាចចេញមក។ ពេលនោះ, ទារកអមតៈធំឡើងប៉ុននឹងរាងកាយនេះ, គម្របក៏ធំ, គម្របនោះក៏ពង្រីកធំដល់ខាងក្រៅរាងកាយ, ជាក់ស្តែងគឺជាទ្វារអាថ៌កំបាំងនោះ។ ដោយសារទារកអមតៈក៏ធំយ៉ាងនេះ, វាប្រាកដណាស់គឺពង្រីកដល់ខាងក្រៅរាងកាយ។

អ្នករាល់គ្នាអាចមើលឃើញពុទ្ធរូបក្នុងវត្ត, មើលឃើញពុទ្ធរូបតែងតែនៅខាងក្នុងរង្វង់មួយ, ជាពិសេសគឺពុទ្ធរូបក្នុងគំនូរ, តែងតែមានរង្វង់មូល, ព្រះពុទ្ធអង្គុយខាងក្នុង។ ពុទ្ធរូបដ៏ច្រើនសុទ្ធតែជាបែបនេះ, ជាពិសេសគឺពុទ្ធរូបក្នុងគំនូរក្នុងវត្តបុរាណ, សុទ្ធតែជាបែបនេះ។ ហេតុអ្វីអង្គុយនៅក្នុងរង្វង់មូលហ្នំ, នរណាក៏និយាយមិនច្បាស់លាស់។ ខ្ញុំប្រាប់អ្នករាល់គ្នា, ជាក់ស្តែងគឺជាទ្វារអាថ៌កំបាំងនេះ។ តែឥឡូវវាបានមិនហៅថាទ្វារអាថ៌កំបាំងទៀត, ហៅថាពិភព, នៅតែមិនអាចដោយមែនទែនហៅថាពិភព។ វាមានតែសំណុំឧបករណ៍នេះ, គឺដូចជារោងចក្ររបស់ពួកយើងមានមួយសំណុំឧបករណ៍, ប៉ុន្តែគ្មានសមត្ថភាពផលិត, ចាំបាច់មានប្រភពថាមពល, បន្ទាប់ពីមានវត្ថុធាតុដើម, វាទើបអាចផលិតបាន។ ប៉ុន្មានឆ្នាំមុនមានមនុស្សប្បួសហាត់ជាច្រើនសម្តែង៖ ខ្ញុំមានគង់ខ្ពស់ជាងពោធិ

សត្វ, ខ្ញុំមានគង់ខ្ពស់ជាងព្រះពុទ្ធ, អ្នកដទៃស្តាប់ហើយមានអារម្មណ៍ដ៏អាថ៌កំបាំង។ ភាពពិតគាត់សម្តែងបន្តិចក៏មិនអាថ៌កំបាំង, គង់មែនទែនគឺនៅលោកីយ៍ហាត់បានខ្ពស់ណាស់។

នោះហេតុអ្វីលេចឡើងកាលៈទេសៈនេះ, បួសសម្រេចហើយតើនៅខ្ពស់ជាងព្រះពុទ្ធឬអត់? មិនអាចពន្យល់នៅលើផ្ទៃបែបនេះ, គង់របស់គាត់មែនទែនដ៏ខ្ពស់។ ដោយសារបន្ទាប់ពីគាត់បួសឡើងដល់លើជាន់ថ្នាក់ដ៏ខ្ពស់, ពេលដែលសម្រេចបានបើកគង់ត្រាស់ដឹងរបស់គាត់, គង់មែនទែនគឺដ៏ខ្ពស់។ គឺនៅមួយសន្ទុះនោះពេលមុនគាត់បើកគង់ត្រាស់ដឹង, យក៨ភាគ១០គង់របស់គាត់ខ្លួនឯងកាច់ចុះមកឱ្យគាត់, សូម្បីតែបរមាណីយចិត្តចរិតរបស់គាត់ក៏ត្រូវតែកាត់ចុះមក។ ប្រើថាមពលនេះដើម្បីបំពេញបន្ថែមពិភពនេះរបស់គាត់, ពិភពរបស់គាត់ខ្លួនឯង។ លោកអ្នកដឹងថាគង់នេះរបស់មនុស្សបួសហាត់, ជាពិសេសរបស់ដែលថែមឡើងបរមាណីយចិត្តចរិត, គឺមនុស្សមួយជីវិតបានរងទុក្ខរាប់មិនអស់, ហាត់ពត់នៅក្រោមបរិយាកាសទុក្ខពិបាក, បួសហាត់ចេញមក, ដូច្នេះវាគឺយ៉ាងដ៏មានតម្លៃបំផុត, យកចេញ៨ភាគ១០របស់ដ៏មានតម្លៃយ៉ាងនេះមកធ្វើឲ្យសម្បូរពិភពរបស់គាត់។ ដូច្នេះអនាគតពេលដែលគាត់បួសសម្រេច, ចង់បានអ្វីលាតដៃបានភ្លាម, ចង់អីមាននោះ, ចង់ធ្វើអីគឺធ្វើនោះ, នៅក្នុងពិភពរបស់គាត់អ្វីក៏មាន។ នេះជាអធិកភាពគុណធម៌របស់គាត់, ខ្លួនឯងឆ្លងកាត់រងទុក្ខបួសចេញមក។

ប្រភេទថាមពលនេះរបស់គាត់អាចប្រែទៅជាអ្វីមួយតាមចិត្ត។ ដូច្នេះព្រះពុទ្ធចង់បានអ្វី, ចង់ញុាំអ្វី, លេងអ្វី, អ្វីក៏មាន, នេះគឺគាត់ខ្លួនឯងបួសចេញមក, ជាក់ស្តែងគឺពុទ្ធផលញាណ, គ្មានរបស់នេះគាត់បួសមិនសម្រេច។ ពេលនេះ, អាចហៅវាថាជាពិភពមួយរបស់ខ្លួនឯង, ហើយ

គាត់នៅសល់តែ២ភាគ១០គង់ដើម្បីសម្រេចបរិបូរ, សម្រេចតាវ។ ទោះបីនៅសល់តែ២ភាគ១០, ប៉ុន្តែរាងកាយរបស់គាត់គ្មានត្រូវចាក់សោ, ឬក៏ជាមិននាំតាមរាងកាយ, ឬក៏នាំតាមរាងកាយ, ប៉ុន្តែរាងកាយត្រូវបានសារធាតុថាមពលខ្ពស់បំប្លែងរួចហើយ, ពេលនោះទេពអំណាចគាត់មហាបង្ហាញ, ឫទ្ធិអំណាចគ្មានផ្ទឹម។ ហើយពេលដែលបួសហាត់នៅក្នុងមនុស្សសាមញ្ញជាញឹកញាប់គឺត្រូវបានចាក់សោ, គ្មានអានុភាពធំយ៉ាងនោះ, គង់ខ្ពស់ដល់ណាក៏នឹងទទួលរងកំហិត, បច្ចុប្បន្នគឺមិនដូចទៀត។

# មេសម្ដែងទី៥

## និមិត្តរូបហ្វាលូន

រូបសម្គាល់របស់ហ្វាលូនតាហ្វាពួកយើងគឺជាហ្វាលូន។ មនុស្សមានសីលគង់, អាចមើលឃើញហ្វាលូននេះកំពុងបង្វិល, មេដាយហ្វាលូនតូចនោះរបស់ពួកយើងក៏ដូចគ្នាផងដែរ, វាកំពុងបង្វិល។ ពួកយើងគឺយោងតាមចរិតពិសេសសច្ចៈ-ករុណា-ខន្តីនៃចក្រវាល, ដើម្បីដឹកនាំការបួសហាត់របស់ពួកយើង។ យោងតាមគោលការណ៍វិវត្តន៍នៃចក្រវាលដើម្បីហាត់, ដូច្នេះគង់នេះដែលពួកយើងហាត់បានគឺធំណាស់។ ពីលើអត្ថន័យណាមួយដើម្បីសម្ដែង, និមិត្តរូបហ្វាលូននេះគឺជារូបភាពបង្រួមតូចរបស់ចក្រវាល។ ពុទ្ធវង្សចាត់ទុកពិភព១០ទិសដូចជាទស្សនាទានមួយ{អំពី}ចក្រវាល, ៤មុខ៨ទិស, ៨ទិសា។ អាចមានមនុស្សខ្លះអាចមើលឃើញលើក្រោមរបស់គាត់ស្ថិតនៅសសរគង់មួយ, ដូច្នេះថែមឡើងលើក្រោម, គាប់ជួនពិភព១០ទិស, ផ្សំឡើងចក្រវាលនេះ, តំណាងឱ្យចក្រវាលនិយាយរួមដែលពុទ្ធវង្សទទួលស្គាល់។

ប្រាកដណាស់ក្នុងចក្រវាលនេះមានកញ្ចុំផ្កាយច្រើនរាប់មិនអស់, រួមបញ្ចូលទាំងប្រព័ន្ធកញ្ចុំផ្កាយរបស់ពួកយើងនៅខាងក្នុង។ ចក្រវាលទាំងមូលកំពុងធ្វើចលនា, កញ្ចុំផ្កាយទាំងអស់ក្នុងចក្រវាលទាំងមូលក៏សុទ្ធតែកំពុងធ្វើចលនា, ដូច្នេះថៃជីនិងនិមិត្តសញ្ញាអក្សរ 卍 តូចខាងក្នុងនិមិត្តរូបនេះក៏កំពុងបង្វិល, ហ្វាលូនទាំងមូលក៏កំពុងបង្វិល, ហើយនិមិត្តសញ្ញាអក្សរ 卍 ធំនៅកណ្ដាលក៏កំពុងបង្វិល។ ពីលើអត្ថន័យណាមួយដើម្បីសម្ដែង, នេះតំណាងឲ្យប្រព័ន្ធកញ្ចុំផ្កាយរបស់ពួកយើង, ក្នុងពេលដំណាលគ្នាក៏ដោយសារពួកយើងគឺជាពុទ្ធវង្ស, ដូច្នេះមជ្ឈមណ្ឌលគឺជា

និមិត្តសញ្ញារបស់ពុទ្ធវង្ស, នេះគឺមើលនៅលើផ្ទៃ។ សារធាតុខុសគ្នាទាំងអស់សុទ្ធតែមានទម្រង់អត្ថិភាពនៅអវកាសផ្សេង, នៅក្នុងអវកាសដទៃគឺជាទម្រង់អត្ថិភាពនិងដំណើរការវិវត្តន៍មួយដែលយ៉ាងសម្បូរបំផុត, យ៉ាងស្មុគស្មាញបំផុត។ និមិត្តរូបហ្វាលូននេះគឺជារូបភាពបង្រួមតូចរបស់ចក្រវាល, នៅរាល់អវកាសខុសគ្នាគាត់ក៏មានទម្រង់អត្ថិភាពនិងដំណើរការវិវត្តន៍របស់គាត់, ដូច្នេះខ្ញុំនិយាយនោះជាពិភពមួយ។

ពេលដែលហ្វាលូនបង្វិលបណ្តោយទ្រនិចនាឡិកា, អាចស្រូបយកថាមពលក្នុងចក្រវាលដោយស្វ័យប្រវត្តិ; ពេលដែលបង្វិលបញ្ច្រាសទ្រនិចនាឡិកា, អាចបញ្ចេញថាមពល។ បង្វិលខាងក្នុង (បណ្តោយទ្រនិចនាឡិកា) ប្រោសខ្លួនឯង, បង្វិលខាងក្រៅ (បញ្ច្រាសទ្រនិចនាឡិកា) ប្រោសមនុស្ស, គឺជាចរិតពិសេសនៃគង់ហ្វារបស់ពួកយើង។ មានមនុស្សនិយាយថា៖ ពួកយើងជាពុទ្ធវង្ស, ហេតុអ្វីនៅមានថៃជី? ថៃជីនេះមិនមែនតាវវង្សហើយឬ? ដោយសារគង់របស់ពួកយើងហាត់បានធំណាស់, ដែលហាត់បានស្មើនឹងជាចក្រវាលទាំងមូល។ ដូច្នោះអ្នករាល់គ្នាគិតសាកមើល, ក្នុងចក្រវាលនេះមានពីរវង្សធំ, ពុទ្ធនិងតាវពីរវង្សធំ, ដកចេញវង្សណាមួយសុទ្ធតែផ្សំឡើងមិនបានចក្រវាលទាំងមូល, សុទ្ធតែមិនអាចនិយាយជាចក្រវាលទាំងមូលបាន, ដូច្នេះពួកយើងទីនេះក៏មានប្រការរបស់តាវវង្ស។ មានមនុស្សសម្តែងថា៖ នោះក៏មិនគ្រាន់តែជាតាវវង្ស, នៅមានអ្វីគ្រិស្តសាសនា, ខុងជឺសាសនា, សាសនាដទៃ។ល។ ខ្ញុំប្រាប់អ្នករាល់គ្នា, ខុងជឺសាសនាបួសហាត់ដល់ជាន់ថ្នាក់យ៉ាងខ្ពស់បំផុត, វាគឺត្រូវបានចាត់ថ្នាក់ជាតាវវង្ស; ហើយទិសខាងលិចមានសាសនាជាច្រើនបន្ទាប់ពីបួសហាត់ដល់ជាន់ថ្នាក់ខ្ពស់, វាគឺត្រូវបានចាត់ថ្នាក់ជាពុទ្ធវង្ស, វាគឺស្ថិតក្នុងខ្សែប្រព័ន្ធតែមួយនឹងពុទ្ធវង្ស។ គឺជាខ្សែ

ប្រព័ន្ធធំពីរយ៉ាងនេះ។

នោះហេតុអ្វីថៃជីនៅមានលើក្រហមក្រោមខៀវពីរ, នៅមានលើក្រហមក្រោមខ្មៅពីរទៀត? ការយល់ដឹងធម្មតារបស់ពួកយើង, សន្មតថាថៃជីគឺដោយបានប្រភេទសារធាតុពីរខ្មៅនិងសផ្សំឡើង, ឈីទាំងពីរអវិជ្ជមាននិងវិជ្ជមាន។ នោះគឺឈរនៅក្នុងជាន់ថ្នាក់មួយដ៏រាក់ដើម្បីយល់ដឹង, នៅអវកាសខុសគ្នាមានការបង្ហាញនៃអវកាសខុសគ្នា។ បង្ហាញនៅក្នុងជាន់ថ្នាក់ខ្ពស់បំផុត, ពណ៌របស់គាត់ជាក់ស្តែងគឺជាបែបនេះ។ តាវដែលពួកយើងធម្មតាសន្មតជាក់ស្តែងគឺជាប្រភេទពណ៌លើក្រហមក្រោមខ្មៅនេះ។ លើកឧទាហរណ៍និយាយ, ពួកយើងមានមនុស្សមួយចំនួនបើកភ្នែកទិព្វរួចហើយ, រកឃើញថាប្រើភ្នែកមើលឃើញគឺជាពណ៌ក្រហម, នៅក្នុងអវកាសផ្សេងខុសតែមួយជាន់មើលឃើញគាត់ផ្ទុយមកវិញគឺជាពណ៌បៃតង។ ពណ៌លឿងមាសនោះនៅក្នុងអវកាសផ្សេងមើលរកឃើញថាផ្ទុយមកវិញគឺជាពណ៌ស្វាយ, គាត់មានភាពផ្ទុយខុសគ្នាបែបនេះ, ពោលគឺពណ៌នៃអវកាសខុសគ្នាក៏កើតឡើងការប្រែប្រួលខុសគ្នា។ ថៃជីលើក្រហមក្រោមខៀវគឺស្ថិតក្នុងមហាតាវពីដើមកំណើត, រួមបញ្ចូលទាំងគង់ហ្វាបួសហាត់ទ្វារវិសេស។ និមិត្តសញ្ញាអក្សរ 卍 នៅ៤មុខគឺជាពុទ្ធវង្ស, នេះដូចគ្នានឹង{និមិត្តសញ្ញា}នៅកណ្តាល, សុទ្ធតែជាពុទ្ធវង្ស។ ពណ៌របស់ហ្វាលូននេះភ្លឺស្រស់បង្គួរ, យើងខ្ញុំយកគាត់ធ្វើជាសញ្ញាសម្គាល់របស់ហ្វាលូនតាហ្វា។

អ្នករាល់គ្នាពួកយើងតាមរយៈភ្នែកទិព្វមើលឃើញហ្វាលូនក៏មិនជាក់លាក់ជាប្រភេទពណ៌នេះ, ពណ៌ផ្ទៃខាងក្រោយអាចផ្លាស់ប្តូរ, ប៉ុន្តែគំនូរនឹងមិនផ្លាស់ប្តូរ។ ពេលហ្វាលូនដែលខ្ញុំដំឡើងឱ្យលោកអ្នកនៅទីតាំងពោះក្រោមកំពុងបង្វិល, ភ្នែកទិព្វលោកអ្នកមើលឃើញអាចជា

ក្រហម, អាចជាស្វាយ, អាចជាបៃតង, ក៏អាចជាគ្មានពណ៌ផងដែរ។ ក្រហម, ទឹកក្រូច, លឿង, បៃតង, ផ្ទៃមេឃ, ខៀវ, ស្វាយ, ពណ៌ផ្ទៃខាងក្រោយរបស់គាត់កំពុងបន្តផ្លាស់ប្តូរពណ៌, ដូច្នេះដែលលោកអ្នកមើលឃើញអាចជាពណ៌ផ្សេង, ប៉ុន្តែពណ៌របស់គំនូរនិមិត្តសញ្ញាអក្សរ 卍 និងផៃដីនៅខាងក្នុងនឹងមិនផ្លាស់ប្តូរ។ យើងខ្ញុំមានអារម្មណ៍ថាពណ៌របស់គំនូរនេះស្អាតបង្គួរ, យើងខ្ញុំក៏យកគាត់កំណត់មកវិញ។ មនុស្សដែលមានសីលគង់អាចឆ្លងធ្លុះជាន់អវកាសនេះមើលឃើញប្រការដ៏ច្រើន។

មានមនុស្សនិយាយថា៖ និមិត្តសញ្ញាអក្សរ 卍 នេះហាក់ដូចជាវត្ថុនោះរបស់អ៊ីទ្លែរ។ {ខ្ញុំ}សម្តែងជាមួយអ្នករាល់គ្នា, និមិត្តសញ្ញានេះខ្លួនវាគ្មានទស្សនាទានវណ្ណៈអ្វី។ មានមនុស្សនិយាយថា៖ មុំនេះប្រសិនបត់ទៅខាងនេះជាក់ស្តែងគឺជាវត្ថុរបស់អ៊ីទ្លែរ។ មិនមែនជាដូច្នេះ, ទាំងសងខាងសុទ្ធតែជាបង្វិល។ សង្គមមនុស្សជាតិពួកយើងបានយល់ដឹងគំនូរនេះជាទូទៅគឺនៅ២៥០០ឆ្នាំមុន, គឺនៅសម័យសក្យមុនីបានយល់ដឹងអំពីគាត់រួចហើយ។ អ៊ីទ្លែរពេលដែលសង្គ្រាមលោកលើកទី២ដល់បច្ចុប្បន្នទើបតែប៉ុន្មានសិបឆ្នាំ, គាត់គឺបានលួចប្រើរបស់នេះ។ ប៉ុន្តែពណ៌របស់វានិងពួកយើងខុសគ្នា, វាគឺជាពណ៌ខ្មៅ, លើសពីនេះទៀតវាគឺឆ្ពោះក្បាលស្រួចឡើងលើ, បញ្ឈរឡើង, ប្រើបញ្ឈរ។ ហ្វាលូននេះសម្តែងតែប៉ុណ្ណេះ, យើងខ្ញុំគ្រាន់តែសម្តែងទម្រង់នៅលើផ្ទៃរបស់គាត់។

ដូច្នោះនិមិត្តសញ្ញាអក្សរ 卍 នេះនៅពុទ្ធវង្សពួកយើងចាត់ទុកជាអ្វី? មានមនុស្សនិយាយថាជាសំណាងល្អដូចបំណង, នេះគឺជាការពន្យល់ក្នុងមនុស្សសាមញ្ញ។ ខ្ញុំប្រាប់អ្នករាល់គ្នា, និមិត្តសញ្ញាអក្សរ 卍 ជារូបសញ្ញានៃជាន់ថ្នាក់របស់ព្រះពុទ្ធ, មានតែសម្រេចបានជាន់ថ្នាក់របស់ព្រះពុទ្ធទើបមាន។ ពោធិសត្វ, អរហន្តមិនមាន, ប៉ុន្តែមហាពោធិសត្វ,

៤មហាពោធិសត្វសុទ្ធតែមាន។ យើងខ្ញុំមើលឃើញមហាពោធិសត្វទាំងនេះសុទ្ធតែបានហួសផុតសែនឆ្ងាយពីជាន់ថ្នាក់របស់ព្រះពុទ្ធធម្មតារួចហើយ, សូម្បីតែខ្ពស់ជាងទាំងយូឡាយ។ ព្រះពុទ្ធដែលជាន់ថ្នាក់ហួសផុតយូឡាយច្រើនលេខរាប់មិនអស់។ យូឡាយមាននិមិត្តសញ្ញាអក្សរ 卍 តែមួយ, សម្រេចបានជាន់ថ្នាក់យូឡាយឡើងទៅ, និមិត្តសញ្ញាអក្សរ 卍 គឺច្រើនជាង។ ហួសផុតយូឡាយទ្វេដងនឹងមាននិមិត្តសញ្ញាអក្សរ 卍 ពីរ, ហួសផុតទៀតនឹងមាន៣, ៤, ៥។ល។ ច្រើនពេញរាងកាយក៏មាន។ លើក្បាល, លើក្បាលស្មា, លើក្បាលជង្គង់សុទ្ធតែនឹងលេចឡើង; ពេលថៃមមិនបានទៀត, បាតដៃ, ប្រអប់បាតដៃ, បាតជើង, ប្រអប់បាតជើងគ្រប់ទីកន្លែងសុទ្ធតែនឹងលេចឡើង។ ស្របតាមជាន់ថ្នាក់បន្តលើកកម្ពស់, និមិត្តសញ្ញាអក្សរ 卍 នឹងបន្តកើនឡើងច្រើន, ដូច្នេះនិមិត្តសញ្ញាអក្សរ 卍 គឺតំណាងឱ្យជាន់ថ្នាក់របស់ព្រះពុទ្ធ, ជាន់ថ្នាក់ព្រះពុទ្ធកាន់តែខ្ពស់, និមិត្តសញ្ញាអក្សរ 卍 គឺកាន់តែច្រើន។

## គង់ហ្វាទ្វារវិសេស

ក្រៅពីគង់ហ្វានៃពីរវង្សពុទ្ធនិងតាវ, នៅមានគង់ហ្វាទ្វារវិសេស, គាត់ហៅខ្លួនឯងថាបួសហាត់ទ្វារវិសេស។ ចំពោះគង់ហ្វាបួសហាត់មនុស្សសាមញ្ញធម្មតាពួកយើងមានការយល់ដឹងបែបនេះ៖ ប្រទេសចិនតាំងពីបុរាណរហូតដល់បច្ចុប្បន្ន, គេសន្មតថាគង់ហ្វានៃពីរវង្សពុទ្ធនិងតាវគឺជាវិធីសាស្ត្របួសហាត់ផ្លូវការ, ក៏ហៅវាថាជាបួសហាត់ធម្មក្ខន្ធសុចរិត។ គង់ហ្វាទ្វារវិសេសនេះគឺពីដើមមកមិនធ្លាប់បានប្រកាសដល់ពិភពលោក, មនុស្សតិចតួចណាស់ដឹងអំពីអត្ថិភាពរបស់វា, គ្រាន់តែជាធ្លាប់ឮនិយាយក្នុងស្នាដៃសិល្បៈប៉ុណ្ណោះ។

មានគង់ហ្វាទ្វារវិសេសដែរឬអត់? មាន។ ខ្ញុំនៅក្នុងដំណើរការបួស

ហាត់, ជាពិសេសគឺប៉ុន្មានឆ្នាំក្រោយមកខ្ញុំធ្លាប់ជួបប្រទះអធិជន៣រូបក្នុងទ្វារវិសេស, បានបង្រៀនឱ្យខ្ញុំសារៈក្នុងធម្មក្ខន្ធរបស់ពួកគាត់, ប្រការសែនពិសេសមានតែមួយ, សែនល្អ។ ជាក់ស្តែងគឺដោយសារប្រការរបស់គាត់ដ៏ពិសេសមានតែមួយ, ដូច្នេះប្រការដែលហាត់ចេញមកក៏សែនចម្លែក, មនុស្សធម្មតាមិនអាចពន្យល់បាន។ លើសពីនេះទៀតនៅសម្តែងប្រយោគមួយ, ហៅថាមិនមែនពុទ្ធមិនមែនតាវ, មិនបួសពុទ្ធ, មិនបួសតាវ។ គេពេលស្តាប់ឮមិនបួសពុទ្ធក៏មិនបួសតាវ, ក៏យកវាហៅថាទ្វារចំហៀងផ្លូវឆ្វេង, វាខ្លួនឯងហៅថាគង់ហ្វាទ្វារវិសេស។ ហៅទ្វារចំហៀងផ្លូវឆ្វេងគឺមានន័យចំអក, តែគ្មានន័យថាជំទាស់, មិនមែននិយាយថាវាគឺជាទុច្ចរិតធម៌, ចំណុចមួយនេះគឺបញ្ជាក់។ ពន្យល់នៅលើផ្ទៃអក្សរក៏គ្មានបង្កប់ន័យថាទុច្ចរិតធម៌។ ពីដើមមកគង់ហ្វាពុទ្ធនិងតាវបានហៅថាបួសហាត់ធម្មក្ខន្ធសុចរិត, ពេលដែលប្រភេទគង់ហ្វានេះរបស់វាមិនត្រូវបានគេយល់ដឹង, គេនិយាយថាវាគឺជាទ្វារចំហៀង, ទ្វារនៅម្ខាង, មិនមែនធម្មក្ខន្ធចម្បង។ នោះផ្លូវឆ្វេងវិញ? ឆ្វេងបង្កប់ន័យថាល្ងីល្ងើ, ល្ងង់ខ្លៅ។ ឆ្វេង, នៅក្នុងនាមសព្ទប្រទេសចិនបុរាណជាញឹកញាប់យកវានិយាយក្លាយជាល្ងីល្ងើ, ទ្វារចំហៀងផ្លូវឆ្វេងមានបង្កប់ន័យមួយជាន់បែបនេះ។

ហេតុអ្វីវាមិនមែនទុច្ចរិតធម៌? ដោយសារវាក៏មានតម្រូវចិត្តចរិតតឹងរឹង, វាក៏យោងតាមចរិតពិសេសនៃចក្រវាលដើម្បីបួសហាត់, វាក៏មិនបំពានចរិតពិសេសនៃចក្រវាល, បទច្បាប់នៃចក្រវាល, វាក៏មិនធ្វើរឿងអាក្រក់, ដូច្នេះមិនអាចនិយាយថាវាគឺជាទុច្ចរិតធម៌។ មិនមែនដោយសារចរិតពិសេសនៃចក្រវាលនេះរបស់ពួកយើងសមស្របនឹងវិធីសាស្ត្របួសហាត់របស់ពីរវង្សពុទ្ធនិងតាវ, ហើយគឺវិធីសាស្ត្របួសហាត់របស់ពីរវង្សពុទ្ធនិងតាវវិញទេសមស្របនឹងចរិតពិសេសនៃចក្រវាល, ទើបក្លាយជា

សុចរិតធម៌។ បួសហាត់របស់គង់ហ្វាទ្វារវិសេសប្រសិនសមស្របនឹងចរិតពិសេសនៃចក្រវាលនេះ, ដូច្នោះវាក៏មិនមែនទុច្ចរិតធម៌, ដូចគ្នាគឺជាសុចរិតធម៌, ដោយសារបរមាណីយវាស់វែងល្អនិងអាក្រក់, ករុណានិងកំណាចគឺជាចរិតពិសេសនៃចក្រវាល។ វាយោងតាមចរិតពិសេសនៃចក្រវាលដើម្បីបួស, ដូច្នេះវាក៏ជាផ្លូវសុចរិត, គ្រាន់តែលក្ខណៈតម្រូវរបស់វាខុសគ្នានឹងពីរវង្សពុទ្ធនិងតាវ។ វាក៏មិនសម្តែងបង្រៀនសិស្សទូលំទូលាយ, ផ្ទៃក្រឡាដែលបង្រៀនតូចណាស់។ តាវវង្សបង្រៀនគង់, បង្រៀនកូនសិស្សមួយចំនួនធំ, ប៉ុន្តែក្នុងនោះមានតែសិស្សម្នាក់គត់គឺបានបង្រៀនពិតប្រាកដ; ពុទ្ធវង្សសម្តែងប្រោសសត្វលោកទាំងឡាយ, នរណាអាចបួសអ្នកនោះបួស។

គង់ហ្វាទ្វារវិសេសនៅក្នុងការស្វែងបង្រៀនក៏មិនអាចរកមនុស្សពីរនាក់, ហើយគឺនៅកាលសម័យប្រវត្តិសាស្រ្តយូរបង្គួរទើបជ្រើសកំណត់បានឯកជនម្នាក់ដើម្បីបង្រៀន, ដូច្នេះប្រការនោះរបស់វាពីដើមមកសុទ្ធតែមិនអាចត្រូវបានមនុស្សសាមញ្ញមើលឃើញ។ ប្រាកដណាស់នៅក្នុងកម្រិតខ្ពស់បំផុតរបស់ឈើគង់, ខ្ញុំរកឃើញថាមានមនុស្សមួយផ្នែកតូចក្នុងគង់ហ្វានេះក៏ចេញមកបង្រៀនគង់។ ប៉ុន្តែបង្រៀនមកបង្រៀនទៅគាត់រកឃើញថាមិនបាន, ដោយសារមានប្រការមួយចំនួនគ្រូរបស់គាត់ជាមូលដ្ឋានគឺមិនអនុញ្ញាតឲ្យគាត់បង្រៀន។ ប្រសិនលោកអ្នកចង់បង្រៀនគង់, លោកអ្នកគឺមិនអាចរើសមនុស្ស, មនុស្សដែលមក, ចិត្តចរិតខ្ពស់ទាបនៅក្នុងជាន់ថ្នាក់ខុសគ្នា។ ឱបតាមគោលគំនិតខុសគ្នាមករៀន, មនុស្សបែបណាក៏មាន, លោកអ្នកគឺមិនអាចរើសកូនសិស្សដើម្បីបង្រៀន។ ដូច្នេះគង់ហ្វាទ្វារវិសេសជាសកលមិនបាន, ងាយស្រួលលេចឡើងគ្រោះថ្នាក់, ដោយសារប្រការនោះរបស់វាដ៏ពិសេស។

មានមនុស្សគិតថា, ពុទ្ធវង្សបួសពុទ្ធ, តាវវង្សបួសអង្គសច្ចំ, គង់ហ្វាទ្វារវិសេសនោះបួសសម្រេចរួចហើយចាត់ថាជាអ្វី? គាត់ជាអាទិទេពដើរទេសចរណ៍, គាត់គ្មានវិសាលភាពនៃពិភពចក្រវាលកំណត់។ អ្នករាល់គ្នាដឹងថា, ព្រះពុទ្ធយូឡាយ, សក្យមុនីមានពិភពសហ; ព្រះពុទ្ធអាមីធូរមានពិភពសុខៈ; ព្រះពុទ្ធយ៉ាវស្ទឺមានពិភពកញ្ចក់ពណ៌; គ្រប់យូឡាយនិងមហាពុទ្ធមានពិភពរបស់ខ្លួនឯង។ អង្គមហាត្រាស់ដឹងនីមួយៗសុទ្ធតែមានឋានសួគ៌ដែលគាត់ខ្លួនឯងចាត់ចែង, កូនសិស្សដ៏ច្រើនរបស់គាត់រស់នៅខាងក្នុង។ ហើយគង់ហ្វាទ្វារវិសេសវាគ្មានវិសាលភាពចក្រវាលកំណត់, គាត់គ្រាន់តែដូចជាអាទិទេពដើរកំសាន្តគ្មានទីកំណត់។

## ហាត់ទុច្ចរិតធម៌

ហាត់ទុច្ចរិតធម៌ជាអ្វី? មានប៉ុន្មានទម្រង់យ៉ាងនេះ៖ មានប្រភេទមនុស្សមួយគឺជំនាញក្នុងការហាត់ទុច្ចរិតធម៌, ដោយសារប្រការនេះនៅសម័យប្រវត្តិសាស្រ្តក៏មានមនុស្សបង្រៀន។ ហេតុអ្វីបង្រៀនរបស់ទាំងនេះ? ដោយសារគាត់ស្វែងរកកិត្តិនាម, ផលប្រយោជន៍, មានទ្រព្យសម្បត្តិក្នុងមនុស្សសាមញ្ញ, គាត់សម្តែងប្រការទាំងនេះ។ ប្រាកដណាស់ចិត្តចរិតរបស់គាត់មិនខ្ពស់, ដូច្នេះគាត់មិនទទួលបានគង់។ គាត់ទទួលបានអ្វី? អំណាចកម្ម។ ពេលដែលអំណាចកម្មរបស់មនុស្សធំ, ក៏នឹងបង្កជាប្រភេទថាមពលមួយ។ ប៉ុន្តែគាត់គ្មានជាន់ថ្នាក់, គាត់ប្រៀបជាមួយមនុស្សហាត់គង់គឺប្រៀបមិនបាន, ប៉ុន្តែប្រៀបនឹងមនុស្សសាមញ្ញផ្ទុយមកវិញអាចរឹតត្បិតលើមនុស្សសាមញ្ញ។ ដោយសាររបស់នេះក៏ជាភាពបង្ហាញនៃប្រភេទថាមពលមួយ, ពេលដែលដង់ស៊ីតេដ៏ធំ, ក៏អាចធ្វើឲ្យសីលគង់របស់រាងកាយមនុស្សខ្លាំងឡើង, ក៏អាចផ្តើមផលប៉ះពាល់បែបនេះ, ដូច្នេះពីដើមមកក៏មានមនុស្សមួយចំនួនបង្រៀនប្រការទាំងនេះ។

គាត់និយាយថា៖ ខ្ញុំធ្វើរឿងអាក្រក់, ជេរមនុស្ស, ខ្ញុំនឹងបង្កើនគង់។ គាត់មិនមែនបង្កើនគង់, តាមពិតជាក់ស្ដែងគឺធ្វើឲ្យដង់ស៊ីតេប្រភេទសារធាតុពណ៌ខ្មៅនេះកើនឡើង, ដោយសារធ្វើរឿងអាក្រក់អាចទទួលបានសារធាតុពណ៌ខ្មៅ—អំណាចកម្ម។ ដូច្នេះគាត់ក៏អាចបណ្ដាលឲ្យសីលគង់តូចនោះដែលនាំតាមលើរាងកាយខ្លួនឯង, ទទួលរងការកើនឡើងរបស់អំណាចកម្ម, ក៏អាចសាងបង្កើតសីលគង់តូចតាច, ផ្ទុយមកវិញធ្វើមិនបានរឿងអ្វីធំដុំ។ ប្រភេទមនុស្សនេះសន្មត, ធ្វើរឿងអាក្រក់ក៏អាចបង្កើនគង់, គាត់មានប្រភេទការថ្លែងនេះ។

មានមនុស្សសម្ដែងអ្វីតាវខ្ពស់១ឆី, ខ្មោចខ្ពស់១ច្ចាង។ នោះគឺប្រភេទទ្រឹស្ដីទុច្ចរិតមួយក្នុងមនុស្សសាមញ្ញ, ខ្មោចនោះជានិច្ចក៏មិនអាចខ្ពស់ជាងតាវ។ មានប្រភេទកាលៈទេសៈមួយបែបនេះ, ចក្រវាលដែលមនុស្សជាតិពួកយើងបានយល់ច្បាស់គ្រាន់តែជាចក្រវាលតូចមួយក្នុងចក្រវាលច្រើនរាប់មិនអស់ប៉ុណ្ណោះ, ពួកយើងហៅកាត់ថាចក្រវាល។ ចក្រវាលនេះរបស់ពួកយើងរាល់លើកបន្ទាប់ពីឆ្លងកាត់សម័យកាលដ៏យូរអង្វែង, សុទ្ធតែកើតឡើងគ្រោះមហន្តរាយធំមួយរបស់ចក្រវាល។ គ្រោះមហន្តរាយមួយនេះគឺធ្វើឱ្យទាំងអស់ក្នុងចក្រវាល, រួមបញ្ចូលទាំងភពផ្កាយសុទ្ធតែអាច{ត្រូវ}កម្ទេចចោល, ជីវិតទាំងអស់ក្នុងចក្រវាលសុទ្ធតែអាច{ត្រូវ}កម្ទេចចោល។ ចក្រវាលធ្វើចលនាក៏ជាមានបទច្បាប់, ចក្រវាលលើកនេះរបស់ពួកយើងក៏មិនមែនគ្រាន់តែជាមនុស្សជាតិប្រែក្លាយជាអាក្រក់, មានជីវិតជាច្រើនបានមើលឃើញកាលៈទេសៈមួយ, ថាបច្ចុប្បន្ន, ក្នុងអវកាសចក្រវាលនេះតាំងពីយូរបានកើតឡើងការបំផ្ទុះធំមួយ។ បច្ចុប្បន្នតារាវិទូមើលមិនឃើញ, គឺដោយសារពេលដែលពួកយើងបច្ចុប្បន្នប្រើកែវយឹតតារាសាស្ត្រធំបំផុតដើម្បីមើល, ទេសកាលដែលមើលឃើញគឺជា

រឿងរ៉ាវនៃ១៥ម៉ឺនឆ្នាំពន្លឺមុន។ ប្រសិនចង់មើលឃើញការប្រែប្រួលនៃរាងកាយលោកធាតុបច្ចុប្បន្ន, ត្រូវតែ១៥ម៉ឺនឆ្នាំពន្លឺក្រោយទៀតទើបអាចមើលឃើញបាន, ដូច្នោះយូរអង្វែងណាស់។

ចំពោះមុខចក្រវាលទាំងមូលបានកើតឡើងការប្រែប្រួលមួយដ៏ធំ, រាល់លើកពេលដែលកើតឡើងការប្រែប្រួលនេះ, ជីវិតក្នុងចក្រវាលទាំងមូលទាំងអស់ស្ថិតក្នុងកម្ទេចចោល, ទាំងស្រុងស្ថិតក្នុងស្ថានភាពកម្ទេចចោល។ ពេលដែលកើតឡើងកាលៈទេសៈនេះម្តងៗ, សុទ្ធតែត្រូវយកចរិតពិសេសនេះស្ថិតនៅក្នុងចក្រវាលមុននិងសារធាតុខាងក្នុងបំផ្ទុះទាំងអស់, ធម្មតាសុទ្ធតែត្រូវបានផ្ទុះស្លាប់ទាំងអស់, ប៉ុន្តែឆ្លងកាត់បំផ្ទុះម្តងៗក៏គ្មានអស់រលីង។ បន្ទាប់ពីចក្រវាលថ្មីត្រូវបានពួកអង្គមហាត្រាស់ដឹងយ៉ាងខ្ពស់បំផុតៗរៀបចំបង្កើតសាជាថ្មី, ក្នុងនោះផ្ទុយមកវិញមានមួយចំនួនគ្មានត្រូវបានផ្ទុះស្លាប់។ ពួកអង្គមហាត្រាស់ដឹងទៅរៀបចំបង្កើតចក្រវាលនេះសុទ្ធតែជាយោងតាមចរិតពិសេសរបស់គាត់ខ្លួនឯង, បរមាណីយរបស់ខ្លួនឯងដើម្បីស្ថាបនាចក្រវាលនេះ, ដូច្នេះនិងចរិតពិសេសនៃចក្រវាលសម័យកាលលើកមុនមានកន្លែងខុសគ្នា។

ដែលគ្មានត្រូវបានផ្ទុះស្លាប់, នឹងឱបយកចរិតពិសេសពីដើមនោះ, គោលសីលធម៌ពីដើមនោះដើម្បីប្រព្រឹត្តរឿងនៅក្នុងចក្រវាលនេះ។ ចក្រវាលនេះដែលរៀបចំបង្កើតចេញថ្មីគឺយោងតាមចរិតពិសេសនៃចក្រវាលថ្មី, តាមគោលសីលធម៌នេះដើម្បីអនុវត្តរឿង។ ដូច្នេះ‹អ្វីៗ›ដែលគ្មានត្រូវបានផ្ទុះស្លាប់នឹងក្លាយជាខ្មោចជ្រៀតជ្រែកគោលសីលធម៌នៃចក្រវាល។ ប៉ុន្តែវាក៏មិនមែនអាក្រក់យ៉ាងនោះ, វាគ្រាន់តែយោងតាមចរិតពិសេសនៃចក្រវាលសម័យកាលលើកមុនដើម្បីអនុវត្តរឿង, នេះជាក់ស្តែងគឺជាខ្មោចមេឃដែលគេធ្លាប់បាននិយាយ។ ប៉ុន្តែចំពោះមនុស្សសាមញ្ញផ្ទុយមកវិញ

វាគ្មានគំរាមកំហែងអ្វី, ជាមូលដ្ឋានវាគឺមិនធ្វើបាបមនុស្ស, វាគ្រាន់តែជាឱបយកគោលសីលធម៌នោះរបស់វាដើម្បីធ្វើរឿង។ អតីតកាលរឿងនេះគឺមិនអនុញ្ញាតឱ្យមនុស្សសាមញ្ញបានដឹង, ខ្ញុំនិយាយថាព្រះពុទ្ធនៃកម្រិតភពដ៏ខ្ពស់ហួសផុតពីជាន់ថ្នាក់យូទ្បាយច្រើនណាស់, ខ្មោចនោះចាត់ថាអ្វី, ប្រៀបមកដ៏តូចៗ។ ចាស់, ឈឺ, ស្លាប់ក៏ជាប្រភេទខ្មោចមួយ, តែនេះក៏ជារក្សាចរិតពិសេសនៃចក្រវាលហើយបង្កើត។

ក្នុងពុទ្ធសាសនាសម្ដែងវដ្ដសង្សារ៦ផ្លូវ, សម្ដែងអំពីបញ្ហា{មាន}ផ្លូវមួយ{គឺ}អសុរ, ភាពពិតនោះគឺជាសត្វនៃអវកាសផ្សេង, ប៉ុន្ដែគ្មានគ្រប់គ្រាន់ចរិតដើមរបស់មនុស្ស។ នៅទីអង្គមហាត្រាស់ដឹងមើលមក, វាគឺយ៉ាងទាបបំផុតៗ, ជាពិសេសគ្មានសមត្ថភាព, ប៉ុន្ដែនៅក្នុងភ្នែករបស់មនុស្សសាមញ្ញគួរឱ្យខ្លាចណាស់, វាមានអត្ថិភាពថាមពលជាក់លាក់, វាចាត់ទុកមនុស្សសាមញ្ញគឺជាសត្វតិរច្ឆាន, ដូច្នេះចូលចិត្តស៊ីមនុស្ស។ ក្នុងប៉ុន្មានឆ្នាំនេះ, វាក៏រត់ចេញដើម្បីបង្រៀនគង់។ វាចាត់ថាជារបស់អ្វី, វាមើលទៅអាចដូចរូបមនុស្សឬ? ដ៏បន្លាចមនុស្ស, រៀនប្រការរបស់វារួចហើយ, គឺត្រូវតែទៅកន្លែងរបស់វានិងដូចជាពួកវា។ មានមនុស្សមួយចំនួនពេលដែលហាត់គង់, មនោគតិមិនត្រឹមត្រូវ, ពេលដែលសមស្របនឹងការគិតរបស់វា, វានឹងមកបង្រៀនលោកអ្នក។ សុចរិតមួយបង្អាប់រាប់រយទុច្ចរិត, ពេលដែលលោកអ្នកមិនស្វែងរក, នរណាក៏មិនហ៊ានប៉ះលោកអ្នក។ លោកអ្នកប្រសិនសាងបង្កើតគំនិតទុច្ចរិត, ស្វែងរករបស់មិនល្អ, វានឹងមកជួយលោកអ្នក, លោកអ្នកនឹងបួសតាមផ្លូវរបស់ខ្មោច, នឹងលេចឡើងបញ្ហានេះ។

នៅមានកាលៈទេសៈមួយហៅថាហាត់ទុច្ចរិតធម៌ដោយមិនដឹងខ្លួន។ អ្វីហៅថាហាត់ទុច្ចរិតធម៌ដោយមិនដឹងខ្លួន? នោះគឺមនុស្សនៅ

ក្រោមកាលៈទេសៈដែលមិនដឹងបានហាត់ទុច្ចរិតធម៌។ រឿងរ៉ាវនេះជាទូទៅខ្លាំងណាស់, សុទ្ធសាធច្រើនខ្លាំងណាស់។ ដូចខ្ញុំថ្ងៃនោះធ្លាប់សម្តែង, មានមនុស្សជាច្រើនហាត់គង់មនោគតិមិនត្រឹមត្រូវ, លោកអ្នកឃើញគាត់នៅទីនោះឈរបង្គោល, ដៃរោយឡើងញ័រ, ជើងក៏ឡើងញ័រ។ ប៉ុន្តែខួរក្បាលរបស់គាត់គ្មានសម្រាក, គាត់គិត៖ តម្លៃទំនិញឡើងខ្ពស់, ខ្ញុំត្រូវតែទៅទិញបន្តិច, ហាត់គង់ចប់ខ្ញុំនឹងទៅទិញ, បើមិនដូច្នោះទេនឹងឡើងថ្លៃ។ មានមនុស្សគិតថា៖ ក្នុងអង្គភាពបច្ចុប្បន្នកំពុងបែងចែកផ្ទះ, តើបែងចែកផ្ទះ{លើក}នេះមានខ្ញុំឬអត់? មនុស្សបែងចែកផ្ទះតឹងតែងជាមួយខ្ញុំដូច្នោះៗ។ កាន់តែគិតកាន់តែខឹង, គាត់បញ្ជាក់មិនផ្តល់ផ្ទះឲ្យខ្ញុំ, ខ្ញុំនឹងឲ្យគាត់ដឹងដៃយ៉ាងនេះៗ...............គំនិតអ្វីក៏មាន។ គឺដូចខ្ញុំសម្តែង, និយាយតាំងពីរឿងគ្រួសារពួកគាត់រហូតដល់កិច្ចការជាតិ, និយាយដល់កន្លែងខឹងកាន់តែនិយាយកាន់តែខឹង។

ហាត់គង់ត្រូវគោរពគុណធម៌, ពួកយើងពេលដែលកំពុងហាត់គង់, លោកអ្នកមិនគិតរឿងល្អ, ក៏មិនអាចគិតរឿងអាក្រក់, ល្អបំផុតគឺមិនគិតអ្វីទាំងអស់។ ដោយសារពេលដែលហាត់គង់នៅជាន់ថ្នាក់ទាបត្រូវការដាក់មូលដ្ឋានមួយចំនួន, ហើយមូលដ្ឋាននេះផ្ទុយមកវិញផ្តើមផលប៉ះពាល់យ៉ាងសំខាន់, ដោយសារសកម្មភាពគំនិតរបស់មនុស្សកំពុងផ្តើមផលប៉ះពាល់ជាក់លាក់។ អ្នករាល់គ្នាគិតសាកមើល, ខាងក្នុងគង់របស់លោកអ្នកបន្ថែមចូលប្រការអ្វីខ្លះ, ប្រការដែលលោកអ្នកហាត់ចេញអាចជាល្អឬ? វាអាចមិនខ្មៅងងឹតឬ? តើមានមនុស្សប៉ុន្មាននាក់មិនមែនឱបយកការគិតនេះដើម្បីហាត់គង់? លោកអ្នកហេតុអ្វីរមែងហាត់គង់ជំងឺមិនជាសះស្បើយ? នៅវាលហាត់គង់មានមនុស្សមួយចំនួនគ្មានគិតរឿងអាក្រក់ទាំងនោះ, ប៉ុន្តែពេលហាត់រមែងឱបយកចំណង់សីលគង់, ចំណង់នេះ

ចំណង់នោះ, ស្ថានភាពផ្លូវចិត្តគ្រប់ប្រភេទ, តណ្ហាខ្លាំងក្លាគ្រប់ប្រភេទ។ ភាពពិត, បានកំពុងហាត់ទុច្ចរិតធម៌ដោយមិនដឹងខ្លួនរួចហើយ, បើលោកអ្នកនិយាយថាគាត់ហាត់ទុច្ចរិតធម៌, គាត់អាចមិនសប្បាយចិត្ត៖ ខ្ញុំគឺបានគ្រូធំឈើគង់ណាមួយបង្រៀនខ្ញុំ។ ប៉ុន្តែគ្រូធំឈើគង់នោះហៅលោកអ្នកគោរពគុណធម៌, លោកអ្នកគោរពហើយឬនៅ? ពេលដែលលោកអ្នកហាត់គង់, លោកអ្នកតែងតែបន្ថែមចូលគំនិតមិនល្អមួយចំនួន, លោកអ្នកនិយាយថាលោកអ្នកអាចហាត់ចេញបានប្រការល្អឬ? ជាក់ស្ដែងគឺជាបញ្ហានេះ, នេះគឺស្ថិតក្នុងហាត់ទុច្ចរិតធម៌ដោយមិនដឹងខ្លួន, ជាទូទៅខ្លាំងណាស់។

## ប្រុសស្រីបួសទាំងទ្វេ

នៅពិភពបួសហាត់មានប្រភេទវិធីសាស្ត្របួសហាត់មួយយ៉ាងនេះ, ហៅថាប្រុសស្រីបួសទាំងទ្វេ។ អ្នករាល់គ្នាអាចមើលឃើញនៅក្នុងវិធីសាស្ត្របួសហាត់មីចុងទីបេ, នៅក្នុងរូបចម្លាក់ព្រះពុទ្ធឬក៏ក្នុងរូបគូរ, មើលឃើញរាងកាយប្រុសម្នាក់ឱបរាងកាយស្រីម្នាក់កំពុងបួសហាត់។ ហើយរាងកាយប្រុសមានពេលខ្លះទម្រង់បង្ហាញគឺជាព្រះពុទ្ធ, ឱបមនុស្សស្រីម្នាក់ដែលមិនពាក់សំពត់មួយផ្ទាំងណា; ក៏មានរាងកាយផ្លាស់ប្រែរបស់ព្រះពុទ្ធ, ប្រែជារូបជីនកាងក្បាលគោមុខសេះ, ឱបរាងកាយស្រីម្នាក់, ក៏ជាមិនពាក់សំពត់មួយផ្ទាំងណា។ ហេតុអ្វីបានជាបែបនេះ? ដំបូងយើងខ្ញុំនិយាយច្បាស់បញ្ហានេះឲ្យអ្នករាល់គ្នា។ លើផែនដីរបស់ពួកយើង, មិនគ្រាន់តែជាប្រទេសចិនពួកយើងទទួលរងឥទ្ធិពលរបស់ខុងជឺវង្ស, មនុស្សជាតិទាំងមូលពួកយើង, នៅសម័យកាលបុរាណប៉ុន្មានសតវត្សរ៍មុន, គោលគំនិតសីលធម៌មនុស្សជាតិសុទ្ធតែមិនខុសគ្នាច្រើន។ ដូច្នេះប្រភេទវិធីសាស្ត្របួសហាត់នេះភាពពិតប្រភពមិនមកពីផែនដីនេះរបស់ពួក

យើង, វាគឺបង្រៀនមកពីភពផ្កាយដទៃ, ប៉ុន្តែប្រភេទវិធីសាស្ត្រនេះមែនទែនអាចបួសហាត់។ ពេលដែលប្រភេទវិធីសាស្ត្របួសហាត់នេះនាគ្រានោះបង្រៀនចូលប្រទេសចិនពួកយើង, ជាក់ស្តែងគឺដោយសារវាមានផ្នែកប្រុសស្រីបួសទាំងទ្វេនិងហាត់សម្ងាត់មួយចំនួន, មិនអាចត្រូវបានជនជាតិចិនទទួលយក, ដូច្នេះនៅអំឡុងឆ្នាំហ្វួយឆាងនៃរាជវង្សថាងត្រូវបានអធិរាជដីជនជាតិហានលុបចោលរួចហើយ។ មិនអនុញ្ញាតឱ្យវាពង្រីកសកម្មភាពនៅដីជនជាតិហាន, ពេលនោះហៅថាថាងមី។ ប៉ុន្តែវានៅក្រោមបរិយាកាសពិសេសរបស់ទីបេ, នៅតំបន់ពិសេសនោះ, វាពង្រីកសកម្មភាពបន្តមក។ ហេតុអ្វីបានជាបួសហាត់បែបនេះ? គោលបំណងរបស់ប្រុសស្រីបួសទាំងទ្វេគឺត្រូវការយកអវិជ្ជមានបំពេញវិជ្ជមាន, យកវិជ្ជមានបំពេញអវិជ្ជមាន, បំពេញនិងបួសទៅវិញទៅមក, សម្រេចបានគោលបំណងតុល្យភាពអវិជ្ជមាន-វិជ្ជមាន។

អ្នករាល់គ្នាបានដឹង, មិនថាពុទ្ធវង្សក៏ដោយ, តាវវង្សក៏ដោយ, ជាពិសេសគឺទ្រឹស្តីអវិជ្ជមាន-វិជ្ជមានរបស់តាវវង្សសម្តែងថា, កាយមនុស្សមានអត្ថិភាពអវិជ្ជមាន-វិជ្ជមានដោយខ្លួនឯង។ ដោយសារកាយមនុស្សមានអត្ថិភាពអវិជ្ជមាន-វិជ្ជមាន, កាយមនុស្សទើបអាចបួសហាត់ចេញសីលគង់គ្រប់ប្រភេទ, ទារកអមតៈ, ទារក, បរមីក៏ដូចជាកាយជីវិត។ ដោយសារមានអត្ថិភាពអវិជ្ជមាន-វិជ្ជមាន, ដូច្នេះគឺអាចបួសហាត់ចេញកាយជីវិតដ៏ច្រើន។ មិនថាជារាងកាយបុរសឬក៏រាងកាយស្ត្រី, សុទ្ធតែជាដូចគ្នា, នៅលើដុំធាននោះនៃតានធានសុទ្ធតែអាចបង្កើតឡើង, ការថ្លែងនេះសមហេតុផលណាស់។ តាវវង្សជាញឹកញាប់មើលកន្លះរាងខាងលើគឺជាវិជ្ជមាន, មើលកន្លះរាងខាងក្រោមគឺជាអវិជ្ជមាន; ក៏មានមើលក្រោយខ្នងគឺជាវិជ្ជមាន, មើលខាងមុខរាងគឺជាអវិជ្ជមាន; នៅមានមើលខាងឆ្វេង

រាងកាយមនុស្សគឺជាវិជ្ជមាន, មើលខាងស្តាំគឺជាអវិជ្ជមាន។ ប្រទេសចិនពួកយើងមានការថ្លែងប្រុសឆ្វេងស្រីស្តាំ, ក៏ជាមកពីកន្លែងនេះ, សមហេតុផលណាស់។ ដោយសាររាងកាយមនុស្សមានអត្ថិភាពអវិជ្ជមាន-វិជ្ជមានដោយខ្លួនឯង, នៅក្រោមផលប៉ះពាល់ទៅវិញទៅមករបស់អវិជ្ជមាន-វិជ្ជមាន, ខ្លួនឯងគឺអាចសម្រេចបានតុល្យភាពអវិជ្ជមាន-វិជ្ជមាន, ក៏នឹងអាចសាងបង្កើតចេញកាយជីវិតដ៏ច្រើនផងដែរ។

នេះគឺនិយាយច្បាស់បញ្ហាមួយ, ពួកយើងមិនជ្រើសប្រើវិធីសាស្ត្របួសហាត់ប្រុសស្រីបួសទាំងទ្វេ, ដូចគ្នាក៏អាចបួសឡើងដល់ជាន់ថ្នាក់ដ៏ខ្ពស់។ ប្រសិនជ្រើសប្រើវិធីសាស្ត្រប្រុសស្រីបួសទាំងទ្វេដើម្បីបួសហាត់, ប្រសិនឃាត់ជាប់មិនល្អ, គឺនឹងចូលអារក្ស, គឺក្លាយជាទុច្ចរិតធម៌។ នៅលើជាន់ថ្នាក់ដ៏ខ្ពស់ក្នុងមីចុងប្រសិនចង់ជ្រើសប្រើប្រុសស្រីបួសទាំងទ្វេ, ចាំបាច់ព្រះសង្ឃនេះ, ឡាម៉ានេះបួសហាត់ឡើងដល់ជាន់ថ្នាក់ដ៏ខ្ពស់រួចហើយ។ ពេលនោះគ្រូរបស់គាត់នាំគាត់ដំណើរការប្រភេទបួសហាត់នេះ, ដោយសារចិត្តចរិតគាត់ដ៏ខ្ពស់, គាត់អាចឃាត់ជាប់បាន, មិនហូរចូលក្នុងប្រការនៃទុច្ចរិត។ ហើយមនុស្សដែលចិត្តចរិតដ៏ទាបគឺដាច់ខាតមិនអាចជ្រើសប្រើ, ជ្រើសប្រើរួចហើយជាក់ស្តែងគឺចូលក្នុងទុច្ចរិតធម៌, ធានា។ ដោយសារចិត្តចរិតមានកំណត់, ចិត្តនៃតណ្ហានៅក្នុងកម្រិតភពមនុស្សសាមញ្ញមិនទាន់កម្ចាត់, ចិត្តសម្រស់មិនទាន់កម្ចាត់, រង្វាស់នៃចិត្តចរិតនៅទីនោះ, ធានាថាប្រើកាលណាជាក់ស្តែងគឺជាទុច្ចរិត។ ដូច្នេះយើងខ្ញុំសម្តែង, តាមអំពើចិត្តបង្រៀននៅលើជាន់ថ្នាក់ទាប, នោះជាក់ស្តែងគឺជាបង្រៀនទុច្ចរិតធម៌។

ប៉ុន្មានឆ្នាំនេះក៏មានគ្រូឈីគង់មិនតិចបង្រៀនប្រុសស្រីបួសទាំងទ្វេ។ ចម្លែកនៅកន្លែងណា? តាវវង្សក៏បានលេចឡើងវិធីសាស្ត្របួស

ហាត់ប្រុសស្រីបួសទាំងទ្វេ, លើសពីនេះទៀតមិនមែនលេចឡើងបច្ចុប្បន្ន, គឺចាប់ផ្តើមតាំងពីរាជវង្សថាងរួចហើយ។ តាវវង្សហេតុអ្វីលេចឡើងប្រុសស្រីបួសទាំងទ្វេ? ទ្រឹស្តីថៃជីរបស់តាវវង្ស, រាងកាយគឺជាចក្រវាលតូច, មានអវិជ្ជមាន-វិជ្ជមានដោយខ្លួនឯង។ មហាធម៌បង្រៀនផ្លូវការពិតប្រាកដសុទ្ធតែជាឆ្លងកាត់សម័យកាលដ៏យូរអង្វែងបន្សល់ទុកមក, ផ្លាស់ប្តូរតាមអំពើចិត្ត, ថែមចូលតាមអំពើចិត្តប្រការណាមួយសុទ្ធតែនឹងធ្វើចលាចលប្រការនៃធម្មក្ខន្ធនោះ, ធ្វើឱ្យគាត់មិនអាចសម្រេចបានគោលបំណងបួសហាត់សម្រេចបរិបូរ។ ដូច្នេះក្នុងគង់ហ្វានោះគ្មានប្រការរបស់ប្រុសស្រីបួសទាំងទ្វេ, ដាច់ខាតមិនបានទៅបួស, ប្រើរួចហើយ, នឹងលេចឡើងគម្លាត, នឹងលេចឡើងបញ្ហា។ ជាពិសេសគឺធម្មក្ខន្ធហ្វាលូនតាហ្វាពួកយើង, គ្មានប្រុសស្រីបួសទាំងទ្វេ, ក៏មិនសម្តែងរឿងនេះ។ បញ្ហានេះ, យើងខ្ញុំគឺមើលឃើញយ៉ាងនេះ។

## ចរិតជីវិតបួសទាំងទ្វេ

បញ្ហាចរិតជីវិតបួសទាំងទ្វេនេះខ្ញុំធ្លាប់បានបរិយាយយ៉ាងល្អិតល្អន់ជាមួយអ្នករាល់គ្នារួចហើយ។ ចរិតជីវិតបួសទាំងទ្វេជាក់ស្តែងគឺក្រៅពីបួសចិត្តចរិត, ក្នុងពេលដំណាលគ្នាក៏បួសទាំងជីវិត, ក៏មានន័យថា, ផ្លាស់ប្រែរាងកាយនេះ។ នៅក្នុងដំណើរការផ្លាស់ប្រែ, ពេលដែលកោសិការបស់មនុស្សបន្តិចម្តងៗត្រូវបានសារធាតុថាមពលខ្ពស់ជំនួស, ភាពចាស់ខ្សោយនឹងបង្អន់។ រាងកាយបង្ហាញចេញថយឆ្ពោះទៅទិសយុវជន, ថយបន្តិចម្តងៗ, បំប្លែងបន្តិចម្តងៗ, ចុងក្រោយពេលដែលត្រូវបានសារធាតុថាមពលខ្ពស់ជំនួសទាំងស្រុង, ដូច្នោះរាងកាយឯកជននេះបានបំប្លែងទាំងស្រុងក្លាយជាប្រភេទរាងកាយសារធាតុមួយផ្សេងរួចហើយ។ ប្រភេទរាងកាយនោះដូចជាដើរចេញក្រៅធាតុទាំង៥ដែលខ្ញុំបានសម្តែង,

មិននៅក្នុងធាតុទាំង៥ទៀត, រាងកាយរបស់គាត់ជាក់ស្តែងគឺជារាងកាយមួយមិនអាចបំផ្លាញ។

បួសហាត់ក្នុងវត្តគ្រាន់តែបួសចរិត, ដូច្នេះមិនសម្តែងចលនា, មិនសម្តែងបួសជីវិត, វាសម្តែងនិព្វាន។ វិធីសាស្ត្រដែលសក្យមុនីសម្តែងគឺសម្តែងនិព្វាន, ភាពពិតសក្យមុនីខ្លួនឯងមានមហាធម៌ខ្ពស់ជ្រៅ, រាងកាយនេះអាចបំប្លែងទាំងស្រុងក្លាយជាសារធាតុថាមពលខ្ពស់ដើម្បីនាំតាម។ គាត់ដើម្បីបន្សល់ទុកប្រភេទធម៌បួសនេះ, គាត់ខ្លួនឯងក៏និព្វាន។ ហេតុអ្វីគាត់បង្រៀនបែបនេះ? គាត់ជាក់ស្តែងគឺដើម្បីទុកឱ្យមនុស្សអតិបរមាលះបង់ចោលចិត្តប្រកាន់, អ្វីក៏លះបង់ចោល, ចុងក្រោយសូម្បីតែរាងកាយក៏លះបង់ចោល, ចិត្តទាំងអស់សុទ្ធតែគ្មានទៀត។ គាត់ដើម្បីទុកឱ្យមនុស្សអតិបរមាធ្វើដល់ជំហានមួយនេះ, ក៏បានដើរផ្លូវនិព្វាននេះ, ដូច្នេះព្រះសង្ឃសម័យប្រវត្តិសាស្រក៏សុទ្ធតែដើរផ្លូវនិព្វាននេះ។ និព្វាននោះគឺព្រះសង្ឃស្លាប់ហើយ, រាងកាយសាច់បោះចោល, វិញ្ញាណដើមរបស់គាត់ខ្លួនឯងនាំតាមគង់ដើម្បីឡើងទៅ។

ចំណុចសំខាន់របស់តាវវង្សធ្លាក់នៅលើបួសជីវិត, ដោយសារគាត់ជ្រើសរើសកូនសិស្ស, {ដូច្នេះ}មិនសម្តែងប្រោសសត្វលោកទាំងឡាយ, ដែលគាត់ប្រឈមមុខគឺជាមនុស្សសែនល្អ, សែនល្អ, ដូច្នេះគាត់គឺសម្តែងរបស់នៃសិល្ប៍សាស្ត្រ, គាត់សម្តែងអំពីបញ្ហាធ្វើដូចម្តេចដើម្បីបួសជីវិត។ ហើយនៅលើវិធីសាស្ត្របួសហាត់ពិសេសជាក់លាក់នេះរបស់ពុទ្ធវង្ស, ជាពិសេសគឺលើវិធីសាស្ត្របួសហាត់នេះរបស់ពុទ្ធសាសនាគឺមិនអាចសម្តែងប្រការនេះ។ មិនមែនសុទ្ធតែមិនសម្តែង, ក្នុងមហាធម៌ខ្ពស់ជ្រៅរបស់ពុទ្ធវង្សជាច្រើនក៏មានសម្តែង, ធម្មក្ខន្ធនេះរបស់យើងខ្ញុំមានសម្តែង។ ធម្មក្ខន្ធហ្វាលូនតាហ្វារបស់យើងខ្ញុំរាងកាយនេះក៏ត្រូវការ,

ទារកអមតៈក៏ត្រូវការ, ទាំងពីរនេះគឺមានភាពខុសគ្នា។ ទារកអមតៈក៏ជារាងកាយផ្សំឡើងដោយសារធាតុថាមពលខ្ពស់, ប៉ុន្តែផ្ទុយមកវិញគាត់មិនអាចលាតត្រដាងតាមអំពើចិត្តនៅអវកាសនេះរបស់ពួកយើង, ហើយប្រសិនចង់រក្សារូបភាពយូរអង្វែងដូចមនុស្សសាមញ្ញនៅអវកាសនេះ, ចាំបាច់មានរាងកាយនេះរបស់ពួកយើង។ ដូច្នេះបន្ទាប់ពីរាងកាយនេះបំប្លែង, ទោះបីកោសិការបស់គាត់ត្រូវបានសារធាតុថាមពលខ្ពស់ជំនួសរួចហើយក៏ដោយ, ប៉ុន្តែលំដាប់រៀបចំម៉ូលេគុលរបស់គាត់គ្មានកើតឡើងការផ្លាស់ប្ដូរ, ដូច្នេះមើលទៅនិងមនុស្សសាមញ្ញធម្មតាមិនខុសគ្នាច្រើន។ ប៉ុន្តែនៅតែមានភាពខុសគ្នា, ក៏មានន័យថា, រាងកាយនេះអាចចូលទៅក្នុងអវកាសដទៃ។

គង់ហ្វាចរិតជីវិតបួសទាំងទ្វេ, ពីខាងក្រៅសង្កេតមើលធ្វើឲ្យគេមានអារម្មណ៍ថាក្មេងណាស់, មើលទៅឯកជននេះនិងអាយុមែនទែនខុសគ្នាធំណាស់។ ថ្ងៃមួយនោះមានមនុស្សសួរខ្ញុំ៖ លោកគ្រូ, ទ្រង់មើលមកកូនមានអាយុប៉ុន្មានហើយ? ភាពពិត, គាត់ជិត៧០ឆ្នាំរួចហើយ, នៅលើផ្ទៃសង្កេតមើលទើបតែអាយុ៤០ឆ្នាំ។ គ្មានស្នាមជ្រួញ, លើមុខភ្លឺស្វាង, សរលោង, សក្រហម, នេះកន្លែងណាដូចមនុស្សជិត៧០ឆ្នាំ។ មនុស្សហាត់ហ្វាលូនតាហ្វាពួកយើងនឹងលេចឡើងកាលៈទេសៈនេះ។ និយាយពាក្យកំប្លែង, ស្ត្រីវ័យក្មេងតែងតែធ្វើការតុបតែង, ចង់ស្បែកប្រែជាសជាង, ស្អាតជាង។ ខ្ញុំនិយាយថាលោកអ្នកហាត់គង់ហ្វាចរិតជីវិតបួសទាំងទ្វេពិតប្រាកដ, ដោយធម្មជាតិគឺសម្រេចបានជំហានមួយនេះ, ធានាថាលោកអ្នកមិនចាំបាច់ធ្វើការតុបតែង។ ឧទាហរណ៍នៃទិដ្ឋភាពនេះយើងខ្ញុំមិនលើកឡើងថែមទៀត។ អតីតកាលដោយសារគ្រប់មុខគ្រប់របរមនុស្សចាស់ច្រើនបង្គួរ, គេក៏ចាត់ទុកខ្ញុំគឺជាយុវជន, បច្ចុប្បន្នល្អហើយ, គ្រប់មុខ

គ្រប់របរយុវជនច្រើនបង្ហួរ។ ភាពពិតខ្ញុំក៏មិននៅក្មេងទៀតដែរ, ក៏កំពុងដល់អាយុ៥០ឆ្នាំហើយ, បច្ចុប្បន្នក៏៤៣ឆ្នាំរួចហើយ។

## បរមី

ហេតុអ្វីលើពុទ្ធបដិមាមានវាលមួយ? មានមនុស្សជាច្រើនពន្យល់មិនបាន, ក៏មានមនុស្សនិយាយថា៖ លើរូបពុទ្ធបដិមាមានវាលគឺដោយសារព្រះសង្ឃសំដៅទៅពុទ្ធបដិមាសូត្រធម៌ហើយសាងបង្កើត, ក៏មានន័យថាវាលដោយបានព្រះសង្ឃទល់មុខបួសហាត់ហើយសាងបង្កើត។ ព្រះសង្ឃបួសហាត់ក៏ដោយ, នរណាបួសហាត់ក៏ដោយ, ប៉ុន្តែប្រភេទថាមពលនេះគឺខ្វាត់ខ្វាយ, មិនតម្រង់ទិស, គួរតែលើដី, លើពិដាន, លើជញ្ជាំងនៃសាលព្រះពុទ្ធសុទ្ធតែមានវាលស្មើគ្នា, ហេតុអ្វីមានតែវាលលើពុទ្ធបដិមាខ្លាំងយ៉ាងនោះ? ជាពិសេសគឺនៅក្នុងភ្នំជ្រៅ, ឬក៏គឺនៅក្នុងរូងភ្នំណាមួយ, ឬក៏ពុទ្ធបដិមាដែលឆ្លាក់លើផ្ទាំងថ្ម, ជាញឹកញាប់សុទ្ធតែមានវាលមួយស្ថិតនៅ។ ហេតុអ្វីលេចឡើងវាលនេះ? មនុស្សខ្លះពន្យល់យ៉ាងនេះ, ពន្យល់យ៉ាងនោះ, ពន្យល់ដូចម្ដេចក៏ពន្យល់មិនធ្លុះធ្លាយ។ ភាពពិតលើពុទ្ធបដិមាមានវាលនោះគឺដោយសារលើពុទ្ធបដិមាមានបរមីមួយរបស់អង្គត្រាស់ដឹង។ បរមីរបស់អង្គត្រាស់ដឹងនៅទីនោះ, ដូច្នេះវាមានថាមពល។

សក្យមុនីក៏ដោយ, ពោធិសត្វក្វានយីនក៏ដោយ, ប្រសិនក្នុងប្រវត្តិសាស្ត្រមែនទែនមានមនុស្សទាំងនេះ, អ្នករាល់គ្នាគិតសាកមើល, ពេលដែលគាត់បួសហាត់, តើគាត់មិនមែនក៏ជាមនុស្សហាត់គង់? មនុស្សបន្ទាប់ពីបួសហាត់ដល់ជាន់ថ្នាក់ដ៏ខ្ពស់ណាមួយខាងក្រៅផុតពីលោកីយ៍ធម៌, គឺនឹងសាងបង្កើតបរមី។ បរមីគឺសាងបង្កើតនៅទីតាំងតានធានរបស់មនុស្ស, គឺដោយបានធម៌និងគង់ផ្សំឡើង, គឺបង្ហាញចេញនៅ

អវកាសផ្សេង។ បរមីមានគ្រប់គ្រាន់អំណាចដ៏ធំរបស់ខ្លួនគាត់, ប៉ុន្តែផ្ទុយមកវិញសតិរបស់បរមី, មនោគតិរបស់បរមីទទួលរងការឃុំគ្រងរបស់ម្ចាស់កាយ។ ប៉ុន្តែបរមីខ្លួនឯងក៏ជាជីវិតបុគ្គលមួយពេញលេញ, ឯករាជ្យ, ប្រាកដជាក់ស្តែង, ដូច្នេះខ្លួនឯងក៏អាចធ្វើរឿងរ៉ាវដោយឯករាជ្យ។ រឿងរ៉ាវដែលបរមីធ្វើនិងរឿងរ៉ាវដែលសតិម្ចាស់របស់មនុស្សចង់ធ្វើគឺដូចគ្នា, ដូចគ្នាបេះបិទ។ រឿងរ៉ាវនោះហៅមនុស្សនេះទៅធ្វើក៏ធ្វើយ៉ាងនោះ, បរមីទៅធ្វើក៏ធ្វើយ៉ាងនោះ, នេះជាក់ស្តែងគឺជាបរមីដែលយើងខ្ញុំនិយាយ។ ខ្ញុំចង់ធ្វើរឿងរ៉ាវអ្វី, ឧបមាថាកែសម្រួលរាងកាយឱ្យកូនសិស្សដែលបួសហាត់ពិតប្រាកដ, សុទ្ធតែដោយសារបរមីរបស់ខ្ញុំទៅធ្វើ។ ដោយសារបរមីមិននាំតាមរាងកាយនោះរបស់មនុស្ស, គឺបង្ហាញនៅអវកាសផ្សេង។ កាយជីវិតនោះក៏មិនមែនស្ថិតស្ថេរមិនផ្លាស់ប្រែ, គាត់អាចប្រែជាធំបង្រួមមកតូច។ មានពេលខ្លះគាត់ប្រែជាដ៏ធំ, ធំដល់ថ្នាក់មើលមិនឃើញទាំងអស់ក្បាលទាំងមូលរបស់បរមី; ពេលខ្លះនឹងប្រែជាដ៏តូច, តូចដល់ថ្នាក់តូចជាងទាំងកោសិកា។

## អភិសេក

ពុទ្ធបដិមាដែលផលិតចេញពីរោងចក្រគ្រាន់តែជាស្នាដៃសិល្បៈមួយប៉ុណ្ណោះ។ អភិសេកជាក់ស្តែងគឺនិមន្តបរមីមួយរបស់ព្រះពុទ្ធមក{ស្នាក់}លើពុទ្ធបដិមា, ក្រោយមក, ចាត់ទុកពុទ្ធបដិមាដូចជារាងកាយមានរូបមួយនៅក្នុងមនុស្សសាមញ្ញដើម្បីគោរពបូជា។ មនុស្សហាត់គង់មានចិត្តគោរពជំនឿនេះ, ពេលដែលបួសហាត់, បរមីលើពុទ្ធបដិមានឹងដើម្បីគាត់ការពារធម៌, មើលថែគាត់, ការពារគាត់, នេះជាគោលបំណងពិតប្រាកដរបស់អភិសេក។ មានតែនៅលើពិធីអភិសេកផ្លូវការផ្ញើចេញគំនិតសុចរិត, ឬក៏មានអង្គមហាត្រាស់ដឹងនៃជាន់ថ្នាក់ដ៏ខ្ពស់,

ឬក៏មនុស្សបួសហាត់នៅលើជាន់ថ្នាក់ដ៏ខ្ពស់ដែលមានគ្រប់គ្រាន់ប្រភេទអំណាចនេះទើបអាចធ្វើរឿងរ៉ាវនេះបាន។

ក្នុងវត្តសម្ដែងថាពុទ្ធបដិមាត្រូវការអភិសេក, ពុទ្ធបដិមាដែលមិនទាន់ឆ្លងកាត់អភិសេកគាត់និយាយថាមិនស័ក្ដិសិទ្ធិ។ ព្រះសង្ឃក្នុងវត្តបច្ចុប្បន្ន, គ្រូអចារ្យធំពិតប្រាកដទាំងនោះ, សុទ្ធតែមិននៅលើលោក។ បន្ទាប់ពី "មហាបដិវត្តន៍វប្បធម៌", ព្រះសង្ឃតូចៗទាំងនោះមានមួយចំនួនមិនដែលទទួលបានការបង្រៀនពិតប្រាកដ, បច្ចុប្បន្នធ្វើព្រះចៅអធិការ, មានប្រការជាច្រើនបានបាត់ការស្នងបង្រៀន។ សួរគាត់អភិសេកដើម្បីធ្វើអ្វី? គាត់និយាយថា៖ អភិសេករួចហើយ, ពុទ្ធបដិមានឹងស័ក្ដិសិទ្ធិ។ ពិស្ដារស័ក្ដិសិទ្ធិដូចម្ដេច, គាត់ក៏និយាយមិនច្បាស់លាស់។ ដូច្នេះគាត់គ្រាន់តែប្រារព្ធពិធីបុណ្យ, យកបទគម្ពីរតូចមួយក្បាលខ្ចប់ខាងក្នុងពុទ្ធបដិមា, បន្ទាប់មកប្រើក្រដាសបិទភ្ជាប់វាមកវិញ, {ហើយ}សំដៅទៅវាសូត្រធម៌, គាត់និយាយថាបានអភិសេករួចហើយ។ ប៉ុន្តែអាចសម្រេចបានអភិសេកហើយឬនៅ? នោះត្រូវមើលគាត់ទៅសូត្រធម៌ដូចម្ដេច។ សក្យមុនីសម្ដែងគំនិតសុចរិត, ត្រូវតែសូត្រធម៌ដោយចិត្តមួយមិនចលាចល, ពិតប្រាកដមានសមត្ថភាពធ្វើឱ្យពិភពធម្មក្ខន្ធបួសរបស់គាត់សាងបង្កើតរញ្ជួយ, ទើបអាចអន្ទងមកបានអង្គត្រាស់ដឹង។ បរមីមួយនៃអង្គត្រាស់ដឹងនោះនឹងឡើងទៅ, {ដូច្នោះ}ទើបអាចសម្រេចបានគោលបំណងអភិសេក។

ព្រះសង្ឃខ្លះនៅទីនោះសូត្រធម៌ផង, គិតផងក្នុងចិត្ត៖ អភិសេកចប់ហើយឱ្យខ្ញុំលុយប៉ុន្មានហ្ន៎។ ឬក៏សូត្រធម៌ផងគិតផង៖ អ្នកណាៗអាក្រក់ចំពោះខ្ញុំយ៉ាងនោះ។ គាត់នៅទីនោះក៏មានការកម្ហាត់គ្នា, បច្ចុប្បន្នក្នុងសម័យកាលផុតធម៌, មិនទទួលស្គាល់ប្រភេទបាតុភូតនេះក៏មិនបាន,

យើងខ្ញុំនៅទីនេះមិនមែនរិះគន់ពុទ្ធសាសនា, សម័យកាលផុតធម៌វត្ត អារាមមួយចំនួនជាក់ស្តែងគឺមិនបរិសុទ្ធ។ ពេលដែលក្នុងខួរក្បាលរបស់គាត់គិតរឿងទាំងនេះ, ផ្ញើចេញគំនិតដែលមិនល្អយ៉ាងនេះ, តើអង្គត្រាស់ដឹងនោះអាចមកឬ? ជាមូលដ្ឋានគឺសម្រេចមិនបានគោលបំណងអភិសេក។ ប៉ុន្តែមិនមែនជាដាច់ខាត, ក៏មានវត្តអារាមនិងវិហារតាវដោយឡែកខ្លះដ៏ល្អ។

ខ្ញុំនៅទីក្រុងមួយមើលឃើញព្រះសង្ឃមួយអង្គ, ដៃនោះខ្មៅងងឹត។ យកបទគម្ពីរមួយក្បាលខ្ទប់ទៅខាងក្នុងពុទ្ធបដិមា, បិទភ្ជាប់ៗ, ក្នុងមាត់រអ៊ូរទាំពីរបីដងបានរាប់ថាអភិសេករួចហើយ។ ម្តងទៀតកាន់ពុទ្ធបដិមាមួយ, ម្តងទៀតរអ៊ូរទាំពីរបីដង, អភិសេកមួយដងគឺ៤០រៀល។ ព្រះសង្ឃបច្ចុប្បន្នបានយក‹អភិសេក›នេះធ្វើក្លាយជាទំនិញលក់ដូរ, រកលុយដោយការអភិសេកពុទ្ធបដិមា។ ខ្ញុំមើលឃើញកាលណាក៏មិនទាន់អភិសេកបាន, ជាមូលដ្ឋានគឺអភិសេកមិនបាន, ព្រះសង្ឃបច្ចុប្បន្ននៅតែធ្វើចេញរឿងរ៉ាវបែបនេះ។ ខ្ញុំនៅមើលឃើញរឿងរ៉ាវអ្វីទៀត? ក្នុងវត្តមានមនុស្សម្នាក់, ប្រហែលដូចជាឧបាសក, និយាយថាគឺអភិសេកឲ្យពុទ្ធបដិមា, គាត់កាន់មុខកញ្ចក់មួយទល់មុខទៅព្រះអាទិត្យ, ទុកឲ្យពន្លឺនោះបញ្ចាំងលើខ្លួនរបស់ពុទ្ធបដិមា, គាត់គឺនិយាយថាអភិសេករួចហើយ។ សុទ្ធតែឈានដល់កម្រិតគួរឱ្យអស់សំណើចយ៉ាងនេះ! ថ្ងៃនេះពុទ្ធសាសនាអភិវឌ្ឍមកដល់ជំហានមួយនេះ, វានៅតែជាបាតុភូតមួយទូទៅណាស់។

ពុទ្ធបដិមាធ្វើដោយសំរិទ្ធមួយផលិតនៅណានជិញ, បានដាក់លើភ្នំតាឃឺនៅហុងកុង, ពុទ្ធបដិមាធំណាស់។ ព្រះសង្ឃជាច្រើនទូទាំងពិភពលោកបានមកដើម្បីអភិសេកពុទ្ធបដិមា, ក្នុងនោះព្រះសង្ឃមួយអង្គបាន

កាន់មុខកញ្ចក់មួយទល់មុខទៅព្រះអាទិត្យ, ទុកឲ្យពន្លឺបញ្ចាំងនៅលើមុខពុទ្ធបដិមាហើយនិយាយថាគឺជាអភិសេក។ ព្រឹត្តិការណ៍ធំដូច្នោះ, ករណីដែលតឹងរឹងដូច្នោះនៅធ្វើចេញរឿងរ៉ាវប្រភេទនេះ, ខ្ញុំមានអារម្មណ៍ពិតជាគួរឲ្យសោកស្ដាយ! មិនឆ្ងល់នោះទេ, សក្យមុនីសម្ដែង៖ ដល់សម័យកាលផុតធម៌, ព្រះសង្ឃសុទ្ធតែពិបាកប្រោសខ្លួនឯង, ប្រោសមនុស្សគឺកាន់តែពិបាកជាង។ ថែមទៀតមានព្រះសង្ឃជាច្រើនឈរនៅលើទស្សនៈរបស់ខ្លួនឯងដើម្បីពន្យល់ពុទ្ធគម្ពីរ, អ្វី "គម្ពីររ៉ាំងមូរនាងនាង" ក៏រត់ចូលបានក្នុងវត្ត, មិនមែនប្រការក្នុងគម្ពីរបុរាណនៃពុទ្ធសាសនាក៏រត់ចូលបានក្នុងវត្ត, ធ្វើឲ្យរញ៉េរញ៉ៃអស់, បច្ចុប្បន្នដ៏រញ៉េរញ៉ៃ។ ប្រាកដណាស់, ព្រះសង្ឃបួសហាត់ពិតប្រាកដនៅតែមាន, នៅតែដ៏ល្អ។ អភិសេកតាមពិតទៅគឺនិមន្តបរមីរបស់អង្គត្រាស់ដឹងមកស្នាក់នៅលើពុទ្ធបដិមា, គឺជាអភិសេក។

ដូច្នោះពុទ្ធបដិមានេះប្រសិនមិនទាន់បានអភិសេកគឺមិនអាចថ្វាយបង្គំ, ថ្វាយបង្គំរួចហើយនឹងនាំមកផលវិបាកធ្ងន់ធ្ងរខ្លាំងណាស់។ ផលវិបាកធ្ងន់ធ្ងរអ្វី? បច្ចុប្បន្នពួកយើងធ្វើសិក្សាវិទ្យាសាស្ត្រ{អំពី}រាងកាយមនុស្សរកឃើញថា, គំនិតរបស់មនុស្សពួកយើង, ផ្ទត់គំនិតក្នុងខួរធំរបស់មនុស្សអាចសាងបង្កើតប្រភេទសារធាតុមួយ។ យើងខ្ញុំនៅក្នុងជាន់ថ្នាក់ដ៏ខ្ពស់មើលឃើញវាមែនទែនគឺជាប្រភេទសារធាតុមួយ, ប៉ុន្តែផ្ទុយមកវិញសារធាតុនេះមិនដូចប្រភេទទម្រង់រលកខួរក្បាលដែលពួកយើងបច្ចុប្បន្នបានស្រាវជ្រាវរកឃើញ, ប៉ុន្តែជាប្រភេទទម្រង់ខួរធំពេញលេញមួយ។ តាមធម្មតាពេលមនុស្សសាមញ្ញគិតអំពីបញ្ហាអ្វីផ្ញើចេញរបស់មួយមានរូបសណ្ឋានខួរធំ, ដោយសារវាគ្មានថាមពល, ដូច្នេះ{បន្ទាប់ពី}ផ្ញើចេញពេលវេលាមិនយូរក៏ខ្ចាត់ខ្ចាយបាត់, ហើយថាមពលដែលមនុស្សហាត់

គង់រក្សាបានពេលវេលាគឺយូរជាង។ ពុទ្ធបដិមានេះមិនមែននិយាយថាផលិតចេញពីរោងចក្ររួចហើយវានឹងមានមនោគតិ, មិនមាន។ មានខ្លះមិនទាន់ឆ្លងកាត់អភិសេក, គាត់កាន់ចូលទៅក្នុងវត្តក៏មិនសម្រេចបានគោលបំណងអភិសេក។ ប្រសិនរកគ្រូឈីគង់ក្លែងក្លាយណាមួយ, {ឬក៏} មនុស្សតាមធម្មក្ខន្ធទុច្ចរិតតាវរៀចដើម្បីអភិសេក, នោះនឹងកាន់តែគ្រោះថ្នាក់, កញ្ច្រោង, សំពោចនឹងឡើងទៅ។

ដូច្នោះប្រសិនពុទ្ធបដិមាមិនទាន់បានអភិសេក, លោកអ្នកឡើងទៅសំពះ, គឺគ្រោះថ្នាក់ខ្លាំងណាស់។ គ្រោះថ្នាក់ដល់កម្រិតណា? ខ្ញុំបានសម្តែងរួចហើយមនុស្សជាតិអភិវឌ្ឍដល់ថ្ងៃនេះ, ទាំងអស់សុទ្ធតែកំពុងអន្តរាយ, រឿងរ៉ាវទាំងអស់ក្នុងសង្គមទាំងមូល, ក្នុងចក្រវាលទាំងមូលក៏កំពុងជាបន្តបន្ទាប់កើតឡើងអន្តរាយ, រឿងរ៉ាវទាំងអស់ក្នុងមនុស្សសាមញ្ញពួកយើងសុទ្ធតែដោយសារខ្លួនឯងបង្កឡើង។ ចង់ចំណង់សុចរិតធម៌, ដើរតាមសុចរិតតាវសុទ្ធតែដ៏ពិបាក, ជ្រៀតជ្រែកគ្រប់ទិដ្ឋភាព។ ចង់ចំណង់ព្រះពុទ្ធ, នរណាជាព្រះពុទ្ធ? ចង់ចំណង់សុទ្ធតែដ៏ពិបាក។ មិនជឿខ្ញុំសម្តែងចេញមក៖ ប្រសិនមនុស្សទីមួយនៅពីមុខពុទ្ធបដិមាមិនទាន់បានអភិសេកដើម្បីសំពះអាចនឹងខូចហើយ។ បច្ចុប្បន្នសំពះព្រះពុទ្ធមានមនុស្សប៉ុន្មាននាក់ក្នុងចិត្តចំណង់ព្រះពុទ្ធចង់សម្រេចមគ្គផល? មនុស្សបែបនេះតិចខ្លាំងណាស់។ គោលបំណងដែលមនុស្សភាគច្រើនសំពះព្រះពុទ្ធជាអ្វី? រំលាយមហន្តរាយ, រំដោះគ្រោះ, មានទ្រព្យសម្បត្តិ, ចំណង់អ្វីទាំងនេះ។ នេះគឺជាប្រការក្នុងគម្ពីរបុរាណពុទ្ធសាសនាឬ? ជាមូលដ្ឋានគឺគ្មានរបស់នៃជាន់នេះ។

មនុស្សសំពះព្រះពុទ្ធប្រសិនចំណង់លុយ, សំដៅទៅពុទ្ធបដិមាសំពះកាលណា, ឬក៏បដិមាពោធិសត្វក្វានយីន, ឬក៏ពុទ្ធបដិមាយូឡាយ

និយាយថា៖ សូមជួយកូនមានទ្រព្យសម្បត្តិបន្តិចមក។ បុរសល្អ, គំនិតពេញលេញមួយនឹងបង្កើតចេញមក។ គាត់គឺសំដៅទៅពុទ្ធបដិមាដើម្បីផ្ញើចេញទៅ, ដូច្នេះមួយរំពេចគឺឡើងដល់ទៅលើពុទ្ធបដិមានេះ។ រាងកាយនេះនៅអវកាសផ្សេង, គឺអាចពង្រីកធំបង្រួមតូច, ឡើងទៅលើរាងកាយនេះ, ពុទ្ធបដិមានេះនឹងមានខួរធំ, នឹងមានមនោគតិ, តែផ្ទុយមកវិញមិនទាន់មានរាងកាយ។ អ្នកដទៃក៏ទៅសំពះ, សំពះមកសំពះទៅ, នឹងផ្តល់ឱ្យវាថាមពលមួយជាក់លាក់។ ជាពិសេសគឺមនុស្សហាត់គង់នឹងកាន់តែគ្រោះថ្នាក់, សំពះកាលណានឹងបន្តិចម្តងៗផ្តល់ថាមពលឱ្យវា, វានឹងបង្កើតជារាងកាយមានរូបមួយ, ប៉ុន្តែរាងកាយដែលមានរូបនេះបង្កើតនៅអវកាសផ្សេង។ បន្ទាប់ពីបង្កើតរួចហើយវានៅក្នុងអវកាសផ្សេង, វាអាចដឹងគោលសីលធម៌មួយចំនួនក្នុងចក្រវាល, ដូច្នេះវាអាចដើម្បីមនុស្សធ្វើបន្តិចរឿង, បែបនេះវាក៏អាចបង្កើនចេញបន្តិចគង់, ប៉ុន្តែវាជួយមនុស្សគឺមានលក្ខខណ្ឌមានតម្លៃ។ នៅអវកាសផ្សេងវាប្រព្រឹត្តបានដូចចិត្ត, គ្របសង្កត់មនុស្សបានដូចចិត្តខ្លាំងណាស់។ រាងកាយមានរូបនេះប្រៀបនឹងរូបភាពរបស់ពុទ្ធបដិមាគឺដូចគ្នាបេះបិទ, ជាក់ស្តែងគឺពោធិសត្វក្លែងក្លាយ, ព្រះពុទ្ធយូឡាយក្លែងក្លាយដែលត្រូវបានសំពះចេញ, គឺដោយសារមនុស្សសំពះចេញមក, មើលទៅដូចជាពុទ្ធបដិមា, សណ្ឋានរបស់ព្រះពុទ្ធ។ ផ្ទុយមកវិញមនោគតិរបស់ព្រះពុទ្ធក្លែងក្លាយ, ពោធិសត្វក្លែងក្លាយគឺយ៉ាងអាក្រក់បំផុត, គឺចំណង់លុយ។ វាសាងបង្កើតនៅក្នុងអវកាសផ្សេង, វាមានមនោគតិ, វាដឹងបានគោលសីលធម៌មួយចំនួន, វាមិនហ៊ានធ្វើរឿងអាក្រក់ធំដុំ, តែវាហ៊ានធ្វើរឿងអាក្រក់តូចតាច។ មានពេលខ្លះក៏ជួយមនុស្សផងដែរ, ប្រសិនមិនជួយមនុស្សទាំងស្រុងគឺជាទុច្ចរិតរួចហើយ, ដូច្នេះត្រូវតែសម្លាប់វា។ ជួយដូចម្តេច? ឯកជននោះ

និយាយថា៖ បួងសួងសូមព្រះពុទ្ធជួយៗកូន, កូនមានអ្នកផ្ទះកើតជំងឺ។ ល្អ, ជួយឯង។ វាទុកឱ្យលោកអ្នកបោះលុយចូលក្នុងប្រអប់អំណោយ, មនោគតិរបស់វាគឺចង់បានលុយ។ បោះលុយចូលខាងក្នុងប្រអប់អំណោយច្រើនប៉ុណ្ណា, គឺទុកឲ្យជំងឺរបស់លោកអ្នកជាសះស្បើយឆាប់ប៉ុណ្ណោះ។ ដោយសារវាមានថាមពលជាក់លាក់, នៅក្នុងអវកាសផ្សេងវាអាចចាត់ចែងមនុស្សសាមញ្ញ។ ជាពិសេសគឺមនុស្សមានគង់ទៅសំពះ, គឺកាន់តែគ្រោះថ្នាក់។ មនុស្សហាត់គង់ចំណង់អ្វី? ចំណង់លុយឬ? អ្នករាល់គ្នាគិតមើល, មនុស្សហាត់គង់ចំណង់លុយទ្រព្យអ្វីទៅ? ចំណង់រំលាយមហន្តរាយរំលាយជំងឺឱ្យសាច់ញាតិសុទ្ធតែជាប្រកាន់ចំពោះស្នេហាសាច់ញាតិ។ ចង់គ្រប់គ្រងជោគវាសនារបស់អ្នកដទៃ, មនុស្សមានជោគវាសនារៀងៗខ្លួន! ប្រសិនលោកអ្នកសំពះវា, រអ៊ូរទាំ៖ សូមជួយកូនមានទ្រព្យសម្បត្តិ។ ល្អ, វាជួយលោកអ្នក, វាចង់ឱ្យលោកអ្នកចំណង់លុយកាន់តែច្រើន, ចំណង់ច្រើនជាងទៀត, វាយកអ្វីៗរបស់លោកអ្នកកាន់តែច្រើន, ផ្តោះប្តូរស្មើតម្លៃ។ អ្នកដទៃបោះលុយឲ្យវាចូលខាងក្នុងប្រអប់អំណោយដ៏ច្រើន, វាទុកឲ្យលោកអ្នកទទួលបាន។ បានដូចម្តេច? ចេញពីទ្វាររើសបានកាបូបលុយ, អង្គភាពជូនឲ្យបន្តិចប្រាក់រង្វាន់, ទោះយ៉ាងណាក៏គិតវិធីសាស្ត្រទុកឲ្យលោកអ្នកទទួលបានលុយ។ វាក៏មិនអាចជួយលោកអ្នកដោយអត់លក្ខខណ្ឌ? មិនបាត់មិនបាន, យកបន្តិចគង់របស់លោកអ្នក, វាខ្វះគង់, ឬក៏យកទៅអ្វីរបស់លោកអ្នកដូចជាតានដែលលោកអ្នកហាត់ចេញ, វាត្រូវការរបស់ទាំងនេះ។

ព្រះពុទ្ធក្លែងក្លាយទាំងនេះមានពេលខ្លះគឺដ៏គ្រោះថ្នាក់។ មនុស្សដ៏ច្រើនពួកយើងបានបើកភ្នែកទិព្វរួចហើយសន្មតថាខ្លួនឯងមើលឃើញព្រះពុទ្ធ។ មានមនុស្សនិយាយថាថ្ងៃនេះក្នុងវត្តមានអង្គព្រះពុទ្ធមួយក្រុម

មក, អង្គព្រះពុទ្ធនេះឈ្មោះអ្វី, បានដឹកនាំមួយក្រុមមក។ និយាយថាម្សិលមិញមួយក្រុមនោះមកគឺជាបែបណា, ថ្ងៃនេះមួយក្រុមមកគឺជាបែបណា, មួយសន្ទុះក៏ចេញទៅ, មួយក្រុមក៏បានមកទៀត។ គឺជាអ្វី? ជាក់ស្តែងគឺស្ថិតក្នុងប្រភេទមួយនេះ។ វាមិនមែនព្រះពុទ្ធពិត, វាគឺជាក្លែងក្លាយ, គឺប្រភេទនេះច្រើនណាស់។

ប្រសិនក្នុងវត្តលេចឡើងកាលៈទេសៈនេះ, គឺកាន់តែគ្រោះថ្នាក់។ ព្រះសង្ឃប្រសិនសំពះវា, ដូច្នោះវាគឺគ្រប់គ្រងព្រះសង្ឃ៖ ឯងមិនមែនសំពះយើងឬ? ឯងច្បាស់ណាស់កំពុងសំពះយើងទេតើ! ល្អ, ឯងមិនមែនចង់បួសហាត់ឬ? យើងគ្រប់គ្រងឯង, យើងទុកឲ្យឯងបួសដូចម្តេចៗ។ វារៀបចំឱ្យលោកអ្នក, ដូច្នោះលោកអ្នកបួសសម្រេចរួចហើយ, បួសទៅដល់ទីណា? វារៀបចំឲ្យលោកអ្នក, ខាងលើធម្មកូទ្ធណាក៏មិនចង់បាន។ វារៀបចំ, ដូច្នេះអនាគតលោកអ្នកគឺប្រគល់មកវាគ្រប់គ្រង។ លោកអ្នកនេះមិនមែនបួសដូចមិនបួសហើយឬ? ខ្ញុំនិយាយថាមនុស្សជាតិបច្ចុប្បន្នចង់បួសសម្រេចមគ្គផលសុទ្ធតែដ៏ពិបាក។ ប្រភេទបាតុភូតនេះទូទៅណាស់, មនុស្សដ៏ច្រើនពួកយើងនៅទីភ្នំល្បីទន្លេធំមើលឃើញរស្មីរបស់ព្រះពុទ្ធ, ភាគច្រើនសុទ្ធតែជាប្រភេទនេះ, វាមានថាមពល, គឺអាចលាតត្រដាងចេញមក។ អង្គមហាត្រាស់ដឹងពិតប្រាកដគឺមិនងាយស្រួលលាតត្រដាង។

អតីតកាលហៅថាពុទ្ធលើដី, តាវលើដី, តិចបង្គួរ, ប៉ុន្តែបច្ចុប្បន្នច្រើនពិសេស។ ពេលដែលវាធ្វើរឿងអាក្រក់, ខាងលើក៏ចង់សម្លាប់វា, បម្រុងសម្លាប់វានឹងរត់ទៅលើពុទ្ធបដិមា។ គោលសីលធម៌នេះរបស់មនុស្សសាមញ្ញ, អង្គមហាត្រាស់ដឹងជាធម្មតាគឺមិនងាយស្រួលប៉ះ, អង្គត្រាស់ដឹងកាន់តែខ្ពស់កាន់តែមិនបំផ្លាញគោលសីលធម៌របស់មនុស្សសាមញ្ញ, មិន

ប៉ះបន្តិចណា។ បន្ទាប់ពីទាំងអស់មិនអាចស្រោប់តែរន្ទះបាញ់ពុទ្ធបដិមាខ្ទេចខ្ទី, គាត់មិនធ្វើរឿងនេះ, ដូច្នេះវារត់ទៅលើពុទ្ធបដិមាគឺមិនគ្រប់គ្រងទៀត។ សម្លាប់វាវាដឹង, វានឹងរត់។ ដូច្នេះពោធិសត្វក្លានយីនដែលលោកអ្នកមើលឃើញគឺជាពោធិសត្វឬ? ព្រះពុទ្ធដែលលោកអ្នកមើលឃើញគឺជាព្រះពុទ្ធឬ? ពិបាកនិយាយណាស់។

មនុស្សដ៏ច្រើនពួកយើងស្រមៃដល់បញ្ហាមួយ៖ ពុទ្ធបដិមាក្នុងផ្ទះពួកយើងធ្វើដូចម្ដេច? អាចមានមនុស្សជាច្រើនបាននឹកដល់ខ្ញុំ។ ដើម្បីឧបត្ថម្ភសិក្ខាកាមបួសហាត់, ខ្ញុំប្រាប់លោកអ្នកអាចធ្វើបែបនេះ៖ លោកអ្នកកាន់សៀវភៅរបស់ខ្ញុំ (ដោយសារក្នុងសៀវភៅមានរូបថតរបស់ខ្ញុំ) ឬក៏រូបថតរបស់ខ្ញុំ, ក្នុងដៃលោកអ្នកទ្រពុទ្ធបដិមា, ធ្វើក្បាច់ដៃផ្កាឈូកធំ, ក្រោយមកគឺដូចជាអង្វរខ្ញុំ, សូមលោកគ្រូអភិសេកឲ្យ។ កន្លះនាទីគឺដោះស្រាយបានបញ្ហា។ ប្រាប់អ្នករាល់គ្នា, គ្រាន់តែកំហិតក្នុងមនុស្សបួសហាត់ពួកយើងប៉ុណ្ណោះ, អភិសេកឱ្យសាច់ញាតិមិត្តភក្តិគឺមិនបាន, យើងខ្ញុំគ្រាន់តែគ្រប់គ្រងមនុស្សបួសហាត់។ មានមនុស្សនិយាយថាកាន់រូបសំណាករបស់លោកគ្រូទៅផ្ទះសាច់ញាតិមិត្តភក្តិដើម្បីបណ្ដេញអំពើអាក្រក់, ខ្ញុំមិនមែនដើម្បីបណ្ដេញអំពើអាក្រក់ឱ្យមនុស្សសាមញ្ញ។ នេះជាការមិនគោរពធំបំផុតចំពោះគ្រូ។

សម្ដែងអំពីបញ្ហាពុទ្ធលើដី, តាវលើដី។ នៅមានប្រភេទកាលៈទេសៈមួយទៀត, ប្រទេសចិនបុរាណមានមនុស្សជាច្រើនបួសហាត់នៅក្នុងភ្នំជ្រៅព្រៃចាស់។ ហេតុអ្វីបច្ចុប្បន្នគ្មានទៀត? ភាពពិតមិនមែនគ្មាន, គឺមិនទុកឱ្យមនុស្សសាមញ្ញដឹងបាន, ក៏មិនខ្វះបន្តិចណា, មនុស្សទាំងនេះសុទ្ធតែមានសីលគង់។ ប៉ុន្មានឆ្នាំនេះមិនមែនមនុស្សទាំងនេះមិននៅ, មនុស្សទាំងនេះសុទ្ធតែនៅទាំងអស់។ បច្ចុប្បន្នលើពិភពលោកនៅតែ

មានប៉ុន្មានពាន់, ប្រទេសពួកយើងច្រើនជាងបង្គួរ។ ជាពិសេសគឺភ្នំល្បី ទន្លេធំទាំងនោះសុទ្ធតែមាន, ក្នុងភ្នំខ្ពស់មួយចំនួនក៏មានផងដែរ។ គាត់ប្រើសីលគង់បិទរូងភ្នំមកវិញ, ដូច្នេះលោកអ្នកមើលមិនឃើញអត្ថិភាពរបស់គាត់។ គាត់បួសហាត់ឃើតយូរបង្គួរ, វិធីរបស់គាត់ឆ្គាំឆ្គងបង្គួរ, គាត់ចាប់មិនបានមជ្ឈមណ្ឌលរបស់បួសហាត់។ ហើយពួកយើងគឺតម្រង់ផ្ទាល់ចិត្តមនុស្ស, យោងតាមចរិតពិសេសខ្ពស់បំផុតនៃចក្រវាលរបស់ពួកយើងដើម្បីបួសហាត់, យោងតាមប្រភេទទម្រង់នោះនៃចក្រវាលដើម្បីបួសហាត់, ប្រាកដណាស់គង់បង្កើនឡើងដ៏ឆាប់រហ័ស។ ដោយសារធម្មក្ខន្ធបួសហាត់គឺជារាងពីរ៉ាមីត, មានតែកណ្តាលទេគឺជាមហាតាវ, តាវតូចនៅជាយទាំងនោះ, ចិត្តចរិតបួសហាត់មិនជាក់លាក់ខ្ពស់, ប្រហែលបួសបានមិនខ្ពស់គឺបើកគង់រួចហើយ, ប៉ុន្តែប្រៀបនឹងមហាតាវបួសហាត់ពិតប្រាកដខុសគ្នាឆ្ងាយខ្លាំងណាស់។

គាត់ក៏កំពុងស្នងបង្រៀនដឹកនាំសិស្ស, គង់ហ្វាមួយនេះរបស់គាត់គឺបួសខ្ពស់យ៉ាងនេះ, ចិត្តចរិតរបស់គាត់ក៏ជាខ្ពស់យ៉ាងនេះ, ដូច្នេះសិស្សដែលគាត់បង្រៀនក៏បួសខ្ពស់យ៉ាងនេះ។ កាន់តែជាតាវតូចលោកីយ៍នៅជាយសម្តែងធម៌កាន់តែច្រើន, វិធីសាស្ត្របួសកាន់តែស្មុគស្មាញ, ចាប់មិនបានមជ្ឈមណ្ឌលដើម្បីបួស។ គេបួសហាត់ចម្បងគឺបួសចិត្តចរិត, គាត់នៅតែមិនយល់ចំណុចមួយនេះ, គាត់សន្មតថារងទុក្ខគឺអាចបួសហាត់។ ដូច្នេះគាត់បានឆ្លងកាត់រយៈពេលជាយូរ, បួសរាប់រយឆ្នាំ, ជាងពាន់ឆ្នាំ, គាត់បង្កើនចេញបន្តិចគង់យ៉ាងនេះ។ តាមពិតគាត់មិនមែនពឹងផ្អែកលើរងទុក្ខបួសចេញមក, បួសចេញមកដូចម្តេច? គឺដូចជាមនុស្ស, នៅវ័យក្មេងចិត្តប្រកាន់ដ៏ច្រើន; ដល់ពេលចាស់, ស្របតាមឆ្នាំខែបានកន្លងទៅ, អនាគតគ្មានសង្ឃឹម, ចិត្តនេះគឺតាមធម្មជាតិលះបង់ចោល,

ធ្លាក់ជ្រុះ, ប្រភេទតាវតូចនេះក៏ជាវិធីសាស្ត្រនេះ។ ពេលដែលគាត់ពឹងផ្អែកលើអង្គុយសមាធិ, កម្លាំងរម្ងាប់, រងទុក្ខ, ដើម្បីបួសឆ្ពោះឡើងលើ, គាត់រកឃើញថាក៏អាចបង្កើនគង់។ ប៉ុន្តែផ្ទុយមកវិញគាត់មិនបានដឹងថាចិត្តប្រកាន់នៃមនុស្សសាមញ្ញនោះរបស់គាត់នៅក្នុងឆ្នាំខែទុក្ខពិបាកជាយូរសន្សឹមៗបានធ្លាក់បាត់ទៅហើយ, សន្សឹមៗចិត្តនោះបានកម្ចាត់រួចហើយគង់បង្កើនឡើងលើ។

ពួកយើងគឺមានភាពចង្អុលចំ, ពិតប្រាកដចង្អុលចេញចិត្តនោះ, កម្ចាត់ចិត្តនោះ, ដូច្នោះបួសគឺលឿនខ្លាំងណាស់។ ខ្ញុំធ្លាប់ឆ្លងកាត់តំបន់មួយចំនួន, ជាញឹកញាប់ជួបប្រទះមនុស្សទាំងនេះ, បានបួសច្រើនឆ្នាំណាស់រួចហើយ។ គាត់ក៏និយាយថា៖ គ្មាននរណាអាចដឹងពួកខ្ញុំនៅទីនេះ, រឿងនេះរបស់លោកពួកខ្ញុំមិនគ្រប់គ្រង, មិនបង្កបញ្ហា។ នេះស្ថិតក្នុងចំណោមមនុស្សល្អបង្គួរ។

ក៏មានមិនល្អ, ដែលមិនល្អយើងខ្ញុំក៏ត្រូវការដោះស្រាយ។ លើកឧទាហរណ៍, ពេលដែលខ្ញុំទៅក្វយចូវបង្រៀនគង់លើកទីមួយ, ក្នុងពេលនៅលើថ្នាក់, មានមនុស្សម្នាក់មករកខ្ញុំ, និយាយថាគ្រូបារបស់គាត់ចង់ជួបខ្ញុំ, គ្រូបារបស់គាត់គឺជានរណាៗ, បានបួសហាត់ជាច្រើនឆ្នាំណាស់មកហើយ។ ខ្ញុំមើលមួយភ្លាមឃើញឯកជននេះនាំតាមឈីអវិជ្ជមាន, ដ៏មិនល្អ, មុខលឿងដូចក្រមួន។ ខ្ញុំនិយាយខ្ញុំមិនទៅជួបគាត់, គ្មានទំនេរ, បដិសេធត្រង់។ លទ្ធផលតាចាស់គាត់នោះគឺមិនសប្បាយចិត្ត, ចាប់ផ្តើមបង្កបញ្ហាជាមួយខ្ញុំ, ម៉្ងៗបង្កបញ្ហាជាមួយខ្ញុំ។ មនុស្សខ្ញុំនេះមិនស្ម័គ្រចិត្តប្រយុទ្ធនឹងគេ, ខ្ញុំក៏មិនខ្វីប្រយុទ្ធជាមួយគាត់។ គាត់បានបោះមករបស់មិនល្អខ្ញុំក៏សម្អាត, សម្អាតចប់ហើយ, ខ្ញុំក៏បង្រៀនធម៌របស់ខ្ញុំ។

អតីតកាលក្នុងរាជវង្សមិញមានមនុស្សបួសតាវម្នាក់, ពេលបួសតាវ

គឺមានកាយភ្ជាប់ពស់, ក្រោយមកមនុស្សបួសតាវនេះមិនទាន់បួសបានសម្រេចក៏ស្លាប់ទៅ, កូនពស់នេះកាន់កាប់រាងកាយរបស់មនុស្សបួសតាវ, ហើយបួសចេញជារូបមនុស្ស។ គ្រូបារបស់ឯកជននោះជាក់ស្តែងគឺរូបមនុស្សដែលកូនពស់នោះបួសសម្រេច។ ដោយសារចរិតដើមរបស់គាត់មិនប្តូរ, ក៏ប្រែក្រឡាជាសត្វពស់ធំមួយបង្កបញ្ហាជាមួយខ្ញុំ។ ខ្ញុំមើលទៅក៏ហួសហេតុពេក, ខ្ញុំក៏ចាប់វាជាប់ក្នុងដៃ, ប្រើប្រភេទគង់មួយសែនខ្លាំងធំ, ហៅថាហ័រគង់, ប្រែកន្លះរាងកាយខាងក្រោមរបស់វារំលាយបាត់, ក្លាយទៅជាទឹក, កន្លះរាងកាយខាងលើរបស់វារត់ត្រឡប់ទៅវិញ។

មានថ្ងៃមួយ, ប្រធានឋានីយជួយណែនាំក្តួយចូវរបស់ពួកយើងត្រូវបានសិស្សរបស់គាត់មករក, និយាយថាគ្រូបារបស់គាត់ចង់ជួបនាង។ ប្រធានទៅដល់, ពេលចូលក្នុងរូងខ្មៅងងឹតអ្វីក៏មើលមិនឃើញ, គ្រាន់តែមើលឃើញស្រមោលមួយអង្គុយនៅទីនោះ, ភ្នែកបាញ់ចេញពន្លឺបៃតង, ពេលសម្លឹងបើកភ្នែករូងក៏ភ្លឺ, ពេលបិទភ្នែកក្នុងរូងក៏ខ្មៅងងឹត។ គាត់ប្រើគ្រាមភាសានិយាយថា៖ លីហ៊ុងជីមកទៀតហើយ, លើកនេះពួកយើងគ្មាននរណាទៅធ្វើរឿងនោះទៀតទេ, ខ្ញុំខុសហើយ, លីហ៊ុងជីគឺមកដើម្បីប្រោសមនុស្ស។ កូនសិស្សសួរគាត់ថា៖ គ្រូបា, គ្រូឈរឡើងទៅ, ជើងរបស់គ្រូយ៉ាងម៉េចហ្នឹង? គាត់និយាយ៖ យើងឈរឡើងមិនបានទេ, ជើងរបស់យើងរងរបួសហើយ។ សួរគាត់របួសដូចម្តេច, គាត់ក៏ចាប់ផ្តើមរៀបរាប់អំពីដំណើរការដែលគាត់បង្កបញ្ហា។ ពិព័រណ៍សុខភាពបូព៌ានៅប៉េកាំងឆ្នាំ៩៣គាត់ម្តងទៀតបង្កបញ្ហាជាមួយខ្ញុំ។ ដោយសារគាត់តែងតែធ្វើរឿងអាក្រក់, គាត់បំផ្លាញខ្ញុំបង្រៀនមហាធម៌, ខ្ញុំបានកម្ទេចគាត់ចោលទាំងស្រុង, បន្ទាប់ពីកម្ទេចចោល, បងស្រី, ប្អូនស្រី, បងប្រុស, ប្អូនប្រុសសុទ្ធតែចង់កម្រើក។ ពេលនោះខ្ញុំបាននិយាយប៉ុន្មានប្រយោគ, ពួកគាត់

សុទ្ធតែមានអារម្មណ៍ភ្ញាក់ផ្អើល, រន្ធត់ណាស់, នរណាក៏មិនហ៊ានកម្រើក, ក៏យល់ច្បាស់គឺជារឿងដូចម្ដេច។ ក្នុងចំណោមពួកគាត់នៅមានមួយចំនួនគឺជាមនុស្សសាមញ្ញទាំងស្រុង, ទោះបីបួសរយៈពេលដ៏យូររួចហើយ។ នេះជាប៉ុន្មានឧទាហរណ៍បានលើកឡើងពេលសម្ដែងអំពីបញ្ហាអភិសេក។

## ផ្នែកជូយ៉ូវ

ផ្នែកជូយ៉ូវជាអ្វី? នៅក្នុងពិភពបួសហាត់, មានមនុស្សជាច្រើននៅក្នុងដំណើរការបង្រៀនគង់, ក៏ចាត់ទុកវាជាប្រការនៃវិសាលភាពបួសហាត់ដើម្បីបង្រៀន, ភាពពិតវាមិនមែនប្រការនៃវិសាលភាពបួសហាត់។ វាជាប្រភេទស្នងបង្រៀនមួយដូចជាល្បិច, មន្តអាគម, បច្ចេកទេស។ ទម្រង់ដែលវាជ្រើសប្រើ, អ្វីដូចជាគូរយ័ន្ត, អុជធូប, អុជក្រដាស, សូត្រគាថាជាដើម, វាអាចព្យាបាលជំងឺ, វិធីសាស្ត្រព្យាបាលជំងឺដ៏ពិសេសមានតែមួយ។ លើកឧទាហរណ៍និយាយ, លើមុខនរណាកើតបូសទ្រនិច, គាត់ប្រើជក់ជ្រលក់លើហិង្គុលរួចហើយគូររង្វង់មូលនៅលើដី, នៅខាងក្នុងរង្វង់មូលគូសជើងក្អែកមួយ, ហៅមនុស្សម្នាក់នេះឈរនៅផ្ចិតរង្វង់, គាត់ក៏ចាប់ផ្ដើមសូត្រមន្តអាគម។ ក្រោយមកកាន់ជក់ជ្រលក់ហិង្គុលគូសរង្វង់មូលនៅលើមុខរបស់គាត់, គូសផងសូត្រអាគមផង, គូសមកគូសទៅ, ដាក់ចំណុចមួយលើបូសទ្រនិច, អាគមក៏សូត្រចប់ល្មម, និយាយថាជាសះរួចហើយ។ លោកអ្នកស្ទាបៗមើល, គឺតូចមកវិញ, មិនចុកទៀត, វាផ្ដើមផលប៉ះពាល់។ ជំងឺតូចនេះគាត់អាចព្យាបាល, ជំងឺធំគាត់គឺមិនបាន។ និយាយថាដើមដៃចុកធ្វើដូចម្ដេច? ក្នុងមាត់ចាប់ផ្ដើមសូត្រអាគម, គាត់ហៅលោកអ្នកសន្ធឹងដើមដៃចេញ, សំដៅទៅស្មៀរ៉ុហៀគូនៃដៃមួយនេះប្រើមាត់ផ្លុំ, ធ្វើឲ្យវាបញ្ចេញតាមស្មៀរ៉ុហៀគូនៃដៃមួយនោះ, គឺមាន

អារម្មណ៍ដូចជាខ្យល់មួយខៀក, ស្ទាបម្ដងទៀត, វាមិនចុកដូច្នោះទៀត។ នៅមានជ្រើសប្រើអុជក្រដាស, គួរយ័ន្ត, បិទយ័ន្តជាដើម, គាត់ធ្វើរឿងទាំងនេះ។

នៅក្នុងតាវតួចលោកីយ៍របស់តាវវង្ស, មិនសម្ដែងបួសជីវិត, ទាំងស្រុងគឺជាហោរាសាស្ត្រ, មើលហុងស៊ុយ, បណ្ដេញអំពើអាក្រក់, ព្យាបាលជំងឺ។ តាវតួចលោកីយ៍ទាំងនេះច្រើនតែជ្រើសប្រើវា។ វាអាចព្យាបាលជំងឺ, ប៉ុន្តែវិធីសាស្ត្រដែលវាជ្រើសប្រើគឺមិនល្អ។ យើងខ្ញុំមិនសម្ដែងវាកេងប្រវ័ញ្ចរបស់អ្វីដើម្បីព្យាបាលជំងឺ, ប៉ុន្តែមនុស្សបួសមហាធម៌ពួកយើងមិនបានជ្រើសប្រើវា, ដោយសារវានាំតាមព័ត៌មានដ៏មិនល្អដ៏ទាប។ ប្រទេសចិនបុរាណយកវិធីសាស្ត្រព្យាបាលជំងឺបែងចែកជាផ្នែកជាភាគ, ឧបមាថា, តឆ្អឹង, ចាក់ម្ជុលវិទ្យាសាស្ត្រ, ម៉ាស្សា, តម្រង់ឆ្អឹង, ចុចស្មៀរ៉ិ, ឈីគង់ព្យាបាលជំងឺ, ថ្នាំស្មៅព្យាបាលជំងឺជាដើម, បែងចែកជាច្រើនប្រភេទ។ ប្រភេទវិធីសាស្ត្រព្យាបាលជំងឺនីមួយៗហៅថាផ្នែកមួយ, ផ្នែកជូយ៉ូវនេះត្រូវបានចុះបញ្ជីជាផ្នែកទី១៣, ដូច្នេះឈ្មោះគ្រប់គ្រាន់របស់វាហៅថាផ្នែកទី១៣ជូយ៉ូវ។ ផ្នែកជូយ៉ូវមិនស្ថិតក្នុងប្រការក្នុងវិសាលភាពបួសហាត់របស់ពួកយើង, វាមិនមែនគង់ដែលទទួលបានដោយការបួសហាត់, តែជារបស់មួយនៃសិល្ប៍សាស្ត្រ។

# មេសម្តែងទី៦

## ឆ្កួតវង្វេងអារក្សចូល

នៅពិភពពបួសហាត់មានប្រភេទការថ្លែងមួយយ៉ាងនេះ, ហៅថាឆ្កួតវង្វេងអារក្សចូល, នៅក្នុងមហាជនមានឥទ្ធិពលក៏ធំណាស់ផងដែរ។ ជាពិសេសគឺមានមនុស្សមួយចំនួនយករឿងនេះឃោសនាដ៏សម្បើម, ដល់ថ្នាក់ធ្វើឲ្យមានមនុស្សមួយចំនួនមិនហ៊ានហាត់គង់ទៀត។ គេពេលណាឮនិយាយថាហាត់គង់នៅតែនឹងឆ្កួតវង្វេងអារក្សចូល, ក៏ភ័យរន្ធត់មិនហ៊ានហាត់ទៀត។ ភាពពិតខ្ញុំប្រាប់អ្នករាល់គ្នា, ឆ្កួតវង្វេងអារក្សចូលជាមូលដ្ឋានគឺមិនស្ថិតនៅ។

មានមនុស្សមិនតិចដោយសារខ្លួនឯងចិត្តមិនសុចរិត, អន្ទងមកកាយភ្ជាប់មួយចំនួន។ សតិម្ចាស់ខ្លួនឯងមិនអាចឃុំគ្រងខ្លួនឯង, នៅតែសន្មតថានេះគឺជាគង់។ រាងកាយត្រូវបានកាយភ្ជាប់គ្របសង្កត់, ច្របូកច្របល់, សូម្បីតែបន្តស្រែកបង្កូកហៅ។ គេកាលណាមើលឃើញហាត់គង់នៅតែជាប្រភេទទម្រង់នេះ, ភ័យរន្ធត់មិនហ៊ានហាត់ទៀត។ ពួកយើងមានមនុស្សជាច្រើនសន្មតថានេះគឺជាគង់, តើនេះគឺជាហាត់គង់ឬ? នេះគ្រាន់តែជាស្ថានភាពទាបបំផុតៗដើម្បីព្យាបាលជំងឺកាយសម្បទាប៉ុណ្ណោះ, ប៉ុន្តែផ្ទុយមកវិញវាគ្រោះថ្នាក់ណាស់។ ប្រសិនលោកអ្នកខ្លួនឯងធ្លាប់តែបែបនេះ, សតិម្ចាស់របស់លោកអ្នករមែងមិនអាចឃុំគ្រងលោកអ្នកខ្លួនឯងបាន, ដូច្នោះរាងកាយលោកអ្នកអាចនឹងត្រូវបានសតិរងឬក៏ព័ត៌មានមកពីខាងក្រៅ, កាយភ្ជាប់គ្រប់ប្រភេទគ្របសង្កត់, គឺអាចធ្វើចេញមកកម្រើកមួយចំនួន, លើសពីនេះទៀតកម្លាំងបំផ្លាញចំពោះពិភពបួសហាត់យ៉ាងធំបំផុត។ នេះគឺដោយសារចិត្តមនុស្សមិនសុចរិត

បង្កើតឡើង, ប្រកាន់លើការបង្ហាញខ្លួនឯង, នេះមិនមែនឆ្កួតវង្វេងអារក្សចូល។ មានមនុស្សមួយចំនួនក៏មិនដឹងហេតុម្តេចបានក្លាយជាអ្វីដែលគេហៅថាគ្រូឈើគង់នោះ, គាត់ក៏សម្តែងឆ្កួតវង្វេងអារក្សចូល។ ភាពពិតហាត់គង់គឺមិនអាចឆ្កួតវង្វេងអារក្សចូល, មនុស្សភាគច្រើនចម្បងគឺបានស្តាប់ពីក្នុងស្នាដៃសិល្បៈ, ស្តាប់បាននាមសព្ទមួយនេះនៅក្នុងប្រលោមលោកក្បាច់គុនណាមួយ។ល។ មិនជឿលោកអ្នកសាកបើកសៀវភៅបុរាណ, ក្នុងសៀវភៅបួសហាត់, មិនមានរឿងបែបនេះ។ ឯណាមានឆ្កួតវង្វេងអារក្សចូលអ្វី? ជាមូលដ្ឋានគឺនឹងមិនលេចឡើងប្រភេទរឿងរ៉ាវនេះ។

មនុស្សធម្មតាសន្មតថាឆ្កួតវង្វេងអារក្សចូលមានប៉ុន្មានទម្រង់, ដែលខ្ញុំទើបតែសម្តែងក៏ជាប្រភេទទម្រង់មួយ។ ដោយសារខ្លួនឯងចិត្តមិនសុចរិត, អន្ទងមកកាយភ្ជាប់, ចំណង់ស្ថានភាពឈើគង់អ្វីមួយដើម្បីបង្ហាញខ្លួនឯងក៏ដូចជាគ្រប់ស្ថានភាពផ្លូវចិត្ត។ មានខ្លះដោយផ្ទាល់ចំណង់សីលគង់ឬក៏បានហាត់ឈើគង់ក្លែងក្លាយ, នៅពេលហាត់ខ្លួនឯងរមែងធ្លាប់តែបន្ទូរសតិម្ចាស់របស់ខ្លួនឯង, អ្វីក៏មិនដឹង, រាងកាយបានប្រគល់ឲ្យអ្នកដទៃរួចហើយ, ច្របូកច្របល់ត្រូវបានសតិរងឬក៏ព័ត៌មានមកពីខាងក្រៅធ្វើម្ចាស់លើរាងកាយ, ធ្វើចេញមកកម្រើកពិសេសមួយចំនួន។ ហៅគាត់លោតពីលើអគារគាត់គឺលោតពីលើអគារ, ហៅគាត់លោតចុះទឹកគាត់គឺលោតចុះទឹក។ គាត់ខ្លួនឯងក៏មិនចង់រស់ទៀត, បានយករាងកាយប្រគល់ឱ្យអ្នកដទៃរួចហើយ។ នេះមិនស្ថិតក្នុងឆ្កួតវង្វេងអារក្សចូល, ប៉ុន្តែនេះស្ថិតក្នុងហាត់គង់វង្វេងចូលផ្លូវខុស, ចាប់ផ្តើមគឺចេតនាធ្វើបែបនេះហើយបង្កើតឡើង។ មានមនុស្សដ៏ច្រើនសន្មតថាយោលៗរង្គើៗគឺជាហាត់គង់, ភាពពិតប្រភេទស្ថានភាពនេះប្រសិនពិតប្រាកដទៅហាត់គង់, នឹងបង្កជាផលវិបាកធ្ងន់ធ្ងរ។ នេះមិនមែនជាហាត់

គង់, គឺជាការប្រកាន់និងចំណង់របស់មនុស្សសាមញ្ញបង្កឡើង។

ប្រភេទកាលៈទេសៈមួយផ្សេងគឺពេលហាត់គង់ឈឺរាំងស្ទះនៅទីណាមួយមិនបើកស្រឡះ, ឈឺដល់កំពូលក្បាលចុះមកមិនបាន, គាត់គឺភ័យខ្លាចណាស់។ រាងកាយមនុស្សគឺជាចក្រវាលតូចមួយ, ជាពិសេសគឺគង់ហ្វាតាវវង្សពេលដែលកំពុងឆ្លងទ្វារ, នឹងជួបប្រទះរឿងរំខានទាំងនេះ, ឆ្លងផុតមិនបាន, ឈឺគឺសំកាំងនៅទីនេះ។ មិនគ្រាន់តែជាកំពូលក្បាល, ទីតាំងផ្សេងៗក៏ដូចគ្នាផងដែរ, ប៉ុន្តែ{កន្លែង}ឆាប់រសើបបំផុតរបស់មនុស្សគឺជាកំពូលក្បាល។ ឈឺឡើងកំពូលក្បាលហើយសម្រុកចុះ, ពេលដែលឆ្លងទ្វារមិនបាន, គាត់នឹងមានអារម្មណ៍ថាក្បាលធ្ងន់, ក្បាលហើម, {ដូចជា}ពាក់មួកឈឺដ៏ក្រាសជាដើមបាតុភូតទាំងនេះ។ ប៉ុន្តែឈឺវាគ្មានផលប៉ះពាល់រឹតត្បិតណាមួយ, វាក៏មិនអាចនាំឲ្យមនុស្សលេចឡើងការរំខានអ្វី, ក៏ជាមូលដ្ឋានគឺមិនអាចសាងបង្កើតជំងឺអ្វី។ មានមនុស្សមួយចំនួនមិនយល់ច្បាស់កាលៈទេសៈមែនទែនរបស់ឈឺគង់, ក៏បញ្ចេញមតិរញ៉េរញ៉ៃដោយអាថ៌កំបាំង, លទ្ធផលបង្កជាប្រភេទបាតុភូតមួយដ៏រញ៉េរញ៉ៃ។ គេក៏បានសន្មតថាឈឺឡើងកំពូលក្បាលហើយចុះមកមិនបានគឺនឹងឆ្កួតវង្វេងអារក្សចូល, លេចឡើងគម្លាតជាដើម, លទ្ធផលមនុស្សដ៏ច្រើនគាត់ខ្លួនឯងភ័យខ្លាចណាស់។

ឈឺឡើងកំពូលក្បាលចុះមកមិនបាន, វាគ្រាន់តែជាស្ថានភាពនៃរយៈពេលមួយប៉ុណ្ណោះ, មនុស្សខ្លះពេលវេលាដ៏យូរ, កន្លះឆ្នាំរួចហើយក៏ចុះមកមិនបាន, ចុះមកមិនបានរកគ្រូឈឺគង់ពិតប្រាកដណែនាំបន្តិចក៏អាចចុះមកបាន។ ដូច្នោះពួកយើងជាទូទៅពេលហាត់គង់ឆ្លងទ្វារមិនបាន, ពេលឈឺចុះមកមិនបាន, ពួកយើងសាកល្បងរកមូលហេតុនៅលើចិត្តចរិត, តើបានវង្វេងនៅក្នុងជាន់ថ្នាក់ណាមួយពេលវេលាយូរ

ពេកហើយ, គួរតែលើកកម្ពស់ៗចិត្តចរិត! ពេលដែលលោកអ្នកពិតប្រាកដលើកកម្ពស់ចិត្តចរិត, លោកអ្នកឃើញថាវាគឺអាចចុះមកបាន។ លោកអ្នកគ្រាន់តែសង្កត់ធ្ងន់លើការផ្លាស់ប្រែនៃគង់របស់ខ្លួនឯងហើយ មិនសង្កត់ធ្ងន់លើការប្រែផ្លាស់នៃចិត្តចរិតរបស់លោកអ្នក, វាអាចជាកំពុងរង់ចាំចិត្តចរិតរបស់លោកអ្នកលើកកម្ពស់, ទើបនឹងកើតឡើងការផ្លាស់ប្រែទាំងមូលបាន។ ឈឺពិតប្រាកដមិនបើកស្រឡះគេក៏មិនបង្កជាបញ្ហាអ្វី, ជាញឹកញាប់សុទ្ធតែជាផលប៉ះពាល់នៃស្មារតីរបស់ពួកយើងខ្លួនឯង, ម្តងទៀតស្តាប់គ្រូឈីគង់ក្លែងក្លាយមួយចំនួននិយាយឈីឡើងកំពូលក្បាល, នឹងលេចឡើងគម្លាតអ្វី, គាត់គឺភ័យខ្លាច។ ការភ័យខ្លាចមួយនេះរបស់គាត់ប្រហែលជានឹងនាំមករំខានពិតប្រាកដ។ ដោយសារកាលណាលោកអ្នកភ័យខ្លាច, ជាក់ស្តែងគឺជាចិត្តស្លន់ស្លោ, នោះមិនមែនចិត្តប្រកាន់ឬ? ចិត្តប្រកាន់របស់លោកអ្នកកាលណាផុសចេញមក, មិនត្រូវតែកម្ចាត់ចោលចិត្តប្រកាន់របស់លោកអ្នកឬ? កាន់តែភ័យខ្លាច, គឺកាន់តែដូចជាជំងឺ, ត្រូវតែយកចិត្តនេះរបស់លោកអ្នកកម្ចាត់ចោលទើបបាន, ទុកឲ្យលោកអ្នកទទួលយកមេរៀនលើកនេះ, ហេតុនេះកម្ចាត់ចោលចិត្តស្លន់ស្លោ, លើកកម្ពស់ឡើងលើ។

មនុស្សហាត់គង់ពេលអនាគតក៏នឹងមិនសុខស្រួល, រាងកាយលេចឡើងគង់ជាច្រើន, សុទ្ធតែជារបស់ដ៏ខ្លាំងក្លានៅក្នុងរាងកាយលោកអ្នកកម្រើកមកកម្រើកទៅ, ធ្វើឲ្យលោកអ្នកមិនសុខស្រួលយ៉ាងនេះ, មិនសុខស្រួលយ៉ាងនោះ។ មូលហេតុលោកអ្នកមិនសុខស្រួលចម្បងគឺលោកអ្នករមែងភ័យខ្លាចរាងកាយខ្លួនឯងកើតជំងឺអ្វីមួយ, ភាពពិតនៅក្នុងរាងកាយសុទ្ធតែលេចឡើងរបស់ខ្លាំងក្លាយ៉ាងនោះ, ដែលលេចចេញសុទ្ធតែជាគង់, សុទ្ធតែជាសីលគង់, នៅមានកាយជីវិតជាច្រើនទៀត។ ប្រសិនជា

កម្រើក, លោកអ្នកនឹងមានអារម្មណ៍ថារាងកាយកើតរមាស់, ឈឺ, ពិបាកទ្រាំជាដើម, ចុងសរសៃប្រសាទញាណក៏ដំរសើប, ស្ថានភាពគ្រប់ប្រភេទសុទ្ធតែនឹងលេចឡើង។ ដរាបណារាងកាយលោកអ្នកមុនពេលមិនទាន់បានសារធាតុថាមពលខ្ពស់ប្រែផ្លាស់, សុទ្ធតែមានប្រភេទអារម្មណ៍នេះ, ដើមមកគឺជារឿងល្អ។ ធ្វើជាមនុស្សបួសហាត់ម្នាក់, លោកអ្នករមែងសន្មតថាខ្លួនឯងគឺជាមនុស្សសាមញ្ញ, រមែងសន្មតថាខ្លួនឯងមានជំងឺ, នោះធ្វើដូចម្តេចដើម្បីហាត់? ពួកយើងក្នុងហាត់គង់ពេលដែលគ្រោះកប្បមក, លោកអ្នកនៅតែចាត់ទុកខ្លួនឯងគឺជាមនុស្សសាមញ្ញ, ខ្ញុំនិយាយថាចិត្តចរិតលោកអ្នកពេលនោះគឺធ្លាក់ទៅដល់ទីរបស់មនុស្សសាមញ្ញរួចហើយ។ ជាក់ស្តែងនៅលើបញ្ហាមួយនេះ, យ៉ាងហោចណាស់លោកអ្នកបានធ្លាក់ទៅដល់ជាន់ថ្នាក់របស់មនុស្សសាមញ្ញរួចហើយ។

ពួកយើងធ្វើជាមនុស្សហាត់គង់ម្នាក់ពិតប្រាកដ, គួរតែនៅលើជាន់ថ្នាក់ដ៏ខ្ពស់ដើម្បីមើលបញ្ហា, មិនអាចប្រើទស្សនៈរបស់មនុស្សសាមញ្ញដើម្បីមើលបញ្ហា។ ពេលដែលលោកអ្នកសន្មតថាគឺមានជំងឺ, នោះអាចប្រហែលជាគឺនាំឲ្យមានជំងឺ។ ដោយសារពេលណាលោកអ្នកសន្មតថាវាមានជំងឺ, ចិត្តចរិតរបស់លោកអ្នកក៏ខ្ពស់ដូចគ្នានឹងមនុស្សសាមញ្ញ។ ហាត់គង់និងបួសហាត់ពិតប្រាកដ, ជាពិសេសគឺប្រភេទស្ថានភាពនេះ, វានឹងមិននាំឲ្យមានជំងឺ។ អ្នករាល់គ្នាដឹងថាពិតប្រាកដកើតជំងឺ, គឺ៧ភាគស្មារតី៣ភាគជំងឺ។ ជាញឹកញាប់គឺស្មារតីរបស់មនុស្សមុនដំបូងដួលរលំ, មុនដំបូងមិនបាន, បន្ទុកដ៏ធ្ងន់, ហើយធ្វើឱ្យស្ថានភាពជំងឺប្រែជាធ្ងន់ធ្ងរ, ជាញឹកញាប់សុទ្ធតែជាបែបនេះ។ លើកឧទាហរណ៍, អតីតកាលមានមនុស្សម្នាក់, ចងគាត់នៅលើគ្រែ, យកដៃរបស់គាត់ចេញ, និយាយថានឹងធ្វើឲ្យគាត់ហូរឈាម។ ក្រោយមកបិទភ្នែករបស់គាត់, យកកដៃរបស់

គាត់គួសមួយ (ជាមូលដ្ឋានគ្មានធ្វើឲ្យគាត់ហូរឈាម), បើកក្បាលរ៉ូប៊ីណេទុកឱ្យគាត់ស្តាប់ឮសំឡេងតក់ៗ។ គាត់គឺសន្មតថាឈាមរបស់ខ្លួនឯងកំពុងស្រក់ចុះ, មួយរយៈក្រោយឯកជននេះគឺស្លាប់។ ភាពពិតជាមូលដ្ឋានគឺគ្មានធ្វើឲ្យគាត់ហូរឈាម, ដែលហូរនោះគឺជាទឹករ៉ូប៊ីណេ, ស្មារតីរបស់គាត់បាននាំឱ្យគាត់ស្លាប់។ ពេលដែលលោកអ្នករមែងសន្មតថាលោកអ្នកមានជំងឺ, ប្រហែលជាគឺអាចនាំឱ្យលោកអ្នកខ្លួនឯងកើតជំងឺ។ ដោយសារចិត្តចរិតរបស់លោកអ្នកបានទម្លាក់ចុះដល់មូលដ្ឋានរបស់មនុស្សសាមញ្ញរួចហើយ, ដូច្នោះមនុស្សសាមញ្ញប្រាកដណាស់គឺនឹងកើតជំងឺ។

មនុស្សហាត់គង់លោកអ្នកតែងតែសន្មតថាវាគឺជាជំងឺ, តាមពិតទៅលោកអ្នកជាក់ស្តែងគឺជាចំណង់, លោកអ្នកចំណង់កើតជំងឺ, ជំងឺនោះគឺអាចសង្កត់ចូលក្នុង។ ធ្វើជាមនុស្សហាត់គង់ម្នាក់ចិត្តចរិតគឺគួរតែខ្ពស់។ លោកអ្នកមិនបានរមែងភ័យខ្លាចកើតជំងឺ, ខ្លាចកើតជំងឺក៏ជាចិត្តប្រកាន់ផងដែរ, ដូចគ្នានឹងនាំរំខានមកឱ្យលោកអ្នក។ ក្នុងបួសហាត់ត្រូវការរំលាយកម្ម, រំលាយកម្មគឺជាទុក្ខឈឺចាប់, ឯណាមានការបង្កើនគង់ដោយសុខស្រួលនោះ! បើមិនដូច្នោះទេចិត្តប្រកាន់របស់លោកអ្នកធ្វើម្តេចកម្ចាត់បាន? ខ្ញុំនិទានរឿងបុរាណមួយក្នុងពុទ្ធសាសនាឲ្យអ្នករាល់គ្នា៖ អតីតកាលមានមនុស្សម្នាក់ចំណាយខិតខំដ៏ធំដើម្បីបួសសម្រេចបានអរហន្ត។ ម្នាក់នោះប្រសិនចង់បួសសម្រេចមគ្គផល, បួសសម្រេចបានអរហន្តហើយគាត់អាចមិនសប្បាយចិត្តឬ? លោតចេញក្រៅត្រៃភពហើយ! ភាពសប្បាយចិត្តមួយនេះជាក់ស្តែងគឺជាចិត្តប្រកាន់, ចិត្តត្រេកអរ។ អរហន្តគួរតែជាសភាពគ្មានបំណង, ចិត្តមិនរំជួល, ប៉ុន្តែគាត់ធ្លាក់ចុះរួចហើយ, បួសដូចមិនបួស។ បួសដូចមិនបួសត្រូវតែបួសឡើងវិញ, ម្តង

ទៀតសាជាថ្មីបួសឡើងលើ, បានចំណាយខិតខំយ៉ាងខ្លាំងម្ដងទៀតបួសឡើងលើបាន។ លើកនេះគាត់ភ័យខ្លាច, គាត់និយាយក្នុងចិត្ត៖ យើងកុំសប្បាយចិត្ត, សប្បាយចិត្តម្ដងទៀតក៏ធ្លាក់ចុះមកទៀត។ គាត់ភ័យខ្លាចកាលណាធ្លាក់ចុះមកម្ដងទៀត។ ភ័យខ្លាចក៏ជាប្រភេទចិត្តប្រកាន់មួយផងដែរ។

មានកាលៈទេសៈមួយទៀតជាក់ស្ដែងគឺមនុស្សខ្លះមានជំងឺវិកលចរិត, ហើយនិយាយថាគាត់ឆ្កួតវង្វេងអារក្សចូល។ ក៏មានមនុស្សខ្លះនៅរង់ចាំខ្ញុំព្យាបាលជំងឺវិកលចរិតឲ្យគាត់ទៀតផង! ខ្ញុំនិយាយថាជំងឺវិកលចរិតមិនមែនជាជំងឺ, ខ្ញុំក៏គ្មានពេលវេលាទៅគ្រប់គ្រងរឿងទាំងនេះ។ ហេតុអ្វី? ដោយសារមនុស្សជំងឺវិកលចរិតគ្មានវីរុស, ក្នុងរាងកាយគ្មានការផ្លាស់ប្ដូររោគសាស្ត្រ, គ្មានចម្លងមេរោគ, បើតាមខ្ញុំឃើញជាក់ស្ដែងមិនមែនជាជំងឺ។ ជំងឺវិកលចរិតជាក់ស្ដែងគឺសតិម្ចាស់របស់មនុស្សទន់ខ្សោយពេក។ ទន់ខ្សោយដល់កម្រិតណា? ដូចជាមនុស្សម្នាក់នោះតែងតែមិនអាចទទួលបន្ទុកខ្លួនឯងបាន, វិញ្ញាណដើមម្ចាស់របស់មនុស្សជំងឺវិកលចរិតជាក់ស្ដែងគឺជាបែបនេះ។ គាត់មិនចង់គ្រប់គ្រងរាងកាយនេះទៀត, គាត់ខ្លួនឯងតែងតែស្រទ្បាំងកាំង, តែងតែស្មារតីមិនងើបឡើងបាន។ ពេលនោះសតិរង, ព័ត៌មានមកពីខាងក្រៅនឹងជ្រៀតជ្រែកគាត់, បណ្ដាជាន់ថ្នាក់អវកាសច្រើនយ៉ាងនោះ, ព័ត៌មានគ្រប់ប្រភេទសុទ្ធតែចង់ជ្រៀតជ្រែកគាត់។ ថែមទាំងវិញ្ញាណដើមម្ចាស់របស់មនុស្សនៅជាតិមុនអាចបានធ្វើរឿងរ៉ាវមិនល្អមួយចំនួន, នៅមានម្ចាស់បំណុលអាចចង់ធ្វើបាបគាត់, រឿងរ៉ាវគ្រប់ប្រភេទសុទ្ធតែនឹងលេចឡើង។ យើងខ្ញុំនិយាយថាជំងឺវិកលចរិតជាក់ស្ដែងគឺជារឿងយ៉ាងនេះ។ ហៅខ្ញុំធ្វើដូចម្ដេចព្យាបាលឱ្យគាត់? ខ្ញុំនិយាយថាជំងឺវិកលចរិតពិតប្រាកដជាក់ស្ដែងគឺកើតយ៉ាង

នេះ។ ដូច្នោះធ្វើដូចម្ដេច? អប់រំគាត់, ទុកឲ្យស្មារតីរបស់គាត់ងើបឡើង, ប៉ុន្តែពិបាកធ្វើបានណាស់។ លោកអ្នកមើលឃើញវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យវិកលចរិតកាន់ដំបងឆក់ក្នុងដៃ, គាត់ភ្លាមៗនោះរន្ធត់ឈប់និយាយអ្វីដែលមិនទំនង។ ហេតុអ្វីទៅ? ពេលនោះស្មារតីនៃវិញ្ញាណដើមម្ចាស់របស់គាត់ងើបឡើង, គាត់ខ្លាចឆក់គាត់។

ជាញឹកញាប់មនុស្សបានចូលក្នុងទ្វារបួសហាត់រួចហើយគឺចូលចិត្តបន្តហាត់, នរណាៗក៏មានពុទ្ធចរិត, នរណាៗក៏មានចិត្តបួសតាវ, ដូច្នេះកាលណាបានរៀនគង់រួចហើយ, មានមនុស្សជាច្រើនគាត់នឹងបន្តហាត់មួយជីវិត។ មិនខ្វល់គាត់អាចឬមិនអាចបួសឡើងទៅលើ, ទទួលបានឬមិនទទួលបានធម៌, ទោះយ៉ាងណាគាត់មានចិត្តចំណង់តាវ, គាត់តែងតែចង់ហាត់។ គេសុទ្ធតែដឹងថាឯកជននេះហាត់គង់, មនុស្សនៅក្នុងការិយាល័យក៏ដឹង, តាមផ្លូវក៏ដឹង, រវាងអ្នកជិតខាងក៏ដឹងថាគាត់ហាត់គង់។ ប៉ុន្តែអ្នករាល់គ្នាគិតសាកមើល, បួសហាត់ពិតប្រាកដ, នៅប៉ុន្មានឆ្នាំមុននរណាធ្វើរឿងរ៉ាវបែបនេះ? គ្មានមនុស្សធ្វើ, បួសហាត់ពិតប្រាកដទើបអាចផ្លាស់ប្រែផ្លូវជីវិតរបស់គាត់។ ហើយគាត់ជាមនុស្សសាមញ្ញម្នាក់, គ្រាន់តែជាហាត់គង់ព្យាបាលជំងឺកាយសម្បទា, នរណាផ្លាស់ប្រែផ្លូវជីវិតឱ្យគាត់? មនុស្សសាមញ្ញទេតើ, ដល់ថ្ងៃណាមួយនឹងកើតជំងឺ, ដល់ថ្ងៃណាមួយនឹងជួបប្រទះរឿងរំខានអ្វីមួយ, ដល់ថ្ងៃណាមួយប្រហែលជានឹងកើតជំងឺវិកលចរិត, ឬក៏អស់ជីវិតស្លាប់ទៅ, មួយជីវិតរបស់មនុស្សសាមញ្ញជាក់ស្ដែងគឺជាបែបនេះ។ លោកអ្នកឃើញគាត់នៅក្នុងឧទ្យានហាត់គង់, គាត់ចង់បួសឡើងលើជាន់ថ្នាក់ខ្ពស់តែក៏មិនទាន់ទទួលបានសុចរិតធម៌, គាត់ក៏បួសឡើងលើមិនបាន។ គាត់គ្រាន់តែមានបំណងចង់បួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, គាត់នៅតែជាអ្នកហាត់គង់នៅក្នុង

ជាន់ថ្នាក់ទាបព្យាបាលជំងឺកាយសម្បទា។ ផ្លូវជីវិតរបស់គាត់មិនទាន់មានមនុស្សទៅផ្លាស់ប្រែឱ្យគាត់, ដូច្នោះគាត់គឺនឹងកើតជំងឺ។ មិនគោរពគុណធម៌ជំងឺក៏នឹងមិនជា, មិនមែននិយាយថាហាត់គង់រួចហើយគឺជំងឺអ្វីក៏មិនកើតទៀត។

គាត់ត្រូវតែទៅបួសហាត់ពិតប្រាកដ, យកចិត្តទុកដាក់ចិត្តចរិត, ទៅបួសហាត់ពិតប្រាកដទើបអាចជាសះជំងឺ។ ដោយសារហាត់គង់មិនមែនជាកីឡា, ហើយគឺលើសផុតប្រការរបស់មនុស្សសាមញ្ញ, ដូច្នោះគឺត្រូវតែមានគោលសីលធម៌និងបរមាណីយខ្ពស់ជាងដើម្បីតម្រូវអ្នកហាត់គង់, ចាំបាច់ត្រូវតែធ្វើបានទើបអាចសម្រេចបានគោលបំណង។ ប៉ុន្តែមនុស្សជាច្រើនសុទ្ធតែគ្មានធ្វើបែបនេះ, គាត់នៅតែជាមនុស្សសាមញ្ញ, ដូច្នេះដល់ពេលវេលាគាត់នៅតែត្រូវកើតជំងឺ។ មានថ្ងៃមួយគាត់ស្រាប់តែកើតអាការៈស្ទះសរសៃឈាមខួរក្បាល, ស្រាប់តែកើតជំងឺនេះ, កើតជំងឺនោះ, ឬក៏មានថ្ងៃមួយកើតជំងឺវិកលចរិត។ គាត់ហាត់គង់អាចនរណាក៏ដឹង, កាលណាឯកជននេះកើតជំងឺវិកលចរិត, គេនឹងនិយាយថាគាត់ហាត់គង់ឆ្កួតវង្វេងអារក្សចូល, មួកធំនេះគឺពាក់ពីលើ។ អ្នករាល់គ្នាគិតសាកមើលធ្វើយ៉ាងនេះសមហេតុផលឬ? មនុស្សក្រៅវិជ្ជាជីវៈមិនដឹង, ពួកយើងមនុស្សក្នុងវិជ្ជាជីវៈ, មនុស្សហាត់គង់ដ៏ច្រើនក៏ដ៏ពិបាកដឹងបានគោលសីលធម៌ពិតប្រាកដខាងក្នុងនេះ។ ប្រសិនឯកជននេះគឺនៅក្នុងផ្ទះកើតជំងឺវិកលចរិតនៅតែងាយស្រួលនិយាយបន្តិច, គេក៏នឹងនិយាយថាគាត់ហាត់គង់ហាត់; ប្រសិនចំនៅលើវាលហាត់គង់គាត់កើតជំងឺវិកលចរិត, ដូច្នោះគឺអាក្រក់ហើយ, មួកធំមួយនេះនឹងពាក់ឡើងលើ, ដោះក៏ដោះចេញមិនបានទៀត។ ហាត់គង់ឆ្កួតវង្វេងអារក្សចូល, កាសែតសុទ្ធតែនឹងបោះពុម្ពផ្សាយ។ មនុស្សខ្លះជាក់ស្ដែងគឺបិទភ្នែកប្រឆាំងឈីគង់៖ "លោក

មើលទើបនៅទីនោះហាត់បានល្អណាស់, ឥឡូវទៅជាបែបនេះហើយ”។ ធ្វើជាមនុស្សសាមញ្ញម្នាក់, គាត់គួរតែលេចឡើងរឿងរ៉ាវអ្វីគឺនឹងលេចឡើង, គាត់អាចក៏លេចឡើងជំងឺផ្សេងទៀត, លេចឡើងរំខានផ្សេងៗ, សុទ្ធតែនិយាយថាគឺដោយសារហាត់គង់ហាត់, សមហេតុផលឬ? ក៏ដូចជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យរបស់ពួកយើង, គាត់ធ្វើវេជ្ជបណ្ឌិត, មួយជីវិតនេះរបស់គាត់គឺជានិច្ចមិនគួរកើតជំងឺ, អាចយល់ដឹងបែបនេះឬ?

ដូច្នេះនិយាយថា, មានមនុស្សជាច្រើនគាត់មិនយល់ច្បាស់កាលៈទេសៈមែនទែនរបស់ឈីគង់, គាត់ក៏មិនដឹងគោលសីលធម៌នៅខាងក្នុង, ហើយនិយាយរញ៉េរញ៉ៃ។ កាលណាមានបញ្ហាអ្វី, មួកអ្វីក៏ពាក់ឡើងលើឈីគង់ទីនេះ។ ពេលវេលាជាសកលឈីគង់នៅលើសង្គមដ៏ខ្លី, មានមនុស្សជាច្រើនកំពុងឱបយកប្រភេទគោលគំនិតប្រកាន់មួយ, តែងតែមិនទទួលស្គាល់វា, មួលបង្កាច់វា, ច្រានចោលវា, ក៏មិនដឹងថាស្ថានភាពផ្លូវចិត្តរបស់គាត់ជាអ្វី, គាត់គឺស្អប់ឈីគង់យ៉ាងនេះ, ហាក់ដូចជាមានអ្វីទាក់ទងជាមួយគាត់, កាលណាលើកឡើងឈីគង់គឺនិយាយថាជាឧត្តមគតិ។ ឈីគង់គឺជាវិទ្យាសាស្រ្ត, គឺជាវិទ្យាសាស្រ្តខ្ពស់ជាង។ គ្រាន់តែជាគោលគំនិតរបស់មនុស្សប្រភេទនោះប្រកាន់ពេក, ចំណេះដឹងតូចចង្អៀតពេកបង្កឡើង។

នៅមានប្រភេទកាលៈទេសៈមួយទៀត, នៅពិភពឈីគង់មានប្រភេទមួយហៅថាឈីគង់ថាយ, ប្រភេទមនុស្សនេះស្មារតីស្រពិចស្រពិល, តែគាត់ក៏មិនមែនឆ្លុតវង្វេងអារក្សចូល, គាត់គឺសែនវិចារណញ្ញាណ។ មុនដំបូងខ្ញុំនិយាយអំពីឈីគង់ថាយគឺជារឿងដូចម្តេច។ អ្នករាល់គ្នាដឹងថា, ពួកយើងហាត់គង់យកចិត្តទុកដាក់លើបញ្ហានិស្ស័យ។ នៅប្រទេសទាំងអស់ទូទាំងពិភពលោកសុទ្ធតែមានមនុស្សជំនឿលើសាសនា, ហើយនៅ

ប្រទេសចិនរាប់ពាន់ឆ្នាំមកសុទ្ធតែមានមនុស្សជឿពុទ្ធសាសនា, តាវសាសនា, ជឿថាសាងល្អបានល្អ, សាងអាក្រក់បានអាក្រក់។ តែមានមនុស្សមួយចំនួនមិនជឿ។ ជាពិសេសនៅអំឡុងពេល [មហាបដិវត្តវប្បធម៌] គឺត្រូវបានរិះគន់, និយាយថាជាអបិយជំនឿ។ មានមនុស្សមួយចំនួនគាត់សន្មតថាមិនអាចពន្យល់, ពីលើសៀវភៅមិនទាន់រៀនដល់, វិទ្យាសាស្ត្រទំនើបមិនទាន់អភិវឌ្ឍដល់ជំហានមួយនោះ, ឬក៏ជារឿងការណ៍មិនទាន់បានទទួលស្គាល់, គាត់បង្រួមមកនិយាយថាជាអបិយជំនឿ។ មនុស្សប្រភេទនេះប៉ុន្មានឆ្នាំមុនច្រើនណាស់, បច្ចុប្បន្នតិចបង្គួរ។ ដោយសារមានបាតុភូតមួយចំនួនលោកអ្នកមិនទទួលស្គាល់វា, ប៉ុន្តែវាប្រាកដជាក់ស្តែងបានឆ្លុះបញ្ចាំងមកដល់ក្នុងអវកាសនេះរបស់ពួកយើងរួចហើយ។ លោកអ្នកមិនហ៊ានប្រឈមមុខនឹងវា, ប៉ុន្តែបច្ចុប្បន្នគេសុទ្ធតែហ៊ានយកវានិយាយចេញមក, គេបានស្តាប់បានឃើញក៏យល់ដឹងបានកាលៈទេសៈមួយចំនួនទាក់ទងដល់ហាត់គង់។

មានមនុស្សមួយចំនួនគឺប្រកាន់ដល់កម្រិតនេះ៖ កាលណាលោកអ្នកនិយាយអំពីឈីគង់, ពីក្នុងចិត្តរបស់គាត់សើចលោកអ្នក, គាត់សន្មតថាលោកអ្នកគឺធ្វើអបិយជំនឿ, គួរឲ្យអស់សំណើច។ កាលណាលោកអ្នកនិយាយអំពីបាតុភូតក្នុងឈីគង់, គាត់គឺមានអារម្មណ៍ថាមនុស្សលោកអ្នកនេះឆោតល្ងង់ពេក។ ប្រភេទមនុស្សនេះទោះបីជាប្រកាន់, ប៉ុន្តែនិស្ស័យមិនប្រាកដថាមិនល្អ។ ប្រសិននិស្ស័យឯកជននេះល្អ, ប្រសិនគាត់ហាត់គង់, ភ្នែកទិព្វអាចគឺនឹងបើកដល់ជាន់ថ្នាក់ដ៏ខ្ពស់, នៅទាំងអាចលេចឡើងសីលគង់។ គាត់មិនជឿឈីគង់, តែគាត់មិនអាចធានាថាខ្លួនឯងមិនកើតជំងឺ, ប្រសិនគាត់កើតជំងឺទៅដល់មន្ទីរពេទ្យពិនិត្យ, វេជ្ជសាស្ត្របស្ចិមប្រទេសពិនិត្យមិនជាទៅដល់ឱសថបុរាណចិនពិនិត្យ,

ឱសថបុរាណចិនក៏ពិនិត្យមិនជា, វេជ្ជបញ្ញាពិសេសអ្វីក៏ពិនិត្យមិនជា, ពេលនេះគាត់បានគិតដល់ឈីគង់។ គាត់ពិចារណា៖ "យើងទៅសាកសំណាងមើល, មើលសាកមើលនៅទីបញ្ចប់ឈីគង់អាចឬមិនអាចព្យាបាលជំងឺនេះរបស់យើង"។ គាត់មកដោយដ៏មិនស្ម័គ្រចិត្ត។ ពេលណាគាត់ហាត់គង់, ដោយសារនិស្ស័យដ៏ល្អ, ភ្លាមៗគឺអាចហាត់បានដ៏ល្អ។ អាចជាមានគ្រូណាមួយចាប់អារម្មណ៍លើ, នៅក្នុងអវកាសដទៃជីវិតកម្រិតខ្ពស់នោះគឺបានជួយគាត់បន្តិច។ គាត់ភ្លាមពេលនេះគឺបើកភ្នែកទិព្វ, ឬក៏ស្ថិតក្នុងស្ថានភាពត្រាស់ដឹងពាក់កណ្តាល។ ភ្នែកទិព្វបើកដល់ជាន់ថ្នាក់ដ៏ខ្ពស់, មួយរំពេចមើលឃើញបានកាលៈទេសៈពិតមែនមួយចំនួនក្នុងចក្រវាល, លើសពីនេះទៀតមានទាំងសីលគង់ទៀតផង។ លោកអ្នកនិយាយមើលប្រភេទមនុស្សនេះមើលឃើញកាលៈទេសៈនេះ, ខួរក្បាលរបស់គាត់អាចទ្រាំទ្របានឬ? លោកអ្នកគិតស្ថានភាពផ្លូវចិត្តនោះរបស់គាត់គឺជាបែបណា? ពីដើមមកសន្មតថាគឺជារឿងរ៉ាវអបិយជំនឿ, ជាដាច់ខាតមិនអាច, រឿងរ៉ាវកាលណាអ្នកដទៃលើកឡើងសុទ្ធតែគួរឲ្យសើច, លាតត្រដាងយ៉ាងជាក់ស្តែងចំពោះមុខគាត់, ហើយប្រាកដជាក់ស្តែងទាក់ទងដល់បាន។ ដូច្នោះខួរធំរបស់គាត់នឹងទ្រាំទ្រមិនបាន, សម្ពាធស្មារតីរបស់គាត់សែនធំ, ពាក្យដែលនិយាយចេញអ្នកដទៃមិនទទួលយកបាន, ប៉ុន្តែផ្នត់គំនិតតក្កវិជ្ជាមិនច្របូកច្របល់, គាត់គ្រាន់តែជារៀបដាក់មិនបានត្រឹមត្រូវទំនាក់ទំនងសងខាង។ គាត់រកឃើញថា, រឿងរ៉ាវដែលមនុស្សជាតិធ្វើគឺខុស, ហើយនៅខាងនោះជាញឹកញាប់គឺត្រូវ។ យោងតាមខាងនោះដើម្បីធ្វើ, គេនឹងនិយាយគាត់គឺខុស។ គេមិនពន្យល់បាន, ដូច្នេះគឺនិយាយថាឯកជននេះហាត់គង់ឆ្គួតវង្វេងអារក្សចូល។

ភាពពិតគាត់មិនមែនឆ្គួតវង្វេងអារក្សចូល, មនុស្សភាគច្រើនពួក

យើងហាត់គង់នឹងមិនលេចឡើងបាតុភូតនេះ, មានតែមនុស្សប្រកាន់ពិសេសទាំងនោះទើបលេចឡើងប្រភេទឈើគង់ថាយនេះ។ មនុស្សពួកយើងដែលកំពុងអង្គុយមានជាច្រើនបើកភ្នែកទិព្វរួចហើយ, ដ៏ច្រើន។ គាត់ប្រាកដជាក់ស្តែងបានមើលឃើញប្រការនៃអវកាសផ្សេង, គាត់មិនមានអារម្មណ៍ភ្ញាក់ផ្អើល, មានអារម្មណ៍ដ៏ល្អ, ខួរធំនឹងមិនទទួលរងរំញោចអ្វី, ក៏នឹងមិនលេចឡើងប្រភេទឈើគង់ថាយនេះ។ បន្ទាប់ពីមនុស្សលេចឡើងឈើគង់ថាយ, គឺសែនវិចារណញ្ញាណ, ពាក្យដែលបាននិយាយមានចរិតទស្សនវិជ្ជាខ្លាំងណាស់, លើសពីនេះចរិតតក្កវិជ្ជាដ៏ល្អ។ គ្រាន់តែជាពាក្យគាត់និយាយចេញ, មនុស្សសាមញ្ញមិនជឿ។ ពេលខ្លះគាត់ប្រាប់លោកអ្នក, និយាយថាគាត់មើលឃើញនរណាម្នាក់បានស្លាប់រួចហើយ, ម្នាក់នោះប្រាប់គាត់ធ្វើអ្វីៗ។ មនុស្សសាមញ្ញគាត់អាចជឿបានឬ? ក្រោយមកគាត់យល់បាន, ទាំងនេះគួរដាក់នៅក្នុងចិត្តខ្លួនឯង, មិនអាចនិយាយ, រៀបដាក់ឱ្យត្រឹមត្រូវទំនាក់ទំនងសងខាងបន្ទាប់មកគឺល្អ។ ជាញឹកញាប់មនុស្សទាំងនេះសុទ្ធតែអមតាមមានសីលគង់ស្ថិតនៅ, នេះក៏មិនមែនឆ្កួតវង្វេងអារក្សចូល។

នៅមានប្រភេទកាលៈទេសៈមួយទៀតហៅថា "ច្ងិនហ្វឹង", ប្រភេទកាលៈទេសៈនេះគឺតិចជួបជាទីបំផុត។ "ច្ងិនហ្វឹង" ដែលយើងខ្ញុំនិយាយមិនមែនឆ្កួតពិត, មិនមែនបង្កប់ន័យនេះ, គឺបង្កប់ន័យថាបួសសច្ចៈ។ "ច្ងិនហ្វឹង" គឺជារឿងដូចម្តេច? ខ្ញុំនិយាយថាក្នុងចំណោមមនុស្សបួសហាត់, ក្នុងចំណោមមនុស្ស១ម៉ឺននាក់អាចមានមនុស្សម្នាក់យ៉ាងនេះ, តិចជួបជាទីបំផុត។ ដូច្នេះវាមិននាំតាមចរិតជាសកល, ក៏គ្មានបង្កជាឥទ្ធិពលដល់សង្គម។

"ច្ងិនហ្វឹង" ជាញឹកញាប់មានលក្ខខណ្ឌជាមុនមួយ, ជាក់ស្តែងគឺ

និស្ស័យឯកជននេះសែនល្អ, នៅត្រូវតែអាយុកាលដ៏ច្រើន។ ពេលអាយុកាលច្រើន, ចង់បួសហាក់បានយឺតពេលរួចហើយ។ និស្ស័យសែនល្អជាញឹកញាប់គឺមាននាំតាមបេសកកម្ម, គឺជាមកពីលើជាន់ថ្នាក់ខ្ពស់។ សង្គមនេះរបស់មនុស្សសាមញ្ញនរណាមកក៏ភ័យខ្លាច, ខួរក្បាលកាលណាលុបលាងរួចហើយនរណាក៏មិនស្គាល់ទៀត។ មកដល់ក្នុងបរិយាកាសសង្គមនេះរបស់មនុស្សសាមញ្ញ, ជ្រៀតជ្រែករបស់គេចំពោះគាត់, នឹងធ្វើឲ្យគាត់ឱ្យតម្លៃកិត្តិនាម, ឱ្យតម្លៃផលប្រយោជន៍, ចុងក្រោយគឺធ្លាក់ចុះក្រោម, ជានិច្ចគ្មានថ្ងៃងើបក្បាលឡើងបាន, ដូច្នេះនរណាក៏មិនហ៊ានមក, នរណាក៏ភ័យខ្លាច។ មានមនុស្សបែបនេះមក, ក្រោយពីមករួចហើយ, គាត់នៅក្នុងមនុស្សសាមញ្ញពិតជាគឺមិនបានទៀត, ពិតជាគឺត្រូវតែធ្លាក់ចុះ, មួយជីវិតបានធ្វើរឿងអាក្រក់មិនតិច។ ពេលដែលមនុស្សរស់ព្រោះតែប្រយោជន៍ឯកជនទៅប្រជែងគឺនឹងធ្វើរឿងអាក្រក់ដ៏ច្រើន, គឺនឹងជំពាក់របស់ដ៏ច្រើន។ គ្រូរបស់គាត់មើលឃើញថា, ឯកជននេះគង់នឹងធ្លាក់ចុះក្រោម។ ប៉ុន្តែគាត់ក៏ជាម្នាក់មានផលញាណ, មិនអាចតាមអំពើចិត្តបែបនេះទុកឲ្យគាត់ធ្លាក់ចុះ! ធ្វើដូចម្តេច? ក៏បារម្មណ៍ណាស់, គ្មានវិធីសាស្ត្រផ្សេងដើម្បីហៅគាត់បួសហាត់, ពេលនោះឡើងទីណាដើម្បីរកគ្រូ? គាត់ត្រូវតែត្រឡប់ក្រោយសាជាថ្មី, បួសត្រឡប់ក្រោយ។ ប៉ុន្តែនិយាយងាយស្រួលពេកហើយ? អាយុកាលក៏ច្រើន, បួសក៏យឺតពេលរួចទៅហើយ, ឡើងទីណាដើម្បីរកគង់ហ្វាចរិតជីវិតបួសទាំងទ្វេ?

ចាំបាច់គឺជាមនុស្សដែលនិស្ស័យសែនល្អ, នៅក្រោមកាលៈទេសៈយ៉ាងពិសេសបំផុតនេះ, ទើបអាចជ្រើសយកវិធីសាស្ត្រទុកឲ្យគាត់ឆ្កួត។ ក៏មានន័យថាជាដាច់ខាតគ្មានសង្ឃឹមទៀត, នៅក្រោមកាលៈទេសៈដែលខ្លួនឯងមិនអាចត្រឡប់ក្រោយ, អាចជ្រើសយកវិធីសាស្ត្រមួយបែប

នេះ, ជាក់ស្ដែងគឺទុកឲ្យគាត់ឆ្កួត, យកទីតាំងណាមួយនៃខួរក្បាលរបស់គាត់បិទជិតឲ្យគាត់។ ឧបមាថាមនុស្សពួកយើងខ្លាចត្រជាក់, ខ្លាចប្រទាក់, យកទីតាំងខ្លាចត្រជាក់នេះនៃខួរក្បាលបិទជិតឲ្យគាត់, ទីតាំងខ្លាចប្រទាក់នេះបិទជិតឱ្យគាត់។ បន្ទាប់ពីបិទជិតទីតាំងមួយចំនួនឲ្យគាត់រួចហើយ, ស្មារតីរបស់ឯកជននេះគឺលេចឡើងបញ្ហា, ពិតជាភ្លីភ្លើៗ។ ប៉ុន្តែជាញឹកញាប់មនុស្សបែបនេះមិនធ្វើរឿងអាក្រក់, មិនជេរមនុស្សក៏មិនវាយមនុស្ស, ជាញឹកញាប់ក៏ធ្វើរឿងល្អទៀតផង។ ប៉ុន្តែផ្ទុយមកវិញគាត់ចំពោះខ្លួនឯងគឺឃោរឃៅណាស់។ ដោយសារគាត់មិនដឹងត្រជាក់, ដូច្នេះសិសិរដូវគាត់រត់នៅក្នុងព្រិលដោយជើងទទេ, ពាក់ខោអាវស្តើង, កកដល់ថ្នាក់ជើងប្រេះស្រាំហូរឈាម; ដោយសារគាត់មិនដឹងប្រទាក់, លាមកគាត់ក៏ហ៊ានស៊ី, ទឹកនោមគាត់ក៏ហ៊ានផឹក។ អតីតកាលខ្ញុំបានដឹងមានមនុស្សម្នាក់បែបនេះ, ដុំលាមកសេះនោះកករឹងក្រញង់, គាត់អង្គៀមមកដូចជាឈ្ងុយណាស់, គាត់អាចរងបានទុក្ខដែលមនុស្សសាមញ្ញនៅក្រោមស្ថានភាពច្បាស់លាស់មិនអាចរង។ លោកអ្នកគិតគាត់ឆ្កួតមួយនេះត្រូវទទួលរងទោសច្រើនប៉ុណ្ណា, ប្រាកដណាស់គាត់ជាញឹកញាប់មាននាំតាមសីលគង់ស្ថិតនៅ, ធម្មតាច្រើនតែស្ត្រីចំណាស់។ អតីតកាលស្ត្រីចំណាស់គឺរុំជើងឲ្យតូច, ជញ្ជាំងខ្ពស់ជាងពីរម៉ែត្រ, រត់ទៅលោតមួយគឺឆ្លងផុតបាន។ អ្នកក្នុងផ្ទះកាលណាមើលឃើញនាងឆ្កួត, រមែងរត់ចេញខាងក្រៅ, ក៏ចាក់សោឲ្យនៅក្នុងផ្ទះ។ រង់ចាំបន្ទាប់ពីអ្នកផ្ទះចេញបាត់រួច, ចង្កុលមួយមេសោនោះគឺបើកចេញ, ដើរចេញទៀត។ ដូច្នោះគឺប្រើខ្សែច្រវ៉ាក់ចាក់សោ, រង់ចាំបន្ទាប់ពីអ្នកផ្ទះចេញបាត់រួច, អង្រួនមួយខ្សែច្រវ៉ាក់ក៏បើកចេញ។ គ្រប់គ្រងគាត់យ៉ាងណាក៏មិនជាប់, ជាក់ស្ដែងបែបនេះគាត់នឹងរងទុក្ខដ៏ច្រើន។ ដោយសារគាត់រងទុក្ខរង

សែនកាចសាហាវ, ទទួលបានក៏សែនខ្លាំងក្លា, គាត់នឹងយកអ្វីមិនល្អដែលជំពាក់សងបានដ៏ឆាប់រហ័ស។ ច្រើនបំផុតមិនហួស៣ឆ្នាំ, ធម្មតា១, ២ឆ្នាំគឺឆ្លងផុតបាន, ទុក្ខនោះដែលទទួលរងគឺធំណាស់។ បន្ទាប់ពីឆ្លងផុតដោយភ្លាមៗយល់ច្បាស់ចេញបាន, ដោយសារគាត់នេះចាត់ថាបានបួសហាត់បញ្ចប់រួចហើយ, ដូច្នេះដោយភ្លាមៗគឺបើកគង់, ទេពអំណាចគ្រប់ប្រភេទសុទ្ធតែនឹងលេចចេញ។ នេះគឺយ៉ាងតិចឃើញបំផុតៗ, ក្នុងប្រវត្តិសាស្ត្រមានបែបនេះ, ក៏មិនមែនមនុស្សនិស្ស័យធម្មតាម្នាក់អាចទុកឲ្យលោកអ្នកធ្វើបែបនេះ។ អ្នករាល់គ្នាបានដឹងមានព្រះសង្ឃឆ្កួត, តាវ{វត្តិ}ឆ្កួត, ក្នុងប្រវត្តិសាស្ត្រមែនទែនមាន, មានកំណត់ត្រា។ អ្វី "សង្ឃឆ្កួតបោសឃើន", តាវវត្តិឆ្កួត, សម្រង់បុរាណនេះច្រើនណាស់។

ឆ្កួតវង្វេងអារក្សចូល, យើងខ្ញុំនិយាយបញ្ជាក់ថាគឺមិនស្ថិតនៅ។ និយាយថានរណាមួយអាចឆ្កួតវង្វេង, បើសិនពិតជាអាចបែបនេះ, ខ្ញុំនិយាយថាឯកជននេះអស្ចារ្យណាស់។ អាចបើកមាត់ផ្លុំចេញភ្លើង, អាចសន្ទឹងដៃភ្លាមបញ្ចេញភ្លើង, ដុតបារីសន្ទឹងដៃចង្អុលភ្លាមគឺភ្លើងមក, ខ្ញុំនិយាយនោះគឺជាសីលគង់។

## ហាត់គង់អន្ទងខ្មោច

ហាត់គង់អន្ទងខ្មោចជាអ្វី? នោះគឺពេលដែលពួកយើងហាត់គង់, ជាញឹកញាប់ងាយស្រួលទទួលរងជ្រៀតជ្រែកមួយចំនួន។ ហាត់គង់ធ្វើម្តេចអន្ទងខ្មោចមកបាន? ដោយសារមនុស្សម្នាក់ចង់បួសហាត់ដោយពិតសែនពិបាក, បួសពិតគ្មានបរមីរបស់ខ្ញុំការពារ, លោកអ្នកជាមូលដ្ឋានគឺបួសមិនសម្រេច, លោកអ្នកចេញពីទ្វារកាលណាគឺអាចពាក់ព័ន្ធដល់បញ្ហាជីវិត។ វិញ្ញាណដើមរបស់មនុស្សគឺអមតៈ, ដូច្នោះលោកអ្នកនៅក្នុងសកម្មភាពសង្គមជាតិមុន, អាចជាធ្លាប់ជំពាក់នរណា, ធ្លាប់សម្លុតក្បត់

នរណា, ឬក៏ធ្លាប់ធ្វើរឿងរ៉ាវអ្វីមិនល្អ, ម្ចាស់បំណុលនោះគឺនឹងរកលោកអ្នក។ នៅក្នុងពុទ្ធសាសនាសម្ដែង៖ មនុស្សរស់ជាក់ស្ដែងគឺជាបង្វិលកម្មផល។ លោកអ្នកជំពាក់គាត់, គាត់មករកលោកអ្នកទារបំណុល, យកច្រើនលើសលើកក្រោយគាត់សងលោកអ្នកវិញ។ កូនអកតញ្ញូចំពោះឪម៉ែ, លើកក្រោយបញ្ច្រាសមកវិញ, ពោលគឺវិលមកវិលទៅបែបនេះ។ ប៉ុន្ដែយើងខ្ញុំមែនទែនមើលឃើញមានខ្មោចកំពុងជ្រៀតជ្រែក, មិនទុកឱ្យលោកអ្នកហាត់គង់, នេះសុទ្ធតែជាមានទំនាក់ទំនងកម្មផល, មិនមែនដោយគ្មានហេតុផល, ដោយគ្មានហេតុផលក៏មិនអនុញ្ញាតឱ្យវាបែបនេះ។

ប្រភេទទម្រង់ហាត់គង់អន្ទងខ្មោចមួយជាទូទៅបំផុត, នោះគឺពេលដែលលោកអ្នកមិនហាត់គង់, បរិយាកាសជុំវិញនៅតែស្ងាត់បង្គួរ។ ដោយសាររៀនគង់រួចហើយ, រមែងចូលចិត្តហាត់, ប៉ុន្ដែកាលណាឆ្ពោះទៅទីនោះអង្គុយសមាធិ, ស្រាប់តែគឺមានអារម្មណ៍ខាងក្រៅមិនស្ងាត់ទៀត។ ត្រែរថយន្ដក៏រោទ៍, នៅច្រករបៀងមានសំឡេងដើរទៅមក, សំឡេងនិយាយគ្នា, សំឡេងគោះទ្វារ, វិទ្យុនៅខាងក្រៅក៏បើក, ជាបន្ទាន់ក៏មិនស្ងាត់ទៀត។ លោកអ្នកមិនហាត់គង់បរិយាកាសនៅតែដ៏ល្អ, កាលណាលោកអ្នកហាត់គង់ជាក់ស្ដែងគឺជាបែបនេះ។ មនុស្សដ៏ច្រើនពួកយើងគ្មានសាកគិតឲ្យស៊ីជម្រៅ, នៅទីបញ្ចប់ជារឿងដូចម្ដេច, គ្រាន់តែមានអារម្មណ៍ចម្លែក, ខកចិត្តណាស់ហាត់មិនបានគង់។ ប្រការចម្លែកមួយគឺរារាំង, នេះជាក់ស្ដែងគឺខ្មោចកំពុងជ្រៀតជ្រែកលោកអ្នក, វាញុះញង់មនុស្សជ្រៀតជ្រែកលោកអ្នក។ នេះជាប្រភេទទម្រង់ជ្រៀតជ្រែកមួយសាមញ្ញបំផុត, សម្រេចបានគោលបំណងមិនទុកឲ្យលោកអ្នកហាត់។ លោកអ្នកហាត់គង់, លោកអ្នកសម្រេចតាវ, ហើយលោកអ្នកជំពាក់

ប្រការច្រើនយ៉ាងនោះលោកអ្នកមិនសង? វាអាចមិនសុខចិត្ត, វានឹងមិនទុកឱ្យលោកអ្នកហាត់។ ប៉ុន្តែនេះក៏ជាឆ្ពុះបញ្ចាំងក្នុងមួយជាន់ថ្នាក់, ឆ្លងមួយដំណាក់កាលពេលវេលាក្រោយមកគឺមិនអនុញ្ញាតឲ្យមានបាតុភូតនេះស្ថិតនៅទៀត, ក៏មានន័យថាក្រោយពីបំណុលនេះឆ្លងផុតរួចហើយ, មិនអនុញ្ញាតឲ្យវាមកជ្រៀតជ្រែកម្ដងទៀត។ ដោយសារបួសហាត់ហ្វាលូនតាហ្វាយើងខ្ញុំបួសបានលឿនបង្គួរ, ទម្លុះជាន់ថ្នាក់ក៏ជាលឿនបង្គួរ។

នៅមានប្រភេទទម្រង់ជ្រៀតជ្រែករបស់ខ្មោចមួយទៀត។ អ្នករាល់គ្នាដឹងថាពួកយើងហាត់គង់អាចបើកភ្នែកទិព្វ, មនុស្សខ្លះបន្ទាប់ពីបើកភ្នែកទិព្វរួចហើយនៅផ្ទះហាត់គង់, នឹងមើលឃើញទស្សនីយភាពភ័យខ្លាចមួយចំនួន, តួមុខគួរឲ្យភ័យខ្លាច។ មានខ្លះក្បាលសំពោងសក់សំយាក, មានខ្លះចង់ប្រយុទ្ធ{ដល់}ស្លាប់នឹងលោកអ្នក, សូម្បីតែធ្វើចេញមកកម្រើកគ្រប់ប្រភេទ, ដ៏បន្លាចមនុស្ស។ មានពេលខ្លះកាលណាហាត់គង់មើលឃើញខាងក្រៅបង្អួចវារៗសុទ្ធតែជា{របស់}ទាំងនេះ, ដ៏បន្លាចមនុស្ស។ ហេតុអ្វីបានជាលេចឡើងកាលៈទេសៈនេះ? នេះសុទ្ធតែជាទម្រង់ជ្រៀតជ្រែករបស់ខ្មោច។ ប៉ុន្តែនៅក្នុងធម្មក្ខន្ធហ្វាលូនតាហ្វាមួយនេះរបស់យើងខ្ញុំ, ប្រភេទកាលៈទេសៈនេះយ៉ាងតិចឃើញបំផុត, មួយភាគរយ, ភាគច្រើនសុទ្ធតែនឹងមិនជួបប្រទះកាលៈទេសៈនេះ។ ដោយសារវាគ្មានកន្លែងល្អអ្វីសម្រាប់ហាត់គង់របស់ពួកយើង, ដូច្នេះគឺមិនអនុញ្ញាតឲ្យវាជ្រើសប្រើប្រភេទទម្រង់នេះមកជ្រៀតជ្រែកលោកអ្នក។ នៅក្នុងបួសហាត់របស់គង់ហ្វាធម្មតា, រឿងនេះជាក់ស្ដែងគឺជាបាតុភូតមួយជាទូទៅបំផុត, ថែមទាំងត្រូវបន្តពេលវេលាដ៏យូរ។ មនុស្សខ្លះជាក់ស្ដែងគឺដោយសារ{រឿង}នេះហាត់មិនបានគង់, រន្ធត់ខ្លាំងណាស់។ ហាត់គង់ពេលយប់សុទ្ធតែជារើសបរិយាកាសដ៏ស្ងាត់, កាលណាឃើញមនុស្ស

ម្នាក់ឈរពីមុខ, មនុស្សមិនមនុស្សព្រាយមិនព្រាយ, រន្ធត់គឺមិនហ៊ាន ហាត់ទៀត។ នៅក្នុងហ្វាលូនតាហ្វាពួកយើងជាធម្មតាគ្មានបាតុភូតនេះ, ប៉ុន្តែយ៉ាងដោយឡែកបំផុតនៅតែមាន, មនុស្សខ្លះកាលៈទេសៈគឺយ៉ាង ពិសេសបំផុត។

នៅមានប្រភេទមួយទៀតជាក់ស្ដែងគឺជាហាត់គង់ហ្វាបួសទាំងក្នុង ក្រៅ, គាត់ទាំងហាត់ក្បាច់គុនទាំងបួសខាងក្នុង, គង់ហ្វាបែបនេះនៅក្នុង តាវវង្សជួបច្រើនបង្គួរ។ មនុស្សពេលណារៀនប្រភេទគង់ហ្វានេះ, ជាញឹក ញាប់នឹងជួបប្រទះប្រភេទខ្មោចបែបនេះ។ គង់ហ្វាធម្មតាមិនជួបប្រទះ, មានតែគង់ហ្វាបួសទាំងក្នុងក្រៅ, គង់ហ្វាហាត់ក្បាច់គុនទើបមាន, ជាក់ ស្ដែងគឺមានមនុស្សរកគាត់ប្រកួតក្បាច់គុន។ ដោយសារលើពិភពលោក មានមនុស្សបួសតាវជាច្រើន, មានដ៏ច្រើនគឺហាត់ក្បាច់គុន, បួសទាំងក្នុង ក្រៅ។ មនុស្សហាត់ក្បាច់គុន, គាត់ក៏អាចបង្កើនគង់។ ហេតុអ្វី? បន្ទាប់ពី គាត់កម្ចាត់ចោលចិត្តផ្សេងៗ, កិត្តិនាម, ផលប្រយោជន៍ចិត្តទាំងនេះ, គាត់ក៏បង្កើនគង់។ ប៉ុន្តែចិត្តប្រជែងប្រយុទ្ធរបស់គាត់ពន្យាជាយូរមិន ចោល, ចោលបានក៏យឺតបង្គួរ, ដូច្នេះគាត់ងាយស្រួលធ្វើចេញមករឿងរ៉ាវ ប្រភេទនេះ, នៅក្នុងជាន់ថ្នាក់ជាក់លាក់នៅតែនឹងលេចឡើង។ ក្នុងពេល អង្គុយសមាធិក្នុងពេលអណ្តែតអណ្តូងគាត់ដឹងបាននរណាៗកំពុងហាត់ គង់, ហើយវិញ្ញាណដើមឃ្លាតពីកាយទៅរកគេប្រកួតក្បាច់គុន, មើល នរណាជំនាញការខ្ពស់, លេចឡើងការប្រជែងប្រយុទ្ធនេះ។ នៅអវកាស ផ្សេងក៏លេចឡើងប្រភេទកាលៈទេសៈនេះ, ក៏មានអ្នកខ្លះមករកគាត់ ប្រជែងប្រយុទ្ធ, វាយគ្នា, ប្រសិនមិនវាយ, ពិតជានឹងសម្លាប់គាត់, គឺវាយ គ្នាទៅមក, វាយមកវាយទៅ។ កាលណាគេងគឺមានមនុស្សរកគាត់ប្រកួត ក្បាច់គុនដើម្បីប្រជែងប្រយុទ្ធ, ធ្វើឲ្យមួយយប់ក៏សំរាកមិនបាន។ ភាពពិត

ពេលនេះជាក់ស្ដែងគឺដើម្បីកម្ចាត់ចិត្តប្រជែងប្រយុទ្ធរបស់គាត់, ចិត្តប្រជែងប្រយុទ្ធនេះរបស់គាត់ប្រសិនមិនកម្ចាត់ចោល, គាត់រមែងជាបែបនេះ, បន្ដយូរដូចនេះ, ប៉ុន្មានឆ្នាំអូសបន្ដក៏ជាចេញមិនបានជាន់ថ្នាក់នេះ។ ធ្វើឲ្យឯកជននេះក៏ជាហាត់មិនបានគង់, រាងកាយសារធាតុនេះក៏ទ្រាំទ្រមិនបាន, ថាមពលបង្ខិនក៏សែនធំ, ធ្វើមិនល្អគឺពិការ។ ដូច្នេះនៅក្នុងគង់ហ្វាបួសទាំងក្នុងក្រៅនឹងជួបប្រទះប្រភេទកាលៈទេសៈនេះ, លើសពីនេះនៅតែជាទូទៅខ្លាំងណាស់។ ក្នុងគង់ហ្វាបួសខាងក្នុងពួកយើងគ្មានប្រភេទកាលៈទេសៈនេះ, មិនអនុញ្ញាតឲ្យវាលេចឡើង។ ប៉ុន្មានប្រភេទទម្រង់នេះដែលខ្ញុំទើបតែសម្ដែងសុទ្ធតែជាស្ថិតនៅជាទូទៅបង្គួរ។

នៅមានប្រភេទទម្រង់ជ្រៀតជ្រែករបស់ខ្មោចមួយទៀត, ក៏ជានរណាៗសុទ្ធតែអាចជួបប្រទះ, ធម្មក្ខន្ធមួយនេះរបស់ពួកយើងក៏ជានរណាៗសុទ្ធតែអាចជួបប្រទះ, ជួបប្រទះខ្មោចសម្រស់។ ប្រការនេះធ្ងន់ធ្ងរខ្លាំងណាស់។ នៅក្នុងសង្គមមនុស្សសាមញ្ញមានជីវិតប្ដីប្រពន្ធ, ទើបអាចធ្វើឲ្យសង្គមមនុស្សជាតិរីករាលដាលជំនាន់ក្រោយ។ មនុស្សជាតិជាក់ស្ដែងគឺអភិវឌ្ឍន៍បែបនេះ, ខាងក្នុងសង្គមមនុស្សជាតិជាក់ស្ដែងគឺមាន "ស្នេហា" មួយនៅ, ដូច្នេះរឿងរ៉ាវនេះសម្រាប់មនុស្សសាមញ្ញដើម្បីនិយាយជាក់ស្ដែងគឺសមតាមគោលការណ៍មេឃដី។ ដោយសារមនុស្សមានស្នេហានៅ, ខឹងជាស្នេហា, សប្បាយជាស្នេហា, ស្រឡាញ់ជាស្នេហា, ស្អប់ក៏ជាស្នេហា, ចូលចិត្តធ្វើរឿងជាស្នេហា, មិនចូលចិត្តធ្វើរឿងក៏ជាស្នេហា, ឃើញនរណាល្អនរណាមិនល្អ, ស្រឡាញ់ធ្វើអ្វីមិនស្រឡាញ់ធ្វើអ្វី, ទាំងអស់សុទ្ធតែជាស្នេហា, មនុស្សសាមញ្ញជាក់ស្ដែងគឺព្រោះតែស្នេហាដើម្បីរស់។ ដូច្នោះធ្វើជាមនុស្សហាត់គង់ម្នាក់, មនុស្សវិសាមញ្ញម្នាក់, គឺមិនអាចប្រើគោលសីលធម៌នេះដើម្បីវាស់វែង, ត្រូវទម្លុះ

ប្រការនេះ។ ដូច្នេះមានចិត្តប្រកាន់ដ៏ច្រើនកើតចេញមកពីក្នុងស្នេហា, ពួកយើងគឺត្រូវតែមើលវាឲ្យស្រាល, ចុងក្រោយបោះចោលទាំងស្រុង។ តណ្ហានិងសម្រស់ប្រការទាំងនេះសុទ្ធតែជាស្ថិតក្នុងចិត្តប្រកាន់នៃមនុស្ស, ប្រការទាំងនេះសុទ្ធតែគួរកម្ចាត់ចោល។

ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំ, ផ្នែកបួសហាត់មួយនេះនៅក្នុងមនុស្សសាមញ្ញគឺមិនមែនហៅលោកអ្នកធ្វើព្រះសង្ឃ, ធ្វើសមណី, យុវជនពួកយើងក៏ត្រូវការរៀបគ្រួសារ។ ដូច្នោះប្រព្រឹត្តដូចម្តេចចំពោះបញ្ហានេះ? ខ្ញុំសម្តែងរួចហើយ, ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំគឺចង្អុលផ្ទាល់ចិត្តមនុស្ស, មិនមែនធ្វើឲ្យលោកអ្នកពិតប្រាកដបាត់ទៅអ្វីខាងផលប្រយោជន៍សម្ភារៈ។ ផ្ទុយស្រទ្បះ, ជាក់ស្តែងគឺនៅក្នុងផលប្រយោជន៍សម្ភារៈរបស់មនុស្សសាមញ្ញដើម្បីហាត់ពត់ចិត្តចរិតរបស់លោកអ្នក, ពិតប្រាកដលើកកម្ពស់ជាក់ស្តែងគឺចិត្តចរិតរបស់លោកអ្នក។ ចិត្តនេះរបស់លោកអ្នកអាចដាក់ចុះបាន, គឺអ្វីលោកអ្នកក៏អាចដាក់ចុះបាន, នៅលើផលប្រយោជន៍សម្ភារៈហៅលោកអ្នកដាក់{ចុះ}, ប្រាកដណាស់លោកអ្នកគឺអាចដាក់ចុះបាន។ ចិត្តរបស់លោកអ្នកដាក់ចុះមិនបាន, អ្វីលោកអ្នកក៏ដាក់ចុះមិនបាន, ដូច្នេះគោលបំណងបួសហាត់ពិតប្រាកដគឺបួសចិត្តនោះ។ បួសហាត់ខាងក្នុងវត្តវាបង្ខំលោកអ្នកបាត់ទៅប្រការទាំងនេះ, ក៏ជាដើម្បីធ្វើឱ្យលោកអ្នកកម្ចាត់ចោលចិត្តនេះ, វាបង្ខំលោកអ្នក, ធ្វើឱ្យលោកអ្នកកាត់ផ្តាច់វាទាំងស្រុង, មិនទុកឲ្យលោកអ្នកគិតដល់វា, វាគឺជាវិធីសាស្ត្រនេះ។ ហើយយើងខ្ញុំមិនតម្រូវដើរបែបនេះ, យើងខ្ញុំតម្រូវគឺនៅពីមុខផលប្រយោជន៍សម្ភារៈ, លោកអ្នកធ្វើដូចម្តេចមើលវាឱ្យស្រាល, ដូច្នេះធម្មក្ខន្ធមួយនេះរបស់ពួកយើងបួសចេញមកគឺរឹងមាំបំផុត។ មិនមែនហៅលោកអ្នកសុទ្ធតែធ្វើព្រះសង្ឃ, ធ្វើសមណី។ ពួកយើងបួសហាត់

នៅក្នុងមនុស្សសាមញ្ញ, អនាគតគង់ហ្វារបស់ពួកយើងបង្រៀនមួយថ្ងៃកាន់តែទូលាយ, និយាយថានរណាៗសុទ្ធតែក្លាយជាព្រះសង្ឃមិនជាព្រះសង្ឃ, ម្នាក់ៗហាត់ហ្វាលូនតាហ្វាសុទ្ធតែក្លាយជាទម្រង់នេះ, នេះមិនបាន។ ក្នុងហាត់គង់យើងខ្ញុំតម្រូវអ្នករាល់គ្នា៖ លោកអ្នកហាត់គង់គូស្នេហ៍របស់លោកអ្នកអាចមិនហាត់គង់, ដោយសារហាត់គង់ធ្វើឲ្យអ្នកទាំងពីរលែងលះគ្នាក៏មិនបាន។ គឺមានន័យថាពួកយើងមើលរឿងរ៉ាវនេះឲ្យស្រាល, លោកអ្នកមិនអាចដូចមនុស្សសាមញ្ញមើលវាសំខាន់យ៉ាងនោះ។ ជាពិសេសបច្ចុប្បន្នលើសង្គមអ្វីរំដោះផ្លូវភេទ, ប្រការកាមសាស្ត្រទាំងនេះកំពុងជ្រៀតជ្រែកមនុស្ស។ មានមនុស្សមួយចំនួនមើលវាសំខាន់ណាស់, ពួកយើងធ្វើជាមនុស្សហាត់គង់, គឺត្រូវតែមើលវាដ៏ស្រាល។

នៅលើជាន់ថ្នាក់ខ្ពស់សង្កេតមើល, និយាយថាមនុស្សសាមញ្ញនៅក្នុងសង្គមសុទ្ធសាធជាក់ស្តែងជាមួយភក់, មិនខ្លាចប្រឡាក់, នៅលើដីលេងជាមួយភក់។ យើងខ្ញុំសម្តែង, លោកអ្នកមិនអាចព្រោះតែរឿងរ៉ាវនេះធ្វើឱ្យគ្រួសារមិនចុះសម្រុងគ្នា, ដូច្នេះនៅក្នុងដំណាក់កាលនេះដែលលោកអ្នកកំពុងមាន, លោកអ្នកមើលវាឲ្យស្រាល, រក្សាជីវិតប្តីប្រពន្ធសុខដុមតាមធម្មតាគឺបានហើយ, អនាគតដល់ជាន់ថ្នាក់ជាក់លាក់នឹងមានស្ថានភាពនៅជាន់ថ្នាក់នោះ, បច្ចុប្បន្នគឺជាបែបនេះ, យើងខ្ញុំតម្រូវលោកអ្នកធ្វើបែបនេះគឺបានហើយ។ ប្រាកដណាស់មិនអាចដូចជាស្ថានភាពនោះរបស់សង្គមបច្ចុប្បន្ន, មិនបានដូច្នោះ។

ក្នុងចំណោមនេះនៅមានបញ្ហាមួយ, អ្នករាល់គ្នាដឹងថា, មនុស្សហាត់គង់ពួកយើងរាងកាយគឺមានថាមពល។ បច្ចុប្បន្ន៨០ - ៩០ភាគរយមនុស្សពួកយើងបន្ទាប់ពីចាកចេញពីថ្នាក់នេះ, មិនត្រឹមតែជំងឺជាសះ, នៅលេចឡើងគង់ទៀតផង, ដូច្នេះរាងកាយលោកអ្នកនាំតាមថាមពល

ធំខ្លាំងណាស់។ គង់ដែលលោកអ្នកនាំតាមនិងចិត្តចរិតរបស់លោកអ្នកបច្ចុប្បន្នគឺមិនសមាមាត្រ។ បច្ចុប្បន្នលោកអ្នកបណ្ដោះអាសន្នគឺគង់ខ្ពស់ជាង, ជួយលោកអ្នកភ្លាមៗលើកឡើងលើ, បច្ចុប្បន្នកំពុងលើកកម្ពស់ចិត្តចរិតរបស់លោកអ្នក។ សន្សឹមៗលោកអ្នកនឹងឡើងតាមដល់, ធានាក្នុងមួយដំណាក់កាលនេះលោកអ្នកនឹងឡើងតាមដល់, ដូច្នេះយើងខ្ញុំបានធ្វើរឿងរ៉ាវបែបនេះទុកជាមុន, ក៏មានន័យថាលោកអ្នកមានថាមពលជាក់លាក់។ ដោយសារថាមពលបួសហាត់ចេញមកពីសុចរិតធម៌គឺជាមេត្តាបរិសុទ្ធ, ដូច្នេះអ្នករាល់គ្នាអង្គុយនៅទីនេះសុទ្ធតែទទួលដឹងបានវាលមួយសន្តិភាពមេត្តា។ ខ្ញុំហាត់គង់គឺធ្លាប់បានបួសហាត់បែបនេះ, ខ្ញុំមាននាំតាមរបស់នេះ។ អ្នករាល់គ្នាអង្គុយនៅទីនេះសុទ្ធតែមានអារម្មណ៍ដ៏សុខដុម, ក្នុងមនោគតិរបស់មនុស្សគ្មានគំនិតទុច្ចរិត, សូម្បីតែជក់បារីក៏មិនគិតដល់។ អនាគតលោកអ្នកក៏យោងតាមតម្រូវរបស់មហាធម៌យើងខ្ញុំដើម្បីធ្វើ, គង់ដែលលោកអ្នកបួសចេញមកអនាគតក៏ជាបែបនេះ។ ស្របតាមពេលដែលអំណាចគង់របស់លោកអ្នកបន្តកើន, ថាមពលខ្វាត់ខ្វាយនៃគង់នោះនាំតាមរាងកាយលោកអ្នកក៏នឹងធំខ្លាំងបង្គួរ។ បើទោះបីគ្មានខ្លាំងធំយ៉ាងនោះ, មនុស្សធម្មតា, នៅក្នុងវិសាលភាពវាលនេះរបស់លោកអ្នក, ឬក៏លោកអ្នកស្នាក់នៅក្នុងផ្ទះ, លោកអ្នកក៏អាចរឹតត្បិតលើអ្នកដទៃ។ សាច់ញាតិក្នុងផ្ទះលោកអ្នកអាចសុទ្ធតែទទួលរងការរឹតត្បិតរបស់លោកអ្នក។ ហេតុអ្វី? លោកអ្នកក៏មិនចាំបាច់កម្រើកគំនិត, ដោយសារវាលនេះគឺបរិសុទ្ធសន្តិភាព, មេត្តា, ជាវាលរបស់គំនិតសុចរិត, ដូច្នេះគេមិនងាយស្រួលគិតដល់រឿងអាក្រក់, មិនងាយស្រួលធ្វើរឿងរ៉ាវមិនល្អ, នឹងផ្ដើមប្រភេទផលប៉ះពាល់បែបនេះ។

ថ្ងៃនោះខ្ញុំសម្ដែងពន្លឺព្រះពុទ្ធចែងចាំង, សុជីវធម៌មូលភ្លឺថ្លា, ជាក់

ស្តែងគឺនិយាយថាថាមពលខ្វាត់ខ្វាយចេញមកពីរាងកាយពួកយើងអាចកែតម្រង់ទាំងអស់ស្ថានភាពមិនត្រឹមត្រូវ។ ដូច្នោះនៅក្រោមផលប៉ះពាល់របស់វាលនេះ, ពេលដែលលោកអ្នកមិនគិតដល់រឿងរ៉ាវទាំងនេះ, ដោយមិនដឹងខ្លួនក៏រឹតត្បិតជាប់គូស្នេហ៍របស់លោកអ្នក, លោកអ្នកគ្មានកម្រើកគំនិត, លោកអ្នកក៏នឹងមិនកម្រើកប្រភេទគំនិតនេះ, គាត់ក៏មិនគិតដល់។ ប៉ុន្តែមិនមែនជាដាច់ខាត, បច្ចុប្បន្នបរិយាកាសនេះ, បើកទូរទស្សន៍មើលកាលណា, អ្វីក៏មាន, ងាយស្រួលថ្លក់ផ្តើមតណ្ហារបស់មនុស្ស។ ប៉ុន្តែក្រោមកាលៈទេសៈធម្មតា, លោកអ្នកអាចផ្តើមប្រភេទផលប៉ះពាល់មួយបែបនេះ។ អនាគតដល់ប្អូសហាត់លើជាន់ថ្នាក់ខ្ពស់, មិនចាំបាច់ខ្ញុំប្រាប់លោកអ្នក, លោកអ្នកខ្លួនឯងគឺដឹងបានធ្វើដូចម្តេច, ពេលនោះមានស្ថានភាពផ្សេង, រក្សារស់នៅស្រុះស្រួលគ្នា។ ដូច្នេះ, រឿងទាំងនេះលោកអ្នកក៏កុំមើលវាសំខាន់ពេក, បើសិនលោកអ្នកបារម្ភហួសពេកក៏ជាស្ថិតក្នុងការប្រកាន់។ រវាងប្តីប្រពន្ធគ្មានបញ្ហាសម្រស់, ប៉ុន្តែមានតណ្ហា, លោកអ្នកមើលវាឱ្យស្រាល, ក្នុងចិត្តតុល្យភាពគឺបានហើយ។

ដូច្នោះនឹងជួបប្រទះខ្មោចសម្រស់បែបណា? ប្រសិនកម្លាំងរម្ងាប់របស់លោកអ្នកមិនគ្រប់, លោកអ្នកនឹងលេចឡើងនៅក្នុងសុបិន្ត, ចំពេលដែលលោកអ្នកគេងឬក៏ចំពេលដែលលោកអ្នកអង្គុយសមាធិ, មួយរំពេចគឺនឹងលេចឡើង៖ លោកអ្នកជាបុរសគឺនឹងលេចឡើងស្រីស្អាត; លោកអ្នកជាស្ត្រីដូច្នោះគឺនឹងលេចឡើងប្រភេទបុរសម្នាក់ដែលលោកអ្នកកោតស្រឡាញ់ក្នុងបេះដូង, ប៉ុន្តែផ្ទុយមកវិញគាត់គឺមិនពាក់អ្វីសោះ។ គំនិតលោកអ្នកកម្រើកកាលណា, អាចគឺបញ្ចេញ, គឺក្លាយជារឿងពិត។ លោកអ្នកគិតសាកមើល, ពួកយើងហាត់គង់, ឈីនៃមេជីវិតនិងរដូវគឺប្រើដើម្បីប្អូសជីវិត, លោកអ្នកមិនអាចរមែងបញ្ចេញបែបនេះ។ ក្នុងពេលដំណាល

គ្នាទ្វារសម្រស់តណ្ហាមួយនេះរបស់លោកអ្នកមិនទាន់ឆ្លងបាន, នោះធ្វើម្ដេចបាន? ដូច្នេះបញ្ហានេះខ្ញុំសម្ដែងជាមួយអ្នករាល់គ្នា, នរណាៗក៏នឹងជួបប្រទះ, ធានាថានឹងជួបប្រទះ។ ពេលដែលខ្ញុំសម្ដែងធម៌, ខ្ញុំគឺនាំតាមថាមពលដ៏ខ្លាំងកំពុងវាយចូលក្នុងខួរក្បាលរបស់លោកអ្នក។ លោកអ្នកអាចចេញពីទ្វារគិតមិនចេញពិស្ដារខ្ញុំសម្ដែងជាអ្វី, ប៉ុន្តែពេលដែលលោកអ្នកពិតប្រាកដជួបប្រទះបញ្ហា, លោកអ្នកនឹងគិតចេញពាក្យដែលខ្ញុំធ្លាប់សម្ដែង។ ដរាបណាលោកអ្នកចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់, មួយសន្ទុះនោះលោកអ្នកអាចនឹកចេញបាន, លោកអ្នកគឺអាចរឹតត្បិតខ្លួនឯងបាន, ដូច្នោះទ្វារមួយនេះលោកអ្នកគឺអាចឆ្លងផុតបាន។ ប្រសិនទ្វារទីមួយឆ្លងមិនបាន, ទ្វារទីពីរគឺដ៏ពិបាកឃាត់ជាប់បាន។ ប៉ុន្តែក៏មានបែបនេះ, លើកទីមួយមិនទាន់ឆ្លងបាន, បន្ទាប់ពីភ្ញាក់ឡើងវិប្បដិសារីក្រៃលែង, អាចចិត្តសាស្ត្រនេះ, ស្ថានភាពនេះរបស់លោកអ្នក, ក៏នឹងធ្វើឲ្យជ្រៅថែមចំណាប់អារម្មណ៍ក្នុងមនោគតិលោកអ្នក, ជួបប្រទះបញ្ហាម្ដងទៀត, លោកអ្នកគឺអាចកាន់ជាប់បាន, គឺអាចឆ្លងផុតបាន។ ប្រសិនជាមនុស្សខ្លះឆ្លងមិនបាន, ក៏មិនខ្វល់, ក្រោយមកគឺកាន់តែពិបាកឃាត់, ធានាគឺជាបែបនេះ។

ទម្រង់នេះមានការជ្រៀតជ្រែករបស់ខ្មោច, ក៏មានគ្រូចង្អុលវត្ថុប្រែវត្តិវិវត្តមកដើម្បីសាកល្បងលោកអ្នក, ទម្រង់ទាំងពីរសុទ្ធតែស្ថិតនៅ, ដោយសារនរណាៗសុទ្ធតែត្រូវការឆ្លងទ្វារមួយនេះ។ ពួកយើងពីមនុស្សសាមញ្ញចាប់ផ្ដើមបួសហាត់, ដើរជំហានទីមួយជាក់ស្ដែងគឺទ្វារមួយយ៉ាងនេះ, នរណាៗសុទ្ធតែនឹងជួបប្រទះ។ ខ្ញុំលើកឧទាហរណ៍មួយឲ្យអ្នករាល់គ្នា, ពេលដែលបើកថ្នាក់នៅវូហានមានសិក្ខាកាមមួយយ៉ាងនេះ, កំលោះម្នាក់អាយុ៣០ឆ្នាំ។ ខ្ញុំទើបតែសម្ដែងមេរៀនមួយនេះរួច, គាត់ត្រឡប់មកផ្ទះ

អង្គុយសមាធិ, ជាបន្ទាន់គឺរម្ងាប់ចុះមកបាន។ បន្ទាប់ពីរម្ងាប់ជាប់, ស្រាប់តែមើលឃើញខាងនេះលេចឡើងព្រះពុទ្ធអាមីធួរ, ខាងនោះលេចឡើងឡៅជឺ។ នេះគឺគាត់និយាយនៅក្នុងចិត្តបានយល់ដឹង។ បន្ទាប់ពីលេចឡើងរួចហើយ, សម្លឹងគាត់គ្មាននិយាយអ្វី, បន្ទាប់មកគឺបំបាំងទៅ។ ម្តងទៀតបានលេចឡើងពោធិសត្វក្វានយីន, ក្នុងដៃកាន់ថូផ្កាមួយ, ពីក្នុងថូផ្កានេះហើរចេញមកផ្សែងសមួយខ្សែ។ គាត់នៅទីនោះអង្គុយសមាធិ, មើលឃើញច្បាស់លាស់ណាស់, គាត់សប្បាយចិត្តយ៉ាងខ្លាំង។ មួយរំពេចប្រែទៅជាស្រីស្អាតប៉ុន្មាននាក់, ស្រីស្អាតនោះជាក់ស្តែងគឺជាទេពអប្សរហោះហើរ, តើស្អាតប៉ុណ្ណា។ លោតរាំឲ្យគាត់, បែបរាំមើលទៅគួរឱ្យស្រឡាញ់! គាត់គិតដោយខ្លួនឯង៖ យើងនៅទីនេះហាត់គង់, ពោធិសត្វក្វានយីនប្រទានឱ្យយើង, ប្រែក្លាយជាស្រីស្អាតប៉ុន្មាននាក់ឱ្យយើងមើល, ទេពអប្សរលោតរាំឲ្យយើង។ ចំពេលគាត់គិតសប្បាយចិត្តបំផុត, មួយរំពេចស្រីស្អាតទាំងនេះគឺមិនពាក់អ្វីសោះ, ធ្វើកាយវិការគ្រប់ប្រភេទ, ហើយឡើងមកអូសកឱបខ្នង។ សិក្ខាកាមរបស់ពួកយើងចិត្តចរិតលើកកម្ពស់ដ៏លឿន, ពេលនោះកំលោះនេះគឺប្រុងប្រយ័ត្ន, គាត់គិតដល់មុនដំបូងនោះគឺ៖ ខ្ញុំមិនមែនជាមនុស្សធម្មតា, ខ្ញុំជាមនុស្សហាត់គង់, ពួកអ្នកមិនបានប្រព្រឹត្តបែបនេះចំពោះខ្ញុំ, ខ្ញុំគឺបួសហ្វាលូនតាហ្វា។ គំនិតនេះផុសចេញកាលណា, "ស៊ូ" មួយរំពេចនោះអ្វីក៏គ្មានទៀត, ដើមមកនោះគឺជាបំភាន់ប្រែចេញមក។ បន្ទាប់មកព្រះពុទ្ធអាមីធួរនិងឡៅជឺសាជាថ្មីលាតត្រដាងចេញមកម្តងទៀត។ ឡៅជឺដៃចង្អុលទៅបុរសវ័យក្មេង, បែរមកព្រះពុទ្ធអាមីធួរសើចហើយនិយាយថា៖ ក្មេងប្រុសអាចបង្រៀនបាន។ នោះមានន័យថាក្មេងប្រុសនេះបាន, អាចបង្រៀន។

នៅលើប្រវត្តិសាស្ត្រឬក៏នៅក្នុងអវកាសជាន់ខ្ពស់, មើលមនុស្សអាច

ឬមិនអាចបួស, មើលរបស់តណ្ហា, សម្រស់នេះរបស់ឯកជននោះចម្បង ណាស់, ដូច្នេះពួកយើងពិតជាត្រូវមើលឲ្យស្រាលរឿងរ៉ាវទាំងនេះ។ ប៉ុន្តែ ពួកយើងបួសហាត់នៅក្នុងមនុស្សសាមញ្ញ, ក៏មិនមែនតម្រូវលោកអ្នក កាត់ផ្តាច់វាទាំងស្រុង, យ៉ាងហោចណាស់នៅដំណាក់កាលបច្ចុប្បន្ន, លោកអ្នកត្រូវមើលវាឲ្យស្រាល, មិនអាចដូចអតីតកាលបែបនោះទៀត។ ធ្វើជាមនុស្សហាត់គង់ម្នាក់ជាក់ស្តែងគឺគួរតែបែបនេះ។ ដរាបណានៅក្នុង ហាត់គង់លេចឡើងជ្រៀតជ្រែកនេះ, ជ្រៀតជ្រែកនោះ, លោកអ្នកខ្លួនឯង ត្រូវតែរកមូលហេតុ, លោកអ្នកមានប្រការអ្វីនៅមិនទាន់ដាក់ចុះបាន។

# ចិត្តខ្លួនឯងបង្កើតខ្មោច

អ្វីហៅថាចិត្តខ្លួនឯងបង្កើតខ្មោច? រាងកាយមនុស្សនៅក្នុងគ្រប់ជាន់ អវកាសសុទ្ធតែមានវាលសារធាតុមួយស្ថិតនៅ, នៅក្នុងវាលពិសេស មួយ, របស់ទាំងអស់ក្នុងចក្រវាលសុទ្ធតែដូចជាស្រមោលបញ្ចាំងមកលើ វាលអវកាសនេះរបស់លោកអ្នក, ទោះបីជាស្រមោលក្តី, ប៉ុន្តែក៏ជា អត្ថិភាពសារធាតុ។ ទាំងអស់លើវាលអវកាសរបស់លោកអ្នក, សុទ្ធតែ ស្តាប់{តាម}សតិខួរធំរបស់លោកអ្នកបញ្ជា, ក៏មានន័យថា, លោកអ្នក ប្រើភ្នែកទិព្វដើម្បីមើល, មិនកម្រើកគំនិតស្ងប់ស្ងាត់ដើម្បីមើលគឺជាពិត មែន, ដរាបណាកម្រើកគំនិតបន្តិច, ដែលមើលឃើញសុទ្ធតែជាក្លែង ក្លាយ, នេះជាក់ស្តែងគឺចិត្តខ្លួនឯងបង្កើតខ្មោច, ក៏បានហៅថាតាមចិត្ត ហើយប្រែ។ នោះគឺដោយសារមានមនុស្សហាត់គង់ខ្លះខ្លួនឯងមិនអាច ចាត់ទុកខ្លួនឯងធ្វើជាមនុស្សបួសហាត់ម្នាក់, មិនអាចខ្លួនឯងកាន់ជាប់ ខ្លួនឯង, គាត់មានចំណង់លើសីលគង់, ប្រកាន់លើសមត្ថភាពតូចសិល្ប៍ សាស្ត្រតូច, សូម្បីតែប្រកាន់លើប្រការមួយចំនួនដែលស្តាប់បានក្នុងអវ កាសផ្សេង, ប្រកាន់លើការស្វែងរកប្រការមួយចំនួន, ប្រភេទមនុស្សមួយ

នេះងាយស្រួលចិត្តខ្លួនឯងបង្កើតខ្មោចបំផុត, ងាយស្រួលធ្លាក់ចុះបំផុត។ មិនខ្វល់ប្អូសហាត់បានខ្ពស់ប៉ុណ្ណា, កាលណាលេចឡើងបញ្ហានេះគឺនឹងធ្លាក់ចុះដល់បាត, បំផ្លាញដល់បាត។ នេះជាបញ្ហាមួយយ៉ាងធ្ងន់ធ្ងរបំផុត។ មិនដូចទិដ្ឋភាពផ្សេង, សាកល្បងចិត្តចរិតលើកនេះមិនទាន់ឆ្លងបាន, ដួលរលំរួចហើយវារឡើងវិញ, នៅតែអាចបន្តប្អូស។ ហើយលេចឡើងបញ្ហាចិត្តខ្លួនឯងបង្កើតខ្មោចនេះគឺមិនបាន, មួយជីវិតនេះរបស់គាត់គឺបំផ្លាញរួចហើយ។ ជាពិសេសគឺមនុស្សហាត់គង់នៅក្នុងជាន់ថ្នាក់ជាក់លាក់បានបើកភ្នែកទិព្វរួចហើយ, ងាយស្រួលលេចឡើងបញ្ហានេះ។ នៅមានមនុស្សមួយចំនួនលើសតិខ្លួនឯងរមែងទទួលរងព័ត៌មានមកពីខាងក្រៅជ្រៀតជ្រែក, ព័ត៌មានមកពីខាងក្រៅប្រាប់គាត់អ្វី, គាត់គឺជឿតាមអ្វី, ក៏នឹងលេចឡើងបញ្ហានេះ។ ដូច្នេះមនុស្សខ្លះពួកយើងបន្ទាប់ពីបានបើកភ្នែកទិព្វរួចហើយ, នឹងទទួលរងព័ត៌មានជ្រៀតជ្រែកគ្រប់ទិដ្ឋភាព។

យើងខ្ញុំលើកឧទាហរណ៍មួយ, ប្អូសហាត់ជាន់ថ្នាក់ទាបចិត្តមិនកម្រើក, ដ៏ពិបាកធ្វើបាន។ លោកគ្រូបែបណាលោកអ្នកអាចមើលមិនច្បាស់លាស់។ ស្រាប់តែមានថ្ងៃមួយ, លោកអ្នកមើលឃើញមហាអាទិទេពមួយរូបទាំងខ្ពស់ទាំងធំមក។ មហាអាទិទេពនេះសរសើរលោកអ្នកពីរប្រយោគ, បន្ទាប់មកបង្រៀនលោកអ្នករបស់ខ្លះ, លោកអ្នកក៏ចង់បាន, នោះគង់របស់លោកអ្នកគឺរញ៉េរញ៉ៃរួចហើយ។ ក្នុងចិត្តលោកអ្នកសប្បាយកាលណា, ទទួលគាត់ធ្វើគ្រូ, ទៅតាមគាត់រៀន, តែគាត់ក៏មិនសម្រេចមគ្គផល, នៅក្នុងអវកាសនោះគឺអាចប្រែធំបង្រួមតូច។ នេះបង្ហាញនៅពីមុខលោកអ្នក, លោកអ្នកមើលឃើញមហាអាទិទេពរូបនេះ, ពិតជារំភើប! ចិត្តអំណរផុសឡើងកាលណា, លោកអ្នកមិនទៅរៀនតាមគាត់ឬ? មនុស្សប្អូសហាត់កាន់មិនជាប់ខ្លួនឯងគឺដ៏ពិបាកប្រោសព្រំ, គឺ

ងាយស្រួលបំផ្លាញខ្លួនឯង។ មនុស្សមេឃសុទ្ធតែជាអាទិទេព, ប៉ុន្តែគាត់ក៏មិនទាន់សម្រេចមគ្គផល, តាមដូចគ្នាចូលក្នុង៦ផ្លូវ។ លោកអ្នកទទួលគ្រូតាមអំពើចិត្ត, លោកអ្នកត្រូវទៅតាមគាត់, គាត់នាំលោកអ្នកឡើងដល់ជំហានណា? គាត់ក៏មិនសម្រេចមគ្គផល, លោកអ្នកមិនមែនបួសដូចមិនបួសហើយឬ? លទ្ធផលបានធ្វើឱ្យគង់លោកអ្នកខ្លួនឯងរញ៉េរញ៉ៃ។ មនុស្សគឺដ៏ពិបាកមិនកម្រើកចិត្ត។ ខ្ញុំប្រាប់អ្នករាល់គ្នា, បញ្ហានេះតឹងរឹងណាស់, អនាគតមនុស្សដ៏ច្រើនពួកយើងនឹងលេចឡើងបញ្ហានេះ ធម៌ខ្ញុំសម្តែងចេញមកឲ្យលោកអ្នករួចហើយ, លោកអ្នកអាចកាន់ជាប់ឬអត់ទាំងស្រុងអាស្រ័យលើលោកអ្នកខ្លួនឯង, ខ្ញុំសម្តែងនេះគឺជាប្រភេទកាលៈទេសៈមួយ។ មើលឃើញអង្គត្រាស់ដឹងក្នុងធម្មក្ខន្ធនិកាយអ្វីផ្សេងក៏មិនកម្រើកចិត្ត, គឺបួសនៅក្នុងធម្មក្ខន្ធមួយ។ ពុទ្ធណា, តាវណា, អាទិទេពណា, ខ្មោចណាក៏កុំចង់កម្រើកចិត្តរបស់ខ្ញុំ, បែបនេះជាក់លាក់នឹងជោគជ័យមានសង្ឃឹម។

ចិត្តខ្លួនឯងបង្កើតខ្មោចនៅមានកាលៈទេសៈផ្សេងទៀត៖ ជ្រៀតជ្រែកជួបសាច់ញាតិបានស្លាប់រួចហើយ, យំសោកបោកខ្លួន, ហៅលោកអ្នកធ្វើរឿងនេះ, រឿងនោះ, រឿងអ្វីក៏លេចឡើង។ លោកអ្នកអាចមិនកម្រើកចិត្តនេះឬ? លោកអ្នកគឺស្រឡាញ់ខ្លាំងកូននេះរបស់លោកអ្នក, លោកអ្នកស្រឡាញ់ឪម៉ែរបស់លោកអ្នក។ ឪម៉ែលោកអ្នកបានស្លាប់រួចហើយ, វាប្រាប់លោកអ្នកធ្វើអ្វីសុទ្ធតែជារឿងរ៉ាវដែលមិនអាចធ្វើ, លោកអ្នកធ្វើគឺជាខូចហើយ, មនុស្សហាត់គង់គឺពិបាកបែបនេះ។ គេសម្តែងថាពុទ្ធសាសនាបានរញ៉េរញ៉ៃរួចហើយ, ប្រការរបស់ខុងជឺសាសនាក៏រត់ទៅក្នុងពុទ្ធសាសនា, អ្វីកតញ្ញូឪម៉ែ, ក្តីស្រឡាញ់កូនចៅសុទ្ធតែរត់ចូលទៅ, ក្នុងពុទ្ធសាសនាគ្មានអត្ថន័យនេះ។ បង្កប់ន័យអ្វី? ដោយសារជីវិតពិត

ប្រាកដរបស់មនុស្សម្នាក់គឺជាវិញ្ញាណដើម, ម្តាយដែលបង្កើតវិញ្ញាណដើមរបស់លោកអ្នកទើបជាម្តាយពិតប្រាកដរបស់លោកអ្នក។ លោកអ្នកនៅក្នុងវិលកើតវិលស្លាប់៦ផ្លូវ, ម្តាយលោកអ្នកជាមនុស្ស, មិនមែនជាមនុស្ស, តួលេខមិនច្បាស់។ កូនចៅរបស់លោកអ្នកគ្រប់ជាតិមានប៉ុន្មាន, ក៏តួលេខមិនច្បាស់។ មួយណាជាម្តាយលោកអ្នក, មួយណាជាកូនលោកអ្នក, ភ្នែកទាំងពីរបិទកាលណានរណាក៏មិនស្គាល់នរណាទៀត, កម្មដែលលោកអ្នកជំពាក់យោងតាមនោះដើម្បីសង។ មនុស្សនៅក្នុងភាពវង្វេង, គឺដាក់ចុះមិនបានរបស់ទាំងនេះ។ មនុស្សខ្លះដាក់ចុះមិនបានកូនរបស់គាត់, ថាវាល្អដូចម្តេច, បានស្លាប់រួចហើយ; ម្តាយគាត់ល្អដូចម្តេច, ក៏បានស្លាប់រួចហើយ, គាត់ព្រួយឈឺចាប់ចង់ផ្តាច់, សុទ្ធសាធពាក់កណ្តាលជីវិតក្រោយចង់ទៅតាមវា។ លោកអ្នកមិនគិតសាកមើល, នេះមិនមែនមកធ្វើទុក្ខលោកអ្នកឬ? ប្រើទម្រង់នេះទុកឲ្យលោកអ្នករស់គ្មានថ្ងៃបានសុខ។

មនុស្សសាមញ្ញអាចពន្យល់មិនបាន, លោកអ្នកប្រសិនប្រកាន់លើរបស់នេះ, លោកអ្នកជាមូលដ្ឋានបួសហាត់មិនបាន, ដូច្នេះក្នុងពុទ្ធសាសនាគ្មានអត្ថន័យនេះ។ លោកអ្នកបើចង់បួសហាត់, ស្នេហារបស់មនុស្សគឺត្រូវការបោះចោល។ ប្រាកដណាស់, ពួកយើងបួសហាត់នៅក្នុងសង្គមមនុស្សសាមញ្ញ, កតញ្ញូគោរពឪម៉ែ, គ្រប់គ្រងបង្រៀនកូនសុទ្ធតែជា{ការ}គួរ, នៅក្នុងបរិយាកាសគ្រប់ប្រភេទសុទ្ធតែត្រូវល្អចំពោះអ្នកដទៃ, ករុណាចំពោះគេ, សូម្បីតែសាច់ញាតិរបស់លោកអ្នក។ ចំពោះនរណាក៏ដូចគ្នា, ចំពោះឪម៉ែ, ចំពោះកូនសុទ្ធតែល្អ, កន្លែងណាក៏ពិចារណាដល់អ្នកដទៃ។ ចិត្តនេះគឺមិនមែនអាត្មានិយម, សុទ្ធតែជាចិត្តសប្បុរស, គឺជាមេត្តា។ ស្នេហាគឺជារបស់ក្នុងមនុស្សសាមញ្ញ, មនុស្សសាមញ្ញជាក់ស្តែង

គឺព្រោះតែស្នេហាដើម្បីរស់។

មនុស្សដ៏ច្រើនកាន់មិនជាប់ខ្លួនឯង, បង្កជាភាពលំបាកដល់បួសហាត់។ មានខ្លះនិយាយថា, ព្រះពុទ្ធនិយាយអ្វីជាមួយគាត់។ ជាទូទៅប្រាប់លោកអ្នក, ថ្ងៃនេះមានគ្រោះថ្នាក់មួយ, នឹងលេចឡើងរឿងអ្វី, លោកអ្នកធ្វើដូចម្តេចដើម្បីចៀសវាងវា។ ឬក៏នរណាប្រាប់លោកអ្នក, សំបុត្រឆ្នោតលេខមួយថ្ងៃនេះគឺជាលេខប៉ុន្មាន, ហៅលោកអ្នកទៅចាក់។ លើកលែងតែពេលមានគ្រោះថ្នាក់ដល់ជីវិតហៅលោកអ្នកបណ្តេញវាដូចម្តេច, ដរាបណាហៅលោកអ្នកទៅទទួលបានកន្លែងល្អនៅក្នុងសង្គមមនុស្សសាមញ្ញសុទ្ធតែជាខ្មោច។ លោកអ្នកនៅក្នុងមនុស្សសាមញ្ញទទួលបានរបស់ល្អ, ឆ្លងមិនបានគ្រោះមួយនេះ, លោកអ្នកគឺលើកកម្ពស់ឡើងមិនបាន។ លោកអ្នកនៅក្នុងមនុស្សសាមញ្ញរស់នៅប្រកបដោយភាពសុខស្រួល, លោកអ្នកបួសដូចម្តេច? អំណាចកម្មរបស់លោកអ្នកធ្វើម្តេចបំប្លែង? ទីណាមានបរិយាកាសដើម្បីលើកកម្ពស់ចិត្តចរិតរបស់លោកអ្នកនិងបំប្លែងអំណាចកម្មរបស់លោកអ្នក? អ្នករាល់គ្នាដាច់ខាតចងចាំចំណុចនេះ។ ខ្មោចនោះក៏នឹងសរសើរលោកអ្នក, និយាយថាលោកអ្នកខ្ពស់ប៉ុណ្ណា, និយាយថាលោកអ្នកជាមហាពុទ្ធខ្ពស់ប៉ុណ្ណា, មហាតាវខ្ពស់ប៉ុណ្ណា, សន្មតថាលោកអ្នកដ៏អស្ចារ្យ, នេះទាំងស្រុងគឺជាក្លែងក្លាយ។ មនុស្សបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់ពិតប្រាកដ, ចិត្តគ្រប់ប្រភេទរបស់លោកអ្នកសុទ្ធតែត្រូវបោះចោល, ពេលដែលជួបប្រទះបញ្ហាទាំងនេះ, អ្នករាល់គ្នាជាក់លាក់ត្រូវការប្រុងប្រយ័ត្ន!

ពួកយើងពេលដែលកំពុងហាត់គង់ភ្នែកទិព្វបើក។ ភ្នែកទិព្វបើកមានកន្លែងពិបាកបួសរបស់ភ្នែកទិព្វបើក, ភ្នែកទិព្វមិនបើកមានកន្លែងពិបាកបួសរបស់ភ្នែកទិព្វមិនបើក, សុទ្ធតែមិនងាយបួសហាត់។ បន្ទាប់ពី

ភ្នែកទិព្វបើករួចហើយ, ពេលដែលព័ត៌មានគ្រប់ប្រភេទជ្រៀតជ្រែកលោកអ្នក, លោកអ្នកពិតជាដ៏ពិបាកកាន់ជាប់ខ្លួនឯង។ នៅក្នុងអវកាសដទៃ, ទីណាក៏ជាវត្ថុដ៏ស្រស់ស្អាតជាច្រើន, ស្រស់ស្អាតខ្លាំងណាស់, ល្អខ្លាំងណាស់, អ្វីក៏អាចកម្រើកចិត្ត។ កម្រើកចិត្តកាលណាលោកអ្នកអាចគឺទទួលរងជ្រៀតជ្រែករួចហើយ, គង់នោះរបស់លោកអ្នកគឺរញ៉េរញ៉ៃរួចហើយ, ជាញឹកញាប់គឺជាបែបនេះ។ ដូច្នេះមនុស្សដែលចិត្តខ្លួនឯងបង្កើតខ្មោច, ពេលដែលកាន់មិនជាប់ខ្លួនឯង, ក៏នឹងលេចឡើងប្រភេទកាលៈទេសៈមួយយ៉ាងនោះ។ ឧបមាថា, ឯកជននេះកាលណាសាងបង្កើតគំនិតមិនសុចរិត, គឺដ៏គ្រោះថ្នាក់។ មានថ្ងៃមួយ, គាត់បើកភ្នែកទិព្វ, គាត់មើលបានក៏ច្បាស់លាស់ណាស់។ គាត់គិត៖ នៅលើទីតាំងហាត់គង់នេះ, គ្រាន់តែភ្នែកទិព្វរបស់យើងបើកបានល្អ, យើងអាចមិនមែនមនុស្សធម្មតា? យើងអាចរៀនហ្វាលូនតាហ្វារបស់លោកគ្រូលី, យើងអាចរៀនល្អយ៉ាងនេះ, យើងខ្លាំងជាងអ្នកដទៃ, យើងអាចក៏មិនមែនមនុស្សធម្មតា។ មនោគតិនេះគឺមិនត្រឹមត្រូវរួចហើយ។ គាត់គិត៖ ប្រហែលជាយើងក៏ជាព្រះពុទ្ធ, អ៎ា, យើងមើលខ្លួនយើងសាកមើល។ គាត់មើលខ្លួនឯងកាលណាពិតមែនជាព្រះពុទ្ធ។ ហេតុអ្វី? ដោយសារសារធាតុទាំងអស់នៅក្នុងវិសាលភាពវាលអវកាសនៃបរិវេណរាងកាយរបស់ខ្លួនគាត់, សុទ្ធតែស្របតាមគំនិតរបស់គាត់ដើម្បីវិវត្ត, ក៏បានហៅថាតាមចិត្តហើយប្រែ។

របស់ដែលឆ្លុះបញ្ចាំងមកពីក្នុងចក្រវាល, សុទ្ធតែស្របតាមគំនិតរបស់គាត់ដើម្បីផ្លាស់ប្រែ, ដោយសារគឺក្នុងវិសាលភាពវាលអវកាសរបស់គាត់សុទ្ធតែរួមមកគាត់គ្រប់គ្រង, ស្រមោលក៏ជាអត្ថិភាពសារធាតុ, ក៏ជាដូចគ្នា។ គាត់គិត៖ យើងជាព្រះពុទ្ធ, យើងអាចស្លៀកក៏ជាសម្លៀកបំពាក់របស់ព្រះពុទ្ធ។ ដូច្នោះគាត់មើលឃើញសម្លៀកបំពាក់ដែលគាត់ស្លៀក

ជាក់ស្ដែងគឺជាសម្លៀកបំពាក់របស់ព្រះពុទ្ធ។ អ៉ាយយោ, យើងពិតមែនជាព្រះពុទ្ធទេតើ, នេះគឺសប្បាយចិត្តដ៏ខ្លាំង។ យើងអាចក៏មិនមែនជាព្រះពុទ្ធតូច, មើលភ្លាម, ខ្លួនឯងក៏ជាព្រះពុទ្ធធំ។ ប្រហែលជាយើងខ្ពស់ជាងទាំងលីហ៊ុងជីផង! សាកមើល, អ៉ាយយ៉ា, យើងពិតជាខ្ពស់ជាងលីហ៊ុងជី។ ក៏មានមនុស្សគឺពីត្រចៀកស្ដាប់បាន, ខ្មោចនោះជ្រៀតជ្រែកគាត់, និយាយថា៖ លោកខ្ពស់ជាងទាំងលីហ៊ុងជី, លោកខ្ពស់ជាងលីហ៊ុងជីទាំងប៉ុណ្ណាៗ។ គាត់ក៏ជឿផងដែរ។ លោកអ្នកមិនគិតសាកមើលលោកអ្នកចាប់ពីពេលនេះតទៅបួសរបៀបណា, លោកអ្នកធ្លាប់បួសឬទេ, នរណាបង្រៀនលោកអ្នកបួស? ព្រះពុទ្ធពិតចុះមកធ្វើរឿងសុទ្ធតែត្រូវបួសសាជាថ្មី, គង់ពីដើមមកក៏មិនផ្ដល់ឲ្យ, ហួសពេកគ្រាន់តែឥឡូវនេះបួសលឿនជាងបន្តិច។ បែបនេះបន្តមក, ឯកជននេះកាលណាលេចឡើងបញ្ហានេះរួចហើយ, ដូច្នោះគាត់គឺដ៏ពិបាកក្រោកឡើងដោយខ្លួនឯង, ជាបន្ទាន់ចិត្តនេះគឺផុសឡើង។ បន្ទាប់ពីផុសឡើងរួចហើយ, គឺអ្វីគាត់ក៏ហ៊ាននិយាយ៖ យើងជាក់ស្ដែងគឺជាព្រះពុទ្ធរួចហើយ, ពួកលោកមិនចាំបាច់រៀនតាមអ្នកដទៃទៀត, យើងជាក់ស្ដែងគឺជាព្រះពុទ្ធរួចហើយ, យើងប្រាប់ពួកលោកធ្វើដូចនេះដូចនោះ។ គាត់ប្រែជាបែបនេះ។

នៅឆាងឈុនពួកយើងមិនមែនក៏មានមនុស្សបែបនេះឬ? ចាប់ផ្ដើមមនុស្សម្នាក់ល្អគួរសម, ក្រោយមកធ្វើក្លាយជារឿងទាំងនេះ។ គាត់គឺជាព្រះពុទ្ធរួចហើយ, ចុងក្រោយគាត់ខ្ពស់ជាងនរណាទាំងអស់, នោះគឺមនុស្សកាន់មិនជាប់ខ្លួនឯង, ផុសចេញចិត្តប្រកាន់បង្កឡើង។ ហេតុអ្វីបានជាលេចឡើងបាតុភូតនេះ? នៅក្នុងពុទ្ធសាសនាសម្ដែងថា៖ លោកអ្នកមើលឃើញរបស់អ្វី, លោកអ្នកកុំខ្វល់នឹងវា, សុទ្ធតែជាខ្មោចបំភាន់, លោកអ្នកគ្រាន់តែខ្វល់ខ្លួនឯងចូលក្នុងសមាធិបួសឡើងលើ។ គាត់ហេតុ

អ្វីមិនទុកឲ្យលោកអ្នកមើល, មិនទុកឲ្យលោកអ្នកប្រកាន់លើរបស់នោះ? គឺគាត់ខ្លាចលេចឡើងបញ្ហានេះ។ បួសហាត់ក្នុងពុទ្ធសាសនាគាត់គ្មានវិធីសាស្ត្របួសហាត់ពង្រឹងអ្វី, នៅក្នុងគម្ពីរក៏គ្មានណែនាំលោកអ្នកធ្វើដូចម្ដេចគេចផុតពីរឿងនេះ។ សក្យមុនីនាគ្រានោះគ្មានសម្ដែងធម៌នេះ, ដើម្បីចៀសវាងបញ្ហាចិត្តខ្លួនឯងបង្កើតខ្មោច, តាមចិត្តហើយប្រែ, គាត់យកទស្សនីយភាពទាំងអស់ដែលមើលឃើញក្នុងបួសហាត់ទាំងស្រុងសុទ្ធតែនិយាយថាជាខ្មោចបំភាន់។ ដូច្នេះកាលណាមានចិត្តប្រកាន់, គឺនឹងសាងបង្កើតខ្មោចបំភាន់នេះ, មនុស្សដ៏ពិបាកគេចផុតពីវា។ ដូច្នោះអាចធ្វើមិនល្អឯកជននេះគឺចប់, ចូលក្នុងអារក្សរួចហើយ។ ដោយសារគាត់និយាយខ្លួនឯងថាជាព្រះពុទ្ធ, គាត់បានចូលក្នុងអារក្សរួចហើយ, ចុងក្រោយក៏អាចអន្ទងមកកាយភ្ជាប់ឬក៏រឿងអ្វីផ្សេង, គាត់គឺចប់ទាំងស្រុងរួចហើយ។ ចិត្តរបស់គាត់ក៏ប្រែជាអាក្រក់, ទីបំផុតធ្លាក់ចុះ, មនុស្សបែបនេះច្រើនណាស់។ នៅលើថ្នាក់នេះបច្ចុប្បន្នគឺមានមនុស្សមានអារម្មណ៍ថាខ្លួនឯងអស្ចារ្យ, អាកប្បកិរិយានិយាយស្ដីក៏ខុសប្លែក។ ខ្លួនឯងនៅទីបញ្ចប់ជារឿងដូចម្ដេច, ជាក់ស្ដែងគឺនៅក្នុងពុទ្ធសាសនាក៏ដ៏បម្រាមប្រការនេះ។ ខ្ញុំទើបតែសម្ដែងនេះក៏ជាប្រភេទកាលៈទេសៈមួយ, នេះហៅថាចិត្តខ្លួនឯងបង្កើតខ្មោច, ក៏ហៅថាតាមចិត្តហើយប្រែ។ នៅប៉េកាំងមានសិក្ខាកាមបែបនេះ, មានតំបន់ខ្លះក៏លេចឡើងផងដែរ, លើសពីនេះជ្រៀតជ្រែកដ៏ធំដល់មនុស្សហាត់គង់។

មានមនុស្សសួរខ្ញុំ៖ លោកគ្រូ, ហេតុម្ដេចទ្រង់មិនសម្អាតប្រការទាំងនេះ? អ្នករាល់គ្នាគិតសាកមើល, ប្រសិនយើងខ្ញុំយកឧបសគ្គទាំងអស់នៅលើផ្លូវបួសហាត់នេះសុទ្ធតែសម្អាតឲ្យលោកអ្នក, លោកអ្នកបួសដូចម្ដេច? ជាក់ស្ដែងគឺនៅក្រោមកាលៈទេសៈមានខ្មោចជ្រៀតជ្រែកទើបអាច

បង្ហាញចេញបានលោកអ្នកអាចឬមិនអាចបួស, លោកអ្នកអាចឬមិនអាចភ្ញាក់ដឹងតាវពិតប្រាកដ, លោកអ្នកអាចឬមិនអាចទទួលរងជ្រៀតជ្រែក, អាចឬមិនអាចខ្ជាប់ខ្ជួនធម្មក្ខន្ធមួយនេះ។ រលកធំរ៉េងខ្សាច់, បួសហាត់ជាក់ស្ដែងគឺរឿងយ៉ាងនេះ, ដែលនៅសល់ទើបជាមាសពិតមែន។ លោកអ្នកគ្មានប្រភេទទម្រង់ជ្រៀតជ្រែកនេះ, ខ្ញុំនិយាយថាមនុស្សបួសងាយស្រួលពេកហើយ, ខ្ញុំកំពុងឃើញថាលោកអ្នកបួសក៏ងាយស្រួលពេក។ អង្គមហាត្រាស់ដឹងលើជាន់ថ្នាក់ខ្ពស់ទាំងនោះឃើញអញ្ចឹងក្នុងចិត្តកាន់តែបាត់តុល្យភាព៖ លោកធ្វើអីហ្នឹង? លោកនេះគឺប្រោសមនុស្សឬ? លើផ្លូវឧបសគ្គអ្វីក៏គ្មាន, បួសកាលណាគឺដល់ទី, នេះគឺបួសឬ? កាន់តែហាត់កាន់តែសុខស្រួល, ជ្រៀតជ្រែកអ្វីក៏គ្មាន, នោះអាចបានឬ? ជាក់ស្ដែងគឺជាបញ្ហានេះ, ខ្ញុំក៏កំពុងពិចារណាបញ្ហានេះ។ នៅពេលវេលាដំបូង, ខ្ញុំបានដោះស្រាយខ្មោចបែបនេះដ៏ច្រើន។ រមែងបន្តបែបនេះ, ខ្ញុំគិតថាក៏មិនត្រឹមត្រូវ។ គេក៏និយាយជាមួយខ្ញុំ៖ លោកទុកឲ្យពួកគាត់បួសបានក៏ងាយស្រួលពេកហើយ។ ខ្លួនគេមានតែគ្រោះបន្តិចនោះ, រវាងមនុស្សនិងមនុស្សតែរឿងបន្តិចនោះ, នៅមានចិត្តដ៏ច្រើននៅតែមិនអាចកម្ចាត់! នៅក្នុងភាពច្របូកច្របល់ខ្លួនឯងអាចយល់ដឹងចំពោះមហាធម៌ឬអត់នៅតែជាបញ្ហា! មានបញ្ហាមួយបែបនេះ, ដូច្នេះគឺនឹងមានជ្រៀតជ្រែក, មានសាកល្បង។ ទើបតែសម្ដែងនេះគឺជាទម្រង់មួយរបស់ខ្មោច។ ពិតប្រាកដប្រោសមនុស្សម្នាក់ដ៏ពិបាក, ប៉ុន្តែបំផ្លាញមនុស្សម្នាក់គឺយ៉ាងងាយស្រួលបំផុត។ លោកអ្នកខ្លួនឯងចិត្តមិនសុចរិតកាលណា, ជាបន្ទាន់គឺចប់។

## សតិម្ចាស់ត្រូវតែខ្លាំង

ដោយសាររឿងមិនល្អមួយចំនួនដែលមនុស្សបានធ្វើពីមួយជាតិទៅ

មួយជាតិ, បង្កជាគ្រោះថ្នាក់ឱ្យមនុស្ស, បង្កជាឧបសគ្គរបស់អំណាចកម្ម ឱ្យអ្នកបួសហាត់, ដូច្នេះនឹងមានស្ថិតនៅកើតចាស់ឈឺស្លាប់។ នេះជាអំណាចកម្មធម្មតា។ នៅមានប្រភេទអំណាចកម្មខ្លាំងធំមួយទៀត, ឥទ្ធិពលសែនធំដល់អ្នកបួសហាត់, ហៅថាកម្មមនោគតិ។ មនុស្សរស់គឺត្រូវតែគិតពិចារណា។ ដោយសារមនុស្សវង្វេងនៅក្នុងមនុស្សសាមញ្ញ, ពេលធម្មតានៅក្នុងមនោគតិសាងបង្កើតប្រភេទគំនិតមួយព្រោះកិត្តិនាម, ផលប្រយោជន៍, សម្រស់, ខឹងជាដើមហើយផុសចេញ, យូរៗទៅ, គឺនឹងបង្កើតជាប្រភេទអំណាចកម្មមនោគតិខ្លាំងធំមួយ។ ដោយសារនៅអវកាសផ្សេងទាំងអស់សុទ្ធតែជាមានជីវិត, កម្មក៏ជាដូចគ្នា។ នៅពេលមនុស្សចង់បួសហាត់សុចរិតធម៌, គឺត្រូវការរំលាយកម្ម។ រំលាយកម្មជាក់ស្តែងគឺយកកម្មកម្ទេចចោល, បំប្លែង។ ប្រាកដណាស់អំណាចកម្មគឺមិនព្រម, ដូច្នេះគេនឹងមានគ្រោះ, មានឧបសគ្គ។ យ៉ាងណាក៏ដោយ, អំណាចកម្មមនោគតិនឹងដោយផ្ទាល់ជ្រៀតជ្រែកខួរធំរបស់មនុស្ស, ហេតុនេះនៅក្នុងមនោគតិមានពាក្យជេរលោកគ្រូ, ជេរមហាធម៌, គិតចេញគំនិតទុច្ចរិតមួយចំនួននិងពាក្យជេរគេ។ បែបនេះបន្តមក, មានមនុស្សបួសហាត់ខ្លះគឺមិនដឹងជារឿងដូចម្តេច, នៅតែសន្មតថាគឺខ្លួនឯងគិតបែបនេះ។ ក៏មានមនុស្សសន្មតថានេះគឺជាកាយភ្ជាប់, ប៉ុន្តែនេះមិនមែនជាកាយភ្ជាប់, តែគឺជាកម្មមនោគតិឆ្លុះបញ្ចាំងឡើងលើខួរធំហើយបង្កឡើង។ មនុស្សខ្លះសតិម្ចាស់មិនខ្លាំង, គឺស្របតាមកម្មមនោគតិធ្វើរឿងអាក្រក់, មនុស្សនេះគឺចប់, ធ្លាក់ចុះក្រោមរួចហើយ។ ប៉ុន្តែមនុស្សភាគច្រើនអាចយកមនោគតិអញ្ញវត្ថុដ៏ខ្លាំង (សតិម្ចាស់ខ្លាំង) ដើម្បីច្រានចោលវា, បដិសេធវា។ បែបនេះ, គឺនិយាយច្បាស់ថាឯកជននេះអាចប្រោសបាន, អាចបែងចែកច្បាស់ល្អអាក្រក់, ក៏ជាក់ស្តែងគឺចរិតភ្ជាក់ដឹងល្អ,

បរមីរបស់ខ្ញុំនឹងជួយលុបបំបាត់ភាគច្រើនប្រភេទកម្មមនោគតិនេះ។ កាលៈទេសៈនេះជួបច្រើនបង្គួរ។ លេចឡើងកាលណា, ជាក់ស្តែងគឺដើម្បីមើលខ្លួនឯងអាចយកឈ្នះលើមនោគតិអាក្រក់នេះឬអត់។ អ្នកអាចខ្ជាប់ខ្ជួន, កម្មអាចរំលាយ។

## ចិត្តដាក់លាក់ត្រូវតែសុចរិត

ចិត្តមិនសុចរិតជាអ្វី? នោះគឺគាត់រមែងមិនចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់។ មនុស្សហាត់គង់នៅក្នុងពេលបួសហាត់នឹងជួបប្រទះគ្រោះ, ពេលដែលគ្រោះនេះមកអាចបង្ហាញនៅក្នុងពេលកកិតរវាងមនុស្សនិងមនុស្ស, នឹងលេចឡើងការកម្ចាត់គ្នាជាដើមរឿងរ៉ាវទាំងនេះ, ដោយផ្ទាល់ឥទ្ធិពលដល់របស់លើចិត្តចរិតលោកអ្នក, ទិដ្ឋភាពនេះច្រើនបង្គួរ។ នៅជួបប្រទះអ្វីទៀត? រាងកាយពួកយើងស្រាប់តែមានអារម្មណ៍មិនសុខស្រួល, ដោយសារសងកម្ម, វានឹងបង្ហាញនៅគ្រប់ទិដ្ឋភាព។ ដល់រយៈពេលដាក់លាក់នៅធ្វើឲ្យលោកអ្នកពិតមិនពិត, ក្លែងក្លាយមិនក្លែងក្លាយ, ទុកឲ្យលោកអ្នកមានអារម្មណ៍ថាតើគង់នេះស្ថិតនៅឬអត់, អាចបួសបានឬអត់, នៅទីបញ្ចប់អាចបួសហាត់ឡើងលើឬអត់, មានព្រះពុទ្ធឬអត់, ពិតមានក្លែងក្លាយមាន។ អនាគតក៏នឹងលេចឡើងកាលៈទេសៈនេះឲ្យលោកអ្នក, បង្កជាអារម្មណ៍ខុសនេះឲ្យលោកអ្នក, ទុកឲ្យលោកអ្នកមានអារម្មណ៍ថាគាត់ប្រហែលជាមិនស្ថិតនៅ, សុទ្ធតែជាក្លែងក្លាយ, គឺដើម្បីមើលលោកអ្នកអាចខ្ជាប់ខ្ជួនឬអត់។ លោកអ្នកនិយាយលោកអ្នកចាំបាច់ត្រូវតែខ្ជាប់ខ្ជួនមិនប្រែប្រួល, ចិត្តបែបនេះ, ដល់ពេលនោះលោកអ្នកពិតជាអាចខ្ជាប់ខ្ជួនមិនប្រែប្រួល, លោកអ្នកតាមធម្មជាតិអាចធ្វើបានល្អ, ដោយសារចិត្តចរិតលោកអ្នកបានលើកកម្ពស់ឡើងលើរួចហើយ។ ហើយបច្ចុប្បន្នលោកអ្នកគឺមិនស្ថិតស្ថេរយ៉ាងនោះ, ប្រសិនបច្ចុប្បន្នឲ្យ

លោកអ្នកលេចឡើងគ្រោះលំបាក, លោកអ្នកជាមូលដ្ឋានគឺមិនភ្ញាក់ដឹង, ជាមូលដ្ឋានគឺមិនអាចបួស។ គ្រប់ទិដ្ឋភាពសុទ្ធតែអាចលេចឡើងគ្រោះលំបាក។

នៅក្នុងដំណើរការបួសហាត់, មនុស្សគឺត្រូវតែបួសហាត់ឡើងលើបែបនេះ។ ដូច្នេះពួកយើងមានមនុស្សខ្លះកាលណារាងកាយគាត់ទីណាមិនសុខស្រួល, គាត់គឺសន្មតថាខ្លួនឯងមានជំងឺ។ គាត់រមែងមិនអាចចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់, ជួបប្រទះរឿងនេះ, គាត់ក៏ស្វ័យប្រវត្តិចាត់ទុកជាជំងឺ, ហេតុម្ដេចលេចឡើងរំខានច្រើនយ៉ាងនោះហ្ន៎? ប្រាប់លោកអ្នក, បានរំលោយចោលដ៏ច្រើនឲ្យលោកអ្នករួចហើយ, រំខាននោះរបស់លោកអ្នកតូចជាងច្រើនរួចហើយ។ ប្រសិនមិនរំលោយឲ្យលោកអ្នក, លោកអ្នកជួបប្រទះរំខាននេះអាចជាស្លាប់បាត់បង់ជីវិត, ក៏អាចដេកនៅទីនោះក្រោកឡើងមិនបាន។ ដូច្នេះលោកអ្នកជួបប្រទះបន្តិចរំខាន, លោកអ្នកគឺពិបាកទ្រាំ, ឯណាមានរឿងសុខស្រួលយ៉ាងនោះ? លើកឧទាហរណ៍, ពេលដែលខ្ញុំបើកថ្នាក់នៅឆាងឈុន, មានឯកជនមួយនិស្ស័យសែនល្អ, ពិតជាវត្ថុធាតុមួយដុំ, ខ្ញុំក៏ចាប់អារម្មណ៍ឯកជននេះ។ បានធ្វើឲ្យគ្រោះរបស់គាត់កើនធំជាងបន្តិច, ទុកឲ្យគាត់សងលឿនជាងបន្តិច, ទុកឲ្យគាត់បើកគង់, ខ្ញុំបម្រុងនឹងធ្វើយ៉ាងនេះ។ តែមានថ្ងៃមួយ, គាត់ភ្លាមៗហាក់ដូចជាកើតរោគសញ្ញាស្ទះសរសៃឈាមខួរក្បាល, រអិលដួលចុះនៅទីនោះ, មានអារម្មណ៍មិនកម្រើកបានទៀត, ហាក់ដូចជាអវយវៈមិនរវៃទៀត, បញ្ជូនទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់។ ក្រោយមកគាត់អាចចុះដី{ចេញពីគ្រែ}បាន។ អ្នករាល់គ្នាគិតសាកមើល, តើកើតជំងឺស្ទះសរសៃឈាមខួរក្បាលឯណាអាចលឿនយ៉ាងនេះគឺអាចចុះដី{ចេញពីគ្រែ}បាន, ដៃ, ជើងសុទ្ធតែកម្រើកបាន? ត្រឡប់មកវិញគាត់និយាយ

ថារៀនហ្វាលូនតាហ្វារៀន, បានធ្វើឲ្យគាត់លេចឡើងគម្លាត។ គាត់គ្មានគិតសាកមើល, តើស្នូះសរសៃឈាមខួរក្បាលគឺលឿនយ៉ាងនេះទេ? ថ្ងៃនេះបើគាត់មិនរៀនហ្វាលូនតាហ្វា, រអិលដួលចុះពេលណា, ប្រហែលជាគឺស្លាប់នៅទីនោះ, ប្រហែលជាខ្វិនជារៀងរហូត, ពិតជាស្ទះសរសៃឈាមខួរក្បាល។

គឺនិយាយថាមនុស្សពិបាកប្រោសយ៉ាងនោះ, ដើម្បីគាត់បានធ្វើច្រើនយ៉ាងនោះហើយ, គាត់នៅតែមិនភ្ញាក់ដឹងជំនួសមកវិញនិយាយយ៉ាងនេះទៀត។ មានសិក្ខាកាមយូរឆ្នាំខ្លះនិយាយថា៖ លោកគ្រូ, កូនហេតុម្ដេចកន្លែងណាក៏មិនសុខស្រួល, ទៅមន្ទីរពេទ្យចាក់ថ្នាំយ៉ាងណាក៏មិនជា, លេបថ្នាំក៏មិនជា។ គាត់នៅហ៊ាននិយាយជាមួយខ្ញុំដូច្នោះ! ប្រាកដណាស់មិនជា។ វាក៏មិនមែនជំងឺ, អាចជាបានឬ? លោកអ្នកត្រួតពិនិត្យទៅ, គ្មានមេរោគ, លោកអ្នកគ្រាន់តែជាពិបាកទ្រាំប៉ុណ្ណោះ។ ពួកយើងមានសិក្ខាកាមម្នាក់ទៅមន្ទីរពេទ្យធ្វើឱ្យគេចាក់ថ្នាំកោងអស់ម្ជុលប៉ុន្មានដើម, ចុងក្រោយថ្នាំក្នុងបំពង់ក៏បាញ់ចេញក្រៅ, ក៏មិនចាក់ចូលក្នុងបាន។ គាត់យល់ច្បាស់រួច៖ អ៊ុំយយោ, យើងជាមនុស្សហាត់គង់ទេតើ, យើងមិនចាក់ថ្នាំទៀត។ គាត់ទើបគិតឃើញមិនចាក់ថ្នាំទៀត។ ដូច្នេះពេលដែលពួកយើងកំពុងជួបប្រទះគ្រោះលំបាក, ដាច់ខាតត្រូវយកចិត្តទុកដាក់បញ្ហានេះ។ មនុស្សខ្លះសន្មតថាខ្ញុំដាក់ស្តែងគឺមិនអនុញ្ញាតឱ្យគាត់ទៅមន្ទីរពេទ្យពិនិត្យ, គឺគិតថា៖ លោកគ្រូមិនឱ្យខ្ញុំទៅមន្ទីរពេទ្យពិនិត្យ, ខ្ញុំរកគ្រូឈីគង់ដើម្បីពិនិត្យ។ គាត់នៅតែចាត់ទុកវាសន្មតថាជាជំងឺ, គាត់រកគ្រូឈីគង់ពិនិត្យ។ ទីណាអាចរកបានគ្រូឈីគង់ពិត? ប្រសិនជាក្លែងក្លាយ, ពេលនោះគឺធ្វើឲ្យលោកអ្នកខូចហើយ។

ពួកយើងនិយាយ, គ្រូឈីគង់នោះពិតមានក្លែងក្លាយមានលោកអ្នក

ដល់ទីណាសម្គាល់ច្បាស់? គ្រូឈើគង់ដ៏ច្រើនសុទ្ធតែជាតែងតាំងដោយខ្លួនឯង, ខ្ញុំគឺឆ្លងកាត់ធ្វើតេស្ត, ក្នុងដៃខ្ញុំមានទិន្នន័យធ្វើតេស្តរបស់ផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រចំពោះខ្ញុំ។ មានគ្រូឈើគង់ជាច្រើនគឺជាក្លែងក្លាយ, តែងតាំងដោយខ្លួនឯង, បង្អួតខ្លួនបោកប្រាស់ច្រើនណាស់។ គ្រូឈើគង់ក្លែងក្លាយនេះក៏អាចពិនិត្យជំងឺ។ ហេតុអ្វីអាចពិនិត្យជំងឺ? គាត់មានកាយភ្ជាប់, គ្មានកាយភ្ជាប់គាត់ក៏បញ្ឆោតមនុស្សមិនបាន! កាយភ្ជាប់នោះវាក៏អាចបញ្ចេញគង់, ក៏អាចព្យាបាលជំងឺ, វាក៏ជាប្រភេទអត្ថិភាពថាមពលមួយ, រឹតត្បិតលើមនុស្សសាមញ្ញសែនងាយស្រួល។ ប៉ុន្តែខ្ញុំសម្តែងរួចហើយ, កាយភ្ជាប់នោះប្រសិនព្យាបាលជំងឺ, បញ្ចេញរបស់អ្វីទៅលើខ្លួនលោកអ្នក? យ៉ាងអតិសុខុមបំផុតសុទ្ធតែជារូបភាពរបស់កាយភ្ជាប់នោះ, បញ្ចេញមកលើខ្លួនលោកអ្នក, លោកអ្នកនិយាយលោកអ្នកធ្វើដូចម្តេច? និមន្តអាទិទេពមកងាយយាងអាទិទេពទៅពិបាក។ មនុស្សសាមញ្ញយើងខ្ញុំមិននិយាយ, គាត់ចង់តែធ្វើមនុស្សសាមញ្ញ, គាត់ចង់តែបានសុខស្រួលបណ្តោះអាសន្ន។ ប៉ុន្តែលោកអ្នកជាមនុស្សហាត់គង់, លោកអ្នកមិនមែនចង់បន្តបន្សុទ្ធរាងកាយឬ? របស់នេះធ្វើផ្តេសផ្តាសលើខ្លួនលោកអ្នក, លោកអ្នកពេលណាទើបអាចរុញវាចេញបាន? លើសពីនេះវាក៏មានថាមពលជាក់លាក់។ មនុស្សខ្លះគិតថា, ហ្វាលូននោះហេតុម្តេចទុកឲ្យវាបញ្ចេញចូលក្នុង? លោកគ្រូមិនមែនមានបរមីការពារពួកយើងឬ? ក្នុងចក្រវាលនេះរបស់ពួកយើងមានគោលសីលធម៌៖ លោកអ្នកខ្លួនឯងចំណង់នរណាក៏មិនគ្រប់គ្រង, លោកអ្នកខ្លួនឯងចង់បាន, នរណាក៏មិនគ្រប់គ្រង។ បរមីរបស់ខ្ញុំនឹងរារាំងលោកអ្នក, នឹងដាស់បំភ្លឺលោកអ្នក, កាលណាឃើញលោកអ្នករមែងជាបែបនេះ, ក៏មិនគ្រប់គ្រងលោកអ្នកទៀត។ ឯណាមានបង្ខំហៅគេបួសហាត់? មិនអាចបង្ខំលោកអ្នកបួស,

បង្ខិតលោកអ្នកបួស។ ត្រូវតែពឹងលើលោកអ្នកខ្លួនឯងដើម្បីពិតប្រាកដលើកកម្ពស់, លោកអ្នកមិនចង់លើកកម្ពស់នរណាក៏គ្មានវិធី។ គោលសីលធម៌ក៏សម្ដែងឲ្យលោកអ្នករួចហើយ, ធម៌ក៏សម្ដែងឱ្យលោកអ្នករួចហើយ, លោកអ្នកខ្លួនឯងនៅតែមិនចង់លើកកម្ពស់, នោះលោកអ្នកបន្ទោសនរណា? លោកអ្នកខ្លួនឯងចង់បាន, ហ្វាលូនក៏មិនគ្រប់គ្រង, បរមីរបស់ខ្ញុំក៏មិនគ្រប់គ្រង, ធានាគឺជាបែបនេះ។ នៅមានមនុស្សខ្លះរត់ទៅវាលរបស់គ្រូឈីគង់ដទៃដើម្បីស្ដាប់របាយការណ៍, មកផ្ទះដ៏ពិបាកទ្រាំ, នោះប្រាកដណាស់។ បរមីហេតុអ្វីមិនបង្ការឲ្យលោកអ្នក? លោកអ្នកទៅដើម្បីធ្វើអ្វី, លោកអ្នកទៅស្ដាប់, លោកអ្នកមិនមែនទៅចំណង់ឬ? លោកអ្នកមិនស្រោចចូលក្នុងត្រចៀក, វាអាចចូលក្នុងបានឬ? មនុស្សខ្លះបានធ្វើឲ្យហ្វាលូនរបស់ខ្លួនឯងសុទ្ធតែប្រែទម្រង់។ ខ្ញុំប្រាប់លោកអ្នក, ហ្វាលូននោះមានតម្លៃទាំងជាងជីវិតលោកអ្នក, គាត់ជាប្រភេទជីវិតកម្រិតខ្ពស់មួយ, មិនអាចតាមអំពើចិត្តគឺកម្ទេចគាត់បាន។ បច្ចុប្បន្នគ្រូឈីគង់ក្លែងក្លាយដ៏ច្រើន, មានខ្លះកេរ្តិ៍ឈ្មោះធំណាស់។ ខ្ញុំបាននិយាយជាមួយថ្នាក់ដឹកនាំនៃសមាគមស្រាវជ្រាវវិទ្យាសាស្ត្រឈីគង់ប្រទេសចិន, ខ្ញុំនិយាយថាសម័យបុរាណធ្លាប់លេចឡើងតាហ៍ជីធ្វើចលាចលរាជវាំង, កូនកញ្ជ្រោងនោះធ្វើឃោរឃៅណាស់, វាក៏មិនទាន់កាចសាហាវស្មើនឹងគ្រូឈីគង់បច្ចុប្បន្ន, សុទ្ធសាធចលាចលទូទាំងប្រទេស, មនុស្សទាំងប៉ុន្មានទទួលរងគ្រោះ! លោកអ្នកឃើញថានៅលើផ្ទៃហាក់ដូចជាដ៏ល្អ, មានមនុស្សប៉ុន្មាននាក់លើរាងកាយនាំតាមរបស់នោះ? គាត់បញ្ចេញគឺផ្ដល់លើលោកអ្នក, សុទ្ធសាធសាហាវខ្លាំងណាស់, ដូច្នេះមនុស្សសាមញ្ញសង្កេតនៅខាងក្រៅដ៏ពិបាកមើលចេញបាន។

មនុស្សខ្លះអាចគិតថា៖ ថ្ងៃនេះចូលរួមស្ដាប់របាយការណ៍ឈីគង់,

ស្តាប់ចប់មេសម្តែងមួយនេះរបស់{លោកគ្រូ}លីហ៊ុងជី, ដើមមកឈីគង់ធំទូលាយស៊ីជម្រៅយ៉ាងនេះ! លើកក្រោយមានរបាយការណ៍ឈីគង់ផ្សេងទៀតខ្ញុំក៏ទៅស្តាប់។ ខ្ញុំនិយាយថាលោកអ្នកដាច់ខាតកុំទៅ, ស្តាប់ហើយរបស់មិនល្អគឺពីត្រចៀកស្រោចចូលក្នុង។ ប្រោសមនុស្សម្នាក់ដ៏ពិបាក, ប្រែផ្លាស់មនោគតិរបស់លោកអ្នកដ៏ពិបាក, កែសម្រួលរាងកាយលោកអ្នកក៏ជាដ៏ពិបាក។ គ្រូឈីគង់ក្លែងក្លាយដ៏ច្រើន, ជាក់ស្តែងគឺគ្រូឈីគង់បង្រៀនសុចរិតពិតប្រាកដ, គ្រូឈីគង់នោះពិតជាធ្វើឲ្យបរិសុទ្ធបានឬ? មានសត្វមួយចំនួនគឺឃោរឃៅណាស់, របស់ទាំងនោះមិនឡើងលើខ្លួនគាត់បាន, ប៉ុន្តែគាត់ក៏រុញទៅមិនបាន។ គាត់គ្មានសមត្ថភាពដើម្បីប្រឈមរបស់ទាំងនេះលើទ្រង់ទ្រាយធំ, ជាពិសេសគឺសិក្ខាកាមរបស់គាត់, គាត់នៅទីនោះបញ្ចេញគង់, របស់អ្វីលាយឡំក៏មាន។ គាត់ខ្លួនឯងពិតជាដ៏សុចរិត, តែសិក្ខាកាមរបស់គាត់មិនសុចរិត, នាំតាមកាយភ្ជាប់គ្រប់ប្រភេទ, អ្វីក៏មាន។

បើសិនលោកអ្នកពិតប្រាកដបួសហាត់ហ្វាលូនតាហ្វា, លោកអ្នកគឺកុំទៅស្តាប់។ ប្រាកដណាស់លោកអ្នកមិនចង់បួសហាត់ហ្វាលូនតាហ្វា, ហើយគឺអ្វីក៏ចង់ហាត់, នោះលោកអ្នកទៅ។ ខ្ញុំក៏មិនគ្រប់គ្រងលោកអ្នក, លោកអ្នកក៏មិនមែនជាសិស្សរបស់ហ្វាលូនតាហ្វា, លេចបញ្ហាលោកអ្នកក៏កុំនិយាយគឺដោយសារហាត់ហ្វាលូនតាហ្វា។ លោកអ្នកយោងតាមបរមាណីយចិត្តចរិតដើម្បីធ្វើ, យោងតាមមហាធម៌ដើម្បីបួសហាត់, នោះទើបជាមនុស្សរបស់ហ្វាលូនតាហ្វាពិតប្រាកដ។ មានមនុស្សសួរថា៖ អាចទាក់ទងមនុស្សហាត់ឈីគង់ដទៃឬអត់? ខ្ញុំប្រាប់លោកអ្នក, គាត់ជាក់ស្តែងគឺហាត់ឈីគង់, លោកអ្នកគឺបួសហាត់មហាធម៌, ចេញពីថ្នាក់នេះទៅ, គម្លាតដាច់ពីគ្នាអំពីជាន់ថ្នាក់មិនដឹងឆ្ងាយប៉ុណ្ណា, ហ្វាលូននេះ

គឺដោយសារមនុស្សនៃប៉ុន្មានជំនាន់បួសហាត់ទើបបង្កើតជារបស់នេះ, គឺមានអំណាចខ្លាំងធំ។ ប្រាកដណាស់បើសិនលោកអ្នកទាក់ទង, អាចរក្សាជាប់មិនទទួលយក, ក៏មិនត្រូវការអ្វីរបស់គាត់, គ្រាន់តែធ្វើមិត្តភក្តិធម្មតា, នោះបញ្ហាមិនធំ។ តែលើខ្លួនមនុស្សនោះបើសិនពិតជាមានរបស់ដ៏អាក្រក់, ល្អបំផុតមិនទាក់ទង។ និយាយអំពីប្ដីប្រពន្ធ, មានហាត់គង់ដទៃ, ខ្ញុំគិតថាបញ្ហាក៏មិនធំ។ តែមានចំណុចមួយ, ដោយសារលោកអ្នកគឺហាត់សុចរិតធម៌, មនុស្សម្នាក់ហាត់គង់, អ្នកដទៃនឹងទទួលបានអត្ថប្រយោជន៍។ គាត់ហាត់ធម្មក្ខន្ធវៀចតាវទុច្ចរិត, លើខ្លួនអាចមានរបស់ធម្មក្ខន្ធវៀចតាវទុច្ចរិត, ដើម្បីសុវត្ថិភាពរបស់លោកអ្នក, ក៏ត្រូវការសម្អាតឲ្យគាត់។ អ្វីនៅអវកាសផ្សេងសុទ្ធតែសម្អាតឲ្យលោកអ្នក, បរិយាកាសក្នុងផ្ទះលោកអ្នកក៏ត្រូវការសម្អាត។ មិនសម្អាតបរិយាកាស, របស់គ្រប់ប្រភេទជ្រៀតជ្រែកលោកអ្នក, លោកអ្នកធ្វើដូចម្ដេចហាត់គង់?

ប៉ុន្តែមានកាលៈទេសៈមួយបរមីរបស់ខ្ញុំមិនអាចសម្អាតឲ្យ។ ខ្ញុំមានសិក្ខាកាមម្នាក់, មានថ្ងៃមួយមើលឃើញបរមីរបស់ខ្ញុំមក, ធ្វើឲ្យគាត់សប្បាយយ៉ាងខ្លាំង៖ បរមីលោកគ្រូមកហើយ, អញ្ជើញលោកគ្រូចូលក្នុងផ្ទះ។ បរមីរបស់ខ្ញុំនិយាយ៖ ក្នុងបន្ទប់នេះរបស់កូនរញ៉េរញ៉ៃពេក, របស់ច្រើនពេក។ គាត់ក៏ចេញទៅ។ និយាយជាទូទៅ, កាយវិញ្ញាណនៃអវកាសផ្សេងច្រើនពេក, បរមីរបស់ខ្ញុំនឹងសម្អាតឲ្យ។ ប៉ុន្តែពេញបន្ទប់របស់គាត់សុទ្ធតែជាសៀវភៅឈីគង់រញ៉េរញ៉ៃ។ គាត់យល់ច្បាស់រួចហើយ, ប្រមូលសម្អាត, ខ្លះយកដុតទៅ, ខ្លះយកលក់ទៅ, បន្ទាប់មកបរមីរបស់ខ្ញុំក៏មកម្ដងទៀត។ នេះគឺសិក្ខាកាមនិយាយជាមួយខ្ញុំ។

នៅមានមនុស្សខ្លះទៅចំណង់គេទស្សន៍ទាយ។ មនុស្សខ្លះសួរខ្ញុំនិយាយថា៖ លោកគ្រូ, កូនហាត់ហ្វាលូនតាហ្វារួចហើយ, សម្រាប់

《ចូវយី》 ឬក៏ទស្សន៍ទាយជីវិតរបស់ទាំងនេះកូនចូលចិត្តណាស់, កូននៅអាចប្រើបានឬអត់? និយាយយ៉ាងនេះ, បើសិនលោកអ្នកមាននាំតាមថាមពលជាក់លាក់, ពាក្យដែលលោកអ្នកនិយាយចេញនឹងផ្ដើមផលប៉ះពាល់។ មិនមែនរឿងយ៉ាងនោះ, តែក៏ប្រាប់គេថាជារឿងយ៉ាងនោះ, ដូច្នោះលោកអ្នកអាចជាបានធ្វើរឿងអាក្រក់រួចហើយ។ មនុស្សសាមញ្ញម្នាក់គឺសែនទន់ខ្សោយ, ព័ត៌មានស្ថិតនៅទីគាត់សុទ្ធតែជាមិនស្ថិតស្ថេរ, ទំនងណាស់កើតឡើងការប្រែផ្លាស់មួយចំនួន។ លោកអ្នកបើកមាត់និយាយចេញឲ្យគេរួចហើយ, ប្រហែលជាគ្រោះមួយនោះនឹងស្ថិតនៅ។ ឧបមាថាអំណាចកម្មរបស់គាត់ដ៏ធំ, គាត់ត្រូវការសងសំណង, លោកអ្នករមែងនិយាយថាគាត់មានរឿងល្អ, តើសួរថាមិនសងអំណាចកម្មបានឬ? មិនមែនលោកអ្នកធ្វើបាបមនុស្សឬ? មនុស្សខ្លះជាក់ស្ដែងគឺដាក់ចុះមិនបាន, គឺប្រកាន់លើរបស់ទាំងនេះ, ហាក់ដូចជាគាត់មានអានុភាព, តើនេះមិនមែនប្រកាន់ឬ? ថែមទៀតបើសិនលោកអ្នកពិតជាដឹង, ធ្វើជាមនុស្សហាត់គង់ម្នាក់រក្សាចិត្តចរិត, ក៏មិនអាចតាមអំពើចិត្តបង្ហាញអាថ៌កំបាំងធម្មជាតិឲ្យមនុស្សសាមញ្ញម្នាក់, ជាក់ស្ដែងគឺជាគោលសីលធម៌នេះ។ យក 《ចូវយី》 ដើម្បីសន្និដ្ឋានដូចម្ដេច, យ៉ាងណាក្ដីមានប្រការមួយចំនួនបានមិនពិតមែនទៀតហើយ, សន្និដ្ឋានមកសន្និដ្ឋានទៅ, ពិតមានក្លែងក្លាយមាន, សង្គមមនុស្សសាមញ្ញគឺអនុញ្ញាតឲ្យរបស់ទស្សន៍ទាយនេះស្ថិតនៅ។ ដូច្នោះលោកអ្នកជាមនុស្សពិតប្រាកដមានគង់, ខ្ញុំនិយាយថាមនុស្សហាត់គង់ពិតប្រាកដគឺគួរតែយកបរមោណីយខ្ពស់ដើម្បីតម្រូវខ្លួនឯង។ ប៉ុន្តែមានមនុស្សមួយចំនួនគាត់រកអ្នកដទៃទស្សន៍ទាយឲ្យគាត់, និយាយ៖ ចូរលោកទស្សន៍ទាយ, មើលៗខ្ញុំបែបណា, គង់នេះហាត់បានដូចម្ដេច? ឬក៏ជាខ្ញុំមានគ្រោះអ្វីឬអត់។ គាត់រកមនុស្សទាយ

រឿងនេះ។ គ្រោះនោះបើសិនទុកឲ្យលោកអ្នកទាយចេញបាន, លោកអ្នកធ្វើម្ដេចលើកកម្ពស់? មនុស្សហាត់គង់មួយជីវិតរបស់គាត់គឺបានប្រែផ្លាស់រួចហើយ, ខ្សែបាតដៃ, រាងរៅមុខ, ម៉ោងថ្ងៃខែឆ្នាំកំណើត, និងរបស់នៃព័ត៌មាននាំតាមរាងកាយបានខុសរួចហើយ, គឺឆ្លងកាត់ប្រែផ្លាស់រួចហើយ។ ពេលដែលលោកអ្នករកគាត់ទស្សន៍ទាយ, លោកអ្នកនឹងជឿគាត់, បើមិនដូច្នោះទេលោកអ្នកទស្សន៍ទាយអ្វី? គាត់និយាយគឺជាប្រការនៅលើផ្ទៃ, ដែលនិយាយគឺជាប្រការក្នុងអតីតកាលរបស់លោកអ្នក, ប៉ុន្តែធាតុពិតទៅបានកើតឡើងផ្លាស់ប្រែរួចហើយ។ ដូច្នោះអ្នករាល់គ្នាគិតសាកមើល, លោកអ្នករកគាត់ទស្សន៍ទាយ, តើលោកអ្នកនឹងស្ដាប់តាម, ជឿតាមមែនទេ? ដូច្នោះមិនមែននឹងបង្កជាបន្ទុកលើស្មារតីរបស់លោកអ្នក? បង្កជាបន្ទុក, ក្នុងចិត្តលោកអ្នកគិតដល់វា, តើមិនមែនជាចិត្តប្រកាន់? ដូច្នោះចិត្តប្រកាន់នេះធ្វើដូចម្ដេចកម្ចាត់? តើនេះមិនមែនគ្រោះមួយបន្ថែមដែលមនុស្សចេតនា? ចិត្តប្រកាន់នេះសាងបង្កើតមិនមែនត្រូវតែរងទុក្ខច្រើនថែមទើបអាចកម្ចាត់ចោលឬ? រាល់មួយទ្វារ, រាល់មួយគ្រោះសុទ្ធតែស្ថិតនៅបញ្ហាបួសឡើងលើឬក៏ធ្លាក់ចុះក្រោម។ ដើមមកគឺពិបាករួចហើយ, នៅមានគ្រោះនេះដែលមនុស្សចេតនាបន្ថែមចូល, ធ្វើម្ដេចឆ្លងបានទៅ? លោកអ្នកអាចដោយសាររឿងនេះគឺនឹងជួបគ្រោះ, រំខាន។ ផ្លូវនេះក្រោយពីផ្លាស់ប្រែរបស់លោកអ្នកគឺមិនអនុញ្ញាតឲ្យអ្នកដទៃមើលឃើញ។ បើសិនអ្នកដទៃមើលឃើញរួចហើយ, បើសិនសុទ្ធតែអាចនិយាយចេញឲ្យលោកអ្នកថាលោកអ្នកដល់ជំហានមួយណាមានគ្រោះអ្វី, លោកអ្នកនៅបួសស្អីទៀត? ដូច្នេះជាមូលដ្ឋានគឺមិនអនុញ្ញាតឲ្យឃើញ។ ធម្មក្ខន្ធផ្សេងនរណាក៏មិនអនុញ្ញាតឲ្យឃើញ, សិស្សក្នុងធម្មក្ខន្ធដូចគ្នាក៏មិនអនុញ្ញាតឲ្យឃើញ, នរណាក៏និយាយមិនត្រូវ។ ដោយសារ

មួយជីវិតនោះគឺប្រែផ្លាស់រួចហើយ, គឺមួយជីវិតបួសហាត់។

មនុស្សខ្លះសួរខ្ញុំថា៖ សៀវភៅក្នុងសាសនាដទៃ, នៅមានសៀវភៅឈើគង់អាចអានឬអត់? ពួកយើងសម្តែង, សៀវភៅក្នុងសាសនា, ជាពិសេសសៀវភៅរបស់ពុទ្ធសាសនា, សុទ្ធតែជាហៅគេធ្វើដូចម្តេចបួសហាត់ចិត្តចរិត។ ពួកយើងក៏ជាពុទ្ធវង្ស, គួរនិយាយគឺគ្មានបញ្ហា។ ប៉ុន្តែមានចំណុចមួយ, ក្នុងគម្ពីរជាច្រើនមានប្រការមួយចំនួននៅក្នុងដំណើរការបកប្រែមានកំហុសរួចហើយ, ថែមទ្បើងដ៏ច្រើនពន្យល់គម្ពីរទៀត, ក៏ជាឈរនៅលើជាន់ថ្នាក់ខុសគ្នាដើម្បីពន្យល់, ដាក់និយមន័យតាមអំពើចិត្ត, នេះជាក់ស្តែងគឺចលាចលធម៌។ មនុស្សមួយចំនួនពន្យល់គម្ពីររញ៉េរញ៉ៃឃ្លាតចាកពីកម្រិតភពរបស់ព្រះពុទ្ធឆ្ងាយខ្លាំងណាស់, ជាមូលដ្ឋានមិនដឹងអត្ថន័យពិតប្រាកដនៅក្នុងនោះ, ដូច្នេះបញ្ហាយល់ឃើញក៏ជាខុសរួចហើយ។ លោកអ្នកចង់អានយល់វាទាំងស្រុង, ក៏មិនងាយស្រួល, លោកអ្នកខ្លួនឯងមិនភ្ញាក់ដឹងច្បាស់បាន។ ប៉ុន្តែលោកអ្នកនិយាយ៖ យើងខ្ញុំគឺចូលចិត្តចំពោះគម្ពីរ។ លោកអ្នករមែងវិលជុំវិញគម្ពីរដើម្បីរៀន, នោះជាក់ស្តែងគឺកំពុងបួសហាត់ក្នុងធម្មក្ខន្ធមួយនោះ, ដោយសារគម្ពីរក៏ជាយកគង់និងធម៌របស់ធម្មក្ខន្ធមួយនោះផ្សំផ្គុំជាមួយគ្នា, កាលណារៀនគឺបានរៀនធម្មក្ខន្ធមួយនោះរួចហើយ, មានបញ្ហាបែបនេះ។ ប្រសិនលោកអ្នកខូងចូលទៅក្នុង, យោងតាមវាដើម្បីបួស, នោះអាចជាបានដើរតាមធម្មក្ខន្ធមួយនោះរួចហើយ, គឺមិនមែនធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំទៀត។ បួសហាត់ពីដើមមកសម្តែងអទ្វេធម្មក្ខន្ធ, បើសិនលោកអ្នកបួសពិតធម្មក្ខន្ធមួយនេះ, អានតែគម្ពីររបស់ធម្មក្ខន្ធមួយនេះ។

និយាយអំពីសៀវភៅឈើគង់, បើលោកអ្នកចង់បួសគឺកុំអាន, ជាពិសេសគឺសៀវភៅទាំងនេះបច្ចុប្បន្ន, កុំមើល។ និយាយអំពីប្រភេទ

អ្វី《ហ្វ៊ឹងទីណើជិញ》,《ស៊ីញមិញហួយជី》, ឬក៏ជា《តាវចាង》ក៏ដូចគ្នា, ទោះបីគ្មានរបស់មិនល្អទាំងនោះក្ដី, ប៉ុន្ដែខាងក្នុងក៏មានស្ថិតនៅព័ត៌មានគ្រប់ប្រភេទនៃបណ្ដាជាន់ថ្នាក់។ ខ្លួនវាគឺជាវិធីសាស្រ្ដបួសហាត់, មើលកាលណាក៏បន្ថែមចូលក្នុងឲ្យលោកអ្នក, ជ្រៀតជ្រែកលោកអ្នក។ លោកអ្នកមានអារម្មណ៍ថាប្រយោគនេះត្រូវ, ល្អតើ, ភ្លាមនេះគឺមកដល់ហើយ។ បន្ថែមចូលក្នុងគង់ឲ្យលោកអ្នក, ទោះបីមិនមែនរបស់មិនល្អក៏ដោយ, ស្រាប់តែបន្ថែមចូលក្នុងបន្ដិចអ្វីផ្សេងឲ្យលោកអ្នក, លោកអ្នកនិយាយលោកអ្នកធ្វើម្ដេចហាត់? មិនមែនលេចឡើងបញ្ហាឬ? គ្រឿងអេឡិចត្រូនិកនេះខាងក្នុងទូរទស្សន៍របស់ពួកយើង, ប្រសិនបន្ថែមចូលគ្រឿងមួយផ្សេងឲ្យលោកអ្នក, លោកអ្នកនិយាយទូរទស្សន៍នេះនឹងបែបណា? គឺខូចជាបន្ទាន់, ជាក់ស្ដែងជាគោលសីលធម៌នេះ។ លើសពីនេះទៀតបច្ចុប្បន្នមានសៀវភៅឈីគង់ខ្លះច្រើនណាស់សុទ្ធតែជាក្លែងក្លាយ, នាំតាមព័ត៌មានគ្រប់ប្រភេទ។ ពួកយើងមានសិក្ខាកាមម្នាក់ពេលបើកសៀវភៅឈីគង់ភ្លាមខាងក្នុងលោតចេញមកសត្វពស់ធំមួយក្បាល។ ប្រាកដណាស់ពិស្ដារខ្ញុំមិនចង់និយាយ។ ដែលខ្ញុំទើបសម្ដែងជាក់ស្ដែងគឺជាមនុស្សហាត់គង់ពួកយើងខ្លួនឯងដោយសារមិនអាចប្រព្រឹត្តត្រឹមត្រូវចំពោះខ្លួនឯង, បង្កជាការរំខានមួយចំនួន, ក៏ជាក់ស្ដែងគឺរំខានដោយចិត្តមិនសុចរិតអន្ទងមក។ យើងខ្ញុំសម្ដែងចេញឲ្យអ្នករាល់គ្នាមានកន្លែងល្អ, ទុកឲ្យអ្នករាល់គ្នាដឹងបានធ្វើដូចម្ដេច, ធ្វើដូចម្ដេចដើម្បីសម្គាល់ច្បាស់ពួកវា, ដើម្បីអនាគតមិនលេចឡើងបញ្ហា។ លោកអ្នកកុំឃើញថាពាក្យនេះដែលខ្ញុំទើបសម្ដែងមិនសំខាន់, អ្នករាល់គ្នាដាច់ខាតយកចិត្តទុកដាក់, ជាញឹកញាប់លេចឡើងបញ្ហាគឺនៅចំណុចនេះ, ជាញឹកញាប់បញ្ហាគឺលេចឡើងនៅទីនេះ។ បួសហាត់គឺយ៉ាងលំបាកបំផុត, តឹងរឹងខ្លាំង

ណាស់, លោកអ្នកមិនយកចិត្តទុកដាក់បន្តិចគឺអាចធ្លាក់ចុះភ្លាម, បំផ្លាញក្នុងមួយភ្លែត, ដូច្នេះចិត្តដាក់លាក់ត្រូវតែសុចរិត។

## ឈើគង់ក្បាច់គុន

ក្រៅពីគង់ហ្វាបួសផ្ទៃក្នុង, ក៏មានឈើគង់ក្បាច់គុន។ នៅពេលខ្ញុំនិយាយអំពីឈើគង់ក្បាច់គុន, ខ្ញុំនៅចង់សង្កត់ធ្ងន់បញ្ហាមួយទៀត, បច្ចុប្បន្នក្នុងពិភពបួសហាត់មានទ្រឹស្ដីជាច្រើនអំពីឈើគង់។

ឥឡូវនេះក៏លេចឡើងអ្វីឈើគង់រូបវិចិត្រ, ឈើគង់តន្ត្រី, ឈើគង់អក្សរផ្ចង់, ឈើគង់របាំ, អ្វីក៏មាន, សុទ្ធតែជាឈើគង់? ខ្ញុំគឺមានអារម្មណ៍ដ៏ចម្លែក។ ខ្ញុំនិយាយនេះជាឈើគង់ចលាចល, មិនត្រឹមតែជាឈើគង់ចលាចលប៉ុណ្ណោះទេ, សុទ្ធសាធគឺជាជាន់ឈ្លីឈើគង់។ មូលដ្ឋានទ្រឹស្ដីជាអ្វី? និយាយថាពេលគូរ, ច្រៀង, រាំ, សរសេរអក្សរ, ឈានចូលក្នុងប្រភេទស្ថានភាពមួយស្រមើស្រមៃ, ហៅថាឈើគង់ថាយ, នោះគឺឈើគង់ឬ? មិនអាចទៅយល់ដឹងបញ្ហាបែបនេះ។ មិនមែនខ្ញុំនិយាយថានោះគឺជាន់ឈ្លីឈើគង់ឬ? ឈើគង់គឺប្រភេទសិក្សាមួយធំទូលាយស៊ីជម្រៅអំពីបួសហាត់រាងកាយមនុស្ស។ អ៎ូ, ស្រមើស្រមៃជាក់ស្ដែងគឺជាឈើគង់? ដូច្នោះពួកយើងស្រមើស្រមៃចូលបន្ទប់ទឹកចាត់ថាអ្វីដែរ? នោះមិនមែនជាន់ឈ្លីឈើគង់? ខ្ញុំនិយាយថាជាក់ស្ដែងគឺជាជាន់ឈ្លីឈើគង់។ នៅពិព័រណ៍សុខភាពបូព៌ាឆ្នាំមុន, មានឈើគង់អក្សរផ្ចង់អ្វីមួយ។ អ្វីហៅថាឈើគង់អក្សរផ្ចង់? ខ្ញុំដល់ឈើគង់អក្សរផ្ចង់ទីនោះសម្លឹងមើល, ឯកជននេះកាន់ជក់នៅទីនោះសរសេរអក្សរ, សរសេរអក្សរចប់ហើយ, ប្រើដៃបញ្ចេញឈើទៅលើអក្សរនីមួយៗ, ដែលបញ្ចេញសុទ្ធតែជាឈើខ្មៅ។ ពេញក្បាលគឺជាលុយ, កិត្តិនាម, លោកអ្នកនិយាយមើលតើអាចមានគង់ឬ? ឈើក៏នឹងមិនមែនជាឈើល្អ។ ព្យួរឡើងទីនោះលក់ថ្លៃណាស់ទៀត

ផង, ប៉ុន្ដែសុទ្ធតែជនបរទេសទិញរបស់គាត់។ ខ្ញុំនិយាយថានរណាទិញទៅផ្ទះអ្នកនោះគឺអភ័ព្វ។ ឈើខ្មៅនោះតើអាចល្អបានទេ? {ខ្ញុំ}ឃើញមុខឯកជននោះសុទ្ធតែជាពណ៌ខ្មៅ, គាត់ខ្ជួងលុយក្នុងក្រសែភ្នែក, គិតតែពីលុយ, តើអាចមានគង់ឬ? ខាងលើនាមប័ណ្ណរបស់ឯកជននេះបានសរសេរមួយគំនររាយនាមយ៉ាងធំ, អ្វីឈើគង់អក្សរផ្ទង់អន្ដរជាតិ។ល។ ខ្ញុំនិយាយថាតើល្បែងក្មេងលេងនេះគឺចាត់ថាឈើគង់?

អ្នករាល់គ្នាគិតសាកមើល, មនុស្សដែលចេញពីថ្នាក់នេះរបស់ខ្ញុំ, មនុស្ស៨០ - ៩០ភាគរយរបស់ពួកយើងពីថ្ងៃនេះតទៅលោកអ្នកមិនត្រឹមតែជាសះជំងឺ, លោកអ្នកទាំងនៅទទួលបានគង់, គង់ពិតប្រាកដ។ របស់នាំតាមរាងកាយលោកអ្នកបានដំរិសាមញ្ញរួចហើយ, បើសិនលោកអ្នកហាត់ខ្លួនឯង, មួយជីវិតលោកអ្នកក៏មិនអាចហាត់ចេញបាន។ យុវជនចាប់ផ្ដើមហាត់ពីឥឡូវនេះ, មួយជីវិតក៏ហាត់មិនចេញបានរបស់ទាំងនេះដែលខ្ញុំដំឡើងឲ្យ, នៅតែត្រូវមានគ្រូពូកែពិតប្រាកដដើម្បីបង្រៀនលោកអ្នក។ យើងខ្ញុំមនុស្សទាំងប៉ុន្មានជំនាន់ទើបបង្កើតបានហ្វាលូននេះនិងយន្ដការទាំងនេះ, របស់ទាំងនេះភ្លាមៗដំឡើងឲ្យលោកអ្នក។ ដូច្នេះខ្ញុំប្រាប់អ្នករាល់គ្នា, កុំដោយសារងាយបានហើយងាយបាត់។ នេះគឺយ៉ាងដ៏មានតម្លៃបំផុត, មិនអាចប្រើគុណតម្លៃដើម្បីវាស់វែង។ ពួកយើងបន្ទាប់ពីចេញពីថ្នាក់នេះតទៅ, ដែលលោកអ្នកនាំតាមគឺគង់ពិតប្រាកដ, គឺជាសារធាតុថាមពលខ្ពស់។ លោកអ្នកមកផ្ទះក៏សរសេរប៉ុន្មានអក្សរ, អក្សរមិនថាស្អាតឬអាក្រក់, តែមានគង់! ដូច្នេះបន្ទាប់ពីចេញពីថ្នាក់របស់ពួកយើង, នរណាៗក៏ថែមឡើងមួយអក្សរ [គ្រូ], សុទ្ធតែជាគ្រូឈើគង់អក្សរផ្ទង់? ខ្ញុំនិយាយថាមិនអាចយល់ដឹងយ៉ាងនេះ។ ដោយសារមនុស្សដែលមានគង់ពិតប្រាកដ, មនុស្សមានថាមពល, លោកអ្នកមិនចាំបាច់

ប្រើគំនិតពិសេសដើម្បីបញ្ចេញ, លោកអ្នកប៉ះឆ្លងអ្វីក៏នឹងបន្សល់ទុកថាមពល, សុទ្ធតែជាបញ្ចេញពន្លឺផ្លេកៗ។

ខ្ញុំនៅអានទស្សនាវដ្ដីមួយក្បាល, បានបង្ហោះសារមួយយ៉ាងនេះ, និយាយថាចង់បើកថ្នាក់បង្រៀនឈីគង់អក្សរផ្ចង់។ ខ្ញុំបានបើកបន្តិច, មើលៗគាត់បង្រៀនដូចម្ដេច។ ខាងក្នុងសរសេរយ៉ាងនេះ៖ មុនបង្អស់សម្រួល, ដកដង្ហើម, បន្ទាប់មកអង្គុយសមាធិគំនិត{ដាក់នៅ}ឈីតានធាន, អង្គុយសមាធិ១៥នាទីដល់កន្លះម៉ោង, គំនិតលើកឈីតានធានឡើងនាំចូលក្នុងកំភួនដៃ, កាន់ជក់ឡើងជ្រលក់ចូលទឹកប៊ិក, ម្ដងទៀតផ្លាស់ទីឈីដល់ចុងជក់។ គំនិតដល់ហើយ, ចាប់ផ្ដើមសរសេរអក្សរ។ នោះមិនមែនបញ្ឆោតមនុស្សហើយឬ? អុំ, លើកឈីដល់ទីណាជាក់ស្ដែងគឺឈីគង់នោះឬ? ដូច្នោះពេលពួកយើងញ៉ាំបាយ, អង្គុយសមាធិមួយភ្លែត, កាន់ចង្កឹះឡើង, ផ្លាស់ទីឈីឡើងដល់ចុងចង្កឹះញ៉ាំបាយ, នោះគឺហៅថាឈីគង់ញ៉ាំបាយ, តើមែនទេ? ម្ហូបក៏សុទ្ធតែជាថាមពល, រឿងនេះគឺនិយាយដូច្នោះ។ ខ្ញុំនិយាយថាជាក់ស្ដែងគឺជាន់ឈ្លីឈីគង់, គាត់មើលឈីគង់រាក់ខ្លីយ៉ាងនេះ, ដូច្នេះមិនអាចទៅយល់ដឹងបែបនេះ។

ប៉ុន្តែឈីគង់ក្បាច់គុនបានអាចចាត់ថាជាមុខវិជ្ជាឈីគង់ឯករាជ្យមួយ។ ហេតុអ្វី? វាមានដំណើរការស្នងបង្រៀនរាប់សហស្សវត្សរ៍, វាមានមួយសំណុំពេញលេញអំពីទ្រឹស្ដីប្ដូសហាត់ក៏ដូចជាមួយសំណុំពេញលេញអំពីវិធីសាស្ត្រប្ដូសហាត់, ដូច្នេះវាអាចបានចាត់ថាមួយសំណុំពេញលេញ។ ទោះបីជាបែបនេះ, ឈីគង់ក្បាច់គុនក៏ជាប្រការក្នុងជាន់ថ្នាក់ទាបបំផុតក្នុងគង់ហ្វាប្ដូសផ្ទៃក្នុងរបស់ពួកយើង។ ឃីញឈីគង់ជាក់ស្ដែងគឺប្រភេទគ្រាប់ថាមពលសារធាតុមួយ, សាមញ្ញបំផុតប្រើសម្រាប់វាយបុក។ លើកឧទាហរណ៍ឲ្យអ្នករាល់គ្នា, ប៉េកាំងមានសិក្ខាកាមម្នាក់,

បន្ទាប់ពីចេញពីថ្នាក់ហ្វាលូនតាហ្វារបស់យើងខ្ញុំ, ដៃមិនអាចចុចរបស់អ្វីបាន។ ដល់ហាងទិញឡានកុមារ, ប្រើដៃសាកមើលឡាននេះរឹងមាំឬអត់, គឺចុចមួយយ៉ាងនេះ, [ផាំង], ផ្ទើបាក់ភ្លាម, គាត់មានអារម្មណ៍ថាដ៏ចម្លែក។ មកផ្ទះអង្គុយកៅអី, គាត់មិនអាចប្រើដៃដើម្បីចុច, ប្រើដៃចុចកាលណាកៅអីនោះ [ផាំង] គឺបាក់ភ្លាម។ គាត់សួរខ្ញុំជារឿងដូចម្ដេច។ ខ្ញុំគ្មានសម្ដែងឲ្យគាត់, ខ្ញុំខ្លាចគាត់សាងបង្កើតចិត្តប្រកាន់។ ខ្ញុំនិយាយថានេះសុទ្ធតែជាស្ថានភាពធម្មតា, បណ្ដោយតាមធម្មជាតិ, កុំខ្វល់ដល់វា, សុទ្ធតែជារឿងល្អ។ សីលគង់នោះ{បើសិន}អនុវត្តបានល្អ, ថ្មនោះប្រើដៃច្របាច់កាលណាសុទ្ធតែត្រូវបែកខ្ទេច។ នេះមិនជាក់ស្ដែងជាឃើញឈើគង់ឬ? ប៉ុន្តែគាត់ក៏មិនដែលហាត់ឃើញឈើគង់។ នៅក្នុងគង់ហ្វាបួសផ្ទៃក្នុងសីលគង់ទាំងនេះជាធម្មតាសុទ្ធតែលេចឡើង, ប៉ុន្តែដោយសារចិត្តចរិតមនុស្សកាន់មិនជាប់, ដូច្នេះជាញឹកញាប់បានលេចឡើងសីលគង់រួចហើយក៏មិនឲ្យលោកអ្នកប្រើ។ ជាពិសេសពេលដែលបួសហាត់នៅជាន់ថ្នាក់ទាប, ចិត្តចរិតរបស់មនុស្សនៅមិនទាន់លើកកម្ពស់ឡើង, សីលគង់ដែលលេចចេញលើជាន់ថ្នាក់ទាបនេះ, ជាមូលដ្ឋានគឺមិនឲ្យយកចេញ។ យូរៗទៅស្របតាមពេលដែលលោកអ្នកលើកកម្ពស់ជាន់ថ្នាក់រួចហើយ, របស់ទាំងនេះគ្មានប្រយោជន៍អ្វីទៀត, ក៏នឹងមិនបានយកចេញមកទៀត។

ឈើគង់ក្បាច់គុនពិស្ដារគឺហាត់ដូចម្ដេច? ហាត់ឈើគង់ក្បាច់គុនវាសម្ដែងផ្លាស់ទីឈើ។ ប៉ុន្តែចាប់ផ្ដើមឈើនេះក៏មិនងាយស្រួលផ្លាស់ទី, និយាយថាលោកអ្នកគិតដល់ផ្លាស់ទីឈើគឺផ្លាស់ទីឡើងបាន, វានៅតែផ្លាស់ទីឡើងមិនបាន។ នោះធ្វើដូចម្ដេច? គាត់ត្រូវតែទៅហាត់ដៃរបស់គាត់, រាងកាយរបស់គាត់ឆ្អឹងជំនីសងខាងឬក៏ជើង, ភ្លៅ, ដើមដៃកំភួនដៃ,

ក្បាលសុទ្ធតែត្រូវហាត់។ ហាត់ដូចម្ដេច? មនុស្សខ្លះប្រើដៃទៅបុកវាយដើមឈើ, ប្រើបាតដៃទៅវាយដើមឈើ។ មនុស្សខ្លះប្រើដៃទះទៅលើផ្ទាំងថ្ម, ផាំងៗទះយ៉ាងនេះ។ លោកអ្នកនិយាយថាឆ្អឹងនេះបោកលើថ្មគួរឈឺប៉ុណ្ណា, នេះកាលណាប្រើកម្លាំងហួសបន្តិចគឺចេញឈាមភ្លាម។ ឈឺនេះក៏មិនទាន់ផ្លាស់ទីចេញបាន។ ធ្វើដូចម្ដេច? គាត់ចាប់ផ្ដើមគ្រវីដើមដៃ, ដើម្បីឲ្យឈាមហូរច្រាសចេញមក, ដើមដៃ, បាតដៃនឹងហើមឡើង។ ដោយពិតជាក់ស្ដែងគឺប៉ោងឡើង, បន្ទាប់មកគាត់វាយទៅលើផ្ទាំងថ្មមួយ, ឆ្អឹងគឺត្រូវបានទ្រនាប់រួចហើយ, មិនអាចប៉ះទង្គិចដោយផ្ទាល់ដល់ថ្មទៀត, ក៏នឹងមិនឈឺយ៉ាងនោះទៀត។ ស្របតាមគាត់ហាត់គង់, គ្រូនឹងបង្រៀនគាត់, យូរៗទៅគាត់នឹងផ្លាស់ទីឈឺបាន។ យ៉ាងណាក៏ដោយគ្រាន់តែផ្លាស់ទីឈឺក៏មិនបាន, ពេលដែលវាយបុកពិតប្រាកដ, គេមិនរង់ចាំលោកអ្នកទេ។ ប្រាកដណាស់ពេលដែលមនុស្សអាចផ្លាស់ទីឈឺគឺអាចទប់ទល់វាយបុក, កាន់ដំបងដ៏ក្រាសវាយពីលើអាចក៏មិនឈឺ, គាត់ផ្លាស់ទីឈឺហើយអាចប៉ោងឡើង។ ប៉ុន្តែឈឺគឺជារបស់បុព្វកាលបំផុតរយៈពេលចាប់ផ្ដើម, ស្របតាមពេលដែលគាត់បន្តហាត់, ឈឺនេះនឹងបំប្លែងឡើងក្លាយជាសារធាតុថាមពលខ្ពស់។ នៅពេលវាបំប្លែងក្លាយជាសារធាតុថាមពលខ្ពស់, បន្តិចម្ដងៗនឹងបង្កើតជាប្រភេទគ្រាប់ថាមពលមួយមានដង់ស៊ីតេដ៏ធំ។ ហើយប្រភេទគ្រាប់ថាមពលនេះគឺមានភាពវៃឆ្លាត, ដូច្នេះវាក៏ជាគ្រាប់សីលគង់មួយ, ជាក់ស្ដែងគឺជាប្រភេទសីលគង់មួយ។ ប៉ុន្តែប្រភេទសីលគង់នេះគឺឯកទេសប្រើសម្រាប់វាយបុក, ទប់ទល់វាយបុក, ប្រើវាសម្រាប់ព្យាបាលជំងឺគឺមិនបាន។ ព្រោះសារធាតុថាមពលខ្ពស់នោះវានៅអវកាសផ្សេង, វាមិនមែនដើរនៅអវកាសនេះរបស់ពួកយើង, ដូច្នេះពេលវេលារបស់វាលឿនជាងរបស់ពួកយើង។ ពេលដែលលោកអ្នកចង់ទៅវាយបុក

អ្នកដទៃ, មិនចាំបាច់ផ្លាស់ទីឈីទៀត, គិតទៀត, គង់នោះបានដល់ទីនោះភ្លាមហើយ។ អ្នកដទៃវាយលោកអ្នក, ពេលដែលលោកអ្នកទៅទប់, គង់ក៏បានដល់ទីនោះរួចហើយ។ មិនខ្វល់លោកអ្នកចេញដៃលឿនដល់ណា, វាលឿនជាងលោកអ្នកទៅទៀត, ទស្សនាទានពេលវេលាសងខាងគឺមិនដូចគ្នា។ ហាត់ឈីគង់ក្បាច់គុនអាចហាត់ចេញអ្វីបាតដៃមន្ទិលដែក, បាតដៃហិង្គុល, ភ្លៅជីនកាង, ជើងអរហន្ត, នេះជាអានុភាពក្នុងមនុស្សសាមញ្ញ។ មនុស្សសាមញ្ញពេលបានឆ្លងកាត់ហ្វឹកហាត់រួចហើយគឺអាចសម្រេចបានជំហានមួយនេះ។

ខុសគ្នាធំបំផុតរវាងឈីគង់ក្បាច់គុននិងគង់ហ្វាបួសផ្ទៃក្នុងគឺ៖ ឈីគង់ក្បាច់គុនតម្រូវហាត់ក្នុងពេលធ្វើចលនា, ដូច្នេះឈីដើរក្រោមស្បែក។ ដោយសារគឺហាត់ក្នុងពេលធ្វើចលនា, មិនអាចចូលក្នុងស្ងប់, ឈីមិនចូលក្នុងតានធាន, ឈីដើរក្រោមស្បែក, ឈីលេចតាមសាច់ដុំ, ដូច្នេះមិនអាចបួសជីវិត, ក៏មិនអាចបួសហាត់ចេញជំនាញការខ្ពស់ជ្រៅ។ គង់ហ្វាបួសផ្ទៃក្នុងពួកយើងគឺតម្រូវហាត់នៅក្នុងស្ងប់។ គង់ហ្វាធម្មតាសម្តែងឈីចូលក្នុងតានធាន, ឈីចូលក្នុងពោះក្រោម, យកចិត្តទុកដាក់បួសហាត់ក្នុងស្ងប់, យកចិត្តទុកដាក់បំប្លែងរាងកាយដើម, អាចបួសជីវិត, អាចបួសហាត់ដល់ជាន់ថ្នាក់ខ្ពស់ជាង។

អ្នករាល់គ្នាអាចឮនិយាយថាមានជំនាញការបែបនេះ, នៅក្នុងប្រលោមលោកសរសេរអំពីអ្វីជីនជុងច្វាវ, ធាពូសាន, ប៉ាយពូឆនយ៉ាង។ ឈីញគង់អ៊ាំ, មនុស្សខ្លះអាចទៅមកលើខ្ពស់; មនុស្សខ្លះសូម្បីតែអាចមុជចូលក្នុងអវកាសផ្សេង។ ប្រភេទជំនាញការនេះមានឬអត់? មាន, ចំណុចមួយនេះគឺបញ្ជាក់, ប៉ុន្តែក្នុងមនុស្សសាមញ្ញមិនមាន។ មនុស្សពិតប្រាកដហាត់ចេញប្រភេទជំនាញការនេះ, គាត់ក៏មិនអាចយកចេញ

មកបង្ហាញ។ ដោយសារគាត់មិនមែនសាមញ្ញហាត់តែក្បាច់គុន, ទាំងស្រុងគឺលើសផុតជាន់ថ្នាក់មនុស្សសាមញ្ញរួចហើយ, ដូច្នោះឯកជននេះគឺចាំបាច់ត្រូវយោងតាមគង់ហ្វាបួសផ្ទៃក្នុងដើម្បីបួស។ គាត់គឺត្រូវតែសម្តែងចិត្តចរិត, លើកកម្ពស់ចិត្តចរិតរបស់គាត់, គាត់ក៏ត្រូវតែមើលឲ្យស្រាលផលប្រយោជន៍សម្ភារៈរបស់ទាំងនេះ។ ថ្វីបើគាត់អាចបួសចេញប្រភេទជំនាញការនេះក៏ដោយ, ប៉ុន្តែផ្ទុយមកវិញពីពេលនេះតទៅគាត់មិនអាចនៅក្នុងមនុស្សសាមញ្ញប្រើតាមអំពើចិត្តបានទៀត, ពេលដែលគ្មានមនុស្សមើលឃើញខ្លួនឯងធ្វើបន្តិចគឺបាន។ លោកអ្នកឃើញក្នុងប្រលោមលោកនោះសរសេរ, និយាយថាឯកជននេះព្រោះតែផែនទីក្បួនដាវ, ព្រោះតែស្វែងរកកំណប់, ព្រោះតែមនុស្សស្រី, ទៅសម្លាប់ទៅប្រយុទ្ធ, អានុភាពនរណាក៏ធំណាស់, ទៅមកដូចអាទិទេព។ អ្នករាល់គ្នាគិតសាកមើល, មនុស្សពិតជាមានប្រភេទជំនាញការនេះមិនមែនគាត់បួសផ្ទៃក្នុងបួសចេញបានឬ? គាត់គោរពចិត្តចរិតទើបបួសចេញមកបាន, ចំពោះកិត្តិនាមផលប្រយោជន៍និងតណ្ហាគ្រប់ប្រភេទបានមើលស្រាលតាំងពីយូររួចហើយ, គាត់អាចទៅសម្លាប់មនុស្សឬ? គាត់អាចមើលសំខាន់លុយទ្រព្យយ៉ាងនោះឬ? ជាមូលដ្ឋានគឺមិនអាច, នោះគ្រាន់តែជាការបំប៉ោងក្នុងសិល្បៈប៉ុណ្ណោះ។ មនុស្សគឺស្វែងរករំញោចស្មារតី, ធ្វើម្តេចសម្រាលគឺបាន។ អ្នកនិពន្ធក៏ក្តាប់ជាប់បានលក្ខណៈនេះ, ទោះយ៉ាងណាក៏ធ្វើឲ្យលោកអ្នកបានសម្រាល, បានសប្បាយចិត្ត, គាត់ប្រឹងអស់ពីចិត្តសរសេរឲ្យលោកអ្នក។ សរសេរកាន់តែអាថ៌កំបាំងលោកអ្នកកាន់តែចូលចិត្តអាន, នោះគ្រាន់តែជាការបំប៉ោងក្នុងសិល្បៈ។ មនុស្សពិតប្រាកដមានប្រភេទជំនាញការនេះពិតមែនក៏នឹងមិនធ្វើបែបនេះ, ជាពិសេសគឺកាន់តែមិនអាចយកចេញមកសម្តែង។

# ចិត្តសាស្ត្របង្ហាញ

ពួកយើងមានសិក្ខាកាមជាច្រើន, ដោយសារបួសហាត់នៅក្នុងមនុស្សសាមញ្ញ, មានចិត្តជាច្រើនដាក់ចុះមិនបាន, មានចិត្តជាច្រើនបានបង្កើតជាធម្មជាតិរួចហើយ, គាត់ខ្លួនឯងមិនកត់សម្គាល់បានទៀត។ ប្រភេទចិត្តសាស្ត្របង្ហាញនេះកន្លែងណាក៏អាចបង្ហាញចេញមក, ពេលធ្វើរឿងល្អក៏អាចបង្ហាញចេញមកចិត្តសាស្ត្របង្ហាញ។ ពេលធម្មតាខ្លួនឯងដើម្បីកិត្តិនាម, ដើម្បីផលប្រយោជន៍ទទួលបានកន្លែងល្អជាងបន្តិច, សម្ដែងៗ, បង្ហាញៗ៖ ខ្ញុំមានអានុភាព, អ្នកខ្លាំង។ ពួកយើងក៏មានប្រភេទកាលៈទេសៈនេះ, ហាត់ល្អជាង, ភ្នែកទិព្វមើលបានច្បាស់ជាង, ចលនាល្អមើលជាង, ក៏មានបង្ហាញផងដែរ។

មានមនុស្សសម្ដែង៖ ខ្ញុំស្ដាប់ឮលោកគ្រូលីនិយាយប្រការអ្វី, អ្នករាល់គ្នាព័ទ្ធជុំវិញដើម្បីស្ដាប់, គាត់នៅទីនោះសម្ដែង, ប្រើការពន្យល់របស់ខ្លួនឯងថែមមែកបូកស្លឹកផ្សព្វផ្សាយពាក្យចចាមអារ៉ាម។ គោលបំណងជាអ្វី? ក៏ជាដើម្បីបង្ហាញខ្លួនឯង។ នៅមានមនុស្សផ្សព្វផ្សាយពាក្យចចាមអារ៉ាមទាំងនោះ, គាត់{ប្រុស}ចម្លងគាត់, គាត់{ស្រី}ចម្លងគាត់, និយាយនៅទីនោះដោយរំជួលចិត្តខ្លាំង, ហាក់ដូចជាគាត់ដ៏ជំនាញខាងផ្ដល់ព័ត៌មាន។ សិក្ខាកាមរបស់ពួកយើងច្រើនយ៉ាងនេះក៏គ្មានយល់ច្បាស់ដូចគាត់, អ្នកដទៃគ្មានដឹងច្រើនដូចគាត់, គាត់បានបង្កើតជាធម្មជាតិរួចហើយ, ប្រហែលមិនទទួលដឹងដោយខ្លួនឯងបានទៀត។ នៅក្នុងអឌ្ឍសម្បជញ្ញៈគាត់គឺមានចិត្តសាស្ត្របង្ហាញនេះ, បើមិនដូច្នោះទេផ្សព្វផ្សាយពាក្យចចាមអារ៉ាមទាំងនេះធ្វើអ្វី? នៅមានមនុស្សផ្សព្វផ្សាយថាលោកគ្រូពេលណាៗត្រឡប់ទៅភ្នំ។ ខ្ញុំក៏មិនមែនមកពីក្នុងភ្នំ, ខ្ញុំត្រឡប់ទៅភ្នំណា? នៅមានមនុស្សនិយាយ, លោកគ្រូថ្ងៃណាៗបានសម្ដែង

ប្រការអ្វីឲ្យនរណា, បានប្រព្រឹត្តពិសេសចំពោះនរណាយ៉ាងណា។ ផ្សព្វផ្សាយប្រការទាំងនេះមានកន្លែងល្អអ្វី? កន្លែងល្អបន្តិចក៏គ្មាន, ប៉ុន្តែយើងខ្ញុំបានមើលឃើញនេះជាចិត្តប្រកាន់របស់គាត់, ប្រភេទចិត្តសាស្ត្របង្ហាញមួយ។

នៅមានមនុស្សរកខ្ញុំដើម្បីស៊ីញ៉េឈ្មោះ, គោលបំណងជាអ្វី? ក៏ជារបៀបរបស់មនុស្សសាមញ្ញ, ស៊ីញ៉េឈ្មោះ, ទុកជាអនុស្សាវរីយ៍។ លោកអ្នកមិនបួស, ខ្ញុំស៊ីញ៉េឈ្មោះឲ្យលោកអ្នកក៏គ្មានប្រយោជន៍។ សៀវភៅរបស់ខ្ញុំមួយអក្សរៗសុទ្ធតែជារូបភាពរបស់ខ្ញុំនិងហ្វាលូន, រាល់ប្រយោគសុទ្ធតែជាខ្ញុំសម្តែង, លោកអ្នកនៅចង់ស៊ីញ៉េឈ្មោះអ្វី? មានមនុស្សសម្តែងថា៖ ស៊ីញ៉េឈ្មោះរួចហើយ, ព័ត៌មានរបស់លោកគ្រូនឹងការពារយើង។ នៅតែសម្តែងអំពីព័ត៌មាននោះ, យើងខ្ញុំក៏មិនសម្តែងព័ត៌មាន។ សៀវភៅនេះគឺមិនអាចប្រើគុណតម្លៃដើម្បីវាស់វែងរួចហើយ។ លោកអ្នកនៅចំណង់របស់អ្វីទៀត? នេះសុទ្ធតែជាប្រការមួយចំនួនដែលឆ្លុះបញ្ចាំងពីចិត្តទាំងនោះ។ នៅមានអ្នកខ្លះមើលឃើញសិក្ខាកាមទាំងនេះដែលតាមក្បែរខ្លួនខ្ញុំ, បន្ទាប់ពីមើលឃើញពាក្យសម្តីឥរិយា, គឺរៀនតាម, ល្អអាក្រក់គាត់ក៏មិនដឹង។ ភាពពិតយើងខ្ញុំមិនខ្វល់គឺនរណាបែបណា, ធម៌មានតែមួយ, មានតែយោងតាមមហាធម៌នេះដើម្បីធ្វើ, នោះទើបជាបរមាណឹយពិតប្រាកដ។ មនុស្សតាមក្បែរខ្លួនខ្ញុំគ្មានបានប្រព្រឹត្តពិសេសអ្វី, ក៏ដូចអ្នករាល់គ្នា, ពួកគាត់គ្រាន់តែជាបុគ្គលិកការងាររបស់សមាគមស្រាវជ្រាវប៉ុណ្ណោះ, កុំបំផុសចិត្តទាំងនេះ។ ពួកយើងជាញឹកញាប់ពេលបំផុសចិត្តនេះកាលណា, លោកអ្នកដោយមិនដឹងខ្លួនគឺបានផ្តើមផលប៉ះពាល់បំផ្លាញមហាធម៌រួចហើយ, ពាក្យដ៏រំជួលចិត្តនេះដែលលោកអ្នកផលិត, សូម្បីតែអាចលេចឡើងទំនាស់, ជាញឹកញាប់ថ្លក់ឡើងចិត្ត

ប្រកាន់ឲ្យសិក្ខាកាម, ក៏អូសទាញដល់ក្បែរលោកគ្រូដើម្បីស្តាប់បានអ្វីច្រើនជាងជាដើម, រឿងរ៉ាវទាំងនេះ, មិនសុទ្ធតែជាបញ្ហានេះឬ?

ចិត្តសាស្ត្របង្ហាញនេះនៅងាយស្រួលនាំមកប្រការអ្វី? ពេលវេលាបង្រៀនគង់របស់ខ្ញុំបានពីរឆ្នាំរួចហើយ, ក្នុងចំណោមសិក្ខាកាមយូរឆ្នាំបួសហាត់ហ្វាលូនតាហ្វាពួកយើង, មានមនុស្សមួយក្រុមអាចបើកគង់ដ៏លឿន; មានមនុស្សមួយក្រុមនឹងចូលក្នុងស្ថានភាពត្រាស់ដឹងបន្តិចម្តង, ភ្លាមៗនោះចូលក្នុងត្រាស់ដឹងបន្តិចម្តង។ ហេតុអ្វីពេលនោះមិនលេចសីលគង់ទាំងនេះ? ដោយសារខ្ញុំភ្លាមៗរុញលោកអ្នកឡើងដល់ខ្ពស់យ៉ាងនោះ, ចិត្តមនុស្សសាមញ្ញរបស់លោកអ្នកសុទ្ធតែមិនទាន់កម្ចាត់គឺមិនបាន។ ប្រាកដណាស់ចិត្តចរិតរបស់លោកអ្នកបានលើកឡើងដ៏ខ្ពស់រួចហើយ, ក៏ប៉ុន្តែមានចិត្តប្រកាន់ជាច្រើនមិនទាន់កម្ចាត់បាន, ដូច្នេះមិនអាចទុកឲ្យលោកអ្នកលេចសីលគង់ទាំងនេះ។ ពេលលោកអ្នកឆ្លងផុតដំណាក់កាលមួយនេះរួចហើយ, នឹងនរចុះរួចហើយ, ភ្លាមៗនោះរុញលោកអ្នកឡើងដល់ស្ថានភាពត្រាស់ដឹងបន្តិចម្តង។ នៅក្នុងស្ថានភាពត្រាស់ដឹងបន្តិចម្តងនេះ, ភ្នែកទិព្វរបស់លោកអ្នកនឹងបើកនៅដ៏ខ្ពស់, លោកអ្នកនឹងលេចសីលគង់ដ៏ច្រើន។ ភាពពិតខ្ញុំប្រាប់អ្នករាល់គ្នា, ពេលដែលបួសហាត់ពិតប្រាកដ, ទើបចូលគឺនឹងលេចឡើងសីលគង់ដ៏ច្រើន, លោកអ្នកបានឈានចូលក្នុងជាន់ថ្នាក់ខ្ពស់យ៉ាងនោះរួចហើយ, ដូច្នេះសីលគង់គឺច្រើនណាស់។ ថ្មីៗនេះពួកយើងមានមនុស្សជាច្រើនអាចនឹងលេចឡើងស្ថានភាពនេះ។ នៅមានមនុស្សមួយចំនួន, គាត់បួសមិនខ្ពស់, របស់នាំតាមខ្លួនគាត់និងកម្លាំងអត់ធ្មត់របស់គាត់ខ្លួនឯងរួមបញ្ចូលគ្នាគឺមានកំណត់, ដូច្នេះមានមនុស្សមួយចំនួននៅជាន់ថ្នាក់ដ៏ទាបគឺបើកគង់ត្រាស់ដឹងរួចហើយ, ត្រាស់ដឹងទាំងស្រុង, នឹងលេចឡើង

មនុស្សបែបនេះ។

ខ្ញុំសម្ដែងចេញបញ្ហានេះជាមួយអ្នករាល់គ្នា, នោះគឺចង់ប្រាប់អ្នករាល់គ្នាថា, ពេលណាមនុស្សបែបនេះលេចឡើង, លោកអ្នកដាច់ខាតកុំចាត់ទុកគាត់ជាអង្គត្រាស់ដឹងអស្ចារ្យអ្វីឲ្យសោះ។ នៅក្នុងបួសហាត់នេះគឺជាបញ្ហាមួយដ៏តឹងរឹង, មានតែយោងតាមមហាធម៌នេះដើម្បីធ្វើទើបជាត្រូវ។ មិនបានឃើញមនុស្សមានសីលគង់, ទេពអំណាច, មើលឃើញប្រការមួយចំនួន, លោកអ្នកគឺទៅតាមគាត់, គឺស្ដាប់តាមបែបនេះ។ លោកអ្នករួចហើយនឹងធ្វើបាបគាត់, គាត់នឹងបង្កើតចេញចិត្តត្រេកអរ, ចុងក្រោយប្រការអ្វីរបស់ខ្លួនឯងក៏បាត់អស់, បិទអស់, ចុងក្រោយធ្លាក់ចុះក្រោម។ បើកគង់រួចហើយក៏នឹងធ្លាក់ចុះក្រោម, កាន់មិនជាប់ត្រាស់ដឹងរួចហើយក៏នឹងធ្លាក់ចុះក្រោម។ ព្រះពុទ្ធនោះកាន់មិនល្អក៏ធ្លាក់ចុះ, សូម្បីតែលោកអ្នកជាមនុស្សបួសហាត់ក្នុងមនុស្សសាមញ្ញ! ដូច្នេះមិនខ្វល់លេចបានសីលគង់ប៉ុន្មាន, សីលគង់ធំដល់ណា, ទេពអំណាចលាតត្រដាងធំដល់ណា, លោកអ្នកជាក់លាក់ត្រូវកាន់ឲ្យជាប់។ ពួកយើងថ្មីៗនេះមានមនុស្សអង្គុយនៅទីនេះគឺបាត់, មួយភ្លែតគាត់ក៏លាតត្រដាងចេញមក, ជាក់ស្ដែងគឺជាបែបនេះ, ទេពអំណាចធំជាងសុទ្ធតែនឹងលេចឡើង។ អនាគតលោកអ្នកធ្វើដូចម្ដេច? ធ្វើជាសិក្ខាកាម, សិស្សរបស់យើងខ្ញុំ, អនាគតរឿងរ៉ាវនេះលោកអ្នកខ្លួនឯងលេចឡើងក៏ដោយ, អ្នកដទៃលេចឡើងក៏ដោយ, លោកអ្នកមិនបានទៅថ្វាយបង្គំគាត់, ទៅចំណង់របស់នេះ។ ចិត្តលោកអ្នកប្រែកាលណា, ជាបន្ទាន់គឺចប់, លោកអ្នកគឺធ្លាក់ចុះរួចហើយ, ប្រហែលជាលោកអ្នកខ្ពស់ជាងគាត់ទៅទៀត, គ្រាន់តែជាមិនទាន់លេចទេពអំណាចប៉ុណ្ណោះ។ យ៉ាងហោចណាស់នៅលើបញ្ហានេះលោកអ្នកគឺធ្លាក់ចុះរួចហើយ, ដូច្នេះអ្នករាល់គ្នាដាច់ខាត

យកចិត្តទុកដាក់បញ្ហានេះ។ យើងខ្ញុំបានដាក់រឿងរ៉ាវនេះលើទីតាំងដ៏សំខាន់, ដោយសារដ៏ឆាប់រហ័សគឺនឹងលេចឡើងរឿងរ៉ាវនេះ, លេចឡើងកាលណា, លោកអ្នកកាន់មិនជាប់គឺមិនបាន។

មនុស្សបួសហាត់លេចគង់រួចហើយ, បើកគង់រួចហើយ, ឬក៏ជាត្រាស់ដឹងពិតប្រាកដរួចហើយ, ក៏មិនអាចមើលខ្លួនឯងថាជាដូច្នេះដូច្នោះ, ប្រការដែលគាត់មើលឃើញ, ជាប្រការមើលឃើញនៅក្នុងជាន់ថ្នាក់នេះរបស់គាត់។ ដោយសារបួសហាត់ដល់ជំហានមួយនេះ, ក៏ជាក់ស្តែងគឺចរិតភ្ញាក់ដឹងរបស់គាត់សម្រេចបានជំហានមួយនេះ, បរមាណើយចិត្តចរិតរបស់គាត់សម្រេចបានជំហានមួយនេះ, បញ្ញារបស់គាត់ក៏ជាដល់ជំហានមួយនេះ។ ដូច្នេះប្រការក្នុងជាន់ថ្នាក់ខ្ពស់ជាង, គាត់អាចនឹងមិនជឿ។ ជាក់ស្តែងគឺដោយសារគាត់មិនជឿ, ទើបនឹងបង្កជាគាត់សន្មតថាអ្វីដែលគាត់មើលឃើញគឺជាដាច់ខាត, សន្មតថាគឺជាទាំងនេះ។ តែនៅខុសឆ្ងាយខ្លាំងណាស់, ដោយសារជាន់ថ្នាក់របស់គាត់គ្រាន់តែនៅទីនេះ។

មានមនុស្សមួយផ្នែកត្រូវការបើកគង់នៅក្នុងជាន់ថ្នាក់នេះ, បួសឡើងលើទៀតគាត់ក៏បួសឡើងមិនបាន, ដូច្នេះគ្រាន់តែអាចនៅលើជាន់ថ្នាក់នេះបើកគង់ត្រាស់ដឹង។ មនុស្សបួសហាត់ចេញមករបស់ពួកយើងពីពេលនេះតទៅ, មានមនុស្សត្រាស់ដឹងនៅតាវតួចលោកីយ៍, មានមនុស្សត្រាស់ដឹងនៅជាន់ថ្នាក់ខុសគ្នា, មានមនុស្សត្រាស់ដឹងនៅសម្រេចមគ្គផល។ ត្រាស់ដឹងនៅសម្រេចមគ្គផលទើបជាខ្ពស់បំផុត, នៅលើជាន់ថ្នាក់ខុសគ្នាសុទ្ធតែអាចមើលឃើញនិងអាចលាតត្រដាងចេញមក។ ជាក់ស្តែងគឺនៅជាន់ថ្នាក់ទាបបំផុតតាវតួចលោកីយ៍បើកគង់ត្រាស់ដឹង, ក៏អាចមើលឃើញអវកាសមួយចំនួន, អង្គត្រាស់ដឹងមួយចំនួន, ក៏

អាចទំនាក់ទំនងជាមួយពួកគាត់។ ពេលនោះលោកអ្នកកុំពេញចិត្តខ្លួនឯងអប្បមាណ, នៅលើតាវតូចលោកីយ៍, នៅលើជាន់ថ្នាក់ទាបត្រាស់ដឹងមិនសម្រេចមគ្គផល, នេះគឺជាបញ្ហាក់។ ដូច្នោះធ្វើដូចម្ដេច? គាត់គ្រាន់តែអាចរក្សានៅក្នុងជាន់ថ្នាក់នេះ, ក្រោយមកបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់ជាង, នោះជារឿងក្រោយមក។ ប៉ុន្តែបួសខ្ពស់យ៉ាងនេះហើយមិនបើកគង់ទុកធ្វើអ្វី? លោកអ្នកនៅតែបួសឡើងលើយ៉ាងនេះ, បួសក៏បួសឡើងលើមិនបាន, ដូច្នេះគឺបើកគង់, ដោយសារបានបួសដល់កំពូលរួចហើយ, នឹងលេចឡើងមនុស្សបែបនេះជាច្រើន។ មិនខ្វល់លេចឡើងកាលៈទេសៈអ្វី, ជាក់លាក់ត្រូវតែកាន់ជាប់ចិត្តចរិត, មានតែយោងតាមមហាធម៌ដើម្បីធ្វើទើបជាត្រឹមត្រូវពិតប្រាកដ។ សីលគង់របស់លោកអ្នកក៏ដោយ, ការបើកគង់របស់លោកអ្នកក៏ដោយ, គឺបួសហាត់នៅក្នុងមហាធម៌លោកអ្នកទើបទទួលបាន។ បើសិនលោកអ្នកដាក់មហាធម៌នៅលើទីតាំងបន្ទាប់បន្សំ, ដាក់ទេពអំណាចរបស់លោកអ្នកនៅលើទីតាំងសំខាន់, ឬក៏មនុស្សត្រាស់ដឹងរួចហើយសន្មតថាយល់ដឹងនេះយល់ដឹងនោះរបស់លោកអ្នកខ្លួនឯងគឺត្រូវ, សូម្បីតែមើលលោកអ្នកខ្លួនឯងសន្មតថាដ៏អស្ចារ្យ, លើសផុតមហាធម៌, ខ្ញុំនិយាយថាលោកអ្នកគឺចាប់ផ្ដើមធ្លាក់ចុះរួចហើយ, គឺគ្រោះថ្នាក់រួចហើយ, គឺមួយថ្ងៃកាន់តែមិនបាន។ ពេលនោះលោកអ្នកអាចពិតជាជួបរឿងរំខាន, បួសដូចមិនបួស, ធ្វើមិនល្អគឺធ្លាក់ចុះក្រោម, បួសដូចមិនបួស។

ខ្ញុំនៅប្រាប់លោកអ្នកៈ ខ្លឹមសារសៀវភៅនេះរបស់ខ្ញុំគឺជាមេសម្ដែងធម៌ក្នុងប៉ុន្មានថ្នាក់រួមបញ្ចូលមក។ សុទ្ធតែជាខ្ញុំសម្ដែង, រាល់ប្រយោគសុទ្ធតែជាខ្ញុំសម្ដែង, សុទ្ធតែជាពីខ្សែអាត់យកចេញមកមួយអក្សរៗ, ចម្លងសរសេរចេញមកមួយអក្សរៗ, សុទ្ធតែជាសិស្ស, សិក្ខាកាមរបស់ខ្ញុំ

ជួយខ្ញុំចម្លងចេញមកពីក្នុងខ្សែអាត់, ក្រោយមកខ្ញុំក៏កែសម្រួលមួយលើកៗ។ សុទ្ធតែជាធម៌របស់ខ្ញុំ, ខ្ញុំសម្ដែងជាក់ស្ដែងគឺជាធម៌មួយនេះ។

# មេសម្តែងទី៧

## បញ្ហាសម្លាប់ជីវិត

បញ្ហាសម្លាប់ជីវិតនេះដ៏រសើប, សម្រាប់មនុស្សហាត់គង់ដើម្បីនិយាយ, តម្រូវរបស់យើងខ្ញុំក៏តឹងរឹងបង្គួរ, មនុស្សហាត់គង់មិនអាចសម្លាប់ជីវិត។ មិនខ្វល់គឺជាពុទ្ធវង្ស, តាវវង្ស, គង់ហ្វាទ្វារវិសេស, ក៏មិនខ្វល់គឺជាធម្មក្ខន្ធណានិកាយណា, ដរាបណាគឺជាបួសហាត់សុចរិតធម៌, សុទ្ធតែមើលវាដាច់ខាតណាស់, សុទ្ធតែមិនអាចសម្លាប់ជីវិត, ចំណុចមួយនេះគឺបញ្ជាក់។ ដោយសារបញ្ហាលេចឡើងក្រោយពីសម្លាប់ជីវិតធំខ្លាំងណាស់, យើងខ្ញុំត្រូវតែនិយាយហ្មត់ចត់ជាមួយអ្នករាល់គ្នា។ សម្លាប់ជីវិត, នៅក្នុងពុទ្ធសាសនាបុព្វកាលចម្បងគឺសំដៅលើសម្លាប់មនុស្ស, នេះគឺធ្ងន់ធ្ងរបំផុត។ ក្រោយមកនេះ, មើលជីវិតធំៗ, បសុសត្វធំៗឬក៏ជីវិតធំជាងបន្តិច, សុទ្ធតែមើលដ៏សំខាន់។ ពិភពបួសហាត់ហេតុអ្វីតែងមើលបញ្ហាសម្លាប់ជីវិតធ្ងន់ធ្ងរយ៉ាងនោះ? អតីតកាលក្នុងពុទ្ធសាសនានិយាយថា, មិនគួរស្លាប់តែត្រូវបានសម្លាប់ងាប់, នឹងក្លាយជាវិញ្ញាណឯកោព្រាយព្រៃ។ អតីតកាលសម្តែងឧទ្ទិស, នោះគឺសំដៅលើផ្នែកមនុស្សនេះ។ ប្រសិនមិនឧទ្ទិសឲ្យ, ជីវិតទាំងនេះនឹងមិនស៊ីមិនផឹក, ស្ថិតក្នុងនៅស្ថានភាពមួយដ៏វេទនា, នេះគឺសម្តែងក្នុងពុទ្ធសាសនាអតីតកាល។

យើងខ្ញុំសម្តែង, ពេលឯកជនមួយធ្វើរឿងរ៉ាវមិនល្អតម្រង់លើឯកជនមួយផ្សេង, គាត់គឺនឹងផ្តល់គុណធម៌យ៉ាងធំឲ្យគេធ្វើជាសំណង, នេះគឺយើងខ្ញុំសំដៅលើជាធម្មតាកាន់កាប់អ្វីរបស់អ្នកដទៃ។ល។ ប៉ុន្តែស្រាប់តែធ្វើបញ្ចប់ជីវិតមួយ, សត្វក៏ដោយ, ភាវៈរស់ដទៃក៏ដោយ, ដូច្នោះគឺនឹងបង្កទុកជាអំណាចកម្មមួយយ៉ាងធំ។ សម្លាប់ជីវិតអតីតកាលចម្បងសំដៅ

លើសម្លាប់មនុស្ស, សាងកម្មធំបង្គួរ។ ប៉ុន្តែសម្លាប់កាយជីវិតធម្មតាក៏ជាមិនស្រាលផងដែរ, ដោយផ្ទាល់សាងបង្កើតអំណាចកម្មដ៏ធំ។ ជាពិសេសគឺមនុស្សហាត់គង់, នៅក្នុងដំណើរការបួសហាត់, នៅលើជាន់ថ្នាក់ខុសគ្នាបានរៀបចំឲ្យលោកអ្នកគ្រោះមួយចំនួន, នោះសុទ្ធតែជាអំណាចកម្មរបស់លោកអ្នកខ្លួនឯង, ជាគ្រោះរបស់លោកអ្នកខ្លួនឯង, ដាក់នៅលើជាន់ថ្នាក់ខុសគ្នាឱ្យលោកអ្នកទុកឱ្យលោកអ្នកលើកកម្ពស់។ ដរាបណាលោកអ្នកលើកកម្ពស់ចិត្តចរិត, គឺអាចឆ្លងផុតបាន។ ប៉ុន្តែភ្លាមៗនោះថែមឡើងអំណាចកម្មធំយ៉ាងនេះ, លោកអ្នកធ្វើម្តេចឆ្លងផុតបាន? ពឹងផ្អែកលើចិត្តចរិតរបស់លោកអ្នក, លោកអ្នកជាមូលដ្ឋានគឺគ្មានវិធីឆ្លងផុតបាន, គឺអាចធ្វើឲ្យលោកអ្នកជាមូលដ្ឋានបួសហាត់មិនបានទៀត។

យើងខ្ញុំរកឃើញ, ពេលដែលឯកជនមួយចាប់បដិសន្ធិ, នៅខាងក្នុងវិសាលភាពជាក់លាក់ក្នុងអវកាសចក្រវាលនេះមានគាត់ដ៏ច្រើនចាប់បដិសន្ធិក្នុងពេលដំណាលគ្នា, និងគាត់មើលទៅដូចគ្នា, ហៅឈ្មោះតែមួយ, រឿងរ៉ាវដែលធ្វើគឺដូចគ្នាភាគច្រើនខុសគ្នាតិចតួច, ដូច្នេះក៏អាចហៅថាជាផ្នែកមួយនៃកាយទាំងមូលរបស់គាត់។ ខាងក្នុងនេះពាក់ព័ន្ធបញ្ហាមួយបែបនេះ, ប្រសិនមានកាយជីវិតមួយ (កាយជីវិតនៃសត្វធំដទៃក៏ជាដូចគ្នា), ស្រាប់តែងាប់ទៅ, ហើយគាត់នៃបណ្តាអវកាសដទៃសុទ្ធតែមិនទាន់ដើរបញ្ចប់ដំណើរការជីវិតដើមមកបានកំណត់, នៅមានដ៏ច្រើនឆ្នាំត្រូវការរស់។ ដូច្នោះឯកជនដែលស្លាប់ទៅនេះគឺធ្លាក់ចូលក្នុងស្ថានភាពមួយគ្មានទីជម្រក, រសាត់នៅក្នុងអវកាសចក្រវាល។ អតីតកាលសម្តែងវិញ្ញាណឯកោព្រាយព្រៃ, គ្មានស៊ីគ្មានផឹក, ដ៏វេទនា, អាចជាបែបនេះ។ ប៉ុន្តែយើងខ្ញុំដោយមែនទែនមើលឃើញគាត់ស្ថិតនៅក្នុងស្ថានភាពមួយដ៏គួរឲ្យខ្លាច, គាត់គឺនឹងរង់ចាំបន្តរហូត, រង់ចាំដល់គាត់នៃបណ្តាអវកាស

សុទ្ធតែដើរបញ្ចប់រួចហើយដំណើរការនៃជីវិត, ទើបអាចជាមួយគ្នារកទីជម្រករបស់គាត់។ ពេលវេលាកាន់តែយូរ, ទុក្ខគាត់ទទួលរងកាន់តែធំ។ ទុក្ខដែលគាត់រងកាន់តែធំ, អំណាចកម្មដោយទុក្ខឈឺចាប់របស់គាត់បង្កឡើងគឺបន្តផ្តល់ថែមលើរាងកាយអ្នកដែលសម្លាប់ជីវិត, លោកអ្នកគិតលោកអ្នកនឹងកើនអំណាចកម្មថែមប៉ុន្មាន? យើងខ្ញុំនេះគឺតាមរយៈសីលគង់មើលឃើញបាន។

យើងខ្ញុំនៅមើលឃើញកាលៈទេសៈមួយបែបនេះ៖ នៅពេលដែលឯកជនមួយចាប់បដិសន្ធិ, នៅក្នុងអវកាសពិសេសជាក់លាក់មួយសុទ្ធតែមានទម្រង់អត្ថិភាពនៃមួយជីវិតរបស់គាត់, ក៏មានន័យថា, ជីវិតរបស់គាត់ដល់វេលាណាមួយ, គួរធ្វើអ្វី, សុទ្ធតែមានខាងក្នុងនោះ។ នរណារៀបចំមួយជីវិតរបស់គាត់? ច្បាស់លាស់ណាស់, ជាក់ស្តែងគឺជាជីវិតកម្រិតខ្ពស់ជាងធ្វើរឿងរ៉ាវនេះ។ ឧបមាថា, ពួកយើងនៅក្នុងសង្គមមនុស្សសាមញ្ញ, ក្រោយពីគាត់កើតចេញ, ក្នុងផ្ទះនេះមានគាត់, សាលាមានគាត់, ឬក៏ធំឡើងក្នុងអង្គភាពមានគាត់, តាមរយៈការងាររបស់គាត់និងសង្គមនឹងទទួលបានទំនាក់ទំនងគ្រប់ទិដ្ឋភាព, ក៏មានន័យថា, ប្លង់របស់សង្គមទាំងមូលសុទ្ធតែជាចាត់ចែងបែបនេះ។ យ៉ាងណាក្តីដោយសារកាយជីវិតនេះស្រាប់តែងាប់ទៅ, មិនមែនយោងតាមការរៀបចំពិសេសជាក់លាក់ពីដំបូង, កើតឡើងផ្លាស់ប្រែ។ ដូច្នោះនរណាដែលធ្វើរញ៉េរញ៉ៃរឿងរ៉ាវនេះ, ជីវិតកម្រិតខ្ពស់នោះក៏មិនអត់ទោសដល់គាត់។ អ្នករាល់គ្នាគិតសាកមើល, ធ្វើជាមនុស្សបួសហាត់, ពួកយើងចង់បួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, ជីវិតក្នុងជាន់ថ្នាក់ខ្ពស់នោះក៏មិនអត់ទោសដល់គាត់, លោកអ្នកនិយាយគាត់នៅអាចបួសហាត់ទៀតឬ? គ្រូខ្លះក៏គ្មានជាន់ថ្នាក់ខ្ពស់ស្មើនឹងជីវិតកម្រិតខ្ពស់ដែលបានរៀបចំរឿងរ៉ាវនេះ, ដូច្នេះគ្រូរបស់

គាត់ក៏នឹងជួបគ្រោះកាចជាមួយ, ក៏ត្រូវបានវាយទម្លាក់ចុះ។ លោកអ្នកគិតសាកមើល, នេះជាបញ្ហាធម្មតាឬ? ដូច្នេះកាលណាធ្វើរឿងរ៉ាវនេះរួចហើយគឺដ៏ពិបាកបួសហាត់។

នៅក្នុងចំណោមសិក្ខាកាមបួសហាត់ហ្វាលូនតាហ្វា, អាចមានមនុស្សធ្លាប់ប្រយុទ្ធនៅឆ្នាំសម័យសង្គ្រាម។ សង្គ្រាមនោះគឺជាប្រភេទស្ថានភាពមួយដោយសារការផ្លាស់ប្រែធំនៃបាតុភូតតារាសាស្ត្រទាំងមូលនាំមក, លោកអ្នកហួសពេកគ្រាន់តែជាចំណែកមួយក្នុងស្ថានភាពនោះ។ បាតុភូតតារាសាស្ត្រផ្លាស់ប្រែប្រសិនជាខាងក្រោមគ្មានមនុស្សកម្រើក, ក៏មិនអាចនាំមកស្ថានភាពមួយឲ្យសង្គមមនុស្សសាមញ្ញ, ក៏ជាមិនហៅថាផ្លាស់ប្រែនៃបាតុភូតតារាសាស្ត្រ។ រឿងរ៉ាវទាំងនោះស្របតាមការផ្លាស់ប្រែធំហើយផ្លាស់ប្រែតាម, រឿងនោះមិនអាចចាត់ថាដោយសារលោកអ្នកទាំងស្រុង។ យើងខ្ញុំសម្តែងទីនេះគឺដោយសារផលប្រយោជន៍ឯកជន, ឬក៏ដើម្បីបំពេញផលប្រយោជន៍ឯកជន, ឬក៏ឥទ្ធិពលដល់របស់អ្វីរបស់ខ្លួនឯង, ខ្លួនឯងត្រូវតែធ្វើរឿងអាក្រក់ហើយនាំមកអំណាចកម្ម។ ជាទូទៅពាក់ព័ន្ធដល់ការផ្លាស់ប្រែធំនៃអវកាសទាំងមូល, ការផ្លាស់ប្រែនៃមហាទេសកាលរបស់សង្គម, នេះសុទ្ធតែមិនស្ថិតក្នុងបញ្ហារបស់លោកអ្នក។

សម្លាប់ជីវិតនឹងបង្កជាអំណាចកម្មដ៏ធំ។ មនុស្សខ្លះគឺគិតថា៖ មិនអាចសម្លាប់ជីវិត, ខ្ញុំគឺធ្វើបាយនៅក្នុងផ្ទះ, បើសិនខ្ញុំមិនសម្លាប់, អ្នកផ្ទះរបស់ពួកខ្ញុំញ៉ាំអ្វី? បញ្ហាពិស្តារនេះខ្ញុំមិនគ្រប់គ្រង, ខ្ញុំគឺសម្តែងធម៌ឲ្យមនុស្សហាត់គង់, មិនមែនតាមអំពើចិត្តសម្តែងឲ្យមនុស្សសាមញ្ញរស់នៅដូចម្តេច។ បញ្ហាពិស្តារទៅធ្វើដូចម្តេច, ដូច្នោះគឺប្រើមហាធម៌ដើម្បីវាស់វែង, លោកអ្នកយល់ថាធ្វើយ៉ាងណាបានល្អ, លោកអ្នកគឺធ្វើយ៉ាងនោះ។ មនុស្សសាមញ្ញចង់ធ្វើអីគាត់គឺធ្វើនោះ, នោះជារឿងរ៉ាវក្នុងមនុស្ស

សាមញ្ញ, នរណាៗក៏បួសពិតនោះគឺមិនអាច។ តែធ្វើជាមនុស្សហាត់គង់, គឺគួរតែ{ប្រើ}បរមាណីយខ្ពស់ដើម្បីតម្រូវ, ដូច្នេះទីនេះគឺជាលក្ខខណ្ឌលើកឡើងឲ្យមនុស្សហាត់គង់។

មិនគ្រាន់តែជាមនុស្ស, សត្វ, ទាំងរុក្ខជាតិក៏មានជីវិត, នៅក្នុងអវកាសដទៃសារធាតុណាមួយសុទ្ធតែបង្ហាញចេញមកជីវិត។ នៅពេលភ្នែកទិព្វរបស់លោកអ្នកបើកដល់ជាន់ថ្នាក់ធម៌ចក្ខុវិស័យ, លោកអ្នករកឃើញថាថ្ម, ជញ្ជាំង, របស់អ្វីៗសុទ្ធតែអាចនិយាយគ្នាជាមួយលោកអ្នក, ជំរាបសួរលោកអ្នក។ អាចមានមនុស្សគិតថា៖ នោះធញ្ញជាតិ, បន្លែដែលពួកយើងញុំាសុទ្ធតែមានជីវិត; នៅមានក្នុងផ្ទះមានរុយ, មូសធ្វើដូចម្ដេច? រដូវក្ដៅខាំដ៏ពិបាកទ្រាំ, សម្លឹងឃើញកំពុងខាំនៅទីនោះមិនកម្រើក, ឃើញសត្វរុយទំនៅលើអាហារយ៉ាងកខ្វក់, ក៏មិនអាចវាយ។ ខ្ញុំប្រាប់អ្នករាល់គ្នា, ពួកយើងគឺមិនអាចដោយគ្មានហេតុផលសម្លាប់ធ្វើបាបសត្វលោកតាមអំពើចិត្ត។ ប៉ុន្តែពួកយើងក៏មិនអាចធ្វើសុភាពបុរសប្រយ័ត្នប្រយែងតែរឿងតូចតាច, រមែងផ្ដោតទៅលើរឿងតូចទាំងនេះ, ដើរតាមផ្លូវក៏ខ្លាចជាន់ងាប់ស្រមោច, ដើរផងលោតផង។ ខ្ញុំនិយាយលោកអ្នករស់ហត់នឿយណាស់, នោះក៏មិនមែនប្រកាន់ឬ? លោកអ្នកដើរផងលោតផង, មិនជាន់ងាប់ស្រមោច, ប៉ុន្តែមានអតិសុខុមប្រាណជាច្រើន, លោកអ្នកក៏ជាន់ងាប់រួចហើយ។ នៅក្រោមអតិសុខុមនៅមានកាយជីវិតតូចជាងជាច្រើន, នៅមានផ្សិតនិងបាក់តេរី, លោកអ្នកប្រហែលជាក៏សុទ្ធតែជាន់ងាប់មិនតិច, ដូច្នោះពួកយើងក៏កុំរស់ទៀត។ ពួកយើងមិនមែនចង់ធ្វើមនុស្សបែបនេះ, នេះគ្មានវិធីណាបួសហាត់។ ត្រូវការផ្ដោតទៅលើកន្លែងធំ, ត្រូវការបួសហាត់ដោយថ្លៃថ្នូរនិងស្មោះត្រង់។

មនុស្សពួកយើងរស់គឺមានសិទ្ធិរក្សាការរស់នៅរបស់មនុស្ស, ដូច្នេះ

បរិយាកាសរស់នៅក៏ត្រូវតែសមស្របនឹងតម្រូវរស់នៅរបស់មនុស្ស។ ពួកយើងមិនអាចចេតនាធ្វើបាបសត្វលោក, ប៉ុន្តែពួកយើងក៏មិនអាចគួរសមហួសពេកដល់រឿងរ៉ាវតូចទាំងនេះ។ ឧបមាបន្លែនិងធញ្ញជាតិបានដាំសុទ្ធតែជាមានជីវិត, ពួកយើងក៏មិនអាចដោយសារវាមានជីវិតគឺកុំញ៉ាំកុំផឹក, នោះនៅហាត់គង់អីទៀត? គួរតែសង្កេតធំទូលាយ។ ឧបមាលោកអ្នកក្នុងដំណើរការកំពុងដើរតាមផ្លូវ, ស្រមោច, សត្វល្អិតគឺរត់ចូលក្រោមជើងរបស់លោកអ្នក, ត្រូវបានជាន់ងាប់, នោះវាអាចជាក់ស្តែងគឺគួរងាប់, ដោយសារលោកអ្នកមិនមែនចេតនាទៅធ្វើបាបវា។ ក្នុងពិភពជីវសាស្ត្រ ឬក៏ក្នុងអតិសុខុមប្រាណដទៃក៏សម្តែងបញ្ហាតុល្យភាពបរិស្ថានជីវសាស្ត្រធម្មជាតិ, ច្រើនពេកក៏នឹងហួសពេក, ដូច្នេះយើងខ្ញុំសម្តែងទៅបួសហាត់ដោយថ្លៃថ្នូរនិងស្មោះត្រង់។ ក្នុងផ្ទះមានរុយ, មូស, ពួកយើងដេញវាចេញ, ដាក់រាំងននមិនទុកឲ្យវាចូលមក។ តែមានពេលខ្លះដេញមិនចេញ, ដូច្នោះវាយងាប់គឺជាវាយងាប់។ អវកាសដែលមនុស្សស្នាក់នៅ, ប្រសិនវាខាំមនុស្សប្រសិនធ្វើបាបមនុស្សប្រាកដណាស់ត្រូវការបណ្តេញវាចេញ, បណ្តេញមិនចេញ, មិនអាចមើលវានៅទីនោះខាំមនុស្ស។ លោកអ្នកជាមនុស្សហាត់គង់មិនខ្លាច, មានកម្លាំងទប់ទល់, អ្នកផ្ទះលោកអ្នកមិនហាត់គង់, ជាមនុស្សសាមញ្ញ, នៅមានបញ្ហាចម្លងជំងឺ, ក៏មិនអាចមើលឃើញខាំនៅលើមុខកូនក្មេងហើយមិនគ្រប់គ្រង។

លើកឧទាហរណ៍ឱ្យអ្នករាល់គ្នា, សក្យមុនីបណ្តាឆ្នាំដំបូងមានរឿងព្រេងមួយយ៉ាងនេះ។ មានថ្ងៃមួយ, សក្យមុនីចង់ស្រង់ទឹក, នៅក្នុងព្រៃក្រាស់ហៅកូនសិស្សរបស់គាត់សម្អាតអាងងូតទឹកឲ្យគាត់។ សិស្សរបស់គាត់ដល់ទីនោះមើល, ខាងក្នុងអាងងូតទឹកសត្វល្អិតវារពាសពេញ, បើសិនសម្អាតអាងងូតទឹកគឺត្រូវធ្វើសត្វល្អិតងាប់។ កូនសិស្សត្រឡប់មក

ប្រាប់សក្យមុនីនិយាយ៖ ក្នុងអាងងូតទឹកសត្វល្អិតវារពាសពេញ។ សក្យមុនីមិនសម្លឹងគាត់, ក៏និយាយមួយប្រយោគ៖ ចូរកូនទៅសម្អាតជ្រះអាងងូតទឹក។ សិស្សរូបនេះដល់កន្លែងអាងងូតទឹកឃើញថាគ្មានវិធីចុះដៃបាន, កម្រើកដៃកាលណាសត្វល្អិតគឺត្រូវងាប់, គាត់ដើរមួយជុំត្រឡប់មកសួរសក្យមុនីម្ដងទៀត៖ លោកគ្រូ, ក្នុងអាងងូតទឹកសត្វល្អិតវារពាសពេញ, បើកម្រើកដៃកាលណាគឺនឹងធ្វើសត្វល្អិតងាប់។ សក្យមុនីសម្លឹងៗគាត់និយាយ៖ យើងហៅកូនសម្អាតគឺជាអាងងូតទឹក។ កូនសិស្សស្រាប់តែភ្ញាក់ដឹង, ជាបន្ទាន់សម្អាតជ្រះអាងងូតទឹក។ ខាងក្នុងនេះនិយាយច្បាស់បញ្ហាមួយ, មិនអាចព្រោះតែមានសត្វល្អិត, ពួកយើងងូតទឹកក៏មិនដុសជំរះ; ក៏មិនអាចព្រោះតែមានមូស, ពួកយើងសុទ្ធតែត្រូវចេញខាងក្រៅរកកន្លែងដើម្បីស្នាក់នៅ; ក៏មិនអាចព្រោះតែធញ្ញជាតិក៏មានជីវិត, បន្លែក៏មានជីវិត, ពួកយើងរឹតករិញ, មិនញ៉ាំក៏មិនផឹកទៀត។ មិនមែនជាបែបនេះ, ពួកយើងគួរតែរៀបដាក់ឲ្យត្រឹមត្រូវទំនាក់ទំនងនេះ, បួសហាត់ដោយថ្លៃថ្នូរនិងស្មោះត្រង់, ពួកយើងមិនចេតនាទៅធ្វើបាបសត្វលោកគឺបានហើយ។ ដូចគ្នាមនុស្សត្រូវការមានអវកាសរស់នៅនិងលក្ខខណ្ឌរស់រានមានជីវិតរបស់មនុស្ស, ក៏ជាត្រូវការរក្សា, មនុស្សក៏ត្រូវការរក្សាជីវិតនិងការរស់នៅធម្មតា។

អតីតកាលមានគ្រូឈីគង់ក្លែងក្លាយមួយចំនួនសម្ដែងថា៖ ១កើត, ១៥អាចសម្លាប់ជីវិត។ មានខ្លះនៅសម្ដែងថា៖ អាចសម្លាប់{សត្វ}ជើងពីរ, ហាក់ដូចជា{សត្វ}ជើងពីរនេះគឺមិនមែនសត្វលោក។ តើ១កើត, ១៥សម្លាប់ជីវិតគឺមិនចាត់ថាសម្លាប់ជីវិត, នោះគឺចាត់ថាជីកដី, តើមែនទេ? មានមួយចំនួនគឺជាគ្រូឈីគង់ក្លែងក្លាយ, ពីសម្ដីនិងទង្វើរបស់គាត់អាចសម្គាល់ចេញបាន, គាត់សម្ដែងជាអ្វី, គាត់ស្វែងរកជាអ្វី, និយាយរួម

គ្រូឈើគង់ដែលមានវាចាប្រភេទនេះជាញឹកញាប់សុទ្ធតែជាកាយភ្ញាប់។ លោកអ្នកមើលគ្រូឈើគង់មានកាយភ្ញាប់កញ្ជ្រោងនោះស៊ីសាច់មាន់បែបណា, សុទ្ធសាធស៊ីលេបដូចខ្លាចចក, ឆ្អឹងក៏មិនចង់ក្អែចេញផង។

សម្លាប់ជីវិតមិនគ្រាន់តែជានឹងសាងបង្កើតអំណាចកម្មធ្ងន់ធំ, ថែមទាំងពាក់ព័ន្ធដល់បញ្ហាចិត្តមេត្តា។ មនុស្សបួសហាត់ពួកយើងមិនត្រូវតែមានចិត្តមេត្តាឬ? នៅពេលចិត្តមេត្តារបស់ពួកយើងផុសចេញមក, អាចឃើញថាសត្វលោកទាំងឡាយសុទ្ធតែទុក្ខ, ឃើញនរណាក៏ទុក្ខ, នឹងលេចឡើងបញ្ហានេះ។

## បញ្ហាញ៉ាំសាច់

ញ៉ាំសាច់ក៏ជាបញ្ហាមួយដ៏រសើប, ប៉ុន្តែញ៉ាំសាច់មិនមែនជាសម្លាប់ជីវិត។ លោកអ្នករៀនធម៌វេលាយូរយ៉ាងនេះហើយ, យើងខ្ញុំមិនដែលតម្រូវលោកអ្នកកុំញ៉ាំសាច់។ មានគ្រូឈើគង់ដ៏ច្រើននៅពេលលោកអ្នកចូលក្នុងថ្នាក់, គឺប្រាប់លោកអ្នកថា៖ ចាប់ផ្ដើមពីពេលនេះមិនអាចញ៉ាំសាច់បានទៀត។ លោកអ្នកអាចគិតថា៖ ស្រាប់តែមិនអាចញ៉ាំសាច់ទៀត, នៅមិនទាន់បម្រុងមនោគតិផង។ ថ្ងៃនេះក្នុងផ្ទះអាចនឹងជាមាន់ចំហុយ, ត្រីដុត, បង្អើរក្លិនយ៉ាងឈ្ងុយក៏មិនអាចញ៉ាំ។ បួសហាត់ក្នុងសាសនាក៏ជាបែបនេះ, បង្ខំមិនឱ្យញ៉ាំ។ គង់ពុទ្ធវង្សធម្មតា, មានគង់តាវវង្សមួយចំនួនក៏ជាសម្ដែងបែបនេះ, មិនអាចញ៉ាំ។ យើងខ្ញុំទីនេះមិនដែលហៅលោកអ្នកធ្វើបែបនេះ, ទោះយ៉ាងណាយើងខ្ញុំក៏សម្ដែងអំពីប្រការនេះ។ ដូច្នោះយើងខ្ញុំគឺសម្ដែងដូចម្ដេច? ដោយសារគង់ហ្វានេះរបស់យើងខ្ញុំគឺជាគង់ហ្វាគង់ហាត់មនុស្ស។ គង់ហ្វាគង់ហាត់មនុស្ស, នោះគឺស្ថានភាពមួយចំនួនសុទ្ធតែនឹងពីក្នុងគង់, ពីក្នុងធម៌បង្ហាញចេញមក។ ក្នុងដំណើរការហាត់គង់, ជាន់ថ្នាក់ខុសគ្នានឹងលេចឡើងស្ថានភាពខុសគ្នា។

ដូច្នោះមានថ្ងៃមួយឬក៏ថ្ងៃនេះខ្ញុំសម្តែងមេសម្តែងចប់មានមនុស្សនឹងចូលក្នុងស្ថានភាពនេះ៖ មិនអាចញ៉ាំសាច់, ហិតទៅឆ្អាបណាស់, ញ៉ាំចូលគឺចង់ក្អួត។ មិនមែនមនុស្សចេតនាគ្របសង្កត់លោកអ្នកមិនឱ្យលោកអ្នកញ៉ាំឬក៏លោកអ្នកគ្របសង្កត់ខ្លួនឯងមិនញ៉ាំ, តែគឺផុសចេញពីក្នុងចិត្តខ្លួនឯង, ដល់ជាន់ថ្នាក់នេះ, ពីក្នុងគង់ឆ្លុះបញ្ចាំងចេញមកគឺមិនអាចញ៉ាំ, សូម្បីបើសិនលោកអ្នកពិតជាលេបចូលក្នុង, គឺពិតជាក្អួតចេញមកវិញ។

សិក្ខាកាមយូរឆ្នាំពួកយើងសុទ្ធតែដឹងថា, បួសហាត់ហ្វាលូនតាហ្វានឹងលេចឡើងស្ថានភាពនេះ, នៅក្នុងជាន់ថ្នាក់ខុសគ្នានឹងឆ្លុះបញ្ចាំងចេញមកស្ថានភាពខុសគ្នា។ ក៏មានសិក្ខាកាមតណ្ហាធំបង្គួរ, ចិត្តញ៉ាំសាច់ខ្លាំងណាស់, ពេលធម្មតាអាចញ៉ាំសាច់ដ៏ច្រើន។ ពេលគេសុទ្ធតែមានអារម្មណ៍ដ៏ឆ្អាបចំពោះសាច់, គាត់មានអារម្មណ៍ថាមិនឆ្អាប, នៅតែអាចញ៉ាំបាន។ ដើម្បីទុកឲ្យគាត់កម្ចាត់ចោលចិត្តនេះ, ធ្វើដូចម្តេចហ្ន៎? គាត់ញ៉ាំសាច់រួចហើយគឺនឹងឈឺពោះ, មិនញ៉ាំគឺមិនឈឺ, នឹងលេចឡើងស្ថានភាពនេះ, មានន័យថាគឺមិនអាចញ៉ាំទៀត។ ធម្មក្ខន្ធមួយនេះរបស់ពួកយើងពីពេលនេះតទៅគ្មានវាសនាជាមួយសាច់ទៀតមែនទេ, មិនមែនបែបនេះ។ តើប្រព្រឹត្តដូចម្តេចចំពោះបញ្ហានេះ? មិនអាចញ៉ាំគឺពិតប្រាកដផុសពីក្នុងចិត្តខ្លួនឯងថាមិនអាចញ៉ាំ។ គោលបំណងជាអ្វី? បួសហាត់ក្នុងវត្តបង្ខំលោកអ្នកមិនញ៉ាំនិងការឆ្លុះបញ្ចាំងចេញមិនអាចញ៉ាំនេះរបស់ពួកយើង, សុទ្ធតែជាចង់កម្ចាត់ចោលតណ្ហានិងចិត្តប្រកាន់នេះរបស់មនុស្សចំពោះសាច់។

មនុស្សខ្លះកាន់ចានបាយឡើងបើគ្មានសាច់ទេនោះ, សុទ្ធសាធលេបបាយមិនចូល, នោះជាក់ស្តែងគឺជាតណ្ហារបស់មនុស្សសាមញ្ញ។ ព្រឹកថ្ងៃមួយខ្ញុំបានដើរកាត់ផ្លូវពីទ្វារក្រោយឧទ្យានស៊ឹងលីនៅឆាងឈុន។

មានមនុស្ស៣នាក់យ៉ាងអ៊ូអរស្រែកខ្លាំងៗពីទ្វារក្រោយចេញមក, ម្នាក់ក្នុងនោះនិយាយថា៖ ហាត់គង់អីគេហើយមិនអាចញ៉ាំសាច់, ស៊ូរស់តិចជាង១០ឆ្នាំខ្ញុំក៏ត្រូវតែញ៉ាំសាច់ដែរ! ប្រភេទតណ្ហាមួយខ្លាំងក្លាយ៉ាងនោះ។ អ្នករាល់គ្នាគិតសាកមើល, តើតណ្ហានេះគួរកម្ចាត់ចោលឬអត់? បញ្ជាក់ថាគឺគួរតែកម្ចាត់។ មនុស្សនៅក្នុងដំណើរការប្ដូសហាត់ជាក់ស្ដែងគឺកម្ចាត់តណ្ហាគ្រប់ប្រភេទ, ចិត្តប្រកាន់របស់មនុស្ស។ និយាយដោយត្រង់, ចិត្តញ៉ាំសាច់មិនកម្ចាត់ទេ, នោះមិនមែនចិត្តប្រកាន់មិនទាន់កម្ចាត់ឬ? អាចប្ដូសសម្រេចបរិបូរបានឬ? ដូច្នេះឲ្យតែជាចិត្តប្រកាន់, ដូច្នោះគឺត្រូវតែកម្ចាត់។ ទោះយ៉ាងណាក៏មិនមែនពីពេលនេះតទៅជានិច្ចមិនញ៉ាំបានទៀត, មិនឱ្យញ៉ាំសាច់ខ្លួនវាមិនមែនគោលបំណង, គោលបំណងគឺមិនឲ្យលោកអ្នកមានប្រភេទចិត្តប្រកាន់នេះ។ បើសិននៅក្នុងដំណាក់កាលពេលវេលានេះមិនអាចញ៉ាំសាច់, លោកអ្នកកម្ចាត់ចោលចិត្តប្រកាន់នេះបាន, ក្រោយមកប្រហែលជាក៏អាចញ៉ាំសាច់បាន, ក្លិនធំមិនឆ្អាបទៀត, ញ៉ាំចូលក៏មិនពិបាកញ៉ាំយ៉ាងនោះទៀត, ពេលនេះលោកអ្នកគឺញ៉ាំ, គ្មានបញ្ហា។

ដល់ពេលដែលលោកអ្នកអាចញ៉ាំបាន, ចិត្តប្រកាន់របស់លោកអ្នកបានបាត់ទៅរួចហើយ, ចិត្តតណ្ហាចំពោះសាច់បានបាត់ទៅរួចហើយ។ ប៉ុន្តែនឹងកើតឡើងការផ្លាស់ប្រែធំមួយ, ក្រោយមកញ៉ាំសាច់ឡើងវិញមិនឈ្ងុយទៀត, ក្នុងផ្ទះធ្វើគឺញ៉ាំជាមួយ, ក្នុងផ្ទះមិនធ្វើក៏មិនគិតដល់, ញ៉ាំចូលគ្មានរសជាតិឈ្ងុយទៀត, នឹងលេចឡើងស្ថានភាពនេះ។ ទោះយ៉ាងណាប្ដូសហាត់នៅក្នុងមនុស្សសាមញ្ញគឺដ៏ស្មុគស្មាញ, ក្នុងផ្ទះរមែងធ្វើសាច់, ពេលវេលាយូររួចហើយ, លោកអ្នកម្ដងទៀតមានអារម្មណ៍ថាញ៉ាំចូលឈ្ងុយ, ក្រោយមកនឹងលេចឡើងច្រំដែល, ក្នុងដំណើរការប្ដូសហាត់

ទាំងមូលនឹងលេចឡើងច្រំដែលច្រើនដង។ ស្រាប់តែម្តងទៀតលោកអ្នកមិនអាចញ៉ាំ, មិនអាចញ៉ាំគឺមិនញ៉ាំ, ពិតជាញ៉ាំមិនបាន, ញ៉ាំចូលគឺចង់ក្អួត; ចូររង់ចាំពេលដែលលោកអ្នកអាចញ៉ាំបានគឺញ៉ាំ, បណ្តោយតាមធម្មជាតិ។ ញ៉ាំសាច់ឬក៏មិនញ៉ាំសាច់ខ្លួនវាមិនមែនគោលបំណង, កម្ចាត់ចោលចិត្តប្រកាន់នោះទើបជាចំណុចគន្លឹះ។

ធម្មក្ខន្ធហ្វាលូនតាហ្វាមួយនេះរបស់ពួកយើងដើរបានលឿនបង្គួរ, ដរាបណាលោកអ្នកលើកកម្ពស់ចិត្តចរិត, រាល់ជាន់ថ្នាក់សុទ្ធតែទម្លុះដ៏លឿន។ មនុស្សខ្លះដើមមកគឺមិនប្រកាន់ពេកចំពោះសាច់, មានឬគ្មានក៏មិនជាបញ្ហា។ មនុស្សប្រភេទនេះរក្សាបន្តមួយឬពីរសប្តាហ៍គឺឆ្លងផុតបាន, គឺយកចិត្តនេះបោះចោល។ មនុស្សខ្លះត្រូវតែរក្សាបន្តដល់មួយខែ, ពីរខែ, បីខែ, អាចដល់កន្លះឆ្នាំ, គ្មានកាលៈទេសៈយ៉ាងពិសេសនឹងមិនហួសពីមួយឆ្នាំក៏អាចញ៉ាំឡើងវិញបាន។ ដោយសារសាច់បានក្លាយជាផ្នែកចម្បងមួយក្នុងអាហាររបស់មនុស្សរួចហើយ។ ទោះយ៉ាងណាបួសជំនាញនៅក្នុងវត្តអារាមមិនអាចញ៉ាំសាច់។

យើងខ្ញុំសម្តែងបន្តិចយល់ដឹងចំពោះញ៉ាំសាច់ក្នុងពុទ្ធសាសនា។ ពុទ្ធសាសនាបុព្វកាលដំបូងបំផុតគឺមិនហាមសាច់។ នាពេលនោះពេលដែលសក្យមុនីដឹកនាំកូនសិស្សបួសទុក្ខនៅក្នុងព្រៃក្រាស, ជាមូលដ្ឋានគ្មានសិក្ខាបទហាមសាច់នេះ។ ហេតុអ្វីគ្មាន? ដោយសារនាពេលនោះពេលសក្យមុនីបង្រៀនធម៌នៅជាង២៥០០ឆ្នាំមុន, សង្គមមនុស្សជាតិឱនថយណាស់, មានតំបន់ជាច្រើនមានកសិកម្ម, មានតំបន់ជាច្រើនមិនទាន់មានកសិកម្ម, ផ្ទៃដីដាំដុះតូចណាស់, ដល់ទីណាក៏ជាព្រៃក្រាស។ ធញ្ញជាតិសែនខ្វះខាត, ក៏កម្រខ្លាំងណាស់។ មនុស្សទើបតែអភិវឌ្ឍចេញមកពីសង្គមបុព្វកាល, ចម្បងរស់ដោយសារបរបាញ់, មានតំបន់ជាច្រើន

យកញ៉ាំសាច់ជាចម្បង។ សក្យមុនីដើម្បីអតិបរមាបោះចោលចិត្តប្រកាន់របស់មនុស្ស, មិនឲ្យទាក់ទងដល់របស់ណាមួយដូចជាទ្រព្យ, សម្ភារៈជាដើម, ដឹកនាំកូនសិស្សសុំបាយ, ទ្រង់បាត្រ។ គេឲ្យអីឆាន់នោះ, ធ្វើជាមនុស្សបួសហាត់ម្នាក់ក៏មិនអាចរើសអើងម្ហូប, ក្នុងម្ហូបបានឲ្យអាចជាមានសាច់។

ផ្ទុយមកវិញនៅក្នុងពុទ្ធសាសនាបុព្វកាលមានការថ្លែងហាមហ៊ុន។ ហាមហ៊ុនជាក់ស្តែងគឺពីក្នុងពុទ្ធសាសនាបុព្វកាលមក, ប៉ុន្តែបច្ចុប្បន្នយកញ៉ាំសាច់និយាយក្លាយថាជាហ៊ុន។ ភាពពិតហ៊ុននាពេលនោះមិនមែនសំដៅលើសាច់, គឺសំដៅលើរបស់ដូចជាខ្ទឹមបារាំង, ខ្ទី, ខ្ទឹមស។ ហេតុអ្វីចាត់ទុកវាជាហ៊ុន? បច្ចុប្បន្នមានព្រះសង្ឃជាច្រើនក៏និយាយមិនច្បាស់លាស់, ដោយសារមនុស្សជាច្រើនពួកគាត់មិនសម្តែងបួសជាក់ស្តែង, ប្រការជាច្រើនក៏មិនដឹង។ ប្រការដែលសក្យមុនីបានបង្រៀនហៅថា [សីល, សមាធិ, បញ្ញា]។ សីលគឺហាមចោលតណ្ហាទាំងអស់ក្នុងមនុស្សសាមញ្ញ; សមាធិគឺសំដៅលើមនុស្សបួសហាត់ទាំងស្រុងនៅក្នុងតាំងសមាធិ, ក្នុងអង្គុយសមាធិបួសហាត់, ត្រូវការចូលក្នុងរម្ងាប់ទាំងស្រុង។ ប្រការទាំងអស់ជ្រៀតជ្រែកមិនអាចចូលក្នុងរម្ងាប់, មិនអាចបួសហាត់, សុទ្ធតែចាត់ទុកជាជ្រៀតជ្រែកធ្ងន់ធ្ងរ, បើសិននរណាញ៉ាំខ្ទឹមបារាំង, ខ្ទី, ខ្ទឹមស, ក្លិនធំខ្លាំងណាស់។ ពេលនោះព្រះសង្ឃគឺនៅក្នុងព្រៃក្រាស, ក្នុងរូងភ្នំ, ៧, ៨អង្គព័ទ្ធជាមួយរង្វង់, អង្គុយសមាធិព័ទ្ធមួយរង្វង់ៗ។ បើសិននរណាបានញ៉ាំរបស់ទាំងនេះ, នឹងសាងបង្កើតក្លិនដ៏រំញោចខ្លាំងក្លា, ឥទ្ធិពលអង្គុយសមាធិ, ឥទ្ធិពលមនុស្សចូលក្នុងរម្ងាប់, ជ្រៀតជ្រែកធ្ងន់ធ្ងរមនុស្សហាត់គង់។ ហេតុនេះគឺមានសិក្ខាបទមួយយ៉ាងនេះ, ចាត់ទុកវាជាហ៊ុន, មិនអនុញ្ញាតឲ្យញ៉ាំរបស់ទាំងនេះ។ កាយជីវិត

ជាច្រើនដែលរាងកាយមនុស្សបួសហាត់ចេញសុទ្ធតែដ៏រំខានក្លិនខ្លាំងធ្ងន់នេះ។ ខ្ទឹមបារាំង, ខ្ទឹ, ខ្ទឹមសក៏អាចរំញោចមនុស្សសាងបង្កើតតណ្ហា, ញុំាច្រើនហើយក៏ញៀន, ដូច្នេះចាត់ទុកវាជាហ៊ុន។

អតីតកាលមានព្រះសង្ឃជាច្រើនក្រោយពីបួសហាត់ដល់ជាន់ថ្នាក់ដ៏ខ្ពស់, ស្ថិតក្នុងស្ថានភាពបើកគង់ឬក៏បើកគង់ពាក់កណ្ដាល, ក៏ដឹងថាសិក្ខាបទទាំងនោះក្នុងដំណើរការបួសហាត់គឺមិនជាបញ្ហា។ បើសិនអាចដាក់ចិត្តនោះចុះរួចហើយ, សារធាតុនោះខ្លួនវាក៏មិនផ្តើមផលប៉ះពាល់, ហើយពិតប្រាកដជ្រៀតជ្រែកមនុស្សជាក់ស្ដែងគឺជាចិត្តនោះ។ ដូច្នេះអធិសង្ឃសម័យប្រវត្តិសាស្ត្រក៏មើលឃើញមនុស្សនៅលើបញ្ហាញុំាសាច់នេះមិនមែនជាបញ្ហាគន្លឹះអ្វី, បញ្ហាគន្លឹះគឺចិត្តនោះអាចដាក់ចុះឬអត់, គ្មានចិត្តប្រកាន់គឺញុំាអ្វីឲ្យពេញក្រពះក៏បាន។ ដោយសារក្នុងវត្តជាក់ស្ដែងគឺធ្លាប់បួសហាត់បែបនេះ, មនុស្សជាច្រើនបានទម្លាប់តាមបែបនេះរួចហើយ។ ថែមទៀតបានលែងសាមញ្ញជាបញ្ហាសិក្ខាបទ, តែបានក្លាយជារបបវិន័យក្នុងវត្តអារាម, ជាមូលដ្ឋានគឺមិនអាចញុំា, ក៏ជាទម្លាប់បួសតាមបែបនេះរួចហើយ។ ពួកយើងសម្ដែងអំពីព្រះសង្ឃជីគង់, នៅក្នុងស្នាដៃសិល្បៈយកគាត់បន្លិចចេញមក, ព្រះសង្ឃគួរតែហាមសាច់, គាត់ឆាន់សាច់, ធ្វើឲ្យគាត់លេចធ្លោណាស់។ ភាពពិត, ជីគង់ត្រូវបានបណ្ដេញចេញពីវត្តលិញឃីន, ប្រាកដណាស់ម្ហូបបានក្លាយជាបញ្ហាមួយដ៏ចម្បងរបស់គាត់, ជីវភាពក៏ស្ថិតក្នុងវិបត្តិ។ ដើម្បីឲ្យពេញក្រពះ, គាត់រកបានអីឆាន់នោះ, ឲ្យតែពេញក្រពះ, ហើយគ្មានប្រកាន់ចំពោះប្រភេទម្ហូបណាមួយ, គឺមិនជាបញ្ហា។ បួសហាត់ដល់ទីនោះរួចហើយ, គាត់យល់ច្បាស់គោលសីលធម៌នេះ, ភាពពិតជីគង់ក៏ហួសពេកគ្រាន់តែចៃដន្យធ្លាប់បានឆាន់សាច់មួយឬពីរដងយ៉ាងនោះ។ កាលណានិយាយព្រះសង្ឃឆាន់

សាច់, អ្នកនិពន្ធគឺចាប់អារម្មណ៍ណាស់, ប្រធានបទកាន់តែភ្ញាក់ផ្អើលមនុស្ស, ធ្វើឱ្យគេកាន់តែចូលចិត្តមើល, ស្នាដៃសិល្បៈប្រភពមកពីជីវិតនិងបំប៉ោងជីវិតឡើង, គឺយកវាផ្សព្វផ្សាយចេញមក។ ភាពពិតពិតប្រាកដកម្ចាត់ចោលចិត្តប្រកាន់នោះ, ដើម្បីឲ្យពេញក្រពះញ៉ាំអ្វីក៏មិនជាបញ្ហា។

នៅអាស៊ីអាគ្នេយ៍ឬក៏ភាគខាងត្បូងប្រទេសយើង, ក្វាងទុងនិងក្វាងស៊ី, មានឧបាសកខ្លះពេលនិយាយស្តី, គាត់មិននិយាយថាគឺជាបួសពុទ្ធ, ហាក់ដូចជានាមសព្ទបួសពុទ្ធនេះហួសសម័យពេក, គាត់និយាយថាគាត់គឺញ៉ាំម្ហូបបួស, ញ៉ាំបួស, បង្កប់ន័យគឺញ៉ាំម្ហូបបួសបួសពុទ្ធ។ គាត់មើលបួសពុទ្ធក្លាយជាប្រការសាមញ្ញយ៉ាងនេះ។ តើញ៉ាំបួសគឺអាចបួសពុទ្ធ? អ្នករាល់គ្នាដឹងថា, វាគ្រាន់តែជាប្រភេទប្រកាន់មួយ, តណ្ហារបស់មនុស្ស, គ្រាន់តែចិត្តមួយយ៉ាងនេះ, គ្រាន់តែកម្ចាត់ចោលចិត្តមួយនេះប៉ុណ្ណោះ។ នៅតែត្រូវយកចិត្តច្រណែន, ចិត្តប្រជែងប្រយុទ្ធ, ចិត្តត្រេកអរ, ចិត្តបង្អាញ, ចិត្តគ្រប់ប្រភេទ, ចិត្តរបស់មនុស្សដ៏ច្រើន, ចិត្តទាំងអស់, តណ្ហាគ្រប់ប្រភេទ, សុទ្ធតែត្រូវកម្ចាត់ចោល, ទើបអាចសម្រេចបានបួសហាត់សម្រេចបរិបូរ។ ហើយគ្រាន់តែចោលចិត្តញ៉ាំសាច់នេះ, តើគឺអាចបួសពុទ្ធ? ការថ្លែងនោះមិនត្រូវ។

មនុស្សនៅលើបញ្ហាញ៉ាំក៏មិនគ្រាន់តែជាញ៉ាំសាច់, ប្រកាន់ចំពោះម្ហូបអ្វីក៏មិនបាន, របស់ផ្សេងក៏ជាដូចគ្នា។ មានមនុស្សនិយាយខ្ញុំគឺចូលចិត្តញ៉ាំមុខនេះ, នេះក៏ជាតណ្ហា, មនុស្សបួសហាត់ក្រោយពីដល់កម្រិតជាក់លាក់រួចហើយ, មិនមានចិត្តនេះទៀត។ ប្រាកដណាស់ធម៌របស់ពួកយើងសម្តែងដ៏ខ្ពស់, គឺតាមរយៈជាន់ថ្នាក់ខុសគ្នារួមបញ្ចូលមកដើម្បីសម្តែង, ភ្លាមៗសម្រេចបានចំណុចមួយនេះគឺមិនអាច។ ឧបមាថាលោកអ្នកគឺចង់ញ៉ាំមុខ{ម្ហូប}នោះ, ពេលដែលបួសហាត់ពិតប្រាកដដល់ពេល

គួរចោលចិត្តនោះ, លោកអ្នកគឺមិនអាចញុំាទៀត, ញុំាចូលគឺមិនត្រូវរសជាតិទៀត, មិនដឹងរសជាតិយ៉ាងណា។ ពេលដែលខ្ញុំទៅធ្វើការនៅអង្គភាព, អាហារដ្ឋានរបស់អង្គភាពរមែងបង់ខាត, ក្រោយមកគឺបិទទ្វារ។ បិទទ្វារហើយទាំងអស់គ្នាយកបាយតាម។ ពេលព្រឹកធ្វើម្ហូបខ្លះ, រវល់ប្រញាប់ទៅធ្វើការយ៉ាងប្រឹងប្រែង។ មានពេលខ្លះទិញនំប៉ាវពីរដុំ, ទិញតៅហ៊ូមួយដុំជ្រលក់ទឹកសៀង។ តាមទ្រឹស្ដីដើម្បីនិយាយម្ហូបអត្តខាត់យ៉ាងនោះក៏អាចបានផងដែរ, បន្តញុំាដូចនោះក៏មិនបាន, ក៏ត្រូវតែបោះចោលចិត្តនេះ។ លោកអ្នកទើបសម្លឹងឃើញតៅហ៊ូ, គឺធ្វើឲ្យលោកអ្នកចង់ក្អួត, ញុំាទៀតក៏ញុំាមិនបាន, ក៏ខ្លាចលោកអ្នកសាងបង្កើតចិត្តប្រកាន់។ ប្រាកដណាស់នេះត្រូវតែក្រោយពីលោកអ្នកបួសហាត់ដល់កម្រិតជាក់លាក់រួចហើយ, ពេលទើបចាប់ផ្ដើមនឹងមិនបែបនេះ។

ពុទ្ធវង្សគឺមិនសម្ដែងផឹកស្រា, លោកអ្នកមើលឃើញអង្គព្រះពុទ្ធណាលើកដបស្រាទេ? មិនមាន។ ខ្ញុំនិយាយថាមិនអាចញុំាសាច់, បួសហាត់នៅក្នុងមនុស្សសាមញ្ញបន្ទាប់ពីបោះចោលចិត្តប្រកាន់រួចហើយ, អនាគតញុំាឡើងវិញក៏មិនបញ្ហា។ ប៉ុន្តែស្រាបន្ទាប់ពីហាមចោលមិនអាចផឹកម្ដងទៀត។ លើរាងមនុស្សហាត់គង់មិនសុទ្ធតែជាមានគង់ឬ? គង់រូបភាពគ្រប់ប្រភេទ, មានសីលគង់ខ្លះលាតត្រដាងនៅលើផ្ទៃរាងកាយលោកអ្នក, សុទ្ធតែជាបរិសុទ្ធ។ លោកអ្នកផឹកស្រាកាលណា, ហ៊្វ ភ្លាមៗសុទ្ធតែឃ្លាតពីរាងកាយ, នៅមួយសន្ទុះនេះ, លើរាងកាយលោកអ្នកអ្វីក៏គ្មានទៀត, នរណាក៏ខ្លាចរសជាតិនោះ។ លោកអ្នកឆ្លងទម្លាប់នេះគឺគួរឲ្យស្អប់ខ្ពើមណាស់, ផឹកស្រានឹងធ្វើឲ្យអវិចារណ៍។ ហេតុអ្វីមានបួសហាត់មហាតាវខ្លះត្រូវការផឹកស្រា? ដោយសារគាត់មិនមែនបួសហាត់វិញ្ញាណដើមម្ចាស់របស់គាត់, គឺដើម្បីសណ្ដំវិញ្ញាណដើមម្ចាស់។

មនុស្សខ្លះញៀនស្រាស្មើជីវិត, មនុស្សខ្លះលោភលន់ស្រា, មនុស្សខ្លះផឹកដល់ថ្នាក់បំពុលក្នុងស្រា, មិនផឹកសូម្បីតែចានបាយក៏កាន់ឡើងមិនរួច, មិនផឹកគឺមិនបាន។ មនុស្សបួសហាត់ពួកយើងគឺមិនគួរបែបនេះ។ ផឹកស្រាប្រាកដជាញៀន, វាគឺតណ្ហាទេតើ, រំញោចប្រសាទញៀនរបស់មនុស្ស, កាន់តែផឹកញៀនកាន់តែខ្លាំង។ ធ្វើជាមនុស្សហាត់គង់ម្នាក់, ពួកយើងគិតសាកមើល, ចិត្តប្រកាន់នេះគួរចោលឬអត់? ចិត្តនេះក៏ត្រូវតែចោល។ មានមនុស្សគឺគិតថា៖ មិនបាន, ខ្ញុំទទួលនិងបញ្ជូន{ភ្ញៀវ}, ខ្ញុំគឺជំនាញបំរើការទំនាក់ទំនងខាងក្រៅ, មិនផឹកស្រារឿងរ៉ាវធ្វើមិនល្អ។ ខ្ញុំនិយាយថាមិនដូចនោះ, ចរចាការងារអាជីវកម្មទូទៅ, ជាពិសេសគឺចរចាការងារអាជីវកម្ម, ដោះស្រាយនឹងជនបរទេស, លោកអ្នកចង់ភេសជ្ជៈ, គាត់ចង់ទឹកសុទ្ធ, គាត់ចង់ស្រាបៀរមួយកែវ។ គ្មាននរណាបង្ខំលោកអ្នក, លោកអ្នករើសខ្លួនឯងផឹកខ្លួនឯងតាមសម្រួល, អាចផឹកបានប៉ុន្មានលោកអ្នកផឹក, ជាពិសេសគឺនៅក្នុងវណ្ណបញ្ញវន្ត, កាន់តែគ្មានរឿងរ៉ាវនេះលេចឡើង, ជាញឹកញាប់គឺជាបែបនេះ។

ជក់បារីក៏ជាការប្រកាន់, មនុស្សខ្លះនិយាយថាជក់បារីអាចធ្វើឲ្យស្មារតីស្រស់ស្រាយ, ខ្ញុំនិយាយនោះគឺបោកខ្លួនបោកមនុស្ស។ មានមនុស្សមួយចំនួនធ្វើការងារដល់ពេលហត់ឬក៏សរសេរអត្ថបទដល់ពេលហត់, គឺចង់សម្រាកមួយរយៈជក់បារី, គាត់គឺមានអារម្មណ៍ថាជក់បារីចប់ហើយស្មារតីស្រស់ស្រាយឡើងវិញ។ ភាពពិតមិនមែន, នោះគឺហេតុតែគាត់បានសម្រាកមួយរយៈយ៉ាងនោះ។ មនោគតិរបស់មនុស្សអាចបង្កជាអារម្មណ៍ខុសមួយ, នៅអាចផ្ដើមឡើងអារម្មណ៍បំភាន់។ ដូច្នោះក្រោយមកគឺពិតជាបង្កើតជាគោលគំនិត, បង្កើតជាអារម្មណ៍ខុស, លោកអ្នកមានអារម្មណ៍ថាជក់បារីហាក់ដូចធ្វើឲ្យស្មារតីលោកអ្នកស្រស់ស្រាយ,

ជាមូលដ្ឋានគឺនឹងមិន, វាមិនផ្តើមផលប៉ះពាល់។ ជក់បារីសម្រាប់រាងកាយមនុស្សកន្លែងល្អបន្តិចមួយក៏គ្មាន, ឯកជននេះជក់បារីពេលវេលាយូរ, ពេលដែលវេជ្ជបណ្ឌិតវះកាត់រាងកាយមនុស្ស, មើលឃើញបំពង់ខ្យល់សុទ្ធតែជាខ្មៅ, ខាងក្នុងសួតសុទ្ធតែឡើងខ្មៅ។

មនុស្សហាត់គង់ពួកយើងមិនមែនសម្តែងបន្សុទ្ធរាងកាយឬ? បន្តបន្សុទ្ធរាងកាយ, បន្តអភិវឌ្ឍសំដៅឡើងជាន់ថ្នាក់ខ្ពស់។ ហើយលោកអ្នកនៅតែនាំចូលក្នុងរាងកាយ, លោកអ្នកនិងយើងខ្ញុំមិនផ្ទុយស្រឡះហើយឬ? ក្រៅពីនេះវាក៏ជាប្រភេទតណ្ហាខ្លាំងក្លាមួយ។ មានមនុស្សក៏ដឹងថាមិនល្អ, តែគឺហាមមិនបាន។ ភាពពិតខ្ញុំប្រាប់អ្នករាល់គ្នា, គាត់គឺគ្មានមនោគតិមួយត្រឹមត្រូវធ្វើជាការដឹកនាំ, ដូច្នេះចង់ហាមយ៉ាងនោះមិនសូវងាយស្រួល។ ធ្វើជាមនុស្សបួសហាត់ម្នាក់, ថ្ងៃនេះលោកអ្នកចាត់ទុកវាជាចិត្តប្រកាន់មួយហើយចោលវាទៅ, លោកអ្នកមើលសាកមើលលោកអ្នកអាចហាមបានឬអត់។ ខ្ញុំផ្តល់យោបល់អ្នករាល់គ្នា, ពិតជាចង់បួសហាត់ចាប់ពីពេលនេះតទៅ{ចូរ}លោកអ្នកហាមបារី, ធានាលោកអ្នកអាចហាមបាន។ នៅលើវាលរបស់ថ្នាក់នេះគ្មានមនុស្សគិតដល់ជក់បារី, លោកអ្នកចង់ហាម, ធានាលោកអ្នកអាចហាមបាន, លោកអ្នកកាន់បារីជក់ឡើងវិញគឺមិនត្រូវរសជាតិទៀត។ លោកអ្នកអានសៀវភៅអានមេសម្តែងនេះ, ក៏នឹងផ្តើមផលប៉ះពាល់នេះ។ ប្រាកដណាស់បើសិនលោកអ្នកមិនចង់បួសហាត់, យើងខ្ញុំក៏មិនគ្រប់គ្រង, ធ្វើជាមនុស្សបួសហាត់ម្នាក់, ខ្ញុំគិតថាលោកអ្នកគឺគួរហាមវាចោល។ ខ្ញុំធ្លាប់លើកឧទាហរណ៍មួយបែបនេះ, លោកអ្នកឃើញអង្គពុទ្ធណា, អង្គតាវណាអង្គុយនៅទីនោះជក់បារីទេ? ឯណាមានបែបនោះ? ធ្វើជាមនុស្សបួសហាត់ម្នាក់, គោលដៅរបស់លោកអ្នកជាអ្វី? តើលោកអ្នកមិនគួរហាមវាចោលឬ?

ដូច្នេះខ្ញុំសម្ដែងបើសិនលោកអ្នកចង់ប្ដូសហាត់, លោកអ្នកគឺយកវាហាម ចោល, វាធ្វើបាបរាងកាយលោកអ្នក, ក៏ជាប្រភេទតណ្ហាមួយផងដែរ, គាប់ជួនផ្ទុយស្រឡះនឹងតម្រូវរបស់មនុស្សប្ដូសហាត់ពួកយើង។

## ចិត្តច្រណែន

ពេលខ្ញុំកំពុងសម្ដែងធម៌ជាធម្មតាសម្ដែងដល់បញ្ហាចិត្តច្រណែន។ ហេតុអ្វី? ដោយសារចិត្តច្រណែននៅប្រទេសចិនបង្ហាញយ៉ាងខ្លាំងក្លាបំផុត, ខ្លាំងក្លាដល់ថ្នាក់បានបង្កើតជាធម្មជាតិរួចហើយ, ខ្លួនឯងក៏ទទួលដឹងមិនចេញទៀត។ ជនជាតិចិនហេតុអ្វីចិត្តច្រណែនបានជាខ្លាំងក្លាយ៉ាងនោះ? វាក៏មានដើមហេតុផងដែរ។ ជនជាតិចិនអតីតកាលទទួលរងឥទ្ធិពលរបស់ខុងជឺសាសនាជ្រៅបង្គួរ, ចរិយាសម្បត្តិសុទ្ធតែសំដៅចូលក្នុងបង្គួរ, ខឹងមិនបង្ហាញចេញមក, រីករាយក៏មិនបង្ហាញចេញមក, សម្ដែងទប់ចិត្ត, សម្ដែងខន្តី។ ដោយសារបានទម្លាប់តាមបែបនេះរួចហើយ, ដូច្នេះជនជាតិយើងទាំងមូលបានបង្កើតជាចរិយាសម្បត្តិដ៏សំដៅចូលក្នុង។ ប្រាកដណាស់គាត់មានកន្លែងល្អរបស់គាត់, មិនបង្ហាញទេពកោសល្យខាងក្នុង។ ទោះយ៉ាងណាក៏មានគុណវិបត្តិស្ថិតនៅ, អាចនាំមកស្ថានភាពមិនល្អ។ ជាពិសេសបានដល់សម័យកាលផុតធម៌, ផ្នែកមិនល្អនេះគឺលាតត្រដាងកាន់តែលេចធ្លោ, គឺអាចធ្វើឲ្យមនុស្សបង្កើនចិត្តច្រណែន។ នរណាមានរឿងល្អបង្ហាញចេញមក, អ្នកដទៃជាបន្ទាន់គឺច្រណែនដល់ថ្នាក់ពិបាកទ្រាំ, នៅអង្គភាពឬក៏ក្រៅអង្គភាពទទួលបានរង្វាន់, ឬក៏មានកន្លែងល្អបន្តិចត្រឡប់មកមិនហ៊ាននិយាយស្ដី, អ្នកដទៃដឹងហើយក្នុងចិត្តគឺបាត់តុល្យភាព។ ជនជាតិភាគខាងលិចហៅនេះថាច្រណែនបូព៌ាក៏ហៅថាច្រណែនអាស៊ី។ តំបន់អាស៊ីទាំងមូលសុទ្ធតែរងឥទ្ធិពលរបស់ខុងជឺសាសនាប្រទេសចិនជ្រៅបង្គួរ, តិចច្រើនក៏មាននាំ

តាមបន្ទិច។ ប្រទេសចិនពួកយើងតែមួយគត់បង្ហាញខ្លាំងក្លាបង្គួរ។

នេះមានទាក់ទងនឹងមនោគមវិជ្ជាសមភាពដាច់ខាតអតីតកាលដែលពួកយើងធ្វើ, យ៉ាងណាក្ដីមេឃបាក់ចុះអ្នករាល់គ្នាស្លាប់; មានកន្លែងល្អអ្វីអ្នករាល់គ្នាចែកស្មើ; ដំឡើងប្រាក់ខែប៉ុន្មានភាគរយ, ម្នាក់មួយចំណែក។ មនោគតិនេះមើលទៅហាក់ដូចជាត្រូវណាស់, នរណាៗក៏ដូចគ្នា។ ភាពពិតធ្វើម្ដេចអាចដូចគ្នា? ការងារធ្វើខុសគ្នា, កម្រិតកាតព្វកិច្ចទំនួលខុសត្រូវក៏មិនដូចគ្នា។ ចក្រវាលនេះរបស់ពួកយើងនៅមានគោលសីលធម៌, ហៅថាមិនបាត់មិនបាន, បានគឺត្រូវតែបាត់។ ក្នុងមនុស្សសាមញ្ញសម្ដែងមិនធ្វើមិនបាន, ធ្វើច្រើនបានច្រើន, ធ្វើតិចបានតិច, បង់ចំណាយច្រើន, គឺគួរតែបានច្រើន។ អតីតកាលអនុវត្តមនោគមវិជ្ជាសមភាពដាច់ខាត, និយាយថាឯកជននោះ, កើតចេញមកសុទ្ធតែជាដូចគ្នា, ថ្ងៃក្រោយទើបផ្លាស់ប្រែមនុស្ស។ ខ្ញុំនិយាយថាការថ្លែងនោះដាច់ខាតពេកហើយ, អ្វីដាច់ខាតពេកគឺមិនត្រូវទៀត។ ហេតុអ្វីមនុស្សកើតចេញមកនៅតែមានប្រុសមានស្រី? ធំឡើងក៏មិនដូចគ្នា? មានមនុស្សកើតចេញមកគឺមានជំងឺ, រូបភាពមិនប្រក្រតី, មិនដូចគ្នា។ យើងខ្ញុំនៅលើជាន់ថ្នាក់ខ្ពស់សង្កេតមើល, នៅអវកាសផ្សេងស្ថិតនៅមួយជីវិតមនុស្សរៀបដាក់នៅទីនោះ, អាចដូចគ្នាឬ? សុទ្ធតែចង់សមភាព, ក្នុងជីវិតរបស់គាត់នោះគ្មាន, ធ្វើម្ដេចសមភាព? មិនដូចគ្នា។

មនុស្សបស្ចិមប្រទេសចរិយាសម្បត្តិសំដៅចេញក្រៅបង្គួរ, រីករាយអាចមើលចេញបាន, ខឹងក៏អាចមើលចេញបាន។ គាត់មានកន្លែងល្អរបស់គាត់, តែក៏មានកន្លែងមិនល្អរបស់គាត់, មិនអាចខន្តីធនទ្រាំ។ ពីរប្រភេទគោលគំនិតចរិយាសម្បត្តិខុសគ្នា, ធ្វើរឿងរ៉ាវនឹងសាងបង្កើតលទ្ធផលខុសគ្នា។ មនុស្សចិនប្រសិនមេដឹកនាំលើកតម្កើង, ឬក៏ឲ្យលោកអ្នក

កន្លែងល្អអ្វីមួយ, ក្នុងចិត្តអ្នកដទៃគឺបាត់តុល្យភាព។ ប្រសិនបានជូនប្រាក់រង្វាន់ច្រើនជាងបន្តិច, ខ្លួនឯងលាក់ៗបាំងៗញាត់ក្នុងហោប៉ៅ, មិនអាចទុកអ្នកដទៃដឹង។ បច្ចុប្បន្នកម្មករគំរូក៏មិនងាយស្រួលធ្វើ៖ បងជាកម្មករគំរូបងធ្វើបានល្អ, បងត្រូវមកឆាប់ចេញយឺត, រឿងនេះសុទ្ធតែបងធ្វើទៅ, បងធ្វើបានល្អ, យើងខ្ញុំមិនបាន, ចំអកឡកឡឺយ, ធ្វើមនុស្សល្អសុទ្ធតែមិនងាយ។

បើសិននៅបរទេសគឺខុសគ្នាស្រឡះ។ ថៅកែថ្ងៃនេះឃើញគាត់ធ្វើការបានល្អ, ជូនរង្វាន់ឲ្យច្រើនជាង។ គាត់រីករាយយ៉ាងខ្លាំងនៅពីមុខមនុស្សគ្រប់គ្នារាប់មួយសន្លឹកៗ, អ៎ា, ថ្ងៃនេះថៅកែឲ្យលុយខ្ញុំច្រើនយ៉ាងនេះ, សប្បាយហ៉ាៗរាប់មួយសន្លឹកៗប្រាប់អ្នករាល់គ្នា, គាត់គ្មានផលវិបាកអ្វី។ បើសិននៅប្រទេសចិន, ឧបមាថាមានមនុស្សបានជូនរង្វាន់, មេដឹកនាំក៏ត្រូវហៅលោកអ្នកឆាប់លាក់ទៅ, កុំឲ្យអ្នកដទៃមើលឃើញ។ នៅបរទេស, កូនក្មេងនៅក្នុងសាលាបើសិនបាន១០០ពិន្ទុ, គាត់សប្បាយចិត្តខ្លាំងរត់ផងស្រែកផង៖ ថ្ងៃនេះកូនបាន១០០ពិន្ទុ, កូនបាន១០០ពិន្ទុ! រត់រហូតពីសាលាដល់ផ្ទះ។ អ្នកជិតខាងនឹងបើកទ្វារស្រែកថា៖ នែ៎, ថម, ល្អណាស់, ក្មេងពូកែណាស់។ ម្នាក់នោះបើកបង្អួច៖ នែ៎, ម៉ាយខ៍, ពិតជាល្អណាស់។ រឿងរ៉ាវនេះបើសិនកើតឡើងនៅប្រទេសចិនគឺចប់, កូនបាន១០០ពិន្ទុ, កូនបាន១០០ពិន្ទុ! កូនក្មេងនេះរត់ពីសាលាដល់ផ្ទះ, ទ្វារនោះនៅមិនទាន់បើកផង, ក្នុងផ្ទះបានជេរឡើងរួចហើយ៖ មានអ្វីដ៏អស្ចារ្យនោះ, មិនមែនគ្រាន់តែបាន១០០ពិន្ទុឬ? មុខមាត់អី! នរណាមិនធ្លាប់បាន១០០ពិន្ទុ! ពីរប្រភេទគោលគំនិតខុសគ្នានេះនឹងសាងបង្កើតលទ្ធផលខុសគ្នា។ វាអាចសាងបង្កើតចិត្តច្រណែនរបស់មនុស្ស, អ្នកដទៃបើសិនល្អ, មិនមែនសប្បាយចិត្តជំនួសអ្នកដទៃ, តែគឺ

ក្នុងចិត្តបាត់តុល្យភាព។ វានឹងលេចឡើងបញ្ហានេះ។

ប៉ុន្មានឆ្នាំមុនអនុវត្តមនោគមវិជ្ជាសមភាពដាច់ខាត, សុទ្ធសាធធ្វើឲ្យរញ៉េរញ៉ៃគោលគំនិតមនោគតិមនុស្ស។ លើកឧទាហរណ៍ពិស្តារ។ ឯកជននេះនៅក្នុងអង្គភាព, គាត់មានអារម្មណ៍ថាអ្នកដទៃសុទ្ធតែមិនស្មើគាត់, គាត់ធ្វើអ្វីក៏បានល្អ, អារម្មណ៍មែនទែនដ៏អស្ចារ្យ។ គាត់គិតក្នុងចិត្តខ្លួនឯង៖ ឲ្យខ្ញុំធ្វើនាយករោងចក្រ, អ្នកគ្រប់គ្រងខ្ញុំក៏អាចធ្វើបាន; ឱ្យខ្ញុំធ្វើមន្ត្រីធំជាងខ្ញុំក៏អាចធ្វើបាន; ធ្វើនាយករដ្ឋមន្ត្រីខ្ញុំឃើញក៏បានដែរ។ មេដឹកនាំក៏អាចនិយាយថាឯកជននេះពិតជាល្អ, ធ្វើអ្វីក៏ល្អ។ មិត្តរួមការងារអាចក៏សុទ្ធតែនិយាយ, ឯកជននេះពិតជាពូកែ, ដឹងរឿង, មានទេពកោសល្យ។ ប៉ុន្តែនៅក្នុងក្រុមរបស់ពួកគាត់ឬក៏ក្នុងការិយាល័យរបស់ពួកគាត់តែមួយមានឯកជនមួយ, ធ្វើអីក៏មិនបាន, ធ្វើអីក៏មិនកើត។ មានថ្ងៃមួយ, ឯកជនគ្មានសមត្ថភាពនេះផ្ទុយមកវិញបានតែងតាំងធ្វើកម្មាភិបាល, មិនតែងតាំងគាត់, លើសពីនេះទាំងធ្វើជាមេដឹកនាំរបស់គាត់។ ក្នុងចិត្តគាត់នោះគឺបាត់តុល្យភាព, ជួបទាំងលើទាំងក្រោមដើម្បីប្រាប់, សោកសៅបាត់តុល្យភាព, ច្រណែនទ្រាំមិនបាន។

ខ្ញុំសម្ដែងគោលសីលធម៌បែបនេះឲ្យអ្នករាល់គ្នា, គោលសីលធម៌ដែលមនុស្សសាមញ្ញមិនអាចយល់ដឹងដល់៖ លោកអ្នកឃើញថាលោកអ្នកអ្វីសុទ្ធតែបាន, ក្នុងជីវិតលោកអ្នកមិនមាន; គាត់ធ្វើអ្វីសុទ្ធតែមិនបាន, ប៉ុន្តែក្នុងជីវិតគាត់មាន, គាត់គឺបានធ្វើកម្មាភិបាល។ មិនខ្វល់មនុស្សសាមញ្ញគិតដូចម្ដេច, នោះជាការគិតរបស់មនុស្សសាមញ្ញ។ នៅជីវិតកម្រិតខ្ពស់ជាងមកមើល, ការអភិវឌ្ឍន៍នៃសង្គមមនុស្សជាតិ, ហួសពេកគ្រាន់តែជាកំពុងអភិវឌ្ឍយោងតាមបទច្បាប់អភិវឌ្ឍន៍ពិសេសជាក់លាក់, ដូច្នេះក្នុងមួយជីវិតរបស់មនុស្សធ្វើអ្វី, គាត់អាចមិនមែនយោងតាមអានុ

ភាពរបស់លោកអ្នកដើម្បីរៀបចំឲ្យលោកអ្នក។ ក្នុងពុទ្ធសាសនាសម្ដែងបង្វិលកម្មផល, គាត់គឺយោងតាមអំណាចកម្មរបស់លោកអ្នកដើម្បីរៀបចំឲ្យលោកអ្នក, អានុភាពលោកអ្នកធំដល់ណា, លោកអ្នកគ្មានគុណធម៌, លោកអ្នកអាចមួយជីវិតនេះអ្វីក៏គ្មាន។ លោកអ្នកឃើញថាគាត់ធ្វើអ្វីក៏មិនបាន, គុណធម៌របស់គាត់ធំ, ធ្វើមន្ត្រីធំ, មានទ្រព្យសម្បត្តិធំ។ មនុស្សសាមញ្ញមើលមិនឃើញចំណុចមួយនេះ, គាត់គឺរមែងមានអារម្មណ៍ថាខ្លួនឯងគួរតែធ្វើរឿងរ៉ាវត្រឹមត្រូវដែលខ្លួនឯងគួរធ្វើ។ ដូច្នេះមួយជីវិតរបស់គាត់ប្រជែងមកប្រយុទ្ធទៅ, ចិត្តនេះរងការឈឺចាប់ដ៏ធំ, មានអារម្មណ៍ដ៏ទុក្ខ, ដ៏ហត់, រមែងបាត់តុល្យភាពក្នុងចិត្ត។ បាយមិនឆ្ងាញ់, ដេកមិនលក់, ចិត្តស្មារតីត្រជាក់ដូចផេះ, ដល់ចាស់ហើយ, ធ្វើឲ្យរាងកាយខ្លួនឯងក្រៀមស្វិត, ជំងឺអ្វីក៏កើតឡើង។

ដូច្នោះមនុស្សបួសហាត់ពួកយើងគឺកាន់តែមិនគួរធ្វើបែបនេះ, មនុស្សបួសហាត់ពួកយើងសម្ដែងបណ្ដោយតាមធម្មជាតិ, ជារបស់លោកអ្នកមិនបាត់, មិនមែនជារបស់លោកអ្នកលោកអ្នកដណ្ដើមក៏មិនបាន។ ប្រាកដណាស់ក៏មិនមែនដាច់ខាត។ បើសិនសុទ្ធតែជាដាច់ខាតយ៉ាងនោះ, ក៏ជាមិនស្ថិតនៅបញ្ហាមនុស្សធ្វើរឿងអាក្រក់, ក៏មានន័យថាវាក៏អាចស្ថិតនៅកត្តាមិនស្ថិតស្ថេរមួយចំនួន។ ទោះយ៉ាងណាពួកយើងធ្វើជាមនុស្សហាត់គង់, តាមទ្រឹស្ដីគឺដោយសារបរមីលោកគ្រូគ្រប់គ្រង, អ្នកដទៃចង់យកអ្វីរបស់លោកអ្នកក៏យកមិនបាន។ ដូច្នេះពួកយើងសម្ដែងបណ្ដោយតាមធម្មជាតិ, មានពេលខ្លះលោកអ្នកឃើញថារបស់នោះជារបស់លោកអ្នក, គេក៏និយាយប្រាប់លោកអ្នក, ថារបស់នេះជារបស់លោកអ្នក, ភាពពិតវាមិនមែនជារបស់លោកអ្នក។ លោកអ្នកអាចសន្មតថាជារបស់លោកអ្នក, ដល់ចុងក្រោយវាមិនមែនជារបស់លោកអ្នក,

ហេតុនោះឃើញថាលោកអ្នកចំពោះរឿងនេះអាចដាក់ចុះបានឬអត់, ដាក់ចុះមិនបានជាក់ស្ដែងគឺជាចិត្តប្រកាន់, គឺត្រូវតែប្រើវិធីសាស្ត្រនេះទុកឲ្យលោកអ្នកចោលចិត្តផលប្រយោជន៍នេះ, ជាក់ស្ដែងគឺជាបញ្ហានេះ។ ដោយសារមនុស្សសាមញ្ញភ្ញាក់ដឹងមិនដល់គោលសីលធម៌នេះ, នៅពីមុខផលប្រយោជន៍សុទ្ធតែចង់ទៅប្រជែង, ទៅប្រយុទ្ធ។

ចិត្តប្រណែននៅក្នុងមនុស្សសាមញ្ញឆ្លុះបញ្ចាំងចេញមកសុទ្ធសាធសែនកាចសាហាវ, នៅពិភពបួសហាត់ពីដើមមកក៏ឆ្លុះបញ្ចាំងលេចធ្លោបង្គួរ។ រវាងនិកាយនឹងគ្នាមិនគោរពគ្នា, គង់របស់អ្នកល្អ, គង់របស់គាត់ល្អ, ថាវែងថាខ្លីសុទ្ធតែមានទាំងអស់, ខ្ញុំឃើញថាសុទ្ធតែជាក្នុងមួយជាន់ថ្នាក់ព្យាបាលជំងឺកាយសម្បទា។ ប្រយុទ្ធជាមួយគ្នាទៅមកភាគច្រើនសុទ្ធតែជាគង់រញ៉េរញ៉ៃដែលកាយភ្ជាប់មួយចំនួននាំមក, ក៏មិនសម្ដែងចិត្តចរិត។ មនុស្សខ្លះហាត់គង់ហាត់ជាង២០ឆ្នាំរួចហើយមិនទាន់លេចឡើងសីលគង់, អ្នកដទៃទើបតែហាត់គឺលេចឡើងសីលគង់, ក្នុងចិត្តរបស់គាត់គឺបាត់តុល្យភាព៖ ខ្ញុំហាត់គង់ជាង២០ឆ្នាំរួចហើយ, ខ្ញុំក៏មិនទាន់លេចសីលគង់, គាត់លេចសីលគង់, គាត់លេចសីលគង់អ្វីហ្នុ៎? ក្នុងចិត្តគាត់ខឹងទ្រាំមិនបាន៖ គាត់នោះត្រូវកាយភ្ជាប់រួចហើយ, ឆ្កួតវង្វេងអារក្សចូលហើយ! គ្រូឈីគង់បើកថ្នាក់, មនុស្សខ្លះអង្គុយនៅទីនោះក៏មិនគោរព៖ អ៊ា, គ្រូឈីគង់អ្វី, ល្បែងក្មេងលេងនោះគាត់សម្ដែងខ្ញុំក៏មិនចង់ស្ដាប់។ គ្រូឈីគង់អាចពិតជាមិនសម្ដែងល្អស្មើគាត់, ប៉ុន្តែដែលគ្រូឈីគង់នោះសម្ដែងជាប្រការក្នុងធម្មក្ខន្ធរបស់គាត់ខ្លួនឯង។ ឯកជននេះគាត់អ្វីក៏រៀន, វិញ្ញាបនបត្របញ្ចប់ការសិក្សាមានមួយគំនរ, គ្រូឈីគង់ណាបើកថ្នាក់គាត់ក៏ចូលរួម, គាត់មែនទែនដឹងបានច្រើនណាស់, ទាំងដឹងច្រើនជាងគ្រូឈីគង់នោះទៀត។ ប៉ុន្តែមានប្រយោជន៍អ្វី? សុទ្ធតែជារបស់

ព្យាបាលជំងឺកាយសម្បទា, គាត់បំពាក់កាន់តែច្រើន, ព័ត៌មានកាន់តែរញ៉េរញ៉ៃ, កាន់តែស្មុគស្មាញ, កាន់តែមិនងាយបួស, សុទ្ធតែរញ៉េរញ៉ៃខូចអស់។ បួសហាត់ពិតប្រាកដគឺសម្តែងឯកទេសតែមួយគត់, មិនលេចគម្លាតខុសណាមួយ។ ក្នុងចំណោមមនុស្សបួសតាវពិតប្រាកដក៏មានភាពផ្ទុះបញ្ចាំងនេះ, មិនគោរពរវាងគ្នាទៅមក, ចិត្តប្រជែងប្រយុទ្ធមិនចោល, ក៏ងាយស្រួលសាងបង្កើតចិត្តច្រណែន។

ពួកយើងសម្តែងអំពីរឿង៖ ស្ទិនគង់ប៉ៅក្នុង《ហ្វឹងស្ទីនយៀនអ៊ី》, មើលឃើញជាំងចឺយ៉ាទាំងចាស់ទាំងគ្មានអានុភាព, ប៉ុន្តែឃ្វានស្ទីធានចុនអនុញ្ញាតឲ្យជាំងចឺយ៉ាតាំងងារអាទិទេព។ ក្នុងចិត្តស្ទីនគង់ប៉ៅគឺបាត់តុល្យភាព, ទុកឲ្យគាត់តាំងងារអាទិទេពយ៉ាងម៉េច? លោកអ្នកឃើញស្ទឹនគង់ប៉ៅខ្ញុំអស្ចារ្យប៉ុណ្ណា, ក្បាលរបស់ខ្ញុំកាត់ចុះហើយនៅអាចដាក់ឡើងវិញបាន, ហេតុម្តេចមិនទុកឲ្យខ្ញុំទៅតាំងងារអាទិទេព? គាត់ច្រណែនពេកទ្រាំមិនបាន, រមែងបង្កបញ្ហាចលាចលជាំងចឺយ៉ា។

សម័យកាលសាសនាបុព្វកាលនោះរបស់សក្យមុនីពុទ្ធគឺជាសម្តែងសីលគង់, បច្ចុប្បន្នក្នុងពុទ្ធសាសនាគ្មាននរណាហ៊ានសម្តែងសីលគង់។ លោកអ្នកបើសិនសម្តែងសីលគង់, គាត់និយាយលោកអ្នកជាឆ្កួតវង្វេងអារក្សចូល។ សីលគង់អ្វី? ជាមូលដ្ឋានគាត់មិនទទួលស្គាល់។ ហេតុអ្វី? ព្រះសង្ឃបច្ចុប្បន្នជាមូលដ្ឋានមិនដឹងរឿងដូចម្តេច។ សក្យមុនីមានសិស្សច្បង១០, មោគ្គល្លានគឺត្រូវបានគាត់និយាយជាទេពអំណាចលេខមួយ។ សក្យមុនីនៅមានសិស្សស្រី, ក្នុងនោះមានម្នាក់ហៅថាឧប្បលវណ្ណា, ក៏ជាលេខមួយទេពអំណាចផងដែរ។ ពុទ្ធសាសនាបង្រៀនចូលប្រទេសចិនក៏ជាដូចគ្នា, សម័យប្រវត្តិសាស្រ្តលេចឡើងអធិសង្ឃជាច្រើន, តាហ៍ម៉ែរពេលមកប្រទេសចិនឆ្លងទន្លេដោយត្រែងមួយទង, ប៉ុន្តែក្នុងពេលប្រវត្តិ

សាស្ត្រអភិវឌ្ឍ, ទេពអំណាចគឺមួយថ្ងៃកាន់តែត្រូវបានច្រានចោល។ មូលហេតុចម្បងគឺព្រះសង្ឃធំ, ព្រះចៅអធិការ, ឧបជ្ឈាយ៍ក្នុងវត្តជាដើម មនុស្សទាំងនេះមិនជាក់លាក់ជាមនុស្សមហានិស្ស័យ, កុំឃើញថាគាត់ធ្វើឧបជ្ឈាយ៍, ធ្វើព្រះសង្ឃធំ, នោះហួសពេកគ្រាន់តែជាមុខតំណែងក្នុងមនុស្សសាមញ្ញ, គាត់ក៏ជាមនុស្សកំពុងបួសហាត់, គាត់ហួសពេកគ្រាន់តែជាបួសជំនាញ។ លោកអ្នកបួសនៅផ្ទះគឺមិនពេញជំនាញ។ បួសសម្រេចបានឬអត់សុទ្ធតែត្រូវពឹងផ្អែកលើចិត្តនោះដើម្បីបួស, សុទ្ធតែជាដូចគ្នា, ខុសបន្តិចក៏មិនបាន។ ប៉ុន្តែព្រះសង្ឃតូចដែលដុតភ្លើងដាំបាយនោះ, គាត់ក៏មិនជាក់លាក់ជាមនុស្សនិស្ស័យតូច។ ព្រះសង្ឃតូចកាន់តែរងទុក្ខកាន់តែងាយស្រួលបើកគង់, ព្រះសង្ឃធំនោះកាន់តែសោយសុខកាន់តែមិនងាយស្រួលបើកគង់, ដោយសារនេះមានបញ្ហាបំប្លែងអំណាចកម្ម។ ព្រះសង្ឃតូចរមែងទុក្ខផងហាត់ផង, សងកម្មនឹងលឿន, ត្រាស់ដឹងនឹងលឿន, ប្រហែលជាមានថ្ងៃមួយគាត់ស្រាប់តែបើកគង់។ នេះបើកគង់កាលណា, ត្រាស់ដឹងឬក៏ត្រាស់ដឹងពាក់កណ្តាល, ទេពអំណាចលេចចេញមក, ព្រះសង្ឃក្នុងវត្តទាំងអស់សុទ្ធតែចង់មកសួរគាត់, មនុស្សគ្រប់គ្នាសុទ្ធតែគោរពគាត់។ ប៉ុន្តែព្រះចៅអធិការនេះគឺទ្រាំមិនបាន៖ ព្រះចៅអធិការនេះរបស់យើងធ្វើម្តេចធ្វើបានទៀត, ត្រាស់ដឹងស្អី? គាត់គឺឆ្កួតវង្វេងអារក្សចូលរួចហើយ, បណ្តេញគាត់ចេញទៅ។ បណ្តេញចេញពីវត្តអារាម។ យូរៗទៅ, ពុទ្ធសាសនាក្នុងដីជនជាតិហានពួកយើងគ្មាននរណាហ៊ាននិយាយអំពីសីលគង់ទៀត។ លោកអ្នកឃើញជីគង់អានុភាពធំប៉ុណ្ណា, បញ្ជូនឈើពីភ្នំអឿម៉យ, ពីក្នុងអណ្តូងបោះមួយកង់ៗឡើងលើ, ចុងក្រោយនៅតែត្រូវបណ្តេញចេញពីវត្តលិញយីន។

បញ្ហាចិត្តប្រណែននេះធ្ងន់ធ្ងរណាស់, ដោយសារវាដោយផ្ទាល់ពាក់

ព័ន្ធដល់បញ្ហាពួកយើងអាចមិនអាចបួសសម្រេចបរិបូរ។ ចិត្តច្រណែនបើសិនមិនចោល, ចិត្តទាំងអស់ដែលគេបួសហាត់បានសុទ្ធតែក្លាយជាដីទន់ខ្សោយ។ នេះមានបទបញ្ញត្តិមួយ៖ មនុស្សនៅក្នុងបួសហាត់, ចិត្តច្រណែនបើសិនមិនចោលគឺមិនសម្រេចមគ្គផល, ដាច់ខាតមិនសម្រេចមគ្គផល។ អតីតកាលអ្នករាល់គ្នាអាចធ្លាប់បានស្ដាប់ថា, ព្រះពុទ្ធអាមីធួរសម្ដែងនាំតាមកម្មកើតជាតិក្រោយ, ចិត្តច្រណែនបើសិនមិនចោលមិនបាន។ ទិដ្ឋភាពផ្សេងៗអន់បន្តិច, នាំតាមកម្មបន្តិចបន្តួចកើតជាតិក្រោយ, បួសម្ដងទៀត, នោះអាចបាន, ប៉ុន្តែចិត្តច្រណែនមិនចោលដាច់ខាតមិនបាន។ ថ្ងៃនេះខ្ញុំសម្ដែងជាមួយមនុស្សហាត់គង់, លោកអ្នកគឺកុំប្រកាន់វង្វេងមិនភ្ញាក់ដឹងបែបនេះ, គោលបំណងដែលលោកអ្នកចង់សម្រេចបានគឺបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់ជាង, ចិត្តច្រណែនចាំបាច់ត្រូវកម្ចាត់ចោល។ ដូច្នេះយើងខ្ញុំយកវាចេញសម្ដែងដោយឡែក។

## បញ្ហាព្យាបាលជំងឺ

និយាយដល់ព្យាបាលជំងឺ, មិនមែនជាបង្រៀនលោកអ្នកព្យាបាលជំងឺ។ សិស្សបួសពិតរបស់ហ្វាលូនតាហ្វានរណាក៏មិនអាចព្យាបាលជំងឺឲ្យមនុស្ស, លោកអ្នកឲ្យតែព្យាបាលជំងឺកាលណា, អ្វីទាំងអស់របស់ហ្វាលូនតាហ្វានាំតាមលើរាងកាយលោកអ្នក, បរមីរបស់ខ្ញុំនឹងដកហូតវិញទាំងស្រុង។ ហេតុអ្វីមើលបញ្ហានេះធ្ងន់ធ្ងរយ៉ាងនេះ? ដោយសារវាជាបាតុភូតមួយបំផ្លាញមហាធម៌។ មិនថាធ្វើខូចខាតរាងកាយលោកអ្នកខ្លួនឯងតែប៉ុណ្ណោះ, មនុស្សខ្លះកាលណាពិនិត្យជំងឺរួចហើយដៃគឺរមាស់, មើលឃើញនរណាក៏ទាញមកពិនិត្យជំងឺឲ្យគេ, បង្ហាញខ្លួនឯង, នេះមិនមែនចិត្តប្រកាន់ឬ? ឥទ្ធិពលធ្ងន់ធ្ងរដល់បួសហាត់របស់មនុស្ស។

មានគ្រូឈីគង់ក្លែងក្លាយជាច្រើនក្ដាប់ជាប់ចិត្តសាស្ត្ររបស់មនុស្ស

សាមញ្ញ, ក្រោយពីរៀនឈីគង់ចង់ពិនិត្យជំងឺឲ្យមនុស្ស, គឺបង្រៀនឲ្យលោកអ្នកប្រការនេះ។ និយាយថាបញ្ចេញឈីអាចព្យាបាលជំងឺ, នោះមិនមែននិយាយកំប្លែងហើយឬ? លោកអ្នកក៏ជាឈី, គាត់ក៏ជាឈី, តើលោកអ្នកបញ្ចេញឈីគឺព្យាបាលជំងឺឲ្យមនុស្ស? ប្រហែលជាឈីរបស់គេព្យាបាលឲ្យលោកអ្នកវិញមិនខាន! រវាងឈីនិងឈីគ្មានផលប៉ះពាល់រឹតត្បិត។ ក្នុងពេលបួសហាត់នៅជាន់ថ្នាក់ខ្ពស់គេបញ្ចេញគង់, បញ្ចេញគឺជាសារធាតុថាមពលខ្ពស់, នេះមែនទែនអាចព្យាបាលជំងឺ, អាចរឹតត្បិតជំងឺ, អាចផ្ដើមផលប៉ះពាល់បង្រ្កាប, តែផ្ទុយមកវិញមិនអាចបំបាត់ឫសគល់។ ដូច្នេះពិតប្រាកដអាចព្យាបាលជំងឺ, ត្រូវមានសីលគង់ទើបអាចព្យាបាលជំងឺទាំងស្រុង។ ប្រភេទជំងឺនីមួយៗសុទ្ធតែមានប្រភេទសីលគង់ព្យាបាលនីមួយៗតម្រង់ចំ, គ្រាន់តែសីលគង់ព្យាបាលជំងឺខ្ញុំនិយាយថាក៏មានជាងមួយម៉ឺនប្រភេទ, មានប៉ុន្មានប្រភេទជំងឺគឺមានប៉ុណ្ណោះប្រភេទសីលគង់តម្រង់ចំដើម្បីព្យាបាល។ គ្មានសីលគង់នេះ, ដៃរបស់លោកអ្នកបញ្ចេញជំនាញអ្វីវាក៏មិនដំណើរការ។

មានមនុស្សខ្លះក្នុងអំឡុងឆ្នាំទាំងនេះធ្វើឲ្យពិភពបួសហាត់ដ៏ចលាចល។ គ្រូឈីគង់ទាំងនោះដែលពិតប្រាកដចេញមកព្យាបាលជំងឺកាយសម្បទា, គ្រូឈីគង់ដែលចាប់ផ្ដើមចេញមកបើកផ្លូវនេះ, តើមានឯណាបង្រៀនគេព្យាបាលជំងឺ? សុទ្ធតែជាគាត់ព្យាបាលជំងឺឲ្យលោកអ្នកឬក៏បង្រៀនលោកអ្នកបួសហាត់យ៉ាងនេះយ៉ាងនោះ, ហ្វឹកហាត់រាងកាយយ៉ាងនេះយ៉ាងនោះ, បង្រៀនលោកអ្នកមួយសំណុំលំហាត់, ក្រោយមកលោកអ្នកខ្លួនឯងតាមរយៈហ្វឹកហាត់ហើយជាសះជំងឺ។ ក្រោយមកគ្រូឈីគង់ក្លែងក្លាយចេញមកធ្វើឲ្យបរិយាកាសខ្មៅអាក្រក់, នរណាចង់ព្យាបាលជំងឺគឺនឹងអន្ទងមកកាយភ្ជាប់, ជាក់លាក់គឺជាបែបនេះ។ បរិយា

កាសនាគ្រានោះក៏មានគ្រូឈីគង់មួយចំនួនពិនិត្យជំងឺ, នោះគឺដើម្បីសហការនឹងប្រភេទបាតុភូតតារាសាស្ត្រនាគ្រានោះ។ ប៉ុន្តែ, វាមិនមែនថ្វីដៃក្នុងមនុស្សសាមញ្ញ, មិនអាចរក្សាបន្តជានិច្ច, គឺជាបាតុភូតតារាសាស្ត្រផ្លាស់ប្រែនាគ្រានោះបានបង្កឡើង, នោះគឺផលិតផលរបស់សម័យនោះ។ ក្រោយមកជំនាញបង្រៀនគេព្យាបាលជំងឺ, គឺបានរញ៉េរញ៉ៃមក។ តើមនុស្សសាមញ្ញម្នាក់៣ថ្ងៃ, ៥ថ្ងៃគឺអាចព្យាបាលជំងឺបានទេ? មានមនុស្សនិយាយ៖ ខ្ញុំអាចព្យាបាលជំងឺនេះ, ជំងឺនោះ។ ខ្ញុំប្រាប់លោកអ្នក, ជាទូទៅបែបនេះសុទ្ធតែជាមាននាំតាមកាយភ្ជាប់, លោកអ្នកដឹងរបស់អ្វីភ្ជាប់ពីក្រោយខ្លួនលោកអ្នកទេ? លោកអ្នកមានកាយភ្ជាប់, លោកអ្នកខ្លួនឯងមិនទទួលដឹងបាន, លោកអ្នកមិនដឹង, លោកអ្នកឃើញថាល្អណាស់, មានអារម្មណ៍ថាខ្លួនឯងមានអានុភាព។

គ្រូឈីគង់ពិតប្រាកដត្រូវឆ្លងកាត់ទាំងប៉ុន្មានឆ្នាំបួសដោយលំបាក, ទើបអាចសម្រេចបានគោលបំណងបែបនេះ។ ពេលដែលលោកអ្នកព្យាបាលជំងឺឲ្យគេ, លោកអ្នកសាកគិតមើលតើលោកអ្នកមានប្រភេទសីលគង់ខ្លាំងធំអាចបំបាត់អំណាចកម្មឲ្យគេឬ? លោកអ្នកធ្លាប់ទទួលបានការបង្រៀនពិតប្រាកដឬនៅ? តើលោកអ្នក៣ថ្ងៃ, ២ថ្ងៃគឺអាចព្យាបាលជំងឺ? ដៃរបស់មនុស្សសាមញ្ញលោកអ្នកអាចព្យាបាលជំងឺបានឬ? ប៉ុន្តែគ្រូឈីគង់ក្លែងក្លាយទាំងនេះគាត់ក្តាប់ជាប់ចំណុចខ្សោយរបស់លោកអ្នក, ក្តាប់ជាប់ចិត្តប្រកាន់របស់មនុស្ស, លោកអ្នកមិនមែនស្វែងរកព្យាបាលជំងឺឬ? ល្អ, គាត់បើកថ្នាក់ព្យាបាលជំងឺ, ជាពិសេសបង្រៀនលោកអ្នកជំនាញព្យាបាល។ អ្វីចាក់ម្ជុលឈី, អ្វីវិធីបញ្ចាំងពន្លឺ, រុញ{ឈី}, បំពេញ{ឈី}, អ្វីចុចស្មៀ, អ្វីសន្ទប់ចាប់, ច្រើនមុខណាស់, គោលបំណងគឺរកលុយរបស់លោកអ្នក។

ពួកយើងចូរនិយាយអំពីសន្ទប់ចាប់។ កាលៈទេសៈដែលយើងខ្ញុំមើលឃើញគឺជាបែបនេះ៖ មនុស្សហេតុអ្វីមានជំងឺ? មូលហេតុមូលដ្ឋានដែលបង្កជាគាត់មានជំងឺនិងអភ័ព្វទាំងអស់គឺជាអំណាចកម្ម, វាលអំណាចកម្មសារធាតុពណ៌ខ្មៅ។ វាគឺរបស់ស្ថិតក្នុងចរិតអវិជ្ជមាន, ស្ថិតក្នុងរបស់ដែលមិនល្អ។ ហើយកាយវិញ្ញាណមិនល្អទាំងនោះ, ក៏ជារបស់ដែលមានចរិតអវិជ្ជមាន, សុទ្ធតែជាស្ថិតក្នុង{ពណ៌}ខ្មៅ, ដូច្នេះវាអាចឡើងមក, បរិយាកាសនេះសមស្របនឹងវា។ វាជាមូលហេតុមូលដ្ឋានបណ្តាលឲ្យមនុស្សមានជំងឺ, នេះជាប្រភពចម្បងបំផុតរបស់ជំងឺ។ ប្រាកដណាស់នៅមានទម្រង់ពីរទៀត៖ មួយប្រភេទគឺកាយវិញ្ញាណតូចដ៏តូចៗតែដង់ស៊ីតេដ៏ធំ, របស់ដូចដុំអំណាចកម្មមួយ; នៅមានប្រភេទមួយទៀតគឺដូចបំពង់បញ្ជូនមក, ប្រភេទនេះតិចជួបបង្គួរ, សុទ្ធតែជាបុព្វបុរសសន្សំមក, ក៏មានកាលៈទេសៈនេះផងដែរ។

យើងខ្ញុំចូរសម្តែង{កាលៈទេសៈ}ទូទៅបំផុត, មនុស្សកន្លែងណាកើតដុំសាច់, កន្លែងណារលាក, មានបន្លាឆ្អឹងនៅកន្លែងណាជាដើម, នៅអវកាសផ្សេងជាក់ស្តែងគឺមានកាយវិញ្ញាណមួយដេកចំកន្លែងនោះ, នៅក្នុងអវកាសមួយដ៏ជ្រៅមានកាយវិញ្ញាណមួយ។ គ្រូឈីគង់ធម្មតាមើលមិនឃើញ, សីលគង់ពិសេសធម្មតាមើលមិនឃើញ, គ្រាន់តែអាចមើលឃើញរាងកាយមនុស្សមានឈីខ្មៅ។ ទីណាមានឈីខ្មៅ, ទីនោះគឺមានជំងឺ, នេះគឺនិយាយត្រូវ។ ប៉ុន្តែឈីខ្មៅមិនមែនមូលហេតុមូលដ្ឋានបង្កជាជំងឺ, គឺនៅក្នុងអវកាសមួយជ្រៅជាងមានកាយវិញ្ញាណមួយយ៉ាងនោះ, គឺវាបញ្ចេញវាលនេះ។ ដូច្នេះមានមនុស្សនិយាយរុញ{ឈី}, បញ្ចេញ{ឈី}។ លោកអ្នករុញទៅ! មិនយូរប៉ុន្មាន, វាសាងបង្កើតម្តងទៀត, មានខ្លះអំណាចធំ, ទើបត្រូវបានរុញចេញទៅម្តងទៀតទាញត្រឡប់មកវិញ,

ខ្លួនឯងអាចដកហូតមកវិញ, ធ្វើឲ្យមិនអាចព្យាបាលបាន។

តាមសីលគង់ពិសេសដើម្បីសង្កេត, ទីណាមានឈើខ្មៅ, សន្មតថាជាឈើជំងឺ; វេជ្ជសាស្ត្រចិនសង្កេតជាក់ស្ដែងគឺទីនោះខ្សែវណ្ណមិនស្រឡះ, ឈើឈាមមិនស្រឡះ, ខ្សែវណ្ណរាំងស្ទះ; ពេទ្យលោកខាងលិចសង្កេត, ជាក់ស្ដែងគឺទីនោះមានបាតុភូតមួយចំនួនដូចជាដំបៅ, ដុំសាច់, បន្លាឆ្អឹង ឬក៏គឺរលាកជាដើម, វាឆ្លុះបញ្ចាំងដល់អវកាសនេះជាក់ស្ដែងគឺជាទម្រង់នេះ។ លោកអ្នកយកវារបស់នោះចេញបាត់រួច, លោកអ្នកនឹងរកឃើញថា លើរាងកាយនៅខាងនេះសុទ្ធតែគ្មានអ្វីទៀត។ អ្វីគម្លាតឱសចង្អេះ, បន្លាឆ្អឹង, នៅពេលលោកអ្នកយករបស់នោះចេញបាត់រួច, យកវាលនោះចេញក្រៅរួច, លោកអ្នករកឃើញថាជាសះមួយរំពេច។ លោកអ្នកថតកាំរស្មី-X ឡើងវិញ, បន្លាឆ្អឹងអ្វីក៏គ្មានទៀត, មូលហេតុមូលដ្ឋានគឺដោយសាររបស់នោះផ្ដើមផលប៉ះពាល់។

មានមនុស្សនិយាយថា៣ថ្ងៃអាចព្យាបាលជំងឺ, ៥ថ្ងៃអាចព្យាបាលជំងឺ, បង្រៀនលោកអ្នករបៀបសន្ធប់ចាប់។ លោកអ្នកចាប់ឲ្យខ្ញុំមើល! មនុស្សគឺខ្សោយបំផុត, តែកាយវិញ្ញាណនោះកាចសាហាវណាស់។ វាគ្របសង្កត់ខួរធំរបស់លោកអ្នក, បង្វិលលោកអ្នកវិលៗដូចល្បែងលេង, ក៏អាចយកជីវិតលោកអ្នកយ៉ាងងាយស្រួល។ លោកអ្នកនិយាយលោកអ្នកចាប់វា, ចាប់ដូចម្ដេច? ដៃមនុស្សសាមញ្ញនេះរបស់លោកអ្នកប៉ះមិនដល់វា, លោកអ្នកនៅទីនោះកោសរញ៉េរញ៉ៃ, វាក៏មិនខ្វល់លោកអ្នក, វានៅពីក្រោយខ្នងថែមទាំងសើចលោកអ្នក, ចាប់ឡើងរញ៉េរញ៉ៃ, គួរឲ្យសើចណាស់; បើសិនលោកអ្នកពិតជាអាចប៉ះដល់វា, វានឹងធ្វើឲ្យដៃលោកអ្នករបួសមួយរំពេច, នោះគឺរបួសពិតមែន! អតីតកាលខ្ញុំធ្លាប់ឃើញមនុស្សមួយចំនួន, ដៃទាំងពីរគ្មានកើតអ្វី, ត្រួតពិនិត្យយ៉ាងណាក៏ដោយ,

រាងកាយគ្មានជំងឺ, ដៃទាំងពីរគ្មានជំងឺ, ប៉ុន្តែជាក់ស្ដែងគឺមិនលើកដៃឡើងបាន, គឺធ្លាក់ចុះយ៉ាងនេះ, អ្នកជំងឺនេះខ្ញុំក៏ធ្លាប់ជួបប្រទះ។ រាងកាយនៅអវកាសផ្សេងរបស់គាត់ត្រូវរបួសរួចហើយ, នោះពិតជាពិការរួចហើយ។ រាងកាយនោះរបស់លោកអ្នកសុទ្ធតែរបួស, នៅតែមិនពិការឬ? មានមនុស្សសួរខ្ញុំថា៖ លោកគ្រូ, តើកូនអាចហាត់គង់ឬអត់? កូនត្រូវបានវះកាត់ផ្លូវភេទរួចហើយ, ឬក៏កាត់ចោលអ្វីរួចហើយ។ ខ្ញុំនិយាយថារឿងនេះក៏គ្មានឥទ្ធិពល, រាងកាយនោះរបស់លោកអ្នកនៅអវកាសផ្សេងគ្មានត្រូវបានវះកាត់, ហើយហាត់គង់គឺរាងកាយនោះផ្ដើមផលប៉ះពាល់។ ដូច្នេះទើបខ្ញុំនិយាយ, លោកអ្នកចាប់វា, លោកអ្នកប៉ះមិនដល់វា, វាក៏មិនខ្វល់លោកអ្នក; លោកអ្នកប៉ះវាបាន, វាអាចធ្វើឲ្យដៃលោកអ្នករបួស។

ដើម្បីគាំទ្រសកម្មភាពឈីគង់ទ្រង់ទ្រាយធំរបស់ប្រទេស, ខ្ញុំនៅប៉េកាំងនាំតាមសិស្សមួយចំនួនចូលរួមពិព័រណ៍សុខភាពបូព៌ា។ នៅពីរលើកពិព័រណ៍យើងខ្ញុំសុទ្ធតែជាលេចធ្លោបំផុត។ ពិព័រណ៍លើកទីមួយហ្វាលូនតាហ្វាយើងខ្ញុំត្រូវបានទទួលស្គាល់ជាតារាគង់ហ្វា; ពិព័រណ៍លើកទីពីរមនុស្សច្រើនពេកសុទ្ធសាធមិនដឹងធ្វើយ៉ាងណា។ តូបតាំងផ្សេងៗគ្មានមនុស្សប៉ុន្មាន, ហើយតូបតាំងរបស់យើងខ្ញុំប្រមូលផ្ដុំខ្នាន់ខ្នាប់ព័ទ្ធជុំវិញ។ រៀបជាបីជួរ, ជួរទីមួយពីព្រលឹមគឺចុះឈ្មោះអស់ដល់ថ្ងៃត្រង់; ជួរទីពីររង់ចាំចុះឈ្មោះឲ្យថ្ងៃរសៀល; មួយជួរទៀតរង់ចាំខ្ញុំស៊ីញ៉េឈ្មោះឱ្យ។ យើងខ្ញុំមិនព្យាបាលជំងឺ, ហេតុអ្វីធ្វើរឿងនេះ? ដោយសារនេះគឺគាំទ្រសកម្មភាពឈីគង់ទ្រង់ទ្រាយធំរបស់ប្រទេស, ដើម្បីរួមចំណែកដល់បុព្វហេតុនេះ, ដូច្នេះយើងខ្ញុំចូលរួម។

ខ្ញុំយកគង់បែងចែកឲ្យសិស្សដែលខ្ញុំនាំតាម, ម្នាក់មួយចំណែក, សុទ្ធតែជាគ្រាប់ថាមពលដែលត្រូវបានរួបរួមពីជាងមួយរយប្រភេទសីល

គង់។ សុទ្ធតែយកដៃរបស់ពួកគាត់បាំងមកវិញ, ជាក់ស្តែងគឺជាបែបនេះ, មានដៃខ្លះនៅតែត្រូវខាំដាច់, ខាំឡើងពង, ខាំឡើងចេញឈាម, នោះនៅតែលេចឡើងជារឿយៗ។ របស់នោះសុទ្ធតែកាចសាហាវយ៉ាងនោះ, តើលោកអ្នកគិតថាដៃមនុស្សសាមញ្ញរបស់លោកអ្នកហ៊ានប៉ះដល់វា? ថែមទៀតលោកអ្នកក៏ចាប់វាមិនបាន, គ្មានប្រភេទសីលគង់នោះក៏មិនធ្វើអ្វីបាន។ ដោយសារនៅអវកាសផ្សេងលោកអ្នកចង់ធ្វើអ្វី, ក្បាលលោកអ្នកគិតកាលណាវានឹងដឹង, លោកអ្នកចង់ចាប់វា, វាគឺរត់តាំងពីយូរ។ រង់ចាំអ្នកជំងឺចេញពីទ្វារពេលណា, ជាបន្ទាន់វាក៏ឡើងទៅ, ជំងឺកើតឡើងវិញម្តងទៀត។ ចង់កម្រើកដៃព្យាបាលវាត្រូវមានប្រភេទសីលគង់មួយយ៉ាងនេះ, លាតដៃកាលណា [ផាំង] គឺនឹងនៅទីនោះ។ នឹងជាប់ហើយ, ពួកយើងនៅមានប្រភេទសីលគង់មួយទៀត, អតីតកាលហៅថាមហាធម៌ខាបព្រលឹង, ប្រភេទសីលគង់នោះកាន់តែអស្ចារ្យ, អាចយកវិញ្ញាណដើមទាំងមូលរបស់មនុស្សទាញចេញក្រៅ, ឯកជននោះជាបន្ទាន់គឺនឹងមិនកម្រើកបាន។ សីលគង់នេះមានចរិតតម្រង់ចំ, យើងខ្ញុំជាក់ស្តែងគឺតម្រង់ចំរបស់នេះដើម្បីចាប់។ អ្នករាល់គ្នាដឹង, បាត្រនោះក្នុងដៃព្រះពុទ្ធយូឡាយ, បញ្ចាំងមួយភ្លាម, លោកអ្នកឃើញស៊ុនអ៊ូខុងធំយ៉ាងនោះ, ភ្លាមៗប្រែក្លាយជាចំណុចមួយតូច។ សីលគង់នេះគឺអាចផ្តើមបានផលប៉ះពាល់យ៉ាងនោះ។ មិនខ្វល់កាយវិញ្ញាណធំប៉ុណ្ណា, មិនខ្វល់កាយវិញ្ញាណតូចប៉ុណ្ណា, ភ្លាមៗសន្ទប់ចាប់ជាប់ក្នុងដៃ, គឺក្លាយជាដ៏តូច។

ក្រៅពីនេះ, និយាយថាលាតដៃចូលទៅក្នុងរាងកាយសាច់របស់អ្នកជំងឺ, ហើយចាប់យកចេញ, នោះមិនបានទេ។ នោះនឹងធ្វើឲ្យផ្ទត់គំនិតមនុស្សនៃសង្គមមនុស្សសាមញ្ញរញ៉េរញ៉ៃអស់, ជាមូលដ្ឋានគឺមិនអនុញ្ញាតធ្វើបែបនេះ, អាចធ្វើក៏មិនអាចធ្វើយ៉ាងនេះ។ គាត់លាតចូលទៅក្នុង

គឺជាដៃនៅអវកាសផ្សេង។ ឧបមាថាបេះដូងរបស់គាត់មានជំងឺ, ពេលដែលដៃនេះសំដៅចូលទីតាំងបេះដូងដើម្បីសន្ទប់, ដៃនោះនៅអវកាសផ្សេងចូលទៅក្នុង។ មួយប៉ប្រិចភ្នែក, លឿនខ្លាំងណាស់ចាប់ជាប់រួចហើយ, ដៃខាងក្រៅរបស់លោកអ្នកចាប់រួច, ដៃទាំងពីររួមចូលគ្នាតែមួយ, គឺចាប់នៅក្នុងដៃ។ វាកាចសាហាវណាស់, មានពេលខ្លះចាប់កម្រើកនៅក្នុងដៃ, ដាល់ចូលក្នុង, ពេលខ្លះខាំ, ពេលខ្លះស្រែកទៀតផង។ លោកអ្នកឃើញឱបនៅក្នុងដៃតូចយ៉ាងនោះ, បើកដៃចេញគឺប្រែក្លាយជាដ៏ធំ។ នេះមិនមែនប្រការនរណាក៏អាចប៉ះបាន, គ្មានប្រភេទសីលគង់នោះជាមូលដ្ឋានគឺប៉ះមិនបាន, ជាមូលដ្ឋានមិនសាមញ្ញយ៉ាងនោះដូចដែលពួកយើងស្រមៃ។

ប្រាកដណាស់អនាគតទម្រង់ឈីគង់ព្យាបាលជំងឺនេះ, ក៏អាចអនុញ្ញាតឲ្យវាស្ថិតនៅ, អតីតកាលក៏តែងតែស្ថិតនៅ។ តែចាំបាច់គឺមានលក្ខខណ្ឌ, ឯកជននេះចាំបាច់គឺជាមនុស្សបួសហាត់, នៅក្នុងដំណើរការបួសហាត់គាត់ផុសពីចិត្តមេត្តា, គាត់ធ្វើរឿងរ៉ាវបែបនេះឲ្យមនុស្សល្អភាគតិចអាចបាន។ ប៉ុន្តែគាត់មិនអាចលុបបំបាត់កម្មនេះឲ្យគេទាំងស្រុង, អធិកភាពគុណធម៌គាត់មិនគ្រប់, ដូច្នេះគ្រោះនៅតែមាន, គ្រាន់តែជំងឺពិស្ដារជាសះប៉ុណ្ណោះ។ គ្រូឈីគង់តូចធម្មតាគាត់មិនមែនមនុស្សបួសហាត់សម្រេចតាវ, គាត់គ្រាន់តែអាចរុញទៅក្រោយឲ្យគេ; ក៏អាចបំប្លែងឲ្យ, ក៏អាចបំប្លែងក្លាយជាគ្រោះមហន្តរាយផ្សេង។ ទោះយ៉ាងណាខ្លួនគាត់អាចមិនដឹងដំណើរការរុញទៅក្រោយ, បើសិនគង់ហ្វាបួសហាត់គឺជាសតិរង, គឺសតិរងរបស់គាត់ធ្វើ។ មានមនុស្សហាត់គង់នៃគង់ហ្វាមួយចំនួនហាក់ដូចជាដ៏ល្បីល្បាញ, គ្រូធំឈីគង់ដ៏ល្បីល្បាញជាច្រើនតែគាត់គ្មានគង់, គង់សុទ្ធតែនៅលើខ្លួនវិញ្ញាណដើមរង។ ក៏មានន័យថានៅក្នុង

ដំណើរកាបួសហាត់អនុញ្ញាតឲ្យធ្វើបែបនេះ, ដោយសារមានមនុស្សមួយចំនួនរក្សាបន្តនៅក្នុងជាន់ថ្នាក់នេះ, ហាត់កាលណាជាក់ស្តែងគឺជាង១០ឆ្នាំ, រាប់សិបឆ្នាំចេញមិនផុតជាន់ថ្នាក់នេះ, ដូច្នេះមួយជីវិតរបស់គាត់នៅតែរមែងពិនិត្យជំងឺឲ្យគេ។ ដោយសារគាត់នៅក្នុងជាន់ថ្នាក់នេះ, ក៏ជាអនុញ្ញាតឲ្យគាត់ធ្វើបែបនេះ។ សិស្សបួសហាត់ហ្វាលូនតាហ្វាជាដាច់ខាតមិនអាចពិនិត្យជំងឺ។ អានឲ្យអ្នកជំងឺសៀវភៅនេះ, បើអ្នកជំងឺអាចទទួលយក, អាចព្យាបាលជំងឺ, ទោះយ៉ាងណាចំពោះមនុស្សមានអំណាចកម្មធំតូចខុសគ្នាលទ្ធផលក៏មិនដូចគ្នា។

## ព្យាបាលជំងឺនៅមន្ទីរពេទ្យនិងព្យាបាលជំងឺដោយឈើគង់

យើងខ្ញុំសម្តែងបន្តិចអំពីបញ្ហាទំនាក់ទំនងរវាងព្យាបាលជំងឺនៅមន្ទីរពេទ្យនិងព្យាបាលជំងឺដោយឈើគង់។ មានវេជ្ជបណ្ឌិតលោកខាងលិចមួយចំនួនមិនទទួលស្គាល់ឈើគង់, នេះអាចនិយាយជាភាគច្រើន។ របៀបនិយាយរបស់គាត់គឺឈើគង់អាចពិនិត្យជំងឺ, នៅត្រូវការមន្ទីរពេទ្យយើងខ្ញុំធ្វើអីទៀត? ពួកលោកជំនួសមន្ទីរពេទ្យរបស់យើងខ្ញុំតែម្តងទៅ! ឈើគង់ពួកលោកប៉ះដៃគឺអាចព្យាបាលជំងឺនេះជា, ក៏មិនចាំបាច់ចាក់ថ្នាំ, លេបថ្នាំ, ចូលមន្ទីរពេទ្យ, ជំនួសមន្ទីរពេទ្យរបស់យើងខ្ញុំល្អប៉ុណ្ណា? ពាក្យនេះនិយាយដ៏មិនសមគោលសីលធម៌, ដ៏មិនសមហេតុផល។ មានមនុស្សមិនយល់ច្បាស់ឈើគង់, ធាតុពិតទៅ, ពិនិត្យជំងឺដោយឈើគង់មិនអាចដូចវិធីសាស្ត្រព្យាបាលក្នុងមនុស្សសាមញ្ញ, វាមិនមែនថ្វីដៃក្នុងមនុស្សសាមញ្ញ, វាជាប្រការវិសាមញ្ញ។ ដូច្នោះប្រការវិសាមញ្ញប្រសិនជ្រៀតជ្រែកសង្គមមនុស្សសាមញ្ញទ្រង់ទ្រាយធំ, នោះអាចអនុញ្ញាតឬ? ព្រះពុទ្ធអានុភាពធំប៉ុណ្ណា, ព្រះពុទ្ធមួយអង្គគ្រវាសដៃមួយភ្លាម, ជំងឺរបស់មនុស្សជាតិទាំងអស់នឹងមិនស្ថិតនៅទៀត។ គាត់ហេតុអ្វីមិនធ្វើហ្ន៎?

ម្យ៉ាងទៀតព្រះពុទ្ធច្រើនយ៉ាងនោះ, ហេតុអ្វីគាត់មិនផុសចេញចិត្តមេត្តាទុកឲ្យជំងឺលោកអ្នកជា? ដោយសារសង្គមមនុស្សសាមញ្ញជាក់ស្តែងគឺជាបែបនេះ, កើតចាស់ឈឺស្លាប់ជាក់ស្តែងគឺជាស្ថានភាពនេះ, សុទ្ធតែជាមានទំនាក់ទំនងកម្មផល, សុទ្ធតែជាបង្វិលកម្មផល, បំណុលលោកអ្នកជំពាក់គឺត្រូវតែសង។

ប្រសិនលោកអ្នកព្យាបាលជំងឺឲ្យគាត់ជា, គឺស្មើនឹងបំផ្លាញគោលសីលធម៌នោះ, សុទ្ធតែអាចធ្វើរឿងអាក្រក់, មិនចាំបាច់សង, នោះអាចបានឬ? មនុស្សនៅក្នុងបួសហាត់ផុសពីចិត្តមេត្តា, ពេលដែលលោកអ្នកមិនទាន់មានអំណាចធំយ៉ាងនោះអាចដោះស្រាយបញ្ហានេះទាំងស្រុង, អនុញ្ញាតឲ្យលោកអ្នកពិនិត្យជំងឺ, ដោយសារលោកអ្នកផុសចេញចិត្តមេត្តារួចហើយ, អនុញ្ញាតឲ្យធ្វើបែបនេះ។ ប៉ុន្តែបើសិនលោកអ្នកពិតប្រាកដអាចដោះស្រាយបញ្ហាបែបនេះ, ដោះស្រាយលើទ្រង់ទ្រាយធំនោះគឺមិនបាន។ នោះលោកអ្នកគឺបំផ្លាញធ្ងន់ធ្ងរស្ថានភាពសង្គមមនុស្សសាមញ្ញ, គឺមិនអនុញ្ញាត។ ដូច្នេះឈីគង់ជំនួសឲ្យមន្ទីរពេទ្យរបស់មនុស្សសាមញ្ញជាមូលដ្ឋានគឺមិនបាន, វាជាធម៌ក្នុងទីវិសាមញ្ញ។

ប្រសិននៅប្រទេសចិនទីនេះធ្វើចេញមន្ទីរពេទ្យឈីគង់, ឧបមាអនុញ្ញាតឲ្យធ្វើយ៉ាងនេះ, គ្រូធំឈីគង់សុទ្ធតែចេញមកធ្វើ, លោកអ្នកមើលសាកមើលគឺជាបែបណា? មិនអនុញ្ញាតឲ្យធ្វើបែបនេះ, ដោយសារនៅតែរក្សាស្ថានភាពនេះរបស់សង្គមមនុស្សសាមញ្ញ។ ប្រសិនបើកចេញមន្ទីរពេទ្យឈីគង់, បើកចេញគ្លីនិកឈីគង់, មណ្ឌលស្តារនីតិសម្បទា, រមណីយដ្ឋានសុខភាព, បើកចេញហើយកាលណា, ព្យាបាលជំងឺរបស់គ្រូឈីគង់នោះនឹងដួលរលំភ្លាមៗ, ប្រសិទ្ធភាពព្យាបាលជាបន្ទាន់នឹងមិនបានទៀត។ ហេតុអ្វី? ដោយសារគាត់ធ្វើប្រការនេះក្នុងមនុស្សសាមញ្ញ,

គឺចាំបាច់ត្រូវខ្ពស់ដូចធម៌របស់មនុស្សសាមញ្ញ, ស្ថិតក្នុងជាន់ថ្នាក់តែមួយនឹងស្ថានភាពរបស់មនុស្សសាមញ្ញ, ប្រសិទ្ធភាពព្យាបាលរបស់វាត្រូវតែដូចគ្នានឹងមន្ទីរពេទ្យ។ ដូច្នេះព្យាបាលជំងឺគឺមិនបាន, គាត់ក៏សម្តែងចេញព្យាបាលជំងឺអ្វីត្រូវការមានប៉ុន្មានវគ្គព្យាបាល, ជាញឹកញាប់សុទ្ធតែជាបែបនេះ។

ឈីគង់មិនខ្វល់វាបើកមន្ទីរពេទ្យក៏ដោយ, មិនបើកមន្ទីរពេទ្យក៏ដោយ, ឈីគង់អាចព្យាបាលជំងឺចំណុចមួយនេះគឺនរណាក៏មិនបដិសេធបាន។ ឈីគង់នៅលើសង្គមជាសកលពេលវេលាយូរយ៉ាងនេះ, មានមនុស្សប៉ុន្មាននាក់តាមរយៈហាត់គង់បានមែនទែនសម្រេចបានគោលបំណងព្យាបាលជំងឺកាយសម្បទា។ ទោះបីគាត់គឺត្រូវបានគ្រូឈីគង់ពន្យាជំងឺក៏ដោយ, ដូចម្តេចក៏ដោយ, យ៉ាងណាក្តីជំងឺនោះឥឡូវគឺគ្មានទៀត, ក៏មានន័យថាឈីគង់អាចព្យាបាលជំងឺគឺនរណាក៏មិនបដិសេធ។ ភាគច្រើនរកគ្រូឈីគង់ពិនិត្យជំងឺ, សុទ្ធតែស្ថិតក្នុងជំងឺពិបាកស្មុគស្មាញ, គឺដល់មន្ទីរពេទ្យមើលមិនជា, ទើបរកគ្រូឈីគង់ទីនោះផ្សងមហាសំណាង, លទ្ធផលព្យាបាលជា។ អាចព្យាបាលជានៅមន្ទីរពេទ្យក៏មិនរកដល់គ្រូឈីគង់, ជាពិសេសនៅពេលចាប់ផ្តើម, គេសុទ្ធតែយល់ដឹងបែបនេះ, ដូច្នេះឈីគង់គឺអាចពិនិត្យជំងឺ។ វាហួសពេកគ្រាន់តែមិនអាចទៅធ្វើដូចរឿងរ៉ាវផ្សេងបែបនោះក្នុងមនុស្សសាមញ្ញ។ ពាក់ព័ន្ធលើទ្រង់ទ្រាយធំគឺដាច់ខាតមិនអនុញ្ញាត, ទ្រង់ទ្រាយតូចឬក៏គ្មានឥទ្ធិពលអ្វីធំពេក, ធ្វើដោយស្ងាត់ៗអាចអនុញ្ញាត, តែមិនអាចធ្វើឲ្យជំងឺជាសះទាំងស្រុង, ក៏ជាបញ្ជាក់។ ខ្លួនឯងប្រើឈីគង់ហ្វឹកហាត់ព្យាបាលជំងឺល្អបំផុត។

ក៏មានគ្រូឈីគង់ខ្លះសម្តែង៖ មន្ទីរពេទ្យព្យាបាលជំងឺមិនបាន, មន្ទីរពេទ្យបច្ចុប្បន្នប្រសិទ្ធភាពព្យាបាលយ៉ាងនេះយ៉ាងនោះ។ ពួកយើងនិយា

យដូចម្ដេច? ប្រាកដណាស់វាមានមូលហេតុច្រើនទិដ្ឋភាព។ ចម្បងបំផុតខ្ញុំឃើញថានៅតែជាកម្រិតសីលធម៌របស់មនុស្សជាតិចុះទាប, បង្កជាជំងឺដ៏ចម្លែកគ្រប់ប្រភេទ, មន្ទីរពេទ្យព្យាបាលមិនជា, លេបថ្នាំក៏មិនដំណើរការ, ថ្នាំក្លែងក្លាយក៏ច្រើន, សុទ្ធតែជាដោយសារសង្គមមនុស្សជាតិពុករលួយដល់កម្រិតនេះ។ មនុស្សម្នាក់ៗក៏កុំបន្ទោសអ្នកដទៃ, នរណាក៏សុទ្ធតែផ្ដើមផលប៉ះពាល់បន្ថែមរលកទៅជាព្យុះ, ដូច្នេះនរណាបួសហាត់ក៏នឹងជួបប្រទះគ្រោះទុក្ខ។

មន្ទីរពេទ្យមានជំងឺខ្លះត្រួតពិនិត្យមិនចេញ, ប៉ុន្តែមែនទែនមានជំងឺ។ មានមនុស្សខ្លះត្រួតពិនិត្យចេញមកជំងឺ, ក៏មិនដឹងហៅថាឈ្មោះអ្វី, សុទ្ធតែជំងឺមិនដែលជួបពីមុន, មន្ទីរពេទ្យហៅរួមថា [ជំងឺទំនើប]។ មន្ទីរពេទ្យអាចព្យាបាលជំងឺឬអត់? ប្រាកដណាស់អាច។ បើសិនមន្ទីរពេទ្យព្យាបាលជំងឺមិនបាន, គេហេតុម្ដេចក៏ជឿ, ហេតុម្ដេចក៏ទៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺ។ មន្ទីរពេទ្យនៅតែអាចព្យាបាលជំងឺ, គ្រាន់តែបច្ចេកទេសព្យាបាលរបស់វាគឺនៅជាន់ថ្នាក់នោះរបស់មនុស្សសាមញ្ញ, ហើយផ្ទុយមកវិញជំងឺនោះគឺជាវិសាមញ្ញ, មានជំងឺមួយចំនួនគឺធំណាស់។ ដូច្នេះមន្ទីរពេទ្យសម្ដែងថាមានជំងឺចាំបាច់ឆាប់ព្យាបាល, ធ្ងន់ពេកគាត់ក៏ព្យាបាលមិនបាន, បរិមាណថ្នាំច្រើនមនុស្សក៏នឹងត្រូវបំពុល។ កម្រិតព្យាបាលនៃវេជ្ជសាស្ត្របច្ចុប្បន្ននិងកម្រិតបច្ចេកវិទ្យារបស់ពួកយើងគឺដូចគ្នា, សុទ្ធតែស្ថិតនៅក្នុងមួយជាន់ថ្នាក់នេះរបស់មនុស្សសាមញ្ញ, ដូច្នេះវាគ្រាន់តែជាប្រសិទ្ធភាពព្យាបាលបែបនេះ។ មានបញ្ហាមួយត្រូវការនិយាយច្បាស់, ព្យាបាលជំងឺដោយឈីគង់ធម្មតានិងព្យាបាលជំងឺនៅមន្ទីរពេទ្យ, នោះគឺយកគ្រោះមូលហេតុមូលដ្ឋានបង្កជាមានជំងឺរុញថយទៅក្រោយ, រុញដល់ពាក់កណ្ដាលជីវិតក្រោយឬក៏ក្រោយមក, ជាមូលដ្ឋានគ្មានប៉ះដល់

អំណាចកម្ម។

ពួកយើងសម្តែងបន្តិចអំពីវេជ្ជសាស្ត្រចិនម្តងទៀត។ ព្យាបាលជំងឺរបស់វេជ្ជសាស្ត្រចិនដ៏ជិតស្និទ្ធនឹងព្យាបាលជំងឺរបស់ឈីគង់។ នៅប្រទេសចិនបុរាណ, គ្រូពេទ្យវេជ្ជសាស្ត្រចិនជាមូលដ្ឋានសុទ្ធតែជាមានសីលគង់ពិសេស, ដូចជាស៊ុនស៊ីមៀវ, ហ័រធួរ, លីស៊ីចិ្ចន, ពានឈ្វោជាដើមអ្នកវេជ្ជសាស្ត្រធំទាំងនេះ, សុទ្ធតែជាមានសីលគង់ពិសេស, នៅក្នុងសៀវភៅវេជ្ជសាស្ត្រសុទ្ធតែមានកត់ត្រា។ ប៉ុន្តែជាញឹកញាប់ប្រការសារៈទាំងនេះបច្ចុប្បន្នគឺទទួលរងការរិះគន់, មរតកវេជ្ជសាស្ត្រចិនហួសពេកគ្រាន់តែជាវេជ្ជបញ្ជាទាំងនោះ, ឬក៏ជាការស្វែងយល់បទពិសោធន៍ប៉ុណ្ណោះ។ វេជ្ជសាស្ត្រចិននៃប្រទេសចិនបុរាណគឺដ៏រីកចម្រើន, កម្រិតរីកចម្រើនលើសផុតពីវេជ្ជសាស្ត្របច្ចុប្បន្ន។ មានមនុស្សគិតថា, វេជ្ជសាស្ត្របច្ចុប្បន្នរីកចម្រើនច្រើន, ថតCTអាចមើលឃើញខាងក្នុងរាងកាយរបស់មនុស្ស, ធ្វើអេកូ, ថតរូប, ថតកាំរស្មី-X។ ឧបករណ៍ទំនើបគឺជឿនលឿនណាស់, តាមខ្ញុំឃើញក៏មិនស្មើវេជ្ជសាស្ត្រនៃប្រទេសចិនបុរាណ។

ហ័រធួរមើលឃើញក្នុងខួររបស់ឆាវឆាវមានដុំសាច់, ចង់បើកលលាដ៍ធ្វើការវះកាត់យកដុំសាច់។ ឆាវឆាវស្តាប់កាលណាសន្មតថាហ័រធួរចង់យកក្បាលរបស់គាត់, បានចាប់ហ័រធួរដាក់ឃុំឃាំង, លទ្ធផលហ័រធួរស្លាប់នៅក្នុងគុក។ ពេលដែលឆាវឆាវកំពុងកើតជំងឺ, នឹកដល់ហ័រធួរ, រកហ័រធួរ, ហ័រធួរបានស្លាប់រួចហើយ។ ក្រោយមកឆាវឆាវពិតជាកើតជំងឺនេះស្លាប់។ ហ័រធួរហេតុអ្វីដឹងបាន? គាត់បានមើលឃើញ, នេះគឺជាសីលគង់ពិសេសរបស់មនុស្សពួកយើង, អ្នកវេជ្ជសាស្ត្រធំៗអតីតកាលសុទ្ធតែមានគ្រប់គ្រាន់អានុភាពនេះ។ ក្រោយពីភ្នែកទិព្វបើករួចហើយ, នៅលើមុខម្ខាងអាចក្នុងពេលតែមួយមើលឃើញទាំងបួនមុខរបស់រាងកាយមនុ

ស្ស, ពីមុខខាងមុខអាចមើលឃើញមុខខាងក្រោយ, មុខខាងឆ្វេងមុខខាងស្ដាំ; នៅអាចមើលឃើញមុខកាត់នៃជាន់នីមួយៗ; នៅអាចឆ្លងធ្លុះអវកាសនេះដើម្បីមើលឃើញមូលហេតុមូលដ្ឋានរបស់ជំងឺជាអ្វី។ បច្ចេកទេសព្យាបាលបច្ចុប្បន្នអាចសម្រេចបានឬ? ខុសឆ្ងាយខ្លាំងណាស់, កន្លងថែមមួយពាន់ឆ្នាំទៀត! CT, អេកូ, កាំរស្មី-Xក៏អាចមើលឃើញខាងក្នុងរាងកាយរបស់មនុស្ស, ប៉ុន្តែម៉ាស៊ីនធំណាស់, របស់ធំនោះក៏មិនអាចនាំតាមខ្លួនបាន, គ្មានអគ្គិសនីក៏មិនបាន។ ហើយភ្នែកទិព្វនេះដើរដល់ណានាំតាមដល់នោះ, ក៏មិនប្រើថាមពល, ធ្វើម្ដេចអាចប្រៀបបាន។

មានមនុស្សសម្ដែងថ្នាំឥឡូវយ៉ាងនេះយ៉ាងនោះ។ ខ្ញុំថាមិនប្រាកដដូច្នោះ, ថ្នាំស្មៅទាំងនោះរបស់ប្រទេសចិនបុរាណពិតជាអាចថ្នាំចូលជំងឺបាត់។ មានប្រការដ៏ច្រើនមិនបានបន្សល់ទុក; មានដ៏ច្រើនមិនត្រូវបានបាត់បង់, កំពុងផ្សព្វផ្សាយក្នុងសាធារណជន, ពេលខ្ញុំបើកថ្នាក់នៅឈីឈីហាអឿ, មើលឃើញមានមនុស្សម្នាក់រៀបតូបតាមផ្លូវដកធ្មេញឲ្យគេ។ មើលភ្លាមមនុស្សនេះជាក់ស្ដែងគឺមកពីភាគខាងត្បូង, សម្លៀកបំពាក់មិនដូចមនុស្សភាគឦសាន។ នរណាមកក៏មិនបដិសេធ, នរណាមកគាត់ក៏ដកឲ្យ, ធ្មេញដកចេញដាក់មួយគំនរយ៉ាងនោះ។ គាត់ដកធ្មេញឲ្យគេមិនមែនជាគោលបំណង, គោលបំណងគឺលក់ទឹកថ្នាំរបស់គាត់។ ទឹកថ្នាំនោះបញ្ចេញផ្សែងលឿងដ៏ខ្លាំង។ ពេលដកធ្មេញ, បើកគម្របដបទឹកថ្នាំចេញ, ពីខាងក្រៅដាក់លើថ្ពាល់ថ្គាមសំដៅទៅធ្មេញដែលត្រូវខូច, ហៅគេហិតចូលផ្សែងទឹកថ្នាំពណ៌លឿង, ទឹកថ្នាំក៏គ្មានស្រកបាត់បន្តិចណា, មួលគម្របវិញដាក់នៅទីនោះ។ ពីក្នុងថង់ស្ពាយៗយកចេញឈើគូសមួយដើម, និយាយអំពីថ្នាំរបស់គាត់ផង, កាន់ឈើគូសសំដៅធ្មេញចុចមួយផង, ធ្មេញគឺធ្លាក់ចុះ, ក៏មិនឈឺ, ជាប់បន្តិចឈាម, ក៏មិនចេញឈាម។

អ្នករាល់គ្នាគិត, ឈើគូសបើសិនប្រើកម្លាំងខ្លាំងបន្តិចអាចបាក់ភ្លាម, ផ្ទុយមកវិញគាត់ប្រើឈើគូសចុចភ្លាមគឺដកបានធ្មេញ។

ខ្ញុំនិយាយថាប្រទេសចិនមានប្រការមួយចំនួនកំពុងផ្សព្វផ្សាយក្នុងសាធារណជន, ហើយឧបករណ៍ភាពជាក់លាក់របស់វេជ្ជសាស្ត្រលោកខាងលិចគឺមិនស្មើគាត់, មើលប្រសិទ្ធភាពនរណាល្អ, ឈើគូសរបស់គាត់ចុចភ្លាមធ្លាក់ចុះមក។ វេជ្ជសាស្ត្រលោកខាងលិចដកធ្មេញមុនដំបូងចាក់ថ្នាំស្ពឹក, ចាក់ខាងនេះ, ចាក់ខាងនោះ, ម្ជុលចាក់ក៏ឈឺណាស់ផងដែរ, រង់ចាំថ្នាំស្ពឹកដំណើរការហើយ, យកដែកកៀបដើម្បីដក។ ដកកន្លះថ្ងៃធ្វើមិនល្អជើងធ្មេញក៏បាក់នៅខាងក្នុង។ កាន់ពូថៅ, កាន់ដាប់ឆ្លោះចុះក្រោមភ្លះ, បុកដល់ថ្នាក់ភ័យខ្លាចជ្រួលជ្រើម, ម្ដងទៀតប្រើឧបករណ៍ភាពជាក់លាក់ស្វានឲ្យលោកអ្នក។ មនុស្សខ្លះស្វានដល់ថ្នាក់ចង់ឈរត្រង់ឡើង, ឈឺណាស់, ចេញឈាមមិនតិច, ស្ដោះចេញឈាមពេញមួយមាត់។ លោកអ្នកនិយាយរបស់នរណាល្អ? លោកអ្នកនិយាយរបស់នរណាជឿនលឿន, ពួកយើងមិនអាចមើលតែឧបករណ៍ខាងក្រៅ, ត្រូវមើលប្រសិទ្ធភាពពិតរបស់វា។ វេជ្ជសាស្ត្រចិននៃប្រទេសចិនបុរាណដ៏រីកចម្រើន, វេជ្ជសាស្ត្រលោកខាងលិចកន្លងប៉ុន្មានឆ្នាំទៀតក៏តាមមិនទាន់។

វិទ្យាសាស្ត្រប្រទេសចិនបុរាណនិងវិទ្យាសាស្ត្រទំនើបដែលពួកយើងរៀនមកពីភាគខាងលិចមិនដូចគ្នា, វាដើរតាមផ្លូវមួយផ្សេង, អាចនាំមកប្រភេទស្ថានភាពមួយផ្សេង។ ដូច្នេះមិនអាចប្រើវិធីសាស្ត្រយល់ដឹងនេះបច្ចុប្បន្នរបស់ពួកយើងដើម្បីយល់ដឹងបច្ចេកវិទ្យានៃប្រទេសចិនបុរាណ, ដោយសារវិទ្យាសាស្ត្រនៃប្រទេសចិនបុរាណគឺតម្រង់ចំរាងកាយមនុស្ស, ជីវិត, ចក្រវាល, ដោយផ្ទាល់សំដៅលើប្រការនេះដើម្បីស្រាវជ្រាវ, ដូច្នេះដើរតាមផ្លូវមួយផ្សេង។ ពេលនោះមនុស្សទៅរៀន, សុទ្ធតែត្រូវការយកចិត្ត

ទុកដាក់អង្គុយសមាធិ, អង្គុយត្រូវការសម្តែងឥរិយាបថ, កាន់ជក់ទ្បើង ត្រូវការសម្តែងផ្លាស់ទីឈើដកដង្ហើម, គ្រប់មុខគ្រប់របរសុទ្ធតែសម្តែងស្ងប់ចិត្ត, សម្រួលដង្ហើម, សង្គមទាំងមូលសុទ្ធតែស្ថិតក្នុងស្ថានភាពមួយយ៉ាងនេះ។

មានមនុស្សសម្តែងថា៖ យោងតាមបច្ចេកវិទ្យាប្រទេសចិនបុរាណដើម្បីដើរ, អាចមានរថយន្ត, រថភ្លើងថ្ងៃនេះឬ? អាចមានទំនើបកម្មថ្ងៃនេះឬ? ខ្ញុំនិយាយថាលោកអ្នកមិនអាចឈរនៅក្នុងបរិយាកាសនេះដើម្បីយល់ដឹងស្ថានភាពផ្សេងបានទេ, គោលគំនិតមនោគតិរបស់លោកអ្នកត្រូវតែកើតទ្បើងការបដិវត្តន៍។ គ្មានទូរទស្សន៍, ខាងមុខក្បាលមនុស្សខ្លួនឯងបាននាំតាម, ចង់មើលអីគឺមើលនោះ, ក៏មានសីលគង់ស្ថិតនៅផងដែរ។ គ្មានរថភ្លើង, រថយន្ត, មនុស្សអង្គុយនៅទីនោះគឺអណ្តែតទ្បើងបាន, ជណ្តើរយន្តក៏មិនត្រូវការទៀត។ វានឹងនាំមកស្ថានភាពអភិវឌ្ឍន៍ផ្សេងរបស់សង្គម, មិនជាក់លាក់កំហិតតែនៅខាងក្នុងពុម្ពនេះ។ យានអវកាសរបស់មនុស្សក្រៅភពទៅមកយ៉ាងឆាប់រហ័ស, អាចធំអាចតូច។ ពួកវាដើរតាមផ្លូវអភិវឌ្ឍន៍ខុសជាងទៀត, គឺជាប្រភេទវិធីវិទ្យាសាស្ត្រមួយផ្សេង។

# មេសម្តែងទី៨

## ពីគូ

មានមនុស្សនិយាយដល់បញ្ហាពីគូ។ បាតុភូតពីគូនេះគឺស្ថិតនៅ, មិនត្រឹមតែមាននៅពិភពបួសហាត់, នៅក្នុងសង្គមមនុស្សជាតិទាំងមូលពួកយើងក៏មានមិនតិចមនុស្សលេចឡើងប្រភេទកាលៈទេសៈនេះ។ មានមនុស្សរាប់ឆ្នាំឬក៏រាប់សិបឆ្នាំមិនញ៉ាំមិនផឹក, តែផ្ទុយមកវិញរស់នៅដ៏ល្អ។ មានមនុស្សនិយាយពីគូគឺជាការបង្ហាញក្នុងមួយជាន់ថ្នាក់ណាមួយ; ក៏មានមនុស្សនិយាយពីគូគឺជាការបង្ហាញរបស់បន្សុទ្ធរាងកាយ; ក៏មានមនុស្សនិយាយវាគឺជាដំណើរការបួសហាត់ក្នុងជាន់ថ្នាក់ខ្ពស់។

ភាពពិតសុទ្ធតែមិនត្រូវ។ ដូច្នោះវាជារឿងដូចម្តេច? តាមពិតទៅពីគូជាក់ស្តែងគឺជាវិធីសាស្រ្តបួសហាត់ពិសេសមួយដែលពួកយើងជ្រើសប្រើនៅក្រោមបរិយាកាសពិសេសជាក់លាក់។ ក្រោមបរិយាកាសពិសេសជាក់លាក់យ៉ាងណាជ្រើសប្រើវា? នៅប្រទេសចិនបុរាណ, ជាពិសេសនៅមុនពេលដែលសាសនានៅមិនទាន់បង្កើត, មានមនុស្សបួសហាត់ជាច្រើនសុទ្ធតែជាជ្រើសប្រើបែបវិធីបួសសម្ងាត់, បួសឯកតាបែបនេះ, ចូលទៅក្នុងភ្នំជ្រៅឬក៏លូនចូលក្នុងរូងភ្នំដើម្បីបួស, ឃ្លាតឆ្ងាយទីលំនៅរបស់មនុស្ស។ កាលណាធ្វើបែបនេះ, ដូច្នោះគឺពាក់ព័ន្ធដល់បញ្ហាប្រភពអាហារ។ បើគាត់មិនជ្រើសប្រើវិធីសាស្រ្តពីគូ, ជាមូលដ្ឋានគឺបួសហាត់មិនបាន, គឺត្រូវឃ្លានស្លាប់ស្រេកស្លាប់នៅខាងក្នុង។ ខ្ញុំពីឆង់ឈីងទៅវ៉ូហានសម្តែងធម៌, អង្គុយទូកបណ្តោយទន្លេឆាងជាំងទៅខាងកើត, មើលឃើញសងខាង{ត្រើយ}សានសៀ, មានរូងភ្នំមួយចំនួននៅពាក់កណ្តាលខ្នងភ្នំ, មានភ្នំល្បីជាច្រើនសុទ្ធតែមានប្រការនេះ។ អតីតកាលមនុស្សបួសហាត់

នោះក្រោយពីប្រើខ្សែពួរវារចូលទៅ, កាត់ដាច់ខ្សែពួរចោល, ហើយនៅក្នុងរូងបួសហាត់, បួសហាត់មិនលេចចេញបាន, នឹងត្រូវស្លាប់នៅក្នុងនោះ។ គ្មានទឹក, គ្មានអាហារ, គាត់ជាក់ស្តែងគឺជ្រើសប្រើវិធីសាស្ត្របួសហាត់ពិសេសមួយនៅក្រោមបរិយាកាសយ៉ាងពិសេសបំផុតបែបនេះ។

មានគង់ហ្វាជាច្រើនគឺឆ្លងកាត់ដំណើរការស្នងបង្រៀនបែបនេះ, ដូច្នេះវាមាននាំតាមពីគូ; មានគង់ហ្វាជាច្រើនមិននាំតាមពីគូ, ក្នុងចំណោមគង់ហ្វាបង្រៀនចេញនៅលើសង្គមពួកយើងសព្វថ្ងៃភាគច្រើនមិននាំតាមប្រការនេះ។ យើងខ្ញុំសម្តែងហាត់គង់ត្រូវឯកទេសតែមួយគត់, លោកអ្នកមិនអាចមនុស្សចេតនាចង់ធ្វើដូចម្តេចគឺធ្វើដូចម្តេច។ លោកអ្នកឃើញថាវាល្អណាស់, លោកអ្នកក៏ចង់ពីគូ, លោកអ្នកពីគូធ្វើអ្វី? មនុស្សខ្លះឃើញថាដ៏ល្អ, ចង់ដឹងចង់ឃើញ, ឬក៏ជាឃើញថាខ្លួនឯងជំនាញការខ្ពស់រួចហើយ, អាចសម្ញែងៗ, គ្រប់ប្រភេទស្ថានភាពផ្លូវចិត្តរបស់មនុស្សសុទ្ធតែមាន។ ទោះបីជ្រើសប្រើវិធីសាស្ត្រនេះបួសហាត់, ក៏ត្រូវតែប្រើប្រាស់ថាមពលរបស់ខ្លួនឯងដើម្បីបំពេញឲ្យរាងកាយ, ដូច្នេះក៏ជាខាតបង់លើសពីទទួលបាន។ អ្នករាល់គ្នាដឹង, ជាពិសេសគឺនៅក្រោយពីសាសនាបង្កើត, លោកអ្នកនៅក្នុងវត្តអង្គុយសមាធិ, បិទទ្វារ, សុទ្ធតែមានមនុស្សផ្គត់ផ្គង់ឲ្យលោកអ្នកតែ, អាហារ, មិនពាក់ព័ន្ធបញ្ហានេះ។ ជាពិសេសគឺពួកយើងបួសហាត់នៅក្នុងសង្គមមនុស្សសាមញ្ញ, លោកអ្នកជាមូលដ្ឋានគឺមិនចាំបាច់ជ្រើសប្រើវិធីសាស្ត្រនេះ, លើសពីនេះក្នុងធម្មក្ខន្ធមួយនោះរបស់លោកអ្នកគ្មាន, លោកអ្នកក៏មិនអាចរញ៉េរញ៉ៃបាន។ តែបើសិនលោកអ្នកពិតជាចង់ពីគូ, លោកអ្នកទៅបួសសាកមើល។ តាមខ្ញុំដឹង, ជាញឹកញាប់គ្រូបង្រៀនគង់ឡើងលើជាន់ថ្នាក់ខ្ពស់, បើសិនពិតប្រាកដនាំមនុស្ស, ខាងក្នុងធម្មក្ខន្ធមួយនេះរបស់គាត់មានពីគូ,

អាចនឹងលេចឡើងបាតុភូតនេះ, ទោះយ៉ាងណាវាមិនអាចជាសកល បាន, ជាញឹកញាប់សុទ្ធតែនាំសិស្សទៅបួសសម្ងាត់, បួសឯកតា។

បច្ចុប្បន្នក៏មានគ្រូឈីគង់បង្រៀនគេពីគូ។ តមបានទេ? ចុងក្រោយ មិនតមបាន, នរណាតមបាន? ខ្ញុំឃើញថាចូលគេងពេទ្យមិនតិច, លេច ឡើងគ្រោះថ្នាក់ដល់ជីវិតមិនតិច។ ដូច្នោះហេតុអ្វីបានជាលេចឡើង កាលៈទេសៈនេះ? បាតុភូតពីគូមិនមែនមានឬ? គឺមាន។ តែមានចំណុច មួយ, ស្ថានភាពនេះនៃសង្គមមនុស្សសាមញ្ញពួកយើងគឺមិនអនុញ្ញាតឲ្យ នរណាងាយស្រួលបំផ្លាញវា, មិនអនុញ្ញាតឲ្យបំផ្លាញ។ មិននិយាយ ទូទាំងប្រទេសមានមនុស្សប៉ុន្មាននាក់ហាត់គង់មិនញ៉ាំមិនផឹក, គ្រាន់តែ និយាយកន្លែងឆាងឈុននេះនរណាក៏មិនញ៉ាំមិនផឹក, ខ្ញុំនិយាយនេះគឺ សម្រួលបញ្ហាពេកហើយ! ក៏មិនចាំបាច់ប្រញាប់ធ្វើបាយទៀត។ កសិករ ធ្វើស្រែលំបាកវេទនា, សុទ្ធតែមិនញ៉ាំទៀត, នេះគឺសម្រួលបញ្ហាពេក ហើយ, គ្រាន់តែធ្វើការ, មិនញ៉ាំបាយ។ នោះអាចបានឬ? នោះជាសង្គម មនុស្សជាតិឬ? បញ្ជាក់គឺមិនបាន, មិនអនុញ្ញាតឱ្យរឿងរ៉ាវបែបនេះជ្រៀត ជ្រែកសង្គមមនុស្សសាមញ្ញលើទ្រង់ទ្រាយធំ។

ពេលដែលមានគ្រូឈីគង់មួយចំនួនបង្រៀនពីគូ, បានលេចឡើង គ្រោះថ្នាក់ដ៏ច្រើន។ មានមនុស្សមួយចំនួនជាក់ស្តែងគឺប្រកាន់លើការ ស្វែងរកពីគូ, ប៉ុន្តែចិត្តនោះរបស់គាត់មិនទាន់ចោល, ចិត្តរបស់មនុស្ស សាមញ្ញដ៏ច្រើនមិនទាន់ចោល, ឃើញម្ហូបឆ្ងាញ់តែមិនបានញ៉ាំគឺនឹង ឃ្លាន, ចិត្តរបស់គាត់ផុសឡើងកាលណា, ដូច្នោះគឺមិនបាន។ គាត់គឺ អន្ទះសា, ចង់ញ៉ាំអ្វីមួយ, តណ្ហាឡើងមកគឺចង់ញ៉ាំ, មិនញ៉ាំគឺមាន អារម្មណ៍ថាឃ្លាន។ ប៉ុន្តែញ៉ាំគឺត្រូវក្អួតចេញ, ញ៉ាំមិនចូល, នេះគឺបង្កជា ស្មារតីតឹងតែង, ភ័យខ្លាចខ្លាំងណាស់។ មនុស្សជាច្រើនសម្រាកក្នុងពេទ្យ,

មែនទែនមានមនុស្សជាច្រើនលេចឡើងគ្រោះថ្នាក់ដល់ជីវិត។ ក៏មានមនុស្សខ្លះរកដល់ខ្ញុំហៅខ្ញុំដោះស្រាយរឿងរញ៉េរញ៉ៃទាំងនេះ, ខ្ញុំក៏មិនចង់គ្រប់គ្រងរឿងទាំងនេះ។ មានគ្រូឈើគង់មួយចំនួនដាក់ស្ដែងគឺភ្លីភ្លើ, នរណាចង់សម្អាតរឿងច្របូកច្របល់ទាំងនេះឲ្យគាត់។

ថៃមទៀត, លោកអ្នកពីគូលេចឡើងបញ្ហា, នោះមិនមែនលោកអ្នកខ្លួនឯងចំណង់ឬ? យើងខ្ញុំសម្ដែងបាតុភូតទាំងនេះគឺស្ថិតនៅ, ប៉ុន្តែវាមិនមែនជាស្ថានភាពអ្វីមួយលេចឡើងក្នុងជាន់ថ្នាក់ខ្ពស់, ក៏មិនមែនប្រតិកម្មពិសេសអ្វី, វាហួសពេកគ្រាន់តែជាបែបវិធីបួសហាត់មួយបានជ្រើសប្រើក្នុងកាលៈទេសៈពិសេស, ប៉ុន្តែវាក៏មិនអាចជាសកល។ មនុស្សមិនតិចស្វែងរកពីគូ, ក៏និយាយវាគឺជាពីគូអ្វី, ពីគូពាក់កណ្ដាល, នៅបែងចែកជាវណ្ណៈទៀត។ មានមនុស្សនិយាយគាត់ផឹកទឹក, មានមនុស្សនិយាយញុំាផ្លែឈើ, នោះសុទ្ធតែជាពីគូក្លែងក្លាយ, ពេលវេលាយូរ, ធានាសុទ្ធតែមិនបាន។ មនុស្សបួសហាត់ពិតប្រាកដ, កាលណាចូលក្នុងរូងភ្នំអង្គុយ, មិនញុំាមិនផឹក, នោះហៅថាពីគូពិត។

## លួចឈើ

និយាយដល់លួចឈើ, មនុស្សខ្លះប្រែសម្បុរដូចជួបខ្លា, ភ័យខ្លាចមិនហ៊ានហាត់គង់។ មនុស្សជាច្រើនគឺដោយសារពិភពបួសហាត់ផ្សព្វផ្សាយទ្រឹស្ដីបាតុភូតឆ្កួតវង្វេងអារក្សចូល, លួចឈើជាដើមបណ្ដាលឲ្យគេមិនហ៊ានហាត់គង់, មិនហ៊ានទាក់ទងដល់ឈើគង់។ ប្រសិនគ្មានការថ្លែងទាំងនេះ, អាចនឹងមានមនុស្សច្រើនជាងទៀតហាត់គង់។ ក៏មានគ្រូឈើគង់ចិត្តចរិតមិនល្អមួយចំនួន, ជំនាញបង្រៀនរបស់ទាំងនេះ, ធ្វើឲ្យពិភពបួសហាត់បរិយាកាសខ្មៅអាក្រក់, ភាពពិតគ្មានគួរឲ្យខ្លាចដូចគាត់និយាយនោះទេ។ យើងខ្ញុំសម្ដែងឈើគ្រាន់តែជាឈើ, ទោះបីលោកអ្នក

និយាយវាគឺជាហ៊ុនឃ្វានឈើ, ឈើនេះ, ឈើនោះ។ រាងកាយមនុស្ស គឺឲ្យតែមានឈើ, ឯកជននេះដាក់ស្ដែងគឺនៅក្នុងមួយជាន់ថ្នាក់នេះព្យាបាលជំងឺកាយសម្បទា, ដូច្នេះនៅមិនទាន់ចាត់ថាជាមនុស្សហាត់គង់។ មនុស្សឲ្យតែមានឈើនៅ, និយាយច្បាស់ថាឯកជននេះនៅមិនទាន់សម្រេចបានរាងកាយបន្សុទ្ធកម្រិតខ្ពស់, ដាក់ស្ដែងគឺមានឈើជំងឺ, នេះគឺជាបញ្ហាក់។ មនុស្សលួចឈើក៏នៅក្នុងជាន់ថ្នាក់របស់ឈើ, តើមនុស្សហាត់គង់ពួកយើងនរណាចង់បានឈើដ៏ប្រឡាក់ល្អក់នោះ? មនុស្សមិនហាត់គង់ឈើរបស់រាងកាយប្រឡាក់ណាស់, ហាត់គង់រួចហើយអាចថ្លាភ្លឺឡើង។ កន្លែងដែលមានជំងឺគឺអាចបង្ហាញចេញសារធាតុពណ៌ខ្មៅមួយដុំមានដង់ស៊ីតេដ៏ធំ។ ហាត់បន្តជាបណ្ដើរ, ពេលដែលពិតប្រាកដបានដល់ព្យាបាលជំងឺកាយសម្បទា, ឈើគឺបន្តិចម្ដងៗប្រែជាពណ៌លឿង។ ហាត់បន្តទៀតគឺពិតជាព្យាបាលជំងឺ, ក៏គ្មានឈើទៀត, ពោលគឺចូលក្នុងស្ថានភាពសដូចទឹកដោះរួចហើយ។

ដូច្នោះក៏មានន័យថាមានឈើគឺមានជំងឺ។ ពួកយើងជាមនុស្សហាត់គង់, ហាត់គង់នរណាចង់បានឈើធ្វើអ្វី? រាងកាយខ្លួនឯងចាំបាច់បន្សុទ្ធ, ហេតុម្ដេចនៅចង់បានឈើប្រឡាក់! បញ្ហាក់មិនអាចត្រូវការ។ មនុស្សចង់បានឈើក៏នៅក្នុងជាន់ថ្នាក់របស់ឈើ, នៅក្នុងជាន់ថ្នាក់របស់ឈើគាត់សម្គាល់មិនបានមួយណាជាឈើល្អ, មួយណាជាឈើអាក្រក់, គាត់គ្មានអានុភាពនេះ។ ហើយដុំច្ធិនឈើនោះក្នុងតានធានរបស់រាងកាយលោកអ្នកគាត់គឺប៉ះមិនបាន, ឃ្វានឈើនោះត្រូវតែមនុស្សជំនាញការខ្ពស់ទើបប៉ះដល់បាន។ ឈើប្រឡាក់ល្អក់នោះរបស់រាងកាយ, ទុកឲ្យគាត់លួចទៅ, មានអ្វីអស្ចារ្យ។ ពេលខ្ញុំហាត់គង់ប្រសិនចង់ស្រោចឈើ, គ្រាន់តែគិតបន្តិច, មួយរយៈពោះក៏ពេញភ្លាម។

តាវវង្សសម្តែងឈរបង្គោល, ពុទ្ធវង្សសម្តែងឱបឈើស្រោចកំពូល, ក្នុងចក្រវាលមានឈើដ៏ច្រើន, លោកអ្នកអាចស្រោចចូលក្នុងមួយថ្ងៃវាស់ល្ងាច។ ស្មៀវ៉ិឡាវគុងវាយបើក, ស្មៀវ៉ិប៉ាយហួយវាយបើក, លោកអ្នកគឺស្រោចចូលក្នុង, គំនិតដាក់នៅតានធាន, ដៃឱប{ឈើ}ចូលក្នុង, មួយរយៈគឺពេញ។ លោកអ្នកស្រោចពេញដល់ណាមានប្រយោជន៍អ្វី? មនុស្សខ្លះពេលដែលហាត់ឈើហាត់ច្រើនណាស់, មានអារម្មណ៍ថាម្រាមដៃហើមឡើង, រាងកាយហើមឡើង។ អ្នកដទៃដើរកាត់ពីមុខ, មានអារម្មណ៍ថាជុំវិញមានវាលមួយ។ អ៉ាយយ៉ា, លោកអ្នកហាត់គង់ហាត់ពិតជាល្អ។ ខ្ញុំនិយាយថាមិនជាអ្វីទាំងអស់, ទីណាមានគង់? នៅតែជាហាត់ឈើ, ឈើច្រើនដល់ណាក៏មិនជំនួសឲ្យគង់បាន។ គោលបំណងរបស់ហាត់ឈើគឺប្រើឈើល្អខាងក្រៅផ្តោះប្តូរឲ្យឈើខាងក្នុងរាងកាយ, ដើម្បីគឺបន្សុទ្ធរាងកាយ, ផ្ទុកឈើនោះធ្វើអ្វី? លោកអ្នកនៅក្នុងជាន់ថ្នាក់នេះ, ពេលដែលមិនទាន់កើតឡើងផ្លាស់ប្រែអំពីធាតុដើម, វាក៏មិនមែនជាគង់។ លោកអ្នកលួចច្រើនដល់ណា, លោកអ្នកហួសពេកគ្រាន់តែជាបាវឈើធំ, នោះមានប្រយោជន៍អ្វី? វាក៏មិនបំប្លែងសំដៅឡើងសារធាតុថាមពលខ្ពស់បាន, ដូច្នេះលោកអ្នកខ្លាចអ្វី, គាត់ពិតជាលួចឈើក៏លួចទៅ។

អ្នករាល់គ្នាគិតសាកមើល, រាងកាយលោកអ្នកមានឈើគឺមានជំងឺ។ ដូច្នោះពេលដែលគាត់លួច, តើមិនមែនលួចទៅទាំងមួយដុំឈើជំងឺរបស់លោកអ្នក? គាត់ជាមូលដ្ឋានសម្គាល់មិនបានប្រការនេះ, ដោយសារមនុស្សចង់បានឈើក៏នៅក្នុងជាន់ថ្នាក់ឈើនេះ, គាត់មិនទាន់មានអានុភាពអ្វីទាំងអស់។ មនុស្សមានគង់មិនចង់ឈើ, នេះគឺជាបញ្ហាក់។ មិនជឿពួកយើងធ្វើការពិសោធន៍, ពិតជាចង់លួចឈើលោកអ្នកឈរទីនោះទុកឱ្យគាត់លួច, ខាងនេះលោកអ្នកគិតថាកំពុងស្រោចឈើចក្រវាលចូលក្នុង,

គាត់នៅខាងក្រោយលួច។ លោកអ្នកឃើញនេះល្អប៉ុណ្ណា, ជំនួសលោកអ្នកពន្លឿនថែមបន្សុទ្ធរាងកាយ, សន្សំឲ្យលោកអ្នកលើកដៃឡើងចុះៗ។ ដោយសារចិត្តដែលគាត់ផុសចេញគឺជាអាក្រក់, គឺបានលួចរបស់អ្នកដទៃ។ ទោះបីយករបស់មិនល្អក៏ដោយ, គាត់ក៏បានធ្វើរឿងខ្វះខ្វាយគុណធម៌រួចហើយ, ដូច្នេះគាត់ត្រូវផ្តល់គុណធម៌ឲ្យលោកអ្នក។ វាបង្កើតជាដំណើរចរន្តមួយ, ខាងនេះយកឈើរបស់លោកអ្នក, ខាងនោះផ្តល់គុណធម៌ឲ្យលោកអ្នក។ មនុស្សលួចឈើនោះមិនដឹង, ប្រសិនគាត់ដឹងគាត់បានមិនហ៊ានធ្វើរួចហើយ!

ជាទូទៅមនុស្សលួចឈើ, សម្បុរមុខសុទ្ធតែប្រែបែតង, សុទ្ធតែជាបែបនេះ។ ដល់ក្នុងឧទ្យានហាត់គង់, មនុស្សដ៏ច្រើនជាក់ស្តែងគឺដើម្បីព្យាបាលជំងឺ, គាត់ជំងឺអ្វីក៏មាន។ ពេលដែលគេព្យាបាលជំងឺ, នៅតែត្រូវរុញចេញក្រៅ, តែមនុស្សលួចឈើគាត់សូម្បីតែរុញក៏មិនរុញចេញ, នៅតែធ្វើឲ្យមួយតួខ្លួន, ឈើជំងឺអ្វីក៏មាន, សូម្បីតែខាងក្នុងរាងកាយសុទ្ធតែខ្មៅស្រអាប់។ គាត់រមែងខ្វះខ្វាយគុណធម៌, ខាងក្រៅរបស់គាត់សុទ្ធតែជាខ្មៅ, វាលអំណាចកម្មធំរួចហើយ, គុណធម៌ខ្វះខ្វាយច្រើនរួចហើយ, ក្នុងក្រៅសុទ្ធតែជាខ្មៅ។ មនុស្សលួចឈើប្រសិនគាត់ដឹងថាខ្លួនឯងកើតឡើងផ្លាស់ប្តូរបែបនេះ, កំពុងផ្តល់គុណធម៌ឲ្យគេ, ពេលដែលធ្វើរឿងល្ងង់ខ្លៅបែបនេះ, គាត់បានមិនធ្វើរួចហើយ។

មនុស្សខ្លះនិយាយយ៉ាងអាថ៌កំបាំងអំពីឈើ៖ លោកអ្នកនៅប្រទេសអាមេរិក, ខ្ញុំបញ្ចេញឈើលោកអ្នកអាចទទួលបាន; លោកអ្នកកំពុងចាំខាងក្រៅជញ្ជាំង, ខ្ញុំបញ្ចេញឈើលោកអ្នកអាចទទួលបាន។ មនុស្សខ្លះដំរសើប, កាលណាបញ្ចេញឈើគឺទទួលបាន។ ប៉ុន្តែឈើនោះវាមិនដើរក្នុងអវកាសនេះ, វាដើរក្នុងអវកាសផ្សេង, អវកាសផ្សេងទីនេះគ្មានជញ្ជាំង។

នោះហេតុអ្វីគ្រូឈីគង់ខ្លះនៅលើដីរាបស្មើបញ្ចេញឈី, លោកអ្នកក៏មិនទទួលដឹងបាន? នៅក្នុងអវកាសផ្សេងទីនេះមានគម្លាត, ដូច្នេះឈីក៏មិនដូចដែលយើងសម្តែងមានកម្លាំងឆ្លងផ្ទុះធំប៉ុណ្ណា។

ពិតប្រាកដអាចផ្តើមផលប៉ះពាល់នៅតែជាគង់, ពេលដែលមនុស្សហាត់គង់អាចបញ្ចេញគង់ចេញមក, គាត់លែងមានឈីរួចហើយ, បញ្ចេញប្រភេទសារធាតុថាមពលខ្ពស់មួយ, ប្រើភ្នែកទិព្វដើម្បីមើលគឺជាប្រភេទពន្លឺមួយ។ បញ្ចេញដល់លើរាងកាយអ្នកដទៃ, មានអារម្មណ៍មួយក្តៅៗ, ដោយផ្ទាល់អាចរឹតត្បិតលើមនុស្សសាមញ្ញ។ ទោះយ៉ាងណាក៏មិនអាចសម្រេចបានគោលបំណងព្យាបាលជំងឺទាំងស្រុង, គ្រាន់តែអាចផ្តើមផលប៉ះពាល់បង្ក្រាប។ ពិតប្រាកដចង់ព្យាបាលជំងឺជាសះស្បើយនៅតែត្រូវមានសីលគង់ស្ថិតនៅ, រាល់ប្រភេទជំងឺមានរាល់ប្រភេទសីលគង់តម្រង់ចំ។ នៅក្រោមអតិសុខុមបំផុត, លើរាល់ភាគល្អិតរបស់គង់, សុទ្ធតែជាដូចគ្នានឹងរូបភាពឯកជនរបស់លោកអ្នក។ វាអាចស្គាល់ដឹងមនុស្ស, សុទ្ធតែជាមានភាពវៃឆ្លាត, ជាសារធាតុថាមពលខ្ពស់, អ្នកដទៃលួចទៅរួចហើយ, វាអាចនៅទីនោះឬ? វាក៏មិននៅទីនោះ, ដាក់ក៏ដាក់ឡើងមិនបាន, មិនមែនជាអ្វីរបស់ខ្លួនឯង។ ជាទូទៅមនុស្សហាត់គង់ពិតប្រាកដ, មនុស្សក្រោយពីបញ្ចេញគង់រួចហើយសុទ្ធតែមានគ្រូកំពុងគ្រប់គ្រង, គ្រូនៅទីនោះមើលលោកអ្នកកំពុងធ្វើអ្វី, យកអ្វីរបស់គេ, គ្រូរបស់គាត់ក៏មិនព្រម។

## ស្រូបឈី

លួចឈីនិងស្រូបឈីសុទ្ធតែមិនមែនជាបញ្ហាដែលយើងខ្ញុំត្រូវដោះស្រាយឱ្យអ្នករាល់គ្នាពេលបង្រៀនគង់នៅលើជាន់ថ្នាក់ខ្ពស់។ ដោយសារខ្ញុំនៅមានគោលបំណងមួយបែបនេះ៖ ស្តារឡើងវិញកេរ្តិ៍ឈ្មោះរបស់បួស

ហាត់, ធ្វើបន្តិចរឿងល្អ, យកបាតុភូតមិនល្អទាំងនេះសម្តែងចេញមក, អតីតកាលគ្មានមនុស្សសម្តែង។ ប្រសិនអ្នករាល់គ្នាពួកយើងដឹងអំពីវា, ចៀសវាងមនុស្សមួយចំនួនតែងតែធ្វើរឿងអាក្រក់, មានមនុស្សមួយចំនួន, មនុស្សដែលមិនច្បាស់សេចក្តីពិតតែងតែនិយាយដល់ប្រែសម្បុរដូចជួបខ្លា។

ឈើនៃចក្រវាលមានដ៏ច្រើន, មានមនុស្សសម្តែងឈើធានយ៉ាង, ឈើទីឃើន។ លោកអ្នកក៏ជាចំណែកមួយក្នុងចក្រវាល, លោកអ្នកគ្រាន់តែទៅស្រូបបានហើយ។ តែមនុស្សខ្លះមិនមែនស្រូបឈើក្នុងចក្រវាល, គាត់ជំនាញបង្រៀនគេស្រូបឈើរបស់រុក្ខជាតិ, សុទ្ធតែសង្ខេបចេញមកបទពិសោធន៍៖ ឈើដើមប្រក្រាបគឺជាពណ៌ស, ឈើដើមស្រល់គឺជាពណ៌លឿង, នៅមានស្រូបយ៉ាងនេះយ៉ាងនោះ, ពេលណាៗស្រូប។ ក៏មានខ្លះនិយាយថា៖ ខាងមុខផ្ទះខ្ញុំមានដើមឈើ, ខ្ញុំស្រូបឈើស្រូបធ្វើឲ្យវាងាប់រួចហើយ។ នោះចាត់ថាអានុភាពអ្វី? តើនោះមិនមែនកំពុងធ្វើរឿងអាក្រក់ឬ? អ្នករាល់គ្នាដឹង, ពួកយើងបួសហាត់ពិតប្រាកដ, គឺយកចិត្តទុកដាក់ព័ត៌មានចរិតស្លូត, យកចិត្តទុកដាក់សមកាលកម្មនឹងចរិតពិសេសនៃចក្រវាល, លោកអ្នកមិនត្រូវសម្តែងអំពីបញ្ហាករុណាឬ? សមកាលកម្មជាមួយចរិតពិសេសសច្ចៈ, ករុណា, ខន្តីនៃចក្រវាល, ត្រូវតែសម្តែងករុណានេះ។ លោកអ្នកធ្វើតែរឿងអាក្រក់តើអាចបង្កើនគង់ឬ? អាចព្យាបាលជំងឺឬ? នោះគាប់ជួនមិនផ្ទុយស្រឡះនឹងមនុស្សបួសហាត់ពួកយើងឬ? នោះក៏ចាត់ថាសម្លាប់ជីវិតធ្វើរឿងអាក្រក់! ប្រហែលជាមានមនុស្សនិយាយថា៖ លោកគ្រូកាន់តែសម្តែងកាន់តែអាថ៌កំបាំង, សម្លាប់សត្វជាសម្លាប់ជីវិត, ធ្វើឲ្យរុក្ខជាតិងាប់ក៏ជាសម្លាប់ជីវិត។ ភាពពិតគឺជាបែបនេះ, ក្នុងពុទ្ធសាសនាសម្តែងវដ្តសង្សារ៦ផ្លូវ, លោកអ្នកអាចនៅក្នុង

វដ្តសង្សារ៦ផ្លូវប្រែក្លាយជារុក្ខជាតិ, ក្នុងពុទ្ធសាសនាគឺសម្តែងយ៉ាងនេះ។ ទីនេះយើងខ្ញុំមិនសម្តែងបែបនេះ។ តែយើងខ្ញុំប្រាប់អ្នករាល់គ្នា, ដើមឈើក៏ជាមានជីវិត, មិនត្រឹមតែមានជីវិត, នៅមានគ្រប់គ្រាន់សកម្មភាពផ្នត់គំនិតដ៏ខ្ពស់។

លើកឧទាហរណ៍៖ ប្រទេសអាមេរិកមានមនុស្សម្នាក់ជំនាញធ្វើការស្រាវជ្រាវអេឡិចត្រូនិក, បង្រៀនគេប្រើប្រាស់ឧបករណ៍ចាប់កុហក។ មានថ្ងៃមួយក្នុងពេលដ៏រំភើបគាត់យកបង្គោលពីររបស់ឧបករណ៍ចាប់កុហកភ្ជាប់នៅលើដើមរាសីធំ, បន្ទាប់មកស្រោចទឹកលើគល់របស់{ដើម}ផ្កា។ ក្រោយមកគាត់រកឃើញថាប៊ិកអេឡិចត្រូនិករបស់ឧបករណ៍ចាប់កុហកយ៉ាងឆាប់រហ័សគូរចេញប្រភេទខ្សែកោងមួយ។ ប្រភេទខ្សែកោងនេះគាប់ជួនដូចគ្នានឹងខ្សែកោងដែលខួរធំមនុស្សនៅក្នុងពេលវេលាដ៏ខ្លីរំភើប, រីករាយហើយសាងបង្កើត។ ពេលនោះគាត់បានភ្ញាក់ផ្អើលយ៉ាងខ្លាំង, រុក្ខជាតិធ្វើម្តេចមានមនោសញ្ចេតនាហ្ន៎! គាត់ស្ទើរតែចង់ចេញថ្នល់ធំដើម្បីស្រែក៖ រុក្ខជាតិគឺមានមនោសញ្ចេតនា។ ដោយទទួលរងការបំផុសពីរឿងរ៉ាវនេះ, ភ្លាមៗបន្ទាប់មកគាត់បានបើកដំណើរការស្រាវជ្រាវលើទិដ្ឋភាពនេះ, បានធ្វើពិសោធន៍ដ៏ច្រើន។

មានមួយដង, គាត់យកដើមឈើទាំងពីរដាក់ជាមួយគ្នា, ហៅសិស្សរបស់គាត់នៅពីមុខដើមឈើមួយផ្សេងជាន់ឈ្លីដើមឈើនេះ, ឈ្លីឲ្យងាប់។ បន្ទាប់មកផ្លាស់ទីដើមឈើមួយផ្សេងទៅក្នុងបន្ទប់, ភ្ជាប់នឹងឧបករណ៍ចាប់កុហក, ហៅសិស្សរបស់គាត់ទាំង៥ឆ្លាស់គ្នាពីខាងក្រៅដើរចូលមក។ សិស្ស៤នាក់មុនចូលមកក្នុង, គ្មានប្រតិកម្ម។ រង់ចាំដល់សិស្សទី៥, សិស្សជាន់ឈ្លីដើមឈើចូលមកកាលណា, នៅមិនទាន់ដើរដល់ពីមុខផង, ប៊ិកអេឡិចត្រូនិកជាបន្ទាន់យ៉ាងឆាប់រហ័សគូរចេញមក

ប្រភេទខ្សែកោងមួយ, មនុស្សពេលកំពុងភ័យខ្លាចទើបអាចគូរចេញខ្សែកោងប្រភេទនេះ។ គាត់ភ្ញាក់ផ្អើលដ៏ខ្លាំង! រឿងរ៉ាវនេះបាននិយាយច្បាស់បញ្ហាដ៏ធំមួយ៖ ពួកយើងពីដើមមកសន្មតថាមនុស្សគឺជាជីវិតកម្រិតខ្ពស់, មនុស្សមានសីលគង់អង្គញាណ, អាចសម្គាល់, មានខួរធំ, អាចវិភាគ។ រុក្ខជាតិធ្វើម្តេចចេះសម្គាល់, នេះមិនមានអង្គញាណហើយឬ? អតីតកាលប្រសិននរណានិយាយរុក្ខជាតិមានអង្គញាណ, មានផ្នត់គំនិត, មានមនោសញ្ចេតនា, អាចស្គាល់ដឹងមនុស្ស, នោះគេនឹងនិយាយជាអបិយជំនឿ។ ក៏មិនត្រឹមតែទាំងនេះ, ទិដ្ឋភាពមួយចំនួនហាក់ដូចជាលើសផុតពីមនុស្សពួកយើងបច្ចុប្បន្ន។

មានថ្ងៃមួយគាត់យកឧបករណ៍ចាប់កុហកភ្ជាប់ទៅលើដើមឈើមួយ, បន្ទាប់មកគាត់គិតថា៖ ធ្វើពិសោធន៍អ្វីហ្ន៎? យើងយកភ្លើងដុតឆេះស្លឹករបស់វា, មើលៗមានប្រតិកម្មអ្វី។ គាត់ទើបគិតបែបនេះ, នៅមិនទាន់បានដុតផង, ប៊ិកអេឡិចត្រូនិកនោះយ៉ាងឆាប់រហ័សបានគូរចេញប្រភេទខ្សែកោងមួយ, ជាក់ស្តែងគឺនៅពេលមនុស្សស្រែកហៅសង្គ្រោះជីវិតទើបអាចគូរចេញមកខ្សែកោងដូច្នេះ។ ប្រភេទសីលគង់អតិអារម្មណ៍នេះ, អតីតកាលហៅថាអានគំនិត, ជាសមត្ថភាពកំបាំង, សភាវគតិរបស់មនុស្ស, ប៉ុន្តែមនុស្សបច្ចុប្បន្នសុទ្ធតែកំពុងឱនថយ, លោកអ្នកត្រូវតែបួសហាត់សាជាថ្មី, ត្រឡប់ដើមមកសច្ចៈ, ត្រឡប់មកចរិតដើមរបស់លោកអ្នក, លោកអ្នកទើបអាចមានគ្រប់គ្រាន់។ តែផ្ទុយមកវិញវាមានគ្រប់គ្រាន់, លោកអ្នកគិតអ្វីវាដឹង, ស្តាប់ទៅដ៏អាថ៌កំបាំង។ ប៉ុន្តែផ្ទុយមកវិញវាគឺជាពិសោធន៍វិទ្យាសាស្ត្រប្រាកដជាក់ស្តែង។ គាត់បានធ្វើគ្រប់ប្រភេទពិសោធន៍, នៅមានសីលគង់បញ្ហាពីចម្ងាយឆ្ងាយ។ បន្ទាប់ពីនិក្ខេបបទរបស់គាត់បោះពុម្ពចេញមក, នាំឲ្យភ្ញាក់ផ្អើលទូទាំងពិភពលោក។

អ្នករុក្ខសាស្ត្រគ្រប់ប្រទេសក៏កំពុងបើកដំណើរការស្រាវជ្រាវលើទិដ្ឋភាពនេះ, ប្រទេសយើងក៏កំពុងធ្វើ, នេះលែងនៅជាប្រការអ្វីអបិយជំនឿទៀតហើយ។ ថ្ងៃនោះខ្ញុំបានសម្ដែងប្រយោគមួយបែបនេះ, ប្រការទាំងនោះដែលកើតមាន, ប្រឌិត, រកឃើញទីមនុស្សជាតិពួកយើងបច្ចុប្បន្នគ្រប់គ្រាន់ដើម្បីផ្លាស់ប្រែសៀវភៅសិក្សារបស់ពួកយើងសព្វថ្ងៃរួចហើយ។ ប៉ុន្តែផ្ទុយមកវិញដោយទទួលរងឥទ្ធិពលរបស់គោលគំនិតប្រពៃណី, គេមិនចង់ទទួលស្គាល់វា, ក៏គ្មាននរណាម្នាក់រៀបចំប្រការទាំងនេះជាប្រព័ន្ធផងដែរ។

នៅឧទ្យានមួយភាគឦសានខ្ញុំមើលមានដើមស្រល់មួយដុំបានងាប់ក្រាបចុះ។ ក៏មិនដឹងថាមនុស្សមួយចំនួនហាត់ជាអ្វី, រមៀលពេញដី, បន្ទាប់ពីរមៀលចប់, ជើងស្រូបយ៉ាងនេះ, ដៃស្រូបយ៉ាងនោះ, មិនយូរប៉ុន្មានដើមស្រល់មួយដុំនោះលឿង, ងាប់ទាំងអស់។ តើនោះលោកអ្នកគឺធ្វើរឿងល្អឬក៏ធ្វើរឿងអាក្រក់? ឈរនៅលើទស្សនៈមនុស្សហាត់គង់ពួកយើងសង្កេតមើល, នោះជាក់ស្ដែងគឺសម្លាប់ជីវិត។ លោកអ្នកជាមនុស្សហាត់គង់លោកអ្នកគឺត្រូវតែធ្វើមនុស្សល្អម្នាក់, បន្តិចម្ដងៗសមកាលកម្មនឹងចរិតពិសេសនៃចក្រវាល, ហាមចោលរបស់ដែលមិនល្អទាំងនោះរបស់ខ្លួន។ នោះប្រសិនឈរនៅលើទស្សនៈមនុស្សសាមញ្ញសង្កេតមើល, ក៏មិនមែនជាធ្វើរឿងល្អ, គឺបំផ្លាញទ្រព្យសម្បត្តិសាធារណៈ, បំផ្លាញរុក្ខជាតិបៃតង, បំផ្លាញតុល្យភាពបរិស្ថានជីវសាស្ត្រធម្មជាតិ, ឈរនៅលើទស្សនៈណាមួយសង្កេតមើលក៏មិនមែនជាធ្វើរឿងល្អ។ ក្នុងចក្រវាលមានឈើដ៏ច្រើន, លោកអ្នកទៅស្រូបតាមដែលចង់បាន។ មនុស្សខ្លះថាមពលដ៏ធំ, ក្រោយពីហាត់ដល់ជាន់ថ្នាក់ជាក់លាក់, នោះពិតជាគឺគ្រវាសដៃមួយភ្លាម, មួយដុំដ៏ធំឈើរបស់រុក្ខជាតិ, ភ្លាមៗស្រូបមកបាន។

នោះហួសពេកក៏គ្រាន់តែជាឈើ, ស្រូបបានច្រើនដល់ណាអាចដូចម្តេច? មនុស្សខ្លះទៅឧទ្យានមិនធ្វើអ្វីផ្សេង, គាត់និយាយថា៖ ខ្ញុំមិនចាំបាច់ហាត់គង់, ខ្ញុំគឺបែបនេះដើរផងស្រូបទាញផងគឺបានហើយ, ខ្ញុំគឺហាត់ចប់រួចរាល់។ ទទួលបានឈើគឺបានហើយ, គាត់សន្មតថាឈើជាក់ស្តែងគឺជាគង់។ គេដើរកាត់ពីមុខគាត់, មានអារម្មណ៍ថារាងកាយគាត់ត្រជាក់ស្រួលៗ។ ឈើរុក្ខជាតិនោះមិនមែនចរិតអវិជ្ជមានឬ? មនុស្សហាត់គង់នៅសម្តែងតុល្យភាពអវិជ្ជមាន-វិជ្ជមាន, លើខ្លួនគាត់សុទ្ធតែជាក្លិនជ័ររបស់ដើមស្រល់, នៅតែមានអារម្មណ៍ថាខ្លួនឯងហាត់បានល្អណាស់។

## នរណាហាត់គង់អ្នកនោះទទួលបានគង់

បញ្ហានរណាហាត់គង់នរណាទទួលបានគង់ជាបញ្ហាមួយយ៉ាងគន្លឹះបំផុត។ អ្នកដទៃសួរខ្ញុំហ្វាលូនតាហ្វាមានកន្លែងណាល្អ, ខ្ញុំនិយាយថាហ្វាលូនតាហ្វាអាចសម្រេចបានគង់ហាត់មនុស្ស, កាត់បន្ថយពេលវេលាហាត់គង់; អាចដោះស្រាយបញ្ហាគ្មានពេលវេលាហាត់គង់, ហើយត្រូវបានគង់ហាត់រយៈពេលយូរបែបនេះ។ ក្នុងពេលដំណាលគ្នាពួកយើងក៏ជាគង់ហ្វាចរិតជីវិតបួសទាំងទ្វេពិតប្រាកដ, ការផ្លាស់ប្រែរាងកាយសារធាតុនេះរបស់ពួកយើងនឹងដ៏ធំ។ ហ្វាលូនតាហ្វានៅមានកន្លែងល្អធំបំផុតមួយទៀត, អតីតកាលរហូតខ្ញុំមិនទាន់សម្តែង, មានតែថ្ងៃនេះយើងខ្ញុំទើបសម្តែងចេញមក។ ដោយសារវាពាក់ព័ន្ធដល់បញ្ហាប្រវត្តិសាស្ត្រប្រភពដើមដ៏ធំ, ក៏ឥទ្ធិពលយ៉ាងធំដល់ពិភពបួសហាត់, នៅក្នុងប្រវត្តិសាស្ត្រពីដើមមកមិនទាន់មានមនុស្សប្រកាសចេញមក, ក៏មិនអនុញ្ញាតឱ្យពួកគាត់ប្រកាស, ប៉ុន្តែខ្ញុំមិនសម្តែងគឺមិនបាន។

សិស្សខ្លះនិយាយថា៖ ប្រយោគនីមួយៗរបស់លោកគ្រូធំលីហុងជីសម្តែងគឺជាអាថ៌កំបាំងធម្មជាតិ, គឺបើកបង្ហាញអាថ៌កំបាំងធម្មជាតិ។

ប៉ុន្តែយើងខ្ញុំគឺពិតប្រាកដនាំមនុស្សឡើងលើជាន់ថ្នាក់ខ្ពស់, ជាក់ស្ដែងគឺប្រោសមនុស្ស។ ត្រូវការទទួលខុសត្រូវចំពោះអ្នករាល់គ្នា, អាចទទួលបន្ទុកទំនួលខុសត្រូវនេះ, ដូច្នេះគឺមិនមែនបើកបង្ហាញអាថ៌កំបាំងធម្មជាតិ។ ហើយមិនទទួលខុសត្រូវទៅនិយាយតាមអំពើចិត្តពោលគឺបើកបង្ហាញអាថ៌កំបាំងធម្មជាតិ។ ថ្ងៃហ្នឹងយើងខ្ញុំគឺយកបញ្ហានេះនិយាយចេញមក៖ ជាក់ស្ដែងគឺបញ្ហានរណាហាត់គង់នរណាទទួលបានគង់។ តាមខ្ញុំមើលបច្ចុប្បន្នគង់ហ្វាទាំងអស់, រួមបញ្ចូលពុទ្ធតាវពីរវង្សនិងគង់ហ្វាទ្វារវិសេសសម័យប្រវត្តិសាស្ត្រសុទ្ធតែជាបួសវិញ្ញាណដើមរងរបស់មនុស្ស (សតិរង), សុទ្ធតែជាវិញ្ញាណដើមរងទទួលបានគង់។ វិញ្ញាណដើមម្ចាស់ដែលយើងខ្ញុំសម្ដែងទីនេះ, ជាក់ស្ដែងគឺសំដៅលើផ្នត់គំនិតរបស់ខ្លួនឯង។ ខ្លួនឯងត្រូវការយល់ច្បាស់ខ្លួនឯងកំពុងគិតអ្វី, ធ្វើអ្វី, នេះជាក់ស្ដែងគឺខ្លួនឯងពិតប្រាកដរបស់លោកអ្នក។ ហើយវិញ្ញាណដើមរងធ្វើអ្វីលោកអ្នកជាមូលដ្ឋានគឺមិនដឹង។ ទោះបីគាត់និងលោកអ្នកកើតចេញក្នុងពេលតែមួយ, ហៅឈ្មោះតែមួយ, ធ្វើម្ចាស់រាងកាយតែមួយ, ធំឡើងដូចគ្នា, តែនិយាយដោយតឹងរឹង, គាត់នៅតែមិនមែនជាលោកអ្នក។

ក្នុងចក្រវាលនេះមានគោលសីលធម៌, នរណាបាត់អ្នកនោះបាន, នរណាបួសហាត់អ្នកនោះទទួលបានគង់។ គង់ហ្វាសម័យប្រវត្តិសាស្ត្រសុទ្ធតែបង្រៀនគេពេលហាត់គង់ត្រូវការស្រមើស្រមៃ, មិនគិតអ្វីទាំងអស់, បន្ទាប់មកចូលក្នុងរម្ងាប់កម្រិតជ្រៅ, រម្ងាប់ដល់ចុងក្រោយខ្លួនឯងអ្វីក៏មិនដឹងទៀត។ មានមនុស្សអង្គុយសមាធិ៣ម៉ោងនាឡិកាគឺដូចមួយប៉ប្រិចភ្នែក, អ្នកដទៃនៅតែកោតគោរពកម្លាំងរម្ងាប់របស់គាត់។ ភាពពិតគាត់ហាត់ឬអត់? ខ្លួនឯងជាមូលដ្ឋានក៏មិនដឹង។ ជាពិសេសគឺគង់ហ្វាតាវវង្សសម្ដែង៖ វិញ្ញាណដឹងស្លាប់វិញ្ញាណដើមកើត។ វិញ្ញាណដឹងដែលគាត់

និយាយ, ពួកយើងហៅថាវិញ្ញាណដើមម្ចាស់; វិញ្ញាណដើមដែលគាត់និយាយ, ពួកយើងហៅថាវិញ្ញាណដើមរង។ វិញ្ញាណដឹងពិតរបស់លោកអ្នកស្លាប់, ដូច្នោះលោកអ្នកពិតប្រាកដគឺស្លាប់បាត់ហើយ, វិញ្ញាណដើមម្ចាស់ពិតជាគ្មានទៀត។ មនុស្សហាត់គង់ហ្វាដទៃនិយាយថា៖ លោកគ្រូ, ពេលកូនហាត់គង់, អ្នកក្នុងផ្ទះកូននរណាកូនក៏មិនស្គាល់ទៀត។ នៅមានមនុស្សប្រាប់ខ្ញុំ៖ កូនមិនដូចអ្នកដទៃហាត់គង់ក្រោកពីព្រលឹមចូលគេងយប់ជ្រៅបែបនោះ, កូនមកផ្ទះហើយគេងលើសាឡុងកាលណា, ខ្លួនឯងរបស់កូនគឺបញ្ចេញទៅហាត់គង់, កូនគេងមើលគាត់ហាត់។ ខ្ញុំមានអារម្មណ៍គួរឲ្យដ៏អាណិត, តែក៏មិនគួរឲ្យអាណិត!

គេហេតុអ្វីប្រោសវិញ្ញាណដើមរង? ល្ខោនទង់ពីនមានប្រយោគថា៖ ស៊ូប្រោសកូនសត្វក៏មិនប្រោសមនុស្ស។ មនុស្សដោយពិតសែនពិបាកភ្ញាក់ដឹង, ដោយសារមនុស្សសាមញ្ញទទួលរងភាពវង្វេងរបស់សង្គមមនុស្សសាមញ្ញ, នៅពីមុខអត្ថប្រយោជន៍តថភាពដាក់ចិត្តនោះចុះមិនបាន។ លោកអ្នកមិនជឿ, មនុស្សខ្លះពេលដែលស្ដាប់មេសម្ដែងចប់ដើរចេញក្រៅសាវនដ្ឋាន, គឺប្រែជាមនុស្សសាមញ្ញ, ប្រសិននរណាញ៉ោះគាត់, ប៉ះដល់គាត់, គាត់គឺមិនព្រម។ ឆ្លងមួយដំណាក់កាលពេលវេលារួចហើយ, ជាមូលដ្ឋានមិនចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់ទៀត។ ក្នុងប្រវត្តិសាស្ត្រមនុស្សបួសតាវជាច្រើនសុទ្ធតែមើលឃើញចំណុចមួយនេះ, មនុស្សដ៏ពិបាកប្រោស, ជាក់ស្ដែងគឺវិញ្ញាណដើមម្ចាស់មនុស្សវង្វេងពេក។ មនុស្សខ្លះចរិតភ្ញាក់ដឹងល្អ, {និយាយ}បន្តិចគឺ{យល់}ធ្លុះ។ មានមនុស្សមួយចំនួនសម្ដែងយ៉ាងណាគាត់ក៏មិនជឿ, គាត់សន្មតថាលោកអ្នកគឺសម្ដែងអំនួត។ យើងខ្ញុំហៅគាត់បួសហាត់ចិត្តចរិតយ៉ាងនេះ, តែគាត់កាលណាដល់ទីមនុស្សសាមញ្ញនៅតែចង់អីធ្វើនោះ។ គាត់សន្មត

ថាបន្ទិចផលប្រយោជន៍យ៉ាងជាក់ស្ដែងនោះក្នុងមនុស្សសាមញ្ញ, ស្ទាបដល់បាន, ប៉ះដល់បាននៅតែជារូបទ្រព្យ, នៅតែត្រូវទទួលបានរបស់ទាំងនេះ។ ធម៌ដែលលោកគ្រូសម្ដែង, ស្ដាប់ទៅក៏សមហេតុផល, ប៉ុន្តែធ្វើមិនបាន។ វិញ្ញាណដើមម្ចាស់របស់មនុស្សពិបាកប្រោសបំផុត, តែវិញ្ញាណដើមរងគាត់អាចមើលឃើញទស្សនីយភាពរបស់អវកាសផ្សេង។ ដូច្នេះគេគិតថា៖ ហេតុអ្វីយើងគួរប្រោសវិញ្ញាណដើមម្ចាស់របស់ឯង, គាត់ក៏ជាឯង, យើងប្រោសគាត់មិនដូចគ្នាឬ? សុទ្ធតែជាឯងទេតើ, នរណាបានមិនមែនជាបាន, សុទ្ធតែជាឯងបាន។

ខ្ញុំសម្ដែងវិធីសាស្ត្របួសហាត់ពិស្ដាររបស់គាត់។ មនុស្សប្រសិនមានសីលគង់ទូរនេត្រ, អាចមើលឃើញទស្សនីយភាពមួយបែបនេះ៖ លោកអ្នកអង្គុយសមាធិកាលណា, លោកអ្នកនឹងមើលឃើញនៅមួយសន្ទុះរម្ងាប់ចុះបាន, [ហ៊ឺ] មួយភ្លាមពីខាងក្នុងរាងកាយលោកអ្នកបញ្ចេញលោកអ្នកមួយដូចគ្នានឹងលោកអ្នក។ ប៉ុន្តែលោកអ្នកសម្គាល់បានខ្លួនឯងរបស់លោកអ្នកនៅទីណា? កំពុងអង្គុយទីនេះ។ លោកអ្នកមើលឃើញក្រោយពីគាត់ចេញទៅ, លោកគ្រូនាំគាត់នៅក្នុងអវកាសមួយដែលលោកគ្រូវិវត្តចេញដើម្បីបួសហាត់, ក៏អាចជាទម្រង់សង្គមអតីតកាល, ក៏អាចជាទម្រង់សង្គមបច្ចុប្បន្ន, ក៏អាចជាទម្រង់សង្គមរបស់អវកាសផ្សេង, បង្រៀនគាត់ហាត់គង់, គាត់បានរងទុក្ខមិនតិច, រាល់ថ្ងៃ១, ២ម៉ោងនាឡិកា។ គេហាត់ចប់គង់ត្រឡប់មកកាលណា, លោកអ្នកក៏ចេញពីសមាធិ, នេះជា{នរណា}អាចមើលឃើញបាន។

ប្រសិនមើលមិនឃើញគឺកាន់តែគួរឲ្យអាណិត, អ្វីក៏មិនដឹង, រម្ងាប់ដោយស្រមើស្រមៃ២ម៉ោងនាឡិកាហើយចេញពីសមាធិ។ មនុស្សខ្លះគេង, គេងកាលណា២, ៣ម៉ោងនាឡិកា, គាត់ក៏ចាត់ថាហាត់គង់ចប់,

ទាំងស្រុងបានផ្តល់ឱ្យគេរួចហើយ។ នេះជាបញ្ចប់ដោយចរិតប្រយោល, រាល់ថ្ងៃអង្គុយសមាធិពេលវេលាយូរយ៉ាងនេះ។ នៅមានបញ្ចប់ដោយចរិតមួយដង, អ្នករាល់គ្នាអាចពុំនិយាយថាតាហ៍ម័រ៉បែរមុខទល់ជញ្ជាំង ៩ឆ្នាំ, អតីតកាលមានព្រះសង្ឃជាច្រើនអង្គុយសមាធិកាលណារាប់សិបឆ្នាំ, ក្នុងប្រវត្តិសាស្ត្រកត់ត្រាយូរបំផុតជាង៩០ឆ្នាំ, នៅមានយូរជាងទៀត, ធូលីលើត្របកភ្នែកដ៏ក្រាស់, លើរាងកាយសុទ្ធតែដុះស្មៅ, នៅតែអង្គុយនៅទីនោះ។ តាវវង្សក៏មានសម្តែងប្រការនេះ, ជាពិសេសគឺមានគង់ហ្វាទ្វារវិសេសមួយចំនួនសម្តែងគេង, គេងកាលណារាប់សិបឆ្នាំមិនចេញពីសមាធិ, មិនភ្ញាក់។ ប៉ុន្តែនរណាហាត់? វិញ្ញាណដើមរងរបស់គាត់បញ្ចេញដើម្បីហាត់, ប្រសិនគាត់អាចមើលឃើញបានគឺនឹងមើលឃើញបានលោកគ្រូនាំវិញ្ញាណដើមរងទៅហាត់។ វិញ្ញាណដើមរងក៏ជំពាក់អំណាចកម្មដ៏ធំ, លោកគ្រូគ្មានអានុភាពរំលាយចោលអំណាចកម្មទាំងស្រុង។ ដូច្នេះប្រាប់គាត់ថា៖ កូននៅទីនេះហាត់គង់ឲ្យល្អ, យើងធ្វើដំណើរមួយជើង, មួយរយៈត្រឡប់មក, កូនរង់ចាំយើង។

លោកគ្រូដឹងច្បាស់នឹងលេចឡើងរឿងអ្វី, ក៏ត្រូវតែធ្វើយ៉ាងនេះ។ ប្រសិនខ្មោចមកបន្លាចគាត់, ប្រែជាស្រីស្អាតទាក់ទាញគាត់, រឿងបែបណាក៏មានទាំងអស់។ កាលណាឃើញគាត់ពិតជាមិនកម្រើកចិត្ត, ដោយសារវិញ្ញាណដើមរងងាយស្រួលបួសបង្គួរ, គាត់អាចដឹងសេចក្តីពិតនេះ។ ខ្មោចនោះក្តៅភ្នែកគឺចង់សម្លាប់គាត់, ដើម្បីដោះកំហឹងសងសឹក, ពិតជាសម្លាប់គាត់, មួយរំពេចនេះបំណុលសងរួចទាំងស្រុង។ ត្រូវសម្លាប់រួចហើយ, វិញ្ញាណដើមរងអណ្តែតអណ្តូងហើរឡើង, បែបដូចជាផ្សែងមួយខ្សែ, ចេញមក។ ម្តងទៀតចាប់ជាតិ, កើតចូលក្នុងគ្រួសារមួយដ៏ក្រីក្រ។ ពីតូចរងទុក្ខ, ពេលដែលធំឡើងដឹងក្តី, លោកគ្រូមក, ប្រាកដ

ណាស់គាត់មិនស្គាល់។ លោកគ្រូប្រើសីលគង់វាយបើកផ្ទត់គំនិតដែលស្តុកទុករបស់គាត់, មួយរំពេចនឹកឃើញវិញ, នេះមិនមែនលោកគ្រូឬ? លោកគ្រូប្រាប់គាត់៖ ឥឡូវបានហើយ, អាចហាត់បានហើយ។ បែបនេះឆ្លងកាត់ជាច្រើនឆ្នាំ, លោកគ្រូយកប្រការនេះនោះបង្រៀនឲ្យគាត់។

ក្រោយពីបង្រៀនចប់លោកគ្រូក៏ប្រាប់គាត់ថា៖ កូនមានចិត្តប្រកាន់ជាច្រើនត្រូវការចោល, កូនចេញទៅឃ្វីនយូរ។ ឃ្វីនយូរគឺដ៏វេទនា, ដើរនៅក្នុងសង្គម, ត្រូវសុំទាន, ជួបប្រទះមនុស្សគ្រប់ប្រភេទ, សើចចំអកគាត់, ជេរប្រមាថគាត់, បញ្ឆោតសម្លុតគាត់, រឿងរ៉ាវបែបណាក៏អាចជួបប្រទះ។ គាត់ចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់, រៀបដាក់ល្អទំនាក់ទំនងជាមួយគេ, រក្សាជាប់ចិត្តចរិត, បន្តលើកកម្ពស់ចិត្តចរិត, ទាក់ទាញផលប្រយោជន៍គ្រប់ប្រភេទនៅមនុស្សសាមញ្ញមិនកម្រើកចិត្ត, ឆ្លងកាត់ប៉ុន្មានឆ្នាំគាត់ឃ្វីនយូរត្រឡប់មកវិញ។ លោកគ្រូនិយាយថា៖ កូនបានសម្រេចតាវរួចហើយ, សម្រេចបរិបូររួចហើយ។ គ្មានរឿងអ្វីទៀត, កូនត្រឡប់ទៅប្រមូលៗបម្រុងទៅ; បើមានរឿងអ្វី, នោះចូរកូនបង្ហើយរឿងរ៉ាវក្នុងមនុស្សសាមញ្ញ។ បន្ទាប់ពីប៉ុន្មានឆ្នាំបែបនេះ, សតិរងត្រឡប់មកវិញ, គាត់ត្រឡប់មកកាលណា, ខាងនេះវិញ្ញាណដើមម្ចាស់របស់គាត់ក៏ចេញពីសមាធិ, សតិម្ចាស់ភ្ញាក់ពីគេង។

ប៉ុន្តែគាត់មែនទែនមិនទាន់បួសហាត់, វិញ្ញាណដើមរងរបស់គេបួសហាត់, ដូច្នេះវិញ្ញាណដើមរងគឺទទួលបានគង់។ ទោះយ៉ាងណាវិញ្ញាណដើមម្ចាស់គាត់ក៏វេទនា, បន្ទាប់ពីទាំងអស់យុវវ័យទាំងមូលរបស់គាត់សុទ្ធតែអង្គុយនៅទីនោះរួចហើយ, រយៈពេលមនុស្សសាមញ្ញបានកន្លងផុតទៅហើយ។ ដូច្នោះធ្វើដូចម្តេច? គាត់មានអារម្មណ៍ថាគាត់ចេញពីសមាធិកាលណាខ្លួនឯងហាត់ចេញគង់មកហើយ, មានសីលគង់រួច

ហើយ, គាត់ចង់ព្យាបាលជំងឺ, ចង់ធ្វើអីគឺអាចធ្វើនោះ, វិញ្ញាណដើមរង នឹងបំពេញចិត្តគាត់។ ព្រោះបន្ទាប់ពីទាំងអស់គាត់ជាវិញ្ញាណដើមម្ចាស់, វិញ្ញាណដើមម្ចាស់ធ្វើម្ចាស់រាងកាយ, ជាអ្នកសម្រេចចិត្ត។ ថៃមទៀត ច្រើនឆ្នាំយ៉ាងនេះគាត់អង្គុយនៅទីនេះ, មួយជីវិតក៏កន្លងផុតរួចហើយ។ បន្ទាប់ពីដល់អាយុ១០០, វិញ្ញាណដើមរងចេញទៅ, ម្នាក់ដើរមួយផ្លូវ។ តាមពុទ្ធសាសនាសម្តែង, គាត់នៅតែត្រូវចូលក្នុង៦ផ្លូវ។ ដោយសារក្នុង រាងកាយគាត់បានប្ញួសចេញមកអង្គមហាត្រាស់ដឹងមួយ, គាត់ក៏ជាសន្សំ បានមហាគុណធម៌, នោះធ្វើដូចម្តេច? អាចជាជាតិក្រោយធ្វើមន្ត្រីធំ, មានទ្រព្យសម្បត្តិធំ។ ក៏គ្រាន់តែអាចបែបនេះ, នោះមិនប្ញួសស្មើសូន្យឬ?

រឿងនេះយើងខ្ញុំយកចេញមកសម្តែង, ក៏ជាចំណាយនិងកង្វល់ដ៏ ច្រើនទើបបានយល់ព្រមសម្តែង។ ខ្ញុំបានចង្អុលបង្ហាញចេញភាពវង្វេង គ្រប់យុគ្គសម័យ, អាថ៌កំបាំងក្នុងអាថ៌កំបាំងដែលដាច់ខាតមិនអាច សម្តែង, ចង្អុលបង្ហាញចេញមូលដ្ឋាននៃវិធីសាស្ត្រប្ញួសហាត់គ្រប់ប្រភេទ ដែលប្ញួសហាត់សម័យប្រវត្តិសាស្ត្រ។ ខ្ញុំមិនមែនបានសម្តែងថាពាក់ព័ន្ធ ដល់ប្រវត្តិប្រភពដើមដ៏ជ្រៅឬ? ជាក់ស្តែងគឺមូលហេតុទាំងនេះ។ លោក អ្នកគិតសាកមើល, តើវង្សណា, ធម្មក្ខន្ធណាមិនមែនប្ញួសហាត់បែបនេះ? លោកអ្នកខ្លួនឯងប្ញួសមកប្ញួសទៅតែលោកអ្នកគ្មានគង់, លោកអ្នកមិន គួរឲ្យអាណិតឬ! នោះនៅអាចបន្ទោសនរណា? មនុស្សជាក់ស្តែងគឺវង្វេង យ៉ាងនោះ, ជាក់ស្តែងគឺមិនភ្ញាក់ដឹង, ដាស់បំភ្លឺដូចម្តេចក៏មិនបាន។ និយាយខ្ពស់ស្តាប់ទៅអាថ៌កំបាំង, និយាយទាបភ្ញាក់ដឹងមិនឡើងបាន។ ខ្ញុំសម្តែងយ៉ាងនេះរួចហើយ, នៅតែមានមនុស្សហៅខ្ញុំព្យាបាលជំងឺឲ្យ គាត់, ខ្ញុំពិតជាមិនដឹងនិយាយអ្វីជាមួយគាត់, យើងខ្ញុំសម្តែងប្ញួសហាត់, ប្ញួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់ទើបអាចគ្រប់គ្រង។

ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំគឺសតិម្ចាស់ទទួលបានគង់, ដូច្នោះ លោកអ្នកនិយាយថាសតិម្ចាស់ទទួលបានគង់គឺសតិម្ចាស់ទទួលបាន គង់? នរណាអនុញ្ញាត? មិនមែនជាបែបនេះ, វាចាំបាច់ត្រូវមានលក្ខ ខណ្ឌជាមុន។ អ្នករាល់គ្នាបានដឹង, ធម្មក្ខន្ធមួយនេះរបស់ពួកយើងមិន ចៀសវាងសង្គមមនុស្សសាមញ្ញដើម្បីបួសហាត់, មិនចៀសវាង, មិនរត់ គេចទំនាស់; នៅក្នុងបរិយាកាសស្មុគស្មាញនេះរបស់មនុស្សសាមញ្ញ, លោកអ្នកគឺដឹងខ្លួនភ្លឺច្បាស់, ច្បាស់ឥតខ្ចោះទទួលរងខាតបង់នៅលើ បញ្ហាផលប្រយោជន៍, ពេលដែលត្រូវអ្នកដទៃលួចយកផលប្រយោជន៍, លោកអ្នកមិនដូចអ្នកដទៃទៅប្រជែងទៅប្រយុទ្ធ; នៅក្នុងជ្រៀតជ្រែកចិត្ត ចរិតគ្រប់ប្រភេទ, លោកអ្នកកំពុងទទួលរងខាតបង់; លោកអ្នកនៅក្នុង បរិយាកាសទុក្ខពិបាកនេះ, ហ្វឹកហាត់ឆន្ទៈរបស់លោកអ្នក, លើកកម្ពស់ ចិត្តចរិតរបស់លោកអ្នក, នៅក្រោមឥទ្ធិពលមនោគតិមិនល្អគ្រប់ប្រភេទ របស់មនុស្សសាមញ្ញ, លោកអ្នកអាចផ្តាច់ចេញមកបាន។

អ្នករាល់គ្នាគិតសាកមើល, ច្បាស់ឥតខ្ចោះរងទុក្ខតើមិនមែនលោក អ្នក, បង់ចំណាយតើមិនមែនវិញ្ញាណដើមរបស់លោកអ្នក, លោកអ្នក បាត់ទៅអ្វីនៅក្នុងមនុស្សសាមញ្ញ, តើមិនមែនលោកអ្នកបាត់ទៅដោយ ច្បាស់ឥតខ្ចោះ? ដូច្នោះគង់នេះគឺគួរតែលោកអ្នកបាន, នរណាបាត់អ្នក នោះបាន។ ដូច្នេះនេះជាក់ស្តែងគឺមូលហេតុហេតុអ្វីធម្មក្ខន្ធមួយនេះរបស់ ពួកយើង, មិនបំបែកចេញពីបរិយាកាសស្មុគស្មាញនេះរបស់មនុស្ស សាមញ្ញដើម្បីបដិបត្តិបួសហាត់។ ហេតុអ្វីពួកយើងត្រូវការបួសហាត់នៅ ក្នុងទំនាស់របស់មនុស្សសាមញ្ញ? ជាក់ស្តែងគឺដោយសារពួកយើងចង់ ខ្លួនឯងទទួលបានគង់។ អនាគតសិស្សបួសជំនាញនៅវត្តអារាមបួស ហាត់ត្រូវទៅឃ្វីនយូរក្នុងមនុស្សសាមញ្ញ។

មនុស្សមួយចំនួននិយាយថា៖ បច្ចុប្បន្នគង់ហ្វាដទៃក៏ហាត់នៅក្នុងមនុស្សសាមញ្ញ? ប៉ុន្តែទាំងនោះសុទ្ធតែជាសកលព្យាបាលជំងឺកាយសម្បទា, ពិតប្រាកដបួសហាត់ឡើងជាន់ថ្នាក់ខ្ពស់ក្រៅពីបង្រៀនឯកតាគ្មាននរណាបង្រៀនជាសាធារណៈ។ ពិតប្រាកដនាំកូនសិស្ស, បាននាំកូនសិស្សទៅអស់រួចហើយ, បង្រៀនឯកជនតែប៉ុណ្ណោះ។ ច្រើនឆ្នាំយ៉ាងនេះ, នរណាសម្តែងរឿងនេះឲ្យសាធារណជនលើទ្រង់ទ្រាយធំ? គ្មាននរណាសម្តែង។ ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំសម្តែងបែបនេះ, ដោយសារយើងខ្ញុំជាក់ស្តែងគឺជាប្រភេទធម៌បួសបែបនេះ, ជាក់ស្តែងគឺទទួលបានគង់បែបនេះ។ ក្នុងពេលដំណាលគ្នា, មិនត្រឹមតែរាប់ពាន់រាប់ម៉ឺនអ្វីៗត្រូវបានដំឡើងក្នុងធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំ, ទាំងអស់ដំឡើងឲ្យវិញ្ញាណដើមម្ចាស់របស់លោកអ្នក, ពិតប្រាកដទុកឲ្យលោកអ្នកខ្លួនឯងទទួលបានគង់។ ខ្ញុំនិយាយថាខ្ញុំបានធ្វើរឿងមួយដែលមនុស្សពីមុនមិនដែលធ្វើ, បានបើកស្លាបទ្វារមួយធំបំផុត។ ពាក្យនេះរបស់ខ្ញុំមនុស្សខ្លះស្តាប់និងយល់ច្បាស់, ប្រការខ្ញុំសម្តែងពិតជាមិនអាចកំបាំង។ ឯកជនខ្ញុំនេះមានទម្លាប់, បើសិនខ្ញុំមាន១ចួាង, ខ្ញុំនិយាយ១ឆី, លោកអ្នកនិយាយខ្ញុំផ្លុំបំប៉ោង។ ភាពពិតនេះគ្រាន់តែជានិយាយចេញបន្តិចប៉ុណ្ណោះ, មហាធម៌ខ្ពស់ជ្រៅជាងដោយសារតែជាន់ថ្នាក់ខុសគ្នាខ្លាំងពេក, ជាមូលដ្ឋានខ្ញុំគឺមិនអាចសម្តែងឱ្យលោកអ្នកបន្តិចសោះ។

ធម្មក្ខន្ធមួយនេះរបស់ពួកយើងជាក់ស្តែងគឺបួសហាត់បែបនេះ, ទុកឲ្យលោកអ្នកខ្លួនឯងពិតប្រាកដទទួលបានគង់, នេះជាលើកដំបូងតាំងពីបើកមេឃបង្កើតដី, លោកអ្នកអាចសាកត្រួតពិនិត្យប្រវត្តិសាស្ត្រ។ ល្អគឺល្អនៅលោកអ្នកខ្លួនឯងទទួលបានគង់, ប៉ុន្តែក៏ដ៏ពិបាកផងដែរ។ នៅក្នុងបរិយាកាសស្មុគស្មាញរបស់មនុស្សសាមញ្ញ, នៅក្នុងកកិតចិត្តចរិតរវាង

មនុស្សនិងមនុស្ស, លោកអ្នកអាចផ្លោះចេញមកបាន, នេះគឺពិបាកបំផុត។ ពិបាកគឺពិបាកនៅកន្លែងលោកអ្នកទទួលរងខាតបង់ដោយច្បាស់ឥតខ្ចោះនៅក្នុងផលប្រយោជន៍មនុស្សសាមញ្ញ, នៅពីមុខផលប្រយោជន៍ផ្ទាល់ខ្លួន, លោកអ្នកកម្រើកចិត្តឬអត់; នៅក្នុងការកម្ចាត់គ្នារវាងមនុស្សនិងមនុស្ស, លោកអ្នកកម្រើកចិត្តឬអត់; នៅពេលញាតិមិត្តជិតស្និទ្ធរងទុក្ខឈឺចាប់, លោកអ្នកកម្រើកចិត្តឬអត់, លោកអ្នកទៅវាស់វែងបែបណា, ធ្វើជាមនុស្សហាត់គង់ម្នាក់គឺពិបាកយ៉ាងនេះ! មានមនុស្សម្នាក់និយាយជាមួយខ្ញុំថា៖ លោកគ្រូ, ធ្វើមនុស្សល្អនៅក្នុងមនុស្សសាមញ្ញគឺបានហើយ, នរណាអាចបួសឡើងលើបាន? ខ្ញុំស្ដាប់ហើយពិតជាខកចិត្ត! គ្មានពាក្យអ្វីនិយាយជាមួយគាត់ទៀត។ ចិត្តចរិតបែបណាក៏មាន, គាត់អាចភ្ញាក់ដឹងខ្ពស់ដល់ណាគឺភ្ញាក់ដឹងខ្ពស់ដល់នោះ, នរណាភ្ញាក់ដឹងអ្នកនោះបាន។

ឡៅជឺសម្ដែង៖ តាវ, ខឿតាវ, ហ្វីឆាងតាវ។ នោះប្រសិននៅពេញដីរើសឡើងគឺបួសសម្រេច, វាក៏ជាមិនដឹមានតម្លៃ។ ធម្មក្ខន្ធនេះរបស់យើងខ្ញុំគឺនៅក្នុងទំនាស់ទុកឲ្យលោកអ្នកខ្លួនឯងទទួលបានគង់, ដូច្នេះពួកយើងត្រូវការអតិបរមាទៅសមស្របនឹងមនុស្សសាមញ្ញ, ខាងសម្ភារៈក៏មិនមែនទុកឱ្យលោកអ្នកពិតប្រាកដបាត់ទៅអ្វី។ ប៉ុន្តែនៅក្នុងបរិយាកាសសម្ភារៈនេះផ្ទុយមកវិញលោកអ្នកត្រូវតែលើកកម្ពស់ចិត្តចរិត។ ងាយស្រួលគឺងាយស្រួលនៅកន្លែងនេះ, ធម្មក្ខន្ធមួយនេះរបស់យើងខ្ញុំងាយស្រួលបំផុត, អាចបួសហាត់នៅក្នុងមនុស្សសាមញ្ញ, អាចមិនចាំបាច់សាងផ្នួស។ ដូច្នោះពិបាកបំផុតក៏ជាពិបាកនៅកន្លែងនេះ, បួសហាត់នៅក្នុងបរិយាកាសមនុស្សសាមញ្ញស្មុគស្មាញបំផុត។ ប៉ុន្តែល្អបំផុតក៏ល្អនៅកន្លែងនេះ, ដោយសារគាត់ទុកឲ្យលោកអ្នកខ្លួនឯងទទួលបានគង់, នេះ

ជាក់ស្តែងគឺប្រការគន្លឹះបំផុតនៃធម្មក្ខន្ធមួយនេះរបស់ពួកយើង, ថ្ងៃនេះខ្ញុំសម្តែងចេញមកឲ្យអ្នករាល់គ្នា។ ប្រាកដណាស់, វិញ្ញាណដើមម្ចាស់ទទួលបានគង់, វិញ្ញាណដើមរងក៏ទទួលបានគង់ ហេតុអ្វីហ្ន៎? ព័ត៌មានទាំងអស់, កាយវិញ្ញាណទាំងអស់របស់រាងកាយលោកអ្នក, កោសិការបស់លោកអ្នកសុទ្ធតែកំពុងបង្កើនគង់។ ប្រាកដណាស់គាត់ក៏នឹងបង្កើនគង់។ ប៉ុន្តែដល់ពេលណាក៏ដោយគាត់ក៏គ្មានខ្ពស់ស្មើលោកអ្នក, លោកអ្នកជាម្ចាស់, វាជាការពារធម៌។

សម្តែងដល់ទីនេះ, ខ្ញុំក៏ចង់និយាយប្រយោគមួយ។ ពិភពបួសហាត់ពួកយើងមានមិនតិចមនុស្សបែបនេះ, តែងតែចង់បួសហាត់ឡើងជាន់ថ្នាក់ខ្ពស់។ ដល់គ្រប់ទីកន្លែងដើម្បីរកធម៌, ចំណាយអស់លុយមិនតិច, ភ្នំត្បូងសមុទ្រជើងដើរអស់មួយជុំ, ទៅរកគ្រូល្បីក៏រកមិនជួប។ មានឈ្មោះល្បីមិនជាក់លាក់គឺពិតប្រាកដដឹងច្បាស់។ លទ្ធផលខាតកម្លាំងទៅគ្រប់កន្លែង, ហត់កាយខាតប្រាក់, ក៏គ្មានទទួលបានអ្វី។ គង់ហ្វាល្អយ៉ាងនេះ, យើងខ្ញុំថ្ងៃហ្នឹងយកចេញមកផ្តល់ឲ្យលោកអ្នក, ខ្ញុំបានលើកឲ្យលោកអ្នក, ផ្ញើមកដល់មាត់ទ្វាររបស់លោកអ្នក។ នេះគឺមើលលោកអ្នកអាចបួសឬអត់, អាចបដិបត្តិឬអត់។ បើលោកអ្នកអាចបដិបត្តិ, លោកអ្នកគឺបន្តបួស; បើលោកអ្នកមិនអាចបដិបត្តិ, បើលោកអ្នកបួសមិនបាន, នោះពីពេលនេះតទៅលោកអ្នកកុំគិតដល់បួសហាត់ទៀត។ ក្រៅពីខ្មោចបញ្ឆោតលោកអ្នកគ្មាននរណាបង្រៀនលោកអ្នកទៀត។ ក្រោយមកលោកអ្នកគឺកុំបួសទៀត។ ប្រសិនខ្ញុំប្រោសលោកអ្នកមិនបាន, នរណាក៏ប្រោសមិនបានលោកអ្នក។ ភាពពិតបច្ចុប្បន្នចង់រកគ្រូសុចរិតធម៌ពិតប្រាកដដើម្បីបង្រៀនលោកអ្នក, ពិបាកជាងឡើងលើមេឃ, ជាមូលដ្ឋានគឺគ្មានរណាគ្រប់គ្រង។ សម័យកាលផុតធម៌, ជាន់ថ្នាក់ដ៏ខ្ពស់សុទ្ធតែនៅក្នុងផុតកប្ប,

កាន់តែគ្រប់គ្រងមិនបានមនុស្សសាមញ្ញ។ នេះជាធម្មក្ខន្ធមួយងាយស្រួលបំផុត, លើសពីនេះគឺដោយផ្ទាល់យោងតាមចរិតពិសេសនៃចក្រវាលដើម្បីហាត់, ប្អូសលឿនបំផុតកាត់បំផុតរួចហើយ, ចង្អុលផ្ទាល់ចិត្តមនុស្ស។

## វង់សកល

នៅក្នុងតាវង្សសម្តែងវង់សកលធំតូច, យើងខ្ញុំក៏សម្តែងបន្តិចវង់សកលជាអ្វី។ វង់សកលធម្មតាដែលពួកយើងសម្តែងគឺតភ្ជាប់២ខ្សែវណ្ណរ៉ឹន-ទូជាមួយគ្នា, វង់សកលនេះជាវង់សកលសំបកក្រៅ, គ្មានអ្វីសំខាន់, គ្រាន់តែជាប្រការព្យាបាលជំងឺកាយសម្បទា, នេះហៅថាវង់សកលតូច។ នៅមានប្រភេទវង់សកលមួយទៀត, វាមិនហៅថាវង់សកលតូច, ក៏មិនហៅថាវង់សកលធំ, គឺទម្រង់វង់សកលប្អូសហាត់ក្នុងសមាធិ។ វាគឺពីខាងក្នុងរាងកាយ, ពីនីវ៉ានដើរមួយជុំចុះក្រោម, ពីខាងក្នុងរាងកាយដល់តានធានវិលមួយជុំឡើងលើ, ដំណើរជុំខាងក្នុង, នោះគឺវង់សកលពិតប្រាកដប្អូសហាត់ក្នុងសមាធិ។ ហើយក្រោយពីវង់សកលនេះបង្កើតក៏នឹងបង្កើតជាចរន្តថាមពលដ៏ខ្លាំងមួយ, ក្រោយមកខ្សែវណ្ណមួយទាញរយខ្សែវណ្ណ, ទាញខ្សែវណ្ណដទៃទៀតសុទ្ធតែបើកតាម។ តាវង្សសម្តែងវង់សកល, ពុទ្ធសាសនាមិនសម្តែងវង់សកល។ ពុទ្ធសាសនាសម្តែងអ្វី? សក្យមុនីនៅពេលបង្រៀនសំណុំធម៌នោះរបស់គាត់គ្មានសម្តែងគង់, មិនសម្តែងគង់, ប៉ុន្តែគង់ហ្វារបស់គាត់ក៏មានទម្រង់វិវត្តន៍ប្អូសហាត់របស់គាត់។ ខ្សែវណ្ណក្នុងពុទ្ធសាសនាគឺដើរទិសដូចម្តេច? ចាប់ផ្តើមពីស្មៀវរ៉ីប៉ាយហួយបើកស្រឡះ, បន្ទាប់មកអភិវឌ្ឍពីលើកំពូលក្បាលឆ្លោះចុះរាងកាយតាមទម្រង់គួទខ្យង, ចុងក្រោយតាមរយៈទម្រង់នេះទាញរយខ្សែវណ្ណបើកតាម។

ខ្សែរវណ្ណៈកណ្តាលក្នុងមីចុងក៏ជាគោលបំណងនេះ។ មានមនុស្ស និយាយថាគ្មានខ្សែរវណ្ណៈកណ្តាល, ដូច្នោះហេតុអ្វីមីចុងអាចបួសហាត់ ចេញបានខ្សែរវណ្ណៈកណ្តាល? ភាពពិតខ្សែរវណ្ណៈទាំងអស់លើរាងកាយ មនុស្សប្ចូកបញ្ចូលគ្នា, ជាងរាប់ម៉ឺនខ្សែ, គឺស្រដៀងសរសៃឈាមឈរនិង ផ្តេកឆ្លងកាត់គ្នា, ទាំងច្រើនជាងសរសៃឈាមទៀត។ ផ្នែកចន្លោះនៃ សរីរាង្គខាងក្នុងគ្មានសរសៃឈាម, តែផ្ទុយមកវិញមានខ្សែរវណ្ណៈ។ ពីកំ ពូលក្បាលដល់គ្រប់ទីតាំងនៃរាងកាយក៏ជាខ្សែរវណ្ណៈឈរនិងផ្តេកឆ្លងកាត់ គ្នា, យកពួកវាតភ្ជាប់ជាមួយគ្នា, ពេលចាប់ផ្តើមអាចជាមិនត្រង់, តភ្ជាប់ ជាមួយគ្នាវាយស្រឡះ។ បន្ទាប់មកបន្តិចម្តងៗពង្រីក, សន្សឹមៗគឺបង្កើត ជាខ្សែរវណ្ណៈមួយត្រង់។ យកខ្សែរវណ្ណៈនេះធ្វើអ័ក្សបង្វិលដោយខ្លួនឯង, ទាញកម្រើកកង់មួយចំនួនក្នុងគំនិតបង្វិលតាមទិសផ្តេក, គោលបំណង ក៏ជាចង់យកខ្សែរវណ្ណៈទាំងអស់នៃរាងកាយទាញបើកតាមទាំងស្រុង។

បួសហាត់ហ្វាលូនតាហ្វាពួកយើងចៀសវាងទម្រង់ "ខ្សែរវណ្ណៈមួយ ទាញរយខ្សែរវណ្ណៈ" នេះ, ទើបចាប់ផ្តើមគឺតម្រូវរយខ្សែរវណ្ណៈទាញបើកក្នុង ពេលតែមួយ, រយខ្សែរវណ្ណៈបង្វិលក្នុងពេលតែមួយ។ ពួកយើងភ្លាមៗឈរ នៅលើជាន់ថ្នាក់ដ៏ខ្ពស់ដើម្បីហាត់, ចៀសវាងរបស់ដ៏ទាប។ ខ្សែរវណ្ណៈមួយ ទាញរយខ្សែរវណ្ណៈ, លោកអ្នកប្រសិនចង់យកវាទាញបើកទាំងអស់, មនុស្សខ្លះហាត់មួយជីវិតនៅតែពិបាកសម្រេចបាន; មនុស្សខ្លះត្រូវតែ បួសហាត់រាប់សិបឆ្នាំ, ដ៏ពិបាក។ នៅក្នុងគង់ហ្វាដ៏ច្រើនសម្តែងថាមួយ ជាតិបួសមិនសម្រេច, មានមនុស្សជាច្រើនបួសហាត់ក្នុងមហាធម៌ខ្ពស់ ជ្រៅអាចអូសវែងអាយុកាល, មិនមែនគាត់សម្តែងបួសជីវិតឬ? អាចអូស វែងអាយុកាលដើម្បីបួសហាត់, បួសកាលណាពេលវេលាដ៏យូរ។

វង់សកលតូចជាមូលដ្ឋានគ្រាន់តែជាព្យាបាលជំងឺកាយសម្បទា,

ហើយវង់សកលធំជាក់ស្តែងគឺជាបួសហាត់, ជាក់ស្តែងគឺជាមនុស្សបួសហាត់ពិតប្រាកដ។ វង់សកលធំដែលតាវវង្សសំដៅលើមិនខ្លាំងក្លាដូចរបស់ពួកយើង, រយខ្សែវណ្ណទាំងស្រុងវាយបើក។ វាគឺជាប៉ុន្មានខ្សែវណ្ណនោះបង្វិល, ៣ខ្សែអវិជ្ជមាន៣ខ្សែវិជ្ជមាននៅដៃ, ក្រោមជើង, ភ្លៅពីររហូតដល់ក្បាលសក់, ដើរពាសពេញរាងកាយមួយលើក, នេះគឺចាត់ថាវដ្តវង់សកលធំ។ វង់សកលធំទើបចាប់ផ្តើមជាក់ស្តែងគឺជាបួសហាត់ពិតប្រាកដ, ដូច្នេះមានគ្រូឈីគង់មួយចំនួនចំពោះវង់សកលធំគឺមិនបង្រៀន, ដែលគាត់បង្រៀនគ្រាន់តែជាប្រការព្យាបាលជំងឺកាយសម្បទា។ មានមនុស្សមួយចំនួនក៏សម្តែងអំពីវង់សកលធំ, ប៉ុន្តែគាត់គ្មានដំឡើងអ្វីឲ្យលោកអ្នក, លោកអ្នកខ្លួនឯងក៏វាយមិនស្រឡះ។ មិនដំឡើងអ្វីសោះ, ខ្លួនឯងពឹងផ្អែកលើគំនិតចង់វាយស្រឡះ, និយាយងាយស្រួលពេកហើយ! គ្រាន់តែដូចហាត់កីឡា, អាចធ្វើឱ្យវាបើកបានឬ? បួសនៅខ្លួនឯង, គង់នៅលោកគ្រូ, [យន្តការ] នេះខាងក្នុងទាំងស្រុងដំឡើងឲ្យលោកអ្នកទើបអាចផ្តើមផលប៉ះពាល់បែបនេះ។

តាវវង្សពីដើមមកមើលរាងកាយមនុស្សជាចក្រវាលតូចមួយ, គាត់សន្មតថាចក្រវាលខាងក្រៅធំប៉ុណ្ណា, ខាងក្នុងធំប៉ុណ្ណោះ, ខាងក្រៅជាបែបណា, ខាងក្នុងគឺបែបនោះ។ រឿងនេះសម្តែងមកហាក់ដូចជាមិនគួរឲ្យជឿ, មិនសូវងាយស្រួលពន្យល់។ ចក្រវាលនេះធំយ៉ាងនេះ, ធ្វើម្តេចអាចប្រៀបធៀបនឹងរាងកាយមនុស្ស? ពួកយើងសម្តែងគោលសីលធម៌មួយបែបនេះ, រូបវិទ្យាពួកយើងបច្ចុប្បន្នស្រាវជ្រាវសមាសភាគរបស់សារធាតុ, ពីម៉ូលេគុល, អាតូម, អេឡិចត្រុង, ប្រូតុង, គ្រាប់ quark, រហូតដល់ neutrino, ឆ្ពោះចុះក្រោមទៀតទំហំប៉ុណ្ណា? ដល់ជំហានមួយនោះមីក្រូទស្សន៍បានមើលមិនឃើញរួចហើយ, ឆ្ពោះចុះក្រោមភាគល្អិតយ៉ាងតូច

បំផុតទៀតជាអ្វី? មិនដឹង។ ភាពពិតចំណុចមួយនេះដែលរូបវិទ្យាបច្ចុប្បន្ន ពួកយើងយល់ដឹងបាន, ប្រៀបនឹងភាគល្អិតអតិសុខុមបំផុតក្នុងចក្រវាល នេះនៅខុសឆ្ងាយខ្លាំងណាស់។ ពេលដែលមនុស្សគ្មានរាងកាយសាច់, ភ្នែករបស់មនុស្សមើលអ្វីៗគឺអាចផ្តើមផលប៉ះពាល់ពង្រីកធំ, អាចមើលឃើញដល់អតិសុខុម។ ជាន់ថ្នាក់កាន់តែខ្ពស់, មើលឃើញដល់អតិសុខុមកាន់តែធំ។

សក្យមុនីនៅក្នុងជាន់ថ្នាក់មួយបែបនោះ, គាត់បានសម្តែងអំពីទ្រឹស្តី ៣ពាន់មហាពិភព, ពោលគឺនិយាយក្នុងកញ្ចុំផ្កាយនេះ, ក៏មានស្ថិតនៅមនុស្សមានកាយសម្បុរបែបនេះដូចមនុស្សជាតិពួកយើង។ នៅសម្តែងទ្រឹស្តីទៀតថាក្នុងគ្រាប់ខ្សាច់មួយរួមបញ្ចូល៣ពាន់មហាពិភព, គឺស្របនឹងការយល់ដឹងរបស់រូបវិទ្យាទំនើបរបស់ពួកយើង, ទម្រង់ធ្វើចលនាដែលអេឡិចត្រុងវិលជុំវិញស្នូលអាតូមនិងផែនដីធ្វើចលនាវិលជុំវិញព្រះអាទិត្យ, មានអ្វីខុសគ្នា? ដូច្នេះសក្យមុនីសម្តែង, នៅក្រោមអតិសុខុម, ក្នុងគ្រាប់ខ្សាច់មួយមាន៣ពាន់មហាពិភព, នោះគឺស្រដៀងចក្រវាលមួយ, ខាងក្នុងមានជីវិតមានសារធាតុ។ ប្រសិនជាពាក្យពិត, អ្នករាល់គ្នាគិតសាកមើល, ដូច្នោះខាងក្នុងពិភពរបស់ខាងក្នុងគ្រាប់ខ្សាច់នោះតើមិនមែននៅមានគ្រាប់ខ្សាច់, ដូច្នោះខាងក្នុងគ្រាប់ខ្សាច់របស់ខាងក្នុងគ្រាប់ខ្សាច់នោះតើមិនមែននៅមាន៣ពាន់មហាពិភព? ដូច្នោះ៣ពាន់មហាពិភពខាងក្នុងគ្រាប់ខ្សាច់របស់ខាងក្នុងគ្រាប់ខ្សាច់នោះតើមិនមែនជានៅមានខ្សាច់? ឆ្ពោះចុះក្រោមរកមើលបន្តគឺគ្មានទីបញ្ចប់, ដូច្នេះសក្យមុនីសម្រេចបានជាន់ថ្នាក់យូឡាយមួយបែបនេះ, ផ្ទុយមកវិញគាត់សម្តែងចេញមកប្រយោគមួយបែបនេះ៖ [ធំនោះគ្មានក្រៅ, តូចនោះគ្មានក្នុង]។ ធំ, មើលមិនឃើញព្រំដែនរបស់ចក្រវាល; តូច, មើលមិនឃើញរបស់ល្អិត

បំផុតនៃប្រភពដើមសារធាតុរបស់វាជាអ្វី។

គ្រូឈីគង់ខ្លះសម្តែងថា៖ ខាងក្នុងរន្ធញើសមានទីក្រុង, ខាងក្នុងរថភ្លើងកំពុងរត់, រថយន្តកំពុងរត់។ ស្តាប់ទៅដ៏អាថ៌កំបាំង, ប៉ុន្តែយើងខ្ញុំឈរនៅលើទស្សនៈរបស់វិទ្យាសាស្ត្រពិតប្រាកដដើម្បីពន្យល់, ដើម្បីស្រាវជ្រាវ, រកឃើញថាការថ្លែងនេះក៏មិនអាថ៌កំបាំង។ ថ្ងៃនោះពេលខ្ញុំសម្តែងបើកភ្នែកទិព្វ, មានមនុស្សដ៏ច្រើនបើកភ្នែកទិព្វនឹងលេចឡើងទស្សនីយភាពបែបនេះ៖ គាត់រកឃើញថាពីផ្លូវរន្ធក្នុងថ្ងាសរបស់គាត់រត់ចេញក្រៅ, ហាក់ដូចជារត់ជានិច្ចក៏មិនដល់ក្បាល។ រាល់ថ្ងៃហាត់គង់សុទ្ធតែពីផ្លូវធំមួយនេះរត់ចេញក្រៅ, សងខាងមានភ្នំ, មានទឹក, ពេលដែលរត់នៅតែត្រូវឆ្លងកាត់ទីក្រុង, នៅមើលឃើញមនុស្សជាច្រើនៗ។ គាត់មានអារម្មណ៍ថានេះជាការបំភាន់។ តើរឿងដូចម្តេច? មើលឃើញច្បាស់លាស់ណាស់, មិនមែនការបំភាន់។ ខ្ញុំសម្តែងថា, ប្រសិនរាងកាយមនុស្សនៅក្រោមអតិសុខុមពិតជាធំមហិមាយ៉ាងនោះ, នោះគឺមិនមែនការបំភាន់។ ដោយសារតាវវង្សហាត់គង់ពីដើមមកមើលរាងកាយមនុស្សជាចក្រវាលតូចមួយ, ប្រសិនពិតជាចក្រវាលមួយ, ពីខាងមុខថ្ងាសដល់ក្រពេញស្រល់មិនគ្រាន់តែជា១០ម៉ឺន៨ពាន់លី, លោកអ្នកសម្រុកចេញក្រៅ, ដ៏ឆ្ងាយដាច់សង្វែង។

ប្រសិននៅក្នុងដំណើរការបួសហាត់ក្រោយពីវាយស្រឡះទាំងស្រុងវង់សកលធំ, នឹងនាំមកឲ្យអ្នកបួសហាត់ប្រភេទសីលគង់មួយ, សីលគង់អ្វី? អ្នករាល់គ្នាដឹង, វង់សកលធំក៏បានហៅថាវង់សកលខ្សែបណ្តោយ, ក៏បានហៅថាការបង្វិលឈានយុន, ក៏បានហៅថាការបង្វិលហឿឆឿ។ នៅក្នុងជាន់ថ្នាក់ដ៏រាក់វង់សកលធំបង្វិលគឺបង្កើតជាចរន្តថាមពលមួយ, វានឹងបន្តិចម្តងៗបង្កើនដង់ស៊ីតេបំប្លែងសំដៅឡើងជាន់ថ្នាក់ខ្ពស់ជាង,

នឹងប្រែក្លាយជាខ្សែក្រវាត់ថាមពលមួយមានដង់ស៊ីតេដ៏ធំ។ ខ្សែក្រវាត់ថាមពលនេះវាកំពុងបង្វិល, នៅក្នុងដំណើរការបង្វិល, ពួកយើងនៅក្នុងជាន់ថ្នាក់ដ៏រាក់ប្រើភ្នែកទិព្វដើម្បីមើល, រកឃើញថាវាអាចធ្វើឲ្យឈីខាងក្នុងរាងកាយផ្លាស់ទី៖ ឈីលើបេះដូងរត់ទៅលើពោះវៀន; ឈីលើថ្លើមរត់ទៅលើក្រពះ..............ប្រសិនអាចមើលឃើញនៅក្រោមអតិសុខុមវាកំពុងផ្ទេរជញ្ជូនគឺជារបស់ដ៏ធំ, ប្រសិនយកខ្សែក្រវាត់ថាមពលនេះវាយចេញដល់ខាងក្រៅរាងកាយ, វាជាក់ស្ដែងជាសីលគង់ផ្ទេរជញ្ជូន។ មនុស្សដែលគង់ដ៏ខ្លាំងក្លា, អាចផ្ទេរជញ្ជូនរបស់ដ៏ធំ, ពោលគឺផ្ទេរជញ្ជូនធំ។ មនុស្សដែលគង់ដ៏ខ្សោយ, អាចផ្ទេរជញ្ជូនរបស់ដ៏តូច, ពោលគឺផ្ទេរជញ្ជូនតូច។ នេះជាក់ស្ដែងជាទម្រង់សីលគង់ផ្ទេរជញ្ជូននិងការបង្កើតរបស់វា។

វង់សកលធំដោយផ្ទាល់ជាក់ស្ដែងគឺជាហាត់គង់, ដូច្នេះនឹងនាំមកស្ថានភាពខុសគ្នានិងទម្រង់របស់គង់ខុសគ្នា, វាក៏នឹងនាំមកឲ្យពួកយើងស្ថានភាពមួយដ៏ពិសេស។ ស្ថានភាពអ្វី? អ្នករាល់គ្នាអាចនៅក្នុងសៀវភៅបុរាណ, ដូចជា《ស្ទិនសៀនឆន》ឬក៏ជាក្នុង《តានជិញ》,《តាវចាង》,《ស៊ីញមិញហួយជី》, សុទ្ធតែសរសេរប្រយោគមួយបែបនេះ, ហៅថា [កណ្ដាលថ្ងៃចែសហោះឡើង], ពោលគឺពេលថ្ងៃច្បាស់ចែសមនុស្សនេះហោះឡើង។ ភាពពិតខ្ញុំប្រាប់អ្នករាល់គ្នា, វង់សកលធំ{បើក}ស្រឡះកាលណាឯកជននេះគឺអាចហើរឡើងអាកាស, គឺសាមញ្ញយ៉ាងនេះ។ មានមនុស្សគិតថា, ហាត់គង់ច្រើនឆ្នាំយ៉ាងនេះ, មនុស្ស{បើក}ស្រឡះវង់សកលធំក៏មិននៅភាគតិច។ ខ្ញុំនិយាយថារាប់ម៉ឺននាក់អាចសម្រេចបានកម្រិតនេះក៏គ្មានអ្វីចម្លែក, ដោយសារវង់សកលធំវាយ៉ាងណាមិញគ្រាន់តែជាជំហានដំបូងក្នុងហាត់គង់។

ដូច្នោះហេតុអ្វីមិនឃើញមនុស្សទាំងនេះអណ្ដែតឡើង? មើលមិន

ឃើញគាត់ហើរឡើងអាកាស? ស្ថានភាពរបស់សង្គមមនុស្សសាមញ្ញគឺមិនអាចបំផ្លាញ, មិនអាចតាមអំពើចិត្តបំផ្លាញឬក៏ផ្លាស់ប្រែទម្រង់សង្គមរបស់សង្គមមនុស្សសាមញ្ញ, មនុស្សសុទ្ធតែហើរនៅលើមេឃនោះអាចបានឬ? នោះជាសង្គមមនុស្សសាមញ្ញឬ? នេះគឺទិដ្ឋភាពមួយចម្បង; ទិដ្ឋភាពមួយផ្សេងទៀត, មនុស្សក្នុងមនុស្សសាមញ្ញមិនមែនដើម្បីធ្វើមនុស្ស, គឺដើម្បីត្រឡប់ដើមមកសច្ចៈ, ដូច្នេះនៅមានបញ្ហាចរិតភ្ញាក់ដឹង។ គាត់មើលឃើញមនុស្សដ៏ច្រើនដោយមែនទែនសុទ្ធតែអាចហោះឡើងបាន, គាត់ក៏ទៅបួស, គឺមិនស្ថិតនៅបញ្ហាចរិតភ្ញាក់ដឹងទៀត។ ដូច្នេះលោកអ្នកបួសបដិបត្តិ, ក៏មិនអាចតាមអំពើចិត្តឲ្យគេមើលឃើញ, មិនអាចបង្ហាញឲ្យគេ, អ្នកដទៃនៅតែត្រូវបួស។ ដូច្នេះក្រោយពីវង់សកលធំស្រឡះ, ដរាបណាចាក់សោលើចុងម្រាមដៃ, ចុងម្រាមជើងឬក៏ផ្នែកណាមួយរបស់លោកអ្នក, លោកអ្នកគឺអណ្តែតឡើងមិនបាន។

ពួកយើងជាញឹកញាប់ពេលដែលវង់សកលធំជិតស្រឡះ, នឹងលេចឡើងស្ថានភាពមួយ, មានមនុស្សពេលអង្គុយសមាធិរមែងផ្អៀងទៅខាងមុខ។ ដោយសារក្រោយខ្នងស្រឡះល្អបង្គួរ, ក្រោយខ្នងស្រាលពិសេស, ខាងមុខមានអារម្មណ៍ធ្ងន់; មានមនុស្សផ្ងារមកក្រោយ, ជាក់ស្តែងគឺក្រោយខ្នងមានអារម្មណ៍ធ្ងន់, ខាងមុខស្រាល។ ប្រសិនលោកអ្នកទាំងស្រុងសុទ្ធតែស្រឡះបានដ៏ល្អ, ដូច្នោះលោកអ្នកនឹងបុកឆ្ពោះឡើង, មានអារម្មណ៍ថាខ្លួនឯងលើកឆ្ពោះឡើង, មានអារម្មណ៍ឃ្លាតពីដី។ ពេលដែលពិតប្រាកដអាចហើរឡើងបានកាលណា, គឺមិនទុកឲ្យលោកអ្នកហើរឡើង, ទោះយ៉ាងណាក៏មិនមែនជាដាច់ខាត។ លេចឡើងសីលគង់នៅពីរក្បាល, កូនក្មេងគ្មានចិត្តប្រកាន់, មនុស្សចាស់ជាពិសេសគឺស្ត្រីចំណាស់គ្មានចិត្តប្រកាន់, ងាយស្រួលលេចឡើងសីលគង់, ងាយស្រួល

រក្សា។ បុរសជាពិសេសគឺយុវជន, កាលណាមានសីលគង់រួចហើយ, ចិត្តសាស្ត្រចង់បង្ហាញរបស់គាត់គឺចៀសមិនបាន, ក្នុងពេលដំណាលគ្នាគាត់អាចយកវាធ្វើជាឧបករណ៍មួយដើម្បីប្រកួតប្រជែងក្នុងមនុស្សសាមញ្ញ។ នេះគឺមិនអនុញ្ញាតឱ្យវាស្ថិតនៅ, ហាត់ចេញបានក៏ត្រូវយកវាចាក់សោជិតវិញ។ ចាក់សោជិតកន្លែងណាមួយ, ដូច្នោះឯកជននេះគឺអណ្ដែតឡើងមិនបាន។ ក៏មិនមែននិយាយដាច់ខាតសុទ្ធតែមិនអនុញ្ញាតឲ្យលោកអ្នកលេចឡើងស្ថានភាពនេះ, អាចអនុញ្ញាតឲ្យលោកអ្នកសាកបន្តិច, មានមនុស្សមួយចំនួនអាចរក្សាបន្តបាន។

បើកថ្នាក់គ្រប់កន្លែងសុទ្ធតែមានកាលៈទេសៈនេះ។ ពេលខ្ញុំបើកថ្នាក់នៅសានទុង, សិក្ខាកាមនៅជីណាន, សិក្ខាកាមនៅប៉េកាំងក៏មាន, មានមនុស្សនិយាយ៖ លោកគ្រូ, កូនដូចម៉េចអញ្ចឹង, ដើរតាមផ្លូវរមែងចង់ឃ្លាតពីដី, សំរាកនៅក្នុងផ្ទះគេងអណ្ដែតឡើងលើ, សូម្បីតែភួយដណ្ដប់ពីលើក៏អណ្ដែតឡើង, រមែងដូចជាប៉េតប៉ោងអណ្ដែតឡើងលើ។ ពេលខ្ញុំបើកថ្នាក់នៅក្វួយយ៉ាង, សិក្ខាកាមយូរឆ្នាំម្នាក់របស់ក្វួយចូវ, គឺស្ត្រីចំណាស់ម្នាក់, ក្នុងផ្ទះរបស់គាត់បានដាក់គ្រែពីរគ្រឿង, បង្អែកជញ្ជាំងម្ខាងមួយ។ គាត់អង្គុយសមាធិនៅលើគ្រែ, គាត់គឺមានអារម្មណ៍ថាខ្លួនឯងអណ្ដែតឡើង, គាត់បើកភ្នែកកាលណាឃើញថាបានអណ្ដែតដល់គ្រែខាងនោះ; គាត់គិតភ្លាម, យើងត្រូវតែត្រឡប់ទៅវិញ, ហើយក៏អណ្ដែតត្រឡប់មកវិញ។

មានសិក្ខាកាមម្នាក់នៅឈិញតាវ, ពេលសម្រាកថ្ងៃត្រង់ក្នុងបន្ទប់គ្មានមនុស្ស, គាត់អង្គុយសមាធិនៅលើគ្រែ, គាត់ទើបអង្គុយសមាធិគឺហើរឡើង, បុកឡើងលើដ៏ខ្លាំងសម្បើម, ខ្ពស់ជាងមួយម៉ែត្រ។ ហើរឡើងហើយក៏ធ្លាក់ចុះមកវិញ, ទុងៗបុកឡើងបុកចុះ, ធ្វើឱ្យភួយក៏បុកធ្លាក់ចុះ

ទៅដី។ មានបន្ទិចរំជួលចិត្ត, ក៏មានបន្ទិចភ័យខ្លាច, បុកមកបុកទៅបុកពេញមួយថ្ងៃត្រង់។ ចុងក្រោយវាយកណ្តឹងដល់ម៉ោងធ្វើការ, ចិត្តគិតថា៖ គឺមិនអាចទុកឲ្យមនុស្សមើលឃើញ, តើនេះសម្រាប់អ្វី, ប្រញាប់បញ្ឈប់មកវិញ។ បញ្ឈប់មកវិញ។ នេះជាក់ស្តែងគឺហេតុអ្វីមនុស្សចាស់អាចឃាត់ជាប់បាន។ ប្រសិនជាយុវជន, វាយកណ្តឹងដល់ម៉ោងធ្វើការ, ទាំងអស់មកមើលៗនែ់, ខ្ញុំហើរឡើងបានហើយ។ មនុស្សមិនសូវងាយស្រួលឃាត់ចិត្តបង្ហាញរបស់ខ្លួនឯងបានគឺនៅកន្លែងនេះ៖ មើលគង់នេះរបស់ខ្ញុំហាត់បានល្អប៉ុណ្ណា, ខ្ញុំអាចហើរឡើងបានហើយ។ កាលណាគាត់បង្ហាញគឺបាត់, មិនអនុញ្ញាតឲ្យស្ថិតនៅបែបនេះ។ រឿងរ៉ាវប្រភេទនេះច្រើនណាស់, សិក្ខាកាមគ្រប់ទីកន្លែងសុទ្ធតែមាន។

ពួកយើងទើបចាប់ផ្តើមគឺត្រូវការរយខ្សែវណ្ណបើកទាំងស្រុង, គិតត្រឹមថ្ងៃនេះ, មនុស្ស៨០, ៩០ភាគរយរបស់ពួកយើងបច្ចុប្បន្នសុទ្ធតែសម្រេចបានស្ថានភាពរាងកាយស្រាល, គ្មានជំងឺ។ ក្នុងពេលតែមួយយើងខ្ញុំសម្តែង, នៅលើថ្នាក់នេះមិនត្រឹមតែត្រូវការរុញឲ្យលោកអ្នកឡើងដល់ស្ថានភាពបែបនេះ, ទុកឲ្យរាងកាយលោកអ្នកបន្សុទ្ធទាំងស្រុង, នៅតែត្រូវការដំឡើងក្នុងរាងកាយលោកអ្នករបស់ជាច្រើន, ទុកឲ្យលោកអ្នកនៅលើថ្នាក់គឺបញ្ចេញគង់, ខ្ញុំស្មើនឹងទាញលោកអ្នកឡើងហើយបញ្ជូនទៅមុខ។ ខ្ញុំបន្តនៅលើថ្នាក់សម្តែងធម៌ឲ្យអ្នករាល់គ្នា, ចិត្តចរិតអ្នករាល់គ្នាក៏កំពុងបន្តកើតឡើងការផ្លាស់ប្រែ។ មនុស្សដ៏ច្រើនពួកយើងក្រោយពីដើរចេញពីសាវនដ្ឋាននេះ, លោកអ្នកនឹងមានអារម្មណ៍ថាដូចជាមនុស្សមួយផ្សេង, ធានាថាទស្សនវិស័យលោកអ្នកសុទ្ធតែកើតឡើងប្រែផ្លាស់, លោកអ្នកដឹងបានអនាគតលោកអ្នកទៅធ្វើមនុស្សបែបណា, មិនអាចស្រមើស្រមៃបែបនោះ, ធានាថាគឺជាបែបនេះ, ដូច្នេះចិត្តចរិតរបស់ពួក

យើងបានឡើងតាមទាន់។

និយាយដល់វង់សកលធំ, ទោះបីមិនអនុញ្ញាតឲ្យលោកអ្នកអណ្ដែតឡើងក៏ដោយ, ប៉ុន្តែលោកអ្នកនឹងមានអារម្មណ៍រាងកាយមួយស្រាល, ដូចជាដើរលើខ្យល់។ អតីតកាលដើរប៉ុន្មានជំហានគឺហត់, ឥឡូវដើរឆ្ងាយប៉ុណ្ណាក៏មានអារម្មណ៍ដ៏ធូរស្រាល, ជិះកង់ហាក់ដូចជាមានមនុស្សរុញលោកអ្នក, ឡើងអគារឡើងខ្ពស់ប៉ុណ្ណាក៏មិនហត់, ធានាគឺជាបែបនេះ។ មើលសៀវភៅនេះបួសខ្លួនឯងដូចគ្នាក៏អាចសម្រេចបានស្ថានភាពដែលគួរមាន។ ឯកជនខ្ញុំនេះពាក្យដែលខ្ញុំមិនចង់និយាយ, ខ្ញុំអាចមិននិយាយ, ប៉ុន្តែពាក្យដែលខ្ញុំនិយាយចេញត្រូវតែជាពាក្យពិត។ ជាពិសេសនៅក្នុងកាលៈទេសៈនេះ, ពេលខ្ញុំកំពុងសម្ដែងធម៌ប្រសិនខ្ញុំមិនសម្ដែងពាក្យពិត, នៅទីនេះនិយាយពាក្យដែលពិបាកនឹងជឿ, មិនអាចកំណត់គោលដៅសម្ដែងរញ៉េរញ៉ៃតាមអំពើចិត្ត, ខ្ញុំជាក់ស្ដែងគឺកំពុងបង្រៀនទុច្ចរិតធម៌។ ខ្ញុំធ្វើរឿងរ៉ាវនេះក៏មិនងាយស្រួលអ្វី, ក្នុងចក្រវាលសុទ្ធតែកំពុងតាមមើល, លោកអ្នកដើរគម្លាតគឺមិនបាន។

មនុស្សធម្មតាគ្រាន់តែដឹងបានមានវង់សកលមួយបែបយ៉ាងនេះគឺចប់រឿងហើយ, ភាពពិតនេះនៅតែមិនទាន់គ្រប់។ ចង់សម្រេចបានរាងកាយត្រូវបានសារធាតុថាមពលខ្ពស់ជំនួសទាំងស្រុង, បំប្លែងលឿនបំផុត, នៅតែត្រូវមានការបង្វិលមានទិសមួយតាមទម្រង់វង់សកល, ទាញកម្រើកខ្សែវណ្ណទាំងអស់នៃរាងកាយលោកអ្នកបង្វិលមានទិស, នោះហៅថាវង់សកលម៉ាវយ៉ូវ, អាចមានមនុស្សតិចតួចណាស់ដឹងបាន។ ក្នុងសៀវភៅពេលខ្លះលើកឡើងនាមសព្ទបែបនេះ, ប៉ុន្តែគ្មានមនុស្សសម្ដែងអំពីវា, មិនប្រាប់លោកអ្នក។ សុទ្ធតែជាកំពុងវិលជុំវិញទ្រឹស្ដី, អាថ៌កំបាំងក្នុងអាថ៌កំបាំងទេតើ។ យើងខ្ញុំទីនេះសុទ្ធតែនិយាយចេញឲ្យលោកអ្នក៖

អាចចាប់ផ្តើមពីស្មៀរុីប៉ាយហួយ (ក៏អាចចេញមកពីស្មៀរុីហួយឃីន), វាយចេញមកដើរនៅមុខប្រសព្វទាំងពីរនៃអវិជ្ជមាន-វិជ្ជមាន, ពីគែមត្រចៀកចុះក្រោម, បន្ទាប់មកដើរតាមស្មាចុះក្រោម។ ដើរតាមចុងម្រាមដៃនីមួយៗ។ បន្ទាប់មកដើរតាមម្ខាងនៃរាងកាយ, ពីក្រោមបាតជើងឆ្លងទៅពីក្រោមក្រលៀនម្ខាងឡើងមក។ បន្ទាប់មកពីម្ខាងផ្សេងទៀតចុះទៅ, ម្តងទៀតដើរចុះបាតជើង, ពីម្ខាងនៃរាងកាយឡើងមក។ ឆ្លងតាមចុងម្រាមដៃនីមួយៗ, វិលមួយជុំដល់កំពូលក្បាល, នេះជាក់ស្តែងគឺជាវង់សកលម៉ាវយ៉ូវ។ គេអាចសរសេរទាំងសៀវភៅមួយក្បាល, ខ្ញុំនិយាយចេញមកតែប៉ុន្មានប្រយោគ។ ខ្ញុំមានអារម្មណ៍នេះក៏មិនចាត់ថាអាថ៌កំបាំងធម្មជាតិអ្វី, ប៉ុន្តែអ្នកដទៃមានអារម្មណ៍ថាប្រការទាំងនេះសុទ្ធតែជាដ៏មានតម្លៃ, ជាមូលដ្ឋានគឺមិនសម្តែង, ពិតប្រាកដបង្រៀនកូនសិស្សទើបសម្តែងវង់សកលម៉ាវយ៉ូវ។ ខ្ញុំទោះបីសម្តែងចេញមកក្តី, ប៉ុន្តែនរណាក៏មិនបានប្រើគំនិតដឹកនាំ, គ្រប់សង្កត់ដើម្បីហាត់, លោកអ្នកហាត់គឺមិនមែនជាហ្វាលូនតាហ្វារបស់យើងខ្ញុំទៀត។ ពិតប្រាកដបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់គឺជាសភាពគ្មានបំណង, គ្មានសកម្មភាពគំនិតណាមួយ, ទាំងស្រុងបានដំឡើងអស់ឲ្យលោកអ្នកអ្វីដែលបានបង្កើតរួចរាល់។ ទាំងនេះសុទ្ធតែជាបង្កើតដោយស្វ័យប្រវត្តិ, យន្តការខាងក្នុងទាំងនេះកំពុងវិវត្តនិងហាត់លោកអ្នក, ដល់ពេលវានឹងបង្វិលដោយខ្លួនឯង។ មានថ្ងៃមួយពេលដែលលោកអ្នកហាត់គង់នឹងយោលក្បាល, ក្បាលបើយោលទិសខាងនេះ, វាជាក់ស្តែងគឺបង្វិលយ៉ាងនេះ; ក្បាលបើយោលទិសខាងនោះ, ជាក់ស្តែងគឺបង្វិលយ៉ាងនោះ, ត្រូវការបង្វិលទាំងសងខាង។

វង់សកលធំ, តូចស្រឡះរួចហើយ, អង្គុយសមាធិនឹងងក់ក្បាល, នេះជាបាតុភូតដែលថាមពលឆ្លងកាត់។ លំហាត់វង់សកលហ្វាលូន

ដែលពួកយើងហាត់ក៏ជាដូចគ្នា, ពួកយើងគឺហាត់បែបនេះ, ភាពពិត ពេលដែលលោកអ្នកមិនហាត់វាក៏បង្វិលដោយខ្លួនឯង។ ពេលធម្មតា បង្វិលបន្តជានិច្ច, ពេលដែលលោកអ្នកហាត់គឺដើម្បីពង្រឹងយន្តការនេះ។ ពួកយើងមិនមែនសម្ដែងធម៌ហាត់មនុស្សឬ? ពេលធម្មតាលោកអ្នករក ឃើញថាវង់សកលនោះរបស់លោកអ្នករមែងកំពុងធ្វើដំណើរជុំ, លោក អ្នកមិនហាត់, យន្តការឈើជាន់នេះដែលដំឡើងខាងក្រៅ, ពោលគឺខ្សែ វណ្ណៈធំមួយជាន់ខាងក្រៅកំពុងទាញរាងកាយលោកអ្នកហាត់តាម, សុទ្ធ តែជាស្វ័យប្រវត្តិ។ វាក៏នឹងវិលបញ្ច្រាស, បណ្ដោយបញ្ច្រាសទាំងពីរមុខ សុទ្ធតែបង្វិល, គ្រប់ពេលគ្រប់វេលាសុទ្ធតែកំពុង{បើក}ស្រឡះខ្សែវណ្ណៈ របស់លោកអ្នក។

ដូច្នោះគោលបំណងបើកស្រឡះខ្សែវណ្ណៈជាអ្វីហ្ន៎? បើកស្រឡះខ្សែ វណ្ណៈខ្លួនវាមិនមែនគោលបំណងហាត់គង់។ លោកអ្នកជាក់ស្ដែងគឺខ្សែ វណ្ណៈស្រឡះរួចហើយ, ខ្ញុំនិយាយថាក៏មិនមែនជាអ្វី។ បន្តបួសទៅមុខ ទៀត, គោលបំណងគឺតាមរយៈទម្រង់វង់សកលខ្សែវណ្ណៈមួយទាញរយ ខ្សែវណ្ណៈនេះ, ធ្វើឲ្យខ្សែវណ្ណៈនៃរាងកាយ, ខ្សែវណ្ណៈទាំងអស់ទាញបើកទាំង ស្រុង។ ពួកយើងបានកំពុងធ្វើរឿងរ៉ាវនេះរួចហើយ។ ហាត់បន្តទៀត, មាន មនុស្សពេលដែលវង់សកលធំដើរនឹងរកឃើញថា, ខ្សែវណ្ណៈនឹងហាត់បាន ដ៏ទូលាយ, ដូចជាចុងម្រាមដៃ, ខាងក្នុងដ៏ទូលាយ។ ដោយសារ ថាមពលក៏ដ៏ខ្លាំងក្លា, ចរន្តថាមពលបង្កើតរួចហើយវានឹងដ៏ទូលាយ, ក៏ នឹងភ្លឺណាស់ផងដែរ។ នេះក៏មិនចាត់ថាជាអ្វី, ត្រូវការហាត់ដល់កម្រិត ណា? ត្រូវធ្វើឲ្យរយខ្សែវណ្ណៈនៃរាងកាយសុទ្ធតែកំពុងបន្តិចម្ដងៗទូលាយ ថែម, ថាមពលមួយថ្ងៃកាន់តែខ្លាំងក្លា, ប្រែជាមួយថ្ងៃកាន់តែភ្លឺ។ ចុង ក្រោយធ្វើឲ្យជាងម៉ឺនទងខ្សែវណ្ណៈភ្ជាប់ជាបំណែកមួយ, សម្រេចបាន

កម្រិតមួយគ្មានខ្សែវណ្ណៈគ្មានស្មៀ, រាងកាយទាំងមូលភ្ជាប់ជាបំណែកមួយ, នេះគឺសម្រេចបានគោលបំណងចុងក្រោយបើកស្រឡះខ្សែវណ្ណ។ គោលបំណងរបស់វាគឺធ្វើឲ្យរាងកាយទាំងមូលសុទ្ធតែត្រូវបានសារធាតុថាមពលខ្ពស់បំប្លែង។

ពេលដែលហាត់ដល់ជំហានមួយនេះ, រាងកាយមនុស្សជាមូលដ្ឋានគឺត្រូវបានសារធាតុថាមពលខ្ពស់បំប្លែង, ក៏មានន័យថាបានហាត់ដល់ជាន់ថ្នាក់ខ្ពស់បំផុតរបស់បួសហាត់លោកីយ៍ធម៌, រាងកាយសាច់របស់រាងកាយមនុស្សបានបួសហាត់ដល់ចំណុចកំពូលបំផុតរួចហើយ។ ពេលដែលបានដល់ជំហានមួយនេះ, ក៏នឹងនាំមកឲ្យលោកអ្នកស្ថានភាពមួយ, ស្ថានភាពអ្វី? គង់របស់គាត់បានបញ្ចេញសម្បូរខ្លាំងណាស់រួចហើយ។ បួសហាត់រាងកាយមនុស្សសាមញ្ញ, ពោលគឺនៅក្នុងដំណើរការបួសហាត់លោកីយ៍ធម៌, សីលគង់ពិសេសទាំងអស់ (សក្តានុពល) របស់មនុស្ស, របស់ទាំងអស់សុទ្ធតែបញ្ចេញមក, ប៉ុន្តែបួសនៅក្នុងមនុស្សសាមញ្ញភាគច្រើនគឺត្រូវចាក់សោ។ ថែមទៀតសសរគង់របស់គាត់បានកើនឡើងដ៏ខ្ពស់រួចហើយ, ទម្រង់របស់គង់ទាំងអស់, សុទ្ធតែត្រូវបានគង់ខ្លាំងធំពង្រឹងដ៏ខ្លាំងក្លា។ ប៉ុន្តែវាគ្រាន់តែអាចផ្តើមផលប៉ះពាល់នៅក្នុងអវកាសកំពុងមាននេះរបស់ពួកយើង, តែមិនអាចរឹតត្បិតលើអវកាសផ្សេងបាន, ដោយសារវាគ្រាន់តែជាសីលគង់បួសហាត់ចេញមកពីរាងកាយសាច់មនុស្សសាមញ្ញពួកយើង។ ទោះយ៉ាងណាបានដ៏សម្បូររួចហើយ, នៅក្នុងគ្រប់អវកាស, លើគ្រប់ទម្រង់អត្ថិភាពរបស់រាងកាយក្នុងអវកាសខុសគ្នា, សុទ្ធតែបានកើតឡើងការផ្លាស់ប្រែដ៏ធំ។ របស់ដែលនាំតាមរាងកាយនោះ, របស់នៃជាន់អវកាសនីមួយៗដែលនាំតាមរាងកាយសុទ្ធតែជាដ៏សម្បូររួចហើយ, មើលទៅគួរឲ្យខ្លាចណាស់។ មនុស្សខ្លះរាង

កាយគ្រប់ទីកន្លែងគឺជាភ្នែក, រន្ធញើសពាសពេញរាងកាយសុទ្ធតែជាភ្នែក, ក្នុងវិសាលភាពអវកាសទាំងមូលរបស់គាត់សុទ្ធតែនឹងមានភ្នែក។ ដោយសារជាគង់ពុទ្ធវង្ស, រាងកាយខ្លះពាសពេញរាងកាយសុទ្ធតែជារូបភាពពោធិសត្វ, ព្រះពុទ្ធ។ សណ្ឋានគ្រប់ប្រភេទរបស់គង់សម្រេចបានកម្រិតយ៉ាងសម្បូរបំផុតរួចហើយ, លើសពីនេះថែមទាំងមានកាយជីវិតជាច្រើនៗលាតត្រដាងចេញមក។

ពេលដែលដល់ជំហានមួយនេះ, គាត់ក៏នឹងលេចឡើងស្ថានភាពមួយ, ហៅថា [ផ្កាបីផ្ដុំកំពូល]។ នោះជាស្ថានភាពមួយច្បាស់លាស់ខ្លាំងណាស់, ក៏លេចច្រងោខ្លាំងណាស់, មនុស្សជាន់ថ្នាក់ភ្នែកទិព្វមិនខ្ពស់ក៏អាចមើលឃើញបាន។ លើក្បាលមានផ្កា៣ទង, មួយទងជាផ្កាឈូក, តែមិនមែនផ្កាឈូកក្នុងអវកាសសារធាតុរបស់ពួកយើង, នៅមានពីរទងក៏ជាផ្កានៃអវកាសផ្សេង, ស្អាតអស្ចារ្យខ្លាំងណាស់។ ផ្កា៣ទងឆ្លាស់គ្នាបង្វិលលើកំពូលក្បាល, បង្វិលបណ្ដោយ, បង្វិលបញ្ច្រាស, ផ្កា៣ទងក៏នឹងបង្វិលដោយខ្លួនឯង។ ទងផ្កានីមួយៗមានសសរធំមួយ, ធំស្មើនឹងអង្កត់ផ្ចិតរបស់ផ្កា។ សសរធំបីបើកស្រឡះត្រង់ដល់កំពូលមេឃ, នោះក៏មិនមែនជាសសរគង់, វាគ្រាន់តែជាទម្រង់បែបនេះ, សែនអាថ៌កំបាំងអស្ចារ្យ, លោកអ្នកខ្លួនឯងមើលឃើញក៏នឹងរន្ធត់ភ្ញាក់ផ្អើល។ ពេលហាត់ដល់ជំហានមួយនេះ, រាងកាយសៗសុទ្ធៗ, ស្បែកក៏ទន់ម៉ដ្តខៃ។ ពេលដែលដល់ជំហានមួយនេះ, ពោលគឺក៏បានដល់ទម្រង់ខ្ពស់បំផុតនៃបួសហាត់លោកីយ៍ធម៌រួចហើយ។ ប៉ុន្តែនេះនៅតែមិនមែនដល់ចំណុចកំពូល, នៅតែត្រូវការបួសហាត់បន្តទៅមុខ, នៅតែត្រូវដើរឆ្ពោះទៅមុខ។

ដើរឆ្ពោះទៅមុខទៀត, គឺបានចូលក្នុងជាន់ថ្នាក់ផ្លាស់ប្តូររវាងលោកីយ៍ធម៌និងផុតពីលោកីយ៍ធម៌, ហៅថាស្ថានភាពរាងកាយសសុទ្ធ (ក៏

ហៅថារាងកាយសថ្លា)។ ដោយសាររាងកាយបួសហាត់ដល់ទម្រង់ខ្ពស់បំផុតរបស់លោកីយ៍ធម៌, ក៏ហួសពេកគ្រាន់តែជារាងកាយសាច់របស់មនុស្សបំប្លែងដល់ទម្រង់ខ្ពស់បំផុតប៉ុណ្ណោះ។ ពេលដែលពិតប្រាកដដើរចូលក្នុងទម្រង់នោះ, រាងកាយទាំងមូលទាំងស្រុងគឺដោយបានសារធាតុថាមពលខ្ពស់ផ្សំឡើង។ ហេតុអ្វីហៅថារាងកាយសសុទ្ធ? គឺគាត់បានឈានដល់បន្សុទ្ធកម្រិតខ្ពស់ដាច់ខាត។ ប្រើភ្នែកទិព្វដើម្បីមើល, រាងកាយទាំងមូលគឺថ្លាយង់, គឺថ្លាយង់ដូចជាកញ្ចក់កែវ។ មើលទៅអ្វីក៏គ្មាន, នឹងបង្ហាញចេញស្ថានភាពមួយយ៉ាងនេះ, និយាយត្រង់, គាត់បានជាពុទ្ធកាយរួចហើយ។ ពីព្រោះរាងកាយផ្សំឡើងដោយសារធាតុថាមពលខ្ពស់និងរាងកាយនៃរាងកាយដើមរបស់ពួកយើងបានខុសគ្នារួចហើយ។ ពេលដល់ជំហានមួយនេះ, សីលគង់ទាំងអស់និងរបស់សិល្ប៍សាស្ត្រដែលរាងកាយលេចឡើងភ្លាមៗនឹងត្រូវបោះចោលទាំងស្រុង។ ដោះវាឲ្យចូលទៅក្នុងអវកាសមួយដ៏ជ្រៅ, គ្មានប្រយោជន៍ទៀត, ពីថ្ងៃនេះតទៅក៏គ្មានប្រយោជន៍ទៀត។ ហួសពេកគ្រាន់តែជាអនាគតថ្ងៃណាមួយនោះលោកអ្នកបួសសម្រេចសម្រេចតាវ, លោកអ្នកវិលក្បាលមកមើលសាកមើលដំណើរការរបស់លោកអ្នក, យកវាចេញសម្លឹងបន្តិច។ ពេលនេះមានតែរបស់ពីរយ៉ាងស្ថិតនៅ៖ សសរគង់នៅតែមាន, ទារកអមតៈដែលបួសហាត់បានបង្កើនធំណាស់រួចហើយ។ ប៉ុន្តែរបស់ពីរយ៉ាងនេះសុទ្ធតែនៅអវកាសមួយដ៏ជ្រៅ, មនុស្សធម្មតាជាន់ថ្នាក់ភ្នែកទិព្វមិនខ្ពស់មើលមិនឃើញ, គាត់គ្រាន់តែអាចមើលឃើញរាងកាយឯកជននេះគឺជារាងកាយថ្លាយង់។

ដោយសារស្ថានភាពរាងកាយសសុទ្ធជាជាន់ថ្នាក់ផ្លាស់ប្តូរ, ពេលដែលបួសហាត់បន្តទៀត, ដូច្នោះគឺពិតប្រាកដដើរចូលក្នុងបួសហាត់ផុត

ពីលោកីយ៍ធម៌, ក៏ហៅថាបួសហាត់ពុទ្ធកាយ។ រាងកាយទាំងមូលគឺដោយបានគង់ផ្សំឡើង, ពេលនេះចិត្តចរិតរបស់មនុស្សបាននឹងថេររួចហើយ។ ចាប់ផ្តើមហាត់សាជាថ្មីម្តងទៀត, ចាប់ផ្តើមបញ្ចេញសីលគង់សាជាថ្មី, នោះមិនហៅថាសីលគង់ទៀត, ហៅថា [ទេពអំណាចពុទ្ធធម៌], គាត់រឹតត្បិតលើគ្រប់អវកាសទាំងអស់, អំណាចគ្មានទីបញ្ចប់។ អនាគតស្របតាមលោកអ្នកខ្លួនឯងបន្តបួសហាត់, របស់នៃជាន់ថ្នាក់ខ្ពស់ជាង, ខ្លួនឯងនឹងដឹងធ្វើដូចម្តេចដើម្បីបួសហាត់និងទម្រង់អត្តិភាពរបស់បួសហាត់។

## ចិត្តត្រេកអរ

និយាយអំពីបញ្ហាមួយយ៉ាងនេះ, នេះក៏ស្ថិតក្នុងចិត្តត្រេកអរ។ មនុស្សដ៏ច្រើនឆ្លងកាត់ហាត់គង់ពេលវេលាយូរ, ក៏មានមនុស្សមិនធ្លាប់បានហាត់គង់, ទោះយ៉ាងណានៅក្នុងមួយជីវិតរបស់គាត់មានការស្វែងរកចំពោះសច្ចធម៌, អត្ថន័យពិតនៃជីវិត, កំពុងគិតពិចារណា។ កាលណាគាត់បានរៀនសូត្រហ្វាលូនតាហ្វារបស់ពួកយើងរួចហើយ, គាត់ភ្លាមៗគឺយល់ច្បាស់នូវបញ្ហាដ៏ច្រើនដែលនៅក្នុងមួយជីវិតមនុស្សរបស់គាត់ចង់យល់ច្បាស់, តែក៏មិនអាចបកស្រាយបាន។ អាចអមស្របជាមួយមនោគតិរបស់គាត់ថ្កើងឡើង, អារម្មណ៍របស់គាត់នឹងសែនជ្រួលរំភើប, ចំណុចមួយនេះគឺបញ្ជាក់។ ខ្ញុំដឹង, មនុស្សបួសហាត់ពិតប្រាកដគឺដឹងបានភាពធ្ងន់របស់វា, គាត់នឹងដឹងឲ្យតម្លៃ។ ទោះយ៉ាងណាជាញឹកញាប់ក៏លេចឡើងបញ្ហាបែបនេះ, ដោយសារភាពរីករាយរបស់មនុស្ស, កើតចេញមកចិត្តត្រេកអរមិនចាំបាច់, គឺនាំឱ្យគាត់នៅលើទម្រង់, នៅក្នុងប្រាស្រ័យទាក់ទងរវាងមនុស្សនិងមនុស្សនៃសង្គមមនុស្សសាមញ្ញ, នៅបរិយាកាសនៃសង្គមមនុស្សសាមញ្ញបង្ហាញមិនប្រក្រតី, ខ្ញុំនិយាយថា

បែបនេះគឺមិនបាន។

ភាគច្រើនសំណុំគង់ហ្វានេះរបស់ពួកយើងគឺបួសហាត់នៅក្នុងសង្គមមនុស្សសាមញ្ញ, លោកអ្នកមិនអាចធ្វើឱ្យខ្លួនឯងចាកឃ្លាតពីសង្គមមនុស្សសាមញ្ញ, លោកអ្នកត្រូវតែច្បាស់ឥតខ្ចោះដើម្បីបួសហាត់។ រវាងមនុស្សនិងមនុស្សនៅតែជាទំនាក់ទំនងធម្មតា, ប្រាកដណាស់ចិត្តចរិតដ៏ខ្ពស់, ស្ថានភាពផ្លូវចិត្តដ៏សុចរិត, លើកកម្ពស់ចិត្តចរិតរបស់ខ្លួនឯង, លើកកម្ពស់ជាន់ថ្នាក់របស់ខ្លួនឯង, មិនធ្វើរឿងអាក្រក់ធ្វើរឿងល្អ, គ្រាន់តែជាការបង្ហាញមួយបែបនេះ។ មនុស្សខ្លះបង្ហាញចេញមកហាក់ដូចជាស្មារតីសុទ្ធតែមិនធម្មតា, ហាក់ដូចជាមើលធុញទ្រាន់លោកីយ៍, ពាក្យនិយាយក៏មិនត្រូវបានគេពន្យល់។ គេនិយាយថា, រៀនហ្វាលូនតាហ្វារួចហើយឯកជននេះហេតុម្តេចប្រែជាបែបនេះហ្ន៎? ហាក់ដូចជាក្នុងស្មារតីកើតជំងឺវិកលចរិត។ ភាពពិតក៏មិនមែន, តែគឺគាត់រំភើបពេក, មិនវិចារណញ្ញាណ, មិនស្របគោលសីលធម៌សាមញ្ញ។ អ្នករាល់គ្នាគិតសាកមើល, លោកអ្នកធ្វើបែបនេះក៏មិនត្រូវ, លោកអ្នកម្តងទៀតបានដើរចូលក្នុងអច្ឆន្តភាពមួយផ្សេង, ក៏ជាចិត្តប្រកាន់។ លោកអ្នកគួរតែបោះវាចោល, រស់ដូចគ្នាជាមួយគេ, បួសហាត់តាមធម្មតានៅក្នុងមនុស្សសាមញ្ញ។ នៅក្នុងមនុស្សសាមញ្ញ, គេសុទ្ធតែមើលលោកអ្នកស្មារតីវិញ្ញាណឆ្កួតវង្វេង, គេសុទ្ធតែមិនទទួលស្គាល់លោកអ្នកដូចជាធម្មតា, ក៏ឃ្លាតឆ្ងាយពីលោកអ្នក, គ្មាននរណាផ្តត់ផ្តង់ឱកាសឲ្យលោកអ្នកលើកកម្ពស់ចិត្តចរិត, នរណាក៏មិនចាត់ទុកលោកអ្នកជាមនុស្សធម្មតា, ខ្ញុំនិយាយនោះមិនបាន! ដូច្នេះអ្នករាល់គ្នាដាច់ខាតយកចិត្តទុកដាក់បញ្ហានេះ, ជាក់លាក់ត្រូវតែសម្រួលឲ្យល្អខ្លួនឯង។

គង់ហ្វារបស់ពួកយើងមិនដូចគង់ហ្វាធម្មតា, ប្រញាប់ប្រញាល់,

ស្រមើស្រមៃ, ស្មារតីវិញ្ញាណធ្លូតវង្វេង។ គង់ហ្វាពួកយើងសុទ្ធតែត្រូវការ លោកអ្នកច្បាស់ឥតខ្ចោះបួសហាត់លោកអ្នកខ្លួនឯង។ មនុស្សខ្លះរមែង សម្តែង៖ លោកគ្រូ, កូនបិទភ្នែកកាលណាគឺឃោលៗ។ ខ្ញុំនិយាយថាមិន មែនជាដូច្នោះ, លោកអ្នកបានបំប៉នជាទម្លាប់បោះចោលសតិម្ចាស់របស់ ខ្លួនឯងរួចហើយ, លោកអ្នកបិទភ្នែកកាលណាគឺបន្ធូរសតិម្ចាស់របស់ខ្លួន ឯង, គ្មានទៀត, លោកអ្នកបានបំប៉នជាទម្លាប់នេះរួចហើយ។ អង្គុយនៅ ទីនេះលោកអ្នកហេតុម្តេចមិនឃោល? លោកអ្នកគឺរក្សាស្ថានភាពកំពុង បើកភ្នែក, បិទភ្នែកស្រាលៗយ៉ាងនេះលោកអ្នកឃោលបានឬ? ដាច់ខាត នឹងមិន។ លោកអ្នកសន្មតថាឈីគង់នេះគឺត្រូវតែហាត់បែបនេះ, លោក អ្នកបង្កើតជាប្រភេទគោលគំនិតមួយ, បិទភ្នែកកាលណាលោកអ្នកគឺ បាត់, ទៅទីណាហើយក៏មិនដឹង។ យើងខ្ញុំសម្តែងសតិម្ចាស់លោកអ្នក ជាក់លាក់ត្រូវការច្បាស់លាស់, ដោយសារសំណុំគង់ហ្វានេះគឺបួសហាត់ លោកអ្នកខ្លួនឯង, លោកអ្នកត្រូវតែច្បាស់ឥតខ្ចោះលើកកម្ពស់។ យើងខ្ញុំ ក៏មានគង់ស្ងប់, សំណុំគង់ស្ងប់នេះរបស់យើងខ្ញុំហាត់ដូចម្តេច? យើងខ្ញុំ តម្រូវអ្នករាល់គ្នា, លោកអ្នកសមាធិជ្រៅដល់ណាក៏ត្រូវតែដឹងខ្លួនឯង កំពុងហាត់គង់នៅទីនេះ, ដាច់ខាតមិនអនុញ្ញាតចូលក្នុងស្ថានភាពអ្វីក៏ មិនដឹង។ ដូច្នោះពិស្តារនឹងលេចឡើងស្ថានភាពអ្វី? នឹងលេចឡើងពេល ទៅទីនោះអង្គុយកាលណា, មានអារម្មណ៍ថាខ្លួនឯងហាក់ដូចជាអង្គុយ នៅក្នុងសំបកពងមាន់ស្អាតអស្ចារ្យ, អារម្មណ៍សុខស្រួលខ្លាំងណាស់, ដឹងថាខ្លួនឯងកំពុងហាត់គង់, ប៉ុន្តែមានអារម្មណ៍រាងកាយទាំងមូល កម្រើកមិនបាន។ នេះជាប្រការដែលគង់ហ្វានេះរបស់ពួកយើងចាំបាច់ លេចឡើង។ នៅមានស្ថានភាពមួយទៀត, អង្គុយមកអង្គុយទៅរកឃើញ ថាជើងក៏គ្មានទៀត, គិតមិនច្បាស់ជើងទៅទីណា, រាងកាយក៏គ្មានទៀត,

ដើមដៃក៏គ្មានទៀត, ដៃក៏គ្មានទៀត, នៅសល់តែខួរក្បាលប៉ុណ្ណោះ។ ហាត់បន្តទៀតខួរក្បាលក៏គ្មានទៀត, មានតែផ្នត់គំនិតរបស់ខ្លួនឯង, បន្តិចគំនិតដឹងថាខ្លួនឯងកំពុងហាត់គង់នៅទីនេះ។ ពួកយើងបើសម្រេចបានកម្រិតប្រភេទនេះគឺគ្រប់គ្រាន់ហើយ។ ហេតុអ្វី? មនុស្សហាត់គង់នៅក្នុងស្ថានភាពមួយបែបនេះរាងកាយសម្រេចបានស្ថានភាពវិវត្តន៍ពេញលេញបំផុត, គឺជាស្ថានភាពស្អាតបំផុត, ដូច្នេះយើងខ្ញុំតម្រូវលោកអ្នកចូលក្នុងស្ងប់នៅស្ថានភាពមួយយ៉ាងនេះ។ តែលោកអ្នកមិនបានគេងលក់បាត់ទៅ, វង្វេងបាត់ទៅ, នោះប្រហែលជារបស់ល្អគឺទុកឲ្យអ្នកដទៃហាត់ទៅបាត់។

មនុស្សហាត់គង់ពួកយើងទាំងអស់ដាច់ខាតយកចិត្តទុកដាក់មិនបាននៅក្នុងមនុស្សសាមញ្ញបង្ហាញដ៏មិនប្រក្រតី។ នៅក្នុងមនុស្សសាមញ្ញលោកអ្នកផ្ដើមផលប៉ះពាល់មិនល្អ, គេនិយាយថា, រៀនហ្វាលូនតាហ្វារួចហើយហេតុម្ដេចសុទ្ធតែបែបនេះ, នេះគឺស្មើនឹងបំផ្លាញកេរ្តិ៍ឈ្មោះរបស់ហ្វាលូនតាហ្វា, ដាច់ខាតយកចិត្តទុកដាក់រឿងរ៉ាវនេះ។ នៅទិដ្ឋភាពផ្សេងនិងក្នុងដំណើរការបួសហាត់ក៏ត្រូវការយកចិត្តទុកដាក់មិនបង្កើតចិត្តត្រេកអរ, ប្រភេទចិត្តនេះដ៏ងាយស្រួលត្រូវខ្មោចកេងប្រវ័ញ្ច។

## បួសមាត់

បួសមាត់, សាសនាអតីតកាលក៏សម្ដែងយ៉ាងនេះ។ ប៉ុន្តែបួសមាត់នេះចំណុចសំខាន់ដែលវាសំដៅលើគឺអ្នកបួសហាត់ជំនាញមួយចំនួន--ព្រះសង្ឃ, តាវវត្តី, បិទមាត់មិននិយាយស្ដី។ ដោយសារជាអ្នកបួសហាត់ជំនាញ, គោលបំណងគឺដើម្បីកម្ចាត់ចិត្តប្រកាន់របស់មនុស្សនៅកម្រិតធំជាង, វាសន្មតថាមនុស្សកម្រើកគំនិតកាលណាគឺជាកម្ម។ ក្នុងសាសនាបែងចែកកម្មជាពីរប្រភេទកម្មកុសលនិងកម្មអកុសល, មិនខ្វល់កម្ម

កុសលក៏ដោយ, កម្មអកុសលក៏ដោយ, ប្រើទទេរបស់ពុទ្ធវង្ស, គ្មានរបស់តាវវង្សដើម្បីសម្ដែងគឺសុទ្ធតែមិនគួរធ្វើ, ដូច្នេះគាត់សម្ដែងខ្ញុំអ្វីសុទ្ធតែមិនធ្វើ។ ដោយសារមើលមិនឃើញទំនាក់ទំនងកម្មផលរបស់រឿងការណ៍, ពោលគឺរឿងនេះនៅទីបញ្ចប់ជារឿងល្អឬក៏ជារឿងអាក្រក់, ទំនាក់ទំនងកម្មផលកំពុងស្ថិតនៅទីនោះ។ អ្នកបួសហាត់ធម្មតាមិនទាន់មានជាន់ថ្នាក់ខ្ពស់យ៉ាងនោះ, មើលមិនឃើញប្រការទាំងនេះ, ដូច្នេះគឺខ្លាច{ថា}បង្ហាញខាងលើផ្ទៃគឺជារឿងល្អ, {តែ}ពេលធ្វើប្រហែលជាគឺរឿងអាក្រក់។ ដូច្នេះគាត់គឺតាមដែលអាចធ្វើទៅបានសម្ដែងសភាពគ្មានបំណង, គាត់មិនធ្វើអ្វីទាំងអស់, បែបនេះគឺចៀសវាងគាត់សាងកម្មម្ដងទៀត។ ដោយសារសាងកម្មគឺត្រូវតែរំលាយកម្ម, គឺត្រូវតែរងទុក្ខ។ ឧបមាថាអ្នកបួសហាត់ពួកយើង, បានកំណត់រួចរាល់គាត់ដល់ជំហានមួយណាបើកគង់, ពាក់កណ្ដាលផ្លូវលោកអ្នកដាក់ចូលក្នុងប្រការអ្វីមិនចាំបាច់, នេះសុទ្ធតែនឹងបង្កជាលំបាកឲ្យបួសហាត់ទាំងមូល, ដូច្នេះគាត់គឺសម្ដែងសភាពគ្មានបំណង។

បួសមាត់ដែលពុទ្ធវង្សសម្ដែង, ពោលគឺនិយាយថា, មនុស្សនិយាយស្ដីសុទ្ធតែជាដោយសារសតិមនោគតិរបស់មនុស្សគ្រប់គ្រង, ដូច្នោះសតិមនោគតិនេះជាក់ស្ដែងគឺជាសភាពមានបំណង។ ប្រសិនសតិមនោគតិរបស់មនុស្សខ្លួនវាកម្រើកគំនិតកាលណា, និយាយអ្វី, ធ្វើអ្វី, គ្រប់គ្រងអង្គញាណ, អវយវៈរបស់មនុស្ស, នៅក្នុងមនុស្សសាមញ្ញអាចជាប្រកាន់មួយ។ លោកអ្នកឧបមាថា, រវាងមនុស្សនិងមនុស្សមានទំនាស់, លោកអ្នកល្អ, គាត់មិនល្អ, លោកអ្នកបួសហាត់បានល្អ, គាត់បួសហាត់មិនបានល្អ, ទាំងនេះខ្លួនវាជាក់ស្ដែងគឺជាទំនាស់។ ពួកយើងគ្រាន់តែនិយាយធម្មតា, ខ្ញុំត្រូវការធ្វើអ្វី, បច្ចុប្បន្នរឿងរ៉ាវនេះគួរតែធ្វើដូច្នេះដូច្នោះ, អាច

ដោយអចេតនាគឺបានធ្វើបាបនរណារួចហើយ។ ដោយសារទំនាស់រវាងមនុស្សនិងមនុស្សសុទ្ធតែជាដ៏ស្មុគស្មាញ, អាចដោយអចេតនាគឺបានសាងកម្មរួចហើយ។ បែបនេះបន្តមក, គឺគាត់សម្តែងដាច់ខាតបិទមាត់មិននិយាយស្តី។ អតីតកាលក្នុងសាសនារមែងមើលបួសមាត់ដ៏សំខាន់, នេះគឺនៅក្នុងសាសនាសម្តែងបែបនេះ។

អ្នកបួសហាត់ហ្វាលូនតាហ្វាពួកយើងភាគច្រើនលើសលប់សុទ្ធតែជាបួសហាត់នៅក្នុងមនុស្សសាមញ្ញ (លើកលែងតែសិស្សបួសហាត់ជំនាញ), ដូច្នោះចៀសវាងមិនបានជីវិតរស់នៅធម្មតារបស់មនុស្សសាមញ្ញនៃសង្គមមនុស្សសាមញ្ញ, ប្រាស្រ័យទាក់ទងនឹងសង្គម។ នរណាៗក៏មានការងារមួយចំណែក, លើសពីនេះនៅតែត្រូវធ្វើការងារឲ្យល្អ; មនុស្សខ្លះជាក់ស្តែងគឺតាមរយៈការនិយាយស្តីដើម្បីធ្វើការងារ, ដូច្នោះនេះមិនមែនទំនាស់ហើយឬ? ក៏មិនទំនាស់។ មិនទំនាស់នៅត្រង់ណា? បួសមាត់ដែលពួកយើងសម្តែង, គឺខុសគ្នាទាំងស្រុងជាមួយពួកគាត់។ ដោយសារធម្មក្ខន្ធបួសហាត់ខុសគ្នា, ដូច្នេះតម្រូវក៏ខុសគ្នា។ ពួកយើងបើកមាត់និយាយស្តី, សុទ្ធតែយោងតាមចិត្តចរិតរបស់មនុស្សហាត់គង់ដើម្បីនិយាយ, មិននិយាយពាក្យញុះញង់ត្រូវខុស, មិននិយាយពាក្យមិនល្អ។ ធ្វើជាមនុស្សបួសហាត់ត្រូវការយោងតាមបរមាណើយរបស់ធម៌ដើម្បីវាស់វែងខ្លួនឯង, គួរឬក៏មិនគួរនិយាយពាក្យនេះ។ ដែលគួរនិយាយ, ប្រើធម៌ដើម្បីវាស់វែងសមស្របនឹងបរមាណើយចិត្តចរិតរបស់មនុស្សហាត់គង់គឺគ្មានបញ្ហា, លើសពីនេះទៀតពួកយើងនៅតែត្រូវសម្តែងធម៌, ផ្សព្វផ្សាយធម៌, ដូច្នេះមិននិយាយស្តីក៏មិនបាន។ ពួកយើងសម្តែងបួសមាត់, គឺជាកិត្តិនាមផលប្រយោជន៍ដាក់ចុះមិនបានក្នុងមនុស្សសាមញ្ញនិងអ្វីគ្មានទាក់ទងដល់ការងារជាក់ស្តែងនៅក្នុងសង្គមរបស់អ្នកបួសហាត់; ឬក៏

ជជែកអត់ប្រយោជន៍មួយចំនួនរវាងសិស្សក្នុងធម្មក្ខន្ធតែមួយ; ឬក៏ដោយសារចិត្តប្រកាន់ចង់បង្ហាញខ្លួនឯង; ឬក៏បេះបួយចម្លងពាក្យចចាមអារ៉ាមមួយចំនួន; ឬក៏រឿងរ៉ាវដទៃមួយចំនួនក្នុងសង្គមពិភាក្សាទៅដ៏រំជួលចិត្ត, ដ៏ចូលចិត្តនិយាយ, ខ្ញុំគិតថានេះសុទ្ធតែជាចិត្តប្រកាន់របស់មនុស្សសាមញ្ញ។ នៅទិដ្ឋភាពទាំងនេះខ្ញុំមានអារម្មណ៍ថាពួកយើងគួរតែយកមាត់បួសមកវិញ, នេះគឺជាបួសមាត់ដែលយើងខ្ញុំសម្ដែង។ ព្រះសង្ឃអតីតកាលមើលប្រការទាំងនេះដ៏ធ្ងន់, ដោយសារគាត់កម្រើកគំនិតកាលណាជាក់ស្ដែងគឺជាកំពុងសាងកម្ម។ ដូច្នេះគាត់សម្ដែង [កាយ, វាចា, ចិត្ត]។ បួសកាយដែលគាត់សម្ដែង, នោះជាក់ស្ដែងគឺមិនធ្វើរឿងអាក្រក់; បួសវាចា, នោះជាក់ស្ដែងគឺមិននិយាយស្ដី។ បួសចិត្ត, នោះជាក់ស្ដែងគឺសូម្បីតែគិតក៏មិនគិតទៀត។ អតីតកាលបួសហាត់ជំនាញនៅក្នុងវត្តអារាមចំពោះតម្រូវទាំងនេះតឹងរឹងណាស់។ ពួកយើងយោងតាមបរមាណីយចិត្តចរិតរបស់មនុស្សហាត់គង់ដើម្បីតម្រូវខ្លួនឯង, គួរនិយាយអ្វីមិនគួរនិយាយអ្វីសម្រួលឲ្យល្អគឺបានហើយ។

# មេសម្តែងទី៩

## ឈីគង់និងលំហាត់ប្រាណ

នៅក្នុងជាន់ថ្នាក់ធម្មតា, គេងាយស្រួលសន្មតថាឈីគង់មានទំនាក់ទំនងដោយផ្ទាល់ជាមួយធ្វើលំហាត់ប្រាណ។ ប្រាកដណាស់សម្តែងនៅលើជាន់ថ្នាក់ទាប, ពីទិដ្ឋភាពសម្រេចបានរាងកាយមួយមាំមួនសង្កេតមើល, ឈីគង់និងធ្វើលំហាត់ប្រាណគឺគោលបំណងតែមួយ។ ប៉ុន្តែវិធីធ្វើលំហាត់ពិស្តាររបស់វា, វិធានការដែលជ្រើសប្រើនិងធ្វើលំហាត់ប្រាណខុសគ្នាគឺធំណាស់។ ធ្វើលំហាត់ប្រាណចង់សម្រេចបានរាងកាយមាំមួនរបស់មនុស្ស, ត្រូវបង្កើនបរិមាណធ្វើចលនារបស់មនុស្ស, ពង្រឹងបង្ហាត់រាងកាយមនុស្ស; ហើយបួសហាត់ឈីគង់ពោលគឺផ្ទុយស្រឡះ, មិនតម្រូវលោកអ្នកកម្រើក, កម្រើកក៏ជាទន់ភ្លន់, យឺត, មូល, សូម្បីតែមិនកម្រើក, នៅស្ងៀម។ នេះនិងទម្រង់ធ្វើលំហាត់ប្រាណគឺខុសគ្នាដ៏ធំ។ ដូច្នោះប្រសិនឡើងលើជាន់ថ្នាក់ខ្ពស់និយាយ, ឈីគង់មិនគ្រាន់តែជាព្យាបាលជំងឺកាយសម្បទា, វាមានប្រការនៃជាន់ថ្នាក់ខ្ពស់ជាង, អត្ថន័យជ្រៅជាង។ ឈីគង់មិនគ្រាន់តែជាប្រការបន្តិចបន្តួចនោះក្នុងជាន់ថ្នាក់នេះរបស់មនុស្សសាមញ្ញ, វាគឺវិសាមញ្ញ, លើសពីនេះនៅលើជាន់ថ្នាក់ខុសគ្នាសុទ្ធតែមានលាតត្រដាងខុសគ្នារបស់វា, វាជាអ្វីលើសផុតសែនឆ្ងាយពីមនុស្សសាមញ្ញ។

ពីធាតុដើមរបស់ធ្វើលំហាត់ដើម្បីសង្កេតមើល, ភាពខុសគ្នារបស់ពួកវាក៏ធំណាស់ផងដែរ។ អត្តពលិកតម្រូវបង្កើនបរិមាណធ្វើចលនា, ជាពិសេសគឺអត្តពលិកបច្ចុប្បន្ន, ដើម្បីធ្វើឲ្យរាងកាយរបស់ខ្លួនឯងសម្របនឹងកម្រិតប្រកួតប្រជែងទំនើប, សម្រេចបានស្តង់ដាមួយបែបនោះ, ដូច្នេះ

គាត់ត្រូវការធ្វើឲ្យរាងកាយតែងតែស្ថិតក្នុងស្ថានភាពល្អបំផុត។ ដើម្បីសម្រេចបានគោលដៅនេះ, គឺត្រូវការបង្កើនបរិមាណធ្វើចលនា, ជំរុញធ្វើឲ្យរាងកាយមនុស្សអាចបានដំណើរជុំឈាមពេញលេញបំផុត, ហេតុនេះបង្កើនសមត្ថភាពមេតាបូលីសរបស់គាត់, ធ្វើឲ្យរាងកាយរក្សាស្ថានភាពសំដៅឡើងលើជានិច្ច។ ហេតុអ្វីត្រូវការបង្កើនសមត្ថភាពមេតាបូលីសហ្ន៎? ដោយសាររាងកាយអត្តពលិកត្រូវតែបង្ហាញចេញស្ថានភាពប្រកួតប្រជែងល្អបំផុតសំដៅឡើងលើជានិច្ច។ រាងកាយមនុស្សគឺបានផ្សំឡើងដោយកោសិកាច្រើនរាប់មិនអស់, កោសិកាទាំងនេះសុទ្ធតែមានដំណើរការមួយ៖ កោសិកាបែងចែកចេញថ្មីមានកម្លាំងជីវិតដ៏ខ្លាំង, បង្ហាញចេញអភិវឌ្ឍន៍ឆ្ពោះឡើងលើ។ ពេលដែលដល់កម្រិតផុតរួចហើយ, គឺវាមិនអាចអភិវឌ្ឍន៍បន្តទៀត, គ្រាន់តែអាចទម្លាក់ចុះក្រោម, ពេលទម្លាក់រហូតដល់ចំណុចប៉ូល, គឺម្តងទៀតមានកោសិកាថ្មីជំនួសវា។ ឧបមាថា, ប្រើមួយថ្ងៃ១២ម៉ោងនាឡិកាមកឧបមា, ពីម៉ោង៦ព្រឹកកោសិកាបែងចែកចេញមក, រហូតបង្ហាញចេញសំដៅឡើង, សំដៅឡើង, ដល់ម៉ោង៨, ៩, ដល់ម៉ោង១០សុទ្ធតែជារយៈពេលល្អខ្លាំងណាស់។ ដល់ម៉ោង១២, វាគឺឡើងទៅមិនបានទៀត, គឺគ្រាន់តែអាចជម្រាលសំដៅចុះ។ អំឡុងពេលនេះកោសិកានៅមានពាក់កណ្ដាលកម្លាំងជីវិត, កន្លះកម្លាំងជីវិតនេះគឺមិនសមស្របនឹងស្ថានភាពប្រកួតប្រជែងរបស់អត្តពលិក។

ដូច្នោះធ្វើដូចម្ដេច? គាត់ត្រូវការពង្រឹងបង្ហាត់, បង្កើនដំណើរជុំឈាមរបស់គាត់, ក្រោយមកសាងបង្កើតកោសិកាថ្មីជំនួសចោលកោសិកាចាស់, គាត់បានដើរផ្លូវនេះ។ ក៏មានន័យថា, ដំណើរការទាំងមូលរបស់កោសិកាមិនទាន់ដើរចប់ផង, ទើបតែដើរបានកន្លះដំណើរការជីវិតគឺយកវាបញ្ចេញចោល, ដូច្នេះរាងកាយរមែងរក្សាភាពមាំមួន, ឆ្ពោះឡើង។ ប៉ុន្តែ

កោសិកាមនុស្សជាតិមិនអាចបែងចែកអនន្តភាពបែបនេះបាន, ចំនួនដងបែងចែករបស់កោសិកាគឺមានកំណត់។ ឧបមាក្នុងមួយជីវិតរបស់មនុស្សកោសិកាអាចបែងចែក១០០ដង, តាមពិតទៅ, ទាំងជាងរយម៉ឺនដង។ ឧបមាថាកោសិការបស់មនុស្សជាធម្មតាបែងចែក១០០ដងរស់បាន១០០ឆ្នាំ, តែឥឡូវកោសិការស់បានតែពាក់កណ្ដាលជីវិត, ដូច្នោះគាត់គ្រាន់តែអាចរស់បាន៥០ឆ្នាំ។ តែពួកយើងមិនដែលមើលឃើញអត្តពលិកណាលេចឡើងបញ្ហាធំខ្លាំង, ដោយសារអត្តពលិកបច្ចុប្បន្នមិនទាន់ដល់អាយុ៣០ផងគឺត្រូវបានជម្រុះរួចហើយ, ជាពិសេសកម្រិតប្រកួតប្រជែងបច្ចុប្បន្នក៏ខ្ពស់, ចំនួនអត្តពលិកជម្រុះក៏ច្រើន, ដូច្នេះគាត់ម្ដងទៀតវិលមកជីវិតធម្មតា, មើលទៅគ្មានឥទ្ធិពលប៉ុន្មាន។ ពីលើទ្រឹស្ដីសង្កេតមើលធាតុពិតគឺជាបែបនេះ, អាចធ្វើឱ្យរាងកាយរបស់គាត់រក្សាបានរូបកាយមួយមាំមួន, តែផ្ទុយមកវិញកាត់បន្ថយជីវិតរបស់គាត់។ សង្កេតមើលពីខាងក្រៅ, អត្តពលិកអាយុដប់ប៉ុន្មានឆ្នាំមើលទៅគឺដូចអាយុម្ភៃប៉ុន្មានឆ្នាំ; ម្ភៃប៉ុន្មានឆ្នាំគឺដូចមនុស្សសាមសិបប៉ុន្មានឆ្នាំ។ ជាញឹកញាប់អត្តពលិកផ្ដល់ឱ្យគេនូវអារម្មណ៍បង្ហាញឆាប់ធំនិងចាស់ខ្សោយមុនអាយុ, មានគុណសម្បត្តិនិងគុណវិបត្តិ, មើលដោយវិចារវិទ្យា, ភាពពិតជាក់ស្ដែងគឺជាដើរផ្លូវនេះ។

បួសហាត់ឈើគង់ផ្ទុយស្រឡះនឹងធ្វើលំហាត់ប្រាណ, នៅលើចលនាមិនតម្រូវធ្វើចលនាខ្លាំងក្លា, មានចលនាក៏ជាទន់ភ្លន់, យឺត, មូល, ទន់ភ្លន់និងយឺតខ្លាំងណាស់, សូម្បីតែមិនកម្រើក, ស្ងៀមស្ងប់ចុះមក។ អ្នករាល់គ្នាបានដឹងសមាធិប្រភេទវិធីសាស្ត្របួសហាត់នេះ, ស្ងៀមស្ងប់នៅទីនោះ, ល្បឿនចង្វាក់បេះដូងក៏ត្រូវថយចុះ, ដំណើរជុំឈាម។ល។ ទាំងអស់សុទ្ធតែត្រូវថយចុះ, ឥណ្ឌាមានគ្រូយូហ្គាជាច្រើន, អាចអង្គុយ

នៅក្នុងទឹកប៉ុន្មានថ្ងៃ, កប់នៅក្នុងដីប៉ុន្មានថ្ងៃ, ទាំងស្រុងធ្វើឱ្យខ្លួនឯងស្ងៀមស្ងប់ចុះមក, សូម្បីតែចង្វាក់បេះដូងក៏អាចឃុំគ្រងជាប់។ ឧបមាថាកោសិកាមនុស្ស១ថ្ងៃបែងចែកមួយដង, ដូច្នោះអ្នកបួសហាត់ធ្វើឲ្យកោសិការបស់រាងកាយមនុស្ស២ថ្ងៃបែងចែកមួយដង, មួយសប្ដាហ៍បែងចែកមួយដង, កន្លះខែបែងចែកមួយដង, សូម្បីតែពេលវេលាយូរជាងបែងចែកមួយដង, ដូច្នោះគាត់បានអូសវែងជីវិតរបស់គាត់រួចហើយ។ នេះជាប្រភេទគង់ហ្វានោះគ្រាន់តែបួសចរិតតែមិនបួសជីវិត, វាក៏អាចសម្រេចបានចំណុចមួយនេះ, ក៏អាចធ្វើឲ្យជីវិតរបស់ខ្លួនឯងអូសវែង។ មានមនុស្សគិតថា៖ ជីវិតរបស់មនុស្ស, មួយជាតិរបស់មនុស្សមិនមែនកំណត់រួចរាល់ហើយឬ? មិនបួសជីវិតធ្វើម្ដេចអាចរស់បានយូរជាង? ត្រូវ, ដោយសារជាន់ថ្នាក់មនុស្សដែលបួសហាត់ទម្លុះត្រៃភពគឺអាចអូសវែង, តែផ្ទុយមកវិញមើលនៅលើផ្ទៃរូបចាស់ខ្លាំងណាស់។

គង់ហ្វាបួសជីវិតពិតប្រាកដ, ត្រូវការបន្ដយកសារធាតុថាមពលខ្ពស់ប្រមូលបានស្ដុកទុកនៅក្នុងកោសិការាងកាយមនុស្ស, ពេលបន្ដបង្កើនដង់ស៊ីតេរបស់វា, បន្ដិចម្ដងៗគឺអាចរឹតត្បិតជាប់កោសិការបស់មនុស្សសាមញ្ញ, សន្សឹមៗគឺជំនួសឲ្យកោសិការបស់មនុស្សសាមញ្ញ។ ពេលនោះនឹងកើតឡើងការផ្លាស់ប្រែគុណភាព, ឯកជននេះនឹងនៅក្មេងជារៀងរហូត។ ប្រាកដណាស់ក្នុងដំណើរការបួសហាត់ជាដំណើរការដ៏យឺតយូរ, បង់ចំណាយត្រូវតែយ៉ាងធំ។ ពលកម្មនៃសរសៃពួរឆ្អឹង, ទុក្ខនៃចិត្តឆន្ទៈ, គឺដ៏មិនងាយស្រួល។ រវាងមនុស្សនិងមនុស្សនៅក្នុងពេលកកិតចិត្តចរិតតើអាចមិនកម្រើកចិត្តឬ? នៅលើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ឯកជនតើអាចមិនកម្រើកចិត្តឬ? រឿងរ៉ាវទាំងនេះធ្វើបានក៏ដ៏ពិបាក, ដូច្នេះមិនមែនចង់សម្រេចបានគោលបំណងនេះគឺអាចសម្រេចបានទេ។ ចិត្តចរិត

របស់មនុស្ស, គុណធម៌របស់មនុស្សសុទ្ធតែបួសឡើងលើទើបអាចសម្រេចបានគោលបំណងបែបនេះ។

ពីដើមមកមនុស្សដ៏ច្រើនសុទ្ធតែមើលឈីគង់ច្រទ្បំនឹងធ្វើលំហាត់ប្រាណធម្មតា, ភាពពិតខុសគ្នាធំខ្លាំងណាស់, ជាមូលដ្ឋានគឺមិនមែនរឿងតែមួយ។ គ្រាន់តែពេលដែលហាត់ឈីនៅជាន់ថ្នាក់ទាបបំផុត, យកចិត្តទុកដាក់ព្យាបាលជំងឺកាយសម្បទា, សម្រេចបានរាងកាយមួយមាំមួន, គោលបំណងរបស់ជាន់ថ្នាក់ទាបបំផុតនិងធ្វើលំហាត់ប្រាណមានភាពស្របគ្នា។ ប៉ុន្តែឡើងដល់ជាន់ថ្នាក់ខ្ពស់, ជាមូលដ្ឋានគឺមិនមែនរឿងតែមួយយ៉ាងនោះ។ បន្សុទ្ធរាងកាយរបស់ឈីគង់ក៏ជាមានគោលបំណង, ថែមទៀតត្រូវការប្រើគោលសីលធម៌វិសាមញ្ញដើម្បីតម្រូវមនុស្សហាត់គង់, មិនអាចប្រើគោលសីលធម៌របស់មនុស្សសាមញ្ញមកតម្រូវ។ ហើយធ្វើលំហាត់ប្រាណគ្រាន់តែជារឿងក្នុងមនុស្សសាមញ្ញ។

# គំនិត

និយាយដល់គំនិត, ក៏ជាក់ស្ដែងគឺសកម្មភាពផ្នត់គំនិតរបស់មនុស្សពួកយើង។ នៅពិភពបួសហាត់មើលគំនិតមនុស្សនៅសកម្មភាពផ្នត់គំនិតនៃខួរធំដូចម្ដេច? មើលទម្រង់ខុសគ្នានៃផ្នត់គំនិត (គំនិត) របស់មនុស្សដូចម្ដេច? គឺបង្ហាញចេញមកដូចម្ដេច? វេជ្ជសាស្ត្រទំនើបស្រាវជ្រាវខួរធំរបស់មនុស្សមានបញ្ហាដ៏ច្រើននៅតែដ៏ពិបាកបកស្រាយ, ដោយសារតែមិនដូចប្រការនៃលើផ្ទៃរាងកាយពួកយើងងាយស្រួលយ៉ាងនេះ។ នៅជាន់ជ្រៅ, អវកាសខុសគ្នាសុទ្ធតែមានទម្រង់ខុសគ្នា។ ទោះយ៉ាងណាក៏មិនដូចមានគ្រូឈីគង់មួយចំនួនសម្ដែងបែបនោះ។ មានគ្រូឈីគង់មួយចំនួនគាត់ខ្លួនឯងមិនដឹងរឿងដូចម្ដេច, គាត់និយាយមិនច្បាស់លាស់។ គាត់សន្មតថាខួរធំរបស់ខ្លួនឯងកម្រើកកាលណា, គំនិតសាង

បង្កើតកាលណាគឺអាចធ្វើរឿងរ៉ាវមួយចំនួន, គាត់ក៏និយាយថាគឺមនោគតិរបស់គាត់ធ្វើ, គំនិតរបស់គាត់ធ្វើ, ភាពពិតជាមូលដ្ឋានមិនមែនគំនិតរបស់គាត់ធ្វើ។

ដំបូងពួកយើងសម្តែងអំពីប្រភពផ្ទត់គំនិតរបស់មនុស្ស, ប្រទេសចិនបុរាណមានការថ្លែងមួយ៖ [បេះដូងគិត]។ ហេតុអ្វីសម្តែងបេះដូងគិត? វិទ្យាសាស្ត្រនៃប្រទេសចិនបុរាណគឺរីកចម្រើនខ្លាំងណាស់, ដោយសារវាដោយផ្ទាល់តម្រង់ចំរាងកាយមនុស្ស, ជីវិត, ចក្រវាលប្រការទាំងនេះដើម្បីស្រាវជ្រាវ។ មនុស្សខ្លះដោយមែនទែនទទួលដឹងគឺបេះដូងកំពុងគិតបញ្ហា, ហើយមនុស្សខ្លះទទួលដឹងគឺខួរធំកំពុងគិតបញ្ហា។ ហេតុអ្វីបានជាលេចឡើងកាលៈទេសៈនេះ? បេះដូងគិតដែលគាត់សម្តែងក៏ជាសមហេតុផល, ដោយសារយើងខ្ញុំឃើញវិញ្ញាណដើមរបស់មនុស្សសាមញ្ញតូចណាស់, ព័ត៌មានពិតប្រាកដដែលខួរធំមនុស្សផ្ញើចេញមិនមែនខួរធំមនុស្សខ្លួនវាផ្តើមផលប៉ះពាល់, មិនមែនខួរធំខ្លួនវាផ្ញើចេញមក, តែគឺវិញ្ញាណដើមរបស់មនុស្សផ្ញើចេញមក។ វិញ្ញាណដើមមនុស្សមិនមែនគ្រាន់តែស្នាក់នៅវិមាននីវ៉ាន។ វិមាននីវ៉ានដែលតាវវង្សនិយាយជាក់ស្តែងគឺជាក្រពេញស្រល់ដែលវេជ្ជសាស្ត្រទំនើបពួកយើងបានយល់ដឹង។ ប្រសិនវិញ្ញាណដើមនៅវិមាននីវ៉ាន, ដូច្នោះពួកយើងមែនទែនទទួលដឹងគឺខួរធំកំពុងគិតបញ្ហា, កំពុងផ្ញើចេញព័ត៌មាន; ប្រសិនគឺនៅបេះដូង, ដូច្នោះដោយមែនទែនទទួលដឹងគឺបេះដូងកំពុងគិតបញ្ហា។

រាងកាយមនុស្សជាចក្រវាលតូចមួយ, កាយជីវិតដ៏ច្រើនរបស់មនុស្សហាក់គង់សុទ្ធតែអាចសាងបង្កើតផលប៉ះពាល់ផ្លាស់ទី។ ប្រសិនពេលដែលវិញ្ញាណដើមកើតឡើងការផ្លាស់ទី, គាត់រត់ទៅលើក្រពះ, ដូច្នោះនឹងទទួលដឹងមែនទែនគឺក្រពះកំពុងគិតបញ្ហា; ប្រសិនវិញ្ញាណ

ដើមរត់ដល់កំភួនជើង, ទៅលើកែងជើង, ដូច្នោះគឺនឹងទទួលដឹងគឺកំភួនជើង, កែងជើងកំពុងពិចារណាបញ្ហា, ធានាគឺជាបែបនេះ, ស្ដាប់ទៅដឹងអាថ៌កំបាំង។ នៅពេលលោកអ្នកបួសហាត់ជាន់ថ្នាក់មិនសូវខ្ពស់, លោកអ្នកគឺនឹងទទួលដឹងអត្ថិភាពរបស់បាតុភូតនេះ។ រាងកាយមនុស្សប្រសិនគ្មានវិញ្ញាណដើមរបស់គាត់, គ្មានអធ្យាស្រ័យ, ចរិតធម្មជាតិ, ចរិតពិសេសរបស់គាត់, គ្មានរបស់ទាំងនេះ, ជាក់ស្ដែងគឺជាសាច់មួយដុំ, គាត់មិនអាចជាមនុស្សម្នាក់ពេញលេញ, មាននាំតាមបុគ្គលភាពខ្លួនឯងឯករាជ្យ។ ដូច្នោះខួរធំរបស់មនុស្សផ្ដើមផលប៉ះពាល់អ្វី? បើហៅខ្ញុំសម្ដែង, ខួរធំរបស់មនុស្សនៅក្នុងទម្រង់អវកាសសារធាតុនេះរបស់ពួកយើង, វាគ្រាន់តែជារោងចក្រកែច្នៃមួយ។ ព័ត៌មានពិតប្រាកដគឺវិញ្ញាណដើមផ្ញើចេញ, ប៉ុន្តែរបស់ដែលគាត់ផ្ញើចេញមិនមែនជាភាសា, ដែលគាត់ផ្ញើចេញជាប្រភេទព័ត៌មានចក្រវាលមួយ, តំណាងឲ្យន័យណាមួយ។ ខួរធំពួកយើងទទួលយកបទបញ្ជានេះរួចហើយ, កែច្នៃវាក្លាយជាភាសាបច្ចុប្បន្នរបស់ពួកយើង, ប្រភេទទម្រង់បង្ហាញនេះ។ ពួកយើងតាមរយៈឥរិយាបថដៃ, ខ្សែភ្នែក, ចលនាទាំងមូលដើម្បីយកវាបង្ហាញចេញមក, ខួរធំគឺបានផ្ដើមផលប៉ះពាល់បែបនេះ។ បទបញ្ជាពិតប្រាកដ, ផ្នត់គំនិតពិតប្រាកដគឺវិញ្ញាណដើមរបស់មនុស្សផ្ញើចេញ។ ជាញឹកញាប់គេគឺសន្មតថាជាផលប៉ះពាល់ឯករាជ្យដោយផ្ទាល់របស់ខួរធំ, ភាពពិតមានពេលខ្លះវិញ្ញាណដើមនៅបេះដូង, មនុស្សខ្លះមែនទែនទទួលដឹងគឺបេះដូងគិត។

បច្ចុប្បន្នអ្នកស្រាវជ្រាវរាងកាយមនុស្សសន្មតថា, ខួរធំរបស់មនុស្សផ្ញើចេញគឺជាប្រភេទរបស់មួយដូចរលកអគ្គិសនីប្រភេទទម្រង់នេះ, ធាតុពិតដែលផ្ញើចេញជាអ្វីយើងខ្ញុំមិនសម្ដែងមុន, ប៉ុន្តែពួកគាត់ទទួលស្គាល់វាគឺជាប្រភេទអត្ថិភាពសារធាតុមួយ, ដូច្នោះក៏ជាក់ស្ដែងមិនមែនអបិយជំ

នឿ។ របស់នេះធ្វើចេញផ្ដើមផលប៉ះពាល់អ្វី? គ្រូឈីគង់ខ្លះសម្តែង៖ ខ្ញុំប្រើគំនិតផ្ទេរជញ្ជូន, ប្រើគំនិតបើកភ្នែកទិព្វឲ្យលោកអ្នក, ប្រើគំនិតព្យាបាលជំងឺឲ្យលោកអ្នក។ល។ ភាពពិតមានគ្រូឈីគង់មួយចំនួន, គាត់ខ្លួនឯងមានសីលគង់អ្វីគាត់មិនដឹងទាល់តែសោះ, ក៏មិនច្បាស់លាស់។ គាត់គ្រាន់តែដឹងថាគាត់ចង់ធ្វើរឿងរ៉ាវអ្វីពេលគិតគឺធ្វើបាន។ ភាពពិតជាក់ស្តែងគឺគំនិតរបស់គាត់កំពុងដំណើរការ, សីលគង់ទទួលរងការឃុំគ្រងពីគំនិតរបស់ខួរធំ, នៅក្រោមបញ្ជារបស់គំនិតធ្វើរឿងពិស្តារ, ហើយគំនិតរបស់គាត់ខ្លួនវាក៏មិនអាចធ្វើបានរឿងណាមួយ។ ពេលដែលមនុស្សហាត់គង់ម្នាក់ធ្វើរឿងរ៉ាវពិស្តារអ្វីមួយ, គឺសីលគង់របស់គាត់កំពុងផ្ដើមផលប៉ះពាល់។

សីលគង់ជាសក្តានុពលរបស់រាងកាយមនុស្ស, ស្របតាមការអភិវឌ្ឍន៍របស់សង្គមមនុស្សជាតិពួកយើង, ផ្ទត់គំនិតខួរធំរបស់មនុស្សមួយថ្ងៃកាន់តែប្រែជាស្មុគស្មាញ, មួយថ្ងៃកាន់តែយកចិត្តទុកដាក់លើតថភាព, មួយថ្ងៃកាន់តែពឹងផ្អែកលើដែលគេហៅថាឧបករណ៍ទំនើបកម្ម, បែបនេះ, សភាវគតិរបស់មនុស្សគឺមួយថ្ងៃកាន់តែឱនថយ។ តាវវង្សសម្តែងត្រឡប់ដើមមកសច្ចៈ, នៅក្នុងដំណើរការបួសហាត់, លោកអ្នកត្រូវតែសច្ចៈ, ចុងក្រោយត្រឡប់ដើមមកសច្ចៈ, ត្រឡប់ទៅដល់ចរិតដើមបុព្វកាលរបស់លោកអ្នក, លោកអ្នកទើបអាចលាតត្រដាងចេញសភាវគតិទាំងនេះរបស់លោកអ្នក។ ពួកយើងបច្ចុប្បន្នហៅថាសីលគង់ពិសេស, ភាពពិតសុទ្ធតែជាសភាវគតិរបស់មនុស្ស។ សង្គមមនុស្សជាតិហាក់ដូចជាជឿនលឿន, ភាពពិតគឺកំពុងសំដៅថយក្រោយ, ឃ្លាតពីចរិតពិសេសនៃចក្រវាលរបស់ពួកយើងមួយថ្ងៃកាន់តែឆ្ងាយ។ ថ្ងៃនោះខ្ញុំសម្តែងច្វាងគួរឡៅជិះលាបញ្ច្រាស, អាចមិនពន្យល់បានគឺជាអត្ថន័យអ្វី។ គាត់រក

ឃើញថាដើរសំដៅទៅមុខជាក់ស្ដែងគឺជាឆ្ពោះថយក្រោយ, មនុស្សឃ្លាតពីចរិតពិសេសនៃចក្រវាលមួយថ្ងៃកាន់តែឆ្ងាយ។ នៅក្នុងដំណើរការវិវត្តន៍របស់ចក្រវាល, ជាពិសេសគឺបច្ចុប្បន្នបន្ទាប់ពីដើរចូលក្នុងជំនោរសេដ្ឋកិច្ចទំនិញ, សីលធម៌របស់មនុស្សជាច្រើនដ៏អន្តរាយ, ឃ្លាតពីចរិតពិសេសសច្ចៈ, ករុណា, ខន្តីនៃចក្រវាលមួយថ្ងៃកាន់តែឆ្ងាយ, នៅក្នុងមនុស្សសាមញ្ញស្របតាមនិន្នាការដើរចុះគេគឺមិនទទួលដឹងបានកម្រិតអន្តរាយរបស់សីលធម៌មនុស្សជាតិ, ដូច្នេះមានមនុស្សមួយចំនួននៅតែសន្មតថាគឺជារឿងល្អ, មានតែមនុស្សដែលចិត្តចរិតបួសឡើងលើរួចហើយពេលបង្វែរមកមើល, ទើបអាចយល់ដឹងបានសីលធម៌មនុស្សជាតិអន្តរាយដល់ស្ថានភាពគួរឱ្យខ្លាចដល់ណា។

គ្រូឈីគង់ខ្លះសម្ដែង៖ "ខ្ញុំបើកបញ្ចេញសីលគង់ឱ្យលោកអ្នក"។ បើកបញ្ចេញសីលគង់អ្វី? សីលគង់របស់គាត់គ្មានថាមពលមិនប្រើបាន, មិនទាន់ចេញមកលោកអ្នកអាចបើកបញ្ចេញមកបានឬ? ពេលដែលសីលគង់របស់គាត់មិនទាន់បានថាមពលរបស់គាត់ពង្រឹងបង្គរូប, លោកអ្នកអាចយកវាបើកបញ្ចេញមកបានឬ? ជាមូលដ្ឋានគឺមិនបាន។ បើកបញ្ចេញសីលគង់ដែលគាត់និយាយ, ហួសពេកគ្រាន់តែជាយកសីលគង់បានបង្គរួចរាល់របស់លោកអ្នកនិងខួរធំរបស់លោកអ្នកតភ្ជាប់ជាមួយគ្នា, ទទួលបញ្ជារបស់គំនិតខួរធំលោកអ្នកហើយផ្ដើមផលប៉ះពាល់, នេះក៏ចាត់ថាគាត់បើកបញ្ចេញសីលគង់, ភាពពិតគាត់គ្មានបើកបញ្ចេញសីលគង់អ្វីឲ្យលោកអ្នក, គ្រាន់តែបានធ្វើរឿងបន្តិចយ៉ាងនេះ។

ចំពោះមនុស្សហាត់គង់សម្ដែង, គំនិតរបស់មនុស្សបញ្ជាសីលគង់របស់មនុស្សដើម្បីធ្វើរឿង; ហើយធ្វើជាមនុស្សសាមញ្ញម្នាក់ដើម្បីសម្ដែង, គំនិតបញ្ជាអវយវៈ, អង្គញាណរបស់មនុស្សដើម្បីធ្វើរឿង, គឺដូចការិយា

ល័យផលិតកម្មរបស់រោងចក្រមួយ, ការិយាល័យនាយកផ្ញើចេញបទបញ្ជា, ពិស្តារផ្ទៃកមុខងារនីមួយៗធ្វើរឿងរបស់ខ្លួន។ គឺដូចជានាយកដ្ឋានបញ្ជាការកងទ័ព, ទីបញ្ជាការទ័ពផ្ញើចេញបទបញ្ជា, បញ្ជាកម្លាំងទាំងមូលទៅបំពេញបេសកកម្ម។ ពេលដែលបើកថ្នាក់នៅកន្លែងផ្សេងខ្ញុំនិងអ្នកដឹកនាំសមាគមស្រាវជ្រាវឈីគង់ទីនោះឧស្សាហ៍និយាយអំពីបញ្ហានេះ។ ពួកគាត់មានអារម្មណ៍ដ៏ភ្ញាក់ផ្អើលៈ "យើងខ្ញុំរមែងកំពុងស្រាវជ្រាវថាផ្នត់គំនិតរបស់មនុស្សមានថាមពលសក្តានុពល, សតិសក្តានុពលដ៏ធំធេង"។ ភាពពិតមិនមែនជាបែបនេះ, គាត់ពេលចាប់ផ្តើមគឺដើរគម្លាតរួចហើយ។ ខ្ញុំនិយាយថាវិទ្យាសាស្ត្រអំពីរាងកាយមនុស្ស, ផ្នត់គំនិតរបស់មនុស្សគឺត្រូវតែកើតឡើងការផ្លាស់ប្តូរ, មិនអាចប្រើវិធីសាស្ត្រសន្និដ្ឋាន, វិធីសាស្ត្រយល់ដឹងបញ្ហារបស់មនុស្សសាមញ្ញដើម្បីយល់ដឹងប្រការវិសាមញ្ញនោះបាន។

និយាយដល់គំនិត, នៅមានប៉ុន្មានប្រភេទទម្រង់គំនិត។ ឧបមាថាមានមនុស្សសម្តែងអំពីអឌ្ឍសម្បជញ្ញៈ, អនុសម្បជញ្ញៈ, បំផុសគំនិត, យល់សប្តិ។ល។ និយាយដល់យល់សប្តិ, គ្មានគ្រូឈីគង់ណាចង់ទៅពន្យល់អំពីវា។ ដោយសារនៅពេលលោកអ្នកចាប់កំណើត, នៅក្នុងអវកាសជាច្រើនរបស់ចក្រវាលសុទ្ធតែមានលោកអ្នកមួយចាប់កំណើតក្នុងពេលដំណាលគ្នា, និងលោកអ្នកជាកាយតែមួយពេញលេញ, សុទ្ធតែមានទំនាក់ទំនងគ្នាទៅវិញទៅមក, សុទ្ធតែមានទាក់ទងពាក់ព័ន្ធនៅលើផ្នត់គំនិត។ ហើយលោកអ្នកខ្លួនឯងក៏មានវិញ្ញាណដើមម្ចាស់, វិញ្ញាណដើមរង, នៅមានរូបភាពរបស់កាយជីវិតដទៃគ្រប់ប្រភេទស្ថិតនៅក្នុងរាងកាយ, រាល់កោសិកា, សរីរាង្គខាងក្នុងទាំងអស់សុទ្ធតែជាព័ត៌មានរូបភាពរបស់លោកអ្នក{មាន}ទម្រង់អត្ថិភាពនៅក្នុងអវកាសផ្សេង, ដូច្នេះគឺ

ស្អុគស្មាញខ្លាំងណាស់។ ពេលលោកអ្នកយល់សប្តិមួយភ្លែតបែបនេះ, មួយភ្លែតបែបនោះ, នៅទីបញ្ចប់គឺពីណាមកហ្ន៎? ក្នុងវេជ្ជសាស្ត្រ, និយាយថាគឺបានកើតឡើងផ្ទាល់ប្រែនៅជាន់សំបកខួរធំរបស់ពួកយើង។ នេះគឺប្រតិកម្មបង្ហាញនៅលើទម្រង់សារធាតុនេះ, ភាពពិតវាគឺរងផលប៉ះពាល់របស់ព័ត៌មាននៃអវកាសផ្សេង។ ដូច្នេះពេលដែលលោកអ្នកយល់សប្តិលោកអ្នកមានអារម្មណ៍ស្រមើស្រមៃ, នេះគ្មានទាក់ទងអ្វីជាមួយលោកអ្នក, លោកអ្នកក៏មិនចាំបាច់គ្រប់គ្រងវា។ មានប្រភេទសុបិន្តមួយមានពាក់ព័ន្ធដោយផ្ទាល់នឹងលោកអ្នក, ប្រភេទសុបិន្តនេះពួកយើងមិនអាចហៅវាថាជាសុបិន្ត។ សតិម្ចាស់របស់លោកអ្នក, ក៏ជាក់ស្តែងគឺវិញ្ញាណដើមម្ចាស់, នៅក្នុងសុបិន្តយល់សប្តិជួបសាច់ញាតិនៅចំពោះមុខ; ឬក៏ដោយមែនទែនទទួលដឹងបានរឿងរ៉ាវមួយ; មើលឃើញរបស់អ្វីឬក៏បានធ្វើរឿងរ៉ាវអ្វី។ ដូច្នោះជាក់ស្តែងគឺវិញ្ញាណដើមម្ចាស់របស់លោកអ្នកពិតប្រាកដបានធ្វើរឿងរ៉ាវអ្វីមួយនៅក្នុងអវកាសផ្សេង, បានមើលឃើញរឿងរ៉ាវអ្វីមួយ, ក៏បានធ្វើរួចហើយ, សតិច្បាស់លាស់, រស់រវើក, ហើយប្រភេទរឿងរ៉ាវនេះដោយមែនទែនគឺស្ថិតនៅ, ហួសពេកគ្រាន់តែជានៅក្នុងអវកាសសារធាតុផ្សេង, អនុវត្តនៅក្នុងវេលា-អវកាសផ្សេង។ តើលោកអ្នកអាចហៅវាថាជាសុបិន្តឬ? មិនមែន។ រាងកាយសារធាតុរបស់លោកអ្នកខាងនេះមែនទែនកំពុងគេង, ក៏គ្រាន់តែហៅវាថាជាសុបិន្ត, មានតែប្រភេទសុបិន្តនេះគឺមានពាក់ព័ន្ធដោយផ្ទាល់ចំពោះលោកអ្នក។

និយាយអំពីប្រភេទរបស់បំផុសគំនិត, អនុសម្បជញ្ញៈ, អឡ្ឋសម្បជញ្ញៈរបស់មនុស្ស, ខ្ញុំនិយាយថានាមសព្ទនេះមិនមែនអ្នកវិទ្យាសាស្ត្រលើកឡើងមក, ជានាមសព្ទដែលអ្នកនិពន្ធលើកឡើងដោយយោងតាមស្ថានភាពទម្លាប់ក្នុងមនុស្សសាមញ្ញ, វាគ្មានចរិតវិទ្យាសាស្ត្រ។ អឡ្ឋសម្ប

ជញ្ញៈដែលគេសំដៅលើនៅទីបញ្ចប់ជាអ្វី? ដ៏ពិបាកនិយាយច្បាស់, ទូទៅណាស់, ដោយសារព័ត៌មានគ្រប់ប្រភេទរបស់មនុស្សស្មុគស្មាញខ្លាំងណាស់, ហាក់ដូចជាបន្តិចការចងចាំស្រពិចស្រពិល។ ចំពោះអនុសម្បជញ្ញៈដែលគាត់បាននិយាយ, យើងខ្ញុំក៏ងាយស្រួលពន្យល់។ យោងតាមនិយមន័យអំពីស្ថានភាពអនុសម្បជញ្ញៈ, តាមធម្មតាគឺសំដៅលើពេលមនុស្សស្រមើស្រមៃបានធ្វើរឿងរ៉ាវមួយ, ជាញឹកញាប់គេក៏និយាយថាគាត់គឺធ្វើដោយអនុសម្បជញ្ញៈ, មិនមែនចេតនាដើម្បីធ្វើ។ ប្រភេទអនុសម្បជញ្ញៈនេះពិតណាស់និងសតិរងដែលពួកយើងហៅគឺជាដូចគ្នា។

ដោយសារក្រោយពីសតិម្ចាស់របស់មនុស្សបន្ធូរ, ពេលដែលគ្មានគ្របសង្កត់ខួរធំ, ស្រមើស្រមៃដូចគេងលក់, ឬក៏នៅក្នុងសុបិន្ត, នៅក្រោមស្ថានភាពមិនដឹងខ្លួនគឺងាយស្រួលត្រូវបានសតិរង, ក៏ជាក់ស្តែងគឺវិញ្ញាណដើមរងធ្វើម្ចាស់។ ពេលនោះវិញ្ញាណដើមរងគឺអាចធ្វើចេញរឿងរ៉ាវមួយចំនួន, ក៏មានន័យថានៅក្រោមស្ថានភាពដែលលោកអ្នកខ្លួនឯងស្រមើស្រមៃធ្វើចេញមក។ ទោះយ៉ាងណា, ជាញឹកញាប់រឿងរ៉ាវទាំងនេះដែលបានធ្វើសុទ្ធតែមិនងាយស្រួលធ្វើអាក្រក់, ដោយសារសតិរងនៅក្នុងអវកាសផ្សេងអាចមើលឃើញធាតុដើមរបស់រឿងការណ៍, មិនរងភាពវង្វេងរបស់សង្គមមនុស្សសាមញ្ញពួកយើង, ដូច្នេះរឿងរ៉ាវដែលគាត់ធ្វើ, រង់ចាំយល់ច្បាស់វិញហើយសង្កេតមើល៖ រឿងរ៉ាវនេះហេតុម្តេចធ្វើបានអន់យ៉ាងនេះ, ពេលខ្ញុំច្បាស់ឥតខ្ចោះគឺនឹងមិនធ្វើបែបនេះ។ ប៉ុន្តែ, លោកអ្នកឥឡូវនេះនិយាយថាវាមិនល្អ, រង់ចាំ១០ថ្ងៃកន្លះខែក្រោយមើលឡើងវិញ៖ អ៊ំាយយ៉ា, រឿងរ៉ាវនេះធ្វើបានល្អយ៉ាងនេះ! ពេលនោះហេតុម្តេចខ្ញុំធ្វើបានរឿងនេះអ៊ំា? ជាញឹកញាប់នឹងលេចឡើងបញ្ហានេះ។ ដោយសារសតិរងមិនខ្វល់ពេលនោះរឿងនេះផ្តើមផលប៉ះពាល់អ្វី, ទោះយ៉ាងណាអនាគត

នឹងផ្ដើមផលប៉ះពាល់ល្អ។ ក៏មានរឿងរ៉ាវខ្លះគ្មានផលវិបាកអ្វី, ជាក់ស្ដែងគឺពេលនោះផ្ដើមផលប៉ះពាល់រួចហើយ, ដូច្នោះសតិរងទៅធ្វើ, អាចពេលនោះគឺធ្វើរឿងរ៉ាវនេះបានល្អខ្លាំងណាស់។

នៅមានប្រភេទទម្រង់មួយទៀត, នោះគឺពួកយើងជាញឹកញាប់មនុស្សដែលនិស្ស័យដ៏ល្អ, ងាយស្រួលទទួលរងឃុំគ្រងរបស់ជីវិតកម្រិតខ្ពស់ដើម្បីធ្វើរឿងរ៉ាវមួយចំនួន។ ប្រាកដណាស់នោះគឺរឿងមួយផ្សេង, ទីនេះមិនសម្ដែង, ចម្បងសម្ដែងអំពីប្រភេទសតិមួយប្រភពមកពីផ្ទាល់ខ្លួនមនុស្សពួកយើង។

និយាយចំពោះបំផុសគំនិត, វាក៏ជានាមសព្ទដែលអ្នកនិពន្ធលើកឡើង។ មនុស្សធម្មតាសន្មតថា៖ បំផុសគំនិតជាក់ស្ដែងគឺជាចំណេះដឹងសន្សំទុកនៅក្នុងមួយជីវិតរបស់មនុស្ស, នៅមួយសន្ទុះនោះដូចជាផ្កាភ្លើងផ្ទុះឡើងមក។ ខ្ញុំនិយាយបើយោងតាមទស្សនៈសម្ភារៈនិយមសង្កេតមើល, ចំណេះដឹងសន្សំទុកក្នុងមួយជីវិតរបស់មនុស្សជាតិ, ចំណេះដឹងសន្សំទុកកាន់តែច្រើន, ខួរធំមនុស្សកាន់តែប្រើគឺកាន់តែសង្វាត។ ដល់ពេលដែលប្រើ, គឺគួរតែចេញមកដូចលំហូរមិនចេះចប់, ក៏ជានិយាយមិនបានបញ្ហាបំផុសគំនិតអ្វី។ ជាទូទៅដែលគេហៅថាកើតបំផុសគំនិត, ឬក៏ពេលដែលបំផុសគំនិតមក, វាមិនមែនស្ថានភាពនេះ។ ជាញឹកញាប់គឺពេលដែលមនុស្សប្រើខួរក្បាល, ប្រើអាំប្រើអំា, ដល់ចុងក្រោយមានអារម្មណ៍ថាចំណេះដឹងរីងស្ងួត, ហាក់ដូចជាប្រើមិនចេញទៀត; សរសេរអត្ថបទដល់ទីនោះមិនដាក់ប៊ិកចុះបានទៀត; តែងបទចម្រៀងមួយគ្មានគិតថែមបានទៀត; ធ្វើគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រមួយធ្វើបន្តមិនបានទៀត។ ជាញឹកញាប់នៅពេលនេះសរសៃបែតងលោតខ្លាំង, កន្ទុយបារីបោះនៅពេញដី, ទាល់ច្រកខួរក្បាលឡើងឈឺ, ក៏គ្មានគិតចេញមកបាន។

ចុងក្រោយសុទ្ធតែជាក្រោមស្ថានភាពអ្វីដែលបំផុសគំនិតមក? ឧបមាពេលហាត់គិតថា៖ [មិនអើពើ, សម្រាកបន្តិចសិន]។ ដោយសារសតិម្ចាស់គ្រប់សង្កត់ខួរធំកាន់តែរឹងមាំ, ជីវិតដទៃក៏កាន់តែសៀតចូលទៅមិនបាន។ គាត់នេះសម្រាកកាលណា, មនោគតិរបស់គាត់បន្ធូរកាលណា, មិនគិតដល់វា, ក្នុងពេលដោយមិនដឹងខ្លួននេះគិតចេញបានភ្លាម, ពីក្នុងខួរក្បាលផុសចេញមក។ បំផុសគំនិតភាគច្រើនសុទ្ធតែមកយ៉ាងនេះ។

ដូច្នោះហេតុអ្វីពេលនេះបំផុសគំនិតមក? ដោយសារខួរធំរបស់មនុស្សនៅក្រោមការគ្របសង្កត់របស់សតិម្ចាស់, ពេលដែលកាន់តែប្រើខួរក្បាល, គាត់គ្របសង្កត់កាន់តែតឹង, សតិរងគឺកាន់តែសៀតចូលមកមិនបាន។ ពេលគាត់គិតដល់ថ្នាក់ឈឺក្បាល, ពេលដែលគិតមិនចេញដ៏ពិបាកទ្រាំ, សតិរងនោះក៏ជាផ្នែកមួយនៃរាងកាយរបស់គាត់, ក៏ជាពីក្នុងពោះម៉ែក្នុងពេលតែមួយបានកើតចេញមក, គាត់ក៏ធ្វើម្ចាស់ផ្នែកមួយរបស់រាងកាយ, គាត់ក៏ពិបាកទ្រាំ, គាត់ក៏ឈឺក្បាល, ឈឺទ្រាំមិនបាន។ ហើយនៅពេលដែលសតិម្ចាស់បន្ធូរ, សតិរងគឺយកអ្វីដែលវាដឹងឆ្លុះបញ្ចាំងដល់ក្នុងខួរធំ, ដោយសារពេលគាត់នៅអវកាសផ្សេងអាចមើលឃើញធាតុដើមរបស់រឿងការណ៍, បែបនេះគឺធ្វើចេញមក, សរសេរចេញមក, តែងចេញមក។

មានមនុស្សសម្តែង៖ នោះពួកយើងនឹងប្រើប្រាស់សតិរង។ គឺដូចទើបមានមនុស្សសរសេរប៉ុន្មានអក្សរថា៖ ធ្វើដូចម្តេចក្តាប់បានទំនាក់ទំនងនឹងសតិរង? លោកអ្នកទំនាក់ទំនងមិនបាន, ដោយសារលោកអ្នកជាមនុស្សទើបតែចាប់ផ្តើមហាត់គង់, អានុភាពអ្វីសុទ្ធតែគ្មាន, លោកអ្នកក៏ជាកុំទំនាក់ទំនង, គោលបំណងជាក់លាក់គឺជាប្រកាន់។ មនុស្សខ្លះអាចគិតថា៖ ពួកយើងនឹងប្រើប្រាស់សតិរងដើម្បីច្នៃប្រឌិតគុណតម្លៃ

ច្រើនជាងឲ្យពួកយើង, ជំរុញសង្គមមនុស្សជាតិអភិវឌ្ឍមិនបានឬ? មិនបាន, ហេតុអ្វីទៅ? ដោយសាររឿងរ៉ាវដែលសតិរងរបស់លោកអ្នកដឹងក៏ជាដ៏មានកំហិត។ អវកាសស្មុគស្មាញ, ជាន់ថ្នាក់ច្រើន, រចនាសម្ព័ន្ធរបស់ចក្រវាលនេះស្មុគស្មាញណាស់, គាត់ក៏គ្រាន់តែអាចដឹងបានប្រការនៃអវកាសដែលគាត់នៅ, ប្រការហួសផុតអវកាសដែលគាត់នៅ, គាត់គឺមិនដឹង។ លើសពីនេះនៅមានអវកាសខុសគ្នាដ៏ច្រើននៃជាន់ថ្នាក់តាមទិសបណ្តោយ, ការអភិវឌ្ឍន៍នៃមនុស្សជាតិគឺជាជីវិតកម្រិតខ្ពស់នៅក្នុងជាន់ថ្នាក់ដ៏ខ្ពស់ទើបអាចឃុំគ្រងបាន, កំពុងដំណើរការយោងតាមបទច្បាប់អភិវឌ្ឍន៍។

សង្គមមនុស្សសាមញ្ញពួកយើងគឺកំពុងអភិវឌ្ឍយោងតាមបទច្បាប់ប្រវត្តិសាស្ត្រ, លោកអ្នកចង់អភិវឌ្ឍដូចម្តេច, សម្រេចគោលដៅអ្វី, ប៉ុន្តែជីវិតកម្រិតខ្ពស់នោះប្រហែលជាមិនមែនគិតបែបនេះ។ មនុស្សបុរាណ, ពួកគាត់មិនធ្លាប់គិតដល់យន្តហោះ, រថភ្លើង, កង់របស់ថ្ងៃនេះឬ? ខ្ញុំនិយាយថាក៏មិនជាក់លាក់មិនគិតដល់។ ដោយសារប្រវត្តិសាស្ត្រមិនទាន់អភិវឌ្ឍទៅដល់ដំណើរការមួយនោះ, គាត់ក៏ច្នៃប្រឌិតចេញមិនបាន។ នៅលើផ្ទៃពីទ្រឹស្តីយល់ដឹងនៃទម្លាប់មនុស្សសាមញ្ញនេះរបស់ពួកយើង, ពីចំណេះដឹងនៃមនុស្សជាតិកំពុងមានលើជំហរមួយនេះទៅមើល, គឺដោយសារវិទ្យាសាស្ត្រមនុស្សជាតិមិនទាន់ឈានដល់កម្រិតមួយនោះ, ច្នៃប្រឌិតចេញមិនបាន។ ភាពពិតវិទ្យាសាស្ត្រមនុស្សជាតិអភិវឌ្ឍដូចម្តេច, ក៏ជាបណ្តោយតាមការរៀបចំនៃប្រវត្តិសាស្ត្រដើម្បីអភិវឌ្ឍ, លោកអ្នកមនុស្សចេតនាចង់សម្រេចបានគោលបំណងណាមួយ, ក៏ជាសម្រេចមិនបាន។ ប្រាកដណាស់ក៏មានសតិរងរបស់មនុស្សខ្លះងាយស្រួលផ្តើមផលប៉ះពាល់, មានអ្នកនិពន្ធសម្តែង៖ ខ្ញុំសរសេរសៀវភៅមួយថ្ងៃអាច

សរសេរប៉ុន្មានម៉ឺនអក្សរ, ក៏មិនហត់បន្តិចណា, បើសិនចង់សរសេរយ៉ាងលឿនក៏សរសេរចេញបាន, អ្នកដទៃអានក៏ឃើញដ៏ល្អ។ ហេតុអ្វីបានជាបែបនេះ? នេះគឺលទ្ធផលនៃផលប៉ះពាល់ចម្រុះរបស់សតិម្ចាស់និងសតិរងរបស់គាត់, សតិរងរបស់គាត់ក៏អាចកើតឡើងកន្លះផលប៉ះពាល់។ ទោះយ៉ាងណាមិនសុទ្ធតែជាបែបនេះ, ភាគច្រើនលើសលប់សតិរងមិនខ្វល់, លោកអ្នកចង់ឱ្យគាត់ធ្វើរឿង, ផ្ទុយមកវិញមិនល្អ, លទ្ធផលបញ្រ្ចាសមកវិញ។

## ចិត្តស្ងប់ស្ងាត់

មានមនុស្សជាច្រើនហាត់គង់ចូលក្នុងស្ងប់មិនបាន, ដល់គ្រប់ទីកន្លែងរកគ្រូឈើគង់ដើម្បីសួរ៖ លោកគ្រូ, កូនហេតុម្តេចហាត់គង់ចូលក្នុងស្ងប់មិនបាន, ចូលក្នុងស្ងប់កាលណាអ្វីក៏គិត, មនោគតិច្របូកច្របល់។ នោះពិតជាទន្លេសមុទ្រប្រែក្រឡាប់, អ្វីក៏ឡើងមក, លោកអ្នកជាមូលដ្ឋានសុទ្ធតែស្ងប់មិនបាន។ ហេតុអ្វីស្ងប់ចុះមកមិនបានហ្ន៎? មនុស្សខ្លះមិនយល់, សន្មតថាមានល្បិចសម្ងាត់អ្វីមួយ, គាត់ក៏រកដល់គ្រូល្បើ៖ សូមបង្រៀនកូនបន្តិចជំនាញខ្ពស់អ្វីមួយ, ដើម្បីអាចស្ងប់ចុះមកបាន។ តាមខ្ញុំឃើញ, នៅតែជាសំដៅចេញក្រៅដើម្បីចំណង់។ លោកអ្នកប្រសិនចង់លើកកម្ពស់ខ្លួនឯង, លោកអ្នកត្រូវតែសំដៅចូលក្នុងដើម្បីរក, ដាក់ជំនាញការនៅលើចិត្តនេះរបស់លោកអ្នក។ លោកអ្នកទើបអាចលើកកម្ពស់ឡើងលើដោយពិតប្រាកដ, ក្នុងពេលអង្គុយសមាធិលោកអ្នកទើបអាចស្ងប់ចុះមកបាន, អាចស្ងប់ចុះមកបានជាក់ស្តែងគឺជាគង់, កម្លាំងរម្ងាប់ជ្រៅប៉ុណ្ណាគឺជាបង្ហាញរបស់ជាន់ថ្នាក់។

មនុស្សសាមញ្ញតាមអំពើចិត្តអាចស្ងប់ចុះបានឬ? ជាមូលដ្ឋានគឺស្ងប់ចុះមិនបាន, លើកលែងតែមនុស្សដែលនិស្ស័យដ៏ល្អ។ ក៏មានន័យ

ថា, មូលហេតុមូលដ្ឋានដែលមនុស្សស្ងប់ចុះមិនបាន, មិនមែនបញ្ហានៅលើបច្ចេកទេសអ្វី, មិនមែនដោយមានជំនាញពិសេសអ្វី, តែគឺមនោគតិរបស់លោកអ្នក, ចិត្តរបស់លោកអ្នកមិនស្ងប់។ លោកអ្នកនៅក្នុងសង្គមមនុស្សសាមញ្ញ, ទំនាស់រវាងមនុស្សនិងមនុស្ស, ដើម្បីផលប្រយោជន៍ឯកជន, ស្នេហា៧តណ្ហា៦, ប្រកាន់និងតណ្ហាគ្រប់ប្រភេទ, លោកអ្នកទៅប្រជែងទៅប្រយុទ្ធជាមួយអ្នកដទៃ, របស់ទាំងនេះលោកអ្នកសុទ្ធតែដាក់ចុះមិនបាន, មិនអាចមើលវាឱ្យស្រាល, លោកអ្នកគឺចង់ស្ងប់ចុះមកបាន, និយាយងាយស្រួលពេកហើយ? មានមនុស្សនៅទីនោះហាត់គង់និយាយថា៖ "ខ្ញុំគឺមិនជឿ, ខ្ញុំត្រូវតែស្ងប់ចុះមកបាន, មិនអាចគិតរញ៉េរញ៉ៃ"។ ទើបតែនិយាយចប់, ម្តងទៀតប្រែក្រឡាប់មកវិញ, គឺចិត្តនោះរបស់លោកអ្នកមិនស្ងប់, ដូច្នេះលោកអ្នកគឺស្ងប់ចុះមិនបាន។

មនុស្សខ្លះអាចមិនយល់ព្រមនឹងទស្សនៈរបស់ខ្ញុំ៖ "គ្រូឈីគង់ខ្លះមិនមែនបង្រៀនគេជ្រើសប្រើបច្ចេកទេសអ្វីឬ? អាចដាក់ចិត្តផ្តោតលើអ្វីមួយ, នឹកគិតក្នុងចិត្ត, ចិត្តដាក់នៅតានធាន, មើលចូលក្នុងតានធាន ឬក៏ជាសូត្រពុទ្ធនាម។ល។ នេះជាប្រភេទវិធីសាស្ត្រមួយ, ប៉ុន្តែវាមិនគ្រាន់តែជាវិធីសាស្ត្រមួយប៉ុណ្ណោះ, វាជាប្រភេទបង្ហាញមួយរបស់ជំនាញការ។ ដូច្នោះជំនាញការគឺជាមានទំនាក់ទំនងដោយផ្ទាល់នឹងចិត្តចរិតដែលពួកយើងបួសហាត់, នឹងជាន់ថ្នាក់ដែលពួកយើងលើកកម្ពស់, គាត់ក៏មិនមែនជ្រើសប្រើឯកទេសតែមួយគត់វិធីសាស្ត្រនេះគឺអាចស្ងប់ចុះមកបាន។ មិនជឿលោកអ្នកសាកមើល, តណ្ហាគ្រប់ប្រភេទរបស់លោកអ្នក, ចិត្តប្រកាន់សែនខ្លាំងក្លា, អ្វីក៏ដាក់ចុះមិនបាន, លោកអ្នកមើលលោកអ្នកអាចស្ងប់ចុះបានឬអត់។ មានមនុស្សសម្តែងសូត្រពុទ្ធនាមធ្វើបានល្អ, សូត្រពុទ្ធនាមលោកអ្នកអាចសម្រេចបានចូលក្នុងស្ងប់ឬ? មានមនុស្ស

សម្ដែង៖ ធម្មក្ខន្ធរបស់ព្រះពុទ្ធអាមីធួរងាយស្រួលហាត់, សូត្រពុទ្ធនាមគឺបាន។ លោកអ្នកសូត្រៗសាកមើល? ខ្ញុំនិយាយថានោះជាជំនាញការ, លោកអ្នកនិយាយងាយស្រួល, ខ្ញុំនិយាយមិនងាយស្រួល, ធម្មក្ខន្ធមួយណាក៏មិនងាយស្រួល។

អ្នករាល់គ្នាបានដឹងសក្យមុនីសម្ដែង [សមាធិ], សួរថាមុនពេល [សមាធិ] គាត់សម្ដែងអ្វី? គាត់សម្ដែង [សីល], យកតណ្ហាទាំងអស់, ការញៀនទាំងមូលបោះបង់ចោល, អ្វីក៏គ្មាន, ទើបអាចរម្ងាប់ចុះមកបាន។ តើមិនមែនគោលសីលធម៌នេះ? ហើយ [សមាធិ] ក៏ជាជំនាញការ, លោកអ្នកភ្លាមៗក៏សម្រេចមិនបានកម្រិតហាមឃាត់ទាំងស្រុង, សន្សឹមៗស្របតាមពេលដែលរបស់មិនល្អទាំងអស់ត្រូវបានហាមឃាត់, កម្លាំងរម្ងាប់ក៏នឹងពីរាក់ចូលក្នុងជ្រៅ។ មនុស្សដែលសូត្រពុទ្ធនាមត្រូវការសូត្រចិត្តមួយមិនចលាចល, ក្នុងចិត្តអ្វីក៏មិនគិត, សូត្រដល់ថ្នាក់ផ្នែកផ្សេងៗនៃខួរធំសុទ្ធតែស្ពឹកអស់, អ្វីក៏មិនដឹង, គំនិតមួយតំណាងម៉ឺនគំនិត, [អាមីធួរភ្ជួ] មួយអក្សរៗសុទ្ធតែលាតត្រដាងនៅចំពោះមុខ។ តើនេះមិនមែនជំនាញការឬ? ទើបចាប់ផ្ដើមគឺអាចសម្រេចបានចំណុចមួយនេះឬ? សម្រេចមិនបាន, សម្រេចមិនបានគឺបញ្ជាក់ថាមិនអាចចូលក្នុងស្ងប់, មិនជឿគឺសាកមើល។ ក្នុងមាត់នៅទីនោះសូត្រមួយដងទៅមួយដង, ក្នុងចិត្តអ្វីក៏គិត៖ ថ្នាក់ដឹកនាំអង្គភាពពួកយើងហេតុម្ដេចមើលមិនឃើញខ្ញុំយ៉ាងនេះ, ប្រាក់រង្វាន់ខែនេះឲ្យខ្ញុំតិចយ៉ាងនេះ។ កាន់តែគិតកាន់តែខឹង, ខឹងដល់ថ្នាក់ទ្រាំមិនបាន, មាត់នៅតែកំពុងសូត្រពុទ្ធនាម, លោកអ្នកនិយាយអាចហាត់គង់ឬ? នេះមិនមែនបញ្ហាជំនាញការឬ? នេះមិនមែនបញ្ហាចិត្តលោកអ្នកខ្លួនឯងមិនស្ងាត់ឬ? មនុស្សខ្លះភ្នែកទិព្វបើក, អាចមើលចូលក្នុងតានធាន។ ដោយសារតានប្រមូលផ្ដុំនៅទីតាំងពោះក្រោមរបស់មនុស្ស, សារ

ធាតុថាមពលនោះកាន់តែបរិសុទ្ធគឺកាន់តែភ្លឺ, កាន់តែមិនបរិសុទ្ធកាន់តែងងឹត, កាន់តែខ្មៅ។ មើលចូលក្នុងតានធានមើលឃើញតាននោះអាចចូលក្នុងស្ងប់បានឬ? ចូលក្នុងស្ងប់មិនបាន, មិននៅវិធីសាស្រ្តខ្លួនវា, គន្លឹះគឺមនោគតិ, គំនិតរបស់មនុស្សមិនស្ងប់ស្ងាត់។ លោកអ្នកមើលចូលក្នុងតានធាន, មើលឃើញតាននោះភ្លឺថ្លាយង់ស្អាតណាស់, មួយភ្លែតតាននេះគឺផ្លាស់ប្រែ, គឺប្រែក្លាយទៅជាផ្ទះ។ [បន្ទប់នេះកូនប្រុសយើងរៀបការហើយប្រើ, បន្ទប់នេះកូនស្រីយើងស្នាក់នៅ, ពីរនាក់ប្តីប្រពន្ធយើងស្នាក់នៅបន្ទប់នេះ, ចំកណ្តាលគឺបន្ទប់ទទួលភ្ញៀវ, ល្អណាស់! ផ្ទះនេះអាចផ្តល់ឲ្យយើងបានទេហ្ន៎? យើងត្រូវតែគិតវិធីយកវាមកឲ្យបាន, ធ្វើដូចម្តេចហ្ន៎?] មនុស្សគឺប្រកាន់លើរបស់ទាំងនេះ, លោកអ្នកនិយាយលោកអ្នកអាចស្ងប់ចុះមកឬ? គេនិយាយថា៖ ខ្ញុំដល់សង្គមមនុស្សសាមញ្ញទីនេះ, គឺដូចស្នាក់នៅផ្ទះសំណាក់, ស្នាក់នៅប៉ុន្មានថ្ងៃ, រួចប្រញាប់ចេញទៅ។ មានមនុស្សខ្លះជាក់ស្តែងគឺអាឡោះអាល័យទីនេះ, បានភ្លេចទាំងផ្ទះរបស់ខ្លួនឯង។

បួសហាត់ពិតប្រាកដ, គឺត្រូវតែសំដៅចិត្តដើម្បីបួស, សំដៅចូលក្នុងដើម្បីបួស, សំដៅចូលក្នុងដើម្បីរក, គ្មានសំដៅចេញក្រៅដើម្បីរក។ មានធម្មក្ខន្ធខ្លះសម្តែង, ថាព្រះពុទ្ធនៅក្នុងបេះដូង, ក៏សមហេតុផល។ មានមនុស្សពន្យល់ប្រយោគនេះមិនត្រូវ, និយាយថាព្រះពុទ្ធនៅក្នុងបេះដូង, ហាក់ដូចគាត់ខ្លួនឯងជាក់ស្តែងជាព្រះពុទ្ធរួចហើយ, ហាក់ដូចក្នុងបេះដូងដូចមានព្រះពុទ្ធរួចហើយ។ គាត់ពន្យល់បែបនេះ, នោះមិនមែនខុសហើយឬ? ឯណាអាចពន្យល់បែបនោះ។ អត្ថន័យជាក់ស្តែងគឺលោកអ្នកត្រូវការសំដៅចិត្តដើម្បីបួស, លោកអ្នកទើបអាចបួសសម្រេច, ជាក់ស្តែងជាគោលសីលធម៌នេះ។ លើខ្លួនលោកអ្នកទីណាមានព្រះពុទ្ធ? លោក

អ្នកត្រូវតែទៅបួសទើបអាចបួសសម្រេច។

មូលហេតុដែលលោកអ្នកស្ងប់ចុះមិនបាន, គឺដោយសារមនោគតិរបស់លោកអ្នកមិនមែនជាទទេ, លោកអ្នកមិនទាន់ជាន់ថ្នាក់ខ្ពស់យ៉ាងនោះ, នោះគឺពីរាក់ចូលក្នុងជ្រៅ, នឹងការលើកកម្ពស់ជាន់ថ្នាក់គឺបំពេញគ្នាទៅវិញទៅមក។ លោកអ្នកដាក់ចិត្តប្រកាន់ចុះ, ជាន់ថ្នាក់របស់លោកអ្នកក៏ឡើងលើ, កម្លាំងរម្ងាប់របស់លោកអ្នកក៏ជ្រៅថែម។ លោកអ្នកចង់តាមរយៈបច្ចេកទេសឬក៏វិធីសាស្ត្រអ្វីមួយដើម្បីស្ងប់, ខ្ញុំនិយាយថានោះសុទ្ធតែជាសំដៅចេញក្រៅដើម្បីចំណង់។ ហើយហាត់គង់ដើរខុសស្រឡះ, ដើរឆ្លងផ្លូវទុច្ចរិត, ជាក់ស្តែងគឺចង្អុលមនុស្សសំដៅចេញក្រៅដើម្បីចំណង់។ ជាពិសេសនៅក្នុងពុទ្ធសាសនា, ប្រសិនលោកអ្នកសំដៅចេញក្រៅដើម្បីចំណង់, គាត់គឺនិយាយលោកអ្នកដើរឆ្លងផ្លូវរបស់ខ្មោច។ ហើយបួសហាត់ពិតប្រាកដត្រូវការបួសហាត់ចិត្តនោះ, មានតែពេលដែលលោកអ្នកលើកកម្ពស់ចិត្តចរិត, ចិត្តលោកអ្នកទើបអាចសម្រេចបានស្ងប់ស្ងាត់, សភាពគ្មានបំណង; មានតែពេលដែលលោកអ្នកលើកកម្ពស់ចិត្តចរិត, ទើបអាចសមកាលកម្មនឹងចរិតពិសេសនៃចក្រវាលពួកយើង, កម្ចាត់ចោលតណ្ហាគ្រប់ប្រភេទ, ចិត្តប្រកាន់, របស់មិនល្អនៃមនុស្ស, លោកអ្នកទើបអាចយករបស់មិនល្អនៃខ្លួនឯងចាក់ចេញបាន, លោកអ្នកទើបអាចអណ្តែតឡើងមកបាន។ មិនរងការរឹតត្បិតរបស់ចរិតពិសេសនៃចក្រវាលទៀត, សារធាតុគុណធម៌នេះរបស់លោកអ្នកទើបអាចបំប្លែងក្លាយជាគង់, នោះមិនមែនបំពេញគ្នាទៅវិញទៅមកឬ? ជាក់ស្តែងជាគោលសីលធម៌យ៉ាងនេះ!

នេះគឺលើអញ្ញវត្ថុមិនអាចធ្វើឲ្យខ្លួនឯងសម្រេចបានតម្រូវបរមាណ៊ីយសរបស់មនុស្សហាត់គង់, បានបង្កជាមូលហេតុស្ងប់ចុះមកមិនបាន។

បច្ចុប្បន្នលើយថាវត្ថុក៏ស្ថិតនៅប្រភេទកាលៈទេសៈមួយបែបនេះ, ជ្រៀតជ្រែកធ្ងន់ធ្ងរលោកអ្នកមិនអាចបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, កំពុងឥទ្ធិពលធ្ងន់ធ្ងរដល់មនុស្សហាត់គង់។ អ្នករាល់គ្នាបានដឹង, ស្របតាមកំណែទម្រង់បើកចំហ, ជំរុញសេដ្ឋកិច្ច, គោលនយោបាយក៏បើកទូលាយ។ មានបច្ចេកវិទ្យាថ្មីជាច្រើនបាននាំចូល, កម្រិតជីវភាពរបស់មនុស្សក៏កំពុងប្រសើរឡើង, ក្នុងមនុស្សសាមញ្ញនរណាក៏សន្មតថាគឺជារឿងល្អ។ ប៉ុន្តែត្រូវសង្កេតមើលទាំងពីរមុខ, តាមវិចារវិទ្យាដើម្បីមើល, របស់មិនល្អក៏ស្របតាមកំណែទម្រង់បើកចំហចូលមកផងដែរ, គ្រប់មុខគ្រប់ប្រភេទ។ ខាងក្នុងស្នាដៃសិល្បៈប្រសិនមិនសរសេរអ្វីបន្តិចអំពីកាមគុណ, ហាក់ដូចជាសៀវភៅនេះក៏លក់មិនដាច់សោះ, ដោយសារសម្ដែងបញ្ហាបរិមាណលក់; ក្នុងភាពយន្តទូរទស្សន៍ប្រសិនគ្មានបន្តិចឈុតនៅលើគ្រែ, ហាក់ដូចភាពយន្តទូរទស្សន៍ក៏គ្មានមនុស្សមើល, សម្ដែងអំពីបញ្ហាអត្រាទស្សនិកជន; ខាងក្នុងវិចិត្រសិល្បៈ, នរណាដឹងគឺជាសិល្បៈពិតឬក៏ធ្វើអ្វីមួយ, ក្នុងសិល្បៈជាតិបុរាណប្រទេសចិនពួកយើងគ្មានរបស់ទាំងនេះ។ ហើយប្រពៃណីនេះនៃជនជាតិចិនពួកយើងមិនមែនជានរណាប្រឌិត, នរណាផលិតចេញមក។ ពេលខ្ញុំសម្ដែងអរិយធម៌បុរេប្រវត្តិបាននិយាយដល់, របស់ទាំងអស់សុទ្ធតែមានដើមហេតុរបស់វា។ បរមាណើយសីលធម៌មនុស្សជាតិសុទ្ធតែរមួលបត់អស់ហើយ, កើតឡើងការផ្លាស់ប្រែរួចហើយ, បរមាណើយវាស់វែងល្អនិងអាក្រក់សុទ្ធតែបានកើតឡើងការផ្លាស់ប្រែ, នោះគឺរឿងរ៉ាវក្នុងមនុស្សសាមញ្ញ។ បរមាណើយនៃចរិតពិសេសចក្រវាលនេះសច្ចៈ, ករុណា, ខន្តី, គឺជាបរមាណើយតែមួយគត់វាស់វែងមនុស្សល្អនិងអាក្រក់, គាត់គឺមិនប្ដូរ។ ធ្វើជាមនុស្សហាត់គង់ម្នាក់, លោកអ្នកបើសិនចង់លោតចេញមក, លោកអ្នកគឺត្រូវតែប្រើបរមាណើយ

នេះដើម្បីរាស់វែង, លោកអ្នកមិនអាចប្រើបរមាណីយមនុស្សសាមញ្ញមកវាស់វែង, ដូច្នេះលើយថាវត្ថុក៏ស្ថិតនៅជ្រៀតជ្រែកមួយបែបនេះ។ ក៏មិនត្រឹមតែទាំងនេះ, អ្វីស្រឡាញ់ភេទដូចគ្នា, សេរីភាពផ្លូវភេទ, ប្រើប្រាស់គ្រឿងញៀនរញ៉េរញ៉ៃគ្រប់មុខសុទ្ធតែលេចឡើងមក។

សង្គមមនុស្សជាតិអភិវឌ្ឍមកដល់ជំហានមួយនេះសព្វថ្ងៃ, អ្នករាល់គ្នាគិតសាកមើល, អភិវឌ្ឍបន្តទៀតគឺជាបែបណា? អាចទុកឱ្យវាស្ថិតនៅបន្តជានិច្ចបែបនេះឬ? មនុស្សមិនព្យាបាលមេឃព្យាបាល។ ពេលដែលមនុស្សជាតិកើតឡើងគ្រោះកប្ប, សុទ្ធតែស្ថិតក្នុងនៅស្ថានភាពមួយបែបនេះ។ ក្នុងមេរៀនច្រើនយ៉ាងនេះ, ខ្ញុំក៏មិនទាន់និយាយដល់បញ្ហាគ្រោះកប្បធំរបស់មនុស្សជាតិ។ សាសនាក៏កំពុងសម្តែង, មនុស្សដ៏ច្រើនក៏កំពុងសម្តែងអំពីប្រធានបទក្តៅនេះ។ ខ្ញុំនិយាយឲ្យអ្នករាល់គ្នាបញ្ហាបែបនេះ, អ្នករាល់គ្នាគិតសាកមើល, នៅក្នុងសង្គមមនុស្សសាមញ្ញពួកយើង, កម្រិតសីលធម៌មនុស្សបានកើតឡើងការផ្លាស់ប្រែបែបនេះ! កម្រិតតឹងតែងរវាងមនុស្សនិងមនុស្សបានដល់កម្រិតនេះរួចហើយ! លោកអ្នកគិតវាមិនមែនបានឡើងដល់មកស្ថានភាពមួយយ៉ាងគ្រោះថ្នាក់បំផុត? ដូច្នេះបច្ចុប្បន្នបរិយាកាសដែលស្ថិតនៅជាយថាវត្ថុនេះ, ក៏កំពុងជ្រៀតជ្រែកធ្ងន់ធ្ងរមនុស្សហាត់គង់ពួកយើងបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់។ រូបអាក្រាតកាយគឺដាក់តាំងទីនោះ, ព្យួរកណ្តាលផ្លូវធំ, ងើបឡើងកាលណាគឺមើលឃើញ។

ឡៅជឺធ្លាប់សម្តែងប្រយោគមួយបែបនេះ៖ វត្ថុលំដាប់លើស្តាប់តាវ, ឧស្សាហ៍បដិបត្តិដល់ចប់។ វត្តុលំដាប់លើស្តាប់តាវ, មិនងាយស្រួលអ្វីទទួលបានសុចរិតធម៌, ថ្ងៃនេះមិនបួសរង់ចាំដល់ពេលណា? បរិយាកាសស្មុគស្មាញ, ផ្ទុយមកវិញខ្ញុំគិតថាជារឿងល្អ, កាន់តែស្មុគស្មាញ,

ទើបអាចផុសចេញអធិជន, ប្រសិនពីទីនេះលោតចេញបាន, នោះទើបប្ញូសបានរឹងមាំបំផុត។

ធ្វើជាមនុស្សម្នាក់ពិតប្រាកដអាចប្ដេជ្ញាចិត្តប្ញូសហាត់, ផ្ទុយមកវិញខ្ញុំនិយាយថាជារឿងល្អ។ គ្មានទំនាស់សាងបង្កើត, គ្មានផលិតឱកាសឲ្យលោកអ្នកលើកកម្ពស់ចិត្តចរិត, លោកអ្នកក៏ឡើងទៅមិនបាន។ លោកអ្នកល្អខ្ញុំក៏ល្អ, ធ្វើម្ដេចដើម្បីប្ញូសហាត់? ធ្វើជាមនុស្សប្ញូសហាត់ធម្មតា, ស្ថិតក្នុង [វត្ថីលំដាប់កណ្ដាលស្ដាប់តាវ], ហាត់ក៏បាន, មិនហាត់ក៏បាន, មនុស្សបែបនេះអាចនឹងមិនសម្រេច។ មនុស្សខ្លះនៅទីនេះស្ដាប់លោកគ្រូសម្ដែង{ឃើញ}សមហេតុផល, ត្រឡប់ដល់ក្នុងសង្គមមនុស្សសាមញ្ញ, នៅតែជាផលប្រយោជន៍តថភាពទាំងនេះប្រាកដជាក់ស្ដែង។ គឺប្រាកដជាក់ស្ដែង, កុំនិយាយលោកអ្នក, លោកខាងលិចមានអ្នកមហាសេដ្ឋី, អ្នកមហាទ្រព្យមានអំណាចជាច្រើនដល់ពេលអាយុ១០០, គាត់រកឃើញថាអ្វីសុទ្ធតែគ្មាន, សម្ភារៈសម្បត្តិកើតនាំមកមិនបាន, ស្លាប់នាំទៅមិនបាន, ពិតជាទទេសូន្យ។ តែហេតុអ្វីគង់ដ៏មានតម្លៃយ៉ាងនេះ? ដោយសារ{វា}ដោយផ្ទាល់នាំតាមនៅលើខ្លួនវិញ្ញាណដើមរបស់លោកអ្នក, កើតនាំមកតាម, ស្លាប់នាំទៅតាម។ យើងខ្ញុំសម្ដែងវិញ្ញាណដើមអមតៈ, នេះក៏មិនមែនអបិយជំនឿអ្វី។ រាងកាយសារធាតុនេះរបស់ពួកយើងក្រោយពីកោសិកាធ្លាក់ចេញ, ហើយផ្ទុយមកវិញសមាសភាគម៉ូលេគុលតូចជាងស្ថិតនៅក្នុងអវកាសសារធាតុផ្សេងគ្មានបំផ្លាញបាត់, វាហួសពេកគ្រាន់តែបានធ្លាក់ពីសំបក។

ដែលខ្ញុំទើបសម្ដែងសុទ្ធតែជាស្ថិតក្នុងបញ្ហាលើចិត្តចរិតរបស់មនុស្ស។ សក្យមុនីធ្លាប់សម្ដែងពាក្យបែបនេះ, តាហ៍ម៉ូរក៏ធ្លាប់សម្ដែង៖ "កន្លែងនេះដីចិនបូព៌ាជាកន្លែងផុសចេញវត្ថីមហាគុណធម៌។" ប្រទេស

ចិនពួកយើងសម័យប្រវត្តិសាស្ត្រមានព្រះសង្ឃជាច្រើន, មានជនជាតិចិនជាច្រើនមោទនភាពណាស់។ បង្កប់ន័យនោះសន្មតថាអាចបួសឡើងគង់ខ្ពស់, ដូច្នេះមានមនុស្សជាច្រើនត្រេកអរ, ពេញចិត្តខ្លួនឯងអប្បមាណ៖ "នៅតែជាជនជាតិចិនពួកយើង, ប្រទេសចិនកន្លែងនេះលេចឡើងមនុស្សមហានិស្ស័យ, លេចឡើងវត្តមហាគុណធម៌។" ភាពពិតមនុស្សដ៏ច្រើនមិនយល់ច្បាស់អត្ថន័យក្នុងនោះ, ប្រទេសចិនកន្លែងនេះហេតុអ្វីអាចលេចឡើងវត្តមហាគុណធម៌, ហេតុអ្វីអាចលេចឡើងគង់ខ្ពស់ហ្ន៎? មនុស្សដ៏ច្រើនមិនដឹងអត្ថន័យពិតប្រាកដនៃពាក្យដែលមនុស្សក្នុងជាន់ថ្នាក់ខ្ពស់សម្តែងចេញ, ក៏មិនដឹងកម្រិតភពឋិតនៅរបស់មនុស្សក្នុងជាន់ថ្នាក់ខ្ពស់, កម្រិតភពខ្ពស់, ស្ថានភាពមនោគតិរបស់គាត់។ ប្រាកដណាស់យើងខ្ញុំសម្តែងរួចហើយ, កុំនិយាយវាជាអត្ថន័យអ្វី, អ្នករាល់គ្នាគិតសាកមើល, មានតែចំណោមក្រុមមនុស្សស្មុគស្មាញបំផុត, បរិយាកាសស្មុគស្មាញបំផុតទើបអាចបួសចេញបានគង់ខ្ពស់, គឺបង្កប់ន័យនេះ។

## និស្ស័យ

និស្ស័យគឺបានកំណត់ដោយសារធាតុគុណធម៌ច្រើននិងតិចដែលគេនាំតាមរាងកាយនៅក្នុងអវកាសផ្សេង។ គុណធម៌តិច, សារធាតុពណ៌ខ្មៅច្រើន, គឺវាលអំណាចកម្មធំ, ដូច្នោះនេះគឺស្ថិតក្នុងនិស្ស័យមិនល្អ; គុណធម៌ច្រើន, សារធាតុពណ៌សច្រើន, គឺវាលអំណាចកម្មតូច, ដូច្នោះនេះគឺស្ថិតក្នុងនិស្ស័យល្អ។ សារធាតុពណ៌សនិងសារធាតុពណ៌ខ្មៅប្រភេទសារធាតុទាំងពីរអាចបំប្លែងទៅវិញទៅមក, បំប្លែងដូចម្តេច? ធ្វើរឿងល្អសាងបង្កើតសារធាតុពណ៌ស, សារធាតុពណ៌សជាក់ស្តែងគឺបានរងទុក្ខ, បានទទួលរងទុក្ខឈឺចាប់, ធ្វើរឿងល្អរួចហើយទទួលបាន។

ហើយសារធាតុពណ៌ខ្មៅជាក់ស្ដែងគឺធ្វើរឿងអាក្រក់, ធ្វើរឿងរ៉ាវមិនល្អ ហើយសាងបង្កើត, វាគឺជាអំណាចកម្ម។ វាមានដំណើរការបំប្លែងមួយបែបនេះ, ក្នុងពេលដំណាលគ្នា, វានៅមានទំនាក់ទំនងយកតាម។ ដោយសារវាដើរតាមវិញ្ញាណដើមដោយផ្ទាល់, មិនមែនរបស់ក្នុងមួយជីវិតមួយជាតិ, គឺជាក្នុងយុគ្គសម័យដ៏យូរអង្វែងមួយសន្សំមក។ ដូច្នេះ សម្ដែងសន្សំកម្ម, សន្សំគុណធម៌, ថែមទៀតបុព្វជនក៏អាចសន្សំទុកឲ្យជំនាន់ក្រោយ។ មានពេលខ្លះខ្ញុំចងចាំជនជាតិចិនបុរាណឬក៏មនុស្សចាស់និយាយថា៖ បុព្វជនសន្សំគុណធម៌, ឬជាសន្សំគុណធម៌, ខ្វះគុណធម៌, ពាក្យនោះនិយាយពិតជាត្រឹមត្រូវយ៉ាងនោះ, ពិតជាត្រឹមត្រូវខ្លាំងណាស់។

និស្ស័យល្អអាក្រក់អាចកំណត់ចរិតភ្ញាក់ដឹងរបស់មនុស្សម្នាក់ល្អនិងអាក្រក់។ មនុស្សនិស្ស័យមិនល្អអាចធ្វើឲ្យចរិតភ្ញាក់ដឹងរបស់គេក៏ប្រែជាដ៏ទាប។ ហេតុអ្វី? ដោយសារមនុស្សដែលនិស្ស័យល្អសារធាតុពណ៌សច្រើន, ប្រភេទសារធាតុពណ៌សនេះនិងចក្រវាលពួកយើងគឺរលាយសម្រប, និងចរិតពិសេសសច្ចៈ-ករុណា-ខន្តីគឺអាចរលាយសម្របជាមួយគ្នា, គ្មានចន្លោះ។ ចរិតពិសេសនៃចក្រវាលដោយផ្ទាល់គឺឆ្លុះបញ្ចាំងចេញមកនៅលើរាងកាយលោកអ្នក, ទាក់ទងដោយផ្ទាល់នឹងរាងកាយលោកអ្នក។ ហើយប្រភេទសារធាតុពណ៌ខ្មៅនេះផ្ទុយស្រឡះ, គឺបានធ្វើរឿងរ៉ាវមិនល្អទទួលបាន, គឺងាកចេញពីគ្នានឹងចរិតពិសេសនៃចក្រវាលពួកយើង, ដូច្នេះគឺសាងបង្កើតការគម្លាតមួយរវាងសារធាតុពណ៌ខ្មៅនេះនិងចរិតពិសេសនៃចក្រវាលពួកយើង។ ប្រសិនពេលដែលសារធាតុពណ៌ខ្មៅនេះច្រើនឡើង, វានឹងបង្កើតជាវាលមួយនៅជុំវិញរាងកាយមនុស្ស, ឡោមព័ទ្ធមនុស្សមកវិញ។ ហើយវាលនេះកាន់តែធំដង់ស៊ីតេរបស់វា

កាន់តែធំ, កាន់តែក្រាស់, គឺធ្វើឲ្យចរិតភ្ញាក់ដឹងរបស់ឯកជននេះកាន់តែមិនល្អ។ ដោយសារគាត់មិនអាចទទួលយកប្រភេទចរិតពិសេសសច្ចៈ, ករុណា, ខន្តីនៃចក្រវាល, ក៏ដោយសារគាត់បានធ្វើរឿងរ៉ាវមិនល្អទើបសាងបង្កើតសារធាតុពណ៌ខ្មៅ។ ជាញឹកញាប់មនុស្សបែបនេះគឺកាន់តែមិនជឿបួសហាត់, ចរិតភ្ញាក់ដឹងកាន់តែមិនល្អ, កាន់តែរងការរារាំងនៃអំណាចកម្ម; រងទុក្ខកាន់តែធំ, គឺកាន់តែមិនជឿ, បួសហាត់ក៏ជាលំបាក។

មនុស្សសារធាតុពណ៌សច្រើនបួសហាត់ងាយស្រួល, ដោយសារនៅក្នុងដំណើរការគាត់បួសហាត់, ដរាបណាគាត់សមកាលកម្មនឹងចរិតពិសេសនៃចក្រវាល, ចិត្តចរិតរបស់គាត់អាចលើកកម្ពស់ឡើងបាន, គុណធម៌នេះរបស់គាត់គឺបំប្លែងដោយផ្ទាល់ក្លាយជាគង់។ ហើយមនុស្សដែលសារធាតុពណ៌ខ្មៅច្រើន, គឺស្រដៀងផលិតផលិតផលក្នុងរោងចក្រ, ថែមនីតិវិធីមួយទៀត, គេមកសុទ្ធតែជាវត្ថុធាតុត្រៀមរួចជាស្រេច, គាត់មកគឺជាវត្ថុធាតុដើម, ត្រូវតែកែច្នៃថែមមួយសាទៀត, ត្រូវតែឆ្លងកាត់ដំណើរការមួយយ៉ាងនេះ។ ដូច្នេះគាត់ត្រូវការរងទុក្ខជាមុន, ដើម្បីរំលាយចុះអំណាចកម្មរបស់គាត់, បំប្លែងទៅជាសារធាតុពណ៌ស, បង្កើតជាសារធាតុគុណធម៌រួចហើយ, គាត់ទើបអាចបង្កើនគង់ខ្ពស់។ ប៉ុន្តែជាញឹកញាប់មនុស្សប្រភេទនេះខ្លួនឯងគឺចរិតភ្ញាក់ដឹងមិនល្អ, លោកអ្នកហៅគាត់រងទុក្ខថែមទៀត, គាត់គឺកាន់តែមិនជឿ, កាន់តែទ្រាំមិនបាន, ដូច្នេះមនុស្សដែលសារធាតុពណ៌ខ្មៅច្រើនមិនងាយបួសហាត់។ អតីតកាលតាវង្សឬក៏ធម្មក្ខន្ធដែលបង្រៀនឯកតាសម្ដែងថាលោកគ្រូរកកូនសិស្ស, មិនមែនកូនសិស្សរកលោកគ្រូ, ក៏ជាសង្កេតមើលរបស់ទាំងនេះដែលរាងកាយគាត់នាំតាមច្រើនឬតិចដើម្បីសម្រេចចិត្ត។

និស្ស័យកំណត់ចរិតភ្ញាក់ដឹងរបស់មនុស្ស, តែក៏មិនមែនដាច់ខាត។

មនុស្សខ្លះនិស្ស័យដ៏មិនល្អ, ប៉ុន្តែបរិយាកាសគ្រួសារដ៏ល្អ, មនុស្សដ៏ច្រើនសុទ្ធតែហាត់គង់, ក៏មានមនុស្សមួយចំនួនជាឧបាសកក្នុងសាសនា, ជឿលើរឿងបួសហាត់ណាស់។ នៅក្នុងបរិយាកាសនេះ, ក៏អាចជំរុញឲ្យគាត់ប្រែជាជឿ, ចរិតភ្ញាក់ដឹងប្រែជាល្អ, ដូច្នេះក៏មិនមែនដាច់ខាត។ ក៏មានមនុស្សខ្លះនិស្ស័យដ៏ល្អ, ប៉ុន្តែជាញឹកញាប់ទទួលការអប់រំចំណេះដឹងតិចតួចនោះកំពុងមាននៃសង្គមតថភាពរបស់ពួកយើង, ជាពិសេសគឺវិធីសាស្ត្រអប់រំមនោគមវិជ្ជាដាច់ខាតប៉ុន្មានឆ្នាំមុន, បានធ្វើឱ្យមនោគតិរបស់មនុស្សប្រែជាសែនចង្អៀត, របស់ទាំងអស់ដែលលើសផុតពីទិដ្ឋភាពដែលគាត់ដឹងគាត់ទាំងស្រុងសុទ្ធតែមិនជឿ, ក៏អាចបណ្ដាលឲ្យចរិតភ្ញាក់ដឹងរបស់គាត់ទទួលរងជ្រៀតជ្រែកធ្ងន់ធ្ងរ។

លើកឧទាហរណ៍, នៅពេលខ្ញុំបើកថ្នាក់បង្រៀន, ថ្ងៃទី២សម្ដែងបើកភ្នែកទិព្វ។ មានមនុស្សម្នាក់និស្ស័យល្អ, ភ្លាមៗគឺបើកភ្នែកទិព្វឲ្យគាត់ដល់ជាន់ថ្នាក់ដ៏ខ្ពស់, គាត់បានមើលឃើញទស្សនីយភាពដ៏ច្រើនដែលអ្នកដទៃមើលមិនឃើញ។ គាត់និយាយជាមួយគេ៖ អ៊ំាយយ៉ា, ខ្ញុំមើលឃើញលើវាលបង្រៀនធម៌ទាំងមូលហ្វាលូនដូចជាផ្កាព្រិលធ្លាក់នៅលើរាងកាយមនុស្ស; ខ្ញុំមើលឃើញរាងកាយពិតរបស់លោកគ្រូលីគឺជាបែបណា; ខ្ញុំមើលឃើញរង់រស្មីរបស់លោកគ្រូលី, មើលឃើញហ្វាលូនគឺជាបែបណា, បរមីមានប៉ុន្មាន។ មើលឃើញជាន់ថ្នាក់ខុសគ្នាសុទ្ធតែមានលោកគ្រូលីកំពុងសម្ដែងធម៌, ហ្វាលូនកែសម្រួលរាងកាយឲ្យសិក្ខាកាមដូចម្ដេច។ នៅមើលឃើញពេលដែលលោកគ្រូសម្ដែងមេរៀន, ជាន់នីមួយៗ, ជាន់ថ្នាក់ខុសគ្នាសុទ្ធតែជារាងកាយគង់របស់លោកគ្រូកំពុងសម្ដែង, លើសពីនេះនៅមើលឃើញទេពអប្សរបាចផ្កា។ល។ ប្រការស្អាតអស្ចារ្យយ៉ាងនេះគាត់សុទ្ធតែបានមើលឃើញ, និយាយច្បាស់ថានិស្ស័យ

ឯកជននេះដ៏ល្អ។ គាត់និយាយមកនិយាយទៅ, ចុងក្រោយបាននិយាយប្រយោគមួយៈ ខ្ញុំមិនជឿប្រការទាំងនេះ។ មានប្រការមួយចំនួនត្រូវបានវិទ្យាសាស្ត្រកំពុងមានបញ្ជាក់រួចហើយ, មានប្រការជាច្រើនក៏អាចទទួលបានការបកស្រាយពីក្នុងវិទ្យាសាស្ត្រកំពុងមាន, មានប្រការមួយចំនួនពួកយើងក៏សុទ្ធតែពិភាក្សារួចហើយ។ ដោយសារប្រការដែលឈីគង់យល់ដឹងមែនទែនលើសផុតពីការយល់ដឹងរបស់វិទ្យាសាស្ត្រទំនើប, នេះគឺបញ្ជាក់។ បែបនេះមើលមកនិស្ស័យក៏មិនរឹតត្បិតលើចរិតភ្ជាក់ដឹងទាំងស្រុង។

## ភ្ជាក់ដឹង

[ភ្ជាក់ដឹង] ជាអ្វី? នាមសព្ទ [ភ្ជាក់ដឹង] ប្រភពមកពីក្នុងសាសនា។ ក្នុងពុទ្ធសាសនាគឺសំដៅលើការបកស្រាយរបស់មនុស្សបួសហាត់ចំពោះពុទ្ធធម៌, ភ្ជាក់ដឹងលើការយល់ដឹងនិងភ្ជាក់ដឹងចុងបញ្ចប់, គឺបង្កប់ន័យសំដៅលើភ្ជាក់ដឹងខាងបញ្ញា។ ប៉ុន្តែបច្ចុប្បន្នបានអនុវត្តមកដល់ក្នុងមនុស្សសាមញ្ញ, និយាយថាឯកជននេះឆ្លាតវៃណាស់, ដឹងបានក្នុងចិត្តថ្នាក់ដឹកនាំគិតជាអ្វី, ជាបន្ទាន់គឺអាចចាប់យកបាន, នៅពីមុខថ្នាក់ដឹកនាំចេះផ្គាប់ចិត្តមនុស្សណាស់។ គេសម្តែងថានេះគឺចរិតភ្ជាក់ដឹងល្អ, ជាញឹកញាប់សុទ្ធតែទៅបកស្រាយបែបនេះ។ ប៉ុន្តែលោកអ្នកលោតចេញពីជាន់ថ្នាក់របស់មនុស្សសាមញ្ញ, នៅក្នុងជាន់ថ្នាក់ខ្ពស់ជាងបន្តិច, លោកអ្នកគឺនឹងរកឃើញថា, គោលសីលធម៌ជាន់នេះដែលមនុស្សសាមញ្ញយល់ដឹង, ជាញឹកញាប់សុទ្ធតែជាខុស។ ភ្ជាក់ដឹងដែលយើងខ្ញុំនិយាយដល់ជាមូលដ្ឋានមិនមែនភ្ជាក់ដឹងនេះ។ ចរិតភ្ជាក់ដឹងរបស់មនុស្សឆ្លាតល្បិចម្នាក់ផ្ទុយមកវិញមិនល្អ, ដោយសារមនុស្សឆ្លាតវៃពេកគាត់នឹងធ្វើការងារនៅលើផ្ទៃ, ទទួលបានការលើកសរសើររបស់ថ្នាក់ដឹកនាំ, ថ្នាក់លើ។ នោះ

ការងារពិតប្រាកដមិនត្រូវទុកឲ្យអ្នកដទៃទៅធ្វើឬ? ដូច្នោះគាត់គឺបានជំពាក់ប្រការរបស់អ្នកដទៃរួចហើយ; ដោយសារគាត់រ៉េ, គាត់ចេះផ្គាប់ចិត្តមនុស្ស, គាត់អាចទទួលបានរបស់ល្អច្រើន, អ្នកដទៃគឺនឹងទទួលបានរបស់អាក្រក់ច្រើន; ដោយសារគាត់រ៉េ, គាត់ក៏មិនអាចរងបង់ខាត, គាត់ក៏មិនងាយស្រួលរងបង់ខាត, នោះអ្នកដទៃគឺត្រូវតែទៅរងបង់ខាត។ គាត់មួយថ្ងៃកាន់តែមើលធ្ងន់ផលប្រយោជន៍តថភាពបន្តិចនេះ, ដូច្នោះចិត្តទ្រូងរបស់គាត់ក៏ជាមួយថ្ងៃកាន់តែតូចចង្អៀត, គាត់កាន់តែមានអារម្មណ៍ថាផលប្រយោជន៍សម្ភារៈរបស់មនុស្សសាមញ្ញទើបជារបស់ដែលមិនឃ្លាតពីដៃបាន, គាត់ក៏ជាសន្មតថាខ្លួនគាត់គឺយកចិត្តទុកដាក់តថភាព, គាត់មិនទទួលរងបង់ខាត។

មានមនុស្សនៅតែស្ញើចសរសើរ! ខ្ញុំប្រាប់លោកអ្នក, កុំស្ញើចសរសើរគាត់។ លោកអ្នកសុទ្ធតែមិនដឹងថាគាត់រស់ហត់យ៉ាងណា, គាត់បាយមិនឆ្ងាញ់, ដេកមិនលក់, យល់សប្តិក៏ភ័យខ្លាចផលប្រយោជន៍របស់គាត់ទទួលរងខូចខាត។ ចំពោះផលប្រយោជន៍ឯកជន, គាត់ខ្វងឆ្លោះចូលចុងស្នែងគោ, លោកអ្នកនិយាយមើលតើគាត់រស់ហត់ឬអត់, មួយជីវិតរបស់គាត់គឺរស់ដើម្បីប្រការនេះ។ យើងខ្ញុំនិយាយនៅពីមុខទំនាស់, ថយមួយជំហានមេឃខ្ពស់សមុទ្រទូលាយ, ធានាគឺទស្សនីយភាពមួយផ្សេង។ ហើយមនុស្សប្រភេទគាត់នេះគឺមិនព្រមថយ, គាត់រស់ហត់នឿយបំផុត, តែលោកអ្នកកុំរៀនតាមគាត់។ នៅពិភពបួសហាត់សម្ដែងថា៖ ឯកជននេះវង្វេងជ្រៅបំផុត, ព្រោះតែផលប្រយោជន៍សម្ភារៈបានវង្វេងបាត់ទាំងស្រុងនៅក្នុងមនុស្សសាមញ្ញ។ ហៅគាត់រក្សាគុណធម៌, និយាយងាយស្រួលពេកហើយ! លោកអ្នកហៅគាត់ទៅហាត់គង់, គាត់អាចមិនជឿ៖ ហាត់គង់ឬ? ពួកលោកអ្នកហាត់គង់វាយមិនសងដៃ, ជេរមិនតមាត់។ គេ

សម្លុតធ្វើបាបលោកអ្នកយ៉ាងអាក្រក់, ក្នុងចិត្តលោកអ្នកក៏មិនអាចទៅប្រព្រឹត្តដូចគេ, ផ្ទុយមកវិញនៅតែត្រូវអរគុណគេទៀត។ ពួកលោកសុទ្ធតែជាអា-Qអស់ហើយ! ម្នាក់ៗជំងឺវិកលចរិតរួចហើយ! មនុស្សបែបនេះ, គាត់គឺគ្មានវិធីណាបកស្រាយបានឬសហាត់។ គាត់និយាយលោកអ្នកទើបជាមិនអាចយល់បាន, គាត់និយាយលោកអ្នកល្ងង់។ លោកអ្នកនិយាយមើលគាត់មិនមែនពិបាកប្រោសឬ?

ភ្ញាក់ដឹងដែលយើងខ្ញុំនិយាយមិនមែនភ្ញាក់ដឹងនេះ។ គាប់ជួនគាត់និយាយគឺពួកយើងល្ងង់បន្តិចនៅលើផលប្រយោជន៍ឯកជន, ដែលខ្ញុំសម្តែងជាភ្ញាក់ដឹងនេះ។ ប្រាកដណាស់ក៏មិនមែនល្ងង់ពិត, ពួកយើងគ្រាន់តែជានៅលើផលប្រយោជន៍ផ្ទាល់ខ្លួនបញ្ហាទាំងនេះមើលឲ្យស្រាល, ហើយនៅទិដ្ឋភាពផ្សេង, ពួកយើងសុទ្ធតែដ៏ប្រាជ្ញាភ្លឺថ្លា។ គំរោងស្រាវជ្រាវវិទ្យាសាស្ត្រដែលពួកយើងធ្វើ, ថ្នាក់ដឹកនាំផ្តល់ឲ្យភារកិច្ចអ្វី, បំពេញការងារអ្វី, ពួកយើងសុទ្ធតែដ៏ច្បាស់លាស់, ច្បាស់ឥតខ្ចោះធ្វើបានដ៏ល្អ។ ហើយពិតណាស់នៅលើផលប្រយោជន៍ឯកជនបន្តិចនោះរបស់ពួកយើងខ្លួនឯង, នៅក្នុងប៉ះទង្គិចនៃទំនាស់រវាងមនុស្សនិងមនុស្ស, ពួកយើងមើលឱ្យស្រាល។ នរណានឹងនិយាយលោកអ្នកល្ងង់? នរណាក៏នឹងមិននិយាយលោកអ្នកល្ងង់, ធានាគឺជាបែបនេះ។

ពួកយើងចូរនិយាយអំពីអ្នកល្ងង់ដែលល្ងង់ពិតនេះ, គោលសីលធម៌នេះនៅលើជាន់ថ្នាក់ខ្ពស់ទាំងមូលសុទ្ធតែផ្ទុយមកវិញ។ អ្នកល្ងង់នៅក្នុងមនុស្សសាមញ្ញមិនអាចធ្វើរឿងអាក្រក់ធំ, មិនអាចដើម្បីផលប្រយោជន៍ឯកជនទៅប្រជែងទៅប្រយុទ្ធ, មិនចំណង់កិត្តិនាម, គាត់នឹងមិនខាតគុណធម៌។ តែផ្ទុយមកវិញអ្នកដទៃនឹងផ្តល់គុណធម៌ឲ្យគាត់, វាយគាត់, ជេរគាត់, សុទ្ធតែផ្តល់គុណធម៌ឱ្យគាត់, ហើយប្រភេទសារធាតុនេះគឺ

យ៉ាងដ៏មានតម្លៃបំផុត។ ក្នុងចក្រវាលនេះរបស់ពួកយើងជាក់ស្ដែងគឺមានគោលសីលធម៌នេះ៖ មិនបាត់គឺមិនបាន, បានគឺត្រូវការបាត់។ គេមើលអ្នកមហាល្ងង់នោះ, សុទ្ធតែនឹងជេរគាត់៖ អាមហាល្ងង់ឯងនេះ។ ស្របតាមពេលបើកមាត់ជេរកាលណា, គុណធម៌មួយដុំបានបោះឆ្លងទៅ។ លោកអ្នកកាន់កាប់ភាពងាយស្រួលដូច្នេះស្ថិតក្នុងភាគីបាន, ដូច្នោះលោកអ្នកគឺត្រូវតែបាត់។ អតីតកាលទាត់គាត់មួយជើង៖ អាមហាល្ងង់ឯងនេះ។ ល្អ, គុណធម៌មួយដុំម្ដងទៀតបានបោះឆ្លងទៅ។ នរណាសម្លុតធ្វើបាបគាត់, នរណាទាត់គាត់មួយជើង, គាត់សើចសប្បាយហ៉ាៗ៖ "លោកមកៗ, យ៉ាងណាក៏ផ្ដល់គុណធម៌ឱ្យខ្ញុំ, ខ្ញុំសុទ្ធតែមិនរុញចេញបន្តិចណា!" ដូច្នោះយោងតាមគោលសីលធម៌នេះនៅជាន់ថ្នាក់ខ្ពស់, អ្នករាល់គ្នាគិតសាកមើល, នរណាឆ្លាត? មិនមែនគាត់ឆ្លាតឬ? គាត់ឆ្លាតបំផុត។ គាត់សុទ្ធតែមិនបាត់គុណធម៌បន្តិចណា, លោកអ្នកយកគុណធម៌បោះឆ្លងឲ្យគាត់, គាត់បន្តិចសុទ្ធតែមិនរុញទៅវិញ, សុទ្ធតែយកទាំងអស់, សុទ្ធតែទទួលយកសប្បាយហ៉ាៗ។ ជាតិនេះល្ងង់ជាតិក្រោយមិនល្ងង់, វិញ្ញាណដើមមិនល្ងង់។ នៅក្នុងសាសនាសម្ដែង, និយាយថាគុណធម៌របស់មនុស្សច្រើនជាតិក្រោយធ្វើមហាមន្ត្រី, មានមហាសម្បត្តិ, សុទ្ធតែជាប្រើគុណធម៌របស់មនុស្សដើម្បីផ្ដោះប្ដូរ។

យើងខ្ញុំសម្ដែង, គុណធម៌អាចដោយផ្ទាល់វិវត្តក្លាយជាគង់។ លោកអ្នកបួសបានខ្ពស់ប៉ុណ្ណា, មិនជាក់ស្ដែងគឺគុណធម៌នេះរបស់លោកអ្នកវិវត្ត? វាដោយផ្ទាល់អាចវិវត្តក្លាយជាគង់។ កំណត់ជាន់ថ្នាក់របស់មនុស្សខ្ពស់ឬទាប, អំណាចគង់ធំឬតូច, មិនជាក់ស្ដែងគឺប្រភេទសារធាតុនេះវិវត្តក្លាយជាឬ? លោកអ្នកនិយាយវាដ៏មានតម្លៃឬអត់? វាអាចកើតនាំមកតាម, ស្លាប់នាំទៅតាម។ ក្នុងពុទ្ធសាសនាសម្ដែង, លោកអ្នកបួសហាត់

ខ្ពស់ប៉ុណ្ណា, នោះគឺផលញាណរបស់លោកអ្នក។ លោកអ្នកបង់ចំណាយ ប៉ុណ្ណា, ទទួលបានប៉ុណ្ណោះ។ ជាក់ស្ដែងជាគោលសីលធម៌នេះ។ ក្នុង សាសនាសម្ដែង, មានគុណធម៌ជាតិក្រោយធ្វើមហាមន្ត្រី, មានមហា សម្បត្តិ។ គុណធម៌តិចសុំទានក៏សុំមិនបាន, ដោយសារគ្មានគុណធម៌ ផ្ដោះប្ដូរ, មិនបាត់មិនបានទេតើ! គ្មានគុណធម៌បន្តិចសោះ, នោះគឺត្រូវតែ រូប-វិញ្ញាណកម្ទេចទាំងស្រុង, ស្លាប់មែនទែន។

អតីតកាលមានគ្រូឈីគង់ម្នាក់, ពេលដែលទើបចេញមកសាធារណ ជនជាន់ថ្នាក់យ៉ាងខ្ពស់, គ្រូឈីគង់នេះក្រោយមកបានធ្លាក់នៅក្នុង កិត្តិនាមផលប្រយោជន៍។ គ្រូគាត់ក៏បានយកវិញ្ញាណដើមរងរបស់គាត់ នាំទៅ, ដោយសារគាត់សុទ្ធតែជាស្ថិតក្នុងបួសហាត់វិញ្ញាណដើមរង។ ពេលដែលវិញ្ញាណដើមរងរបស់មនុស្សនៅ, គឺទទួលរងការឃុំគ្រងរបស់ វិញ្ញាណដើមរង។ លើកឧទាហរណ៍, មានថ្ងៃមួយអង្គភាពបែងចែកផ្ទះ, អ្នកដឹកនាំនិយាយ៖ មនុស្សខ្វះផ្ទះស្នាក់នៅចូរចូលមក, ពិពណ៌នាអំពី ស្ថានភាព, សម្ដែងសាកមើលឯកជនចាំបាច់ផ្ទះដូចម្ដេច។ ម្នាក់ៗ និយាយរឿងៗខ្លួន, គាត់នោះមិននិយាយអ្វីសោះ។ ចុងក្រោយអ្នកដឹកនាំ ពេលសង្កេតឃើញគឺគាត់លំបាកជាងគេ, ផ្ទះគួរផ្ដល់ឲ្យគាត់។ អ្នកដទៃ ថា៖ មិនបាន, ផ្ទះមិនអាចផ្ដល់ឲ្យគាត់, ត្រូវតែផ្ដល់ឲ្យខ្ញុំ, ខ្ញុំខ្វះផ្ទះយ៉ាង នេះយ៉ាងនោះ។ គាត់និយាយ៖ អញ្ចឹងបងក៏យកទៅ។ បើហៅមនុស្ស សាមញ្ញមើល, ឯកជននេះល្ងង់។ មានមនុស្សដឹងបានគាត់ជាមនុស្ស ហាត់គង់, ក៏សួរគាត់៖ មនុស្សហាត់គង់ពួកបងអ្វីក៏មិនចង់បាន, សួរថា បងចង់បានអ្វី? គាត់និយាយ៖ អ្វីអ្នកដទៃមិនចង់បាន, ខ្ញុំចង់បាន។ ភាព ពិតគាត់សុទ្ធតែមិនល្ងង់បន្តិចណា, ដ៏ប្រាជ្ញាភ្លឺថ្លា។ ត្រង់នៅលើផល ប្រយោជន៍ផ្ទាល់ខ្លួនរបស់ឯកជន, គឺប្រព្រឹត្តបែបនេះ, គាត់សម្ដែង

បណ្ដោយតាមធម្មជាតិ។ អ្នកដទៃសួរទៀតថា៖ មនុស្សឥឡូវអ្វីមិនចង់បាន? គាត់និយាយ៖ ដុំថ្មលើដីទាត់មកទាត់ទៅគ្មាននរណាចង់បាន, អញ្ចឹងខ្ញុំគឺរើសដុំថ្មនោះ។ មនុស្សសាមញ្ញមានអារម្មណ៍មិនអាចយល់បាន, មនុស្សសាមញ្ញមិនអាចពន្យល់មនុស្សហាត់គង់, គ្មានវិធីពន្យល់បាន, កម្រិតភពមនោគតិខុសគ្នាឆ្ងាយពេក, ជាន់ថ្នាក់ទាញដាច់ពីគ្នាធំពេក។ ប្រាកដណាស់គាត់នឹងមិនទៅរើសដុំថ្មនោះ, គាត់បាននិយាយចេញគោលសីលធម៌ដែលមនុស្សសាមញ្ញភ្ញាក់ដឹងមិនដល់៖ ខ្ញុំមិនចំណង់របស់ក្នុងមនុស្សសាមញ្ញ។ ចូរនិយាយអំពីដុំថ្មនេះ, អ្នករាល់គ្នាដឹងក្នុងពុទ្ធគម្ពីរសរសេរ៖ ពិភពសុខៈដើមឈើគឺជាមាស, ដីគឺជាមាស, ចាបគឺជាមាស, ផ្កាគឺជាមាស, ផ្ទះក៏ជាមាស, សូម្បីតែពុទ្ធកាយក៏ជាពន្លឺមាសចែងចាំង។ ដល់ទីនោះរួចហើយរកមិនបានថ្មមួយដុំ, លុយចាយតាមនិយាយជាក់ស្ដែងគឺជាថ្ម, យ៉ាងណាគាត់នឹងមិនយកដុំថ្មឡើងទៅទីនោះបាន, ប៉ុន្ដែគាត់និយាយចេញគោលសីលធម៌មួយយ៉ាងនេះ, មនុស្សសាមញ្ញពន្យល់មិនបាន។ ដោយមែនទែនមនុស្សហាត់គង់សម្ដែង៖ របស់ដែលមនុស្សសាមញ្ញបានស្វែងរក, យើងខ្ញុំមិនស្វែងរក; របស់ដែលមនុស្សសាមញ្ញមាន, យើងខ្ញុំក៏មិនខ្វល់; តែរបស់ដែលយើងខ្ញុំមាន, មនុស្សសាមញ្ញចង់បានក៏មិនអាច។

ភាពពិត, ភ្ញាក់ដឹងដែលយើងខ្ញុំទើបសម្ដែង, នេះនៅតែជាស្ថិតក្នុងប្រភេទភ្ញាក់ដឹងក្នុងដំណើរការបួសហាត់, នេះផ្ទុយស្រឡះនឹងភ្ញាក់ដឹងក្នុងមនុស្សសាមញ្ញ។ ភ្ញាក់ដឹងពិតប្រាកដដែលពួកយើងសំដៅលើ, ជាក់ស្ដែងគឺជាធម៌ដែលលោកគ្រូសម្ដែងនៅក្នុងដំណើរការពួកយើងហាត់គង់, តាវដែលលោកគ្រូក្នុងតាវវង្សសម្ដែង, គ្រោះលំបាកដែលខ្លួនឯងជួបប្រទះនៅក្នុងដំណើរការបួសហាត់, អាចភ្ញាក់ដឹងខ្លួនឯងជាមនុស្សបួសហាត់ឬ

អត់, អាចពន្យល់បានឬអត់, អាចទទួលយកឬអត់, នៅក្នុងដំណើរការបួសហាត់អាចអនុលោមតាមធម៌នេះដើម្បីធ្វើឬអត់។ មនុស្សខ្លះមិនថានិយាយដូចម្តេចគាត់ក៏មិនជឿ, នៅតែជាអត្ថប្រយោជន៍សម្ភារៈក្នុងមនុស្សសាមញ្ញ។ គាត់ឱបគោលគំនិតជាប់រឹងមិនលែង, ហើយបង្កជាធ្វើឲ្យគាត់មិនអាចជឿ។ មនុស្សខ្លះគឺចង់ព្យាបាលជំងឺ, ខ្ញុំទីនេះកាលណាសម្តែងឈីគង់ជាមូលដ្ឋានមិនមែនប្រើដើម្បីព្យាបាលជំងឺ, មនោគតិរបស់គាត់គឺមិនចូលចិត្តយ៉ាងខ្លាំង, ហេតុនេះគឺមិនជឿប្រការដែលបានសម្តែងមកទៀត។

ចរិតភ្ញាក់ដឹងរបស់មនុស្សមួយចំនួនជាក់ស្តែងគឺជាឡើងមិនបាន, មនុស្សខ្លះកាន់សៀវភៅនេះរបស់ខ្ញុំកោសៗគូរៗតាមអំពើចិត្ត។ មនុស្សដែលបើកភ្នែកទិព្វក្នុងពួកយើងសុទ្ធតែមើលឃើញ, សៀវភៅនេះមើលទៅពន្លឺចម្រុះពណ៌, ពន្លឺមាសចែងចាំង, អក្សរនីមួយៗសុទ្ធតែជារូបភាពបរមីរបស់ខ្ញុំ។ ខ្ញុំបើសិននិយាយពាក្យក្លែងក្លាយជាក់ស្តែងគឺកំពុងបញ្ឆោតអ្នករាល់គ្នា, ដែលគួរចេញពីប៊ិកនោះរបស់លោកអ្នកខ្មៅងងឹត, តើលោកអ្នកហ៊ានគូរពីលើតាមអំពើចិត្ត? យើងខ្ញុំធ្វើអ្វីនៅទីនេះ? មិនមែននាំលោកអ្នកបួសឡើងលើឬ? មានរឿងរ៉ាវខ្លះលោកអ្នកក៏គួរតែគិតសាកមើល, សៀវភៅនេះអាចណែនាំលោកអ្នកបួសហាត់, លោកអ្នកគិតគាត់ដ៏មានតម្លៃឬអត់? លោកអ្នកសំពះព្រះពុទ្ធអាចធ្វើឱ្យលោកអ្នកបួសហាត់ពិតប្រាកដឬអត់? លោកអ្នកដ៏គោរព, មិនហ៊ានប៉ះពុទ្ធបដិមានោះបន្តិច, រាល់ថ្ងៃអុជធូបឲ្យវា, ហើយមហាធម៌ពិតប្រាកដអាចណែនាំលោកអ្នកបួសហាត់ផ្ទុយមកវិញលោកអ្នកហ៊ានទៅជាន់ឈ្លី។

សម្តែងបញ្ហាចរិតភ្ញាក់ដឹងរបស់មនុស្ស, នេះគឺសំដៅលើនៅក្នុងដំណើរការបួសហាត់, ចំពោះប្រការណាមួយ, ធម៌ណាមួយលេចឡើង

នៅគ្រប់ជាន់ថ្នាក់ឬក៏ជាលោកគ្រូសម្ដែង, លោកអ្នកពន្យល់វាដល់កម្រិតណា។ ទោះយ៉ាងណានៅតែមិនមែនជាភ្ញាក់ដឹងមូលដ្ឋានដែលយើងខ្ញុំសម្ដែង, ភ្ញាក់ដឹងមូលដ្ឋានដែលយើងខ្ញុំសម្ដែងជាក់ស្ដែងគឺនៅអំឡុងឆ្នាំគាត់មានជីវិត, ពីទើបចាប់ផ្ដើមបួសហាត់, បន្តថ្កើងសំដៅឡើងលើ, បន្តកម្ចាត់ចោលចិត្តប្រកាន់, តណ្ហាគ្រប់ប្រភេទរបស់មនុស្ស, គង់ក៏កំពុងបន្តកើនសំដៅឡើងលើ, ចុងក្រោយបន្តដើរដល់ជំហានចុងក្រោយដែលគាត់បួសហាត់។ ទាំងអស់សារធាតុគុណធម៌នេះវិវត្តក្លាយជាគង់, ផ្លូវបួសហាត់ដែលលោកគ្រូរៀបចំឲ្យដើរដល់ទីបញ្ចប់, នៅមួយសន្ទុះនេះ, [ជាំង] ភ្លាមៗសោទាំងអស់ផ្ទុះបើក។ ភ្នែកទិព្វសម្រេចបានចំណុចខ្ពស់បំផុតក្នុងជាន់ថ្នាក់ឋិតនៅរបស់គាត់, មើលឃើញសេចក្ដីពិតនៃគ្រប់អវកាសក្នុងជាន់ថ្នាក់ឋិតនៅរបស់គាត់, ទម្រង់អត្ថិភាពរបស់កាយជីវិតគ្រប់ប្រភេទនៃបណ្ដាវេលា-អវកាស, ទម្រង់អត្ថិភាពរបស់សារធាតុក្នុងបណ្ដាវេលា-អវកាស, មើលឃើញសេចក្ដីពិតក្នុងចក្រវាលរបស់ពួកយើង។ ទេពអំណាចមហាបង្ហាញ, សុទ្ធតែអាចទំនាក់ទំនងជាមួយកាយជីវិតគ្រប់ប្រភេទ។ ពេលដែលដល់ជំហានមួយនេះនៅតែមិនមែនអង្គត្រាស់ដឹងឬ? មនុស្សបួសហាត់បានត្រាស់ដឹងហើយឬ? បកប្រែជាពាក្យឥណ្ឌាបុរាណជាក់ស្ដែងគឺជាពុទ្ធ។

ភ្ញាក់ដឹងនេះដែលយើងខ្ញុំសម្ដែង, ប្រភេទភ្ញាក់ដឹងមូលដ្ឋាននេះនៅតែជាស្ថិតក្នុងទម្រង់ភ្ញាក់ដឹងភ្លាម។ ភ្ញាក់ដឹងភ្លាមគឺនៅអំឡុងឆ្នាំគាត់មានជីវិតបួសដោយចាក់សោ, មិនដឹងគង់របស់ខ្លួនឯងខ្ពស់ប៉ុណ្ណា, មិនដឹងគង់ខ្លួនឯងហាត់ចេញគឺជាសណ្ឋានអ្វី, ជាមូលដ្ឋានគឺគ្មានប្រតិកម្មណាមួយ, សូម្បីតែទាំងកោសិការាងកាយរបស់ខ្លួនឯងសុទ្ធតែត្រូវបានចាក់សោ, គង់ហាត់ចេញសុទ្ធតែត្រូវបានចាក់សោ, រហូតបួសហាត់ដល់

ជំហានមួយចុងក្រោយទើបបានវាយបើក។ នេះត្រូវតែជាមនុស្សមហានិស្ស័យទើបអាចធ្វើបាន, បួសហាត់គឺដ៏វេទនា។ ពីធ្វើមនុស្សល្អឡើង, រមែងលើកកម្ពស់ចិត្តចរិតរបស់ខ្លួនឯង, រមែងរងទុក្ខ, រមែងបួសឆ្ពោះឡើងលើ, រមែងតម្រូវលើកកម្ពស់ចិត្តចរិត, តែមើលមិនឃើញគង់របស់ខ្លួនឯង។ ប្រភេទមនុស្សនេះគឺបួសលំបាកបំផុត, នេះចាំបាច់ត្រូវតែជាមនុស្សមហានិស្ស័យ, បួសទាំងប៉ុន្មានឆ្នាំ, អ្វីក៏មិនដឹង។

នៅមានប្រភេទភ្ជាក់ដឹងមួយហៅថាភ្ជាក់ដឹងបន្តិចម្តង។ ទើបចាប់ផ្តើមមនុស្សដ៏ច្រើនសុទ្ធតែទទួលដឹងបានហ្វាលូនកំពុងបង្វិល, ក្នុងពេលដំណាលគ្នាខ្ញុំនៅបើកភ្នែកទិព្វឲ្យអ្នករាល់គ្នា។ មនុស្សខ្លះដោយសារមូលហេតុគ្រប់ប្រភេទ, ពីមើលមិនឃើញដល់អនាគតក៏នឹងមើលឃើញ, ពីមើលមិនច្បាស់នឹងមើលបានច្បាស់, ពីមិនចេះប្រើដល់ចេះប្រើ, ជាន់ថ្នាក់កំពុងបន្តលើកកម្ពស់។ ស្របតាមចិត្តចរិតលោកអ្នកលើកកម្ពស់ឡើងនិងចិត្តប្រកាន់គ្រប់ប្រភេទបោះចោល, សីលគង់គ្រប់ប្រភេទសុទ្ធតែបញ្ចេញមកក្រៅ។ ភាពប្រែប្រួលរបស់ដំណើរការបួសហាត់ទាំងមូល, ដំណើរការបំប្លែងរបស់រាងកាយ, សុទ្ធតែកើតឡើងការផ្លាស់ប្រែនៅក្រោមកាលៈទេសៈដែលលោកអ្នកខ្លួនឯងអាចមើលឃើញឬក៏ទទួលដឹងបាន។ បែបនេះដើរដល់ជំហានមួយចុងក្រោយ, ទាំងស្រុងយល់ដឹងបានសច្ចធម៌នៃចក្រវាល, ជាន់ថ្នាក់បានឈានដល់ចំណុចកំពូលដែលលោកអ្នកគួរបួសហាត់ដល់, ផ្លាស់ប្រែរបស់រាងកាយដើម, ពង្រឹងរបស់សីលគង់សុទ្ធតែបានដល់កម្រិតជាក់លាក់, បណ្តើរៗសម្រេចបានគោលបំណងនេះ។ នេះគឺស្ថិតក្នុងភ្ជាក់ដឹងបន្តិចម្តង។ វិធីសាស្ត្របួសហាត់នេះតាមប្រភេទភ្ជាក់ដឹងបន្តិចម្តងក៏មិនងាយស្រួល, មានសីលគង់រួចហើយ, មានមនុស្សមួយចំនួនចិត្តប្រកាន់គឺដាក់ចុះមិនបាន, គឺងាយស្រួល

បង្ហាញ, គឺងាយស្រួលទៅធ្វើរឿងរ៉ាវមិនល្អ។ បែបនេះលោកអ្នកនឹងត្រូវតែបាត់គង់, លោកអ្នកនឹងបួសដូចមិនបួស, ចុងក្រោយនឹងវិនាស។ មានមនុស្សមួយចំនួនអាចមើល, អាចមើលឃើញលាតត្រដាងរបស់កាយជីវិតគ្រប់ប្រភេទនៅជាន់ថ្នាក់ខុសគ្នា, គាត់អាចទាញលោកអ្នកទៅធ្វើនេះធ្វើនោះ, គាត់អាចទាញលោកអ្នកទៅបួសហាត់ប្រការរបស់គាត់, ទទួលលោកអ្នកធ្វើកូនសិស្ស, តែផ្ទុយមកវិញគាត់មិនអាចធ្វើឲ្យលោកអ្នកសម្រេចមគ្គផល, ដោយសារគាត់ក៏ជាមិនសម្រេចមគ្គផល។

ក្រៅពីនេះ, មនុស្សនៃអវកាសជាន់ខ្ពស់សុទ្ធតែជាអាទិទេព, ប្រែជាដ៏ធំ, ទេពអំណាចមហាបង្ហាញ, ចិត្តកាលណាមិនសុចរិត, លោកអ្នកនឹងដើរតាមគាត់ឬអត់? លោកអ្នកកាលណាដើរតាមគាត់, ភ្លាមៗបួសដូចមិនបួស។ គាត់ជាក់ស្តែងគឺជាពុទ្ធពិត, តាវពិត, លោកអ្នកក៏ត្រូវតែបួសហាត់ពីដំបូងម្តងទៀត។ មនុស្សនៃទាំងប៉ុន្មានជាន់មេឃ, នោះមិនសុទ្ធតែជាអាទិទេពឬ? មានតែបួសហាត់ដល់ជាន់ថ្នាក់យ៉ាងខ្ពស់បំផុត, ពេលដែលសម្រេចបានគោលបំណង, ទើបអាចទាំងស្រុងលោតចេញទៅបាន។ ទោះយ៉ាងណា, នៅពីមុខមនុស្សសាមញ្ញធម្មតាអាទិទេពនោះដោយមែនទែនបង្ហាញចេញខ្ពស់ផងធំផង, អានុភាពក៏ដ៏ធំ, ប៉ុន្តែគាត់ក៏មិនជាក់លាក់គឺសម្រេចមគ្គផល។ នៅក្រោមជ្រៀតជ្រែកនៃព័ត៌មានគ្រប់ប្រភេទ, នៅក្រោមទាក់ទាញនៃទស្សនីយភាពគ្រប់ប្រភេទ, លោកអ្នកអាចឬមិនអាចមិនកម្រើកចិត្ត? ដូច្នេះនិយាយថាបើកភ្នែកទិព្វបួសក៏ពិបាក, រក្សាជាប់ចិត្តចរិតកាន់តែពិបាកជាង។ ប៉ុន្តែភ័ព្វល្អពួកយើងមានមនុស្សមួយចំនួនគឺស្ថិតក្នុងពាក់កណ្តាលផ្លូវម្តងទៀតវាយបើកសីលគង់ឲ្យលោកអ្នក, ឈានចូលក្នុងស្ថានភាពត្រាស់ដឹងបន្តិចម្តង។ ភ្នែកទិព្វរបស់នរណាក៏បានបើក, មនុស្សដ៏ច្រើនមានសីលគង់មិនអនុញ្ញាតឲ្យ

លោកអ្នកបញ្ចេញ, ក្រោយពីចិត្តចរិតលោកអ្នកសន្សឹមៗលើកកម្ពស់ដល់មួយជាន់ថ្នាក់, ស្ថានភាពផ្លូវចិត្តចិរភាព, ពេលដែលអាចរក្សាជាប់ខ្លួនឯង, ក្រោយមកភ្លាមៗផ្ទុះបើកឲ្យលោកអ្នក។ ដល់ជាន់ថ្នាក់មួយអនុញ្ញាតឲ្យលោកអ្នកលេចឡើងស្ថានភាពត្រាស់ដឹងបន្តិចម្ដង, ពេលនោះងាយស្រួលរក្សាជាប់បង្គួរ, សីលគង់គ្រប់ប្រភេទសុទ្ធតែលេចឡើង, ខ្លួនឯងបួសឡើងលើ, ដល់ចុងក្រោយបើកទាំងស្រុង។ នៅពាក់កណ្ដាលផ្លូវបួសហាត់អនុញ្ញាតឲ្យលោកអ្នកលេចឡើង, មនុស្សដ៏ច្រើនពួកយើងគឺស្ថិតក្នុងប្រភេទមួយនេះ, ដូច្នេះកុំប្រញាប់មើលឃើញបាន។

អ្នករាល់គ្នាអាចស្ដាប់ឮថាឆានចុងក៏មានសម្ដែងអំពីបែងចែក "ភ្លាម" និង "បន្តិចម្ដង"។ សិស្សទី៦ហួយណឹងសម្ដែងភ្ញាក់ដឹងភ្លាម, និកាយខាងជើងស៊ឺនសៀវសម្ដែងភ្ញាក់ដឹងបន្តិចម្ដង។ នៅក្នុងប្រវត្តិសាស្ត្រពួកគាត់ពីរនាក់ក្នុងពុទ្ធសាស្ត្របានកើតឡើងពិភាក្សាតទល់ពេលវេលាដ៏យូរ, ពិភាក្សាតទល់ទៅមក។ ខ្ញុំនិយាយថាអត់មានន័យ, ហេតុអ្វី? ដោយសារដែលគាត់សំដៅលើហួសពេកគ្រាន់តែជាការយល់ដឹងចំពោះគោលសីលធម៌មួយក្នុងដំណើរការបួសហាត់។ គោលសីលធម៌មួយនេះ, មានមនុស្សគឺយល់ដឹងបានភ្លាម, ហើយមានមនុស្សគឺបន្តិចម្ដងភ្ញាក់ដឹងបាន, យល់ដឹងបាន។ ភ្ញាក់ដឹងដូចម្ដេចគឺមិនបាន? យល់ដឹងបានភ្លាមល្អជាង, បន្តិចម្ដងភ្ញាក់ដឹងបាននោះក៏បាន, មិនសុទ្ធតែជាភ្ញាក់ដឹងឬ? សុទ្ធតែជាភ្ញាក់ដឹង, ដូច្នេះមួយណាក៏មិនខុស។

## មនុស្សមហានិស្ស័យ

អ្វីជាមនុស្សមហានិស្ស័យ? មនុស្សមហានិស្ស័យនិងមនុស្សនិស្ស័យល្អឬអាក្រក់នៅតែមានភាពខុសគ្នា។ ប្រភេទមនុស្សមហានិស្ស័យនេះពិបាករកខ្លាំងណាស់, សុទ្ធតែជាឆ្លងកាត់សម័យកាលប្រវត្តិសាស្ត្រដ៏

យូរ, ទើបអាចបង្កើតចេញមនុស្សម្នាក់។ ប្រាកដណាស់មនុស្សមហានិស្ស័យជាដំបូងចាំបាច់ត្រូវមានគុណធម៌ដ៏ធំ, វាលសារធាតុពណ៌សនេះត្រូវតែយ៉ាងធំ, ចំណុចមួយនេះគឺបញ្ជាក់។ ក្នុងពេលដំណាលគ្នាគាត់នៅតែត្រូវអាចរងទុក្ខក្នុងចំណោមទុក្ខ, នៅតែត្រូវមានចិត្តមហាខន្តី, នៅតែត្រូវអាចលះ, នៅតែត្រូវអាចរក្សាគុណធម៌, នៅតែត្រូវភ្ញាក់ដឹងល្អ។ល។

អ្វីជាទុក្ខក្នុងចំណោមទុក្ខ? ក្នុងពុទ្ធសាសនាសន្មតថាធ្វើមនុស្សជាក់ស្ដែងគឺជាទុក្ខ, ដរាបណាលោកអ្នកធ្វើមនុស្ស, គឺត្រូវតែទទួលរងទុក្ខ។ វាសន្មតថាកាយជីវិតនៅអវកាសទាំងអស់សុទ្ធតែគ្មានរាងកាយនេះរបស់មនុស្សសាមញ្ញពួកយើង, ដូច្នេះនឹងមិនកើតជំងឺ, ក៏ជាមិនស្ថិតនៅបញ្ហាកើតចាស់ឈឺស្លាប់, ក៏ជាមិនស្ថិតនៅប្រភេទទុក្ខឈឺចាប់នេះ។ មនុស្សនៃអវកាសផ្សេងអាចអណ្ដែតឡើង, មិនមានស្រាលធ្ងន់, ស្អាតអស្ចារ្យខ្លាំងណាស់។ មនុស្សសាមញ្ញត្រង់ដោយសារមានរាងកាយនេះ, ដូច្នេះលេចឡើងបញ្ហាមួយៈ ត្រជាក់ទ្រាំមិនបាន, ក្ដៅទ្រាំមិនបាន, ស្រេកទ្រាំមិនបាន, ឃ្លានទ្រាំមិនបាន, ហត់ក៏ទ្រាំមិនបាន, នៅមានកើតចាស់ឈឺស្លាប់, យ៉ាងណាលោកអ្នកក៏គ្មានសុខស្រួល។

ខ្ញុំធ្លាប់អានកាសែតមួយចុះផ្សាយគឺជាពេលរញ្ជួយដីនៅថាងសាន, មានមនុស្សជាច្រើនស្លាប់នៅក្នុងរញ្ជួយដីនោះ, តែមានមនុស្សមួយចំនួនត្រូវបានសង្គ្រោះមកវិញ។ ការស្ទង់មតិសង្គមពិសេសមួយត្រូវបានធ្វើឡើងសម្រាប់ក្រុមមនុស្សនេះ៖ សួរថាពួកគាត់មានអារម្មណ៍អ្វីនៅក្រោមស្ថានភាពបាត់បង់ជីវិត? ប៉ុន្តែដោយមិននឹកស្មានដល់គឺមនុស្សទាំងនេះសុទ្ធតែនិយាយដល់ស្ថានភាពពិសេសមួយ, ថែមទៀតគឺស្របគ្នា, ជាក់ស្ដែងគឺជាមនុស្សនៅមួយសន្ទុះបាត់បង់ជីវិតនោះគ្មានអារម្មណ៍ភ័យខ្លាច, ផ្ទុយមកវិញទាំងស្រុងស្រាប់តែទទួលដឹងបានមានប្រភេទអារម្មណ៍រំដោះ

មួយ, មានប្រភេទអារម្មណ៍សក្តានុពលម្យ៉ាង; មនុស្សខ្លះមានអារម្មណ៍ខ្លួនឯងភ្លាមៗគ្មានចំណងរបស់រាងកាយ, ស្រាលអណ្តែតស្អាតអស្ចារ្យខ្លាំងណាស់អណ្តែតឡើងមក, នៅមើលឃើញរាងកាយរបស់ខ្លួនឯង; មនុស្សខ្លះនៅមើលឃើញកាយជីវិតក្នុងអវកាសផ្សេង; មនុស្សខ្លះថែមទាំងទៅកន្លែងនេះកន្លែងនោះ។ មនុស្សទាំងអស់សុទ្ធតែបាននិយាយដល់មួយសន្ទុះនោះទទួលដឹងបានប្រភេទអារម្មណ៍សក្តានុពលមួយនៃអារម្មណ៍រំដោះម្យ៉ាង, គ្មានអារម្មណ៍ទុក្ខឈឺចាប់។ ពោលគឺនិយាយថាពួកយើងមានរាងកាយសាច់របស់មនុស្សជាក់ស្តែងគឺជាទុក្ខ, ប៉ុន្តែអ្នករាល់គ្នាសុទ្ធតែជាបែបនេះពីក្នុងពោះម៉ែចេញមក, ដូច្នេះក៏មិនដឹងគឺជាទុក្ខ។

ខ្ញុំនិយាយថាមនុស្សត្រូវតែរងទុក្ខក្នុងចំណោមទុក្ខ។ ថ្ងៃនោះខ្ញុំបាននិយាយ, ទស្សនាទានអវកាសវេលា-អវកាសនេះរបស់មនុស្សជាតិនិងវេលា-អវកាសធំជាងផ្សេងក៏មិនដូចគ្នា, មួយស៊ីឆឺនខាងនេះរបស់ពួកយើងគឺ២ម៉ោងនាឡិកា, ជាក់ស្តែងគឺជា១ឆ្នាំនៅអវកាសនោះរបស់គាត់។ និយាយថាឯកជននេះនៅក្រោមបរិយាកាសទុក្ខយ៉ាងនេះហាត់គង់, ពិតជាអស្ចារ្យណាស់; និយាយថាឯកជននេះមានចិត្តចំណង់តាវ, បំណងចង់បួសហាត់, ឯកជននេះសុទ្ធសាធឆ្នើមខ្លាំងណាស់។ ទុក្ខយ៉ាងនេះគាត់នៅតែមិនទាន់ពន្លត់បាត់ចរិតដើមរបស់ខ្លួន, គាត់នៅតែចង់បួសហាត់ត្រឡប់បញ្ច្រាសមកវិញ។ ហេតុអ្វីអាចជួយមនុស្សបួសហាត់ដោយអត់លក្ខខណ្ឌ? ជាក់ស្តែងគឺជាបែបនេះ។ និយាយថានៅក្នុងអវកាសរបស់មនុស្សសាមញ្ញអង្គុយសមាធិមួយយប់, គេមើលឃើញកាលណា, និយាយថាឯកជននេះពិតជាអស្ចារ្យ, គាត់បានអង្គុយនៅទីនេះ៦ឆ្នាំរួចហើយ។ ដោយសារមួយស៊ីឆឺនរបស់ពួកយើងគឺជាមួយឆ្នាំនៅខាងនោះ។

មនុស្សជាតិពួកយើងជាអវកាសយ៉ាងពិសេសបំផុត។

ដូចម្តេចគឺរងទុក្ខក្នុងចំណោមទុក្ខ? លើកឧទាហរណ៍និយាយ, ឯកជននេះមានថ្ងៃមួយទៅធ្វើការ។ អង្គភាពដំណើរការមិនសូវចម្រើន, មនុស្សច្រើនការងារតិចស្ថានភាពនេះមិនបាន, អង្គភាពត្រូវការកំណែទម្រង់, ទទួលកម្មករកិច្ចសន្យា, បុគ្គលិកនៅសល់ត្រូវបានបញ្ឈប់ពីការងារ។ គាត់ក៏ជាម្នាក់ក្នុងចំណោមនោះ, ស្រាប់តែត្រូវបាត់ចានបាយ។ នេះជាអារម្មណ៍អ្វី? គ្មានកន្លែងរកលុយបានទៀត, តើរស់ដូចម្តេច? ធ្វើអ្វីផ្សេងទៀតក៏មិនចេះ, បាត់បង់នូវក្តីសង្ឃឹមត្រឡប់មកផ្ទះ។ មកដល់ផ្ទះ, តាចាស់ក្នុងផ្ទះឈឺ, ជំងឺដ៏ធ្ងន់ធ្ងរ, ប្រញាប់ដូចភ្លើងឆេះ, យ៉ាងឆាប់រហ័សបញ្ជូនយកទៅពេទ្យ, មិនងាយស្រួលអ្វីខ្ចីបានលុយស្នាក់នៅមន្ទីរពេទ្យ។ វិលមកផ្ទះរៀបចំរបស់របរបន្តិចឲ្យតាចាស់, ទើបមកដល់ផ្ទះ, គ្រូនៅសាលារកដល់មាត់ទ្វារនិយាយថា៖ កូនរបស់លោកវាយគេធ្ងន់ណាស់, លោកឆាប់ប្រញាប់ទៅមើលៗ។ ទើបតែដោះស្រាយរួចរាល់រឿងនេះវិលមកផ្ទះ, អង្គុយចុះភ្លាម, ទូរស័ព្ទរោទ៍និយាយថា៖ ប្រពន្ធលោកមានសាហាយហើយ។ ប្រាកដណាស់អ្នករាល់គ្នានឹងមិនជួបប្រទះរឿងរ៉ាវបែបនេះ។ មនុស្សធម្មតាមិនអាចរងទុក្ខនេះរួច, គិតថា៖ នេះនៅរស់ធ្វើអ្វីទៀត, រកខ្សែព្យួរព្យួរឡើង, មិនរស់ទៀត! មួយគឺចប់! ខ្ញុំគឺនិយាយថាមនុស្សត្រូវតែអាចរងទុក្ខក្នុងណោមទុក្ខ, ប្រាកដណាស់ក៏មិនជាក់លាក់គឺជាទម្រង់បែបនេះ។ ដូច្នោះការកម្ទាត់គ្នារវាងមនុស្សនិងមនុស្ស, កកិតខាងចិត្តចរិត, ក្នុងពេលប្រជែងប្រយុទ្ធផលប្រយោជន៍ឯកជនក៏មិនខ្សោយជាងប្រការនេះ។ មានមនុស្សប៉ុន្មាននាក់ព្រោះតែរក្សាទុកមុខដើម្បីរស់, ទ្រាំមិនបានគឺព្យួរឡើងស្លាប់។ ដូច្នេះពួកយើងត្រូវការនៅក្នុងប្រភេទបរិយាកាសស្មុគស្មាញមួយបែបនេះដើម្បីបួសហាត់, ត្រូវតែអាចរងទុក្ខ

ក្នុងណោមទុក្ខ, ក្នុងពេលដំណាលគ្នានៅតែត្រូវមានចិត្តមហាខន្តី។

អ្វីជាចិត្តមហាខន្តី? ធ្វើជាមនុស្សហាត់គង់ម្នាក់មុនដំបូងគួរតែធ្វើបានជាក់ស្តែងគឺវាយមិនសងដៃ, ជេរមិនតមាត់, ត្រូវខន្តី។ បើមិនដូច្នេះទេ, លោកអ្នកចាត់ថាមនុស្សហាត់គង់អ្វី? មានមនុស្សនិយាយៈ ខន្តីនេះដ៏ពិបាកធ្វើបាន, ខ្ញុំចិត្តក្តៅមិនល្អ។ ចិត្តក្តៅមិនល្អគឺកែ, មនុស្សហាត់គង់ចាំបាច់ត្រូវតែខន្តី។ មានមនុស្សគ្រប់គ្រងកូនក្មេងក៏ខឹងក្រោធ, សុទ្ធសាធជេររំខានពេញមួយថ្ងៃ, លោកអ្នកគ្រប់គ្រងកូនក្មេងក៏មិនចាំបាច់បែបនោះ, លោកអ្នកខ្លួនឯងមិនបានខឹងពិតប្រាកដ, លោកអ្នកត្រូវការអប់រំកូនក្មេងដោយវិចារណញ្ញាណជាង, ទើបអាចពិតប្រាកដអប់រំកូនក្មេងបានល្អ។ រឿងតូចសុទ្ធតែឆ្លងមិនបាន, ហើយខឹងចិត្តក្តៅ, នៅតែចង់បង្កើនគង់។ មានមនុស្សនិយាយៈ ដើរនៅតាមផ្លូវ, នរណាទាត់ខ្ញុំមួយជើង, ក៏គ្មាននរណាស្គាល់ដឹងខ្ញុំ, នេះខ្ញុំអាចធ្វើបានខន្តី។ ខ្ញុំនិយាយថានេះនៅតែមិនគ្រប់, អនាគតប្រហែលជាគឺនៅពីមុខមនុស្សដែលលោកអ្នកខ្លាចបាក់មុខបំផុត, ត្រូវគេទះកំផ្លៀងពីរដៃ, ធ្វើឲ្យលោកអ្នកបាក់មុខយ៉ាងអាម៉ាស់, លោកអ្នកប្រព្រឹត្តដូចម្តេចចំពោះបញ្ហានេះ, មើលលោកអ្នកអាចខន្តីឬអត់។ លោកអ្នកអាចខន្តីជាប់, តែក្នុងចិត្តដាក់ចុះមិនបាន, នេះក៏មិនបាន។ អ្នករាល់គ្នាដឹង, សម្រេចបានជាន់ថ្នាក់នោះរបស់អរហន្ត, ជួបប្រទះរឿងរ៉ាវអ្វីក៏មិនដាក់នៅក្នុងចិត្ត, រឿងរ៉ាវទាំងអស់ក្នុងមនុស្សសាមញ្ញជាមូលដ្ឋានគឺមិនដាក់នៅក្នុងចិត្ត, ជាដរាបសប្បាយហ៉ាៗ, រងបង់ខាតយ៉ាងណាក៏សប្បាយហ៉ាៗមិនកង្វល់។ ពិតជាអាចធ្វើបាន, លោកអ្នកសម្រេចបានផលញាណអរហន្តបឋមរួចហើយ។

មានមនុស្សសម្តែង, ខន្តីនេះប្រសិនធ្វើដល់កម្រិតនេះ, មនុស្សសាមញ្ញក៏នឹងនិយាយថាពួកយើងទន់ខ្សោយពេក, ងាយស្រួលសម្លុត

ពេក។ ខ្ញុំនិយាយថា, នោះមិនមែនទន់ខ្សោយ។ អ្នករាល់គ្នាគិតសាកមើល, មនុស្សវ័យចំណាស់ក្នុងមនុស្សសាមញ្ញ, មនុស្សដែលកម្រិតវប្បធម៌ខ្ពស់ក៏សម្តែងអំពីអប់រំខាងក្នុង, មិនប្រៀបធៀបជាមួយគេ។ សូម្បីតែមនុស្សហាត់គង់ពួកយើង? តើនោះជាទន់ខ្សោយដូចម្តេច? ខ្ញុំនិយាយថានោះជាការបង្ហាញរបស់ចិត្តមហាខន្តី, នោះជាការបង្ហាញរបស់ឆន្ទៈរឹងមាំ, មានតែមនុស្សហាត់គង់ទើបអាចមានចិត្តមហាខន្តីបែបនេះ។ មានប្រយោគមួយយ៉ាងនេះ៖ ជនធម្មតារងប្រមាថ, ហូតដាវចេញមកច្បាំង។ មនុស្សសាមញ្ញនោះប្រាកដណាស់, អ្នកជេរខ្ញុំ, ខ្ញុំជេរអ្នក; អ្នកវាយខ្ញុំ, ខ្ញុំគឺវាយអ្នក។ នោះជាក់ស្តែងគឺជាមនុស្សសាមញ្ញ, តើអាចនិយាយថាគាត់ជាមនុស្សហាត់គង់ឬ? ធ្វើជាមនុស្សបួសហាត់ម្នាក់, លោកអ្នកប្រសិនគ្មានឆន្ទៈរឹងមាំ, លោកអ្នកឃុំគ្រងមិនបានខ្លួនឯង, គឺលោកអ្នកធ្វើមិនបានចំណុចមួយនេះ។

អ្នករាល់គ្នាបានដឹងបុរាណកាលមានហានស៊ីន, និយាយថាហានស៊ីននេះមានអានុភាព, នាយឧត្តមសេនីយ៍របស់លៀវប៉ាង់, សសរស្តម្ភរបស់ប្រទេស។ ហេតុអ្វីអាចធ្វើបានរឿងធំយ៉ាងនោះ? និទានថាហានស៊ីននេះពីក្មេងគឺមិនមែនមនុស្សធម្មតា។ មានសម្រង់បុរាណយ៉ាងនេះ, និយាយអំពីហានស៊ីនទ្រាំអាម៉ាស់លូនក្រោមក្រលៀន។ កាលយុវវ័យហានស៊ីនគឺហាត់ក្បាច់គុន, មនុស្សហាត់ក្បាច់គុនសុទ្ធតែកាន់ដាវតាម។ មានថ្ងៃមួយដើរនៅតាមផ្លូវ, ជនពាលខិលខូចម្នាក់ទំពក់ដៃរាំងកាត់ផ្លូវដើររបស់គាត់៖ ឯងកាន់ដាវតាមទុកធ្វើអី? ឯងហ៊ានសម្លាប់មនុស្សទេ? ឯងហ៊ានសម្លាប់មនុស្សឯងកាប់ក្បាលរបស់អញចុះមក។ កំពុងនិយាយគឺយកក្បាលសន្ធឹងឆ្លងទៅ។ ហានស៊ីនគិត៖ យើងកាប់ក្បាលឯងធ្វើអី? កាលនោះកាប់ក្បាលមនុស្សក៏ត្រូវរាយការណ៍ទៅមន្ត្រីសងជីវិត, អាច

សម្លាប់មនុស្សតាមអំពើចិត្តឬ? គាត់ឃើញហានស៊ីនមិនហ៊ានសម្លាប់, ក៏និយាយថា៖ ឯងមិនហ៊ានសម្លាប់អញ, ឯងលូនឆ្លងពីក្រោមក្រលៀនរបស់អញ។ ហានស៊ីនគឺពិតជាលូនឆ្លងពីក្រោមក្រលៀនរបស់គាត់។ នេះនិយាយច្បាស់ថាហានស៊ីនមានចិត្តមហាខន្តីដ៏អស្ចារ្យ, គាត់មិនដូចមនុស្សសាមញ្ញធម្មតា, ទើបគាត់អាចធ្វើរឿងធំយ៉ាងនេះ។ មនុស្សប្រជែងគ្នារក្សាទុកមុខ, នោះជាពាក្យរបស់មនុស្សសាមញ្ញ។ រស់ព្រោះតែរក្សាទុកមុខនេះ, អ្នករាល់គ្នាគិតសាកមើល, តើរស់ហត់ឬអត់? វេទនាឬអត់? ស័ក្តិសមឬអត់? ហានស៊ីនយ៉ាងណាក៏ជាមនុស្សសាមញ្ញ, ពួកយើងជាមនុស្សបួសហាត់ម្នាក់, ពួកយើងនៅតែត្រូវការខ្លាំងជាងគាត់។ គោលដៅរបស់ពួកយើងគឺសម្រេចបានជាន់ថ្នាក់លើសផុតមនុស្សសាមញ្ញ, សំដៅជាន់ថ្នាក់ខ្ពស់ជាងដើម្បីឈានដល់។ រឿងនេះពួកយើងគឺមិនជួបប្រទះ, តែមនុស្សបួសហាត់នៅក្នុងមនុស្សសាមញ្ញពេលដែលទទួលរងអាម៉ាស់, ទទួលរងបង្អាប់, ក៏មិនជាក់លាក់ខ្សោយជាងនេះ។ កកិតក្នុងចិត្តចរិតរវាងមនុស្សនិងមនុស្ស, ខ្ញុំនិយាយថាមិនខ្សោយជាងរឿងនេះ, មានលើសជាងនោះទៅទៀត, ក៏ជាយ៉ាងពិបាក។

ក្នុងពេលដំណាលគ្នា, មនុស្សបួសហាត់នៅត្រូវអាចលះ, លះចោលប្រកាន់គ្រប់ប្រភេទ, តណ្ហាគ្រប់ប្រភេទក្នុងមនុស្សសាមញ្ញ។ ភ្លាមៗធ្វើមិនបាន, ពួកយើងអាចសន្សឹមៗដើម្បីធ្វើបាន។ ថ្ងៃនេះលោកអ្នកភ្លាមៗគឺអាចធ្វើបាន, ថ្ងៃនេះលោកអ្នកជាក់ស្ដែងគឺជាព្រះពុទ្ធ។ បួសហាត់ត្រូវតែសន្សឹមៗដើម្បីធ្វើ, ប៉ុន្តែលោកអ្នកមិនបានបន្ធូរ។ លោកអ្នកនិយាយ៖ លោកគ្រូសម្ដែង, បួសហាត់ត្រូវតែសន្សឹមៗដើម្បីធ្វើ, នោះពួកយើងគឺសន្សឹមៗដើម្បីធ្វើ។ នោះអាចមិនបាន! លោកអ្នកត្រូវតែតម្រូវដោយតឹងរឹងចំពោះខ្លួនឯង, បួសហាត់ពុទ្ធធម៌លោកអ្នកត្រូវការព្យាយាមមោះមុត។

នៅត្រូវតែអាចរក្សាគុណធម៌, ត្រូវការរក្សាចិត្តចរិត, មិនអាចធ្វើផ្ដេសផ្ដាស។ លោកអ្នកមិនអាចតាមអំពើចិត្តចង់ធ្វើអីគឺធ្វើនោះ, លោកអ្នកត្រូវការអាចរក្សាជាប់ចិត្តចរិតរបស់ខ្លួន។ ក្នុងមនុស្សសាមញ្ញអ្នករាល់គ្នាជាធម្មតាស្ដាប់ឮប្រយោគមួយបែបនេះ៖ សន្សំគុណធម៌ធ្វើរឿងល្អ។ មនុស្សហាត់គង់មិនសម្ដែងសន្សំគុណធម៌, ពួកយើងសម្ដែងរក្សាគុណធម៌។ ហេតុអ្វីសម្ដែងរក្សាគុណធម៌? ដោយសារយើងខ្ញុំមើលឃើញកាលៈទេសៈមួយបែបនេះ៖ សន្សំគុណធម៌ជាប្រការសម្ដែងក្នុងមនុស្សសាមញ្ញ, គាត់ត្រូវការសន្សំគុណធម៌, អនុវត្តិករុណា, ជាតិក្រោយទទួលបាន{ផល}ល្អ។ ហើយពួកយើងទីនេះគ្មានបញ្ហានេះ, លោកអ្នកប្រសិនបួសសម្រេចគឺសម្រេចតាវ, គ្មានរឿងជាតិក្រោយនោះ។ ពួកយើងទីនេះសម្ដែងរក្សាគុណធម៌, នៅមានអត្ថន័យមួយជាន់ទៀត, ពោលគឺ, ប្រភេទសារធាតុពីរដែលពួកយើងនាំតាមរាងកាយមិនមែនមួយជីវិតមួយជាតិសន្សំទុកមក, វាគឺឆ្លងកាត់យុគ្គសម័យយូរអង្វែងបន្សល់ទុកមក។ លោកអ្នកបើកឡានរត់ពេញទីក្រុង, ក៏មិនជាក់លាក់ជួបបានរឿងល្អដើម្បីធ្វើ។ លោកអ្នករាល់ថ្ងៃធ្វើបែបនេះ, ក៏មិនជាក់លាក់ជួបបាន។

នៅមានអត្ថន័យមួយជាន់ទៀត, ទុកឲ្យលោកអ្នកសន្សំគុណធម៌, លោកអ្នកមើលឃើញរឿងរ៉ាវនោះគឺជារឿងល្អ, តែប្រសិនលោកអ្នកធ្វើ, ប្រហែលជាចេញទៅរឿងអាក្រក់; ពេលដែលលោកអ្នកមើលឃើញរឿងរ៉ាវនោះគឺជារឿងអាក្រក់, ប្រសិនលោកអ្នកគ្រប់គ្រង, ប្រហែលជាម្ដងទៀតគឺជារឿងល្អ។ ហេតុអ្វី? ដោយសារលោកអ្នកមើលមិនឃើញទំនាក់ទំនងកម្មផលនៅក្នុងនោះ។ ច្បាប់រដ្ឋគ្រប់គ្រងរឿងរ៉ាវក្នុងមនុស្សសាមញ្ញ, នេះគឺគ្មានបញ្ហា។ ធ្វើជាមនុស្សហាត់គង់ម្នាក់ជាក់ស្ដែងគឺជាវិសាមញ្ញ, នោះលោកអ្នកធ្វើជាមនុស្សវិសាមញ្ញម្នាក់, ដូច្នេះត្រូវតែប្រើគោលសីល

ធម៌វិសាមញ្ញដើម្បីតម្រូវលោកអ្នក, ហើយមិនអាចប្រើគោលសីលធម៌ក្នុងមនុស្សសាមញ្ញដើម្បីរាស់រវែង។ លោកអ្នកមិនដឹងទំនាក់ទំនងកម្មផលរបស់រឿងរ៉ាវមួយ, ដូច្នេះលោកអ្នកងាយស្រួលធ្វើរឿងរ៉ាវនេះខុស។ ដូច្នេះយើងខ្ញុំសម្តែងសភាពគ្មានបំណង, លោកអ្នកមិនអាចចង់ធ្វើអីគឺធ្វើនោះ។ មានមនុស្សនិយាយះ ខ្ញុំគឺចង់គ្រប់គ្រងមនុស្សអាក្រក់។ គឺខ្ញុំនិយាយថាលោកអ្នកធ្វើនគរបាលទំនង។ ទោះយ៉ាងណាពួកយើងក៏មិនមែនហៅលោកអ្នកឃើញសម្លាប់មនុស្សដុតបំផ្លាញក៏មិនគ្រប់គ្រង។ ខ្ញុំសម្តែងជាមួយអ្នករាល់គ្នា, រវាងមនុស្សនិងមនុស្សកើតឡើងទំនាស់, គាត់ទាត់គេមួយជើង, គាត់វាយគេមួយដៃ, អាចធ្វើមិនល្អគឺពីមុនម្នាក់នោះជំពាក់គាត់, ពីរនាក់គាត់ទូទាត់បំណុល។ ប្រសិនលោកអ្នកគ្រប់គ្រង, រវាងពួកគាត់គ្មានបញ្ចប់បាន, រង់ចាំដល់លើកក្រោយត្រូវសាឡើងវិញ។ នេះពោលគឺលោកអ្នកមើលមិនឃើញទំនាក់ទំនងកម្មផល, ងាយស្រួលធ្វើរឿងអាក្រក់, ហេតុនេះបាត់គុណធម៌។

មនុស្សសាមញ្ញគ្រប់គ្រងរឿងរ៉ាវរបស់មនុស្សសាមញ្ញគឺគ្មានបញ្ហា, គាត់ប្រើគោលសីលធម៌របស់មនុស្សសាមញ្ញដើម្បីរាស់រវែង។ លោកអ្នកគឺត្រូវតែប្រើគោលសីលធម៌វិសាមញ្ញដើម្បីរាស់រវែង, លោកអ្នកមើលឃើញសម្លាប់មនុស្សដុតបំផ្លាញនោះប្រសិនមិនគ្រប់គ្រងជាក់ស្តែងគឺជាបញ្ហាចិត្តចរិត, បើមិនទេបង្ហាញចេញមនុស្សល្អដូចម្តេច? សម្លាប់មនុស្សដុតបំផ្លាញលោកអ្នកក៏មិនគ្រប់គ្រង, លោកអ្នកគ្រប់គ្រងអ្វីទៅ? តែមានចំណុចមួយ, រឿងទាំងនេះគ្មានទំនាក់ទំនងអ្វីជាមួយមនុស្សបួសហាត់ពួកយើង។ មិនជាក់លាក់រៀបចំឲ្យលោកអ្នក, មិនជាក់លាក់ទុកឲ្យលោកអ្នកជួបប្រទះ។ យើងខ្ញុំសម្តែងរក្សាគុណធម៌ជាក់ស្តែងគឺចៀសវាងលោកអ្នកធ្វើរឿងអាក្រក់, ប្រហែលជាលោកអ្នកទើបធ្វើរឿងរ៉ាវនោះបន្តិច, អាច

ជាក់ស្តែងគឺជាធ្វើរឿងអាក្រក់, ដូច្នោះលោកអ្នកគឺត្រូវបាត់គុណធម៌។ លោកអ្នកបាត់គុណធម៌កាលណា, ជាន់ថ្នាក់របស់លោកអ្នកធ្វើម្តេចលើកកម្ពស់ឡើងលើ? ធ្វើម្តេចសម្រេចបានគោលដៅចុងបញ្ចប់របស់លោកអ្នក? ខាងក្នុងនេះមានបញ្ហាបែបនេះ។ ក្រៅពីនេះ, នៅតែត្រូវភ្ញាក់ដឹងល្អ, និស្ស័យល្អអាចភ្ញាក់ដឹងក៏នឹងល្អ, ឥទ្ធិពលរបស់បរិយាកាសក៏ផ្តើមផលប៉ះពាល់ផងដែរ។

យើងខ្ញុំនៅសម្តែង, ប្រសិនពួកយើងនរណាៗសុទ្ធតែសំដៅចូលក្នុងដើម្បីប្អូស, នរណាៗសុទ្ធតែពីចិត្តចរិតរបស់ខ្លួនឯងដើម្បីរក, កន្លែងណាធ្វើមិនល្អខ្លួនឯងរកមូលហេតុ, លើកក្រោយធ្វើឲ្យល្អ, ធ្វើរឿងពិចារណាដល់អ្នកដទៃមុន។ ដូច្នោះសង្គមមនុស្សជាតិក៏នឹងប្រែជាល្អ, សីលធម៌ក៏នឹងថ្កើងឡើងវិញ, ស្មារតីអរិយធម៌ក៏នឹងប្រែជាល្អ, ស្ថានភាពសន្តិសុខសាធារណៈក៏នឹងប្រែជាល្អ, ប្រហែលជាក៏គ្មាននគរបាលទៀត។ មិនចាំបាច់មនុស្សគ្រប់គ្រង, នរណាៗសុទ្ធតែគ្រប់គ្រងខ្លួនឯង, សំដៅក្នុងចិត្តរបស់ខ្លួនឯងដើម្បីរក, លោកអ្នកនិយាយនេះល្អប៉ុណ្ណា។ អ្នករាល់គ្នាដឹងថាច្បាប់រដ្ឋឥឡូវកំពុងកែលម្អម្តងមួយជំហាន, ប្រសើរឡើងម្តងមួយជំហាន, តែមានមនុស្សហេតុអ្វីនៅតែធ្វើរឿងអាក្រក់? មានច្បាប់មិនធ្វើតាម? ជាក់ស្តែងគឺដោយសារលោកអ្នកគ្រប់គ្រងមិនបានចិត្តរបស់គាត់, ពេលមើលមិនឃើញ, គាត់នៅតែនឹងធ្វើរឿងអាក្រក់។ ប្រសិននរណាៗសុទ្ធតែសំដៅចូលក្នុងដើម្បីប្អូស, នោះគឺខុសស្រឡះហើយ។ ក៏មិនចាំបាច់លោកអ្នកប្រឆាំងនឹងអំពើអយុត្តិធម៌។

ធម៌គ្រាន់តែអាចសម្តែងដល់ជាន់មួយនេះ, ខ្ពស់ជាងទៀតត្រូវពឹងលើលោកអ្នកខ្លួនឯងទៅប្អូសទើបនឹងទទួលបាន។ មនុស្សខ្លះលើកឡើងបញ្ហាកាន់តែលើកឡើងកាន់តែពិស្តារ, បញ្ហាក្នុងជីវភាពប្រសិនសុទ្ធតែ

ទុកឲ្យខ្ញុំមកតបឆ្លើយ, លោកអ្នកខ្លួនឯងនៅបួសហាត់អ្វីទៀត! លោកអ្នកត្រូវការខ្លួនឯងទៅបួស, ខ្លួនឯងទៅភ្ញាក់ដឹង, ប្រសិនខ្ញុំសុទ្ធតែសម្ដែងចេញមក, គឺគ្មានលោកអ្នកបួសទៀត។ ភ័ព្វល្អមហាធម៌បានបង្រៀនចេញរួចហើយ, លោកអ្នកអាចយោងតាមមហាធម៌ដើម្បីធ្វើ។

* * * * * * * * *

ខ្ញុំគិតថាពេលវេលាដែលខ្ញុំបង្រៀនធម៌ជាមូលដ្ឋានជិតបញ្ចប់, ដូច្នេះចង់យកប្រការពិតប្រាកដបន្សល់ទុកឲ្យអ្នករាល់គ្នា, ដើម្បីអ្នករាល់គ្នានៅក្នុងពេលបួសហាត់ពីពេលនេះតទៅ, មានធម៌ដើម្បីដឹកនាំអ្នករាល់គ្នា។ នៅក្នុងដំណើរការបង្រៀនធម៌ទាំងមូល, ខ្ញុំក៏ជាក្នុងស្មារតីទទួលខុសត្រូវចំពោះអ្នករាល់គ្នា, ក្នុងពេលតែមួយក៏ទទួលខុសត្រូវចំពោះសង្គម, តាមពិតយើងខ្ញុំក៏ជាក្នុងស្មារតីគោលការណ៍នេះដើម្បីធ្វើ, សម្រាប់ធ្វើបានល្អអាក្រក់យ៉ាងណាខ្ញុំក៏មិនសម្ដែង, មានមតិសាធារណៈខ្លួនឯង។ បំណងរបស់ខ្ញុំគឺយកមហាធម៌បង្រៀនចេញ, ទុកឲ្យមនុស្សច្រើនជាងទៀតពួកយើងអាចទទួលបានអត្ថប្រយោជន៍, ធ្វើឲ្យមនុស្សពិតប្រាកដចង់បួសហាត់អនុលោមធម៌អាចបួសហាត់ឡើងលើ។ ក្នុងពេលដំណាលគ្នានៅក្នុងដំណើរការបង្រៀនធម៌, យើងខ្ញុំក៏បានសម្ដែងចេញគោលសីលធម៌ធ្វើមនុស្ស, ក៏សង្ឃឹមថាអស់លោកអ្នកក្រោយពីថ្នាក់នេះតទៅ, ប្រសិនមនុស្សមិនអាចយោងតាមមហាធម៌ដើម្បីបួសហាត់, យ៉ាងហោចណាស់ក៏អាចធ្វើមនុស្សល្អម្នាក់, បែបនេះសម្រាប់សង្គមពួកយើងក៏មានអត្ថប្រយោជន៍។ ភាពពិតលោកអ្នកបានចេះធ្វើមនុស្សល្អរួចហើយ, ពីពេលនេះតទៅ, លោកអ្នកក៏អាចធ្វើមនុស្សល្អម្នាក់។

នៅក្នុងដំណើរការបង្រៀនធម៌ក៏មានកន្លែងមិនរលូន, ជ្រៀតជ្រែក

គ្រប់ទិដ្ឋភាពក៏ដ៏ធំ។ ដោយសារអង្គភាពរៀបចំនិងថ្នាក់ដឹកនាំគ្រប់មជ្ឈដ្ឋានផ្តល់ជូនការគ្រាំទ្រយ៉ាងមុតមាំនិងការខិតខំប្រឹងប្រែងរបស់បុគ្គលិកការងារ, ថ្នាក់បង្រៀនរបស់ពួកយើងបានសម្រេចបរិបូរគួរសម។

ពេលនៅក្នុងថ្នាក់, ប្រការទាំងនេះដែលខ្ញុំសម្តែងសុទ្ធតែជាដឹកនាំអ្នករាល់គ្នាបួសហាត់ឆ្ពោះឡើងលើជាន់ថ្នាក់ខ្ពស់, ក្នុងពេលសម្តែងធម៌អតីតកាលគ្មានមនុស្សសម្តែងប្រការទាំងនេះ។ ប្រការដែលយើងខ្ញុំសម្តែងភ្លឺច្បាស់ខ្លាំងណាស់, គឺរួមគ្មានូវវិទ្យាសាស្រ្តទំនើបនិងវិទ្យាសាស្រ្តទំនើបនៃរាងកាយមនុស្សដើម្បីសម្តែង, លើសពីនេះទៀតជាន់ថ្នាក់ដែលសម្តែងដ៏ខ្ពស់។ ចម្បងគឺដើម្បីអ្នករាល់គ្នា, ទុកឲ្យលោកអ្នកអនាគតអាចពិតប្រាកដទទួលបានធម៌, បួសហាត់ទៅលើ, នេះជាចំណុចចាប់ផ្តើមរបស់ខ្ញុំ។ យើងខ្ញុំនៅក្នុងដំណើរការបង្រៀនធម៌បង្រៀនគង់មនុស្សដ៏ច្រើនមានអារម្មណ៍ថាធម៌ក៏យ៉ាងល្អ, ប៉ុន្តែធ្វើទៅដ៏ពិបាក។ ភាពពិតខ្ញុំមានអារម្មណ៍ថាពិបាកនិងមិនពិបាក, មើលសម្រាប់មនុស្សណាដើម្បីសម្តែង, មនុស្សសាមញ្ញយ៉ាងទូទៅម្នាក់, មិនចង់បួសហាត់, គាត់នឹងមានអារម្មណ៍ថាបួសហាត់សុទ្ធសាធសែនពិបាក, មិនអាចយល់បាន, បួសមិនសម្រេច។ គាត់ជាមនុស្សសាមញ្ញ, គាត់មិនចង់បួសហាត់, គាត់នឹងមើលឃើញដ៏ពិបាក។ ឡៅជឺសម្តែង៖ វត្តីលំដាប់លើស្តាប់តាវ, ឧស្សាហ៍បដិបត្តិដល់ចប់; វត្តីលំដាប់កណ្តាលស្តាប់តាវ, ភ្លេតនៅភ្លេតបាត់; វត្តីលំដាប់ក្រោមស្តាប់តាវ, មហាសំណើច; មិនសើចមិនគ្រប់ហៅថាតាវ]។ មនុស្សបួសហាត់ពិតប្រាកដ, ខ្ញុំនិយាយថាគឺដ៏ងាយស្រួល, មិនមែនរបស់អ្វីខ្ពស់មិនអាចឈោងដល់។ ភាពពិតកំពុងអង្គុយមានសិក្ខាកាមយូរឆ្នាំជាច្រើននិងសិក្ខាកាមយូរឆ្នាំដែលគ្មានមកបានបួសហាត់ឡើងទៅដល់ជាន់ថ្នាក់យ៉ាងខ្ពស់រួចហើយ។ ខ្ញុំមិនទាន់សម្តែង

ប្រការទាំងនេះឲ្យលោកអ្នកគឺខ្លាចថាលោកអ្នកសាងបង្កើតចិត្តប្រកាន់, កត្តាដែលពេញចិត្តខ្លួនឯងអប្បមាណ។ល។ មានឥទ្ធិពលលើការបង្កើនអំណាចគង់របស់លោកអ្នក។ ធ្វើជាមនុស្សបួសហាត់ម្នាក់ពិតប្រាកដមានចិត្តប្ដេជ្ញា, គាត់អាចខន្តីជាប់, នៅពីមុខផលប្រយោជន៍គ្រប់ប្រភេទអាចដាក់ចុះចិត្តប្រកាន់នេះបាន, អាចមើលវាដ៏ស្រាល, ដរាបណាអាចធ្វើបានគឺមិនពិបាក។ មនុស្សដែលនិយាយពិបាក, ជាក់ស្ដែងគឺគាត់ដាក់ចុះមិនបានរបស់ទាំងនេះ។ គង់ហ្វាបួសហាត់ខ្លួនវាគឺមិនពិបាក, លើកកម្ពស់ជាន់ថ្នាក់ខ្លួនវាគឺគ្មានអ្វីពិបាក, ជាក់ស្ដែងគឺចិត្តរបស់មនុស្សដាក់ចុះមិនបាន, ដូច្នេះគាត់ទើបនិយាយពិបាក។ ដោយសារកំពុងក្នុងផលប្រយោជន៍តថភាពដ៏ពិបាកដាក់វាចុះ, ផលប្រយោជន៍នេះគឺនៅទីនេះ, លោកអ្នកនិយាយចិត្តនេះធ្វើម្ដេចដាក់ចុះបាន? គាត់សន្មតថាពិបាក, តាមពិតក៏ជាពិបាកនៅកន្លែងនេះ។ ពួកយើងនៅពេលកើតឡើងទំនាស់រវាងមនុស្សនិងមនុស្ស, ខន្តីមិនបានការរក្សាទុកមុខនេះ, សូម្បីតែមិនអាចចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់ម្នាក់ដើម្បីប្រព្រឹត្ត, ខ្ញុំនិយាយនេះគឺមិនបាន។ ពេលដែលខ្ញុំបួសហាត់អតីតកាល, មានអធិជនជាច្រើនធ្លាប់បានសម្ដែងឲ្យខ្ញុំពាក្យបែបនេះ, គាត់និយាយ៖ [ពិបាកខន្តីអាចខន្តី, ពិបាកបដិបត្តិអាចបដិបត្តិ]។ ភាពពិតជាក់ស្ដែងគឺជាបែបនេះ, អាចផងដែរអ្នករាល់គ្នាត្រឡប់ទៅផ្ទះសាកមើល។ នៅក្នុងពេលគ្រោះកប្បពិតប្រាកដឬក៏ក្នុងពេលឆ្លងទ្វារ, លោកអ្នកសាកមើល, ពិបាកខន្តី, លោកអ្នកខន្តីសាកមើល; ឃើញថាពិបាកធ្វើ, និយាយថាពិបាកធ្វើ, ដូច្នោះលោកអ្នកគឺសាកបន្តិចមើលនៅទីបញ្ចប់បានឬមិនបាន។ ប្រសិនលោកអ្នកពិតជាអាចធ្វើបាន, លោកអ្នកនឹងរកឃើញថាពិតជាសូលងងឹតផ្កាភ្លឺភូមិមួយទៀត!

ដោយសារខ្ញុំសម្តែងច្រើនពេកហើយ, សម្តែងច្រើនពេកលោកអ្នកដឹ៏ពិបាកចាំបាន។ ចំណុចតម្រូវចម្បងដែលខ្ញុំស្នើឡើង៖ សង្ឃឹមថាអ្នករាល់គ្នានៅក្នុងពេលបួសហាត់ពីពេលនេះតទៅ, ចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់ម្នាក់, ពិតប្រាកដបន្តបួសហាត់។ ខ្ញុំសង្ឃឹមថាសិក្ខាកាមថ្មីនិងយូរឆ្នាំ, សុទ្ធតែអាចបួសហាត់នៅក្នុងមហាធម៌, សុទ្ធតែអាចជោគជ័យសម្រេចបរិបូរ! សង្ឃឹមថាអ្នករាល់គ្នាត្រឡប់ទៅឆ្លៀតឱកាសដើម្បីបួសជាក់ស្តែង។

* * * * * * * * *

........

[ជួនហ្វាលូន] មិនស្រស់ស្អាតនៅលើផ្ទៃនៃអក្សរសាស្ត្រ, សូម្បីតែមិនសមស្របទៅនឹងវេយ្យាករណ៍ទំនើប។ ទោះយ៉ាងណា, ប្រសិនខ្ញុំប្រើវេយ្យាករណ៍ទំនើបមកកែសម្រួលមហាធម៌នេះ, គឺនឹងលេចឡើងបញ្ហាមួយធ្ងន់ធ្ងរះ បទដ្ឋានរចនាសម្ព័នភាសាអក្សរសាស្ត្រទោះបីមានភាពល្អិតល្អន់ក៏ដោយ, ផ្ទុយមកវិញនឹងគ្មានអត្ថន័យស៊ីជម្រៅនិងខ្ពស់ជាង។ ដោយសារប្រើបទដ្ឋានវាក្យសព្ទទំនើបជាមូលដ្ឋានគឺគ្មានវិធីបង្ហាញចេញការដឹកនាំរបស់មហាធម៌នៃជាន់ថ្នាក់ខុសគ្នានៅខ្ពស់ជាងនិងការបង្ហាញរបស់ធម៌នៅជាន់នីមួយៗ, ក៏ដូចជាមិនអាចនាំមកការវិវត្តន៍អំពីរាងកាយដើមនិងគង់របស់សិក្ខាកាមជាមួយនឹងការផ្លាស់ប្រែមែនទែនក្នុងការលើកកម្ពស់។

........

*—លីហុងជឺ*

*ថ្ងៃទី០៥ខែមករាឆ្នាំ១៩៩៦*

# អក្ខរានុក្រម

ចំណាំទាំងអស់នៅក្នុងសៀវភៅសុទ្ធតែសរសេរតាមការយល់ដឹងនិងស្វែងយល់របស់អ្នកបកប្រែ, មិនមែនអត្ថបទដើម, ប្រាកដណាស់មិនមែនជាធម៌, គ្រាន់តែមានតួនាទីជាឯកសារយោង។ អ្នកបកប្រែធ្វើការបកប្រែនេះតាមស្តង់ដាបម្រុងទុកអត្ថបទដើមរបស់លោកគ្រូច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ ស្តង់ដាបកប្រែរលូនស្ទាត់ជំនាញបានចាត់ទុកជាបន្ទាប់បន្សំ។ ដូច្នេះបកប្រែអានឡើងសំឡេងដូចចិនច្រើនជាងដូចខ្មែរ។

វាយក្នុងបរិសិដ្ឋនេះចម្បងជាពាក្យដែលអ្នកបកប្រែបម្រុងទុកភាសាចិន, ពោលគឺមិនបកប្រែមកភាសាខ្មែរសុទ្ធសាធទាំងអស់, ហើយពាក្យមួយចំនួនគឺបានប្រើសូរសំឡេងចិនដោយផ្ទាល់។ ព្រមទាំងមានពាក្យឬឃ្លានិងសុភាសិតដែលពិបាកបកប្រែឲ្យអស់ពីន័យ, អ្នកបកប្រែគ្រាន់តែខិតខំពន្យល់ន័យខាងលើផ្ទៃអក្សរតែមិនប៉ះដល់អត្ថន័យបង្កប់ខាងក្នុង។

ចំពោះឈ្មោះអសាធារណៈ, ប្រភពគឺពាក្យបរទេសមិនមែនជាពាក្យចិន, មានកន្លែងខ្លះប្រើពាក្យចិន, មានកន្លែងខ្លះប្រើពាក្យអង់គ្លេសនិងពាក្យដើម, ទោះយ៉ាងណាក៏ដោយ, ចំពោះពាក្យបាលែឬសំស្រ្កឹតដែលជនជាតិខ្មែរយើងធ្លាប់បានប្រើតែមានចំណុចខុស, អ្នកបកប្រែសរសេរឡើងវិញតាមពាក្យត្រូវរបស់បាលែបុរាណខ្មែរ។ ដូចជា៖ បារមី=>បរមី; អាចារ្យ=>អចារ្យ។ល។

ក្នុងពេលបកប្រែក៏ដ៏ពិបាកចៀសវាងការត្រូវដាក់ពាក្យខ្មែរខ្លះចូលឲ្យមានន័យគ្រប់គ្រាន់។ មិនជាក់លាក់ជាគំនិតរបស់លោកគ្រូ។ ពាក្យបានដាក់ចូលគឺនៅក្នុងវង់ក្រចកស្រួច{}។

នេះគឺគម្ពីរពុទ្ធវង្ស, ពិតណាស់អត្ថន័យស៊ីជម្រៅអាថ៌កំបាំង, អ្នកបកប្រែប្រមាណកម្លាំងមានកំណត់, ប្រាកដនឹងនៅមានខុសឆ្គង, សូមគោរព

សង្ឃឹមមិត្តភក្តិ, មិត្តអ្នកបួសចូលរួមចំណែកកែតម្រូវ។
**កាយចម្លង** (載體)៖ [សីលគង់ឬអ្វីមួយធ្វើ] កាយបញ្ជូនចម្លង។
**ការបង្វិលហឿឆឿ** (河車運轉)៖ ហឿ (河)=> ទន្លេ;
ឆឿ (車)=> ឡាន។
**ការបង្វិលឈានឃុន** (乾坤運轉)៖ ឈាន (乾)=> មេឃ;
ឃុន (坤)=> ដី។
**ក្វយចូវ**(貴州)៖ ជាខេត្តមួយនៅភាគនិរតីនៃប្រទេសចិន។
**ក្វានយិន** (觀音)៖ ឈ្មោះរបស់ពោធិសត្វ។
**កញ្ជ្រោងសំពោចព្រាយពស់** (胡黃百僚)៖ បណ្តោះអាសន្នបកប្រែខាងលើផ្ទៃគឺជាដូច្នេះ, ខ្លួនវាពាក្យកញ្ជ្រោងសំពោចព្រាយពស់មានអត្ថន័យទូទៅបន្ថែមទៀត។
**ខាបព្រលឹង** (捏魂)៖ [សីលគង់] ចាប់ព្រលឹង។
**ខួងចុងស្នែងគោ** (鑽牛角尖)៖ របៀបនិយាយរបស់ជនជាតិចិន, បង្កប់ន័យថាលូនចូលផ្លូវទាល់។
**ឆ្ចិនឈី** (真氣)៖ យោងតាមទ្រឹស្តីនៃឱសថបុរាណចិន, ឆ្ចិនឈីគឺជាសារធាតុមូលដ្ឋានបំផុតដែលរក្សានូវសកម្មភាពជីវិតរបស់មនុស្ស, ការរស់រានមានជីវិតរបស់មនុស្ស, អាស្រ័យទាំងស្រុងលើឈីនេះ។
**គង់** (功)៖ ថាមពលហាត់បាន, វិធីសាស្ត្រដែលហាត់ថាមពលនោះ។
**គង់គោលសីលធម៌, គង់ហ្វា** (功法)៖ តាមទម្លាប់បង្រៀនរបស់ឈីគង់, មានផ្នែកទ្រឹស្តី, ហៅថាគង់គោលសីលធម៌, និងផ្នែកអនុវត្តចលនា, ហៅថាគង់ហ្វា។
**គ្រូនាំចូលខ្លោងទ្វារ, បួសហាត់នៅឯកជន** (師父領進門，修行在個人)៖ គ្រូនាំចូលខ្លោងទ្វារ, ហើយបួសបដិបត្តិគឺជារឿងឯកជនរបស់មនុស្សប្បួសហាត់។

**ច្ចាង** (丈)៖ ឯកតារង្វាស់សម័យដើមស្មើ**២**ពូគឺ**៣,៣៣**ម៉ែត្រ។
**ឆុន** (寸)៖ ឯកតារង្វាស់ក្នុងឱសថបុរាណចិន, ជាធម្មតាពិពណ៌នាទីតាំងរបស់ចំណុចចាក់ម្ជុលវិទ្យាសាស្ត្រ, ធម្មតាយកកន្លែងទូលាយបំផុតរបស់ម្រាមដៃមេ។ ឆុនគ្មានតម្លៃជាក់លាក់មធ្យមគឺ**២**ដល់**២,២**សង់ទីម៉ែត្រ។
**ឆឺ** (尺)៖ ឯកតារង្វាស់សម័យដើមស្មើ**៣៣**សង់ទីម៉ែត្រ។
**ជីនជុងច្ចាវ** (金鐘罩)៖ គម្របជួងមាស។
**ជើងអរហន្ត** (羅漢腳)៖ បាតជើងអរហន្ត។
**ឈីញគង់** (輕功)៖ ជំនាញការធ្វើឲ្យមនុស្សស្រាល។
**ដាស់បំភ្លឺ**(點化)៖ ផ្តល់យោបល់ដល់មនុស្សតាមរបៀបផ្សេងៗ ដូចជាយល់សប្តិ និយាយតាមរយៈអ្នកដ៏ទៃ បង្កឲ្យមានឧប្បត្តិហេតុកើតឡើងដូចជារអិលជើងជាដើម។
**ដើរតានតាវ** (走丹道)៖ ទៅតាមផ្លូវហាត់តាន។
**ដើមមក** (本來)៖ ជាមូដ្ឋានដំបូងមកគឺជាដូច្នោះ។
**ណានជិញ**(南京)៖ ជាទីក្រុងមួយក្នុងខេត្តជាំងស៊ូ, ទីក្រុងនេះនៅខាងក្រោមទន្លេឆាងជាំង(ឬហៅថាទន្លេយ៉ាងចឺ)។
**តាហ៍ជី** (妲己)៖ (១០៧៦-១០៤៦) មុន.គ.សមានឈ្មោះពេញថាៈស៊ូតាហ៍ជីជាកូនស្រីរបស់ស៊ូហ៊ូនៃរាជវង្សស្ហាង (商朝) ក្នុងប្រទេសចិន, ដោយបានសត្វកញ្ជ្រោងកន្ទុយ៩បញ្ជោ, នាងជាស្រីស្នំរបស់ស្តេចស្ហាងៈជូវ៉ាង, ត្រូវពង្វក់, លង់លក់ក្នុងសម្រស់របស់តាហ៍ជីរាជវង្សស្ហាងក៏ដួលរលំបាត់បង់។
**តារី** (大日)៖ ព្រះអាទិត្យធំឬក៏មហាសុរិយា។
**តានធាន** (丹田)៖ ស្រែតាននៅទីតាំងពោះក្រោម; ធាន (田)=> ស្រែ។
**តានជិញ**(丹經), **តាវចាង**(道藏), **ស៊ីញមិញហួយជឺ**(性命圭旨)៖ គឺជា

សៀវភៅគម្ពីរក្នុងតាវសាសនា។
**តាវវង្ស** (道家)៖ ខាងតាវ, ពិពណ៌នាទូទៅគង់ហ្វាបួសតាវ។
**តាវសាសនា** (道教)៖ ជាធម្មតាយល់តាមន័យថាសាសនាមានប្រភពអំពីឡៅជឺ។
**តាវ, ខឿតាវ, ហ្វីឆាងតាវ** (道，可道，非常道)៖ ហៅថាតាវក៏បាន, តែជាតាវសែនអស្ចារ្យ, ផ្លូវនោះអាចទៅប៉ុន្តែជាផ្លូវសែនអស្ចារ្យ។
**តានជុង** (膻中)៖ ស្នៀវ៉ីនៅកណ្ដាលទ្រូង, យកចំណុចកណ្ដាលរវាងក្បាលសុដន់ទាំងពីរ។
**ថៃយ៉ាង** (太陽)៖ ស្នៀវ៉ីនៅសងខាង, ពីកន្ទុយភ្នែកខិតទៅក្រោមមួយធុន។ ព្រះអាទិត្យឬក៏សុរិយា។
**ទារកអមតៈ** (元嬰)៖ យៀន (元)=> របស់មុនដំបូង; អិញ (嬰)=> ទារក។ ទារអមតៈបកតាមន័យអក្សរក្នុងសៀវភៅជូនហ្វាលូនភាសាអង់គ្លេស។
**ទេពអំណាចមហាបង្ហាញ** (神通大顯)៖ ទេពអំណាចបង្ហាញដ៏ធំ។
**ធាពូសាន** (鐵布衫)៖ អាវក្រោះដែក។
**ប្រភពដើម** (本源)៖ មូលដ្ឋានប្រភពដើមដំបូងមក។
**និស្ស័យ** (根基)៖ ឫសគល់មូលដ្ឋាន, មូលដ្ឋានលក្ខខណ្ឌមុនដំបូងរបស់មនុស្សបួសហាត់។
**នីវ៉ាន, វិមាននីវ៉ាន** (泥丸宫)៖ ពាក្យខាងតាវវង្សចង្អុលកន្លែងមួយនៅក្នុងរាងកាយ, ស្របនឹងទីតាំងរបស់ក្រពេញស្រល់។
**៨ទេព** (八仙)៖ ៨អង្គតាវក្នុងរឿងព្រេងបុរាណចិន, រួមមាន៖ លីធៀក្វៃ, ហានជុងលី, ឆាវគ័រចៀវ, ល្ហួរទង់ពីន, ហឿសៀនគូ, ឡានឆាយហឿ, ហានសៀងចឺ, ច្វាងគួរឡៅ។
**បីពាន់មហាពិភព** (大千世界)៖ បីពាន់ពិភពធំ។

**បួសនៅខ្លួនឯង, គង់នៅលោកគ្រូ** (修在自己，功在師父)៖ បួសនៅខ្លួនឯង, គង់នៅលោកគ្រូ, បួសគឺជាការខិតខំខ្លួនឯងរបស់មនុស្សបួសហាត់, តែវិវត្តគង់បានធ្វើពឹងលើលោកគ្រូ។
**បួសជំនាញ** (專修)៖ មនុស្សបួសហាត់ឯកទេស, ពោលគឺមនុស្សដែលតាមទម្រង់បួសហាត់ឯកទេស, ពួកគាត់ភ្លាមៗកាត់ផ្តាច់ទំនាក់ទំនងជាមួយសង្គម។
**បួសពិត** (真修)៖ គឺជាអ្នកបួសពិតប្រាកដក្នុងធម្មក្ខន្ធណាមួយ, មិនមែនបួសក្លែងក្លាយ។
**បួសជាក់ស្តែង** (實修)៖ ស្ថានភាពជាក់ស្តែងដែលជួបប្រទះ, ឆ្លងកាត់ក្នុងដំណើរការបួស។
**ប៉ាង់ហឿ** (棒喝)៖ ដំបងព្រមាន។
**បាំងជញ្ជាំងមើលវត្ថុ** (隔牆看物)៖ (សីលគង់) មើលបានវត្ថុឆ្លងកាត់ជញ្ជាំង។
**ប៉ាយពូឆនយ៉ាង** (百步穿杨)៖ ឃ្លាតរាប់រយពូឆ្លងស្លឹកសូល, មួយពូស្មើ៥ឆឺគឺ១,៦៦ម៉ែត្រ។
**ប៉ាយហួយ** (百會)៖ ស្សៀវមួយលើកំពូលក្បាលទាញពីត្រចៀកទាំងពីរសងខាងឡើង, ពេលអង្គុយសមាធិវាគឺជាកន្លែងខ្ពស់បំផុត។ ន័យលើផ្ទៃគឺរាប់រយប្រមូលផ្តុំមក។
**ផ្កាបីផ្តុំកំពូល** (三花聚頂)៖ ផ្កាបីទងប្រមូលផ្តុំនៅកំពូលក្បាល។
**ផុតកប្ប** (末劫)៖ ពិភពបួសហាត់ជឿថាចក្រវាលវិវត្តទៅតាមបណ្តារយៈពេល, បណ្តាដំណាក់កាល។ ផុតកប្បគឺជាដំណាក់កាលចុងក្រោយ។
**ពិបាកខន្តីអាចខន្តី, ពិបាកបដិបត្តិអាចបដិបត្តិ** (难忍能忍，难行能行)៖ ខន្តីទាំងរឿងដែលពិបាកខន្តីបាន, ធ្វើរឿងដែលពិបាកធ្វើបាន។
**ពុទ្ធវង្ស** (佛家)៖ ខាងពុទ្ធ, ពិពណ៌នាទូទៅគង់ហ្វាបួសពុទ្ធ។

**ពុទ្ធសាសនា** (佛教)៖ និយាយរួមមុខវិជ្ជាខាងពុទ្ធដែលបង្រៀនតាមទម្រង់សាសនា, ច្រើនតែយល់ថាមានន័យដូចជាសាសនារបស់សក្យមុនី, សាសនាដែលចាប់ផ្ដើមពីសក្យមុនី។

**ពលកម្មនៃសរសៃពួរឆ្អឹង** (勞其筋骨)៖ ហាត់នឿយសរសៃពួរឆ្អឹង, ការរងទុក្ខខាងរាងកាយ។

**មិញម៉ឺន** (命門)៖ ស្នៀវ៉ីនៅចន្លោះរវាងសន្លាក់ឆ្អឹងខ្នង, ចន្លោះឆ្អឹងខ្នងកងទី២និងទី៣។

**យ្វានឈី** (元氣)៖ យ្វានឈីគឺជាឈីមូលដ្ឋាននិងសំខាន់បំផុតក្នុងរាងកាយមនុស្សនិងជាកម្លាំងជំរុញសកម្មភាពជីវិតរបស់មនុស្ស។

**យ៉ាវស្ទឺ** (藥師)៖ គ្រូឱសថ។

**យិញឈីគង់** (硬氣功)៖ មុខវិជ្ជាឈីគង់ក្បាច់គុនហាត់អំពីជំនាញការរឹងទល់, វាយប្រហារ។

**យ៉ីចិ្ហន** (玉枕)៖ ស្នៀវ៉ីមួយនៅផ្នែកខាងក្រោយខួរក្បាល។

**យ្វីនយូវ** (雲游)៖ យ្វីន (雲)=> ពពក, យូវ (游)=> ការធ្វើដំណើរ, ត្រាច់ចរ។

**រាងកាយគង់** (功身)៖ រូបកាយត្រូវបានធ្វើពីគង់។

**រំលាយផ្សំ** (熔合)៖ 熔 គឺក្ដៅរលាយ, 合 គឺប្រមូលផ្ដុំ, សរុប, ភ្ជាប់មក, 熔合 បង្កប់ន័យថាក្ដៅរលាយក្លាយជាតែមួយ, បញ្ចូលគ្នា។

**រលាយសម្រប** (溶洽)៖ 溶 គឺរំលាយ, 洽 គឺចុះសម្រុងគ្នា, ត្រូវគ្នា, 溶洽 បង្កប់ន័យថាបានរំលាយចុះសម្រុងគ្នាទាំងស្រុងដូចរំលាយនៅក្នុងទឹក។

**រ៉ិន-ទូ** (任督)៖ ឈ្មោះខ្សែវណ្ណពីររត់ក្រោមស្បែក, ខ្សែវណ្ណមួយផ្នែកខាងមុខកណ្ដាលខ្លួន, ខ្សែវណ្ណមួយផ្នែកខាងក្រោយកណ្ដាលខ្លួន។

**រួមសម្រប** (園容)៖ ផ្ទុក, ចំណុះ, ខ្លឹមសាររួមបញ្ចូល។

**រាងកាយដើម** (本題)៖ រាងកាយធម្មជាតិដើមដំបូង។

**រៀបទីញបង្កើតឡ, ជ្រើសឱសថស្លតាន (安鼎設爐，採藥煉丹)៖** ដាក់ទីញ (鼎) (ថ្លាងដែកជើងបី) បង្កើតឡ, ប្រមូលថ្នាំស្លតាន។ នៅក្នុងគង់ហ្វានៃតាវវង្ស។

**លី (里，裡，裏)៖** ឯកតាមួយសម្រាប់វាស់ចម្ងាយនាសម័យដើមប្រហែល៥០០ម៉ែត្រ។ និយាយ១០ម៉ឺន៨ពាន់លីគឺសំដៅលើចម្ងាយផ្លូវដ៏ឆ្ងាយ។

**លិញឈី (灵氣)៖** ថាមពលរស់របស់ចក្រវាល។

**វាយមិនសងដៃ, ជេរមិនតមាត់ (打不還手, 罵不還口)៖** ត្រូវវាយមិនវាយសង, ត្រូវជេរមិននិយាយសង។

**វូសាសនា (巫教)៖** ចូលអារក្ស, គ្រូធ្មប់។

**វង់សកលម៉ាវយ៉ូវ (卯酉周天)៖** ម៉ាវ (卯)=> ថោះ, យ៉ូវ (酉)=> រកា។

**វត្តលិញយីន (靈隱寺)៖** ត្រូវបានបង្កើតឡើងក្នុងឆ្នាំដំបូងនៃសៀនហៀរាជវង្សជីនភាគខាងកើត (៣២៦ឆ្នាំ), និងមានប្រវត្តិជាង១៦៩០ឆ្នាំ។

**វត្តីលំដាប់លើស្តាប់តាវ, ឧស្សាហ៍បដិបត្តិដល់ចប់; វត្តីលំដាប់កណ្តាលស្តាប់តាវ, ភ្លេតនៅភ្លេតបាត់; វត្តីលំដាប់ក្រោមស្តាប់តាវ, មហាសំណើច; មិនសើចមិនគ្រប់ហៅថាតាវ (上士聞道勤而行之；中士聞道若存若亡；下士聞道大笑之; 不笑不足以為道)៖** វត្តីកម្រិតលើដែលស្តាប់បានតាវនឹងឧស្សាហ៍បដិបត្តិ, វត្តីកម្រិតកណ្តាលស្តាប់បានតាវគឺមួយភ្លេតនៅមួយភ្លេតបាត់, ប្រភេទមនុស្សកម្រិតក្រោមដែលស្តាប់បានតាវនឹងសើចធំឡើង, មិនសើចគឺមិនគ្រប់ហៅថាតាវ; នេះជាប្រយោគរបស់ឡៅជឺ។

**សានកិន (山根)៖** ស្ពៀរ៉ុនៅចន្លោះកណ្តាលចិញ្ចើម។

**មេតាបូលីស (新陈代谢)៖** យកថ្មីជំនួសចាស់, បាតុភូតដែលកោសិកាចាស់ត្រូវបំផ្លាញនិងជំនួសដោយកោសិកាថ្មី។

**ហិង្គុល** (硃砂)៖ ពណ៌ក្រហមភ្លឺដែលទទួលបានមកពីបារ៉ត។
**ហ្វាំងទីណីជិញ**(黃帝內經)៖ គឺជាអត្ថបទវេជ្ជសាស្ត្របុរាណរបស់ចិន ដែលត្រូវបានគេចាត់ទុកថាជាប្រភពគោលលទ្ធិជាមូលដ្ឋាននៃឱសថចិនបុរាណអស់រយៈពេលជាងពីរសហស្សវត្សរ៍, ហើយក៏ជាសៀវភៅដ៏សំខាន់មួយស្ដីពីទស្សនវិជ្ជានិងរបៀបរស់នៅរបស់តាវនិយមផងដែរ។
**សរសៃបែតងលោតខ្លាំង** (青筋暴跳)៖ នេះបង្ហាញថាការត្រឡប់មកវិញនៃឈាមត្រូវបានរារាំង, សម្ពាធកើនឡើង, ហើយបរិមាណឈាមច្រើនកកកុញនៅក្នុងសរសៃឈាមខ្មៅ (ពាក្យនិយមប្រើក្នុងពេទ្យបានហៅថា 靜脈-Vein)។ អាចមើលឃើញជាចម្បងនៅលើដៃ, ក្បាល, ទ្រូង, ពោះ និងអវយវៈក្រោម។ (青筋) គឺជាសរសៃឈាមខ្មៅ, បកថាសរសៃបែតង គឺតាមន័យលើផ្ទៃអក្សរ។
**ស៊ឺឆឺន** (時辰)៖ **១**ម៉ោងគិតតាមវិធីបែងចែកពេលវេលាប្រពៃណីមួយថ្ងៃមាន**១២**ម៉ោង៖ ជូត, ឆ្លូវ...កុរ។ ចាប់ផ្ដើមពីម៉ោងជូតគឺពីម៉ោង**២៣**ដល់**១**ទាបភ្លឺ។ មួយស៊ឺឆឺនស្មើ**២**ម៉ោងនាឡិកាបច្ចុប្បន្ន។
**ស្លូលងងឹតផ្កាភ្លឺភូមិមួយទៀត** (柳暗花明又一村)៖ ឆ្លងកាត់ដើមស្លូលងងឹតមួយតំបន់, ស្ងួនផ្កាភ្លឺ, គឺដល់ភូមិមួយទៀត។ ន័យលើផ្ទៃអក្សរ៖ ជួបទីបញ្ចប់ (ផ្លូវទាល់) កុំទុទ្ទិដ្ឋិនិយមបោះជំហានថយក្រោយ។
**ស្លូល** (柳)៖ ដើមស្លូល (weeping willow)។
**សង្ឃឆ្កួតបោសឈីន** (瘋僧掃秦)៖ សម្រង់បុរាណរបស់ព្រះសង្ឃនៅវត្តលិញយីញប្រើអំបោសដែលលោកកំពុងបោសទីលានដើម្បីបោស**ឈីនក្វយ**ចេញពីវត្ត, **ឈីនក្វយ**ជាព្រះមហាឧបរាជ, ជាមហាមន្ត្រីទុច្ចរិតសម័យរាជវង្សសុងខាងត្បូង។
**ស្នេហា៧តណ្ហា៦** (七情六欲)៖ ស្នេហា៧និយាយរួមអំពីស្ថានភាព**មនោសញ្ចេតនាគឺ**៖ *សប្បាយ, ខឹង, ព្រួយ, ខ្លាច, ស្រឡាញ់, ស្អប់,*

*ចង់។* **តណ្ហា៦គឺ៖** *ភ្នែកមើលសប្បាយ (眼看喜), ត្រចៀកស្តាប់ខឹង (耳聽怒), ច្រមុះហិតចូលចិត្ត (鼻嗅愛), អណ្តាតភ្លក្សគិត (舌嘗思), កាយតែងបារម្ភណ៍ (身本憂), គំនិតឃើញចង់ (意見欲)។*

**ស្នៀវីុឬក៏ស្នៀ** (穴位)៖ ចំណុចចាក់ម្ជុលវិទ្យាសាស្ត្រ។

**សភាពគ្មានបំណង** (無為)៖ ដោយអចេតនា, ដោយមិនគិត, អសកម្ម, មិនចំណង់។ (ពាក្យនេះពិបាកសម្រាយអស់ពីន័យ), ផ្ទុយជាមួយវាគឺសភាពមានបំណង។

**ហួយឆាង** (會昌)៖ (ចាប់ពីខែទី១ឆ្នាំ៨៤១ដល់ខែទី១ឆ្នាំ៨៤៧) គឺជារជ្ជកាលរបស់លីយានដែលជាអធិរាជរូចុងនៃរាជវង្សថាងដែលមានរយៈពេល៧ឆ្នាំ។

**ហួយយីន** (會陰)៖ ស្ថិតនៅចំកណ្តាលប្រសព្វពីគល់ប្រដាប់ភេទទៅរន្ធគូថ, ពោលគឺត្រូវគ្នានឹងបាតឆ្អឹងអាងត្រគាក។ ពេលអង្គុយសមាធិនេះជាចំណុចទាបបំផុតរបស់រង្វង់វ៉ុន-ទូ។

**ហាត់៖** ពេលសំដៅលើការហាត់គង់របស់ហ្វាលូនតាហ្វារបស់ពុទ្ធវង្ស, តាវវង្ស, ធម្មក្ខន្ធទ្វារវិសេសគឺជាប្រើអក្សរហាត់មានមូលស័ព្ទ (ភ្លើង 火)-(煉), ហើយពេលដែលសំដៅលើហាត់ឈីផ្សេង, ឈីគង់រញ៉េរញ៉ៃគឺជាប្រើអក្សរហាត់មានមូលស័ព្ទ (សរសៃសូត្រតូច-糸)-(練)។ បកប្រែមកភាសាខ្មែរគឺសុទ្ធតែបកថាហាត់។

**ហាមហ៊ុន** (戒葷)៖ ហាមឃាត់ម្ហូបមានជាតិប្រៃ។

**ហ៊ុន** (葷)៖ ម្ហូបប្រៃ។

**ហ៊ុនយ្វានឈី** (混元氣)៖ ជាពាក្យរូបវិទ្យា, គឺជាទម្រង់នៃអត្ថិភាពដែលតំណាងឲ្យខ្លឹមសារនៃវត្ថុនៅក្នុងស្ថានភាពនៃភាពវៃឆ្លាតវិសាមញ្ញ។

**ហៀគូ** (合谷)៖ ស្នៀវីុនៅលើខ្នងបាតដៃ, ជិតកន្លែងគល់ម្រាមដៃមេនិងម្រាមចង្អុល។

**ឡាវគុង (**劳宫**)៖** ស្មៀរ៉ាមួយនៅកណ្តាលប្រអប់បាតដៃ។
**ឡីហ្វឹង** (雷锋)**៖** ឈ្មោះឯកជនគំរូម្នាក់នៅប្រទេសចិនទសវត្សរ៍ ១៩៦០។
**អភិសេក (**開光**)៖** គោរពអញ្ជើញបរមី។
**អតិសុខុម (**微觀**)៖** សង្កេត/ទស្សនីយភាពនៅថ្នាក់/កម្រិតមីក្រូ។
**អទ្វេធម្មក្ខន្ធ (**不二法門**)៖** មិនបួសពីរធម្មក្ខន្ធ, គ្រាន់តែឯកទេសចូលធម្មក្ខន្ធមួយ។
**អា-Q (**阿 Q**)៖** ឈ្មោះតួអង្គល្បីល្បើក្នុងប្រលោមលោក《អា-Qរឿងចម្បង》របស់ប្រទេសចិន។
**អ៊ីកប្ប (**億劫**)៖** អក្សរអ៊ី (億) ស្មើ១00លាន, ១0កោដិ, ប៉ុន្តែក្នុងអក្សរចិនបុរាណមួយអ៊ី (億) គឺស្មើ១0ម៉ឺន។

**Copyright © 2024 by Li Hongzhi**

All Rights Reserved

Translated in khmer,

កំណែភាសាខ្មែរ, បកប្រែនៅកម្ពុជា

http://kh.falundafa.org